RÉGIE DU TIMBRE FRANÇAIS
ET LÉGAL
INDOCHINE

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងទាងសាសនា ទំនៀមប្បវេណី ប្រពៃណីជាតិ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា៖ ព្រះទេវសង្ឃ ស្រ៊ុ - ហាយ
ព្រមទាំងគណៈព្រះធម្មចិត្ត ទាងពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកាសៀវភៅ	ទំព័រ
មហាឧទម - ណាត្រឹ	ទំនាទសុភាសិត	៤៨១
លោកយោគ្យាវិទូ មៅ - ម៉ុំ	ល្បែងផ្សេងៗ	៤៨៥
លោក កាំយ - ប៊ុក ក្រមការ	សុភាសិតភាគទី ២	៤៩៣
ហ្សង់ឌីពទូមត្រឹ ញ៉ាក - ថែម	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសនិយ្យៀ (តទៅ)	៥០០
	សំពួតកាំងប្រៃដាខ្មែរ (តទៅ)	៥០៧
អ្នកឧកញ៉ា ឌួរ - កន	ប្រឹងសាមកុក (តទៅ)	៥១៥
អ្នកឧកញ៉ា ព្រះឃ្លាំងនគរ	ប្រឹង ឧកញ៉ាកុសកុមារ (តទៅ)	៥២៥
ផ្នែកសាសនា		
ហ្សង់ឌីពទូមត្រឹ ញ៉ាក - ថែម	ពន្ធីអាស៊ីទូប (តទៅ)	៥៣១
មហាឧទម - ណាត្រឹ	មុនីសុភាសិត (តទៅ)	៥៤១
កំណត់មតិព្រមវត្តិការណ៍		
ព្រះទេវសង្ឃ ស្រ៊ុ - ហាយ	ពីធ្លីស្រែចម្ការ លោកគ្រូអាចារ្យ ហង្ស - ប៊ែង	៥៤៨
ក្រសួងឧត្តមការ	អំពីការតាំងលើកដំបូងថ្មី (តទៅ)	៥៥៤

ភ្នំពេញ ៦១ — លេខ ៧ ខែកក្កដា ឆ្នាំ ១៩៤៩ — តំលៃដាច់ ១ ឆ្នាំ ៩៦ រៀល ។

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
Mahâ Om-Nagry	Nidânasubhasit	481
M. le Yokbat Mau-Mey	Jeux populaires Cambodgiens	485
M. Ray-Buc kramkar (I.B.)	Proverbes et maximes Tome II	497
Luong Nibandhamantrî Nhok-Thêm	Histoire sommaire de l'Inde (suite)	500
—id—	Recueil de Dictons et devises français (suite)	508
Neak Oknha Nou-Kân	Histoire de « Sam Kok » (suite)	515
Neak Oknha Nong	Bhog kulkumar (en vers) (suite)	525

Partie religieuse:

Luong Nibandhamantrî Nhok-Thèm	Lumière de l'Asie (suite)	531
Maha Om-Nagry	Munisubhâsit (suite)	540

Notes et chroniques

Vén. Brah Debasatthâ So-Hay	Cérémonie de l'ondoiement du Vén. Hang-Péng	548
Ministère des cultes	Nomination des nouveaux chau Adhikar (suite)	554

21e Année: N° 7 Juillet 1949 — Prix d'abonnement: 96$00 par an.

និទានសុភាសិត

"ខ្លាពឹងព្រៃ ព្រៃពឹងខ្លា"

(ព្យញ្ជនាគត តិកនិបាត)

មហាឱម - ណាគ្រី

ឃុំស្វាយចៅ ស្រុកសង្កែ ខេត្តបាត់ដំបង ថ្ងៃរៀបរៀង

កន្លងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រប់គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វឧប្បត្តិជារុក្ខទេវតាមួយអង្គ គង់នៅជាយព្រៃធំមួយ ។ មានរុក្ខទេវតាមួយអង្គជាទៀត នៅនឹងដើមឈើដែលធំបំផុតក្នុងព្រៃដ៏តរមានរបស់ព្រះពោធិសត្វ ។

ក្នុងព្រៃនោះ មានរាជសីហ៍នឹងខ្លាធំអាស្រ័យនៅផង ព្រោះដូច្នោះទើបមិនមានមនុស្សណា ហ៊ានទៅធ្វើស្រែចំការក្នុងទីជិតនោះ ឬតាប់ដើមឈើក្នុងព្រៃនោះឡើយ ព្រោះខ្លាចសត្វទាំងពីរនោះបៀតបៀន ។ សត្វទាំងពីរនោះចាប់ម្រឹគជាតិផ្សេងៗ ស៊ីជាអាហារ ចោលសាច់នឹងអាយុះដែលស៊ីសេសសល់ទុកសំណល់ក្នុងទីនោះៗ ហើយរកស៊ីទៀតតទៅ ។ ព្រៃនោះមានក្លិនឆ្អាបឆ្អេះស្អុយអសោចទៅដោយខ្ទេចអសុកនៃម្រឹគជាតិ ។

គ្រានោះ រុក្ខទេវតាដែលនៅនឹងដើមឈើធំ ជាអ្នកខ្លៅល្ងង់មិនសូវឲ្យយល់ដល់ហេតុការណ៍ ថ្ងៃមួយបាននិយាយនឹងព្រះពោធិសត្វថា "សំឡាញ់! ព្រៃនេះមានក្លិនស្អុយអសោចខ្លាំងពេកណាស់ ព្រោះតែរាជ-

សីហ៍ធំធ្ងន់ជាហេតុ យើងនឹងដេញវាឲ្យរត់ទៅកុំឲ្យនៅរៀបទៅទៀត!" ។
ពោធិសត្វពោលឃាត់ថា "នែសំឡាញ់! វិមានរបស់យើងគាំងនៅបាន
ព្រោះគាស្រ័យសត្វទាំងពីរនោះ បើយើងដេញវាទៅហើយវិមានយើង
មុខជាវិនាសមិនខាន មនុស្សទាំងឡាយកាលមិនឃើញជានដើងរាជសីហ៍
ធំធ្ងន់ ក៏នឹងនាំគ្នាមកកាប់ឈើរើព្រៃ ជាកគាស់ឲ្យស្រឡះទៅជាវាល
នឹងធ្វើស្រែចំការមិនខាន អ្នកកុំចូលចិត្តយ៉ាងនេះឡើយ!" ។

កាលព្រះពោធិសត្វថ្លែងហេតុយ៉ាងនេះហើយ ទេវតាគោតខ្លា
នោះមិនយកចិត្តទុកដាក់ធ្វើតាមសោះ ថ្ងៃមួយបានសំដែងរូបារម្មណ៍ដ៏ធំ
ពន្លឹកគួរខ្លាច បន្លាចលង្គែហ៊ឹមគម្រាម ដេញរាជសីហ៍ធំធ្ងន់ឲ្យ
រត់ចាត់អស់ទៅ ។

មនុស្សទាំងឡាយ កាលមិនឃើញជានដើងរបស់សត្វទាំងពីរនោះ
ក៏សំគាល់ថារាជសីហ៍ធំធ្ងន់ទៅនៅព្រៃជាខ្លៃហើយ ទើបនាំគ្នាកាប់គាស់
ដើមឈើក្នុងព្រៃអស់ជាច្រើន ។ រុក្ខទេវតានោះ លុះឃើញព្រឹត្តិការណ៍
ដូច្នោះកើតខ្លឹង ទើបចូលទៅរកព្រះពោធិសត្វហើយនិយាយថា "សំ-
ឡាញ់! ខ្ញុំមិនបានធ្វើតាមពាក្យរបស់អ្នក ដេញសត្វទាំងពីរនោះឲ្យរត់
អស់ទៅ ឥឡូវពួកមនុស្សដឹងថាសត្វទាំងនោះមិននៅ ទើបនាំគ្នាចូលទៅ
កាប់គាស់ឈើក្នុងព្រៃអស់ជាច្រើន បើយ៉ាងនេះ តើយើងគិតដូចម្តេច
ទើបស្រួល!" ។ ព្រះពោធិសត្វបានឮលំដឹកនាំច្បាប់ទ្រង់ថា

"ឥឡូវសត្វតាំងពីរនោះ ទៅនោកឯព្រៃឯណោះ អ្នកទៅបបួលវាឲ្យត្រឡប់មកវិញចុះ" ។ រុក្ខទេវតាក៏ចូលទៅកឯព្រៃនោះតាមពាក្យពោធិសត្វ អង្គុយផ្តឹងអញ្ជើញវាងមុខសត្វតាំងពីរ ហើយអង្វរកឲ្យត្រឡប់ទៅទៅព្រៃដដែលវិញ ។ សត្វតាំងពីរនោះ ទោះបីទេវតាអង្វរយ៉ាងណាៗក្តី ក៏បដិសេធយ៉ាងដាច់ខាតថា "អ្នកចូរទៅចុះ យើងមិនទៅទេ" រុក្ខទេវតាគាល់គំនិត ក៏ត្រឡប់មកកាន់ព្រៃដាក់ទ្វេងដើមវិញ ។ មនុស្សតាំងឡាយ ក៏នាំគ្នាដីកគាស់កាប់រំលើងរំលំដើមឈើរហូតអស់ព្រៃ មិនយូរប៉ុន្មានក៏ធ្វើផែនដីនោះឲ្យទៅជាស្រែចម្ការកសិកម្មអស់ទៅ ។

កន័្ទរបស់រឿង

រឿងនោះពន្យល់ឲ្យដឹងថា	"ខ្លាពឹងព្រៃ ព្រៃពឹងខ្លា"
ខ្លាទៅព្រោះព្រៃបិទ	ព្រៃសណ្តៀតព្រោះខ្លាទៅ
ដីត្រូវបាក់ព្រោះស្មៅ	ស្មៅលូតលាស់ព្រោះដីល្អ ។
អ្នកមានក្បាលត្រង់	ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញក្បាលវែង	ដូចសំពៅពឹងសំប៉ាន ។
រាជការបានប្រាក់ខែ	ក៏ព្រោះតែការស្តាប់ឱ្យពន្ធ
ការស្តាប់ចាកអស់ពួក	ព្រោះរាជការជួយការពារ ។
ហេតុនេះត្រូវស្ម័គ្រស្មោះ	ជួយសង្គ្រោះគ្នានឹងគ្នា
ទើបបានសុខសាន្តដា	អស់វេលាយូរយារអើយ!!! ។

សុភាសិត

ការដក់គាកៀនការញៀនកញ្ជា ការផឹកសុរាហ៊ឺហាហ៊ឹកហ៊ាក់
ការលេងល្បែងក្តាល់បៀចោ៊ងឡុកឡាក់ ឥត្តីធុត្តៈការលេងស្រីញី ។
ការដើរលេងយប់យឺតយូរហួសយាម ការជាប់ជាក់ជាមសេពគប់សម្ផី
នឹងមនុស្សគាគ្រក់លាមកផឹកស៊ី ទាំងនេះនាំវិនាសអន្តរាធាន ។

មហា ទម - ណាត្រិ

ល្បែងដេ្ឋង ។

របស់លោកយោក្សត្រ មៅ ម៉ី

ក្រសួងមហាផ្ទៃ ភ្នំពេញ

"រង្វាន់លេខ ពីរ"

ល្បែងតាំងនេះ កើតមានជាយូរយារណាស់មកហើយ គឺល្បែងលេងពួន, លោតអង្ខាក់, លាក់កន្សែង, ចាប់កូនខ្វែង, ប៉ឺង ឬវាយកូនបែ៉ង, លេងអង្គញ់, ចោលឈូង, ទឹងគាញព្រ័ត្រ ។ល។

ល្បែងតាំងនេះ មានលេងរើសពេលខ្លះ មិនរើសពេលខ្លះ មានលេងបានតែក្មេង ។ខ្លះ មានលេងសុទ្ធតែមនុស្សចាស់ ។ខ្លះ ចែកចេញជាពីរចំណែក :

១) ល្បែងលេងពួន, ចាប់កូនខ្វែង, លោតអង្ខាក់, លាក់កន្សែង, កូនបែ៉ង មានលេងច្រើនតែកូនក្មេង ឥតមានរើសពេលវេលាទេ ឲ្យតែយប់ខ្លីចេះតែលេងបានតាំងអស់ រៀវលេងតែកូនបែ៉ង ១ ចេញ ព្រោះល្បែង ១ នេះលេងបានតែពេលថ្ងៃ ប្រហ៊ែយក្មេងដែលលេងនោះទៀតច្រើនតែក្មេងឃ្លាលក្របី នាំគ្នាលេងនៅទុកាសឃ្លាលក្របី ។

២) ល្បែងចោលឈូង, អង្គញ់, គាញព្រ័ត្រ, ច្រើនតែមនុស្សចាស់លេង ក្នុងទុកាសចូលឆ្នាំថ្មី កំណត់កាលដែលលេងនោះ ៣ យប់ ៣ ថ្ងៃ ចួនកាលលេងនៅកងកូមិ ចួនកាលលេងកងវត្តអារាម ។

ល្បែងទាំងនេះខ្ញុំសូមអធិប្បាយដូនតាមមាតិកាដូចខាងក្រោមនេះ ៖-

ក) **ល្បែងលេងពួន** - (លេងនៅវាលត្រពាំងវែង) កាលខ្ញុំនៅជាកុមារតូចនៅឡើយ ខ្ញុំធ្លាប់លេងនឹងគេដែរ, នៅពេលយប់ខែភ្លឺទួលទានបាយរួចហើយ ក្មេងប្រុសស្រីដើរបបួលគ្នាបាន ១០ នាក់ឆ្លើមគ្នាលេងពួន មានក្មេងម្នាក់នៅចាំទី ក្មេងឯទៀតទៅពួន ។ មុនទីឆៅពួន រាល់ដំកង់គ្នាជុំវិញ, មានក្មេងម្នាក់ឈរនៅចំកណ្តាល ជាអ្នកចាត់ចែងរើសអ្នកចាំទី ក្មេងនោះយកដៃទៅចង្អុលដើមទ្រូង ក្មេងឯទៀតដែលឈរជុំវិញខ្លួននោះ ហើយថាជាពាក្យដូច្នេះ " គ្រាយត្រកគ្រាយត្រែង ចាក់ក្រអេងណាំខ្ទើក ចាក់កាឌឹកខុយយ៉ា ចាក់ក្រយាយោយឌិច " ពាក្យចុងបង្អស់ទៅត្រូវតឹមក្មេងណា ក្មេងនោះត្រូវទៅពួន ។

រាថាដដែល ។ កាលតែគ្រប់គ្នា នៅសល់ក្មេងណា ក្មេងនោះត្រូវនៅចាំទី ។ ឯទីនោះ គឺវាគួរជាទីរង់មូលជុំវិញ សន្មតជាទីរបស់វា ហើយក្មេងអ្នកចាំទី តាំងយកដៃបិទមុខ ដើម្បីសញ្ញាឲ្យក្មេងឯទៀតទៅពួន ។ លុះ ១ ស្របក់រាស្រែកថា " បើកគ្រប់ហើយ " ក្មេងដែលពួនតាំងលាក់ខ្លួនសម្ងំស្ងាត់ជ្រៃប ពុំហ៊ានមាត់កឲ្យឮទេ ទំរើលបៗទន្លុបទៅរកចូលទី កុំឲ្យក្មេងចាំទីឃើញ តែវាឃើញវាចាប់ញៀចស្ទឹកត្រៀក ម្ល៉ោះហើយក្មេងៗ មានសេចក្តីគិតភ័យខ្លាំងណាស់ ។ ចំណែកក្មេងអ្នកចាំទី ក៏ប្រឹងគយគន់មើលគ្រប់ច្រកល្កកផុះ ក្រែងឃើញក្មេង

ដែលតួន នឹងគាលចាប់ញៀច បើចាប់ញៀចឯានម្នាក់ៗ មានចិត្តត្រែតអណាស់ ព្រោះសង្ឃឹមថា ពេលគ្រោយនឹងឯានទៅតួននឹងគេ បើញៀចមិនឯានទេ ដល់ពេលតួនលើកគ្រោយ គេក៏ឲ្យវាទៅតែចាំទីរហូតដល់ទៅឈប់លេង ។

ល្បែងលេងតួន ចប់តែបែបណ្ណោះ

ខ) **ល្បែងលោតអន្ធាក់** – ល្បែងនេះ គាលខ្ញុំនោតីក្មេង ខ្ញុំធ្លាប់លេងនឹងគេដែរ, ដើមដំបូង យកក្មេងពីរនាក់ឲ្យកាន់ដៃគ្នា អង្គុយចោងហោងបែរមុខរកគ្នា ក្មេងឯទៀតជាអ្នកលោត ។ ម្ខាងអន្ធាក់នោះខ្ពស់បន្តិចចេះតែខ្ពស់ៗទៅ បើក្មេងណាលោតទៅគាក់នឹងដៃក្មេងដែលធ្វើអន្ធាក់នោះ ត្រូវឈប់លោតតទៅទៀត ក្មេងណាដែលគាចលោតឯ្លាខ្ពស់នោះ ត្រូវចេះតែលោតៗទៅ ។ ល្បែងនេះ ចេះតែឆ្ងាស់គ្នាធ្វើអន្ធាក់ម្ខាងៗ រហូតទៅទល់នឹងឈប់លេង ។ ល្បែងនេះសង្កេតឃើញថា ជាល្បែងហាត់ចំរើនកំពស់ ។

ល្បែងលោតអន្ធាក់ ចប់តែប៉ុណ្ណោះ

គ) **ល្បែងលាក់កន្សែង** – ល្បែងនេះ ខ្ញុំធ្លាប់លេងដែរ គាលនៅពីកុមារ – រៀបលេងមានច្រើនគ្នា នាំគ្នាអង្គុយជុំគន់ជុំវិញ ក្មេងម្នាក់ជាអ្នកកាន់កន្សែងដើរលាក់ ។ ឯកន្សែងនោះ ចួនគាលយកក្រមាឆ្នូតវិកឆ្លុះធ្វើជាដុំ ១ ហើយកាន់ដើរដុំវិញក្មេងដែលអង្គុយជុំគន់នោះ ល្មមតែក្មេងគាំងនោះអង្គុយក្ងេចត្រចៀក យកកន្សែងទៅលាក់ពីក្រោយខ្នង

ហើយដើរមួយដុំទៀតទៀត ក្មេងដែលគេលាក់កន្សែងពីក្រោយខ្នង បើដឹងខ្លួន ក៏យកដៃស្ទាបពីក្រោយខ្នង បើឃើញត្រូវរើសយកកន្សែង ដើរលាក់ម្តង ។ បើអ្នកលាក់កន្សែងត្រឡប់មករើសយកកន្សែងបានពីក្រោយខ្នងក្មេងណា ត្រូវគក់ទឹងលុកកន្សែងត្រង់កណ្តាលខ្នងក្មេងនោះ ១ ក្តុក ហើយកាន់ដើរលាក់តទៀតទៀត ។

ល្បែងនេះ សង្ឃឹមឃើញថាជាល្បែង ១ សម្រាប់ឲ្យមានស្មារតីប្រុងខ្លួនជានិច្ច កុំឲ្យគេលួចយករបស់អ្វីទៅលាក់ក្បែរខ្លួន បើទុកជាគេយកមកលាក់ ក៏ឲ្យដឹងថាគេលាក់ ។

បបំល្បែងលាក់កន្សែង តែប៉ុណ្ណោះ

ឃ) **ល្បែងចាប់កូនខ្វែង** — ល្បែងនេះ គេលេងត្រាប់តាមសត្វខ្វែងដែលធាបចាប់កូនមាន់, តែដែលហៅថាចាប់កូនខ្វែងទៅវិញ គឺជាពាក្យផ្ទុយគ្នានឹងចាប់កូនមាន់ ។

វិធីដែលនឹងលេង គឺក្មេងម្នាក់ដែលមានរូបមាឌធំមាំជាងគេ ធ្វើជាសត្វខ្វែង ។ ក្មេងម្នាក់ទៀតធំមាំជាងគេ ធ្វើជាមេមាន់ ហើយក្មេងឯទៀតធ្វើជាកូនមាន់ គោចចង្កេះទោតៗ គ្នាពីមេមាន់រហូតទៅក្រោយក្មេងដែលធ្វើជាខ្វែង តាំងរត់ផ្អៀងខ្លួនរេចុះរេឡើង ធ្វើជាអ្នកក្ងាហានធាបដុំវិញមេមាន់ ដើម្បីដណ្តើមយកកូនមាន់ដែលគោងពីក្រោយ ឯមេមាន់ក៏ទំការពារកូនដែរ ប្រាថ្នាសត្វខ្វែងមិនឲ្យឆក់យកកូនបាន ។ ចួនកាលការពារឈ្នះ ចួនកាលក៏ការពារមិនឈ្នះ ខ្វែងដណ្តើមយកកូនបានខ្លះទៅ ។

ល្បែងនេះ ជាវិធីហាត់ប្រាណឲ្យរហ័សរហួន ដើម្បីរក្សាបស់ទ្រព្យដែលគេបំរុងដណ្តើមយក កុំឲ្យគេយកបាន ។

ចប់ល្បែងបាច់ក្តួងខ្វៃគ តែប៉ុណ្ណោះ

ឆ) **ល្បែងក្តួងប៉ែង ឬ ហ៊ុំង** — ល្បែងនេះ គាលខ្ញុំនៅពីក្មេងធ្លាប់បានលេងជាច្រើនដងណាស់ ព្រោះខ្ញុំបាននៅឃ្លាលក្រប៉ំនឹងគេដែរ ពួកក្មេងដែលលេងច្រើនតែក្មេងឃ្លាលក្រប៉ី ។ ឯទីកន្លែងដែលលេងៗនៅពេលដែលឃ្លាលនោះ ។ ប្រដាប់សម្រាប់លេងហ៊ុំនេះ គឺមានកូនប៉ែង ១ ប្រវែង ១ ចំអាម ហើយនឹងព្រនង់ ១ ប្រវែង ២ ហត្ថ ។ រៀបលេងត្រូវចែកពួកគ្នាជា ២ ពួកឲ្យស្មើភាគគ្នា ទីកន្លែងលេង ត្រូវជីកដីធ្វើជារន្ធសណ្ឋានទ្រវែង ទំហំប៉ុនព្រនង់នោះ ហើយយកកូនប៉ែងទៅជាក់ទទឹងរន្ធនោះ រួចយកព្រនង់ឆ្កេះឲ្យលឿនទៅមុខ អ្នកឆ្កេះនោះ លុះឆ្កេះរួចហើយត្រូវយកព្រនង់ជាក់ទទឹងរន្ធវិញ ឯក្មេងពួកម្ខាងត្រូវឈរចាំចាប់ បើចាប់កូនប៉ែងបានត្រូវបោះទៅឲ្យត្រូវព្រនង់ដែលនៅលើរន្ធ បើបោះត្រូវៗទៀងមកឆ្កេះវិញ បើបោះមកមិនត្រូវ, អ្នកឆ្កេះដំបូង ត្រូវប៉ែងកូនប៉ែងទៅមុខទៀត ហើយយកដំបងមកគ្រវាសនៅរន្ធ បើគាលណាគេបោះកូនប៉ែងមុក ត្រូវវាយជាក់ឲ្យត្រូវកូនប៉ែង ឲ្យឃ្លាតឆ្ងាយពីមាត់រន្ធចំនួនប្រវែង ១ ព្រនង់, បើឆ្ងាយជាងនេះ ត្រូវវាស់នឹងព្រនង់ហើយកាប់ បើបាន ១០ ហើយ ត្រូវឈប់ប៉ែងទៅទៀត, បើខ្លះត្រូវប៉ែងឲ្យគាលតែបានគ្រប់

ចំនួន ១០ លុះគ្រប់ ១០ ហើយ ត្រូវយកកូនបែ"ងមកវែតនឹងពួនដ៏ រាប់ថា មួយ, ពីរ, បី, ... បើកូនបែ"ងធ្លាក់ត្រឹមចំនួនណា ត្រូវឈប់វែតត្រឹមណោះ ហើយក"យកដំបងវាយកូនបែ"ងនោះ ឲ្យធ្លាយទៅមុខ, ឯពួករក្នុងម្ខាងដែលចាញ់នោះចាំមើល បើឃើញកូនបែ"ងធ្លាក់ត្រឹមណា ត្រូវទៅរើសយកកូនបែ"ងនោះក្តាប់ក្នុងដៃហើយរត់ស្រែកថា "ហ៊ឹង!" កុំឲ្យជាប់សំឡេង រត់សំដៅមករកវន្ត ដល់ហើយ យកកូនបែ"ងមកប៉ោះជាក់នៅវន្ត ។ បើជាប់សំឡេងនៅកន្លែងណា អ្នកម្ខាងដែលឈ្នះ ត្រូវវាយកូនបែ"ងបន្តពីកន្លែងនោះទៅទៀត ចាប់អ្នកចាញ់ឲ្យហ៊ឹងម្តងទៀត ដរាបណាល់តែមិនជាប់សំឡេង, វាយកូនបែ"ងឲ្យគ្រប់នឹងវែត បើបាន ១ ត្រូវហ៊ឹងតែ ១, បើបានពីរត្រូវហ៊ឹង ២ ដង, រួចហើយផ្ទាស់គ្នាលេងម្តងម្នាក់ រហូតទៅទល់នឹងឈប់លេង ។

ល្បែងនេះ គេលេងសំរាប់បំបាត់ងងុយដេក នៅពេលដែលឃ្លានគេ ត្រប៉ ព្រោះស្មារតីកូនក្មេង តែនៅស្ងៀម ច្រើនតែងងុយដេក ម្ល៉ោះហើយនាំគ្នាលេងផង មើលគេ ត្រប៉ដែ ។

ចប់ល្បែងកូនបែ"ង ឬ ហ៊ឹងតែប៉ុណ្ណោះ

ល្បែងទាំង ៣ ប្លាយដែលបានពណ៌នាមកហើយនេះឯង ជាល្បែងសម្រាប់កូនក្មេងលេង ទាំងជាល្បែងមិនសើសពេល ។ តអំពីនេះ នឹងអធិប្បាយអំពីល្បែងសម្រាប់មនុស្សចាស់លេងតទៅទៀត ។

ល្បែងដែលមនុស្សចាស់លេងបាននោះ គឺល្បែងអង្គញ់ - ចោលឈូង - ទាញព្រ័ត្រ, ល្បែងទាំង ៣ មុខនេះ ក្មេងក៏លេងបាន មនុស្សចាស់ក៏លេងបាន តែច្រើនលេងក្នុងថ្ងៃចូលឆ្នាំ ៣ យប់ ៣ ថ្ងៃ លេងខ្លួនឯងគាប់ចិត្ត, ចូនកាលលេងក្នុងភូមិ ចូនកាលលេងក្នុងវត្ត ។ ក្នុងល្បែងទាំង ៣ មុខនេះ សូមនិយាយតែល្បែងចោលឈូង នឹងទាញព្រ័ត្រ ដូចមានអធិប្បាយតទៅនេះ :

ល្បែងចោលឈូង

ល្បែងនេះ មានលេងនៅខែត្រពៃវែង ខ្ញុំធ្លាប់លេងជាញឹកញាប់ក្នុងខ្ញុំកុងនុកាសបុណ្យចូលឆ្នាំរាល់ឆ្នាំ , ដែលហៅថា ឈូង គឺគេយកសំពត់ប្តូរកមាចង្កឹមកមូរធ្វើជាដុំមូល រួចយកកមា ១ មករុំវេចចង់ព័ទ្ធក្រៅ ទុកំបន្សល់ចុងជាយសម្រាប់យួរទៅមក ។ ល្បែងឈូងនេះ មានលេងជា ២ យ៉ាង មួ៉ាងហៅថា លេងឈូងចោល មួ៉ាងទៀតហៅថាលេងឈូងច្រៀង ។ ឯរបៀបលេងមានប្រុសម្ខាង ស្រីម្ខាងដូចគ្នា ប៉ុន្តែប្លែកគ្នាតែងរបៀបលេង ដូចខាងក្រោមនេះ :

លេងឈូងចោល

លេងឈូងចោលនេះ អ្នកត្រូវលេងសុទ្ធតែឈរ ប្រុសម្ខាងស្រីម្ខាងពួកខាងប្រុសចោះឈូងទៅឲ្យខាងស្រី បើខាងស្រីចាប់បានត្រូវចោល

ឈូងតម្រង់ទៅខាងប្រុស បើត្រូវគ្រង់ខ្លួនប្រុសណា ពួកស្រីៗ នាំគ្នា
ទៅទាញអូសយកប្រុសនោះមកទុកក្នុងវង់របស់ខ្លួនឲ្យធ្លើជា ខ្ចិបរើហើយក៏
ចោះឈូងនោះទៅឲ្យខាងប្រុសវិញ បើខាងប្រុសចាប់បាន ត្រូវលោះ
យកគូកនដែលនៅក្នុងវង់ស្រីមកវិញ ហើយចោះឈូងទៅឲ្យស្រី ចេះ
តែចោលគ្នាទៅវិញទៅមក ។ ល្បែងនេះ គេសន្មតថាឈ្នះ ដោយអា-
ស្រ័យពួកខាងណាចោលឈូងទៅត្រូវច្រើនជាង គឺបើស្រីចាប់បាន
ចោលទៅប្រុស ត្រូវច្រើនជាង គេឃើញប្រុសៗមកនៅក្នុងវង់ស្រីជា
ច្រើន, បើខាងប្រុសឈ្នះគេឃើញមានស្រីជាច្រើនមកនៅក្នុងវង់ប្រុស ។
ឯអ្នកលេងល្បែងនេះ មានចិត្តរីករាយសប្បាយណាស់ ដោយពួកគ្រមុំ
ទឹងកំឡោះបានស្និទ្ធស្នាលនិយាយស្តីជាមួយគ្នា គ្មានកោតញ្ញើតទេ ។

លេងឈូងប្រៀង

ពួកអ្នកលេងចែក ២ ពួក គឺពួកម្ខាងប្រុស ពួកម្ខាងស្រី ដូចលេង
ឈូងចោលដែរ ប៉ុន្តែបើចាប់ឈូងបានហើយ មិនចោលគ្នាទៅវិញទៅ
មកទេគឺបើខាងប្រុសចាប់បាន ត្រូវខាងស្រីពាយទំនុកច្រៀងផ្សេងៗ,
បើខាងស្រីចាប់បានវិញ ត្រូវខាងប្រុសច្រៀង, ល្បែងនេះសន្មតថា
ឈ្នះចាញ់ដោយហេតុ ពួកខាងណាចាប់ឈូងបានច្រើនជាង ត្រូវឈ្នះ
ខាងណាចាប់មិនសូវបានត្រូវចាញ់គេ គេប្រើឲ្យច្រៀងច្រើនជាងគេ ។

ល្បែងទាញព្រ័ត្រ

នៅពេលថ្ងៃបែរព្រឹក ជាថ្ងៃទី ៣ នៃថ្ងៃចូលឆ្នាំ ពួកក្រមុំកំឡោះ បបួលគ្នាលេងទាញព្រ័ត្រ នៅក្នុងទីវត្ត ។ របៀបលេង មានខ្សែពួរ ១ វែងប្រវែង ៥០ ម៉ែត្រ ធ្វើពីជក់ដូចទំហំប៉ុនកដៃ ជាក់លាស្នឹងនៅដី, ពួកប្រុសកំឡោះចំនួន ២០ នាក់កាន់កន្ទុយពួរម្ខាង ពួកស្រីក្រមុំចំនួន ២០ នាក់ដែរ កាន់កន្ទុយពួរម្ខាង ហើយក៏តាំងទាញប្រណាំងគ្នាទំប្រឹងទាញពេញទំហឹងទាំងសងខាង ។ ខាងប្រុសឃើញមួរដើងខោយកសំពត់ក្រមាក្រវាត់គាតនៅចង្កេះយ៉ាងមាំ, ខាងស្រីឃើញចងក្បឿនក្រវាត់សំពត់ដូចគ្នា ។ ក្នុងពេលដែលទាញនោះ ឃើញបែកញើសហូរសស្រាក់តែរៀងខ្លួន ទាំមាត់ទំលាក់ខ្ទុះបន្ទាបនុនចុះស្ទក់លើខ្សែពួរ ។ ចំណែកអ្នកកាន់កន្ទុយពួរទាំងសងខាង ឃើញយកកន្ទុយរុំព័ទ្ធជុំវិញចង្កេះខ្លួន ហើយបន្ទាបដើងខ្លាង ដើងខ្លាងទៀតជាក់ដីជ្រែងទំប្រឹងមិនឲ្យខ្សែពួរបូតពីចង្កេះខ្លួន ។ ពួកអ្នកលេងនឹងពួកអ្នកឈរមើល ឮសូរតែស្រែកទ្រហឹងអឺងកង ទំប្រឹងទាញខោយឺត ។ មើលទៅឃើញដូចជាក្អែបវារនៅផ្លូវ, ប្រហែល ១ ស្របក់ស្រាប់តែឮសូរហ៊ោគ្រេវឡើង ពួនកាលឃើញខាងប្រុសទាញខ្សែអូសទាំងស្រែមកខាងទីរបស់ខ្លួន ពួនកាលឃើញខាងស្រីទាញអូសប្រុសៗ ទាំមកខាងទីរបស់ខ្លួន, អ្នកឈរមើលទាំងប៉ុន្មានក៏សើចក្អាកក្អាយសប្បាយពាល់គ្នា ។

ល្បែងនេះ ចួនកាលខាងប្រុសតិចជាងខាងស្រី ដូចថាខាងប្រុស ១០ នាក់ខាងស្រី ១៥ នាក់ ព្រោះធម្មតាមនុស្សប្រុសច្រើនជាអ្នកកម្លាំងខ្លាំង ឯមនុស្សស្រីមានកម្លាំងខ្សោយ អាស្រ័យហេតុនេះហើយ ឃានជាដល់ពេលលេងទាញព្រ័ត្រម្តង។ ខាងស្រីច្រើនតក់ឲ្យឃានគ្នាច្រើនជាងខាងប្រុស ។ កាលលេងទៅចួនកាលខាងប្រុសឈ្នះ ចួនកាលខាងស្រីឈ្នះ។

ចប់ល្បែងទាញព្រ័ត្រ តែប៉ុណ្ណោះ

ល្បែងទាំងប៉ុន្មានដែលខ្ញុំឃានតែងមកនេះ ខ្ញុំឃានដឹងតែល្បែងទាញព្រ័ត្រ១ទេ ដែលជាល្បែងមានជាប់ទាក់ទងនឹងរឿងព្រេង, ឯល្បែងក្រៅពីនេះ ខ្ញុំគ្រាន់តែធ្លាប់លេងធ្លាប់ឃើញអ្នកស្រុកលេងត ៗគ្នា មកជាយូរអង្វែងហើយ ។

ឯរឿងព្រេងទាញព្រ័ត្រនោះ ខ្ញុំឃានឮពីសំណាក់ព្រះតេជព្រះគុណព្រះសព ព្រះមហាវិមលធម្ម នាមថោង ចាងហ្វាងសាលាឃាលីជាន់ខ្ពស់ កាលគង់ព្រះជន្មនៅឡើយ ។ លោកនិទានថា ល្បែងទាញព្រ័ត្រកើតមានឡើងជាដំបូង គឺមកពីពួកយក្ខនឹងពួកទេវតាច្បាំងប្រកួតកម្លាំងគ្នា ដូចមានក្នុងរឿងភមាយណៈ (ភមក្ខ័) ។

ដំណាលថា មានថ្ងៃមួយ ពួកយក្សកើតសេចក្តីច្រណែនឫស្យានឹងពួកទេវតា ថាពួកទេវតាគ្មានរិទ្ធិតំឡាំងខ្លាំងពូកែជាងពួកយើងជាយក្សទេ ប៉ុន្តែឃានទីហានខ្ពស់ជាងពួកយើង ដោយសារតែព្រះជាម្ចាស់ (ព្រះឥស្សរ)

ទ្រង់ប្រោសប្រាណរាប់អាន ប្រសិនបើពួកទេវតាចង់ល្បងពិសោធន៍ខាងកម្លាំងពលំវិញ មុខជានឹងចាញ់យើងឥឡូវហើយ ។ ពួកទេវតាបានឮក៏មានសេចក្តីអៀនខ្មាសនឹងពួកយក្ស បានអួតតបទៅនឹងពួកយក្សវិញថា យើងមិនខ្លាចទេ មានត្រឹមកម្លាំងយក្ស ប្រសិនបើចង់ប្រកួតកម្លាំងគ្នាយើងក៏ហ៊ានដែរ រៀវៃលន់តែប្រើវិធីយុទ្ធសង្គ្រាមចេញ សូមឲ្យប្រើវិធីអ្វីមួយ ចំពោះប្រកួតតែកម្លាំងនឹងកម្លាំង ។ កាលណោះ យក្សនឹងទេវតាបានសុខចិត្តមូលមាត់ព្រមគ្នាថា ត្រូវយកវិធីខាញ្រ៉ាត្រក្នាល់កម្លាំងគ្នា បើខាងយក្សខាញ្រ៉ាឈ្នះទេវតា យក្សត្រូវបានហានទីខ្ពង់ខ្ពស់ជាង ទោះបូលទៅតាល់ព្រះឥសូរក្តី ឬទៅកាន់ទីប្រជុំឯណាមួយក្តី ត្រូវយក្សមានសិទ្ធិអង្គុយលើអាសនៈខ្ពស់ជាងទេវតាជារាប ហើយក៏ព្រមព្រៀងគ្នាថានឹងយកវិធីខាញ្រ៉ាត្រជាវិធីប្រកួតកម្លាំងគ្នា ហើយក៏ដំនុំគ្នាយកនាគ ១ មកធ្វើជាខ្ញ្រ៉ាត្រខាញ្រ៉ាកងវៃលៃឆ្ងៃស្អែកមុខនេះ ។ មុនពេលខាញ្រ៉ាខ្ញ្រ៉ាត្រនេះ ខាងពួកទេវតាខាំគ្នាដើរស្រុះស្រោះឡើងទៅមុខព្រះលានព្រះឥសូរ ទូលពេលនោះព្រះពាលីក៏ចូលទៅតាល់ព្រះឥសូរដែរ ស្តេចពាលីបានយល់ហេតុដូច្នោះ ក៏ត្រាស់សួរទៅទេវតាថា ចុះមានហេតុកេតដូចម្តេច ឃានជាខាំគ្នាដើរស្រុះស្រោះឡើង ។ ទេវតាបានទូលតាមដំណើរសព្វគ្រប់ដល់ស្តេចក្រុងពាលី ។ ក៏មានបន្ទូលឆានាអះអាងថា នឹងជួយជោះទុក្ខដល់ពពួកទេវតា ប៉ុន្តែឲ្យពួកទេវតាធ្វើតាមបង្គាប់ទៅពេលដែលខាញ្រ៉ាត្រនោះ គឺ

ត្រូវឲ្យពួកទេវតាទាញខាងក្បាលនាគឲ្យពួកយក្សទាញខាងកន្ទុយ លុះដល់ពេលនឹងទាញឲ្យឈរតម្រៀបគ្នា ពីក្បាលនាគទៅដល់នឹងពោះនាគ នៅពេលកំពុងទាញ ឲ្យទេវតា១អង្គយកម្រាមដៃចុចត្រង់ធ្មិតនាគ តែកាលណាចុចទៅ នាគមុខជាវាសើបហើយវានឹងខំប្រឹងវាត់កន្ទុយឲ្យផុតរបូតអំពីដៃយក្ស ផ្សំនឹងកម្លាំងទេវតាផង កម្លាំងនាគផង មុខជានឹងឈ្នះយក្សពុំខាន ។ ពួកទេវតាកាលបើបានស្តាប់ស្តេចក្រឹងពាលីពន្យល់កលកិច្ចដូច្នោះ ក៏មានចិត្តរីករាយសោមនស្សណាស់ ។ លុះដល់ពេលទាញព្រំត្រូតពួកទេវតាក៏សូមទាញខាងក្បាលនាគ ពួកយក្សក៏យល់ព្រមដល់ប្រកួតទាញនោះ ពួកទេវតាក៏មានជ័យជំនះឈ្នះពួកយក្សប្លែកជាក្នុងពេលនោះមែន ។ ហេតុនេះហើយបានជាមានទំនៀមទម្លាប់ជាប់រហូតមកដល់សព្វថ្ងៃនេះគ្រប់តែស្រុក តែកាលណាចង់ក្លាល់កម្លាំងគ្នា គេតែងតែលេងលែ្បងទាញព្រំត្រូតនេះ ។ ព្រោះហេតុនេះ ឃានជាគេឃើញរូបចម្លាក់នៅជញ្ជាំងប្រាសាទនគរវត្ត មានរូបនាគ១វែងលាយ ខាងក្បាលឃើញសុទ្ធតែពួកទេវតា ខាងកន្ទុយឃើញសុទ្ធតែពួកយក្សទាញប្រជែងគ្នាមានទំនងដូចជារបៀបដែលយើងទាញព្រំត្រូដូច្នោះ ប៉ុន្តែខុសគ្នាតែត្រង់ព្រំត្រូ យើងសព្វថ្ងៃនេះប្រើខ្សែព្រួរជំនួសព្រំត្រូ ។ ឯខ្សែព្រួរនោះធ្វើពីដក់ដូង ឬ ពីផ្តៅ ប្រើជាព្រំត្រូសម្រាប់ទាញ ។

ចប់រឿងព្រែងទាញព្រំត្រូ តែប៉ុណ្ណោះ

ម៉ៅ-ម៉ី យោកស្បាត់ ក្រសួងមហាផ្ទៃ ភ្នំពេញ

សុភាសិត ភាគទី ២

លោក ព័យ-ប៊ុក ក្រមការលេខ ២ រៀបរៀង

ឃុនសុវត្ថិវេធី យូរ-អ៊ុន ពិនិត្យកែ

១.– ជាតិវគ្គ

១ – ក្រហស្ថទង់ជ័យ ព្រះសង្ឃវិន័យ ជាសម្បត្តិខ្លួន ទង់ជ័យ វិន័យ ត្រូវទំថែងួន ប្រតិបត្តិតាមក្បួន កុំឆ្ងេសសព្វថ្ងៃ ។ កប៉ាល់នាវ៉ា សញ្ចរយាត្រា មានត្រីវិស័យ ដូចមនុស្សក្នុងលោក ត្រូវពឹងទង់ជ័យ ទើបផុតទុក្ខភ័យ ថ្លើងរិទ្ធិចេស្តា ។ ទង់ដូចប្រទីប បំភ្លឺគ្រប់ទីប ចក្រវាឡ ឲ្យសត្វទីពឹង ចំរើនសុខា ក្នុងវដ្តសង្សារ រៀងដល់និព្វាន ។

២ – បុគ្គលណា ស្ងាប់ព្រោះជាតិ,ធម៌ បុគ្គលនោះឈ្មោះល្អទុក ដូចរស់ អ្នកដែលរលះចោលជាតិ,ធម៌ស្មោះ បើទុកជារស់ក៏ដូចស្ងាប់ ។

៣ – អ្នកណាចិត្តហានក្លា ព្រៃធ៌ាស្មាបើកទ្វារឲ្យ អ្នកណាចិត្តកំសោយ តែងថ្ងោះធ្វោយដួបក្តីក្រ ។ ប្រៀបដូចមាន់ប្រជល់ មិនចាញ់កល់មាន់សម្ង តែងចូលសង្វៀនត ច្បាំងសត្រូវមិនញាត់ញើត ។

៤ – វល្ល៌ស្មៅតូចមែនពិត តែវេចតែដំរីបាន កណ្ដៀរសត្វតិរច្ឆាន កញ្ជូនឋានដំបូកធំ ។ ដៀបដូចសាមគ្គី កើតពេញទីកង៌សង្គម ជាគុណគាប់ខត្តម អាចកើតសម្រិទ្ធិជោគ ។

៥ - បើធ្វើកិច្ចការ ចូរគិតពិចារ ឲ្យបានម៉ាំមួន បើបរាជ័យ ចាញ់ដៃថ្មោះខ្លួន ត្រូវខំថែធួន សួនខ្លួនឡើងវិញ ។ បើដើរមគ្គា ភ្លាត់ជួល ផ្កាប់ផ្ងា ត្រូវក្រោកឡើងឃ្មាត ប្រឹងដើរតទៅ លុះដល់ជាអាទិ៍ ទីដែលសង្ឃាត ទើបសម្រេចផល ។

៦ - គួរខ្លាចក៏ខ្លាច បើហ៊ានបុកាច ប្រើសុភាពពិត អ្នកហ៊ានស្បែកផាច អ្នកខ្លាចស្បែកស្អិត នេះសុភាសិត បណ្ឌិតប្រដៅ ។

៧ - ស្រមោចរូបមាឌតូចមែនពិត តែសាមគ្គីចិត្តសម្លាប់ចាន មេអំបៅដង្កូវធំរូបច្បាណ ឆនកល្យាណគួរយកតម្រាប់តាម ។

៨ - ចូរចាំរៀន សិល្បសាស្ត្ររៀន កុំចាំបាច ត្រូវខំទន្ទេញក្បួនច្បាប់ទាំង ធម៌អាថ៌បទចាប ខាន់រ័យនៅកេង ។ ជាតិជាប្រុសស្រី នៅនាលោកិយ អប់រំខ្លួនឯង ដោយសិល្បវិជ្ជា ម៉ឺងម៉ាត់ជាក់ស្តែង គុណវិជ្ជាតែង ឲ្យរុងរឿងវៃក្រៃ ។

៩ - វែកចាវធ្ងន់មែន វែកការិយាសែន ត្រួយហើយធ្ងន់ផង ការពផែនដី ធ្ងន់ក្រៃកន្ទុង ពាលោកជាតុហោង ធ្ងន់តគណនា ។

(ខ) លីចាវឬឈើធ្ងន់ណាស់សា តែធ្ងន់ការិយាក្រៃបំផុត ការពផែនដីជាតិសាសន៍សុទ្ធ ធ្ងន់ផុតលើសលែងធ្ងន់នានា ។

១០ - ត្រូវនឹកប្រមូលការគ្រប់មុខ មកពិនិត្យទុកមុននឹងធ្វើ ការណាយល់ថាគាប់ប្រសើរ ត្រូវប្រឹក្សាយាមនឹងមាន ; ព្រោះធម៌ពីរ

នេះជាអាវុធ សម្រាប់តយុទ្ធនឹងបុគ្គល គ្រោះកាចស្អប់ការដែលពាសរុះ ឲ្យ
ចាញ់តេជះការសម្រេច ។

១១ - អ្នកណាឧស្សាហ៍ ព្យាយាមតាំងធ្លា មែកឈើពាលរំថ្ម លុះ
អនាគត ឋាកុំសង្ស័យ កើតផ្លូវប្រសើរ ក្នុងលោកព្រហ្ម ។

១២ - ប្រទេសមួយស្តេចពីរមិនកើម្យ វត្តមិនគួរមសំយោគពីរ
ព្រះពុទ្ធទ្វេអង្គហោចសាមគ្គី អាទិត្យពីរទើក្តៅនៅមិនបាន ។

១៣ - បើច្បាំងត្រូវតាំងយកឈ្នះចាញ់ បើធ្វើអញ្ចឹងឲ្យដល់ពាល
ប៉ើរៀនវិជ្ជាឲ្យផុតពាល ទើបអាចបណ្តាលឲ្យគុណគាប់ ។

១៤ - ក្អែកទឹកមិនស្គាល់ទន្សេស្លឹង មិនស្គាល់ថ្លុកចឹងកុកក្រសារ
ពានមិនស្គាល់ព្រៃព្រឹក្សា អ្នកកាន់សាសនាមិនស្គាល់ព្រះ ។

១៥ - លំបាកខ្លួនឋាណាទើបស្គាល់ធម៌ លំបាកខ្លួនគួរទើបសុីរ-
ឡើយ ធ្វើវដ្តសង្សារលំបាកកៃ គប់តាលចង្រៃលំបាកលើស ។

១៦ - សុីធ្វើសង្ឃាមទើបនាមជាតិល្បី សុីចុះចាញ់ស្រីទើបក្តី
ស្លប់ស្លាត់ សុីប្រឹងធ្វើការទើបស្គាពរអ័ត្ត សុីប្រតិបត្តិទើបខ្ជាត់មន្ទិល ។
(សុីប្រឹងធ្វើការទើបស្គាពរអ័ត្ត សុីប្រតិបត្តិទើបខ្ជាត់មន្ទិល) ។
សុីកុងការរៀនទើបរបៀនចេះចប់ សុីកុំឲ្យស្លប់ទើបអប់សុីលៃ
សុីធ្វើល្អកាត់ទើបឋាត់ខូចខិល សុីខំកាន់សីលទើបក្រៃលាភឋាបាន)

(មានត)

ហ្វូងនិពន្ធមន្ត្រី ញ៉ុក - ថែម រៀបរៀង

(តមក)

លុះតមកក្នុងរាជ្យព្រះពុទ្ធសករាជ ៩៨៣ ត្រូវពួកហ៊ុនលុកលុយជណ្តើមយកដែនដីនៅខាងអឺរ៉ុបទៅ ហើយតមកទៀត ២៥ ឆ្នាំក៏ត្រូវសត្រូវជណ្តើមយកដែនកស្ទឹរៈទៅទៀត ហេតុដូច្នេះ តាំងអំពីពុទ្ធសករាជកន្លងមកជាង ១ ពាន់ឆ្នាំ អំណាចរបស់រាជវង្សយ៉ូអេដ៏ក៏មាននៅតឹមខែត្រដែនគន្ធារៈប៉ុណ្ណោះ ។

កាលអំណាចរបស់រាជវង្សយ៉ូអេដ៏សាប់សូន្យថយខ្សោយចុះទៅអាណាចក្រនៅខាងជើងកន្លែងត្រឡប់ជាមានសេចក្តីចំរើនរុងរឿងឡើងជាលំដាប់ ២ អាណាចក្រ គឺអាណាចក្រអន្ធ្រៈ នឹងសុរាស្ត្រ ។ ទីលួលខ្ពស់ដែលជាដែនដ៏របស់ជើងកន្លែងសុទ្ធនោះ គឺនៅជាច្រើនទេទៀតគេធាវ៉ែនឹងទេទៀតក៏ស្មា មានអាណាចក្រមួយតាំងខ្លួនឡើងបាន កាលពីពុទ្ធសករាជ ៣២៣ ហៅថាអន្ធ្រៈ អំពីដើមមកដែនដីចំណែកនេះធ្លាប់នៅជាចំណុះអាណាចក្រមគធៈ ដោយហេតុព្រះបាទពិម្ពុសារវាយយកបាន កាលពីពុទ្ធសករាជ ២៦៣ ដែលគួរនាំឲ្យសន្និដ្ឋានថាជាគ្រាដំបូង ដែលពួកអារ្យកៈបានលុកលុយចូលទៅក្នុងដែនដីជើងកន្លែង ។ ព្រះរាជឧរសរបស់ព្រះបាទពិម្ពុសារ គឺព្រះបាទអសោកមហារាជ ទ្រង់បានព្យាយាមផ្សាយព្រះពុទ្ធសាសនាចូល

មកកន្លងដែនដីនេះទាល់តែបាន ។ កាលព្រះបាទអសោកមហាពាជទិវង្គត់ ហើយ សិស្សក: ដែលព្រះបាទអសោកមហាពាជ ទ្រង់តាំងឲ្យជាអ្នកស្តីការពាជការនៅដែននេះ ក៏មិនព្រមចំណុះដែនមគធ:តទៅទៀតហើយ ប្រកាសតាំងជាឯករាជ្យឡើងតាំងជាអាណាចក្រអន្ធ្រ:នេះឡើង កាលពុទ្ធសករាជ ៣២៣ មានអាណាខែត្រតាំងអំពីភ្នំវិន្ធ្យៈទៅទិសខាងជើងរហូតចុះមកដល់ទន្លេកិស្នាទៅទិសខាងត្បូង, ដំបូងតាំងទីក្រុងនៅស្រុកអមរាវតី លើឆ្នេរទន្លេកិស្នាខាងត្រើម លុះកាលតមក ទើបផ្ទាស់មកតាំងនៅស្រុក ប្រតិធន:ប៊ុយប៉ៃធន: លើឆ្នេរទន្លេគោទាវរីខាងលើ ។ ឯរង្វែក្សត្រដែលគ្រប់គ្រងនៅស្រុកនេះហៅថា រង្វែសាតាការនិស ឬាន គ្រប់គ្រងនៅដែននេះជារវៀល ៤៥៦ ឆ្នាំ គឺតាំងអំពីពុទ្ធសករាជ ៣២៣ រហូតដល់ពុទ្ធសករាជ ៧៧៩ នៅវេលាដែលក្សត្រពាជរង្វែនេះគ្រប់គ្រងនោះ ការផ្សាយព្រះពុទ្ធសាសនានៅកន្លងដែនជិតក៏ន ដែលព្រះបាទអសោកឬានចាត់ផ្សាយមកហើយនោះ ក៏ឬានឆ្លើតទៅទៀតដោយប្រពៃ ទើបប្រទេសនេះមានព្រះសូបន្ទឹងអនុស្សាវរីយ៍ដែរជាសាសនាតេញ ។ នៅកន្លងសម័យនេះហើយដែលព្រះពុទ្ធសាសនាឬានមកប្រតិស្ឋាននៅនាសិក, សញ្ញើនឹងអមរាវតី ។ ទុកជាមានព្រះពុទ្ធសាសនាចំរើនដូច្នេះហើយក៏ដោយ ក៏នៅតែមានក្សត្រអង្គខ្លះកន្លងពាជរង្វែសាតាការនិសគោរព

ក៏បំអានសាសនាព្រាហ្មណ៍ក៏មាន មានអង្គខ្លះ កាន់សាសនាព្រាហ្មណ៍ផង ពុទ្ធសាសនាផង ប្រព្រឹត្តទៅតាមព្រះពាជនិយមក៏មាន ។

ព្រះចៅផែនដីអន្ធរៈតាំងឡាយនេះ មានគួរប្រណាំងប្រជែងដែលសំខាន់គឺព្រះចៅផែនដីសុភស្ត្រ ដែលជាពូជអម្បូរបស់ពួកដែលត្រូវពួកយួនដេញចេញមកពីខែត្រដែនសេអីស្ថានទឹងខែត្រសិន្ធ ក្នុងរវាងពុទ្ធសករាជ ៥០០ ទើបថយចុះទៅខាងឈូងសមុទ្រ កាលីវរ ទឹងខាងទីខំនាប គុជរដ្ឋ ដែលក្នុងសម័យបុរាណហៅថា សុភស្ត្រ ។ នៅតំបន់នេះមានកំពង់ដំនួញហៅថា មារីកាសា (វេលានេះហៅថាម៉ាកេជ) ដែលជាកំពង់សំខាន់មួយខាងផ្លូវដំនួញរបស់ក្រិក ។ មួយវិញទៀត ពួកនេះធ្លាប់នៅក្នុងស្រុកចំណុះរបស់ក្រិកខាងអ៊ីរ៉ានមកជាយូរ ទើបបានទទួលអារ្យធម៌របស់ក្រិកមកជាច្រើន ហេតុដូច្នេះ កាលបានតាំងឡាក់ហានខាងសុភស្ត្រហើយ ក៏ធ្វើឲ្យផ្លូវដំនួញរវាងឥណ្ឌានឹងក្រិក, រោមចំ-រើនឡើង ។ លុះតមកក្នុងរវាងពុទ្ធសករាជ ៦០០ ឆ្នាំ ទើបមានសង្គ្រាមរវាងដែនសុភស្ត្រ ទឹងដែនអន្ធរៈជាច្រើនដងច្រើនគ្រា ។ ដើមហេតុនេះសឹកសង្គ្រាមនេះ មកអំពីសាសនាច្រើនជាងរឿងដទៃទៀត តែក្នុងរវាងដែលធ្វើសង្គ្រាមនោះមិនមានរឿងរ៉ាវជាពិតប្រាកដថា តើខាងណាជាពួកពុទ្ធសាសនា ខាងណាជាពួកសាសនាព្រាហ្មណ៍ ។

សង្ក្រាមគ្រានោះ ជាន់ដើមបែកខាងអន្ទរៈមានៈច្រើន ។ ក្នុងពុទ្ធសករាជ ៦៦៩ ព្រះបាទគោតមីបុត្រ ក្សត្រចេសអន្ទរៈ ឆ្លើតតំព្រះបាទនហាបនៈ ក្សត្រសុភស្តេចញបាន ទើបទ្រង់ឃានដែនដីសុភស្តមកទុកក្នុងការគ្រប់គ្រងរបស់ព្រះអង្គ តែព្រះអង្គទ្រង់តាំងព្រះអង្គម្ចាស់ ១ អង្គទៅសុភស្តនោះឯងជាអ្នកគ្រប់គ្រងនគរតៗមក លុះដល់ពុទ្ធសករាជ ៦៨៤ មានក្សត្រគ្រងនគរសុភស្ត ១ អង្គតាំងក្សត្រវង្សហើយឃានបង្ក្រាបឈ្នះមហាក្សត្រអន្ទរៈ ឃានដែនដីមកបញ្ចូលចែមខ្លួនជាច្រើន ។ តាំងអំពីនោះមក អាណាចក្រអន្ទរៈក៏មានព្រំប្រទល់ដែនដល់ដីកព័ន្ធ ហើយគង់ទ្រង់រហូតមកដល់ពុទ្ធសករាជ ៧៧៤ ទើបត្រូវឆន ១ ពួកហោរាឃាលវៈ ទំលាយបំផ្លាញ ។ ឯពួកឃាលរៈនេះមិនមានគេដឹងឬសគល់ពិតប្រាកដទេ តែសន្និដ្ឋានថាជាពួកឃ្លាវធ្យ៍ ដែលឃានដើរតាត់ស្រុកអ៊ីន្ទចូលមកក្នុងតំណែ្ន កាលពីរាប់ពុទ្ធសករាជ ៧០០ ។ ចំណែកខាងពួកស្តេចគ្រងនគរដែលតាំងខ្លួនឡើងឃាន កាលពីពុទ្ធសករាជ ៦៨៥ នោះក៏តាំងឡាក់ឃាន ហើយមានអំណាចក្នុងដែនសុភស្ត ហើយលុកចូលមករហូតដល់ដែនសិន្ធនទឹងមាលវៈ រង្សក្សត្រដែលគ្រប់គ្រងនៅខែត្រដែននេះឃានគ្រប់គ្រងដែននេះរហូតដល់ពុទ្ធសករាជ ៨៥៣ ទើបត្រូវរង្សក្សត្រគុប្តៈផ្តួលរំលំទៅ ។

តាំងអំពីព្រះបាទអសោកសោយទិវង្គតទៅហើយរហូតមកដល់ពុទ្ធ-
សករាជ ៨០០ ឆ្នាំ ដែនដីនៅខាងទន្លេគង្គា ដែលធ្លាប់ជាទីប្រជុំនៃអារ្យ:
ធម៌របស់ឥណ្ឌៀមកអំពីដើមនោះ ក៏ទ្រុឌទ្រោមសាបសូន្យទៅជាច្រើនមិន
មានអំណាចប្តូរក្តីឈ្នះយ៉ាងណាទៀយ លុះមកដល់ព្រះពុទ្ធសករាជ
៨៣៣ ទើបត្រឡប់តាំងខ្លួនមាន កើតឈ្មោះល្បីល្បាញឡើងវិញ ដោយ
មានព្រះអង្គម្ចាស់ជាវង្សក្សត្រគ្រប់គ្រងក្រុងរាជគឹរមកអំពីដើម ១ អង្គ
ទ្រង់ព្រះនាមស្រីគុប្ត: ហ្មូនតាំងខ្លួនឡើងហើយលុបលាងអំណាចក្សត្រ
វង្សយួរអេដីអស់ទៅ លុះតមកដល់ពុទ្ធសករាជ ៨៥១ ទើបព្រះរាជន្តា
របស់ព្រះបាទស្រីគុប្ត:ព្រះនាមថា ព្រះបាទចន្ទ្រគុប្ត:ទី ១ ទ្រង់មានអំ-
ណាចពេញគ្រប់គ្រងខែត្រដែនបេង្គីល, រាជគឹរនឹងកោសល ហើយទ្រង់
តាំងទីក្រុងនៅស្រុកប៉ាដលីបុត្រ ។ ព្រះរាជនុរសរបស់ព្រះបាទចន្ទ្រគុប្ត:
ទី ១ ទ្រង់ព្រះនាមព្រះបាទសមុទ្រគុប្ត:ទ្រង់មានវិទ្ធិខ្លាំងពូកែ ទ្រង់លើក
កងទ័ពទៅច្បាំងខាងខែត្រដែនដ៏កកន ។ ក្សត្រតមក ១ អង្គទៀត ទ្រង់
ព្រះនាម ចន្ទ្រគុប្ត:ទី ២ ទ្រង់រាយប៉ាយដែនមាលវ:, គុជរដ្ឋនឹងសិន្ធុ ។
ហេតុដូច្នោះ មកដល់រាជ្ជពុទ្ធសករាជ ៨៥៣ អាណាខែត្ររបស់ពួកវង្ស
គុប្ត:ប៉ាន់តែធំឡើង តាំងអំពីទន្លេសិន្ធុរហូតដល់ទន្លេព្រហ្មបុត្រ និងអំពី
កំពូហិមាល័យរហូតដល់ទន្លេនាម៉ាដា ដែនមគធ:ក៏ត្រឡប់ប៉ាន់សេចក្តី
រុងរឿងឡើងវិញម្តងទៀត ។

រាជវង្សគុប្តៈនេះបានផ្ទាស់ទីក្រុងជាច្រើនគ្រា ជាន់ដំបូងទ្រង់តាំងទីក្រុងនៅឫាជលីបុត្រ តមកបានមកតាំងទីក្រុងនៅពាជគ្រឹះ តមកទៀតទៅតាំងនៅស្រុកកោសម្ពី ។ ស្រុកកោសម្ពីនេះជាកន្លែងសមគួរនឹងតាំងទីក្រុងគឺតំបន់ជាទីប្រជុំ កណ្តាលរវាងដែនសិន្ធុនឹងបេង្គលហើយជាសម្បាប់ត្រួតត្រាខែត្រដែនមាលវៈនឹងជិតកន្លែងបានដោយងាយស្រួលផង ។ តែពាជវង្សនេះនៅតែមិនទាន់ពេញព្រះទ័យ ទើបផ្ទាស់ទៅនៅក្រុងពារាណសី, ខ្ចែនី, ចេតិយ៍នឹងសញ្ចី ។ ឯពាជវង្សគុប្តៈនេះបានចំរើនរុងរឿងបំផុតក្នុងសម័យព្រះបាទកុមារគុប្តៈ (រវាង ៣. ស. ៩៩០) លុះមកដល់ ៣. ស. ១០២០ក៏ធ្លុះធ្លាយមកដោយហេតុពួកហ៊ូនលុកលុយចូល ។

ឯហានៈ របស់ព្រះពុទ្ធសាសនាកន្លងសម័យពាជវង្សគុប្តនោះ យើងបានដឹងរឿងពិតប្រាកដ ដោយអាស្រ័យសេចក្តីពាយការកត់ហេតុរបស់លោកសង្ឃចិន ១ អង្គឈ្មោះ ហ្វាហៀន ដែលបានចូលមកតណ្ឌកាលព័ពុទ្ធសករាជ ៩៤២ ដោយតាំងចិត្តស្វះស្វែងរកគម្ពីរព្រះពុទ្ធសាសនា សេចក្តីកត់ហេតុរបស់លោកនេះនាំឲ្យយើងបានដឹងថា ព្រះពុទ្ធសាសនាក្តី ស្រុកទេសដែលកាន់ព្រះពុទ្ធសាសនាហើយធ្លាប់ចំរើនរុងរឿងកាលពីសម័យពុទ្ធកាលក្តី បានធ្លុះធ្លាយទៅជាច្រើន ក្នុងរយៈវេលាជាង ៩០០ ឆ្នាំក្រោយព្រះពុទ្ធបរិនិព្វានមក ។ លោកហ្វាហៀននោះគេបានទទួលកាប់ចង្អាប់រុងរឿងកន្លងណ្តៀ ព្រះបាទចន្ទគុប្តៈទី ២

កំពុងគ្រប់គ្រងក្នុងវេលានោះ ឋានចាត់ឲ្យលោកឋានទៅមើលស្ថានទីផ្សែង ។ ដែលទាក់ទងនឹងពុទ្ធប្រវត្តិ ។ ក្នុងសេចក្តីពិភាក្សារបស់លោក និយាយថា ស្រុកទេសផ្សែង ។ ដែលចំរើនរុងរឿងក្នុងសម័យពុទ្ធកាលត្រូវធំលាយវិនាសអស់ជាច្រើន ក្នុងសារត្តីស្ទើរតែទៅជាព្រៃអស់ក្រែងតបិលពស្តក៏កាន់តែដុនដាបណាស់ទៅទៀត ស្រុកកុសិនារា ជាទីដែលព្រះពុទ្ធជាម្ចាស់បរិនិព្វាននោះក៏នៅមានសល់តិចតួចតែម ២-ញអង្គ ។ ឯក្រុងឋាជលីបុត្រ ដែលលោក ហ្វាហៀន ឋានឃើញពីមុនក្រុងដែលសេសសល់តែឋាក់បែក របស់ដែលសំខាន់គឺឋាសាទរបស់ព្រះឋាទអសោក ។ កាលលោកហ្វាហៀន ចេញអំពីក្រុងឋាជលីបុត្រហើយទើបទៅមើលក្រុងរាជគឹរហើយទៅដល់គយា ដែលជាទីមានព្រៃពឹក្សាដុះពាសពេញដូចគ្នាដែរ តែដើមមហាពោធិពឹក្សដែលព្រះអង្គឋានត្រាស់ដឹងនោះនៅគង់ត្រចះត្រចង់ល្អ លោកហ្វាហៀន ឋានត្រចៀកក្នុងឥណ្ឌាជាវេលា ១៤ ឆ្នាំ ហើយចុះឆ្លងទៅកោះលង្កា ត្រឡប់មកស្រុកចិនវិញ ក្នុងពុទ្ធសករាជ ៩៥៦ ។

តាមសេចក្តីពិភាក្សារបស់លោក ហ្វាហៀន ឃើញច្បាស់ថា ព្រះពុទ្ធសាសនាមិនមែនជាសាសនាសម្រាប់ស្រុកក្នុងរាជវង្សគុប្តៈនោះទេ តែមានអនុស្សាវរីយ៍ជាច្រើនឲ្យឃើញថា ព្រះពុទ្ធសាសនាមានសេចក្តីសំខាន់ច្រើនដែរ ទុកជារាជវង្សគុប្តៈមិនបានទំនុកបំរុង ក៏មិនបានរំលាយ

បំផ្លាញទេ លុះតមកឆ្នុតពាជវង្សគ្រុប្តៈហើយ ទើបពួកពុទ្ធសាសនិកជន
ត្រូវពួកហ៊ានប្រើអំណាចបៀតបៀនជាខ្លាំង ។

ហ៊ានចំពូកនេះហៅថា ហ៊ានស ជាពួកមានពូជខ្សែស្បែកជាតិ
ខូរគី ។ ជាន់ដំបូង បានតាំងទីលំនៅ ក្នុងដែនដីសកលជ្រៀនទំនឹងប្រាក់ត្រែន
ដែលពួកយូអេដ៏ធ្លាប់នៅមកមុន គាលបានតាំងឡាក់ហានមាំមួនក្នុងដែនដី
តាំងពីរអន្ទើនេះហើយ ក៏ចំពង្រីកអាណាខែត្រចេញទៅ រហូតដល់ដែន
ដីដែលពាជវង្សគ្រុប្តៈគ្រប់គ្រង ។ ក្នុងរវាងពុទ្ធសកពាជ ១០០៩ បាននាំគ្នា
ដើរតាត់ភ្នំហិណ្ឌូកូដ ទ្រង់ហូសចូលមកក្នុងដែនបុញ្ជាប ។ សម័យនោះ
ពាជវង្សគ្រុប្តៈមានព្រះរាជាធិរាជ ព្រះនាម សកន្ធគុប្តៈ ព្រះមហាក្សត្រអង្គ
នេះ ទ្រង់ចាំងបណ្តេញឲ្យពួកហ៊ានចេញទៅបានម្តងហើយ លុះដល់
ផុតពាជ្យព្រះបាទសកន្ធគុប្តៈហើយ ពួកហ៊ានក៏ត្រឡប់ចូលមកលុកលុយ
ទៀត ។ ហើយមិនត្រមថយចេញពីខែត្របុញ្ជាបឡើយ ។ ឯនាយក
របស់ពួកហ៊ាននេះហៅថា តូរ៉ាម៉ន បាននាំបក្ខពួកលុកលុយចូលទៅ
រហូតដល់ដែនម៉ាលវៈ ហើយដល់មកក្នុងពុទ្ធសកពាជ ១០៣៨ បាន
ជណ្តើមយកពាជសម្បត្តិរបស់ព្រះមហាក្សត្រពាជវង្សគុប្តៈ ព្រះនាមពាណ
ទិត្យៈទៅបាន ។

សព្ទានុក្រមកំនែប្រែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

ហ្វ្រង់ស័ពន្ធមន្ត្រី ញ៉ូក-យ៉ក រួបរួម

(ភាគ៣)

Chapitre = វគ្គ

Capitale = ក្រុងធំ, រាជធានី

Langue officielle = ភាសាដែលប្រើជាផ្លូវការ

La loi est l'expression de la volonté nationale = ច្បាប់ជាសេចក្តីសំដែងឆន្ទៈរបស់ប្រជាជាតិ

La liberté = សេរីភាព

Décision motivée = ដីកាសំដែងហេតុផល

Ressource = ធនធាន

Message = ព្រះរាជសារ, សារលិខិត

Grades civils = បណ្តាសំក្តិ

Immunité = អភ័យឯកសិទ្ធិ

Janvier = មករា

Février = កុម្ភៈ

Mars = មីនា

Avril = មេសា

Mai = ឧសភា

Juin = មិថុនា

Juillet = កក្កដា

Août = សីហា

Septembre = កញ្ញា

Octobre = តុលា

Novembre = វិច្ឆិកា

Décembre = ធ្នូ

Conseil du Royaume = ក្រុមប្រឹក្សាព្រះរាជអាណាចក្រ

Conseil d'état = ក្រុមប្រឹក្សានៃរដ្ឋ

Conseil de la Famille Royale = ក្រុមសង្គហៈព្រះរាជវង្សានុវង្ស

Conseil de la magistrature = ក្រុមប្រឹក្សាតុលាការ

Haute Cour de Justice = សភាតុលាការជាន់ខ្ពស់

Elire = ជ្រើសតាំង

Nommer = តែងតាំង

Désigner = ចាត់តាំង

Ministère = ក្រសួងរដ្ឋមន្ត្រី

ពាក្យខាងលើនេះ គណៈកម្មការបានពិភាក្សានៅថ្ងៃព្រហស្បតិ៍ ២-១-៤៧

Secrétariat d'Etat = រដ្ឋលេខាធិការដ្ឋាន

Service = ក្រុម

Directeur de Service = នាយក្រុម

Chef de Serdice = នាយក្រុម

Chef de Cabinet = នាយការិយាល័យ

Chef de Bureaux = នាយប៊ុយរ៉ូ

Directeur des Bureaux = នាយកប៊ុយរ៉ូ

Directeur de Cabinet = នាយកការិយាល័យ

Chef de Section = នាយផ្នែក

Statut = លក្ខន្តិកៈ

Vertu = គុណធម៌

Sur la proposition de = ដោយសេចក្តីណែនាំ

(គណៈកម្មការបានពិភាក្សានៅថ្ងៃច័ន្ទ ៦-១-៤៧)

Charte = បទបញ្ញត្តិ ធម្មនុញ្ញ

O. N. U. = អង្គការសហប្រជាជាតិ

Commissaire du Gouvernement = ស្នងការ

Traité = សន្ធិសញ្ញា

Convention = អនុសញ្ញា

Accord = កិច្ចព្រមព្រៀង

Arrangement = សេចក្តីព្រមព្រៀង

Pacte = កតិកាសញ្ញា

Protocole = ពិធីការ, ពិធីសារ

Pseudonyme = ឈ្មោះសន្យានាម

(ដូច- ១-ដូច)

Homonyme = សទិសនាម

Synonyme = វេរចនានាម

Vacance = វិស្រមកាល

Journal Quotidien = កាសែតពាយថ្ងៃ

Journal hebdomadaire = កាសែតពាយសប្តាហ:

Périodique = កាលិកបត្រ

Théorie = ទ្រឹស្តី

Pratique = វិធីប្រតិបត្តិ

En principe = តាមគោលការ

Paronyme = ឈ្មោះទិសនាម

(៣ - ២ - ៤៧)

Matériellement = ដោយផ្នែកកាយ

Intellectuellement = ដោយផ្នែកប្រាជ្ញា

Spirituellement = ដោយផ្នែកចិត្ត

Moralement = ដោយសីលធម៌

Volonté = ឆន្ទៈ

Donner procuration = ប្រគល់អាសា

Volontairement = ដោយស្ម័គ្រចិត្ត, ដោយចេតនា

A la lettre = តាមព្យញ្ជនៈ

Dans l'esprit = តាមចេតនារម្មណ៍, តាមអត្ថ, តាមបំណង

Orthographe des mots = អក្ខរាវិរុទ្ធនៃពាក្យ

Donner le mandat = ឲ្យអាណត្តិ

(១៧ - ៤ - ៤៧

Sous-entendu = សន្និដ្ឋានវចនៈ

Présidence du Conseil des ministres = ទីស្តីការនាយករដ្ឋមន្ត្រី

Demander des conseils = សុំសេចក្តីប្រឹក្សា

Donner des conseils = ឲ្យសេចក្តីយល់

Explicitement = ដោយនិប្បរិយាយ

Implicitement = ដោយបរិយាយ

Démagogie = ប្រជាតិថុតិ(ការបះញ្ជាវាស្ត្

Douane = គយ

Régie = រដ្ឋាភរ ឬអាភរ

(៦៤ - ២ - ៤៧)

Geste = អាកប្បកិរិយា

Fanatiste = អធិមុត្តក៏

Fanatisme = អធិមុត្តិ

Moyen = ដោយផ្លូវ១ប្បាយ,មធ្យោប្បាយ

Comportement = អាចារ:

Tempérament = ចរិត, និស្ស័យ

Caractère = ចរិត,-

Programme = កម្មវិធី, ត្រាងការ

Tourisme = ទេសចរ

Gouvernement de Sa Majesté = ព្រះរាជរដ្ឋាភិបាល

Caractère gai = ចរិតរីករាយ

Caractère politique = មានលក្ខណ:ជានយោបាយ

Martyr = ទុក្ករបុគ្គល

Martyriser = ស៊ូស្បាប់

(៣-៣-៤៧)

Sentiment = មនោសញ្ចេតនា-

Etat associé = សម្ពាគតរដ្ឋ

Conférence = ដំនុំការ, សន្និសិទ្ធិ

Sensation = វេទនារម្មណ៍

Décision = សម្រេច

Guérilla = ទ័ពព្រៃ

Egoïsme = អត្តទដ្ឋភាព

Altruisme = បរទដ្ឋភាព

Microbe = សុខុមជ្ញាណ

Microscope = សុខុមទស្សន៍

(១០-៣-៤៧

Matériel = សម្ភារៈ

Prestige = កិត្យានុភាព

Dynamisme = ពលភាព, ថាមភាព

(មានត)

រឿងសាមកុក

លោកទេកញ្ញា ខូរ - កន រៀបរៀង

(ពមក)

ទើបតាំងតុឲ្យអញ្ជើញហាងដូរហៀបឡើងគង់លើរតនបល្ល័ង្ក ក្រែមព្រះមហាស្វេតច្ឆត្រ ជួបជុំពាជបរិសទ្យសេវាកាមាតុមុខន្ត្រីសេដ្ឋគហបតីពាជបរិក្ខារ សឹងតែក្រាបថ្វាយបង្គំពាល់គ្នាជា ។ ឮរាកគឹកកង្ខក្នុងទីព្រះពាជពេងរម្យ ស្រែចហើយឲ្យយកហាងដូរទៀនទឹងព្រះនាងហោហៅជាមាតា ព្រមទាំងនាងស្នំក្មេងហាងដូរទៀន ទៅបង្ខាំងទុកក្នុងទីព្រះតំណាក់ចាក់សោមិនឲ្យចេញទៅណាបាន ហាមប្រាមពួកនាហ្មឺនឱ្យពាជការមិនឲ្យនរណាទៅមកសួរនាំសោះ រៀលនោះនាហ្មឺនមុខន្ត្រីនូវអស់អាណាប្រជានុពស្តុងាសកវបណ្តាដែលមានទាំងប៉ុន្មាន សឹងមានសេចក្តីសៅសោកអាណិតអាណាតនៃហាងដូរទៀនទឹងព្រះនាងហោហៅពន់ពេកណាស់ កាលដែលតាំងតុ តាំងហាងដូរហៀបឲ្យឡើងសោយរាជសម្បត្តិនោះព្រះជន្មវស្សាបាន ៩ ឆ្នាំគត់ (ព. ស. ៧៣៣) ថ្វាយព្រះនាមហៅថាព្រះហៅហៀនតេ ។

ចំណែកតាំងតុក៏តាំងខ្លួនជា "សាងកុក" កាសាខ្មែរហៅថាស្តេចមហាឧបរាជអាចគាន់ព្រះសែងគ្រប់ចូលគាល់ពាល់រៀលបានតាមចិត្តប្រាថ្នាទឹងចេញចូលបានជាប ឯអាជ្ញាសិទ្ធិវិន្ធានុភាពនៃតាំងតុនោះក៏កាន់តែ

កំរែបក្សាហានមានឧឡឹងជាងពីដើម បណ្តាសេនាគាហានទឹងបក្ខពួកតាំង
ប៉ុន្មាន ក៏សឹងតែឆ្លើកាអាក្រក់ដើរតក់ជណ្តើមុខព្យាបស់អស់អាណា-
ប្រជានុរស្តុបានសេចក្តីក្តៅក្រហាយណាស់ ។

ឯចោនោក៏ប្រាន់ចូលទៅធ្វើខ្លួន ឲ្យតាំងតុះប្រើប្រាស់ក្នុងកិច្ចការ
លើយូធាទីប្រឹក្សាក៏ប្រាន់និយាយនឹងតាំងតុះថា សព្វថ្ងៃនេះរាជការផែន
ដីតាំងមូលក៏ចូលមកនៅក្នុងកណ្តាប់ដៃនៃលោកតាំងអស់ហើយ សុំកុំឲ្យ
លោកសំដែងអំណាចឲ្យនាហ៊ុននឹងរាស្តុបានសេចក្តីស្អប់ខ្ពាញ់ ចូរ
លោកធ្វើយបន្ទន់ចិត្តអាណិតស្រឡាញ់អាណាប្រជានុរស្តុ ឲ្យបាននៅ
ជាសុខក្សេមក្សាន្ត លោកក៏នឹងបានចំរើនទូវតស្សរិយយសខ្ពស់ធំឡើង
ទៀត ។ ប្រការមួយទៀតមានមនុស្សម្នាក់នៅខែត្រក្រៅឈ្មោះ សួយ៉ឹង
មានសតិបញ្ញាស្ទាត់ណាស់ សុំឲ្យលោកយកខ្លួនស៊ួយ៉ឹងនោះមកធំនុកបំរុង
តាំងឲ្យមានយសសក្តិជានាហ៊ុនក្នុងក្រុង លោកក៏នឹងមានកម្លាំងធ្វើការ
រាជការចំរើនឡើងទៀត តាំងតុះយល់ព្រមក៏ប្រើបំរើឲ្យទៅហៅសួយ៉ឹងៗធ្វើ
ព្រងើយកន្តើយមិនបានចូលមក តាំងតុះក៏ចាត់បំរើឲ្យទៅហៅម្តងទៀត
ហើយឲ្យថ្លែងប្រាប់ថាបើសួយ៉ឹងរឹងទទឹងមិនចូលមកទេ នឹងឲ្យគាហានទៅចាប់
សម្លាប់ចេញឲ្យអស់ទាំងគ្រួ ។ សួយ៉ឹងបានឮខ្លាចមិនអាចនឹងនៅបាន
ក៏រៀបខ្លួនថ្លែងណាចូលមកដល់តាំងតុះ ។ ក៏តាំងសួយ៉ឹងបានឡើងធ្វើជាមន្ត្រី
មានយសស័ក្តិ តាំងតុះទុកចិត្តដឿយកជាទីប្រឹក្សាការរាជការទាំងពួង ។

ឯហាន់ជូតៀនទើន ព្រះខាន់ហោហៅហៅខ្ញុំវត្តព្រះស្តេចដែលតាំងតុឲ្យឃុំ
ខ្ញុំនុកនោះ កំមានសេចក្តីវេទនាសោកាហាន់ខ្ញុំនោះស្តាំងស្តមទ្រមដោយ
ទុក្ខខ្លាំងណាស់ ថៃមួយមានសត្វសារិការហើរចូលមកកន្លងតំណាក់តាំងគូ
ហាន់ជូតៀនទតឃើញកំចងជាឃ្មោង ព្រះនុកនោះជញ្ជាំងប្រែបបង្ហូច
តំណាក់មានសេចក្តីថា:

ទុតិយជាតិវិមានស្មាត គឺ ចុំ ចុំ សាទមហាក្សត្រា
ព្រះបរមនេតជាបិតា ករុណា ចុំ សុំ ណា ប្រទានឲ្យ ។
យើងជាពាជបុត្រកុមារ គ្រប់ គ្រងរដ្ឋាតទៅក្រោយ
តទ្បែរយើងមកសោកសុបសោយ ព្រមដោយ ព្រះវរាជមាតា ។
ព្រោះគេតាំងឃាត់បំបាក់មុខ ឆ្នើរភោសជាក់តុកកន្លង ចុំ ចុំ-
សាទសមជូបសត្វសេកសារិកា ខ្ញុំបង្ហាកន្លងស្តីវិញ្ញាណ ។
ទុតិយកាជការនាហ្នឹនមុខ តតិយភាគយើងមែនមាន
បិត្តសត្យសុបវិតគួរគិតធ្យាន ជួយយើងឲ្យបានរួចទុក្ខា ។
ដ្បិតកន្លងយើងជូបភ្លើងនេះ ឈឺលឈឺតុំប្រែព្រួតធ្យូងផ្សា
បើបានសង្ឃឹកស្រែចកាលណា យើងមហាអាគុណជួនរំនេក ។

ចំណែកតាំងតុតែងប្រើបំរើទៅស៊ើបស្តាប់ការទៅទី ព្រះតំណាក់
ដែលបង្ខាំងហាន់ជូតៀនទោះជារឿយ។ ដើម្បីឲ្យដឹងថាតំនិតហាន់ជូតៀន
ទោះនឹងគិតដូចម្តេចខ្លះ ។ លុះបំរើទៅលបមើលឃើញពាក្យឃ្មោងចងទៅ

បង្អួច កំលួចស្រាយយកទៅបង្ហាញតាំងតុ។ ឃានមើលដឹងសេចក្តីក៏ខឹងណាស់ថា ហាងដូរឿនធ្វើពាក្យឃ្លោងទុកនេះគ្រាន់ថាឆ្លងដឹងចង់រកមនុស្សខំនុកទុកចិត្តមកធ្វើសងសឹកយើងវិញ ឥឡូវប៉ុយើងនឹងសម្លាប់ចេញ ក៏មិនមានអ្នកឯណានឹងតវាហានិន្ទាថាយើងអាក្រក់ គិតហើយតាំងតុក៏បង្គាប់លីយូឲ្យនាំពេជ្ឈឃាជ ១០ នាក់ទៅសម្លាប់ហាងដូរឿននឹងព្រះនាងហោហៅនូវពួកព្រះស្នំទាំងអស់ចេញ លីយូនោះមិញ ក៏ទទួលបង្គាប់នាំពេជ្ឈឃាជទាំង ១០ នាក់ទៅបើកទ្វារតំណាក់ហើយចូលទៅ ពួកស្នំក្រឡេកឃើញ ក៏ចូលទៅទូលហាងដូរឿន។ ក៏ស្តុតព្រះទ័យភ័យណាស់ លីយូចូលទៅដល់ ក៏ឈរហុចពែងស្រាជាក់ថ្នាំពុលឲ្យហាងដូរឿនសោយ ហាងដូរឿនសួរថាអ្វី? លីយូតបថា មហាឧបរាជយល់ឃើញថា ឥឡូវនេះ ស្រុកទេសជាសុខរាបទាបហើយ ទើបឲ្យទូលព្រះបង្កើយកស្រានេះមកថ្វាយឲ្យទ្រង់សោយ ។

ព្រះនាងហោហៅបានឮដូច្នោះ ក៏ងឿងឆ្ងល់ក្នុងព្រះទ័យណាស់ ទើបត្រាស់សួរទៅថា តាំងតុឲ្យយកស្រាមកថ្វាយព្រះពជបុត្រយើងសោយនោះ យើងក៏មានសេចក្តីត្រេកអរនឹងគុណលោកណាស់ តែថាត្រូវខ្លួនអ្នកដែលកាន់ស្រាមកនោះ ផឹកមុនឲ្យយើងឃើញសិន សឹមយើងឲ្យព្រះពជបុត្រយើងសោយខាងក្រោយ លីយូឮពាក្យដូច្នោះក៏ខឹងណាស់ រួសរហៀតពេជ្ឈឃាជ ឲ្យយកគ្រឿងនឹងសោចរាក់មកបោះទម្លាក់ទុកចំ-

ពោះមុខហើយថា មហាទេវកាដឲ្យយកស្រាមកថ្វាយឲ្យសោយ បើព្រះនាងហោហៅនឹងទទឹងមិនព្រមឲ្យសោយទេ ត្រូវទទួលយកវបស់ ២ នេះវិញនឹងយកច្រវាក់ឬគ្រឿប៉ី បណ្តាពួកស្រីស្នំក៏ប្រណម្យដៃលុតជង្គង់ចុះទាំងអស់គ្នាហើយនិយាយនឹងលីយូថា លោកនឹងឲ្យហាងដូពៀនសោយស្រានោះ យើងខ្ញុំទាំងអស់គ្នាទទួលផឹកចំនួសចុះ យើងខ្ញុំសូមតែជីវិតព្រះនាងហោហៅនឹងហាងដូពៀនឲ្យគង់ព្រះជន្មតទៅ លីយូស្រែកគំហកថាមិនគួរឯងកាលគ្នានឹងមកទទួលស្ងាប់ដូសនោះទេ ហើយលីយូក៏យកពែងស្រាហុចឲ្យ ព្រះនាងហោហៅផឹកមុនព្រះនាងមិនព្រមទទួលសោយសោះ ក៏មានបន្ទូលទៅគោរំលើកថា ព្រោះតែអាហូជិនជាបងអញ្ជើញពេញជាមនុស្សគ្រិតខ្វល់ នាំយកពួកអាចារខ្ចីយសចូលមកក្នុងព្រះពុទ្ធហានអន្តរាយទើបមានដល់ខ្លួនអញនឹងព្រះពុទ្ធបុត្រក្នុងគ្រានេះ ។

សាមកុកកវគ្គ ទី ៤

តាំងពីលីយូធ្វើគតព្រះបាទហាងដូពៀន នឹងព្រះនាងហោហៅ ក្លាវស្រីព្រះស្នំដោយច្បាប់ចំពុលណាយនឹងស្រា ។ លុះដល់អ្នកសៀវដាមេទ័ព ប្រែគូរ អ៊ូ ទៅច្បាំងនឹង ហ្គូ ឃុំង ។

ឯលីយូនៅឈរតឿនព្រះបាទហាងដូពៀនថា ទ្រង់នឹងយកគ្រឿប៉ី ឬច្រវាក់ ក៏ត្រូវយកឲ្យធាប់ប្រញាប់ទៅ ។ ព្រះបាទហាងដូពៀនធ្វើយថា ខ្លួនយើងនឹងព្រះវរមាតាត្រូវស្ងាប់ជាមួយគ្នាក្នុងថ្ងៃនេះ យើងក៏បានដឹងច្បាស់លាស់ណាស់ហើយ ប៉ុន្តែសុំបង្អង់ឲ្យយើងទូលលាព្រះវរមាតា

យើងសិនចុះ ខ្ញុំមានបន្ទូលតែប៉ុណ្ណោះក៏ខ្ញុំចូលទៅនមស្ការព្រះចុលាតាព្រះ-
វរម៉ាតា ហើយក៏ខ្ញុំព្រះកន្ទែងថ្វែងពាលាបសោកាតាំង ២ ព្រះអង្គនៅ
ក្នុងព្រះតំណាក់មុខគួរឲ្យអនិច្ចា ។ លុយវែសែកថា ដែលនឹងសៀម
ព្រនើយនៅដូច្នេះគ្មាននរណានឹងជួយឲ្យរួចដំរិតទេ បើឆ្លៀតផ្តាំគ្នាយ៉ាងណា
ឲ្យផ្តាំឆាប់ ។ ទៅ មហាឧបរាជនៅចាំយើងឯណោះព្រះនាងហោហៅ
ទ្រើយថា អាតាំងតុវជាមេចោរក្បត់ផែនដី ដែលវាឲ្យធ្វើអន្តរាយយើង
ក្នុងថ្ងៃនេះ ខ្មោចបីខ្លួនអញម្តាយនឹងកូនដល់ទូរសេចក្តីស្លាប់ចំពោះមុខទេវ-
តានឹងមនុស្ស ក៏អញមិនមែនកោតសរសើរវាដែរ តាំងអាលីយូសោត
ក៏វាជាពួកក្បត់ដូចគ្នា វាក៏មិនមានសេចក្តីចំរើនប៉ុន្មាន យូរទៅគង់មានគេ
សម្ងាប់វាវិញជាច្បាកដ ។ លុយបានឮដូច្នោះ ក៏ឈឺចិត្តណាស់ សុះទៅ
អូសកន្ត្រាក់ព្រះនាងហោហៅដៃម្ខាង ។ ទៀតហូតកន្ត្រាក់នាងស្មំតាញទៅ
ក្រៅផ្ទា ហើយឲ្យគេផ្សាយដចង់រឹតព្រះនាងហោហៅទូវស្រីព្រះស្មំ
តាលតែស្លាប់ហើយលុយក៏ត្រឡប់ចូលទៅចាប់ព្រះចុទហង់ផ្ទៀនទៀត
ហើយចាប់បង្ក្រាបចូលទៅក្នុងបំពង់ក ក៏ខ្ញុំទីវង្គតក្នុងទីនោះ ។ ស្រែច
ហើយទើបលីយូបង្គាប់ឲ្យនាំព្រះសពនោះ ទៅកប់ចោលក្រៅក្រុងទាំង
អស់ លីយូក៏លែងត្រឡប់មកដំរាបតាំងតុ ។ មានសេចក្តីត្រែកអរណាស់ក្នុង
ខណៈនោះ តាំងតុមានសេចក្តីកំរើបចិត្តគិតធ្វើការអាក្រក់ផ្សេង ។ មិនមាន
ល្អែងក្រែងខ្លាចអំណាចអ្នកឯណា ចួនកាលពេលយប់ ក៏ចូលទៅដេក

លើព្រះខែនដែលព្រះចៅឡេនតេខែនដ៏ធ្ងំ ហើយលបលួចព្រះស្ងំស្រីផ្កា រួមវេណីជាទីត្រេកត្រអាល ។

. អំណើះតមកតាំងតុ កំលើកព្យូហទំពាចេញទៅស្រុកយ៉ុងសៀ ហើយឲ្យគាហានព័ទ្ធកំផែង ចូលទៅក្នុងស្រុករដែលយកបានយកបរស់ទ្រព្យ ហើយសម្ងាប់ម្ងាស់ផ្ទះប្រុស ។ ចេញជាច្រើន ចាប់យកស្រីមកទុកជាឈ្មួយ ហើយឲ្យគាត់យកក្បាលមនុស្សស្លាប់នោះផ្ទុកដីកនឹងរនេះត្រឡប់ចូលមកទីក្រុង ហើយឲ្យស្រែកអាក្រៃសតាមផ្លូវថា យើងលើកទ័ពទៅចាប់ពួកអាចោរកំណាចបាន គាត់ក្បាលយកមកជាច្រើនណាស់ លុះឆ្លើដូច្នេះហើយក៏ឲ្យយកទៅគរដុតចោលទាំងអស់ ឯទ្រព្យរបស់ដែលរបយកបានមក ហើយនឹងស្រី ។ នោះក៏ចែករំលែកគ្នាជាសម្រាប់គាហានទាំងពួង ។

ឯផ៉ាហ៊ីងាទ័មន្ត្រីធំ លុះឃើញតាំងតុប្រព្រឹត្តសេចក្តីរាក្រក់ខ្លាំង ក៏តាំងតែមានចិត្តនោះក្តួលក្តៅណាស់ គិតនឹងសម្ងាប់តាំងតុមិនលោះ ១ វេលា លុះកន្លងមកថ្ងៃ ១ នោះ ផ៉ាហ៊ីយកកាំបិតសៀតបង្កប់កន្ងែអាវ ហើយចូលទៅគាន់ទីគាល់ ខណួលពេលនោះតាំងតុចេញមកដល់ទ្វារពាំង ផ៉ាហ៊ី ដកកាំបិតបង្កប់ចេញនឹងចាក់តាំងតុ ។ ក្រឡែកទៅឃើញគាន់ការពារបាន លីហ៊ូ ក៏ស្ទុះចូលទៅជួយចាប់ផ៉ាហ៊ីដាប់ហើយថា ហេតុម្តេចទើបខ្លួនមកគិតធ្វើគំនិតអាក្រក់ ចាក់មហាឧបរាជាជាបិតាយើងដូច្នេះ ផ៉ាហ៊ី

មិនខ្វាចសេចក្តីស្លាប់ច្រាប់ថា តាំងតុធ្វើការអាក្រក់ណាស់. អញមាន
បំណងនឹងកាត់យកក្បាលផ្តាលឲ្យទេវតានឹងមនុស្សយើញជាក់ច្បាស់ក្នុង
លោកិយ តាំងតុបានឮសំដីក៏តតែចិត្តពន់ប្រមាណ បានបង្គាប់ពេជ្ជ-
ឃាដឲ្យនាំខ្លួនដៅហ៊ូទៅអារពន្លះសាច់ឆ្កេចជីវិត ពេជ្ជឃាដក៏ស្ទុះចូល
ចាប់យកខ្លួន ដៅហ៊ូ។ មិនមានតក់ស្លុតរំដួលខ្លាច ស្រែកដេរតាំងតុថាល់
តែពេជ្ជឃាដកាប់ដាច់ខ្យល់ស្លាប់ តាំងពីនោះមកតាំងតុឲ្យថាហានវេន
រក្សាព្រះបរមកជកាំងយ៉ាងមាំមួនជាងពីដើម ។

ឯអ្នកសៀវដែលជាទីចៅហ្វាយស្រុក ពុតលៃ បានល្បីឮកិត្តិសព្ទ
ថា តាំងតុធ្វើការអាក្រក់សម្លាប់ព្រះនាងហោហៅ នូវព្រះបាទហាងជូពៀន
ជាម្ចាស់ផែនដីក្រុយព្រះជន្មដូច្នោះ ក៏តែងសំបុត្រជាសំងាត់ទៅដល់អង្គអ្នក
ដែលជានាហ្មឺននៅក្នុងក្រែង ក្នុងសេចក្តីសំបុត្រនោះថា "សព្វថ្ងៃនេះតាំងតុ
កំរើបចិត្តគិតការក្បត់ផែនដី ទឹងរកនាហ្មឺនមុខមន្ត្រីណាមានច្បាស់ធ្វើ
ឆ្នាតគិតសង្ឃឹតរំលាងបំផ្លាញ តាំងតុ ចេញគ្មាន ដែលយើងចេញទៅនៅ
ខែត្រក្រៅគ្រានេះ ទឹងបានដេកឆ្កេចមិនគិតក៏ដេ គឺ១៤ស្បាហ៍បញ្ជុះ
បញ្ចូលសេនាទាហាន ទឹងប្រែនបង្គាប់ឲ្យស្ងួញស្ងាត់ក្នុងការសង្ក្រាមមិន
លោះមួយវេលា ព្រោះជារសេចក្តីកតញ្ញូទឹងផែនដី ដើម្បីយកអាសាកំចាត់
តាំងតុជាសត្រូវពាជសម្បត្តិនោះចេញ បើអ្នកណាយល់ត្រូវតាមគំនឹតចិត្ត
យើងហើយ កុំគប្បីព្រងើយកន្តើយគិតការខាងក្នុងឲ្យមាំមួនចុះ យើងនឹង
លើកកងទ័ពចូលមកធ្វើការឲ្យបានសម្រេចដោយងាយ ។

អង្គអ៊ុនបានយល់ក្នុងសេចក្តីសំបុត្រនោះគ្រប់ប្រការ កំមានសេចក្តីវិតក្កវិចារៈមិនមានក្តេចសោះ លុះកន្លងមកថ្ងៃមួយជាពេលចេញចាកទីគាល់ អង្គអ៊ុនក៏រង់ចាំនិយាយនឹងនាហ្មឺនចាស់ទុំតាំងពួងថា ថ្ងៃនេះត្រូវការនឹងអញ្ជើញអស់លោកទៅពិសាក្រយានៅឯផ្ទះខ្ញុំ ជាកំសាន្តសប្បាយបណ្តានាហ្មឺនតាំងឡាយក៏ស្រុះស្រួលបបួលគ្នាទៅស៊ីលៀងលើផ្ទះអង្គអ៊ុន កាលដែលប្រជុំព្រមគ្នានឹងបរិភោគអាហារនោះ អង្គអ៊ុនក៏អង្គុយយំជាទុក្ខខ្លឹកខ្លួល នាហ្មឺនតាំងពួងក៏ឆ្ពើលឆ្ពៃលទៅសួរថាលោកយុំសោកជាទុក្ខព្រោះអ្វី? អង្គអ៊ុនឆ្លើយថា តាំងតុចូលមកនៅក្នុងស្រុកក្រងធ្វើការទុច្ចរិតសម្លាប់ព្រះនាងហោហៅ នូវព្រះបាទហង់ដុះពឿនក្សត្រយ៍ព្រះជន្ម ខ្ញុំមានសេចក្តីក្តៅចិត្តណាស់ ឧបមាដូចជាដេកលើគំនរក្តៅ ខ្ញុំសំឡឹងទៅមិនឃើញអ្នកឯណា ទើងដួយគិតចំទុកបំរុងឆែនដើម្បីបានសេចក្តីសុខសោះ ខ្ញុំគិតឃើញដូច្នោះទើបយុំជាទុក្ខ នាហ្មឺនតាំងពួងបានស្តាប់ ក៏មានសេចក្តីសង្វេគស្រក់ទឹកភ្នែកយំសោកតាំងអស់គ្នា ។

មានតែ ចោធោ ម្នាក់គ្រាកឡើងឈរទៃដៃសើច ហើយថាចោលម្បៀតអស់លោកនាហ្មឺនចាស់ទុំប្រជុំ គិតការប៉ុណ្ណោះមិនធ្ងន់ធ្ងាយហើយមកបបួលគ្នាអង្គុយយុំ ។ អង្គអ៊ុនឮដំណាស់និយាយតបទៅចោធោថាដីតានឹងបិតារបស់អ្នកឯងក៏ជានាហ្មឺនបានស៊ីច្រាក់បៀវត្សមកពីដើមដែរ ម្តេចអ្នកឯងមិនមានគតញ្ញូនឹងផែនដី យើងគិតការនឹងបំផ្លាញរំលាងតាំងតុ

ចេញ តែថាតាំងតុមានសេនាខាហានខ្លាំងពូកែច្រើនណាស់ យើងដំរះមិនធ្លុះឆ្លាយទើបឈឺចិត្តអង្វយយុំដូច្នេះ ហេតុអ្វីអ្នកឯងមកក្លែងខ្លះដៃសើចបំអកឲ្យកេីងដូច្នេះ? ចោរនោ ឆ្លើយថា អស់លោកចាស់ទុំសុទ្ធតែជានាហ្នឹតមកពីដែនដីមុនមានចិត្តគិតនឹងខំនុកបំរុងដែនដីជាប្រាកដ ហេតុម្តេចក៏គិតនឹងកំចាត់តាំងតុប៉ុណ្ណោះមិនបាន នាំគ្នាអង្វយយុំខ្ញុំយើញដូច្នេះបានជាអស់សំណើច ឯដីតាំងបិតារបស់ខ្ញុំជាខ្ញុំរាជការមកពីដើមនោះ ខ្ញុំក៏គិតកត្ញាដល់ដែនដីជាជរាប ប៉ុន្តែតាំងតុនោះបើខ្ញុំនឹងគិតសម្លាប់ចេញវេលាណាក៏បាន ។

អង់អ៊ុនថា អ្នកឯងនិយាយដូច្នេះ យើងមិនទាន់យល់ឃើញផងទេដែលនឹងគិតសម្លាប់តាំងតុនោះ ត្រូវគិតយ៉ាងម្តេចចូរអធិប្បាយឲ្យយើងស្តាប់សិនមើល ។ ចោរនោឆ្លើយតបថា ខ្ញុំត្រូវធ្វើសេចក្តីព្យាយាម ចូលទៅផ្ញើខ្លួនឲ្យតាំងតុប្រើប្រាស់ទាល់តែស្និទ្ធទុកចិត្តប្រាកដ មិនមែនឃើញដោយលាកសក្ការៈអ្វីៗ ព្រោះគិតកត្ញាដល់ដែនដីប្រាថ្នានឹងសម្លាប់តាំងតុឲ្យបាន តែថានៅខាស់ព្រោះគ្មានអាវុធកាន់កំដរដៃ ខ្ញុំដឹងថាគ្រប់ខ្លួនរបស់លោកមាន់ បើលោកឲ្យខានគ្រប់នោះមកខ្ញុំ ខ្ញុំនឹងសៀតបង្កប់ជាប់នឹងខ្លួនចូលទៅដល់តាំងតុ ហើយនឹងសម្លាប់កាត់យកក្បាលមកជូនលោកឥឡូវនេះ អង់អ៊ុនបានស្តាប់ដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់ ទើបក្រោកឡើងលុតជង្គង់គំនាប់ចោរនោហើយចាក់ស្រាឲ្យចោរនោផឹក ។ (ម.ខ៣)

រឿងកោកកុលកុមារ

អ្នកឧកញ៉ាព្រះឃ្លាំង នង រៀបរៀង

(តមក)

ខ្ញុំមើលស្គាល់ជាក់ ចិញ្ចៀនដែលពាក់ ពិតពុំសង្ស័យ ទើបខ្ញុំចរចូល
មកទូលក្សត្រថ្ងៃ ឲ្យជ្រាបព្រះទ័យ តាមតែមេត្តា ។ ស្តេចស្តាប់ទំនូល
រាជបុត្រីទូល ពីព្រះសុណិសា មកដល់ស្រះស្រង់ ស្តេចទ្រង់ចិត្តា
ត្រេកអរោមនស្សា- ទរះទើបបង្គាប់ ។ ថាហៃសេនា ទាំង៤ម្ខីម្នា រួស
រៀបប្រដាប់ ត្រៃត្រះរាជយាន មាសមានសម្រាប់ ក្បៀងកូសផ្ទាប់ ត្រៃត្រឹងពណ៌ពស្ដា ។ ឲ្យលួសមគ្គុរ ចេញទៅទទួល យកកូនប្រសា អញពីកំពង់ ស្រះស្រង់រងថ្វា ទាំមកម្ខីម្នា កុំឲ្យផ្សុផ្សង ។
សេនាស្តេងស្តាប់ ស្តេចទ្រង់បង្គាប់ ច្បាប់គ្នាពុំលង់ រៀបត្រឹងប្រដាប់
សម្រាប់ស្តេចទ្រង់ នាំគាត្រេចត្រង់ ដល់ឆ្នេរស្រះស្រី ។ យកមហា-
បុរស រត្នរូបស្រៀបស្រស់ លើសលែងលោកិយ៍ ទើបអស់សេនា
យោធាមន្ត្រី ចរចូលអភិ- រាទររេងា ។ ទូលថាសូមទាន ពីមហា-
ក្សត្រក្សាន្ត ជាព្រះបិតា - ដ៏ពាឧត្តម ប្រើខ្ញុំកុណា យកព្រះកូសា
ព្រះតំណែងដែលទ្រង់ ។ ព្រះរាជទានឲ្យ មកអម្ចាស់មាន រួបរត្នវរ- ដ្ឋា
ស័ក្តិសួស្តីសម ឲ្យអម្ចាស់ទ្រង់ ស្រេចហើយឲ្យគង់ លើរាជយានទៅ ។
ព្រះពោធិសត្វ មហាបុរសរត្ន រិសេសចំមចៅ ទទួលពស្ដា កូមាស

មាសឆ្នៅ ល្អះល្អតសៅ អ្នកយកមកទ្រង់ ។ សក្តិសមសោភា ហាក់
អង្គខ្ពើ យាងយាសឡើងគង់ លើព្រះភជយាន មាសមានពលពង្ស
សេនាចតុរង្គ ហៃៗរៀងៗយ ។ បើកចាំងកូសក្ងំ ខ្ពង់ខ្ពស់ត្រសុំ
ត្រស័កត្រសាយ ត្រសៀករំហើយ រំគើយព្រះពាយ ទៅទៀបបន្ទាយ
ភជរាំងក្សត្រា ។ អ្នកចរចុះថ្ពាន ពីព្រះភជយាន យាងយាសលីលា
ឡើងលុះលើហាន ពិមានភជា ក្រួញក្រាបវន្ទា ប្រណម្យនិត្យទៅ ។
កាលណោះក្សត្រា ជាព្រះបិតា គយគន់មើលទៅ យល់ពោធិសត្វ
រូបវត្ថុល្អេញល្អៅ ព្រះភ័ក្ត្រតសៅ - ហ្នងមានរស្មី ។ ដូចចន្ទ្រវែងចាំង
ក្តីផ្ទៃអស់ទាំង អាកាសនភ័ តតនឹអ្នកស្មើ លើសលើលោកិយ័ ប្រុស
នៅដែនដី ផ្ទាប់ផ្ទឹមមិនមាន ។ ទ្រង់ព្រះចិន្តា ក្នុងព្រះទ័យថា នុបុត្រ
បុរាណ សំណាងកូនអញ សំឡាញ់មកបាន ស្វាមីមិញមាន ឆោម
ឆាយសោភា ។ គាប់គួរជាគូ ល្អល្អះត្រឹមត្រូវ សាក់សំនឹងគ្នា ស្តេច
គិតឯងអរ សាទរមហិមា ត្រេកត្រាស់សួរថា ហៃបុត្រពិសី ។
អាពុកចង់ជឹង ចង់ជ្រាបដំណឹង ដំណើរអំពី ព្រហ្មទត្តពាលា ហៅ
ប៉ាទៅថ្វី ប៉ានជាបុត្រី រត់មកតើម្តេច ។ កាលណោះព្រះពង្ស តួជ
ពោធិវ - ង្សាសក្តិសពិជ្ញ ទុនអង្គបង្គំ ប្រណម្យស្រែលស្រែច ទូលទៅ
សម្តេច ព្រះវរបិតា ។ ពីនាងនាដរត់ ព្រោះព្រះព្រហ្មទត្ត កាចគិត
ឫស្យា គ្រាស់ឲ្យមកហៅ ខ្ញុំទៅភោក្តា សឹងស៊ុតមាន់ទា លាយនឹង

ចំណី ។ ខ្ញុំបរិភោគ្គ ស្រែចះហើយលុតលា មកមណ្ឌលខ្លី រកនាង
ពុំយល់ សោកសល់សែនធ្ងី ដឹងដើមសេចក្តី ដោយឆ្កែប្រាប់ប្រា ។
ឋានាឯកល្យាណ ខឹងខៅពុំកង្វាន្ត រត់មកស្រុកអាយ ទើបខ្ញុំត្រែចមក
តាមរកនោមឆាយ ធ្វើដល្អសាសាយ រួចដល់ត្រើយគ្រាន ។ ទើប
ឆ្កែមរណា ភ្នាតនាំមាគ៌ា ៧យោជន៍ឋាន ភ្នាតនោះសោតស្ងាប់ ស្រែច
ស្រាប់តែមាន ឆ្កែកនាំផ្លូវឋាន ៧យោជន៍សល់ ។ ឆ្កែកនោះសោត
ស្ងាប់ មានរុយមួយប្រាប់ ណែនាំដើរដល់ ៧យោជន៍ឆ្ងាយ ចម្ងាយ
ទូលិ រុយស្ងាប់ទៀតយល់ តំពិលអំពែក ។ មួយមានឆ្មី រុងរឿង
ស្មើ អស្ចារ្យចំឡែក ល្អដូចក្តាយត្រឹក ភ្លឺផ្កែពន់ពេក កណ្តាលផ្លែ
មេឃ លើសលែងតាក ។ នាំខ្ញុំត្រែចត្រង់ មកដល់ស្រះស្រង់ ទ្រង់
ព្រះករុណា ពិសេសហើយហោះ ផ្ញើនទៅសួគ៌ា សមអង្គទេវ៍ មែន
មិនដទៃ ។ បពិត្រអម្ចាស់ ខ្ញុំលំបាកណាស់ កាលដើរដោយថ្មៃ
ម្ចាក់ឯងពុំគិត ជីវិតក្នុងក្រយ៉ៃ សូមជ្រាបព្រះទ័យ ពុំចេះមេត្តា ។
ស្តេចស្តាប់ពាក្យពី ភូដឥន្ទ្រភោធី ទូលទើបក្សត្រា ជ្រាបសព្វសេច
ក្តែច ហើយស្តេចអនិច្ច សង្វែគចិន្តា អាណិតពោធី ។ ទើបស្តេច
ត្រាស់ឲ្យ រៀបក្រយាស្ងោយ គោជន៍ភ័ស្តពិសី ពិសាត្រកាល អាហារ
ថ្មោងថ្មី មកឲ្យពោធី - សត្វសោយស្កប់ស្កល់ ។ កាលណោះក្សត្រា
ទ្រង់ព្រះចិន្តា ដោយព្រះយោបល់ ជាបុត្រប្រសា សោកានិមិល

មានវិទ្ធិពល ឫតវិទ្ធី ។ គិតគួរតែអញ យកធម្មជាញ់ លេងលង
ជារមី ទើបបើកព្រះសូរ បន្ទូលទៅខ្ញុំ ថាហៃមន្ត្រី កំណាន់រក្សា ។
ចូរទៅចរទៅ យកធសិល្បនៅ សារសក្តិថ្លៃថ្លា សែងមកឲ្យធាប់ ប្រ-
ញាប់ម៉ត្មា មន្ត្រីលុតលា ចុះចរួសពន់ ។ ប្រែនាយជ្រាប់ពាល ហៅ
គ្នារបល់ ចូលមកបំពាន់ កាន់ឈើស្នែងទៅ សែងធកំណាន់ រត់រួស
រន្ទាន់ ដល់ថ្ងាយក្សត្រា ស្តេចទតទៅយល់ ធដ័យមកដល់ បើកបន្ទូលថា
ហៃចៅគោគកុល និមិលសោកា កូនអើយចូរជា ជាញ់ធនេះមើល ។
ចង់ដឹងវិទ្ធី ពាលពាលជារមី ជាបុត្រប្រសើរ លេងលងចេស្តា ឲ្យ
អាពុកមើល ឲ្យដឹងដំណើរ កាលគ្រានេះម្តង ។

ចរពំនោល

ព្រះពោធិសត្វចាស់ច្បង ក្រែញក្រាបពាប់រង ទទួលព្រះពាជនុង្ការ ។
លុតលាយាត្រាត្រអាល ទៅដល់កណ្តាល ទីមុខព្រះលានក្សត្រា ។
ទើបអ្នកឈរឈោងហត្ថា យកធសរថ្នា គ្រវាសគ្រវីលេងលង ។
យល់ហាក់ស្រាលកែកន្ធង ដូចកល់ស្រីផង កាន់ដងដំថ្ពេចសំឡី ។
រាយវាត់ដំឡើងធាប់ខ្លី និរកិតឃ្លាតខ្លី ទើបយកសរមកផ្ចាប់ ។ ចែរ
ជាញ់ចេញទៅពុសព្ទ សូរ្យសរហាក់ផ្ចាប់ ក្រឡាប់ទាំងកូមិកពគារ ។ ពុ
ទៅដល់ក្រៅចក្រពាល កំពែងចក្រវាល ហាក់ដូចនឹងផ្ចាប់ក្រែមខ្ទុះ ។
ពុះពោរដន់ដោរសមុទ្រ សុមេរុបពិត កក្រើករំពើកញាប់ញ័រ ។ លាន់

ព្រះទ្រឹអស្ចារ្យ រំពងខ្ចរខ្ចារ ដូចសែនទន្ទេរគណនា ។ អស់រាស្ត្រតិតព័យ
តក្កមា លុះលាន់មាត់ថា នុះអះពាះស្ងាប់នេះម្តង ។ ស័ព្ទអ្វីឮក្រៃកន្ធង
ស្ងៀរស្ងុះដំពង សើរនឹងបែកខ្លែងតាមា ។ ព៉ាស្ត្រខ្ទរដឹងហើយថ្ងាប់ថា
ជ្ញតព្រះសុណិសា ក្សត្រាធិរាជថ្កើងថ្កាន ។ ចុះញ៉ាំធ្លាមុខព្រះលាន
តាណាអើយកុំតាណ តិតព័យខ្ញុំចក្ស័យជន្ម ។ អស់មុខមន្ត្រីយោធា
យង់យល់ចេស្តា ខុភាពព្រះអង្គលើសលៃ ។ សឹងកោតស្ងប់ស្ងៀងឥតែ
ព្រើសត្រមជួយជ័យ ចំរើនព្រះពារអីអឹង ។ សិល្បសរសត្តិ
សោតវិលវឹង វិលមកខ្មៅនឹង បំពង់ដែលជាក់និត្យខ្មៅ ។ ទើបអ្នកលី
លាខ្លើងខ្មៅ បង្គំគាល់ហ្មៅ នៃព្រះជនកក្សត្រា ។ ស្តេចយល់
វិទ្ធិពលចេស្តា បុណ្យបុត្រប្រសា ប្រសើរប្រសប់សិល្បសេយ្យ ។
ត្រូចព្រឹព្រើសព្រះកត្តិថ្ងៃ ត្រែកត្រៃព្រែនទ័យ រំពៃរំពឹងរកកល ។
ដោយព្រះទិព្វញ្ញាណយោបល់ បង់ល្បងឲ្យយល់ អំពល់អំពើកម្រ ។
ឲ្យយករនេះពីរមក៏ មួយជាក់គ្រាប់ល្ង មួយខុកនះនេនិត្យខ្មៅ ។ ទើប
ស្តេចបើកបន្ទូលខ្មៅ តាស់ថាហៃចៅ គោគកុលជាបុត្រសំឡាញ់ ។
ចូរបាទសព្វាហ៍អស់អញ រើសគ្រាប់ល្ងចេញ ពីកន្ត័រនេះនេះខ្មៅ ។ ជាក់
រនេះទេខ្មៅ ម្តងមួយគ្រាប់ខ្មៅ ឲ្យអស់ក្នុងថ្ងៃនេះថ្ងាត់ ។ ឯអង្គព្ធជ
ពង្សពុទ្ធរត្ន ក្រែញគ្រាបប្រណិបត្តិ ទទួលព្រះពរជាជ្យ ។ អ្នកគិត
តាំងចិត្តចិន្តា ប្រណិធានសច្ចា នឹកដល់ព្រះឥន្ទ្រជិបតី ។ ថាទុអស់
បុណ្យថ្ងាមើ អញសាងអំពី ម្តៃអស្ចារ្យយ៉ា ។ បើអញនឹងបាន

គ្រាស់ជា· អង្គព្រះសម្មា - សម្ពុទ្ធច្រៀកដរៀងទាត់ · ។ ធ្វាស់ធ្លងការ
កូមិកពវដ្ត - សង្ឃរនាំសត្វ ជាក់ដល់នគរនិព្វាន ។ សូមឲ្យព្រះឥន្ទ
ហោះធ្យាន មកដួយឲ្យចុំាន សម្រែចដូចចិត្តច្រាថ្នា ។ តេជៈហេតុ
ចារមីតា ពន្ធកសាស្តា ក្តៅដល់មណ្ឌលកម្ពុល ។ សិលាអាសនាច្តើង
ច្តល់ ទិព្វទីមណ្ឌល សម្តេចអមរិន្ទ្រគ្រា ។ ចាន់បែរបើកទិព្វចក្ខា
យង់យល់ព្រះមហា បុរសព្រួយព្រះហ្ឫទ័យ ។ ស្តេចហោះចុះចាក
ហានកៃ - ត្រង់ត្រេចត្រង់ឮ បុរីសត្តកូដរាជ ។ ច្រួញច្រាណ
ច្រឹងច្រែកាឡា និមិត្តកាយា ជាក់ជ្រាសមោចខ្មៅខ្លួ ។ ពេញ
ពាសដេរជាសទ្ធ្លល ពាំលូជាជួរ ជញ្ជាន់ពីរខេះចេញ ។ ជាក់
ទៅរខេះមួយមិញ មួយរំពេចពេញ ពុំសល់ដល់មួយគ្រាប់ទៅ ។
ព្រះវរបិតាចមចៅ ស្តែងស្តេចទតទៅ យល់ជាអស្ចារ្យពេកពន់ ។
សេនាយោធាមុខម - ន្ត្រីច្រជាជន យល់ហើយសឹងកោតចេស្តា ។
ស្រែងបុណ្យស្រែងចារមីតា សឹងឲ្យសព្ទ័សា - ធុការចំរើនព្រះពរ ។
កាលណោះសម្តេចព្រះវរ - បីតាសាទរ ព្រះអង្គទ្រង់ព្រះចិន្តា ។
ចង់លចង់ល្បងច្រាជ្ញា បុណ្យបុត្រច្រសា ច្រសើរឲ្យចានបីជង ។
ស្តេចច្រើនាយព្រះក្រាលផង គ្រាលព្រំចៀមចង រនាំងចាំងព្រះ
សន្ទិយា ។ ស្រែចឲ្យអស់អង្គធីតា ឰអង្គា លីលាឡើងមកគាល់
គង់ ។ រៀបរៀងពាល់រាយពីកង បន្ទេចតែចុង ច្រមាមព្រះហស្តមក្រៃ ។

តន្ត្រីអាស៊ីទ្វីប

ហ្គីតទិពន្ធមន្ត្រី ញ៉ុក - ថែម ប្រែ - រៀបរៀង

(តមក)

ក្នុងខណៈនោះ ព្រះសិទ្ធត្ថិទ្រង់យាងរួសរាន់ទៅជួយលើកមនុស្ស ជម្ងឺឡើង ដោយព្រះហស្តដ៏ទន់ភ្លន់មានមេត្តា ទ្រង់សន្សឹមៗ ជាក់ក្បាលអ្នកជម្ងឺលើព្រះជាណុ រួចទ្រង់សួរបអង្អែលបំបាត់សេចក្តីឈឺចាប់ ហើយទ្រង់មានព្រះបន្ទូលសួរថា នែបង ចុះវាឈឺចាប់យ៉ាងណា តើតវេគអ្វី? ហេតុអ្វីក៏ក្រែកមិនរួច? នាយធន្ន:, ហេតុអ្វីក៏គាត់ហាត់បំរែនខ្លៀលនិយាយមិនរួចមានអាការមុខគួរឲ្យអាណោចអាធម្ម៉ង់?—

នាយសារថីក្រាបទូលតបថា "ទ្រង់មហាក្សត្រថ្លៃ, មនុស្សនេះតើតវេគប៉ែស្តីមួយយ៉ាង ដែលបណ្តាលឲ្យធាតុទាំងពួងថយកម្លាំងរលត់ទៅ, ឈាមដែលតែងហូរទៅតាមសព្វសរសៃដូចជាប្រឡាយទឹកនោះឥឡូវតើតអោកអួលដុតដាលក្តាយទៅជាក្តក់ក្តើងឡើង បែរជួងដែលធ្លាប់កំរើក មានរយៈស្មើគ្នាតាមធម្មតា ឥឡូវប្រែជាកំរើកញាប់ក៏មានយឺតៗក៏មាន ហាក់ដូចជាស្តារដែលគេរ៉ាយមិនត្រូវតាមចង្វាក់ ដុំសាច់គ្រប់ភាគធ្លាយទៅដូចខ្សែធ្នូដែលធូរ, កម្លាំងពលំរបស់គាត់ថយខ្សោយអស់ទៅពីកំភួនដើង ចង្កេះខ្នងរបស់គាត់ហើយ, ឫកពាហាក់ដូចជាតើតការតែកយតាមធម្មតារបស់មនុស្សធ្លុតរបូតអស់ទៅហើយ; នេះហើយគឺមនុស្ស

ឈឺ ត្រូវពេគាព្យាធិកំពុងដុតពេល ។ សូមទ្រង់ទតមើល, គាត់អេះ
ខ្ចាំខ្ជួនរបស់គាត់ ដើម្បីដកយកដម្បីដំកាត់ចេញ គាត់ទំប៉ិងបម្រះនទៀល
ខាំមាត់សង្កៀតធ្មេញជកជង្គើមប្រជឹតប្រជក ហាក់ដូចមនុស្សឈ្លក់
ផ្សែង ។ សូមទ្រង់ទតមើល! គាត់គង់ចង់ស្លាប់ទៅធាប់ ប៉ុន្តែមិនងាយ
នឹងស្លាប់ធាប់ មុនពេគជម្ងឺនោះវាបៀតបៀនឲ្យបានវេទនាជាពន្ធឹកដោយ
សម្លាប់សរសៃប្រសាទតាំងឡាយឲ្យស្លាប់ទៅមុនជីវិត ហើយកាលដែល
អះយៅតាំងពួងរលត់ទុក្ខវេទនាហើយ ទើបការឈឺចាប់ចេញចាកខ្ជួនគាត់
ហើយចាប់បៀតបៀនទីជនៃគេទៅទៀត" ។ "ខ! ព្រះម្ចាស់ថ្លៃ, មិន
សមគួរនឹងការដែលព្រះអង្គលើកបីត្រកងខ្ជួនគាត់ទេ, ដ្បិតជម្ងឺនេះអាចធ្វើ
ពាលជាលដល់ព្រះអង្គផង" ។

ព្រះពាជកុមារទ្រង់ជួយលួងលោមបំបាត់ទុក្ខសោកមនុស្សនោះ ហើយ
មានព្រះបន្ទូលថា "នៅមានមនុស្សដទៃទៀត ដែលមានជម្ងឺឈឺចាប់
ដូច្នេះ មានច្រើនដែរឬ? ហើយខ្ជួនខ្ញុំអាចទៅជាមនុស្សដូច្នេះដែរឬទេ? ។

នាយសារថីក្រាបទូលស្នងថា "សូមទ្រង់ព្រះមេត្តាជ្រាស, ការ
ឈឺចាប់នោះ វាមែងកើតមានដល់មនុស្សគ្រប់ជំពូក ដោយអាការពេគ
ផ្សេងៗគ្នា គឺសេចក្តីឈឺចាប់នឹងរបួសផ្សេងៗ ព្យាធិ, ពេគស្លាប់ជើង
ស្លាប់ដៃ, ឃ្លង់, ពេគគ្រុនក្តៅ, ពេគរាកមួល នឹងបួសកមផ្សេងៗ
វាមែងប៉ះពាល់ដល់សព្វសត្វ ហើយធ្វើពាលជាលទៅសព្វអន្ទើ" ។

ព្រះពជកុមារត្រាស់សួរថា "ចុះដង្វើដែលកើតឡើង គេមើលក៏មិនឃើញទេឬ? នាយឆន្នត្រាបទូលថា "ពេគអស់នោះហាក់ដូចជាអសិពិសដ៏សាហាវមកចឹកខាំយើង ដោយមិនឃើញរូបរាជាមុន, ដូចខ្លាកាចដែលលាក់ខ្លួនពួននៅក្នុងគុម្ព ក៏រួះ: ក្បែរផ្លូវក្នុងព្រៃធំ សម្ងំចាំឧកាសល្អនឹងលោតទៅចាប់សត្វខាំឆ្អែយស៊ីជាអាហារ, ឬដូចជារន្ទះដែលធ្លាក់ចុះមក ប៉ះត្រូវមនុស្សខ្លះប៉ះក៏មិនត្រូវ" ។

"ចុះមនុស្សគ្រប់រូបរស់នៅក្នុងអាគារគួរស្រប់ស្រែងមែនឬ?

"ទ! ក្បត្រៃថ្ងៃ មនុស្សយើងរស់នៅក្នុងទំនងដូច្នោះមែន" ។

"ចុះគ្មាននរណាហ៊ានពោលថា: ខ្លួនខ្ញុំដែលជាសុខសម្បាន្តរហូត ១ យប់នេះ ជរាបដល់ភ្លាក់ឡើងវិញ មែនឬទេ!-

"សូមទ្រង់ព្រះមេត្តាត្រាស, គ្មាននរណាហ៊ានក៏ប៉ះងទេ" ។

"ហើយនៅទីបំផុតនៃសេចក្តីលំបាកជាអនេកប្រការនេះ ដែលក៏ចូលមកប៉ះពាល់ មិនឲ្យមើលឃើញ មិនឲ្យដឹងខ្លួន ហើយបណ្តាលឲ្យមានផល គឺពងកាយខ្ទុះត្រាម វិញ្ញាណខ្ទួលភាព ឲ្យដល់ខ្លួរជរាភាព ដូច្នោះឬ?

"សូមទ្រង់ព្រះមេត្តាត្រាស, បើមនុស្សមានជរាតែយ៉ាងយូរមកដល់ថ្នាក់នេះ តែងតែដូច្នេះឯង" ។

"ប្រសិនបើយើងមិនអាចអត់ធន់អំណាចរបស់ក៏ប្រាន ឬបើយើងអត់ធន់ទ្រាំត្រូវហើយ បើយើងចង់ឲ្យក៏ផុតរលត់ទៅ ឬបើយើងអត់ធន់

ត្រាំត្រែ ហើយបើមានអាការដូចជាបុរសដ៏ខ្វល់ខ្វាយណាស់នេះ ហើយមិនអាចនឹងមានជីវិតតទៅទៀតបើចង់រស់តទៅទៀត ត្រូវតែចាស់ជរាទៅ។! បើដូច្នេះតើនឹងមានទីបំផុតដូចម្តេច?-

"សូមទ្រង់ព្រះមេត្តាត្រាស, យើងត្រូវស្លាប់ទៅនៅទីបំផុត" ។

"យើងត្រូវតែស្លាប់ដែរឬ?

"សូមទ្រង់ព្រះមេត្តាត្រាស, ពិតណាស់, នៅទីបំផុត យើងត្រូវតែស្លាប់ មិនថានៅទិសតំបន់ណា ឬនៅពេលណាទេ, អ្នកខ្លះចាស់ស្លាប់ អ្នកខ្លះគោរងទុក្ខវេទនាហើយឈឺស្លាប់ទៅ, ប៉ុន្តែមនុស្សគ្រប់រូបត្រូវតែស្លាប់; សូមទ្រង់ទតមើលចុះ ន៎ុះហ្ន៎ សេចក្តីស្លាប់ដែលគេហៅហួសទៅ! ។

គ្រានោះ ព្រះសិទ្ធត្ថរាជកុមារងើបព្រះនេត្រទតមើលទៅទ្រង់យើញក្បួនហែមួយ ហែយឺតៗតាមដងស្ទឹង មានមនុស្សស្រែកយំតាមហែផង ខាងមុខក្បួនមានមនុស្សម្នាក់កាន់ភាជន៍ដីពេញដោយរងើកភ្លើង ខាងក្រោយមានពួកញាតិសន្តានគោរក្បាលស្រែកពាក់កាន់ទុក្ខ ហើយស្រែកខ្លាំងៗថា! ពមា, ពមា, សូមទ្រង់ស្តាប់! សូមបងប្អូនដួយអង្វរពមាផង" ។ តបន្ទាប់មក មានមឈូសដាក់សពត្បាញដោយបុស្បីដើងទៅខាងមុខរំងស្តុកស្តឹង មានតែស្បែកដណ្តប់ឆ្អឹង, ឆ្អឹងដំនីរផតខ្លួង, មាត់ស្រេញប្រឡាក់លាបដោយផង់ក្រហមនឹងលឿង; លុះហែទៅដល់

ផ្លូវបំបែក ពួកអ្នកសែងក៏បង្វិលក្បាលសពទៅខាងមុខ ហើយតាំងស្រែកឡើងថា "ពមា, ពមា" ។ ហើយនាំគ្នាសែងសពទោះទៅមាត់ស្ទឹងដែលមានគំនរខ្សាច ហើយដាក់សពពីលើ រួចគេយកខ្សាច់សង្កត់ថែមពីលើសពទៀត – អ្នកដែលដេកសម្រាកលើដំណេកដូច្នេះ តែងដេកលក់យ៉ាងស៊ប់សួន (លែងក្រោក) ទោះបីត្រូវក្តា - ត្រជាក់គ្របសង្កត់ក៏មិនធ្វើឲ្យគេភ្ញាក់រលឹកឡើងបានទេ បើទុកដាក់ឃើញទៅហាលខ្យល់តាំងអាក្រាតកាយក៏ដោយ ក៏តែងមានភ្ញាក់ខ្លួន ។ រួចពីនោះ គេនាំគ្នាជុតភ្លើងឡើងតាំង ៤ ទិស ភ្លើងក៏សន្ធឹមៗ នេះកាលដាលឡើង នេះគំនរខ្សាចអណ្តាតភ្លើង ធាបធួលឡើងមួយរំពេចធាបនេះរូបអស់ទោះ ហើយស្បែកដំរីមក៏រលេះរលាកទៅ ហើយដំណឹងក៏ជាច់ធ្លាក់ចេញខ្លាត់ខ្លាយ, ទៅទីបំផុត ឆ្អឹងភ្លើងដ៏ក្រាស់ក៏សន្ធឹម ។ រួចយូរទៅ ទុកសល់ខែវតែធ្នឹងសក្បុស – នេះហើយជាសំណល់របស់មនុស្សយើងគ្រប់រូប" ។

ឧណៈទោះ ព្រះពជកុមារមានព្រះបន្ទូលថា "ទោះហើយ ទីបំផុតនៃជីវិតដែលធំចំនួនពួកជនគ្រប់រូប ដែលមានជីវិតរស់ទៅដូច្នោះឬ?–

នាយឆន្នៈក្រាបទូលស្នងថា "នេះហើយជាការបំផុតដែលបំរុងទុកសម្រាប់មនុស្សគ្រប់រូប, អ្នកដែលដេកលើគំនរខ្សាចអម្បាញ់មិញនេះមានរបស់សំណល់សល់ទុកតិចណាស់ សូម្បីសត្វក្អែកដែលកំពុងស្រែក

ឃ្លាន កំមិនចង់ត្រឡែកមើលផង - ពីមុនមក មនុស្សនេះ ចេះស៊ុំ, ផឹក, សើច; ស្រឡាញ់ រស់រានមានជីវិតហើយចេះស្រឡាញ់ជីវិតរបស់ខ្លួន ។ តមកសម័យក្រោយ ត្រឡប់ប្រែប្រួលយ៉ាងដូចម្តេចទៅ? នរណាដឹងបាន?- ឃ្យល់ព្យុះក្នុងវៃធំ, ដើរភ្លាត់ដើងធ្លាក់ពីផ្លូវ; ចំរូងចំរះកងអណ្តូង; ពស់ចឹក រងាត្រជាក់ ឆ្អឹងត្រី ឬ ក្បឿងធ្លាក់; អស់នេះអាចបំផ្លាញជីវិតឲ្យវិនាសទៅបាន: ហើយមនុស្សក៏ស្លាប់ ។ ហើយគេលែងដឹងរសជាត; លែងរីករាយ, លែងមានទុក្ខវេទនា, ទោះបីអណ្តាតក្តៅងាបឆេះដុតពេលខ្លួន គេក៏ឥតដឹងខ្លួនយ៉ាងណាសោះ សាច់ឈាមត្រូវក្តៅឆេះក្រៀមទៅ ទោះបីកូនត្រអូបរបស់ខ្លឹមចន្ទន៍ ចម្រុះលែងដឹងក្លិន, មាត់មិនទទួលរសជាត, ត្រចៀកលែងទទួលស្តាប់សំឡេង, កែកលែងទទួលស្គាល់រូបារម្មណ៍ទាំងអស់, ដូនជាទីពេញចិត្តរបស់អ្នកស្លាប់ មានតែការយំសោកកន្ទក់កន្ទេញតែឯកឯង ហើយត្រូវតែទំលាយបំផ្លាញកាយនោះទៅ ដើម្បីកុំឲ្យកងកាយក្លាយជាអាហារដែលគួរអាណោចអាធម្មរបស់ដង្កូវ, កាយដែលតាំងនៅដោយជីវិត ។ ដែលជាចន្ទ្រែងខាងក្នុង ។ នេះឯងជាដោគលាភធម្មតា សម្រាប់សាច់ឈាមរបស់មនុស្ស; ទោះបីអ្នកមានវិជ្ជិតេជះប្រឹងត្រយ៉ាងណាក៏ដោយ ល្អប្រសើរក្រក់ក៏ដោយ ក៏ត្រូវតែស្លាប់ដូចគ្នាទាំងអស់; ហើយបើពោលតាមពាក្យដែលគេតែងទូន្មានមកនោះ ថាកាលស្លាប់ទៅហើយក៏ត្រូវកើតជា

ថ្មីទៀតដែលឥតអ្នកណាដឹងជាក់ច្បាស់ថាទៅកើតនៅទីណា ហើយ
កើតឡើងដូចម្តេច; នេះឯងហើយ គឺវដ្តសង្សារបស់មនុស្សលោក" ។

កាលព្រះសិទ្ធត្ថៈពុជកុមារ ទ្រង់ឆើបព្រះកន្ត្រឡឹង មានព្រះអស្សុ
ជលជោរជន់ ទតព្រះនេត្រទៅលើផ្ទៃមេឃ ហើយទតមកផែនដី
ព្រះទ័យពោរពេញដោយសេចក្តីមេត្តា ហើយហាក់ដូចទ្រង់ពិចារណា
ស្រាវជ្រាវរកយោបល់អ្វីមួយដ៏ជ្រាលជ្រៅ ដែលមានជាប់ទាក់ទង
រវាងមេឃនឹងផែនដី គឺយោបល់មួយដ៏វិសេសជាក់ស្តែងដែលមើលមិន
ឃើញដោយភ្នែក ប៉ុន្តែកាលបើទំស្រាវជ្រាវក៏គាចនឹងបានដួចប្រទះឃើញ
ហើយស្គាល់ជាក់ច្បាស់បាន" ។

គណៈនោះ ទ្រង់មានព្រះគាគារកិរិយាដ៏សំបើម ទ្រង់មានព្រះ
ទ័យដ៏ត្រេកត្រអាយ ដោយមានព្រះចំណាន់ខ្ជាំងក្លា សម្បយុត្តដោយ
មេត្តាករុណាដ៏លើសលុប ហើយមានព្រះទ័យដ៏ធ្ងៃជាក់កងសេចក្តី
សង្ឃឹមគ្មានទីបំផុត ទាំងមិនសោះសូន្យ ទើបទ្រង់បន្ទូលព្រះទេវាន-
ភ្ញាថា "ឧ! លោកវិនាសម្ង! ឧ! បងប្អូនទាំងឡាយ ទាំងស្គាល់គ្នា
ទាំងមិនដែលស្គាល់គ្នា សុទ្ធសឹងជាប់ជំពាក់នៅកងសំណាញ់ទុក្ខវេទនា
នឹងមរណៈទេតើ! យើងឃើញ យើងដឹងក្នុងហេតុនៃការវិវរ៌ករបស់
ផែនដីហើយ; អំនួតនៃសេចក្តីរីករាយ, ការចោកច្រាសនៃសេចក្តីសុខ
សប្បាយ, ការញាប់ញ័រឈឺចាប់នឹងការទុក្ខព្រួយ, សេចក្តីក្សេមក្សាន្តផុត

អស់ទៅ, កាលបើទៅដួបប្រទះនឹងទុក្ខព្រួយ, រីឯក្មេងផុតរលត់ទៅ កាលទៅដួបនឹងចាស់ជរា, សេចក្តីស្នេហាធ្វើឲ្យកើតទុក្ខ កាលបើព្រាត់ច្បាស់របស់ស្នេហានោះទៅ, កើតហើយក៏មានស្ងាប់ កាលស្ងាប់ទៅក៏ត្រឡប់កើតឡើងវិញទៀត ដែលធ្វើឲ្យមនុស្សធ្លាំដំណើរជាច្រើនទៀត ក្នុងកងគាំនៃសំសារចក្រ ដើម្បីឲ្យវិលវល់កងរង្គន់នៃសេចក្តីសប្បាយដែលមិនទៀង នឹងសេចក្តីទុក្ខព្រួយដ៏ទៀងទាត់ប៉ុណ្ណោះ ។ ខ្ញុំយើងនេះក៏ដូចគ្នាដែរ , យើងត្រូវគេបញ្ជោតដោយនុយតាមទំនងនេះ ។ ឯដីវិតហាក់ដូចជាកូនជាទីស្នេហារបស់យើង . ហើយមានទំនងដូចជាខ្សែទឹកកណ្តាលថ្ងៃ . ដែលហូរទៅជានិច្ចនិរន្តរ៍ ក្នុងសេចក្តីសុបតកកល្អក់ប៉ុន្តែទន្ទេរដែលហូរកាត់ទីដ៏ដេរដាសដោយផ្កាដ៏ក្រអូបក៏ដោយ តែនៅទីបំផុតទឹកថ្ងាយដ៏ដូចជាកញ្ចក់ ក៏ហូរយ៉ាងរួសរាន់ចូលទៅក្នុងសមុទ្រដ៏មានរសជៃមិនបរិសុទ្ធនោះឯង ។ ចង្កូតទូកដែលធ្វើឲ្យយើងខ្ញុំកាន់ជីវិតនេះវិនាសអន្តរាយអស់ហើយ ។ ខ្ញុំយើងនេះ ក៏ដូចជាមនុស្សពាំងអស់ក្នុងលោក ដែលនាំគ្នាបួងសួងអង្វរអស់លោកទេព្តា តែលោកឥតស្តាប់សោះ ។ ប៉ុន្តែទុកជាយ៉ាងណាក៏ដោយ ត្រូវមានវិធីណាមួយសម្រាប់ជួយអ្នកដទៃនឹងខ្ញុំយើង នឹងពួកជនដែលត្រូវការជំនួយអំពីយើង ! ប្រហែលពួកទេព្តា ក៏ត្រូវការជំនួយតាមទំនងនេះដែរ ! ចុះហេតុអ្វីក៏អស់លោកខន់ខ្លាយម្ល៉េះ មិនអាចជួយស្រោចស្រង់អ្នករងគ្រោះថ្នាក់ដែលគ្មានទីបង្ស

ស្តេចអង្វរ! យើងមិនចង់បណ្តោយឲ្យជនដែលយើងអាចជួយសង្គ្រោះបាន ឲ្យនៅតែទ្រហោយំទេ! ចុះហេតុម្តេចបានជាព្រះព្រហ្មទ្រង់បានកសាងលោកនេះឡើងហើយបណ្តោយឲ្យធ្លាក់ទៅក្នុងភ័យអន្តរាយដូច្នេះ? ប្រសិនបើលោកជាអ្នកមានឫទ្ធិមែន មិនពាក់ថាជាអ្នកសប្បុរសទេ ហើយខ្លួនលោកក៏មិនមែនជាព្រះពិតៗផង? - នាយឆន្ទៈយើងល្មមត្រឡប់ទៅដំណាក់វិញហើយ? ខ្ញុំបានឃើញរឿងវល្លិសមគួរដែរហើយ!" ។

កាលព្រះបាទសម្តេចព្រះវរបិតា ទ្រង់បានឆ្លើយហេតុដូច្នោះ ទ្រង់ចាត់ឲ្យមានពួកយាមរក្សាទ្វារព្រះពន្ធកំផង ថែមទាំងបានគេឡើងទៀតហើយទ្រង់ចេញព្រះពន្ធបាសាមផ្តាច់ មិនឲ្យជនណាមួយចូលឬចេញ មិនថាយប់មិនថាថ្ងៃ ដរាបរាល់តែផុតកំណត់ថ្ងៃ ដែលទ្រង់បានជាបន្ទូលព្រះសុបិននិមិត្តនោះ ។

វគ្គទី ៤

ប៉ុន្តែដល់ថ្ងៃកំណត់ ដែលព្រះជាម្ចាស់នៃយើងទ្រង់ចេញទ្រង់ព្រះឆន្ទៈនោះ គេបានឮសូរសំពួយសោកកន្ធរកន្ធេញ ក្នុងប្រាសាទពន្ធ ទាំងមហាក្សត្រជាព្រះវរបិតា ក៏ទ្រង់ក្សត្រឡូលវង្វេងព្រះហឫទ័យជាខ្លាំង ថែមទាំងអាណាប្រជាជនក្នុងប្រទេសទាំងមូលក៏យំសោកស្តាយទាំងអស់គ្នា ប៉ុន្តែព្រះពន្ធដំណើរនេះជាបច្ច័យនាំឲ្យសត្វលោកខ្លួនឯងផុតចាកកងទុក្ខទាំងពួង ហើយពួកជនដែលបានស្តាប់ព្រះធម៌របស់ព្រះអង្គក៏អាចដោះខ្លួនឲ្យផុតរបូតចាកតណ្ហាបានផង ។ (មានត)

មហា "ទិម-ណាគ្គី"

ឃុំស្វាយចេ្ចា ស្រុកសង្កែ ខេត្តបាត់ដំបង ប្រែរៀបរៀង,

(តមក)

.....

ពាលបណ្ឌិតវគ្គ

ពាលំ នបស្សេ ន សុណោ ន ច ពាលេន សំវសេ
ពាលេភិ ស្ហាបសល្លាបំ ន កយិរេ ន ភោចយេ ។

មិនគួរចង់ឃើញ មិនគួរចង់ស្តាប់ មិនគួរសេពគប់ មិនគួរសន្ទនា
មិនគួរស្មោគមនឹងក្រុមពាល មិនគួរឲ្យវាចូលចិត្តស្និទ្ធផង ។

ន ចាបជនសំសេវី ឧច្ចត្តំ សុខមេធតិ
អនត្ថាយេវ វឌ្ឍន្តិ ពាលំ អភូបសេវតោ ។

អ្នកដែលមិនសេពគប់នឹងជាបជន តែងបានសុខសន្តិលើសលុន-
ពេកណាស់ ។

ជាបគ្រែះចង្រៃសេចក្តីវិនាស តែងកើនប្រទះអ្នកគប់ពាលពេក ។

ន សន្ធំ កាបុរិ.សេន កយិរា
អសន្តេនោ ចាបជនេន សេយ្យោ
មិនគួរធ្វើសេចក្តីស្រឡាញ់ស្និទ្ធ ជាមួយជាមិត្តមនុស្សអាក្រក់
ការមិនសេពគប់មនុស្សតក់ម៉ក់. គឺមនុស្សអាក្រក់ប្រសើរជាង ។

ពាលសង្គតចារី ហិ . ឥឃមន្ទាន សោចតិ ។

អ្នកដែលសង្គមនឹងក្រុមពាលខ្លៅ តែងសោយសោកសៅមួរមៅសង្កែង
អស់កាលយូរយោរលោអង្កែង ទុក្ខទោសលើសលែងលើសលប់
លើសលន់ ។

ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា
ការនៅមួលមិត្តស្និទ្ធនឹងជនពាល ប៉ណ្ណាលឲ្យកើតទុក្ខទោសមួរមៅ
សព្វទិនទាំងជានិរន្តរ៍ទៅ ដូចនៅជាមួយសត្រូវសាមាទ្យ ។

ធីរេ ច សុខសំវាសោ ញាតីនំវ សមាគមោ
ការនៅមួលមិត្តស្និទ្ធនឹងអ្នកប្រាជ្ញ តែងអាចបណ្ដាលឲ្យកើតសុខសាន្ត
ដូចនៅជាមួយពួកញាតិសន្តាន ដែលតែងពប់អានស្មោះស្ម័គ្រមេត្រី ។

យោ ពាលោ សេវតិ សោ វិនាសំ ចានុណាតិ
នរណាសេពគប់តប់នឹងពាលខ្លៅ នរនោះដល់នូវផ្លូវវិនាសជាក់
ហិនវៃហិនហោចពុំចម្រើនឡើយ ហេតុនេះលោកអ្នកត្រូវវៀសជៀសវាង ។

យំ វេ សេវតិ តាទិសោ
បើយើងសេពគប់តប់នឹងនរណា កិរិយានៃយើងក៏ដូចនរនោះ
បើគប់នឹងពាលក៏ពាលតាំងអស់ បើគប់សប្បុរសក៏សប្បុរសដែរ

និហីយតិ បុរិសោ និហីនសេវី ច មាយេន
តុល្យសេវី

សេដ្ឋមុបកតំ ឧទេតំ តស្មា អត្តនោ ឧត្តរំ កតេ ៥

គប់ជនអាក្រក់តែងអាក្រក់ចុះ គប់មនុស្សស្មោគតែងមិនវិនាស
គប់ជនប្រសើរជាងតែងខ្ពង់ខ្ពស់ ហេតុនោះគួរគប់ជនគ្រាន់ជាងខ្លួន ។

តក្កកស្សវិសំ ទន្តោ មក្កិតាយ វិសំ សិរោ
វិច្ឆិកស្ស វិសំ វុត្តោ សព្វង្គេ ទុជ្ជនេ វិសំ ។

ពស់មានចង្កឹមជាពិសខ្លឹមហន្ត រុយពិសសំខាន់មាននៅត្រង់ក្បាលវា
ឃ្មុយមានពិសកណ្តាលខ្លួនឫទ្ធិមហិមា ឯទុជ្ជនពាលាពិសវាទៅសាំពាង្គ ។

អនស្សន្តេន ពាលានំ និច្ចមេវ សុខី សិយា
ជនមានសេចក្តីសុខសាន្តជានិច្ច ព្រោះមិនទង្គិចដួបប្រទះពាល
ជាអ្នកអាក្រក់លាមកពាសពាល ជាអ្នកបណ្តាលទុក្ខទោសពៀរភ័យ

ហាដ្ឋាហំ ហាតចក្កស្មិ កន្តារទ្ធានមាកតោ
មវិស្សាមិ នោ តមិស្សាមិ ឧត្តិ ពាលេ សហាយតា ។

ថ្វី ! បើអញមានចក្ខុខ្វាក់ មកកាន់កន្តារៈមគ្គា
អញស៊ូវតែស្ងាប់រងវេទនា អញមិនទៅជាមួយឯងទេ ។
ព្រោះថាសហាយតាគុណ មិនមានក្នុងជនជាពាលេ
ឯងជាសំឡាញ់អញក៏ទេ ព្រោះឯងរៀចរៅលាមកណាស់ ។

សចេ លភេថ និបកំ សហាយំ
សទ្ធិចរំ សាធុវិហារិ ធីរំ

អតិកុយ្យ សញ្ញាន បរិស្សយានិ
ចវេយ្យ តេនត្តមនោ សតីមា ។
នោចេ លភេថ និមកំ សហាយំ
សទ្ធិចរំ សាធុវិហារិ ធីរំ
រាជារដ្ឋំ វិជិតំ បាហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។
ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេសហាយតា
ឯកោ ចរេ ន ច បាបានិ កយិរ
អប្បស្សុកោ មាតង្គរញ្ញេវ នាគោ ។

បើបុគ្គលបានមិត្តសំឡាញ់	មានចិត្តភ្ជួបភាញ់ស្និទ្ធស្នេហា
ជាមិត្តប្រកបដោយបញ្ញា	សម្រាប់រក្សាខ្លួនចិត្តកាយ ។
ជាអ្នកប្រាជ្ញដែលមានព្រះធម៌	ជាគ្រឿងអំពារណ៍នៅសប្បាយ
គ្រប់ទៅជាមួយមិនឃ្លាតឆ្ងាយ	សង្កត់អន្តរាយគ្រប់យ៉ាងបាន ។
ជាអ្នកគ្រែកអរដោយមេត្តី	មានស្មារតីមានវិញ្ញាណ
គប្បីគ្រែចទៅកុំឲ្យខាន	ជាមួយកល្យាណមិត្តនោះចុះ ។
បើមិនបានមិត្តដ៏ពិរុម្ប	ស័ក្តិសមខ្ពស់គុណដូច្នោះ
គឺមិត្តអាក្រក់មានចិត្តទ្វេស្ស	គួរវៀរចាកចុះល្អជាជាង ។
បុគ្គលនោះគួរតែគ្រែចទៅ	សំដៅទីណាតែម្នាក់ឯង

ប្រៀបដូចមហាក្សត្រិយ៍លះកន្ទែង　　គឺដែនស្តេចស្តែងទ្រង់មានជ័យ ។
ហើយទ្រង់ត្រេចទៅតែឯកោ　　គ្មានសំដៅពឹងដំរៃ
ឬប្រៀបដូចជាដំរីថ្ងៃ　　ត្រេចទៅក្នុងព្រៃតែឯកអង្គ ។
ការដែលបុគ្គលតែឯកកាយ　　ត្រេចទៅជិតឆ្ងាយតាមចំណង់
ហៅពេញប្រសើរយ៉ាងខ្ពស់ខ្ពង់　　ព្រោះវង្សបុគ្គលពាលសាមាន្យ ។
មិនដែលមានសហាយគ្នា　　គុណឯណាមួយក្នុងសន្តាន
ទីឆ្ងាត្រេចជាមួយផងពុំបាន　　ព្រោះវាមិនមានគុណខ្ពង់ខ្ពស់ ។
បុគ្គលត្រេចទៅតែម្នាក់ឯង　　ប្រសើរកៃលែងពិតដូច្នោះ
តែគួរកុំធ្វើបាបឲ្យសោះ　　ទើបឈ្មោះថាត្រេចទៅប្រពៃ ។
ប្រៀបដូចហត្ថិនាគខ្វល់ខ្វាយតិច　　ត្រេចទៅតែម្នាក់ឯងក្នុងព្រៃ
បុគ្គលគួរធ្វើយ៉ាងនេះនៃ　　ទើបបានសេចក្តីចំរើនអើយ ។
សចា សមេតិ សតាំ　　សមេតិ អសតា អសំ
ភយសោ ករុណាបំ យាតិ　　ករុសុមំ យាតិ ជប្បនេ ។

ក្នុងកាលទាំងពួង

សប្បុរសតែងទៅសមាគម　　ជាមួយពួកក្រុមសប្បុរស
ដូចកុមរជាតិតែងស្ទុះស្ទះ　　ត្រេចឆ្ពោះទៅរកផ្លាផ្លា ។
ឯអសប្បុរសតាលោខ្លៅ　　ទាំងពួងអសប្បុរសដូចគ្នា
ទៅកាន់សមាគមសកា　　ដូចជាក្អែកត្រេចរកសាកសព ។

បរេសុ្ជ ហារកោ ពាលោ បរំ ទុក្កតំតាមិកោ
បរេសុ្ជ ឆាយកោ ធីរោ បរំ សុកតំតាមិកោ ។

ជនពាលលួចយកទ្រព្យអ្នកដទៃ ក៏តែងជួបភ័យក្នុងលោកខាងមុខ
គឺត្រែចទៅកើតក្នុងកំណើតទុក្ខ ប្រែតប្តូនរកនឹងតិរច្ឆាន ។
ចំណែកបែកជនដែលជាអ្នកប្រាជ្ញ លោកអាចចំណាយចាយលះធនធាន
ដល់ជនដទៃលៃធ្វើជាទាន តែងទៅកាន់ស្ថានសុគតិភព ។

ឯវេកធរិយា ទេវលោកំ វជន្តិ ពាលា មាវេនប្បសំសន្តិ
ធានំ ធីរោច ធានំ អមោទមានោ តេនេវ សោ ហោតិ

សុខី បរត្ថ

ជនពាលមិនដែលសរសើរទាន ជនពាលតែងមានចិត្តស្វាញស្ងួត
ទៅកាន់ទេវលោកមិនបានពិត ចំណែកបណ្ឌិតមានប្រាជ្ញា
ទើបអនុមោទនាទាន លោកវែមែងបានឋានសុខា
កន្លងលោកខាងនាយត្រែវតែការ អនុមោទនាទាននោះឯង ។

យស្មឹ ចាចានិ កម្មានិ សវេ កល្លោតំ វុច្ចតិ
ឋាបកម្មមានៅកន្លងចិត្តនរណា នរនោះឈ្មោះថាជាមនុស្សខ្សៅ
ជាមនុស្សខ្មោចជាមនុស្សទៅ ជាមនុស្សខ្សៅជាមនុស្សសេ្ងា ។

សុកភនិ អសាធូនិ អត្តនោ អហិតានិ ច
យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។

អំពើឯណាមិនល្អផង ដែលជាគន្ធនៃអបាយ
មិនមានប្រយោជន៍ដល់ចិត្តកាយ អំពើទាំងឡាយនោះឯងណា ។
ជនពាលតែងធ្វើបានដោយងាយ តែកម្មនោមនាយល្អថ្លៃថ្លា
មិនមានប្រយោជន៍ដល់អាត្ម ជនពាលមិនធ្វើបានក្រ ។

សុករំ សាធុនា សាធុ សាធុ ចារេន ទុក្ករំ
ចាបំ ចារេន សុករំ ចាបមរិយេហិ ទុក្ករំ ។

អំពើល្អធម៌សុចរិត សាធុបណ្ឌិតធ្វើបានងាយ
កល្យាណកម្មពាលទាំងឡាយ ខ្វល់ខ្វាយធ្វើបានដោយក្រៃក្រ
អំពើបាបជនបាបសាមាន្យ ធ្វើបានដោយងាយស្រួលកៃវ
បាបកម្មលាមកល្អក់ចរៃន ព្រះអរិយៈធ្វើបានក្រ ។

អរិសាធភាសិតនៃពាលបណ្ឌិតវគ្គ

គប់ប្រាជ្ញនាំប្រាណឲ្យបានសុខ គប់ពាលនាំស្តុកទុក្ខមកសង
គប់ប្រាជ្ញនាំឃ្លាតចាកបាបផង គប់ពាលសៅហ្មងជាប្រក្រតី ។
គប់ប្រាជ្ញនាំប្រាណទៅស្ថានសួគ៌ គប់ពាលនាំគួទៅអវិចី
គប់ប្រាជ្ញនាំប្រាណឲ្យបានថ្លៃ គប់ពាលចរៃនាំចោកឋាប ។
គប់ប្រាជ្ញនាំប្រាណឲ្យធ្វើបុណ្យ គប់ពាលទុជ្ជនានាំធ្វើបាប
គប់ប្រាជ្ញនាំប្រាណឲ្យបានសុភាព គប់ពាលចោកឋាបនាំហឺហា ។
គប់ប្រាជ្ញនាំប្រាណរក្សាសីល គប់ពាលខូចខិលនាំផឹកស្រា

គប់ប្រាជ្ញានាំប្រាណបានអាចារ្យ គប់ពាលមិត្តាកើតអាចារ ។
គប់ប្រាជ្ញានាំប្រាណឲ្យបានប្រាជ្ញ គប់ពាលអាចនាំឲ្យពាលោ
គប់ប្រាជ្ញានាំចិត្តគិតត្រូវធម៌ គប់ពាលនាំវង្វេចិត្តគិតខុស ។
គប់ប្រាជ្ញានាំចំរើនប្រយោជន៍ គប់ពាលនាំហោចហិនវិនាសពុះ
គប់ប្រាជ្ញានាំឲ្យសាមគ្គីស្មោះ គប់ពាលចិត្តទ្រុស្តនាំបែកបាក់ ។
គប់ប្រាជ្ញានាំឲ្យចេះអត់ធន់ គប់ពាលខ្ជិននាំកាប់ចាក់
គប់ប្រាជ្ញានាំឲ្យចេះទុកជាក់ គប់ពាលអប្បលក្ខណ៍នាំខ្ទេះខ្ទាយ ។
គប់ប្រាជ្ញានាំប្រាណខ្ពស់ជានិច្ច គប់ពាលនាំលិចលង់អន្តរាយ
គប់ប្រាជ្ញានាំទៅនិព្វានទាយ គប់ពាលនាំទៅអបាយភូមិ ។

ចប់ពាលបណ្ឌិតវគ្គ

បញ្ញាបវគ្គ

សព្វទាបិ ស្សុ អកាលំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ ។

ការមិនធ្វើបាបគ្រប់បែបយ៉ាង ការសាងបំពេញកុសលវត្ត
ការជម្រះចិត្តស្អាតម៉ត់ចត់ ទាំងនេះជាបទពុទ្ធសាសនា ។

(នៅមានត)

ពិធីបុណ្យស្រោចទឹក

លោកគ្រូអាចារ្យ ហង្ស-ប៉ែង

ដែលបានទទួលជាចៅអធិការនៃអនុគណ វត្តសិរីសុន្ទរវង្ស ឃុំ-ស្រុក-ខេត្ត-ក្រចេះ ។

កាលពីថ្ងៃ ៧-៨-៩ កើតខែអាសាធ ឆ្នាំឆ្លូវឯកស័ក ព. ស. ២៤៩២ ត្រូវនឹងថ្ងៃ ២-៣-៤ កក្កដា គ. ស. ១៩៤៩ មានរៀបធ្វើបុណ្យស្រោចទឹកប្រែគេនលោកគ្រូអាចារ្យ ហង្ស-ប៉ែង ដែលបានទទួលឋានន្តរៈថ្មី ជាចៅអធិការនៃអនុគណ សម្រាប់ស្រុកក្រចេះ ខែត្រក្រចេះ មានសមណសក្តិជាព្រះគ្រូសីលគន្ធប្បជ្ជោត ។

របៀបរៀបចំ

មានសាលាបុណ្យប្រក់ក្បឿងត្រឿងឈើទំហំបណ្តោយ ១៤ ម៉ែត្រ ទទឹង ១០ ម៉ែត្រ ដែលប្រតិស្ថានពីខាងទក្សិណនៃព្រះវិហារចំមុខព្រះចេតិយធំ ។ តួសាលានោះសឹងមានរំកាយសំពត់ដ៏តំនឹងផ្កាភ្ញីពុំដុំវិញ ហើយតែងស្ទឹកឈើមានពណ៌ក្រហម-ស-ខៀវ-បៃតងស្រស់ប្រិមប្រិយ៍, ស្រោបស្មុសរនឹងផ្ទោងផ្ទានសព្វអន្ទើ ចងពិតានតែងជារំយោលព្យួរសំយុងចុះរយោងរយានត្រង់ចន្លោះៗគ្រប់ល្វែងទាំងអស់គួរឲ្យអ្នកផងចាប់ចិត្តចង់មើលហើយមើលទៀត ព្រមទាំងដោតទង់ជាតិខ្មែរ-ចារាំងអមតាមលំដាប់ជួរទាំងនោះ ដើម្បីជាកិត្តិយសនៃពិធីបុណ្យ ។ នៅចំចន្លោះនៃ

ព្រះវិហារទើងសាលានោះ មានតាក់តែងពនមា ៤ ជាន់កំពស់ ៣ ម៉ែ ៥០ ទទឹងប្រាយជាបុស្សបុក មានកំពូលស្រួចខ្ពស់សម្រាប់ព្រះគ្រូសីលគន្ធប្បង្ហោតស្រង់ទឹក មានជណ្តើរពីរជាក់ទន្ទឹមគ្នា, ពីខាងកើតសម្រាប់ព្រះសង្ឃទើងមន្ត្រីខែត្រ ឡើងទៅស្រោចគន្ធភារី ។ តួពនមានោះសឹងពាសសំពត់សពន្ធដុំវិញគាំង ៤ ថ្នាក់, ក្នុងថ្នាក់ទីមួយៗមានរចនាក្បាច់ចាក់ចេកវិលចពណ៌ជាគ្រឿងលំអ ប៉ាងខាងទើងសុំទ្វារគ្រប់មុខទ្វារគាំង ៤ តាមជួរសសរ, ពីខាងលើសឹងពាសពិតានសំពត់សចងរំយោលផ្កា, រៀបធើងផ្កាជាគូៗ តែងត្រួងពនមាគាំង ៤ ជាន់ គួរជាទីរីករាយ ។ ឯថ្នាក់ទី ៣ ពនមាមានដំកល់តែវទឹក១ជាតែទឹក៤ដែលជាក់សុគន្ធភារី សម្រាប់តស្សរជនស្រោចទឹកទៅលើព្រះគ្រូសីលគន្ធប្បង្ហោត ដែលតងទៅក្នុងបុស្សបុកឈមព្រះភក្ត្រទៅឯបច្ចិមទិស ទទួលពរជ័យ ។ ព្រះសង្ឃសូត្រជយន្តោបេតនពេលនោះ ។ មានទិស័ទនដ្ឋាន ១ ទៀត ទៅពីខាងទិសអគ្នេយ៍ពនមា ដែលមានប្រដាប់ដោយគៅអីតមៀបជាជួរៗ សម្រាប់ព្រះសង្ឃតងសូត្រជយន្តោ ។ ប៉ាង ១ ទៀតទៅខាងលិចមុខពនមា សម្រាប់មន្ត្រីខែត្រ ។ ពេងប៉ាង ១ ទៀតទៅពីខាងចំពាយ័ត្យពនមា សម្រាប់ទទួលបរិស័ទ្យអ្នកមានសទ្ធាចូលបុណ្យ ។ ក្នុងប៉ាងទាំង ៣ នេះមានរបៀបតាក់តែងស្រដៀងសាលាបុណ្យនោះដែរ ។

កម្មវិធីបុណ្យ

ថ្ងៃទី ១ ម៉ោង ២០ ថ្ងៃសៅរ៍ ៧ កើត ខែអាសាធ ត្រូវនឹងថ្ងៃ ២ កក្កដា ឆ្នាំ ១៩៤៩, ដួចជុំពុទ្ធបរិសទ្យ ច្រើនណែនណាន់តាន់តាប់នៅសាលាបុណ្យ នឹងលានវត្ត ធ្វើនមស្សការចំពោះព្រះរតនត្រ័យ រួចនិមន្តព្រះសង្ឃ ៣០ អង្គចំរើនព្រះបរិត្ត ផ្សាយសំឡេងដោយឧគ្ឃោសនសព្ទ ពុំគឹកកងរំពងសព្ទសាយពេញទីអាកាស ។ ម៉ោង ១១ និមន្តធម្មកថិកសំដែងធម៌ទេសនាយ៉ាង ពីកេះក្បៃះក្បាយអំពីធម្មកថាជាច្រើននឹងរបៀបបុណ្យស្រោចទឹកលុះចប់ទេសនាក៏មានលេងល្បែងជាលំដាប់ហូរហែតទៅ ។

ថ្ងៃទី ២ ម៉ោង ៨ ព្រឹកពួកពុទ្ធបរិសទ្យចាត់ចែងយាគូប្រគេនព្រះសង្ឃ ៧៥ អង្គ ដែលនិមន្តមកពីវត្តក្រៅនឹងក្នុងវត្ត, ដល់ម៉ោង ១១ អង្គាសចង្ហាន់ព្រះសង្ឃ ។ ម៉ោង ១៧ ប្រគេនភេសជ្ជៈដល់ព្រះសង្ឃចំនួនដដែល ម៉ោង ២០ មានរបៀបចាត់ចែងដូចថ្ងៃទី ១ ។

ថ្ងៃទី ៣ ម៉ោង ៨ ចាត់ចែងយាគូប្រគេនព្រះសង្ឃ ៧៥ អង្គ រួចហើយដួចជុំបរិសទ្យ រៀបពិធីទទួលលោកចៅហ្វាយខែត្រ-ស្រុក ដែលអញ្ជើញមកជាអធិបតីក្នុងទុកាសបុណ្យ, ដល់ម៉ោង ៩, ១៥ នាទីពេលព្រឹក ៩ កើត ព្រះទេពសត្តា សូ-ហាយ ក្រុមដំទុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ, សូត្រសុន្ទរកថា បន្ទាប់ពីនោះព្រះសាសនមុនីមាស-កង ចៅអធិការវត្តពិកទួរង្សី ក្រុងកំពុងពេញ នឹងលោកចៅហ្វាយខែត្រ និមន្ត

ទឹងអញ្ជើញទៀងលើកាន់មាំ ស្រោចទឹកសុគន្ធរាវទៅលើព្រះគ្រូសីលគន្ធ-ប្បជ្ជោត, តពីនោះមានលោកគ្រូចៅអធិការចំនួន ១៧ វត្ត ដែលនិមន្តមកអំពីវត្តក្រៅ នឹងមន្ត្រីខែត្រ-ស្រុក ទៀងស្រោចជាលំដាប់តទៅ ។ ព្រះសង្ឃក៏សូត្រជយន្តោជាច្រើនចប់ក្នុងពេលនោះ លុះរួចកិច្ចស្រោចទឹកហើយ ទើបលោកចៅហ្វាយខែត្របានសញ្ជាប័ត្រតាំងពីរចំពោះទៅព្រះគ្រូសីលគន្ធប្បជ្ជោត ហង្ស-ប៉ែង រួចលោកក៏មានប្រសាសន៍ប្រគេនពរ ព្រមទាំងប្រកាសដល់ព្រះសង្ឃនឹងគ្រហស្ថអំពីកិច្ចតាំងចៅអធិការនឹងអនុគណដោយសង្ខេប ។

ម៉ោង ១១ អង្គាសចង្ហាន់ចំពោះព្រះសង្ឃ ៧៥អង្គជាកិច្ចបង្ហើយបុណ្យសម្រេចក្នុងពេលនោះ ។

សុទ្ធរកថា ទី ១

ព្រះករុណាទាំងឡាយគ្រប់អង្គ !

ព្រះតេជព្រះគុណចៅហ្វាយខែត្រ !

អស់លោក-អ្នកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណាអាត្មាភាពទាំងពីរូបនេះ នៅឯក្រុងកំពុតញ ជានមកកាន់ពិធីបុណ្យស្រោចទឹកនេះ ដោយកិច្ចនិមន្តនៃពុទ្ធបរិស័ទមកដំទួលព្រះតេជព្រះគុណព្រះសង្ឃនាយក ដើម្បីជាកត្តាក្នុងពិធីបុណ្យទទួលអំណរចំពោះព្រះគ្រូសីលគន្ធប្បជ្ជោតអនុគណស្រុកនេះ ដែលទើបនឹងជានហានៈជាចៅអធិការ, ជាអនុគណថ្មីៗ ។

អាត្មាភាពទាំងពីរបូបនេះ ឈ្មោះថាជាតំណាងព្រះនាមព្រះមហាសុ-
មេធាធិបតីសង្ឃនាយកមកបំពេញកិច្ចបុណ្យនេះ ដោយការណ៍ពិសេស ។
ខ្ញុំព្រះករុណាអាត្មាភាពបានមកឃើញពិធីបុណ្យនេះ ដែលពួកពុទ្ធបរិ-
សទ្យដើងវត្ត បានរៀបចំបុណ្យនេះឲ្យមានរបៀបរៀបរយល្អ មានកម្ម
វិធីដ៏ប្រសើរ ដែលគួរសរសើរដោយពិត ។

លោកគ្រូអាចារ្យ ហង្ស-ប៉ែង ដែលបានឡើងឋានៈជាចៅអធិការ,
ជាអនុគណ ក៏ដោយអំណាចសេចក្តីខ្នះខ្នែងរបស់ព្រះតេជព្រះគុណចៅ
ហ្វាយខែត្រនឹងចៅហ្វាយស្រុក ដែលបានចាត់ចែងតាមផ្លូវការដោយ
សេចក្តីស្រុះស្រួលអំពីពុទ្ធបរិសទ្យដើងវត្ត ។ ក្នុងពេលនេះព្រះតេជព្រះ
គុណចៅហ្វាយខែត្រ ចៅហ្វាយស្រុកក៏ធ្វើតរកគុកាសអញ្ជើញមកកាន់
ពិធីបុណ្យនេះ ដោយការសំដែងមិត្តភាពចំពោះពុទ្ធបរិសទ្យផង ដើម្បី
ជួយឈ្លឹងឆ្លាលបំពេញករណីយកិច្ចបុណ្យនេះផង ។ ការបុណ្យនេះឈ្មោះ
ថាជាកិត្តិយស ១ ដ៏ប្រសើរបស់ព្រះតេជព្រះគុណចៅហ្វាយខែត្រ ដែល
គួរចំណាំទុកក្នុងចិត្តយ៉ាងជាក់លាក់តទៅ "លោកគ្រូអាចារ្យអង្គនេះ
ដែលបានឋានៈជាចៅអធិការ, ជាអនុគណ ព្រមទាំងកិច្ចបុណ្យនេះ គឺនៅ
ក្នុងជំនាន់កាលដែលព្រះតេជព្រះគុណចៅហ្វាយខែត្រ ចៅហ្វាយស្រុក
មកឈរនៅខែត្រនេះ" ។

ក្នុងឱកាសបុណ្យនេះខ្ញុំតក៏ព្រះតេជព្រះគុណ មានអធ្យាស្រ័យទុកជាក់ជាន់ចាត់ការឲ្យលោកអ្នកក្រុមនគរបាលមកថែរក្សា សន្តិសុខរៀងរាល់យប់ ។

អាត្មាភាពទាំងពីរូប ដែលមកពីកំពេញឃើញការនេះក៏មានចិត្តត្រេកអរសាទរជាទីបំផុត ។

សូមជូនពរ ៤ ប្រការ ចំពោះព្រះតេជព្រះគុណនឹងអស់លោកអ្នកមន្ត្រីគ្រប់គ្នាសូមឲ្យបានចំណែកបុណ្យនេះស្មើៗគ្នា ។

អំពីតាំងចៅអធិការថ្មី

(តមក)

សញ្ញាប័ត្រលេខ ២៦៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ផុក - គេង នាមធាយ៉ា ឥន្ទជោត កើតឆ្នាំរោង អាយុ ៤៥ វស្សា ២៤ ជាចៅអធិការវត្តកំពង់សាលា ឃុំរំចេក ស្រុកចាំក្នុំ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៦៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែ - មៅ៉ល នាមធាយ៉ា ធម្មសរ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣៣ ជាគ្រូសូត្រស្តាំ វត្តបល្ល័ង្ក ឃុំពង្រ ស្រុកវាលវែ្ង ខេត្តកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ២៦៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ធាយ - លឿង នាមធាយ៉ា សន្តមប្បញ្ញោ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣២ ជាគ្រូសូត្រឆ្វេងនៅវត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ២៦៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈាង - សាម នាមធាយ៉ា កេសរសិរិយសត្ថេរ កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣២ ជាចៅអធិការវត្តពោធិវន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ២៦៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុំ - ផេង នាមធាយ៉ា ជោតសន្តមត្ថេរ កើតឆ្នាំកុរ អាយុ ៥០ វស្សា ៣០ ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ២៦៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខូច - ឆៃហោង នាមធាយ កេសរជោត កើតឆ្នាំកុរ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រធ្វេងនៅវត្ត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម - ឌុន នាមធាយ មង្គលជោត កើតឆ្នាំរកា អាយុ ៤០ វស្សា ១៥ ជាចៅអធិការវត្តញាណពោធិ ឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខែត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ២៧០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ - ថោង នាមធាយ ព្រហ្មត្រេរ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៨ ជាចៅអធិការវត្តលើន ឃុំលើន ស្រុកស្វាយរៀង ខែត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៧១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ុម - ឌួន នាមធាយ ចន្ទត្រេរ កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៥ ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មៅ - កែន នាមធាយ យសត្រេរកើតឆ្នាំថោះអាយុ ៤៦ វស្សា ២៥ជា គ្រូសូត្រធ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស - ហុម នាមធាយ ធម្មជោត កើតឆ្នាំវក អាយុ ២៩ វស្សា ៨ ជា

ចៅអធិការវត្តពេជ្រមន្ត្រី ឃុំប្រែសូត ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៧៤ ចុះគាល់បរិច្ឆេទជវៃល តាំងលោកគ្រូ អ៊ុក - សែម នាមធាយ៉ា ចន្ទត្ថេរ អាយុ ៣០ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្ត ឃុំ - ស្រុក - ខេត្តជវៃល ។

សញ្ញាប័ត្រលេខ ២៧៥ ចុះគាល់បរិច្ឆេទជវៃល តាំងលោកគ្រូ ម៉ុម - អុក នាមធាយ៉ា ឥន្ទត្ថេរ អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តជវៃល ។

សញ្ញាប័ត្រលេខ ២៧៦ ចុះគាល់បរិច្ឆេទជវៃល តាំងលោកគ្រូ ទិត - ឥន នាមធាយ៉ា ធម្មប្បញ្ញោ អាយុ ៥៤ វស្សា ៣៤ ជាចៅអធិការ វត្តព្រៃឆ្នូក ឃុំស្វាយតាយាន ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៧៧ ចុះគាល់បរិច្ឆេទជវៃល តាំងលោកគ្រូ ទិត - យូ នាមធាយ៉ា សុវណ្ណត្ថេរ អាយុ ៣០ វស្សា ៨ ជាគ្រូសូត្រ ស្តាំ នៅវត្ត - ឃុំ - ស្រុក ខេត្តជវៃល ។

សញ្ញាប័ត្រលេខ ២៧៨ ចុះគាល់បរិច្ឆេទជវៃល តាំងលោកគ្រូ ម៉ម - ខាត់ នាមធាយាធម្មនន្ទោអាយុ ២៤ វស្សា ៤ ជាគ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តជវៃល ។

សញ្ញាប័ត្រលេខ ២៧៩ ចុះថ្ងៃចន្ទ ១០ កើតខែកត្តិកឆ្នាំជូតសំរឹទ្ធិ-ស័ក តាំងលោកគ្រូដុំ - នោម នាមធាយាសុវណ្ណត្ថេរ កើតឆ្នាំខាលអាយុ

៤៧ វស្សា ២៥ ជាចៅអធិការវត្តពោធិ៍បន្ទាយ ឃុំប្រសូត ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចិន-ស្រី នាមធាយា សុវណ្ណសរ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាចៅអធិការវត្តព្រៃអង្គ ឃុំប្រសូតស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ធាំ នាមធាយាសុវណ្ណជោត កើតឆ្នាំខាល អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ដដែល ។

សញ្ញាប័ត្រលេខ ២៨២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ា-ហុង នាមធាយា ឥន្ទវត្ថេ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១១ ជាចៅ-អធិការ វត្តព្រៃអង្គុញ ឃុំច្រកមូស ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈុន-ជិង នាមធាយា មង្គលសរ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-គោន នាមធាយា មង្គលត្ថេរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ រ័ណ-ថន នាមធាយា ធម្មត្ថេរ អាយុ ៣៧វស្សា ១៥ ជាចៅអធិការ វត្តព្រៃគគីរ ឃុំព្រៃគគីរ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-វង់ នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រស្តាំ នៅវត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គិម-កែន អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់-ហែម នាមធាយា ចន្ទាភោ កើតឆ្នាំ ១៩២២ អាយុ ២៦ វស្សា ៥ ជាចៅអធិការ វត្តព្រៃម្នាស់ ឃុំសំរ៉ី ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-ង៉ាន់ នាមធាយា ញាណសំវរោ កើតឆ្នាំ ១៩២២ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឡឹក-សារី នាមធាយាធម្មត្ថេរ កើតឆ្នាំ ១៩២៧អា យុ ២២ វស្សា ២ ជាគ្រូសូត្រឆ្វេង នៅវត្តឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-យូរ នាមធាយា វត្តត្នេរ កើតឆ្នាំច អាយុ ៥១ វស្សា ៣០ ជាចៅអធិការ វត្តតាចុ" ឃុំសំឡី ស្រុកស្វាយចាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៩២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-យ៉ែម នាមធាយា ធម្មជោតោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជា គ្រូសូត្រស្តាំ នៅវត្ត-ឃុំ--ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថែន-យាង នាមធាយា ធម្មបណ្ឌិតោ កើតឆ្នាំខាល អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង នៅវត្តឃុំ--ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រាប-មឿង នាមធាយា តន្ទុត្តរោ កើតឆ្នាំមមែ អាយុ ៤២ វស្សា ២២ ជាចៅអធិការវត្តព្រៃខ្ចូត ឃុំច្រែស ស្រុកស្វាយចាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៩៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អុក-អ៊ូនាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១១ ជាគ្រូសូត្រស្តាំនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ថេរ នាមធាយា សីលវិសុទ្ធោ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេង នៅវត្តឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-អៀង នាមឆាយា សិក្ខានន្ទោ កើតឆ្នាំរកា អាយុ ២៩ វស្សា ៧ ជាចៅអធិការ វត្តជ័យវតន: ឃុំជ្រាប ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២៩៨ ចុះថ្ងៃសុក្រ ១៤ កើតខែកត្តិកឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ស្វាយ-អ៊ិម នាមឆាយា វជិរប្បញ្ញោ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៩ ជាចៅអធិការ វត្តសំពៅមាស ឃុំលេខ ៥ ក្រុងកំពង់ពេញ ។

សញ្ញាប័ត្រលេខ ២៩៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ផៃ-ម៉ៃ នាមឆាយា មេធាធិម្មោ កើតឆ្នាំមមែ អាយុ ៤២ វស្សា ២០ ជាគ្រូសូត្រស្តាំនៅវត្ត-ឃុំ-ក្រុងដដែល ។

សញ្ញាប័ត្រលេខ ៣០០ ចុះថ្ងៃចន្ទ ២ កេចខែកត្តិកឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ គិម-អ៊ឹង នាមឆាយា ឥន្ទធម្មោតេ្ឋ កើតឆ្នាំកេង អាយុ ៥៧ វស្សា ៣២ ជាចៅអធិការ វត្តអម្ពវនារាម ឃុំស្វាយសាច់កុំ ស្រុកស្រីសុន្ទរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៣០១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យង់-កែក នាមឆាយា ឥន្ទជោត កើតឆ្នាំកេង អាយុ ៣៣ វស្សា ១១ ជាចៅអធិការ វត្តស្វាយអៀ ឃុំចំណារ ស្រុកស្អាង ខេត្តកំពង់ធំ ។

(មានត)

កម្ពុជសុរិយា

DU DÉPÔT LÉGAL

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀមវប្បធម៌ ប្រៀបធៀបភាសា
អំពីពុទ្ធសាសនាឥណ្ឌូស្ថាន

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ៖ ហ្វង់ទំនៀងន្ទ្រី ញ៉ុក-ថែម, បណ្ឌិត ម៉ៅ
-ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា៖ ព្រឹះទេវសន្ត សួរ-ហាយ
ព្រុមដងពុំព្រះថ្លៃចំនិក ម៉ៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
លោក ភាយ-ប៊ុក ព្រុមការ	សុភាសិតខ្មែរកោតទី ២ (តទៅ)	៥៦១
មហា ខម-ណាត្រី	ទំនាយសុភាសិត	៥៦៤
សាមៈណេរ ព្រាប-ឆិប	រៀងល្បែងប្រជែងក្នុងភាសាខ្មែរ	៥៧៤
ហ្វង់ទំនៀងន្ទ្រី ញ៉ុក-ថែម	ស័ព្ទបរិភាសខ្មែរបច្ចុប្បន្ន (តទៅ)	៥៨២
—	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសជប៉ុន (តទៅ)	៥៨៩
អ្នកឧកញ៉ា ព្រះឃ្លាំងខេត្ត	រឿងកោតក្លាហានរបស់ពលទាហានក្លាហាន (តទៅ)	៥៩៨

ផ្នែកសាសនា		
ហ្វង់ទំនៀងន្ទ្រី ញ៉ុក-ថែម	ពន្ធអាស៊ីទ័ប (តទៅ)	៦០៩
មហាខម-ណាត្រី	ម៉ូទីសុភាសិត (តទៅ-ចប់)	៦១៥

កំណាត់មតិប្រវត្តិការណ៍		
ព្រឹស្ទសាសនធម្មការ	បញ្ជីរាយនាមបើកអធិការដែលតាំងថ្មី (តទៅ)	៦២៩

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
M. Ray-Buc kramkar (I.B.)	Proverbes et maximes Tome II (suite)	561
Mahâ Om-Nagry	Nidânasubhasit.....	564
Sâmner Preap-Dip	Course de piroque.....	574
Luong Nibandhamantrî Nhok-Thêm	Traduction du Commission culturelle	582
—id—	Histoire sommaire de l'Inde (suite)..	589
Neak Oknha Brah Khleang Nong	Bhog kulkumar (en vers) (suite)....	598

Partie religieuse:

Luong Nibandhamantrî Nhok-Thèm	Lumière de l'Asie (suite).....	609
Maha Om-Nagry	Munisubhâsit (suite et fin).....	617

Notes et chroniques

Ministère des cultes	Nomination des nouveaux chau Adhikar (suite).....	629

21e Année: No 8 Août 1949 — Prix d'abonnement: 96$00 par an.

OTHÈQUE
IONALE
AMBODGE

CENTRE NATIONAL DE DOCUMENTATION & D'EDITION
BIBLIOTHEQUE
Inventaire សុភាសិតកាត់ជីវ ៤.៥.៦៣
លោក កុយ - បុក ត្រមក្សារលេខ ២ រៀបរៀង
CDU (គម្ពក) Côte

២ .– បណ្តាំតវត្តិ

១ – ចូរកែតូចល្អ សាបត្រែនទុកគត ទៅអនាគត បើដីមានដី ឲ្យផលចំហុត ច្រូតកាត់ធាប់ធុត ផុតភ័យអន្តរាយ ។

២ – មនុស្សក្នុងភូមិភព ច្បាច្បាប់ស៊ីប់ ត្រង់ទៅនិព្វាន ត្រូវស្គាល់លោកមុន មនោមុតក្លាហាន ស្នេហ៍ជាតិកល្យាណ ខើបយល់ធម្មា ។ កាប់គាប់ដីតគាស់ កង់កម្មកិលេស វដ្តសង្សារ ឃើញច្បាស់ខ្លួនឯង ក្លីខែងធម្មា សម្ងាប់តណ្ហា អវិជ្ជាផុតជាតិ ។ ច្បាជ្ញាញ្ញេយ្យញ្ញាណ ចាក់ផ្ទុះតាមស្ថាន ពុទ្ធៈនុវាទ ជាតិធម៌បើឃើញ បណ្ឌិតនុហាត វត្តុលោកខ្ចាត ខះខាតមិនស្គាយ ។

៣ – បណ្តាបុណ្យទៃញ ឯបុណ្យគួរគាប់ មិនមានអន្តរាយ សម្បត្តិទៃញច្បាក់ ចោរលួចខ្ចាត់ខ្ចាយ មិនបានវែងឆ្ងាយ បានតែមួយជាតិ ។

៤ – បុណ្យត្រែជាក់ចិត្ត ម្ចាប់ឈើតាមពិត ត្រែជាក់អ្នកជែក ច្បាបឲ្យក្តៅមនោ ចេះគួរលៃលក ភ្លុំឲ្យច្បាបមក ពាក្យឯហប្ញទ័យ ។

៥ – ក្តីទុក្ខសព្វសត្វ សឹងមានច្បាកដ គ្មានថ្នាំក្រៃច្បាណ

ឧសថកងខ្លួន ទើបតែសុំខមាភ្ជ ចិត្តស្ងប់សម្រាន្ត ជាថ្នាំថ្លៃថ្លា ។
ចិត្តជាមេទ័ព ត្រូវប្បាំងប្រាប្ត ខប់ទល់អន្ធការ បើចិត្តក្លាហាន មិនចាន
ញញើត ដល់តេលក្តា កក្តាញញឹម ។

៦ — បើប្រាថ្នាត្រួតប្រទេសជាតិ ត្រូវខិញ្ចឹងតហាត់ចិត្តខ្លួន ក្នុង
ការរៀនវិទ្យាឲ្យមួន ទើបគ្រប់គ្រងសួនពស្ត្រដោយស្រួល ។

៧ — ពត់កដាលំអនកាល័យ បុប្ផាក្នុងវៃលំអត្រីកា រលក
លំអនៃសាគរ គោរពកស្តាលំអនៃស្រី ។ ពជទសពិធធម៌លំអស្តេច
ស្តុមដោយស្មាធ៌កិច្ចលំអតសី សិក្ខាបទលំអសង្ឃព្រះជិនស្រី ប្រុស
កាឡីលំអដោយវិជ្ជា ។ ពេលថ្ងៃលំអនៃព្រះអាទិត្យ ពេលយប់
ឆ្នឹតលំអបន្ទាល់ អំពើចុបជាលំអភួកតាលា កុសលធម្មាលំអភួក-
សប្បុរស ។

៨ — អំពោរសផ្ទៃមរិសេសណាស់ ផ្ទៃមស្រីស្អាតល្អរលើសអំពៅ
សុភាសិតបណ្ឌិត្យពោលប្រដៅ ផ្ទៃមលើសអំពៅនឹងស្រីល្អ ។

៩ — ជនត្រកូលខាបត្រូវខ្ជាត់ក្រ ចង់ឮសរសើរញាប់លើសលែង
ជនខ្លាយកម្ចាំងចង់ខាតបែង ជនល្ងង់ខំស្វែងអ្នកបរាជ ។
ជនបីពួកនេះត្រូវតាមស្មោក ថាហ៊ានជ័យជោគអង្គអាត្ម អ្នកឆ្លងមិន
គួរប៉ង់ប្រាថ្នា យកជាតម្រាតម្រាប់ឡើយ ។

១០ - ស្រីគ្រែម៉ុំកុំប្រកាសខ្លួនខើបល្អ
ចន្ទ្រាចរកង្គតីខើបក្លឹប្បាស់
មន្តវិជ្ជាអួតខ្លួនវែងថោកណាស់
ធម៌ប្រកាសខើបគ្រែចរគុណបវរ ។
ព្រះអាទិត្យសោភ័ណពិតតែពេលថ្ងៃ
ទិដ្ឋិគ្រែដែលអាគ្រែកន់បើកមិនល្អ
ជាតិប្រទេសភាំងសាស្ត្រាលើកបវរ
ព្រោះជាធម៌តែងតាក់ទងដល់កូនយើង ។

១១ - ឈ្នះអ្នកស័ក្តិខ្ពស់ដោយលុតគ្រាប ឈ្នះអ្នកទន់ខាបដោយឲ្យទាន បំបែកសាមគ្គីឈ្នះអ្នកក្បាហាន ឈ្នះអ្នកស្មើប្រាណដោយតស៊ូ ។

១២ - ចង់ជនលោកដោយឲ្យធនធាន ចង់ប្រាជ្ញកល្យាណដោយពាក្យសត្យ ចង់អ្នកៈធ្មឹងធ្មែងដោយប្រណិប័តន៍ ចង់អ្នកល្ងង់ក្តាត់ដោយបណ្តោយតាម ។

១៣ - ផ្តាញ់អ្នកគ្រោធដោយក្តីមិនគ្រោធ ផ្តាញ់អសប្បុរសពាលាដោយក្តីល្អ ផ្តាញ់អ្នកកំណាញ់ដោយឲ្យទេយ្យធម៌ ផ្តាញ់អ្នកកូតករដោយពោលពាក្យពិត ។

១៤ - អាវុធស្តេចស្រែចនៅព្រះឧង្ការ អាវុធសមណាគឺសច្ចៈ អាវុធសេដ្ឋីគឺមាសប្រាក់ អាវុធអ្នកក្លឹកគឺកម្លាំង ។

(មានត)

"កាមជាតហេតុ"

មហា ឧម-ណាគ្រី

ឃុំស្វាយចេក ស្រុកសង្កែ ខេត្តបាត់ដំបង ខែធ្នូ ឆ្នាំ ២០០៤

ក្នុងកាលដ៏កន្ទុងយូរលង់ ព្រះពុទ្ធជាក្រុងពារាណសីមួយអង្គ ខ្ញុំ
លុះក្នុងអំណាចសេចក្តីប្រាថ្នា ខ្ញុំមិនឆ្អែតឆ្អន់ល្មមគាន់ក្នុងព្រះពុទ្ធ-
ទ័យចំពោះរាជសម្បត្តិដែលខ្ញុំគ្រប់គ្រងនោះឡើយ ខ្ញុំមានសេចក្តី
លោភចង់បានរាជសីមាអាណាចក្រឯទៀត ។ មិនមានកំណត់ ។

ក៏ក្នុងកាលនោះ ព្រះពោធិសត្វឧប្បត្តិកើតជាសក្កទេវរាជ កាល
ខ្ញុំរំពឹងរំពៃលៃគំនិតគិតមើលការប្រព្រឹត្តទៅនៃមនុស្សនិករក្នុងមនុស្ស
លោកដោយទិព្វនេត្រ ខ្ញុំជ្រាបហេតុក្តីបំណងនៃព្រះពុទ្ធនោះហើយ
ទើបខ្ញុំគិតរិះថា "បើអាត្មាអញ ព្រងើយកន្តើយហើយ លោកសន្ទាំង
ភ័ន្ធក្តៅក្រហាយ ព្រោះសេចក្តីប្រាថ្នារបស់ព្រះពុទ្ធអង្គនេះមិនខាន,
បើដូច្នេះអាត្មាអញនឹងទៅផ្ញើផ្ញាល់ព្រះអង្គឲ្យខ្ញុំអៀនខ្មាស ហើយឲ្យ
រម្ងាប់ព្រះហឫទ័យនោះ បែរឆ្ពោះមកកាន់សេចក្តីសួរវិញ" ។

កាលខ្ញុំតម្រិះយ៉ាងនេះហើយ ទើបខ្ញុំហោះចុះមកដោយក្តែងកេង
ជាព្រាហ្មណមាណព ចូលទៅគោរពគាល់ព្រះពុទ្ធជាក្រាបទូលថា" សូម
តេជៈ ! ខ្ញុំព្រះអង្គបានដើរទៅឃើញនគរទេត្តរបញ្ចាល, នគរតន្ទបព្ភនឹងនគរ

សាកែត; ពួជនាទីនាំងឮនេះ សឹងតែញៀវដោយសេចក្តីសុខស្រួលណុក
ក្សេមក្សាន្តសប្បាយ ឆ្អែាហារគាំងឡាយ កំបរិបូណ៌ពោរពេញឥតខ្វះ
ខាតនាំងពលដំរី ពលសេះ ពលរទេះ ពលថ្មើរជើងក៏មានគ្រប់គ្រាន់
អាចចេញតតាំងច្បាំងនឹងបច្ចាមិត្រឲ្យានគ្រប់វេលា នាំងសម្បូណ៌ដោយ
សម្បត្តិយ៉ាងសម្បើម មានមាសប្រាក់លុយកាក់តែវែកឆ្ងាដើម ។ បើ
ព្រះអង្គមានព្រះពួជបំណងចង់ឲ្យានឧត្តមនាំងនោះ ខ្ញុំព្រះអង្គនឹងសូមព្រះ
ពួជទានពលត្រឹមបន្តិចបន្តួចប៉ាប់ងន្តួល យកអាសាទៅរបាន់ដណ្តើម
យកឧត្តមនាំងនោះឲ្យឲ្យានដោយឆាប់ឆាយ ហើយនឹងលើកថ្វាយដល់
ព្រះអង្គ " ។

ព្រះពួជាកាលត្រង់ជ្រាបថា នឹងឲ្យានឧត្តមនាំងមួនាំងនោះ ក៏
ត្រង់សោមនស្សចុះព្រះហឫទ័យ យល់ព្រមឲ្យព្រាហ្មណ:មាណពនោះនាំ
នាំងទៅច្បាំង កំណត់វេលាលើកទាំពទៅកងថ្ងៃរះឡើង ។ តែត្រង់
ភ្លេចមិនឲ្យានព្រះពួជាននិវេសនដ្ឋាន កន្លែងសំណាក់អស់រយៈនឹងស្បៀង
អាហារដល់ព្រាហ្មណ:មាណពនោះសោះ ។

លុះថ្ងៃរះឡើង ព្រះអង្គត្រង់មានព្រះពួជឧង្ការឲ្យតែ:ម្រាបពលឲ្យ
ជាត់ទាំពយ៉ាងស្រេច ត្រាស់ឲ្យអាមាត្យាធិបតីនាំងឲ្យាយចូលគាល់
ត្រាស់ឲ្យសន្យាដែលត្រង់សន្ធិដ្ឋានឧនឹងព្រាហ្មណ:មាណព ដោយសព្វ
គ្រប់ ឧនឹងត្រាស់ឲ្យហៅមាណពនោះចូលគាល់ ។ លំដាប់នោះ ក៏

ត្រូវអាមាត្យាធិបតីទាំងឡាយទូលតឿនឲ្យទ្រង់រលឹកដល់គារវៈដែលមុំនឹងបាន
ប្រទានទៀវេសនដ្ឋានទឹងស្បៀងអាហារ ដល់ព្រាហ្មណ:មាណពនោះ
ព្រោះដូច្នោះ កាលអាមាត្យាធិបតីទូលសួរ ក៏ទ្រង់មិនអាចធ្វើបាបបានក្នុង
ទីបំផុតទ្រង់បង្គាប់ធ្វើបាបឲ្យទៅតាមរកព្រាហ្មណ:មាណពគ្រប់ផ្លូវថ្នល់ច្រក
ល្អកផ្សេង ។ ក្នុងទីក្រុងតែមិនប្រទះសោះ ។

ព្រះរាជាគ្រាទ្រង់ជ្រាបថា មិនឃើញព្រាហ្មណ:មាណពនោះ ក៏អន់
ព្រះហឫទ័យយ៉ាងខ្លាំង ទ្រង់កើតទោមនស្សទុក្ខមួញពេញទៅដោយសោក
ស្តាយយ៉ាងលើសលុបលើសលន់ថា " ឪ ! តស្សរិយយ:ដ៏ឧស្ម័មហិមា
ដែលអាត្មាអញសំដៅប៉ងបំណងទុកមក វិនាសទូចអស់ហើយហ្ន៎ !! " ។
ទ្រង់មានព្រះរាជហឫទ័យខ្វក់ខ្វល់ ក្រហល់ក្រហាយសោកស្តាយព្រោះ
សេចក្តីប្តូរប្តាច់ រហូតដល់ឆ្កាត់ព្រះលោហិតយ៉ាងខ្លាំង បណ្តាល
ទៅជាបក្ខន្ធិកាពាធ គឺឈឺឆ្កាត់ឈាមពាសពាត់ ពួកពេទ្យមិនអាចចែវក្សា
ឲ្យសះជាបានព្រោះជារោគចំពួតតរយើញស្មុកស្មាមអ្វីបន្តិចឡើយ ។

សម្តេចសក្កទេវរាជ ទ្រង់ពិចារណាឃើញថា " តឡូវនេះអាការ
ប្រឈួនព្រោះសេចក្តីប្តូរប្តាច់របស់ព្រះរាជាកើតឡើងហើយ ល្មមដល់ការ
ដែលអាត្មាអញនឹងធ្វើយដម្បូន ឲ្យទ្រង់ភ្លក់កំណើតកើតគំនិតយើញ
ត្រមក្រកន្លងស្ងួបវិញ " ។ ទើបស្តេចទ្រង់យាងមកដោយភ្លែងកេរជា
ព្រាហ្មណ៍ចូលទៅធានាទំនួលក្នុងការក្សាព្រះរាជាពាធ មុនដំបូង

ព្រះរាជាត្រាស់នឹងអាមាត្យថាពេទ្យមុន ។ ទាំងអស់ មិនអាចកែទៃដម្បី
នេះបាន ព្រាហ្មណ៍នោះនឹងថែរក្សាដូចម្តេចកើត ? ចូរឲ្យវង្វាន់ហើយ
បង្គាប់ឲ្យត្រឡប់ទៅវិញចុះ ។ ទើបព្រាហ្មណ៍ក្រលេបបថា មិនចង់បានវង្វាន់
អ្វីឡើយ គឺមានសេចក្តីតាំងចិត្តនឹងថ្វាយការរក្សាព្យាបាលពេតតែម្យ៉ាង
ប៉ុណ្ណោះ ។ ត្រាព្រះរាជាទ្រង់អនុញ្ញាតហើយ ទើបក្រាបទូលសួរអាការៈ
សម្បជ្ញានៃពេត ព្រះរាជាត្រាស់ឲ្យស្តាប់ដោយសំឡេងត្រចៀក ហើយត្រាស់
អញ្ជើញព្រាហ្មណ៍ឲ្យជាក់ទុសចដោយគាថាថា :

ទីក្រុងដែនទាំងប៉ា ឮឃ្លាតខ្ញុំបាច្ចាមក
បញ្ចាលនឹងកេកក , ក្បុរពជានី ។
ជាងខោះណាព្រាហ្មណ៍ណា ខ្ញុំបាច្ចាយ៉ាងពេញចិ
អញ្ជើញជាក់ថ្នាំតាមពិធី ចិត្តវាក់វែកាមទាំងឡាយ ។

មាណពទើបទូលថា អាការដែលខ្ញុំប្រឈួនខេះ ទឹងថ្វាយការ
រក្សាដោយទុសចធម្មតាមិនបានទេ តែនឹងសូមថ្វាយការរក្សាដោយទុសច
ម្យ៉ាងគឺញាណហើយក្រាបទូលដោយគាថាជាសុភាសិតថា :

បើតស់ចឹកគង់ពេទ្យតស់ចេះឆ្លៀវឆ្លៀ គឺជាក់ថ្នាំរម្ងាប់តិសកំណាចបាន
បើខ្មោចធ្វើគង់គ្រូខ្មោចចេះលំអាន កែទៃបានដោយអាគមមន្តគាថា ។
ឯចំណែកបែកដម្បីឈឺព្រោះកាម ចិត្តរហាមតាមចំណង់នៃតណ្ហា

តើសំដៅទៅស្មាកស្មាមកន្លែងណា នរណាហ្ន៎អាចដាក់ថ្នាំជម្ងឺចិត្ត
ដល់ជនល្មើសធម៌នោះកើត? ។

ឥន្ទ្រីពាហ្មណ៍ កាលសំដែងដូចនេះហើយ ទើបពោលតទៅឲ្យទ្រង់
ជ្រាប ដោយព្រះអង្គឯងថា "មហាវាជ! មិនគួរឡើយដែលទ្រង់គ្រាន់
តែឮសូរសៀងសំនៀងសំដីថ្នាក់តែមប៉ុណ្ណោះ ក៏ចុះព្រះទ័យលែបំណង
ប៉ងថ្នាក់ការក្នុងលោកឲ្យដោកដល់ម្ល៉ះទេ នេះព្រោះសេចក្តីថ្នាក់ទើប
ក្លាយទៅជាសមុដ្ឋាននៃការប្រឈួនដ៏ខ្លាំងក្លាស៊ើរនឹងអស់ព្រះជន្ម សូម
ព្រះអង្គទ្រង់រំពៃរំពឹងពិនិត្យគិតមើលដោយព្រះអង្គឯងចុះថា ព្រះអង្គទ្រង់
ថ្នាក់ពាជសម្បត្តិខាងប៉ុណ្ណោះយកមកធ្វើម៉ច? បើប្រសិនជាទ្រង់ថាន
គ្រប់គ្រងរាជសម្បត្តិកន្លងមកខាងនោះទ្រង់នឹងបរិភោគឧបភោគខាងឡាយ
លើសពីមួយផ្នែកទៅឬ? ព្រះអង្គទ្រង់សោយក្រយាស្ងោយមិនហួសពី
មួយផ្នែកដោយពិត មិនគួរតាំងព្រះទ័យឲ្យថ្លៃរង្គោយទៅក្នុងអំណាច
តណ្ហាឬកាមគឺចំណង់ការបង់នេះឡើយដែលឈ្មោះថាកាមឬតណ្ហានេះ ជា
មូលនៃវិបត្តិគ្រប់ប្រការ កាលចំរើនកើនឡើងស៊ើរូបណា រមែងធ្វើនរៈនោះ
ឲ្យឋានទទួលទុក្ខទោសខាងក្នុងលោកនេះ ដូចទ្រង់ថានជួបប្រទះក្នុង
ពេលនេះឯង ខាងក្នុងលោកខាងមុខ អាចនាំទៅសោយទុក្ខក្នុងអបាយ
មាននរកជាដើម" ។ ឥន្ទ្រីពាហ្មណ៍ថានសម្តែងអំពីកាមទីនវាទោស និង
ពណ៌នាគុណនៃការសូបថាកកាមឲ្យទ្រង់ជ្រាបដោយច្បាស់លាស់ ។

ព្រះពុទ្ធាគាល ទ្រង់សង្វេគាវពោក្យតទៅទៀតដោយនិរយ៍ភ័យ ព្រមទាំងនរ៍ទនោះហើយ ក៏ទ្រង់កើតព្រះប្រាជ្ញាញាណគឺសេចក្តីដឹងច្បាស់ឡើងភ្លាម ប្រាជ្ញាញាណនោះ ខុកដូចជាទុសថយ៉ាងវិសេស កំចាត់សោកឲ្យបាត់ប្រឈួនក្នុងខណៈនោះឯង ។ តអំពីនោះ ក៏ទ្រង់លះលែងសេចក្តីប្រាថ្នាឈប់យាត្រាលើកទ័ពទៅញាំញីរដ្ឋសីមាអាណាចក្រដទៃ។ ទ្រង់ពេញព្រះហ្ឫទ័យក្នុងឯកជសម្បត្តិរបស់ព្រះអង្គ ទ្រង់បំពេញកុសលចរិយាផ្សេងៗ នឹងគ្រប់គ្រងប្រជាជនដោយធម៌ ស្រុកទេសក៏ចំរើនរុងរឿងសុខសាន្តបានសប្បាយគ្មានខ្វល់ឈឺតរៀងទៅហោង ។

(រឿងនេះប្រែពីភាសាមគធតសុត្តជាតក ខុទ្ទនិកាយ ខុទ្ទកនិកាយ)

គតិរបស់រឿង

រឿងនេះ ប្រាន់គតិដែលគួរគិតយ៉ាងនេះ

១ - ក្តីបំណងប៉ងប្រាថ្នា តម្រេកត្រេកត្រអាល ស្រើបស្រាលតក់ស្លុតខ្លាច រំភើបញាប់ញ័រកក្រើកខ្វើតតាមឲ្យល់ខ្យល់តាមលេកហៅថា "តណ្ហា" ជាសភាវៈឥតមានរូបកាយវៀសណ្តានទ្រង់ឲ្យយ៉ាងនេះយ៉ាងនោះទេ គ្រាន់តែជានាមធម៌ សម្រាប់កសាងកំណើតឲ្យសត្វកើតក្នុងភពបីជាថ្មីទៀតច្រើនកប់មិនបានប្រមាណមិនអស់ ; ជាសភាវៈជក់ជិតជិត ជាប់នៅក្នុងចិត្តគំនិតរបស់មនុស្សសត្វទេពតាខ្លួនឯង នាំឲ្យត្រូវការចំណង់ចង់បានវត្ថុតាមនឹងកិលេសកាម គឺ រូប សំឡេង ក្លិន រស

សម្ផស្ស សក្តិយសកេរ្តិ៍ឈ្មោះ ទ្រព្យសម្បត្តិ អាយុ ពណ៌ កំឡាំងនឹង សេចក្តីសុខ ។

២ — ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់តាមពិតថា មនុស្សសត្វទេពតា ទាំងអស់សុទ្ធតែលិចលង់ទៅក្នុងទន្លេតណ្ហាជានិច្ច ចង់បាននេះ ចង់បាន នោះ មិនឈប់ឈរ មិនឆ្អែតឆ្អន់ មិនគប់គ្រាន់ មិនធុញទ្រាន់ មិន ជំនុំណាយ បានហើយចង់បានទៀត ឆ្កៀតរកមកបន្ថែមគ្មានផ្សះបន្ធូរ បន្ថយដោយមិនចេះឆ្អែតស្កប់ ។ រត់តាមនឹងតំណៃសកាម ដែលរក បានមកមិនមែនយកទៅណា គឺត្រូវការបំពេញបំពោកបំពោរកាយឲ្យ សប្បាយជល់ចិត្តប៉ុណ្ណោះ ខ្លះក្អែកតូចសោះខ្លះ តែយកបូមមកងាក់មិន ចេះពេញ ឬ ចាក្អែកមិនចេះឆ្អែតនឹងការម៉ៅរបបសោះ ខ្លួនត្រចៀកៈនោះ ក៏តូចដែរតែមិនឆ្អែតនឹងសម្លេង ។ ចិត្តមិនឆ្អែតនឹងកុំនិយាយ អណ្តាតមិនឆ្អែត នឹងរស កាយមិនឆ្អែតនឹងសម្ផស្ស ត្រចៀមដែលមិនឆ្អែតនឹងចំរៀង ភ្នែក មិនឆ្អែតនឹងខ្សែដៃ ឬ នាឡិកាចង់ដៃ ត្រចៀកមិនឆ្អែតនឹងការ-ទំហូ ភ្នែក ឆ្អែតនឹងខ្សែក សេដ្ឋមិនឆ្អែតនឹងបុណ្យសេដ្ឋី មេឃុំមិនឆ្អែតនឹងយសមេឃុំ ចៅហ្វាយស្រុកមិនឆ្អែតនឹងយសៈចៅហ្វាយស្រុក ចៅហ្វាយខេត្តមិនឆ្អែត នឹងយសចៅហ្វាយខេត្ត រដ្ឋមន្ត្រីមិនឆ្អែតនឹងយសរដ្ឋមន្ត្រី មហាក្សត្រិយ៍ មិនឆ្អែតនឹងរាជសម្បត្តិ ដូចសមុទ្រមិនឆ្អែតនឹងទឹក ភ្លើងមិនឆ្អែតនឹងទស ជួរភ្នោះ ចេះតែមានសេចក្តីខ្វះខាតទៅជានិច្ច ម្ល៉ោះហើយក៏ខំប្រឹងវ៉ៃដែង

ស្វែងរកវត្ថុតាមនឹងកិលេសតាមនោះ មកចម្រើកាយចិត្តគតិតដល់ការ
ខ្មីឃាត់ ព្រះសុគតសម្តែងទើបត្រាស់ថា "ឆន្ទោ លោកោ
អត្តន្តោ តណ្ហា ធាសោ: សត្វលោក មានសេចក្តីខ្វះខាតនៅជា
និច្ច មិនចេះឆ្អែតមិនចេះឆ្អន់ ស្មុគ្គតែជាប្រាថ្នាវត្ថុតំណរបស់តណ្ហា" ។

៣- កន្លងបណ្តាហេតុ ឬ សម្តែងនៃទុក្ខសោកភេតភ័យតាំងពី
ចំណែកតូច រហូតដល់ចំណែកធំ មិនមានអ្វីដែលក្រៃលែងជាងអវិជ្ជា
សេចក្តីមិនដឹងតាមពិត គំនិតដឹងខុស ចូលចិត្តខុសនេះទេ ។ ព្រោះ
ថាអវិជ្ជាកាលកើតឡើងក្នុងចិត្ត រមែងរុំពែតឹកចិត្តឲ្យងងឹតងងុយ
ស្មើ ដូចជាពពកចាំងពន្លឺព្រះចន្ទ ធ្វើឲ្យសំគាល់យល់ឃើញខុស គិត
ខុស និយាយខុស ធ្វើខុសជានិច្ច ។ ព្រោះដូច្នោះ មនុស្សដែលមាន
អវិជ្ជាជាគ្រែលនោះខាងកន្លងហើយ ទើបមានចំណុចចំណង់ចង់បានអ្វីៗ
មិនកំណត់ ដោយខុសបទមិនត្រូវបែប ឃ្លៀងឃ្លាតចាកធម៌ ទុកជា
ខ្លះណាក្តៅក្រហាយដោយសារខ្លួនយ៉ាងណា ក៏មិនគិត ។ អវិជ្ជានឹង
តណ្ហា ទើបមានដំណើរជាគូគ្នា ត្រៃថា "ព្រោះមិនដឹងតាមពិត ទើប
នាំចិត្តឲ្យគិតប្រាថ្នា" ។ តណ្ហា គឺសេចក្តីប្រាថ្នានេះឯងជាទុក្ខសមុទ័យ
គឺហេតុឲ្យកើតទុក្ខ; ឲ្យកើតទុក្ខយ៉ាងណាខ្លះ? ឲ្យកើតទុក្ខយ៉ាងនេះ គឺ
នាំឲ្យកើតទុក្ខកន្លងការស្វែងរក បើកមិនបានសមបំណងក៏ឲ្យកើតទុក្ខ ប្រ-
សិនបើរកបានមក ក៏កើតទុក្ខនឹងការចែករក្សាទៀត ភ័យចម្រើនាសទៅវិញ

ដោយអគ្គិភ័យ ទឧកភ័យ ចោរភ័យប្តូរបស័ត្តណាមួយ ។ "ទ្រព្យច្រើនត្រួយរក្សា ទ្រព្យតិចណាត្រួយរិនគិត" ។ ទំងនាំឲ្យបានដួបច្រែះជាតិទុក្ខ ជរាទុក្ខ មរណទុក្ខជាដើម ។

๔ – តណ្ហាតែងមានគ្រប់គ្នាជាធម្មតា តែថាកុំឲ្យជ្រុលជ្រួសហួសជ្រងគេក កុំឲ្យលោភលោភល្មើសលើសលុបព្រមនៅគ្រាមតណ្ហារហូតដល់ហៅថា "តណ្ហាខ្លាក់" នោះមិនកើតទេ ព្រោះតណ្ហាខ្លាក់តតគិតបាបបុណ្យគុណទោសអ្វីឡើយ គិតឲ្យតែខាងបាន ឲ្យតែប្រទះដៃតតស្គាល់អាយុដីវិតទ្រព្យសម្បត្តិកូនប្រពន្ធនរណា ត្រូវសម្លាប់សំឡេះក៏សម្លាប់សម្លេះ ត្រូវលួចក៏លួចបួនក៏បួន ត្រូវចាក់គាបក៏ចាក់គាប់ ត្រូវស៊ីក៏ស៊ី ធឹកក៏ធឹកជាដើម កាលៈបើបណ្តែតបណ្តោយតាមតណ្ហាខ្លាក់ដែបនេះ ច្បាកដជាខ្មោះឃ្លាងគ្មុតប្រកាក់គ្រោះថ្នាកបកាំដៃហៅហើយ លុះស្លាប់ទៅ ត្រូវទទួលទុក្ខកង់អប្បាយទៀត ។

๕ – តាមឬតណ្ហាពាប់ថាជាគោសរបស់ចិត្តយ៉ាងសំខាន់ ដនដែលត្រូវតាមតណ្ហាគ្រប់សង្កត់ រមែងងងឹតមិនដឹងខុនប្រហែលនឹងមនុស្សខ្មោចចូលត្រឡប់ត្រូវទៅជាខុសៗ ទៅជាត្រូវវិញ; ដើម្បីច្រើទប្រាយជួយជនពួកនេះឲ្យដឹងខ្លួន ត្រៃថាកអ្នកមានបញ្ញាកង់សម្មុជ្ជានៃពេតនេះហើយ មិនមាននរណានឹងជួយបាន ថ្នាំធម្មតាយកទៅកែកុនរក្សាឲ្យជាសះស្បើយមិនបានឡើយ ។

វិធីកាត់ការពោរពេញចិត្តដូច្នេះ ដែលបានផលមកហើយ គឺ :

ក) ផ្សាយជាស់គឿនក្រើនរំលឹក អ្នកដែលត្រូវពេញតណ្ហាគ្របសង្កត់ ឲ្យកើតហិរិអៀនខ្មាសដល់ចិត្ត ទុត្តប្ប : ខ្ញើមរអើមខ្ជាបអាចំពោះបាប ។

ខ) ពន្យល់ឲ្យឃើញទោសនៃកាមតណ្ហាថាជាអណ្តូងនៃទុក្ខសោក ភេតភ័យតាំងពួង និងឲ្យឃើញគុណនៃសេចក្តីច្បាសចាកតណ្ហាថាជា បង្ហាយនាំមកនូវសេចក្តីត្រជាក់ត្រជំ ស្ងប់ស្ងាត់សុខស្រួមនៃចិត្ត ។

ពុទ្ធកាសិត

យស្ស តណ្ហា កាមភវេ មជ្ជិតោ កាមកណ្ដា កា
មោហកូយមនុប្បត្តោ សុខទុក្ខេ ន វេធតិ ។
បុគ្គលឯណាធ្លង់ទូវកក់ គឺកាមលាមកដ៏សាវ
ទឹងញាំញីជកទូវបន្ទា គឺកាមតណ្ហាចាកចិត្តជាប់ ។
បុគ្គលនោះឯងទឹងអស់ទៅ នូវមោហៈធម៌ជាលំជាប់
ជាអ្នកមិនតក់ស្លុតញ័រញាប់ ក្នុងសុខទុក្ខសព្វប្រការឡើយ ។

ចប់

រឿងល្បែងប្រណាំងទូក

របស់

សាមណេរ ព្រាប - ឌិប វត្តលង្កាកុំពេញ

ល្បែងប្រណាំងទូកនេះ ជាល្បែងសម្រាប់លេងតំសាន្តមួយយ៉ាង-ទុទ្ធារិក របស់ជនជាតិខ្មែរចាស់ - ក្មេង - ប្រុស - ស្រី - គេទុកជាទំនៀមទម្លាប់ខាងល្បែងមួយយ៉ាងប្រសើរ របស់ជនជាតិខ្មែរ តាំងពីបុរាណ-សម័យ រហូតមកដល់សម័យសព្វថ្ងៃនេះ ក៏មានន័យមលេងជារៀងរាល់ខែត្រ រាល់ស្រុក ក្នុងដែនកម្ពុជានេះ ។ មិនប៉ុន្តែប៉ុណ្ណោះសោត សូម្បីជនជាតិដទៃ ដូចយ៉ាងជនជាតិចាម - ជ្វាដែរ ក៏ចូលចិត្តលេងប្រណាំងទូក ដូចខ្មែរយើងដែរ ។

ឯការលេងប្រណាំងទូកនេះ ជនជាតិខ្មែរច្រើនតែប្រណាំងក្នុងខែភ្ជុំវស្សា ដែលទឹកឡើងលិចល្អាចល្អិមសព្វទីកូមិហាន ។

ក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌម្តងៗ មហាជនជាតិខ្មែរតាំងក្មេង - ចាស់-ប្រុស - ស្រី គេដើរប្រមូលគ្នាលើសេរកទូកប្រណាំងយ៉ាងលឿនហើយរហ័ស ទូកនឹងជាក់ចំណុះឱ្យស្មើគ្នា បើទូកមួយមានគ្នា ២០ នាក់ទូកមួយក៏ត្រូវឱ្យមានគ្នា ២០ នាក់ដែរ ឬលើសខ្វះពីគ្នាបន្តិចបន្តួចក៏គេសុខចិត្តព្រមលេងដែរ តែគេរើនឱ្យពួកកុមារនៅក្រុមពេញដង់អង្គុយខ្នងទូកខាងមុខ ពួកកុមារអង្គុយខ្នងទូកខាងក្រោយ ហើយអ្នកកាន់ចង្កូតទូកប្រណាំងនោះ

គេច្រើនយកច្រពាំងធំធេងវែងមកកាប់ចង្កឹតខ្លួកផង ឯអ្នកស្រែវិញនោះគាន់ច្រកគ្រប់ដៃតែខ្សែរឿងៗ ខ្លះ ហើយមានម្នាក់ទៀតហៅថាគ្រូបង់បត់ ប្តូ ក្នុកមានសំដីច្នូមាត់គ្រាន់បើអង្គុយលុតជង្គង់ត្រង់ច្រកក្បាលខ្លួក អ្នកនេះគាន់ច្រកលនយ៉ាន់ណ្ហះហើយដួតក្បាលធន៍ សម្រាប់ស្រែកយកជ័យ ឬស្រែកថា "មួយយ៉ូ" ក្នុងកាលដែលកំពុងប្រណាំងគ្នា ។

កាលបើរៀបចំខ្លួកប្រណាំង ស្រួលបួលស្រែចហើយគេនាំគ្នាអុំបប្រះទឹកពួសរ "ភ្លុង" ទៅយកដើមទីសិន ហើយគេនាំគ្នាស្រែកច្រៀងឡើងថា: "បង់អុំខ្លួកទៅ - ហៃសារិយ៉ាំង! ស្រីរៀបតាម - ហៃសារិយ៉ាំង! ទឹកត្រែកហាម តាមគ្រោយខ្លួកបង់" ។

លុះដល់ដើមទីហើយ គេត្រឡប់បត់បង្វិលក្បាលមកវិញឲ្យត្រឹមស្មើគ្នាទាំងអស់; ក្នុងពេលអុំទៅមួយលើកៗ មានខ្លួក ២ ក៏មាន ៣ ក៏មាន ៤ ក៏មាន ចាប់អុំទាំងអស់ស្មើគ្នាតែម្តង គេចាប់អុំពីដើមទីហូតដល់ចុងទីតាមពាក្យមកសន្យាពីមុនពេលប្រណាំង ។

លុះដល់ត្រង់កន្លែងសន្ទុះនោះហើយ គេឈប់អុំទាំងអស់គ្នា ហើយតាំងស្រែកហ៊ោគ្រេវឡើង ។ ឯពួកមនុស្សម្នាដែលឈរមើរកុះករនៅលើគោកឬបណ្តែតខ្លួកអុំតាមមើល គេឃើញមានជ័យជំនះឈ្នះទៅខាងខ្លួកណាច្រួនកាលគេច្រកាន់ជាភ្លូកៗ ជាក់លុយឬជាក់តែអ្វីក្តាល់គ្នាក៏មាន ។

កន្លះពេលបុណ្យភ្ជុំបិណ្ឌ គេអុំទូកគ្រប់ ៣ ថ្ងៃក៏មាន តាមបែបបទពីបុរាណនាយមក ។

លុះដល់ថ្ងៃចេញព្រះវស្សា គេអុំទូកប្រណាំងគ្នាម្តងទៀតហើយ គេច្រែនហៅថា អុំទូកផ្តាច់ព្រ័ត្រផង ។ ឯទូកអុំប្រណាំងគ្នានោះ គេចូលចិត្តរកទូកណា ដែលមានឈ្មោះល្បីល្បាញជាងគេ ហើយមានសណ្ឋានទ្រង់ទ្រាយជាទូកវែងជាក់ចំណុះបានច្រើន តែបើគ្មានទូកល្អនោះទេ សូម្បីទូកអុំធម្មតា ក៏មានគេអុំប្រណាំងគ្នាជាច្រើនដែរ នេះជាបែបខាងទូកងអុំប្រណាំង (អាត្មាភាពកាលនៅជាគ្រហស្ថ បានលេងល្បែងទូកនេះជាញឹកញាយដែរ) ។

ឯទូកចែវប្រណាំងវិញ, ជនជាតិខ្មែរច្រើនរើសរកយកទូកដែលមានដើងចែវចំនួន ២០ ឡើងទៅដល់ ៣០ - ៣១ - ៣២ ។ ឯទូកមានចំនួនដើងចែវតិច មិនសូវឃើញមានយកមកប្រណាំងគ្នាក្នុងពេលមានបុណ្យងាន់ធំម្តងៗ នោះទេ ។

កន្លះពេលដែលប្រណាំងទូកនោះ មិនត្រូវនិយាយពាក្យផ្តេសផ្តាសមិនត្រូវនោមជាក់លើទូកនោះជាដើម ហើយគេដោតទង់ជ័យរូបក្ងោកឬរូបហនុមានខ្ទៅកនៃទូក មានម្នាក់ទៀតជាគ្រូបង់បត់ ឬជាអ្នកមានសំដីថ្លឹមត់គ្រាន់បើ សម្រាប់ស្រែកយកជ័យ ឬស្រែកថា "មួយយ៉ូ" ជូនទូកអុំដែរ ។ លុះដល់ពេលនឹងចែវប្រណាំងគ្នា អ្នកចាំងនោះក៏ចែវប្រែប្រៃទឹកទៅយកទឹពីចម្ងាយមកវិញ ល្មមនឹងចែវយកឈ្នះយកបាញ់បាន ។

ឯអ្នកចំការលួក កំនាំគ្នាធ្វើមវៃស្រែកប្រៀងឡើងថា "វើយៗកន យើងប្រឹងដៃប្រឹងដើង ម្តងនេះទៀតហើយ" មានបទចំនុកប្រៀងក្រៅពីនេះទៅទៀតជាច្រើន ។ លុះដល់ទីហើយ គេត្រឡប់បត់ក្បាលខ្លួកមកវិញ ឲ្យត្រឹមស្មើគ្នា ហើយគេចាប់ដងចែវប្រឹងប្រែបត្រប់ប្រាណ ទើបគេវៃស្រែកឡើងថា: ១ - ២ - ៣ ហើយចែវត្រឹបស្មើគ្នាឡើង ឯអ្នកអុំក្បាលខ្លួកនោះក៏វៃស្រែកឡើងថា "អ៊ុយ៉ូវ" ដូច្នេះ លុះត្រាតែចែវដល់ទីទើបឈប់វៃស្រែក ។

បើខ្លួកណាចែវមកដល់ទីមុនផុតស្រឡះពីខ្លួកក្រោយ ខ្លួកនោះឈ្នះថាឈ្នះ តែបើឈ្នះគេបានត្រឹមតែមួយខ្លួនឬពីរខ្លួនខ្លួកប៉ុណ្ណោះ មិនបានឈ្នះថាឈ្នះទេ ទោះបើពុំព្រមទទួលថាចាញ់ទេ ត្រូវចែវម្តងទៀតជាលើកទីពីរ បើលើកទីពីរមិនឈ្នះមិនចាញ់ទេ គេចែវត្រប់ ៣-ដងក៏មាន ។

ឯអ្នកឈរចាំមើល មិនមែនតែជាតិខ្មែរប៉ុណ្ណោះទេគឺមានជាតិយួន ចិន ទឹងចាវជាដើម ហើយជាតិចាវច្រើនយកមកឲ្យប្រណាំងក្នុងពិធីបុណ្យរបស់ខ្លួនជាច្រើនណាស់ដែរ ថែមទាំងក្លាល់ជាក់របស់ផ្សេងៗ ឬជាក់ប្រាក់កាសជាច្រើនណាស់ផងក៏មាន ។

តែជនជាតិខ្មែរវិញ ច្រើនចូលចិត្តនាំគ្នាមកប្រណាំងនៅមុខព្រះវិហារ វត្តណាដែលមានទឹកនៅមុខវត្ត (រដូវវស្សា) គឺនៅឯបុណ្យភ្ជុំបិណ្ឌ

ប្តូរថ្ងៃចញ្ច្រៃរសៀ ប្តូរបុណ្យហែកចិន បុណ្យហែផ្កាដាំដើម គេតែងខ្ចូកងយ៉ាងល្អស្អាត ហើយចែរសណ្តាងយោងមុខវ៉ែត - តៃហ៊ោកំមាន ។

មួយវិញទៀត គេមុននឹងចុះទៅលើខ្ចូកង បុមុននឹងអូសខ្ចូកងនោះជាក់ចុះពីលើបង្គន់ គេច្រែនលើកដៃធ្វើកំបង់អញ្ជាលីរំលឹកដល់ព្រាយបង់បត់ជាមុនសិន ទើបគេហ៊ានប៉ះពាល់ប្តូរចែរជាខាងគ្រាយគ្រានខ្ចូកងល្អៗ ច្រែនមានព្រាយបង់បត់ចែរក្បា តាំងពីយកឈើមកធ្វើជាខ្ចូកងនោះម្ល៉ះ ។

សេចក្តីអធិប្បាយអំពីខ្ចូក

ខ្ចូកងនេះ គឺជានាវមួយ មានលំអដោយគំនូរគូរវៃសក្តិរក្បាច់រចនាជាវិកវិកក្តឹកឡឹកចិត្តសត្វលោកពន់ពេក, ដើមឡើយខ្ចូកងគេធ្វើពីឈើសុទ្ធសាធ គេច្រែនរើសយកឈើគគីរ បុឈើឆ្កែក បុឈើស្រែឡៅធ្វើជាខ្ចូកង, តែគេច្រែនរើសយកឈើគគីរច្រែនជាងឈើដទៃទាំងអស់ ព្រោះឈើគគីរមានសាច់ស្តូតក្រែង ហើយច្រែនដំជាងឈើដទៃទាំងអស់ក្នុងបណ្តាឈើ ២ ៣ ឈ្មោះនោះ ចែមទាំងយកមកច្រើការជាច់ចិតនេះ យូរអង្វែងជាងឈើទាំងពួងឯង ។ ឯឈើគគីរនេះ ច្រែនតែដុះនៅលើព្រៃភ្នំក្រែងដែលជាទីស្តុកធំ គឺភ្នំធំៗ បុព្រៃរហាហានដែលគេមិនសូវទៅមក នោះទើបមានឈើគគីរធំៗ តែនៅស្រុកអាយើងនេះច្រែនតែមានដើមគគីរតូចៗ ទើយកធ្វើជាខ្ចូកមិនបានទេ ។ ព្រោះខ្ចូកងនេះ

គ្មានបំណង ហេតុនេះ ទើបគេត្រូវរកឈើមានសាច់ស្តុតគ្រប់ហើយវែងឆ្ងាយ ទើបធ្វើជាទូកងបាន ។

ឯដើមគគីវែលជុះនៅលើព្រៃភ្នំនោះ ពីបាកនឹងយកមកប្រើការគេកណាស់ ព្រោះច្រើនមានបង់បត់ (ខេតកែ្ស) រក្សាផង ។ រីឯដែលគេទៅអារគាប់យកមកនោះ មុនដំបូងគេរៀបពីការបូជា មានរៀបធ្វើកន្ធោង មានក្បាលជ្រកនឹងចេកខ្ទង់ជាដើម ថ្វាយដល់មង់បត់សិន ហើយគេសរសេរប្រកាសបំភ្លឺដើមឈើនោះថា " នៅ ៧ ថ្ងៃទៀត គេនឹងគាប់ឈើនេះហើយ សូមអស់លោកអ្នកបរៀសចេញឲ្យឆ្ងាយទៅ " ។

លុះដល់គារគាប់ឈើនោះយកមក គេតមមាត់គ្រប់ៗ គ្នា ទើបបង់បត់នោះមិនបែកបៀន លុះគាប់បានយកមកហើយគេជ្រើសរើសរកជាងធ្វើទូកងដែលឯកទើបគេធ្វើ ។

ឯការធ្វើទូកងនេះ តាមមតិរបស់ជនជាតិខ្មែរថា ត្រូវធ្វើទូកងជាសណ្ឋានឥសរៃ្ត គឺក្បាលពងឥសរៃ្ត កន្ទៃពងកសត្វប្រើស ហើយបាតត្រង់ទ្រកការខាងក្បាលឲ្យដក់ទឹកបន្តិច បាតត្រង់ទ្រកការខាងកន្ទៃឲ្យឡើងស្រយាលពីទឹកបន្តិច ទើបទូកងនោះមានល្បឿនលឿនរត់បានខ្លាំង ។

តែថាទូកងនេះ ស្រែចនៅលើជាងប៉ុន្មានប្រសបណ្ឋាសវែងស្តួតធំនាញខាងចេនាទូកងនោះ មានល្បឿន ហើយពងរៀបសមសណ្ឋានជាទូកងប្រកដ ។

ទៅក្នុងដែនកម្ពុជានេះអ៊ុំទូកងប្រណាំង, ទូកងចែវប្រណាំងមានគ្រប់ស្រុក ភូមិ - ខែត្រ រៀវលែងតែស្រុកណាគ្មានទន្លេឬគ្មានទឹកឡើងជន់ខ្លាំងភូមិសោះ ។ (អាត្មាភាព) ឃើញទូកងប្រណាំងនៅខែត្រកំពង់ឆ្នាំងច្រើនណាស់ គឺនៅវត្តព្រៃតសាលា - ឃុំទឹកហូតស្រុកឧរលៀប្អៀរ (កំពង់ឆ្នាំង) ជាដើម វត្តនោះមានទូកងសម្រាប់ចែវប្រណាំងមួយឈ្មោះស្រីស្រៀវ ចំណុះដើងចែវជាង ៣០ មានកេរ្តិ៍ឈ្មោះល្បីល្បាញកាលពីជាន់មុន តែគន្លះនេះ ទូកនោះចាស់គាំគ្រាណាស់ទៅហើយ ។

ឯរឿងត្រែងនិយាយពីទូកង មិនសូវឃើញមាននិយាយទេ ឃើញមាននិយាយតែអំពីរឿងទូក (ចង្ក្រានហុយ) ក្នុងរដ្ឋសម័យព្រះករុណាជាអម្ចាស់ជីវិត (ព្រះនរោត្តម) នឹងរឿងឯទៀតខ្លះ ។

ក្នុងសម័យតុន្ទកាល របស់ពួកនាគ (ក្នុងរឿងអត្ថនោបុព្វកម្មវត្ថុ) គម្ពីរធម្មបទដ្ឋកថា ភាគ ៣ ទំព័រ ១៣៧ បន្ទាត់ទី ១១ ។

រឿងត្រែអំពីនេះ មិនសូវឃើញមាននិទានទេ ។

អំពីផលប្រយោជន៍នៃទូកង

ឯផលប្រយោជន៍សំខាន់ៗ របស់ទូកងនោះគឺបានតែយកមកប្រឹការប្រណាំងគ្នាលេងគ្នា ឬបានតែយកមកប្រើជាការលំអក្នុងពេលមានបុណ្យធំៗ ដូចបុណ្យភ្ជាត់ទឹកសួយេតជាដើម សេស បុណ្យអ៊ុំទូកលួយ

ប្រទីប ព្រះពុទ្ធពិធីព្រះកុរណាជាអម្ចាស់ជីវិតលើត្បូងខៀវគ្រែងភ្នំពេញ ជាដើម ។

ខ្ញុំគង់នេះ នឹងនាំយកមកផ្តុកដឹកនាំទំនិញចេញចូលដូចខ្ញុំកំពេលនោះមិនបានឡើយ ។

សេចក្តី : ដែលបានអធិប្បាយបរិយាយរៀបរាប់មកប៉ុណ្ណេះនេះ មានគោលការណ៍សំខាន់ ត្រង់ការដាស់តឿនក្រើនរំលឹកដល់ជនជាតិខ្មែរឲ្យកែប្រែសតិបញ្ញា យល់ច្បាស់ លាស់ពីរឿងព្រះជាន់បុព្វណនឹងសម័យឥឡូវនេះគ្រប់គ្នាឡើង ។

សូមសង្ខេបសេចក្តីអធិប្បាយត្រឹមប៉ុណ្ណេះ

សព្ទានុក្រមភាសាខ្មែរ

របស់

គណៈកម្មការវប្បធម៌

ហ្លួងធិពន្ធមន្ត្រី ញាក-លែម រួបរួម

(ត្រង់)

Personnalité = ... { *បច្ចត្តលក្ខណៈ*
បច្ចត្តភាព
តស្សរជន

(ជ - ញ - ដ)

Groupe mobile: = *គង់ចលនៈ*

Notion = *សញ្ញាណ (ចំណេះ)*

Rudiment = *ចំណេះខាងដើម, ចំណេះថោកថយ*

Générosité = *ចិត្តបុណ្យ, ចិត្តទូលំទូលាយ*

Charité = *ចិត្តសប្បុរស*

Dévouement = *ស្មោះត្រង់, ចិត្តភក្តី*

Pondération = *ចិត្តទឹងដឹង, ចិត្តល្មមប្រមាណ*

Désastre = *ហាយនភាព*

Catastrope = *មហន្តរាយ*

Facture = វិក្កយប័ត្រ

Arbitre suprême de la nation = អគ្គពិនិត្យនៃជាតិ

Sécrétaire journalier = ស្មៀនទិនិក

Adresse = ទីលំនៅ

Art = សិល្បៈ

Beaux-Arts = វិចិត្រសិល្បៈ

Libéral = ចិត្តទូលំទូលាយ

Bonté = ចិត្តល្អ

Destruction = វិនាសកម្ម

Accident = គ្រោះថ្នាក់

Péril = មហាភ័យ

(១៣ - ៥ - ៤៧)

បណ្តាសព្ទគិតខាងឥណ្ឌូឆីន

Homme de troupe = ពលខាងថាន

Soldat de 2ᵉ classe = ពលគោ

— 1ᵉ — = ពលឯក

Caporal — = នាយគោ

— chef = នាយឯក

Sous—officiers = នាយនាហានរង

Sergent = ពលចាលត្រី

Sergent chef = ពលចាលទោ

— major = ពលចាលឯក

Adjudant = ត្រីខូចាលទោ

— chef = ត្រីខូចាលឯក

Aspirant = នាយចំណាង់

Troupe = កង

Officiers = នាយនាហាន

Sous-lieutenant= អនុសេនីយ

Lieutenant = អនុសេនីយទោ

Capitaine = អនុសេនីយឯក

Commandant = វរសេនីយត្រី

Lieutenant Colonel = " ទោ

Colonel = " ឯក

Général de brigade = ឧត្តមសេនីយត្រី

— de division = " ទោ

— de corps d'armée = " ឯក.

Maréchal = សេនាប្រមុខ

Généralissime = អគ្គសេនាប្រមុខ

groupe = កង

Section = កងអន្តរសេនាតូច

Compagnie = កងអន្តរសេនាធំ

Bataillon = កងវរសេនាតូច

Régiment = កងវរសេនាធំ

Brigade = កងពលតូច

Division = កងពលធំ

Armée = កងទ័ព

Chef de groupe = មេកងឥតហាន

Corps d'armée = កងអគ្គទ័ព

បណ្តាសព្ទទាហានជើងទឹក

Equipage de la flotte = ពលទាហានជើងទឹក

Maître principal = នាយចក្រខ្ចាស

Premier maître = ចក្រខ្ចាសឯក

Maître = ចក្រខ្ចាសទោ

Séconde maître = ចៅក្រុមលេខ២

Quartier maître = ចៅក្រុមលេខ៣

Quartier maître-chef = ចៅក្រុមលេខ១

Matelot = កម្មករនាវា

Matelot breveté = កម្មករនាវាពិសេស

Armée Royale khmère = កងទ័ពខេមរភូមិន្ទ

Garde nationale = ក្រុមការពារប្រទេស

Armée de mer = កងទ័ពជើងទឹក

Amiral d'escadre = នាឧត្តមនាវីនាយក

Amiral = នាឧត្តមនាវីឯក

Vice-Amiral = នាឧត្តមនាវីរង

Contre Amiral = នាឧត្តមនាវីត្រី

Capitaine de vaisseau = នាវាសេនាឯក

Capitaine de frégate = នាវាសេនារង

Capitaine de corvette = នាវាសេនាត្រី

Lieutenant de vaisseau = អនុនាវីរង

Enseigne de vaisseau 2e cl. = អនុនាវីត្រី

Marin = ពលនាវាជាន់ទឹក

Masse = ច្របាកគរ, ច្របាខិតរ

Infanterie = កងទាហានថ្មើជើង

Artillerie = កងកាំភ្លើងធំ

Fantassin = ពលថ្មើរជើង

(៩-៩-៤៧)

Climat = អាកាសជាតុ

Epidemie = រោគរាតត្បាត

Maladie infantile = រោគទារក

Convoi = ក្បួនដួន

Slogan = ពាក្យស្លោក

Luxe = ច្រណែត, ឆើត

Idée = គំនិត

Pensée = ចិន្តា

(២៣-៩-៤៧)

La défensive = ការតទប់

L'offensive = ការលុកចូល

La force morale = កំឡាំងចិត្ត

Les renseignements = ដំណឹង, ដំណើរការ, ហេតុការណ៍

Attaquer = ក់យ

Combattre = ច្បាំង

Le feu = ការបាញ់

La compagne = ចំបាំង

La poudre = រំសេវ

L'explosif = រំសេវផ្ទុះ

L'embuscade = ការចាំឆក់

Embusquer = ចាំឆក់

(៣០-៨-៤៧)

Département ministériel = ក្រសួង

Administration = ពដការ, ការគ្រប់គ្រង, រដ្ឋបាល

Service = ក្រម, (ការបំរើ)

Direction = នាយកដ្ឋាន

Recette (des régies nationales) = ផ្នែកគយនិងរដ្ឋាករ

Poste de surveillance (des régies nationales) = ឥតិវរដ្ឋាករ

Impôt = ពន្ធ (6-1-48)

Taxes indirectes: = ពន្ធមិនចំពោះ

(ម១៣)

ប្រវត្តិសាស្ត្រសង្ខេបប្រទេសវៀតណាម

ហ្វូងនិពន្ធមន្ត្រី ញ៉ុក - ថែម រៀបរៀង

(ភាគ៣)

កងរាជពុទ្ធសករាជ ១០៥៤ មានក្សត្រតណ្ហៀ ១ អង្គកងព្រះវង្សវៀលក៏ ព្រះនាម កាតារ: ទ្រង់ច្បាំងតទល់ខាល់តែមានជ័យជំនះពួក ហ៊ាន ហើយ អញ្ជើញព្រះបាទតាលាទិត្យ: ឡើងគ្រងរាជសម្បត្តិឡើងវិញបាន ទើបធ្វើ ឲ្យពួក ហ៊ាន ដកខ្លួនថយទៅខាងស្រុកកស្មីរ: តែមិនយូរប៉ុន្មានពួក ហ៊ាន ក៏ត្រឡប់លុកលុយចូលមកបានទៀត ហើយរាជវង្ស គុប្ត: ក៏មិនអាចទប់ ការពារទប់ទល់បានផង ទើបរួចខាតដែនដីអស់ទៅជាច្រើន នៅសល់ តែមដែនមគធ:ប៉ុណ្ណោះ ។

កងវេលាដែលពួកហ៊ានបានបរាជ័យ ក្សត្រ កាតារ: រាជវង្សវៀលក៏ កាលពីពុទ្ធសករាជ ១០៥៨ នោះ ពួក ហ៊ាន បានព្យាយាមរួបរួមកម្លាំង ទ័ពឲ្យកាន់តែរឹងប៉ឹងឡើងទៀតជាច្រើន នៅវេលាដែលពួកនេះចូលមក ប្រទូស្តរាយរាជវង្ស គុប្ត: ទៀតនោះ តូរ៉ាម៉ុន មេទ័ព ហ៊ាន បានអនិច្ចកម្មទៅ ហើយ ពួក ហ៊ាន បានតាយកថ្មីឈ្មោះ មិហិរ៉ាកូល លុះពួកនេះច្បាំងបាន ជ័យជំនះរាជវង្ស គុប្ត: កងគ្រានេះហើយទើបនាំគ្នាទៅតាំងអាណាចក្រមាន ទីក្រុងនៅស្រុក ល:ហ៊ា ហើយតាំងខ្លួនជាសត្រូវនឹងព្រះពុទ្ធសាសនា យ៉ាងគាបសាហាវ ពួកនេះបានដុតវិហារ កេងឲ្យបោសថទៅស្រុកបុញ្ញាប

ហើយបានចំផ្ងាញព្រះពុទ្ធរូបអស់ទៅជាច្រើន ។ មានព្រះមហាថេរៈ១អង្គ ឈ្មោះសិមហៈ កំពុងតែវត្តហ៊ុន ប្រហារជីវិតបង់ទៅ តិក្ខាំងឡាយក៏នាំគ្នារត់ខ្ចាត់ខ្ចាយចេញពីប្រទេសតណ្ហៀ ទៅនៅកោះលង្កា, ភូមា, ជ្វា នឹងពួកគ័ស្ពានទិសខាងកើត ហើយចូលទៅនៅប្រទេសវិៈបត់នឹងស្រុកចិន ។

អ្នកប្រាជ្ញប្រវត្តិសាស្ត្រមិនទាន់ដឹងប្រាកដថា តំណាចរបស់ពួកហ៊ុនបានផ្សាយទៅដល់ត្រឹមណា គ្រាន់តែដឹងថាគាលព័ត្ថុសករាជ ១០៦៩ មានព្រះចៅផែនដី ១ អង្គក្នុងវង្ស មាលវៈ ព្រះនាមថា យសោធរៈម៉ុន ឃានបង្ក្រាបទប់ទល់ការពារពួក ហ៊ុន ឲ្យឈប់លុកលុយចូលមកបាន ព្រះមហាក្សត្រអង្គនេះហើយ ដែលបានជួយឲ្យប្រទេសតណ្ហៀផុតរបូតពីកណ្តាប់ដៃពួក ហ៊ុន ទើបគួរគប់ថាជាអ្នកគ្រាហានមានកេរ្តិ៍ឈ្មោះល្បីល្បាញ ។ មានរឿងព្រៃងកើតឡើងដោយការតែងតាមទំនង រឿងពាក់ព័ន្ធរបស់ព្រះបាទយសោធរៈម៉ុន នោះឯងក៏មាន ហើយឲ្យឈ្មោះពីរៈបុរសក្នុងរឿងនោះថា វិក្រមាទិត្យ ។

លុះព្រះបាទ យសោធរៈម៉ុន សោយទិវង្គតទៅ ហើយអាណាចក្រមាលវៈ ក៏បែកខ្ញែកជាអាណាចក្រតូចៗអស់ទៅដោយច្រើនអាណាចក្រ ។ មានអាណាចក្រខែត្រ ១ គង់ទ្រង់នៅ គឺអាណាចក្រ គុជរដ្ឋ តាំងនៅក្នុងវាលដីចាស់របស់សុភស្តិ មានព្រះចៅផែនដីដែលជាខ្សែស្រឡាយរាជវង្សគុប្តៈ តាំងជាវង្សក្សត្រថ្មី ហៅថា រាជវង្សរលតី ដែលធ្លាប់បាន

ច្រាប់ច្រាមពួកហ៊ានមានជ័យជំនះមកម្ដង ហើយបានគង់ទ្រង់នោះហូតមកដល់ព្រះពុទ្ធសករាជ ១២០៩ លុះអំណើះតាលយូរលង់មកទៀត ទើបធ្លាក់ទៅនៅកងអំណាចរបស់ពួកតាលុក្ស: ដែលនឹងមានរឿងក៏វែងវិត្ត ជាលំដាប់តទៅ ។

ចំណែកនៅត្រើយខាងស្ដាំទន្លេយមុនា មានស្រុកតូច ៗ ឈ្មោះ ចានិស្សារ៍ មានក្សត្រគ្រងរាជ្យ ១ អង្គព្រះនាម ប្រកាករ: ទ្រង់បានព្យាយាមតស៊ូទប់ទល់នឹងពួក ហ៊ាន យ៉ាងម៉ឺងម៉ាត់ ក្នុងសម័យដែលមានពួកហ៊ានលុកលុយចូលមកកាន់តណ្ឌ ។ ព្រះបាទ ប្រកាករ: មានព្រះរាជទ្រវេស ២ អង្គ អង្គច្បងព្រះនាម រាជវរ:ធន អង្គប្អូនព្រះនាម ហាសិវរ:ធន តែគេច្រើននិយមហៅ សីលាទិត្យ: ។ ព្រះអង្គម្ចាស់រាជវរ:ធន ត្រូវពិឃាតក្នុងចម្បាំង ក្នុងគ្រាកើតសង្គ្រាមនឹងក្សត្រ បេង្គ៌ល ទើប សីលាទិត្យ: ជាប្អូនបានគ្រងរាជសម្បត្តិជាដំណាតមកដល់ ៤៣ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១១៨៩ ដល់ ១១៩១ ទ្រង់ក៏បានស្រុកកាន់ដី ដែលទ្រង់បានចាត់តាំងជាទីក្រុង ហើយបានពង្រីកអាណាខេត្តរួយអំណាចចេញទៅរហូតដល់ប្រទេសតណ្ឌ ភាគខាងជើង ។

កាលព្រះបាទ សីលាទិត្យ: បានគ្រងរាជសម្បត្តិហើយទ្រង់ក៏ចាប់ផ្ដើមធ្វើសង្គ្រាមនឹងព្រះចៅផែនដី បេង្គ៌ល ដែលបានពិឃាតព្រះដន្ធព្រះជេដ្ឋារបស់ព្រះអង្គ ។ សង្គ្រាមរវាងព្រះបាទ សីលាទិត្យ: នឹងព្រះចៅផែន

ដ៏បេង្គំលនោះ ដំបូងគ្រាន់តែជាការសង់សឹកគ្នាក្នុងព្រះពុទ្ធវង្សប៉ុណ្ណោះ តែ
ដល់មកចុងក្រោយក្លាយទៅជាសង្គ្រាមខាងក្នុងវិសាសនាវិញ ដោយហេតុ
ព្រះបាទ សីលាទិត្យ: ជ្រះថ្លាយ៉ាងខ្លាំងក្នុងព្រះពុទ្ធសាសនា ចំណែកឯ
ក្សត្រ បេង្គំល មិនបានជ្រះថ្លាខ្លឹងព្រះពុទ្ធសាសនាសោះឡើយ ហើយមាន
សេចក្តីដំណាលថា ហេតុដែលកើតសង្គ្រាមកាន់តែខ្លាំងឡើង ។ នោះ
ព្រោះព្រះចៅផែនដី បេង្គំល ធ្វើរំលោភមើលងាយប្រមាទព្រះមហាពោធិ-
ព្រឹក្ស ជាដើមឈើដែលព្រះពុទ្ធជាម្ចាស់ឋានត្រាស់ដឹង ។ កាលទ្រង់
មានជ័យជំនះមហាក្សត្រ បេង្គំល ហើយ ព្រះបាទសីលាទិត្យ:ក៏ទ្រង់
ប្រយាក់តអាណាខែត្រតទៅទៀត ទើបបានដែនមាលវៈ ទឹងបានស្រុកកា-
នោដ៏ដែលទ្រង់តាំងជាទីក្រុង ។ តអំពីនោះមក ព្រះចៅផែនដីក្នុងអាណា-
ចក្រឯទៀត ។ របស់តណ្ហៀបែកខាងដើង ក៏ព្រមទទួលអំណាចពាជសក្តិ
របស់ព្រះបាទ សីលាទិត្យ: បណ្តាអាណាចក្រអស់នេះ មានអាណា-
ចក្រខ្លះព្រមទទួលដោយស្រួលទឹងស្មគ្រគំក្តី ដូចអាណាចក្ររបស់ពាជវង្ស
គុប្ត: នៅពាជគីរ ជាដើម ។ អាណាចក្រខ្លះព្រមទទួល លុះតែទ្រង់
កម្ចាំងរបស់ ព្រះបាទ សីលាទិត្យ: មិនបានដូចពួកហ៊ុននៅខាងបុញ្ជាប ទឹង
ព្រះចៅផែនដីកស្មីរ: ។ ចំណែកខាងគុជរដ្ឋ ព្រះចៅផែនដីពាជវង្សវលភី
អង្គក្រោយ ទ្រង់ព្រះនាម ធរុវ៉ាសេនាទី ២ ទន់ខ្សោយហួសពេកក្នុងការ
តទល់ទឹងព្រះបាទ សីលាទិត្យ: ក៏ត្រូចវាត់ចូលទៅក្នុងខែត្រដែនជិតព័ន្ធតែ

ព្រះបាទសីលាទិត្យ: ទ្រង់ឲ្យហៅត្រឡប់មកវិញ ហើយទ្រង់យល់ព្រមឲ្យ ធ្វើជាក្សត្រគ្រងរាជដីតទៅទៀត ដោយមានខបណ្តាប់ថា ពាជវង្សវិលតី អំពីដើមមកធ្លាប់កាន់តែសាសនាព្រាហ្មណ៍ ឥឡូវនេះ ត្រូវតែគោរពកាន់តាមព្រះពុទ្ធសាសនាវិញ បើមិនព្រមធ្វើដូច្នេះទេ នឹងមិនបានគ្រប់គ្រងរាជគ្គជវង្ស តទៅទៀតឡើយ ។

លុះមកដល់ពុទ្ធសករាជ ១១៥៩ ព្រះបាទសីលាទិត្យ: ក៏ជាក្សត្រដែលមានអំណាចពាជសក្តិយ៉ាងធំវៃក្រៃលែង ១ អង្គក្នុងឥណ្ឌូចិ គឺទ្រង់ជាមហាក្សត្រគ្រងរាជនឥណ្ឌូចិនាគលើទាំងអស់ មានអាណាខែត្តតាំងអំពីកុំ ហិមាល័យ ចុះមកហួតដល់ទន្លេ ណារបាជា រហូតទីទំនាបជងទន្លេគង្គា ដែលជារាជនអរិយក:ទាំងអស់ ។ ការដែលធ្វើឲ្យបានជាន្តាយចៅហ្វាយលើប្រទេសឥណ្ឌូចិនាំងមូលបាន នោះមានតែ ១ ផ្លូវ គឺលុកចូលក់យខាងខែត្តរាជនដ ដីកក័ន ដូចយ៉ាងពាជវង្សគុប្ត: បានធ្លាប់ធ្វើមកហើយ ។

ប៉ុន្តែថា ពាប់ចាប់ដើមតាំងអំពីសម័យពាជវង្សគុប្ត: មក ដែនដីខាងដីកក័ន មានសេចក្តីចំរើនរុងរឿងឡើងជាច្រើន មិនមែនដូចជាពៃដូចពីមុននោះទេ ។ ពួកដែលមានកំឡាំងខាហានយ៉ាងសំខាន់គឺពួក តាលុក្ស: តាំងនៅកណ្តាលដែនមហាកន្ត្រ មានពាជវង្សក្សត្រខ្មែរស្រឡាយមកអំពីពាជ-ពុត សឹងមានបំណងចង់ធ្វើជាន្តាយចៅហ្វាយធំ ក្នុងខែត្តរាជនដ ដីកក័ន

តាំងមូល ។ លុះព្រះបាទសីលាទិត្យ: លុកលុយចូលមកកាលព័ត្ទសក-
រាជ ១១៦៣ ព្រះបាទ ពូលិកេសុមុ ទី ២ ដែលជាក្សត្រ គាលុក្ស: ក៏បាន
ទំប្រឹងច្បាំងតទល់គ្រាតែព្រះបាទ សីលាទិត្យ: ចេញទ័ពត្រឡប់ទៅវិញក្នុង
គ្រានេះឯង រួបនោមនៃប្រវត្តិសាស្ត្រតណ្ហៀ បានប្រែប្រួលប្លែកព័ត៌កាល
កន្លងមកហើយក្នុងសម័យបុរាណជាច្រើន គោលគំពួកអរិយក:ទឹងបានថា
ខ្លួនមានសេចក្តីចំរើនហើយខ្លាំងពូកែ ជាងពួកមិលក្ខ: តទៅទៀតមិន
បានទេ ហើយក្នុងខណៈនុ៎ះឯង ដែនដីតាំង ២ ភាគរបស់តណ្ហៀមានអំ-
ណាចនឹងអារ្យធម៌ប្រហែលៗគ្នា ហើយតាំង ២ ចំណែកក៏កំពុងប្រណាំង
ប្រជែងគ្នា ដោយអាស្រ័យអំណាចពីប្រទេសខាងក្រៅចូលមកជួយផង ។
ព្រះបាទ ពូលិកេសុមុ ទ្រង់ព្យាយាមចង់ស្ថាបនាមេត្រីនឹងប្រទេសបែរ្យ៉ា ចំ-
ណែកខាង ព្រះបាទសីលាទិត្យ: ទ្រង់ព្យាយាមចង់មេត្រីនឹងប្រទេសចិន
ក្នុងសម័យនោះ ព្រះបាទវៃសុង កំពុងមានវិទ្ធីអំណាចយ៉ាង
រុងរឿង ហើយទ្រង់បានពង្រីកអាណាខេត្តចេញមកហួតដល់ភ្នំហិមា-
ល័យ ។ ព្រះបាទវៃសុង ទឹង ព្រះបាទ សីលាទិត្យ: ធ្លាប់មានរាជទូតទៅ
មកការគ្នាជាច្រើនគ្រា តមកទាល់តែដល់ពុទ្ធសករាជ ១១៧៣ ទើប
មានសមណទូតរបស់ចិន ១ អង្គ ឈ្មោះយួនឆាង ចាកចូលមកក្នុងប្រទេស
តណ្ហៀ ដែលគួរកត់ចាំជាប្រវត្តិការណ៍ដ៏សំខាន់ ១ គ្រាទៀតនៃលទ្ធិ
មហាយាន ។

លោកសមណ យួនឆាង ឬដែលហៅតាមភាសាចិនថា "ថ័ងសឹម-ច័ង" ចាន់ចូលមកដល់ប្រទេសឥណ្ឌា កាលពុទ្ធសករាជ ១១៧៣ នោះ ធ្វើឲ្យយើងបានដឹងប្រវត្តិរបស់ឥណ្ឌាក្នុងគ្រានោះបានច្បាស់លាស់ ដូចគ្រាសមណខូត ជាង់មុននេះដែរ ។ ព្រះសមណាយួនឆាងបានចូលមកខាងស្រុកគុន្ធារៈ ហើយដើរមើលវិហារវត្តអារាមក្នុងតំបន់អស់នោះហើយ ទើបទៅស្នាក់នៅនឹងព្រះសង្ឃកស្មីរៈ ជាវេលា ២ ឆ្នាំ ដើម្បីចម្លងយកគម្ពីរដើ-ការផ្សេង ។ ។ តអំពីនោះទៅ ទើបដើរមើលអនុស្សាវរីយ៍ពុទ្ធសាសនា ដែលបានខ្ទុះខ្ទោមអស់ទៅជាច្រើន ហើយសូម្បីតែក្រុងពារាណសីក៏ តើតមានវិហារព្រាហ្មណ៍ តើតឡើងជាជំនួសពុទ្ធសាសនាជាច្រើន ។ ព្រះសមណៈយួនឆាងបានទៅដល់ក្រុងកបិលពស្តុ, កុសិនារ, ពាជគ្រឹះ, ពោធិគយា, ហើយចូលទៅមើល វេឡុវនមហាវិហារ ។ ក្នុងវេលានោះ នៅខាងក្រៅក្រុងពាជគ្រឹះមានមហាវិទ្យាល័យដ៏សំខាន់ ១ អន្លើ សម្រាប់ជាកន្លែងរៀនសូត្របរិយត្តិធម៌ មហាវិទ្យាល័យនេះឈ្មោះថា នាលន្ទៈ ដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្រអង់គ្លេស ចូលចិត្តហៅថា អុក្សហ្វត៍ របស់ឥណ្ឌា ។ មហាវិទ្យាល័យនោះជាទីប្រជុំរួមគម្ពីរព្រះពុទ្ធសាសនា ហើយមានភិក្ខុសង្ឃទៅសិក្សារៀនសូត្រជាចំនួនពាប់ហ្មឺនរូប ។ អំពីចំណោទដែលចោទសួរគ្នាជានិច្ចក្នុងមហាវិទ្យាល័យនេះ គឺនិយាយអំពីលទ្ធិមហា-យាន ន៊ឹង ហីនយាន តើខាងណាប្រសើរជាង ហើយពុទ្ធសាសនានឹងសាសនា ហិណ្ឌូ តើខាងណាប្រសើរជាងគ្នា ។

កាលខាងវិទ្យាល័យចាន់ដំណឹងថា មានសមណទូតមកពីប្រទេសចិន ក៏នាំគ្នារៀបចំចាំទទួលអ៊ឹកធឹក ព្រះសមណៈយួនឆាងចាន់ជួបប្រទះនឹងអ្នកចេះដឹងសំខាន់ៗ ក្នុងមហាវិទ្យាល័យនោះបែកខាងព្រះពុទ្ធសាសនាជាច្រើនណាស់ ហើយលោកចាន់នោះក្នុងមហាវិទ្យាល័យនាលន្ទៈរាល់វេលាដល់ ៥ ឆ្នាំ ដើម្បីចម្លងយកគម្ពីរដីកាផ្សេងៗ ដែលមាននៅក្នុងមហាវិទ្យាល័យនោះ ។ មួយវិញទៀត យើងត្រូវដឹងថា ការចម្លងគម្ពីរដីកាផ្សេងៗក្នុងគ្រានោះ មិនចាន់ចម្លងត្រង់ៗតាមភាសាដើមទេ តែច្រើនបែរចេញជាភាសាចិនស្រេចទៅវិញ ឬមានខ្លះដូចព្រះពុទ្ធឃោសាចារ្យទៅចម្លងគម្ពីរពីលង្កានោះ លោកចាន់បែរធ្វើមកជាភាសាតន្តិភាសា ដោយមិនចាន់ចម្លងយកភាសា ស័ង្ស្រឹតឡើយ ។ ព្រះសមណៈយួនឆាង ចាន់ចេញពីមហាវិទ្យាល័យនាលន្ទៈ ហើយដើរទៅមើលស្រុកផ្សេងៗ ទៀតនៅខែត្រជិនដឹកកំនត់ រួចត្រឡប់មកមហាវិទ្យាល័យនាលន្ទៈវិញទៀត ។ ក្នុងសម័យនោះ ខាងខែត្រជិន អស្សាំ ឬ ថៃគាហុម ឬមានឈ្មោះហៅម្យ៉ាងទៀតថាតាមរូបនោះ ប្រជាជនដោយច្រើនគោរពកាន់សាសនាហិណ្ឌូ តែព្រះចៅផែនដីធ្លាប់គោរពកាន់ព្រះពុទ្ធសាសនា ទើបត្រង់និមន្តព្រះសមណៈយួនឆាង ឲ្យចូលមកកាន់ខែត្រអស្សាំ តែទៅមិនចាន់យូរប៉ុន្មាន ព្រះចាន់ សីលាទិត្យៈ និមន្តឲ្យចូលមកកាន់ស្រុក គាឡាដ ព្រះចាន់ សីលាទិត្យៈ ត្រង់ខំនុកបំរុងឧបត្ថម្ភព្រះពុទ្ធសាសនាលទ្ធិម-

ហាយានដោយពិតប្រាកដណាស់ ទើបគេដាស់ត្រូវនឹង លទ្ធិសាសនាព្រាហ្មណ៍ រហូតដល់ទៅជាសត្រូវនឹង លទ្ធិហីនយាន ផង ឯការទទួលព័ប់ផ្តែព្រះសមណៈយួនគាង នេះ ប្លាន់រៀបចំធ្វើយ៉ាងអឺកធឺកមហាឡារណាស់ មានក្បួនជំរើហែដល់ចំនួន ៥០០ ។

សមណៈយួនគាងប្លាន់ចេញពីប្រទេសឥណ្ឌៀទៅ តាលព័ពុទ្ធសក-រាជ ១១៩១ ហើយតមកមិនយូរប៉ុន្មាន ព្រះបាទសីលាទិត្យក៏សោយទិវង្គតទៅ ។ តព័ពេលនោះមក ប្រវត្តិសាស្ត្រឥណ្ឌៀក៏ប្រែប្រួលប្លែកពីដើមទៅតែម្តង គឺឥណ្ឌៀខាងដើមដែលធ្លាប់មានសេចក្តីចំរើនរុងរឿងជាបំផុតនោះ ប្រែត្រឡប់ទៅជាកើតរវើកឡើងច្រើន មេទ័ពរបស់ព្រះបាទ សីលាទិត្យ ម្នាក់ឈ្មោះអរទដុន ប្លាន់តាំងខ្លួនឡើងត្រួតត្រាជបល័ង្កទៅស្រុកកាន្យាជ ។ ចំណែកខាងស្រុកចិន ព្រះមហាក្សត្រចិនធ្លាប់មានមេត្រីស្និទ្ធស្នាលនឹងព្រះបាទ សីលាទិត្យ នោះ ក៏បញ្ជូនពលទូត នៃអរទដុន មិនព្រមទទួលតាមផ្លូវដែលមានស្ពានមេត្រីនឹងគ្នា ត្រឡប់ជារុញពលទូតចិនផង ទើបកើតមានជាសឹកសង្គ្រាមឡើង ។ ឯការដែលប្រទេសចិនធ្វើការច្បាប់ច្បាម អរទដុន មិនចាំច្បាប់លើកពលទ័ពមកពីស្រុកចិនទេ ដ្បិតពួកមនុស្សដែលមានឈាមក្តាន់ណាខែត្រឥណ្ឌៀនោះឯង សុទ្ធតែស្ម័គ្រចិត្តទៅច្បាំងដើម្បីប្លន់ដណ្តើមយកទ្រព្យរបស់ព្រះមហាពជដែលមានព្រះពជទ្រព្យស្តុកស្តម្ភ ។ (ម្ភ៩៣)

រឿងកោតកុលសុមារ

លោក ទុតញ្ញាព្រះឃ្លាំង នង រៀបរៀង

(តមក)

ស្តែងស្តេចបើកបន្ទូលទៅ គ្រាស់ថាម៉ៃហេទៅ គោតកុលជាបុត្រស្នេហា ។ ចាមើលអម្រាមមាត្តា កវិយានៃចា គ្រងំណាចាប់ឲ្យត្រូវត្រង់ ។ ព្រះពោធិសត្វវរវង្ស ស្តាប់ស្តេចគ្រាស់ទ្រង់ បង្គាប់ឲ្យចាប់ហត្ថា ។ អ្នកទតទៅយល់ដូចគ្នា ពុំស្គាល់គ្រងំណា ជាក់ជាព្រះហស្តក្សត្រី ។ តែជះហេតុព្រះចារមី ទើបព្រះគោសីយ៍ កាឡាអង្គាគួរគាប់ ។ ជារុយមាសមួយមកផ្ទាប់ ខាងព្រះស្រោតស្រាប់ ខ្សឹបប្រាប់ព្រះពង្សពុទ្ធ ។ បើអ្នកពុំស្គាល់ហត្ថា នៃនាងសុខុមា រន្ធាទេវីវរវង្ស ។ យើងទៅទំនៅនាចុង អម្រាមចាប់ត្រង់ ណោះឯងព្រះហស្តធីតា ។ ប្រាប់ហើយទៅទំម៉ឺម្ចា ទើបអ្នកប្រាជ្ញ ចាប់តាមតែរុយទៅទំ ។ អ្នកខូលក្សត្រីថ្លៃឧត្តម ម្រាមកវិយាខ្ញុំ នេះឯងប្រាកដជៀងជាក់ ។ ទើបនាងសុខុមារ-លក្ខណ៍ ចេញមកសំណាក់ សំណេះសំណាលសាកសួរ ។ តួនអង្គាគង់គាល់គួរ បិតាស្តេចស្រួល ព្រះទ័យត្រេកសោមនស្សា ។

បទកាកគតិ

កាលណោះព្រះបាទ សត្តភូដកជាតិ ជាព្រះបិតា យល់តេជតេជះ តបះរិទ្ធា បុណ្យបុត្រប្រសា ប្រសើរពេកក្រៃ ។ គ្រាកាលកន្លង

រម្ងងប្រុសផង ទីរអ្នកដទៃ ណាខ្មីងធ្មមបាន ក្បត្រកក្បាន្តដេស្តង្គ័យ ត្រៃក
ត្រាស់ថាហៃ មុន្ត្រីសេនា ។ អញខ្មីងអកំ - សេករាជបុត្រី ខៅបុត្រ
ប្រសា សេតសោយរាជស្នង ត្រៃប់ត្រៃងស្ងីមា ចូរអស់ត្រៃប់គ្នា រួសរៀប
រណ្តាប់ ។ តាកតែងក្នាក់ងារ រកបណ្តាការ តាប់គួរដោយច្បាប់
មន្ត្រីអាមាត្យ បរបាទនស្តាប់ ខ្លួលបង្គាប់ បង្គំលុតលា ។ បរចុះដើរ
ដល់ ទីហានមណ្ឌល ប្រាមប្រាប់គ្នីគ្នា រួសរកកសុកាវ ដោយងាវអោត្តា
ប្រដាប់ប្រដា បញ្ជាប់ខ្លួលខ្លាយ ។ ខ្លះទៅស្រុកស្រែ រួសរកបន្ទែ
សណ្តែកតពាយ ម្ហាស់ខនោងខៅ រះរៅខ្លួន្តាយ ខ្លៀមខ្លឹមគុយនាយ
ត្រឡាចម្រែចខ្ញី ។ ម្រះម្ងសុំ ក្រសាំងទំហំ លីងលាក់ភ័ក្តដំរ ក្រូប
ត្រាប់រលីង រំដេងផ្លេងផ្លែរ សណ្តែកកន្ទងដំ រមៀតម្រះព្រៅ ។ ឥឡឹក
ស្ងឹកត្រៃ ត្រសក់ស្តីស្តៃ ឃ្យោកល្ហុងត្រប់ត្រៃ ចេកតតត្រយូង អំបូង
ខ្លួនទៅ ចេកផ្ងាអំពៅ អំពិលក្រសាំង ។ ខ្លះរកដំឡូង ឈាមមាន
ត្នោតជូង ដំឡូងជ្វាភំង ដំឡូងដៃខ្វា តុត្រាខ្នុំរណាំង ក្តីបស្វាយទំពាំង-
ដូរដីរសែពៅ ។ រកបានសព្វត្រប់ ដោយមុខងារសព្វ មន្ត្រីកងក្រៅ
ទើបប្រើអាជ្ញា ។ យាត្រាប្រាប់ហៅ ខុនណាងឲ្យទៅ អង្គុយពេង
ថែម ។ ខុនណាងខ្លួនខ្លះ សម្បុរសេដ្ឋះ ខ្លះទៅសាអែម មុខមាត់ខ្មីមរឹម
ញញឹមញញែម លាបប្រែងរលេម រលង់ស្ងើរស្រស់ ។ ខ្លះដោះ
សណ្តាយ មុខស្រស់រីកឆាយ យកស្លឹតសិតសក់ លាបប្រែងផាត់មេ្ល

ម៉ែលទៅកញ្ចក់ ក្រែងខ្លួនអាក្រក់ ប្តីមិនស្រឡាញ់ ។ នាងខ្លះដោះក្បាំ
ពាក់អាវសសម សក់វែងភ្ជាប់ភ្ញាញ់ ស្បែកខៀនហាន ធ្លាស្រកាលេញ
យាងយាសចរចេញ ពីផ្ទះអាត្មា ។ នាងខ្លះដោះញារ ពាក់អាវត្រែស
ដណ្តប់កាសា ស្បែកសំពត់ហូល បរិបូណ៌ខៀនធ្លា ផាត់មេ្យគន្ធា
បញ្ចើអង្គអាត្ម ។ នាងខ្លះញែ៉ងញ៉ង បួងបត់សក់ចង រូបរាងស្អាងស្អាត
ថ្ពាល់ម៉ដ្ឋប៉ផ្សរ ស្បែកហូលសុទ្ធតាត ចរចូលប្លាសាទ ដើងខៀន
ទិព្វទៅ ។ ខុនណាងចាស់ៗ ឆ្ងិតឆ្នើងថ្ងៃណាស់ ងូតទឹកលាបមេ្យ
បែរបើកកញ្ចក់ ឆ្លុះមុខមើលទៅ អង្គឯងហាក់នោ ក្រមុំពាលពិត ។
ថ្ពាល់ឆតសងខាង ខិតខំស្អិតស្អាង បួងសក់កំប៉ុត សក់ស្រោតសត្រោង
ខ្លងកោងដោះស្លិត ក្អែកសោតឆងឆីត រួសរៀបចង់ស្អា ។ ឆ្នេញប្លាក់
គ្រហុប បបូរមាត់ខុប ស្តួរគិតអនិច្ចា នៅតង់តែកង ខំស្អាងអាត្មា ខ្លើង
លើះថា ជាន់ជិះចរទៅ ។ ខ្លះដំរីត្រែស្នែង តលាលសោតសែង
ជង្រែខ្លះខ្មៅ ខ្លះអង្រឹងយួន ស្នែងបួនហែទៅ ខ្លះដើរសំដៅ អង្គុយ
ពេងថែម ។ ស្រែឆដឹស្មា ឆួបជំនុំគ្នា ញ៉ាញឹមញាញែម ដេរកន្ទោង
គ្រប រៀបរបស់ខ្លែមសែម នាងខ្លះធ្វើណែម ធ្វើនំប្លាកំង ។ នំឆ្អែនំតម
នំកូរអន្សម កនេ្លាមចាបចាំង នំចាក់ក្រចាន់ ច្រែនជាន់មានភាំង
នំស្ងោនំអាំង ត្រាបលួងខ្លៀន ។ ខ្លះធ្វើនំប៉ោ .ខ្លះធ្វើអមេ្ល
សណ្តែកនំខៀន នំខន់ពេញខ្ចប់ នូវនំផ្លែមៀន នំដូងក្រៀន នំខ្ទិ-

សង្ឃ្យា ។ ខ្ញុះធ្វើនំក្រៀប បត់ចានដាក់ទៀប នំកន្ទុយប្រា លំអង
រំចេក កងលេខដ្ឋាលា នូវនំចាយស្រា នំគ្រក់ក្រូចក្រាយ ។ នំខ្ទួត
ក្រចៅ នំបង់ខ្ទាញ់ខៅ នំឈ្មោះចែតាយ គ្រាបលាងនំគ្រាប នូវនំ
ផលអាយ នំស្រួយនំធ្លាយ គ្រប់ពណ៌ស្រែចស្រាប់ ។ ខ្ញុះលូកដៃឈោង
ទៅយកកន្ទោង រកវៀបដំណាប់ គ្រឡាចល្អងគ្នោត កន្ទុតក្រូចគ្រាប់
ម្ទាស់ស្វាយខ្ទាប់ ចេកខ្នុរពុត្រា ។ ខ្ញុះធ្វើសម្ល ហុងហើយខ្ញុះខ្ទរ
គោមមាន់ទឹមគា ខ្ញុះស្ងោរជើងជ្រូក គ្រាប់ឈូកលាយគ្នា ខ្ញុះញាំខ្ញុះភ្ងា
ខ្ញុះភ្លក់លមើល ។ ខ្ញុះស្ងោរសេរីស ខ្ញុះស្ងោរមើមស្ពៃ ខ្ញុះភ្លក់បណ្តើរ
ខ្ញុះសូម្បរថ្នឹង ធ្យូនឹងសាច់ឆ្អើរ ខ្ញុះអាំងខុកឆ្ងៃ សូផ្កាត្រចុក ។ ខ្ញុះបេះ
សាច់ត្រា សាច់មាន់សូផ្កា ទឹកនំបញ្ចុក ខ្ញុះសូប្រហើរ ខ្ញុះធ្វើហាំ៉ុក
ធ្វើខ្សងសម្រក[1] បណ្តេញភ្ញៀវផង ។ ខ្ញុះសូទំពាំង ខ្ញុះបេះត្រីអាំង
ញាំនឹងសម្រង ខ្ញុះញាំគោះប្រា ខ្ញុះភ្ងាបង្គង ខ្ញុះយកអង្ក្រង ញាំនឹង
ប្រស់ស្វា ។

---

១ ខ្សងសម្រក ជាឈ្មោះម្ហូបមួយមុខ។ របស់ខ្មែរពីដើមជាម្ហូបដែលត្រូវលើកដួងភ្ញៀវ
បុងក្រោយចង្កៀស ក្នុងទាកសមានពិធីបុណ្យជូចជាអាពាហ៍ពិពាហ៍ជាដើម ។ ពួកភ្ញៀវដែល
កំពុងបរិភោគភោជនាហារ តែគេលើកខ្សងសម្រកទៅឲ្យក៏ដឹងប្រាស់ថាម្ហូបអស់ត្រឹមប៉ុណ្ណេះ
ឯង ទើបមានភាសាចំនៀងថា ខ្សងសម្រក បណ្តេញភ្ញៀវផង ។

កាលណោះមន្ត្រី សេនាបតី ឡើងទូលក្សត្រា បពិត្រយើងខ្ញុំ
រៀបចំគ្រប់គ្នា ប្រដាប់ប្រដា គ្រប់គ្រាន់ស្រេចស្រាប់ ។ ក្សត្រិយ៍ថ្ងៃ
ឥសូរ ស្តាប់មន្ត្រីទូល ទើបស្តេចប្រញាប់ រើសរកកូនស្រី មន្ត្រីគួរ
គាប់ ឲ្យមានសណ្តាប់ សន្តានតង្ឃ ។ ខ្លះរៀបដើរហែ កាន់ផ្ទៃតបត់
បែរ ញញឹមបរចា ខ្លះកាន់គ្រប់គ្រឿង រុងរឿងថ្កុំថ្កា ស្អិតស្អាងអាត្ម
ហែរាជបុត្រី ។ នាងខ្លះមុខមូល ថ្ពាល់ម៉ដ្ឋប៉ផ្លូរ កាន់ព្រះវីជនី ព័ទ្ធាត់
ពាក់អាវ លាវខ្មៅស្រស់ថ្មី ស្បៃកខៀនផុះភ្លឺ រល្បីឈរបនា ។ នាង
មួយមុខម៉ដ្ឋ ខ្លួនស សិតត់ ស្រគាំកាយា ពាក់ពណ៌អាវលាវ ផាត់
គារសោភា កាន់ព្រះតនិច្ចា អង្គុយគង់គាល់ ។ នាងមួយមុខប៉ែន
ដោះស្រាលក្បាំណែន កាន់ពានព្រះស្រី ពាក់អាវលាវខៀវ ពង្រៀវ
តន្ត្រីយ៍ ស្បៃកខៀនលេចចំ ធុលធុះសឹងឆ្កា ។ នាងមួយមុខឈ្ងន
ថ្ពាល់ផ្លូរបំព្រង ធង់ធាត់សុគន្ធា ពាក់អាវប្បាបច្បាស់ ជំទាស់ហត្ថ
កាន់ព្រះគូសា មាសមែពណ្ណរាយ ។ នាងមួយមុខឈរ ផ្អៀងផ្អង
ថ្ងៃចថ្ងូរ អំពើកែក្រាយ ថ្ពាល់ធូរធាត់មេ្យ ពាក់អាវលាវស្វាយ កកាន់
ព្រះឆាយ ព្រះសំអាងអង្គ ។ នាងមួយមុខរាង ប្លងបត់កេសា ថ្ពាល់
ផាត់ផ្លូរផង់ ពាក់អាវដកគាំ ស្រគាំបញ្ចង់ បញ្ចើមានត្រង់ កាន់ពាន
ព្រះស្រី ។ នាងមួយមុខដេច ដោះតូចខ្ទើបចុច ស្បៃកខៀនទេសថ្មី
ពាក់អាវក្រហម ល្អាត់ល្មមតន្ត្រីយ៍ ស្រគត់ប្រឹមប្រិយ៍ កាន់ពានព្រះពស្ត្រ

សឹងភាក់សសាល់ ស្ងៀតសក់ផ្កាញ់រ សឹងដាំតួងបុស្ប ពាក់ចិញ្ចៀន
ច្រាល ខ្មោលស្រៀបស្រស់ សំកសមកំពស់ កំពុងពេញពាល ។
ស្តេចឲ្យរើសប្រុស ធោមធាយស្រៀបស្រស់ ហៃបុត្រកូឋាល សឹងកូន
មន្ត្រី ពីសីពិសាល មានរូបត្រគាល ត្រកូលថ្លៃថ្លា ។ ពាក់កង
ចិញ្ចៀន ស្ងៀកសំពត់ខៀន អាវផាយកាសា ពណិពាក់កាន់
សុវណ្ណបទុមា ហៃបុត្រប្រសា ប្រសើរសោភ័ន ។ កាន់ព្រះវីជនី
កាន់តានព្រះស្រ័ ព្រះខាត់ព្រះខាន់ ព្រះសិទ្ធិរស ព្រះពស្ត្រកៅឥណ្ឌ
កាន់ព្រះសោភ័ន ព្រះស្រីព្រះធាយ ។ កាន់ព្រះកនិដ្ឋា ព្រះសុគន្ធា
រៀបពល់រៀងពាយ ទន្លែងទន្ទាំ លំនាំឆើតធាយ តើលកាងតែកាយ
យាសយល់សត្តិសម ។ ទើបស្តេចឲ្យគ្រាល រួសរៀបកម្រាល ព្រះ
កដរោងរម្យ ពួកតាសខ្លាត់ខ្លែង ចាត់ចែងចៀមចំ ខ្នល់ខ្ទើយព្រៃព្រំ
ប៉ាក់ឆ្នាក់ចេនា ។ ពីជានពីជាស រំយោលគេញពាស សំយុងមាលា
ស្ងួតប្ដីត្រធាយ រំកាយសោភ័ន ចាំង់ព្រះសន្ធិយា ជុំក្នុងព្រះហាន ។
ឯអង្គមន្ត្រី សេនាបតី ប្រជាប់ខ្លួនច្បាណ ស្ងៀកល្បើកហានខ្មៅ ពាក់
អាវផាយប៉ាន សៃសយមាសមាន តាមបណ្ដាសក្តិ ។ អ្នកខ្លះស្ងៀក
ខៀវ បបូរដើងខៀន ខ្លះស្ងៀកសឹងប៉ាក់ បង្ហិតបន្ទាយ ជ្រលាយល្បើក
ឆ្នាក់ សឹងសៃសយដាក់ រំលេចផុះផ្កា ។ យួរថងដៃម្ខាយ ដៃម្ខាងបង់
ចោយ កាន់ផ្ទិតលីលា ឡើងលើកជវេ ច្រើនក្តាត់ត្រៀបត្រា តង់

គាល់ព្រះបាទ តាមដោយសក្តិសម ។ ឯអស់ខុនណាង ដំណាងខ្លួនាង ស្រីង្គារព្រះស្នំ លាបច្រែងច័ន្ទន៍ចួង បត់ចួងសក់សំ - ពោងពាក់បំរបៃពេកា ។ ស្អិតស្អាងតួតែង ដណ្តប់សៃរ្យវែង សសឹងគាសា យួរចង់ឡើងគាល់ រៀងរាល់រៀបគ្នា តាមដោយសក្តិតា ធំតូចខ្ទីខ្ទៃ ។ ទើបព្រះមហាក្សត្រ ឲ្យស្អាងបុត្រវត្ត ពីរពង្សប្រពៃ សឹងគ្រឿងទិព្វខែន ចិញ្ចែងថ្ងាថ្ងៃ មែនមានដំឡៃ តតឯគណនា ។ ព្រះពោធិសត្វ ទ្រង់ព្រះមកុដវត្ត រុងរឿងរចនា អាវាមវត្តាយ ធ្វើតធាយសោភា កណ្តាលខេត្ត សង្ឃារកុងក ។ ទ្រង់ព្រះភូសា ដាយប៉ាន់ចាក់ផ្កា ដារូបនាគនរ ស្រែការំលេច សឹងគេចប្រវែ ហាក់ហែលដើយង រូវស់សក្តិសិទ្ធិ ។ ទ្រង់ព្រះពស្ត្រដាយ ពណ៌ស្រែតដើតដាយ ប៉ុតប៉ុនល្អពិត សឹងស្រែសយស្រែម រិសេសរិសិង្ក ដាក់ដាំរិចិត្រ រំលេចថ្នក់ផ្កា ។ ព្រះហស្តទ្រីសទ្រង់ សឹងព្រះខម្រង់ ពេជ្រពិទូរ្យា ខ្ចីមពាំងខ្ចីករិល មហានីលតារ មរកដមុក្តា បទុមរាគរាយ ។ ខ្នុបព្រះអង្គ មាសរៃមសឹងតែ ពេនតំខ្ពស់ស្អាយ ខែងខ្ចីមទាសទាត់ ដាំដាក់ត្នោយ រឿងរ៉ាំរ៉ីសាយ ភ្លឺឆ្វេកពេកក្តាត់ ។ ស្នាបព្រះឆង្ឃា សុពណ៌ចាទា សឹងមាសពិចិត្រ ខ្លាក់ខ្លៅក្បូរក្បាច់ រំលេចដាំជិត តែរតែមតាលតិត រៀបរៀងប្រពៃ ។ ឯនាងសុខុមា ខ្លោធីតា ទ្រង់គ្រឿងទិព្វថ្ងៃ មកុដតែវតង អម្ពរណ៌ល្អត្រៃ ហាក់ស្រីសួគ៌ត្រៃ - ត្រឹង្សាសមសក្តិ ។ នាងទ្រង់

ព្រះពស្ត្រ ប្រទៃស្រៀបស្រស់ សែសយដាំជាក់ ពយត្នេរចនា ដោយ
ឆ្លាតឆ្នាក់ ទ្រង់ព្រះសុភ័ក្ត្រ វែងកសល្អល្អះ ។ ទសគុលីទ្រង់ សឹង
ព្រះទម្រង់ ត្នេរឿងត្រចះ ត្រចាចត្រចង់ អស់រង្គេហាក់ព្រះ ច័ន្ទចែង
រឿងរះ ពីបូព៌ាទិសទី ។ លុះបានពេលា នាទីលក្ខណា ទុត្តមយាមបី
ឫក្សបើកបរីហាន ដោតមានសួស្តី ទើបព្រះពោធី ទ្វេវាជធីតា ។ បរចេញ
ធ្មឹមផ្ទាល់ ទនអង្គគន់គាល់ ទន្ទឹមផងគ្នា ប្រញ្ជាប្រាណប្រណម្យ បង្គំវន្ទា
ព្រះវរបិតា មាតាក្សត្រី ។ ពីព្រះមហាក្សត្រ បង្វែរាស្ត្រដ្ឋ ពាជ
ប្រវណ៌ ឲ្យរាជបុត្រស្នង គ្រប់គ្រងបូរី ចំរើនវុឌ្ឍី - ទាំងពីរបុត្រកូ ។
អស់អង្គព្រាហ្មណ៍ព្រឹទ្ធ សុទ្ធសេយ្យសាស្ត្រសិទ្ធ ចំរើនជយ៍ ថ្វាត់ថ្វាយ
ព្រះពរ បវរសេដ្ឋា សិរីវិយោ - យុយឺនសួស្តី ។ ផ្ទុំត្រៃសង្ឃសម សំពូ
សូវរងំ ទទួងកេរ៉ៃ គោះគងប្រគំ សូវសំភួតន្ត្រី សាដៀវខ្ទុយប៉ី ស្រទៀ
ពាទគង ។ ក្ងេរកនគ្រែតន្ត្រែ ចាប៉ី ។ អរ តែនកខ្ទេរគង សម្ពោ
រនាទ ពិណពាទ្យឈឹងធង ស្គរជាស្គរទង ស្គរទួងស្គរទ័ព ។ ស្គរក្ងេរ
រមនា ហ្គុកស្គរផ្ទះ ស្គរហាតតប្បាប់ ពីងពាំងខ្ទុយស្គរ ដោយពណិ
សម្រាប់ ទង្គេងសូរសំពូ លាន់ឮព្រមគ្នា ។ ទើបអស់ព្រះវង្ស ព្រះ
ញាតិនៅអង្គ មន្ត្រីសេនា ក្រុញក្រាបបង្គំ ប្រណម្យពាជា ក៏ចូលគ្រប់
គ្នា ចំរើនព្រះស្រី ។ កូចព្រះហស្តក្សត្រ ពីពង្សរុបរត្ន តស្ងួរសិរីសី
ទើបដោះអាវផាយ កែក្រាយខ្ទី ក្រុញក្រាបឃ្លានបី ជងដោះខ្លីងកំ ។

ប្រែប្រឹងប្រាណប្រញ ការងារគង្វញ ខន្ធដងខ្នាំ តាមបទចៅឃុន
ទន់ភ្លន់លំនាំ ភរែកវេរ៉ា បីបទលាតលា ។ អ្នកខ្លះមានឡាស ខំឡើង
ខ្សែខ្លះ ញ៉ែរអស់អង្កា ងងិតមុខមាត់ ភ្ញាំងភ្ញាត់ជាតា ខំពាំរេព ជាន
តែមួយបទ ។ អ្នកខ្លះថែចប់ មុខសួតស្ងៀមស្ងប់ ទបចិត្តខំអត់ ក្រួញ
ក្រាបក្រោកឡើង ញ៉ែរដើងខ្នត់ បែកញើសហូរហាត់ លាកលាចរ
ចេញ ។ គេស៊ើចទ្រហឹង អឿនឯងទ្រមឹង ខឹងចិត្តអម្ញេញ ខុនណាង
ពីក្តង រហង់មើលពេញ សឹងបែរមុខចេញ ញញឹមស៊ើចសល់ ។
ពាំរួចគ្រប់គ្នា ទើបលើកក្រយា ស្ងួយស្ងួចដំគល់ លើសុពណិកាជន
ចំញ្ជោចមកដល់ ថ្ងាយក្បត្រនិរមល តាំងបួនអង្កា ។ ភ្នាក់ងារកង-
សោយ លើកកិលអណ្តោយ អណ្តាប់រៀងគ្នា ថ្ងាយថ្ងាត់ចំចាំង រួត
ពាំងសន្ធិយា ស្តេចសោយនុដា ព្រះក្រយាស្ងួយ ។ ទើបអស់មន្ត្រី
លើកគោកចំណី មករៀបជាក់ដោយ មុខឯងទីវៃ លាងដៃជាគ្រោយ
ធីហៃស្តេចសោយ បរិបូណ៌ស្កល់ស្កប់ ។ តាំងបួនព្រះអង្គ ស្តេច
យាត្រាត្រង់ ទតល្បែងមហោស្រព លោតគុនពេនត្បាល់ ប្រដាល់
ប្រតប់ ត្រីវិស័យសព្វ ក្បួងដើតស្បែក ។ ជាំដូងហក់គោ ហក់ជាវ
រត់គោ មានតាំងទំពែក ដើយងដល់គ្នា ល្អដាចំឡែត ក្បាច់ស្រួល
ល្អពេក សៀមបួននាងក្រោយ ។ ពាំស្នែងខន្ធោង សួរព្រ័ត្រយោល
ខោង ផ្ងារគូផ្ងារាយ ល្ងោនរបាំ រេរាំតែក្រាយ ច្រៀងច្រចនិយាយ

ពីរោះសូរសេម ។ មានតាំងចំប៉ាប់ ស្បៃកខោតាតខ្លាប់ រាងរូបធាត់ធំ ដឹកដៃផ្លុំផ្លាប់ ធ្មឹមផ្លាប់ទំហុំ ឲ្យល្មមស្មុនសម ចូលកន្ទឹមស្មាមជ័យ ។ ប្រញ្ជាប្រាណប្រលេះ តាមរដោយចំណេះ រហៀនពីរៃ លូកដៃដល់ជាក់ កន្ត្រាក់រំលៃរ៉ៃ គេចដោះដុំដៃ ជាល់ដួលស្រាងឆ ។ ផ្ងារដេកនៅដី ជុំយផងធូលី ពេញអស់រូបកាយ ខ្លះចូលប្រចាប់ កៀកខ្ចាប់ពីខាង ខ្លះលោតរ៉ៃរាង សុះសូត្រស្មើគ្នា ។ ខ្លះគ្រាបគ្រាញគ្រាម ប្រឹងផ្ងាយ ទាំងផោម ទាំដីប្រក៉ា ខ្លះធ្លាក់ជាជ្រោង ចំកោងអាត្មា ហួនហាក់បាទា ដោះគេចរំលៃរ៉ៃ ។ ខ្លះនៅពីលើ តាមតែនឹងធ្វើ រកកល់គុណរ៉ៃស្រែ ខ្លះលូកខ្លះចាប់ ថ្នមខ្ចាប់ដល់ដៃ ទង់ភាញពីរៃ ប្រឹងប្រែប្រាំសប្រាណ រលាត់មុខថ្ងាស់ ក្រោកឡើងខ្វេសខ្វាស់ ដៃជោសខ្លួនប្រាណ គេសើចគ្រហឹង អឺអឺងសំពូសាន ពស្ត្រាងឆគ្រប់ប្រាណ មើលមីរត្រៀបត្រា ។ ខ្លះនុនឱ្យបខ្យៃរ៉ៃ កកេះកកៀរ បង្ហាញគ្នីគ្នា ខ្លះឈរជំទើតចំអើតអង្កា ភ្លាំងក្ងេចឆីស្ងា ច្រហាំងមាត់ ។ ស្តែងស្តេចឲ្យលេងគ្រប់ពណ៌ជាល្បែង មង្គលការរ៉ៃត្រែ ប្រាំពីរទិព្យ នុឡារកត្តាត់ សឹងសូរក្ងេងក្ងាត់ លាន់ឮសព្ទសាយ ។ លុះស្រែចការស្តាល់ បរិបូណ៌មង្គល សាន្តសុខសប្បាយ មន្ត្រីសេនា យោធាទាំងឡាយ ឡើងគាល់រៀងៗខ្លួន តាមដោយក្រិត្យក្រម ។ ព្រះពោធិសត្វ ទ្រង់នាវីរត្ថសេនាសោយសុខស - ម្បត្តិបានពរជ្យទ្រង់ ទុតុង្គទុត្តម ស្តេចចូលបន្ទំ

បន្ទូលត្រាស់ថា ។ ម្នៃហ្អួនទន្ទ្ធ សួនអើយចិត្តបង បង់ចរយោគ្រា យកទាំងហ្អួនសួន ខ្ញុំមខ្ញុនពុំវា ទៅនគរ ពារាណសី ។ បង់មើលគំនិត មេស្រុកកាចគិត ខឹងក្បត្រែអប្រិយ៍ ឥន្ទឹងធ្វើម្តេច កលកិច្ច ទៀតថ្មី បង់ជឹងសេចក្តី ឲ្យអស់ចិត្តភ ។ ស្រីវត្តទត្តម នាងថ្លាយបង្គំ ទើបទូលទៅថា បើម្ចាស់គន់គិត គំនិតម្តេចម្តា ខ្ញុំឥតប៉ិយ៉ា ព្រមតាមព្រះទ័យ ។ ស្តេចស្តាប់នាងនាថ ព្រើសព្រមឱ្យាត ទៀងទើបក្បត្រែថ្ងៃ ពីរពង្សធ្មឹមធ្ងំ បរមសុខសេយ្យ លើគ្រែមាសមៃ រុងរឿងសោភា ។

ចប់ព្រហ្មគីត

លុះព្រឹកព្រាងស្រាងស្រេច ទើបសម្តេចព្រះពាជា នាំនាងនាថលីលា ទៀងតាល់ព្រះបិតាក្បត្រែ ។ ខ្លួវព្រះវរមាតា ទ្រនអង្គាព្រញ ប្រណិបត្តិ ប្រណម្យទូលទៅថ្លៃត ថាបតិត្រែក្បត្រែថ្ងៃថ្លា ។ ព្រើសទ្រង់ខ្លួវព្រះគុណ វិសេសឆ្ងន់តតុបមា ពុំគួរនឹងឃ្លាតឃ្លា ពីព្រះ-ចាទព្រះអង្គនោ ។ គួរតែខ្ញុំបិតហាន ទៅនេះចាន់ទៀងតាល់ហ្មាយ បំរើសព្វថ្ងៃនោ លុះអស់ជីពអស់ជន្ម ។ គឺមានខ្ញុំចង់យល់ បង់ជឹងកលកំនិតវា មេស្រុកនឹងក្បត្រែ ព្រហ្មទត្តចិត្តទុដ្ឋ ។ វានឹងគិតកលកិច្ច ធ្វើដូចម្តេចវិញទៀតខ្លី ខ្ញុំបង់ជឹងសេចក្តី ឲ្យវាធ្វើអស់ចិត្តវា ។

(មានត)

ពន្លឺអាស៊ីទ្រីប

ហ្វូងនិតន្តមន្ត្រី ញ៉ុក - ថែម ប្រែ - រៀបរៀង

(តមក)

តណ្ហៀកគ្រីសន្សឹមៗ ផ្សាយចេញទៅសព្វភូមិភាគក្នុងយប់មានព្រះចន្ទពេញដួងនៃខែចែត្រ:សុទ្ធ (ខែចេត្រ) មៅពេលដែលដើមស្វាយតាំងឡាយប្រែពណ៌សន្ធឹកក្រហមខ្ចី ហើយគុម្ពោតព្រៃអសោក[1] ផ្សាយក្លិនក្រអូបក្រអែបខ្ជួលៗ ហើយជាពេលជិតថ្ងៃ ដែលព្រះពាមទ្រង់ប្រសូត ជាថ្ងៃដែលអ្នកស្រុកស្រែចំការ នឹងអ្នកក្រុងតាំងឡាយមានចិត្តរីករាយសប្បាយតាំងអស់គ្នា ។ ភក្ត្រីនោះក៏សន្សឹមៗ គ្រងជណ្តប់ទៅលើស្រែមរែន ដែលផ្សាយផ្សប់ដោយសុគន្ធពីដោរ, ផ្កែមេយដេរជាសដោយដួងតារាឥតគណនា ហើយត្រដាក់ស្រួលណាស់ដោយក់យោបក់មកពីកំពូលគិរីហិមាលយ៉ា ដ៏ដេរជោរដោយហិម: ពីព្រោះដួងចន្ទ្រារះចេញមកពីក្រោយកំពូលភ្នំទិសខាងកើតឡើងកាន់ខ្ពស់មេយបញ្ចាំងពន្លឺរស្មីដ៏ត្រចះត្រចង់លើរលកទឹកស្ទឹងកេហិនី លើកំពូលើៈជ្រោះដ្រលងត្រមតាំងទឹកលដ៏ស្ងាត់ជ្រងំ ហើយធ្លុះពន្លឺពណ៌ប្រាក់ទៅលើប្រាសាទកំសុខសម្រាន្ត ដែលគេកល់គ្នាកំពុងដេកលក់ស្ងាត់ប្រៀប លើកលែងតែភូតគាហានយាមខ្លោងទ្វារខាងក្រៅ ដែលនាំគ្នាស្រែកពាក្យយាមល្បាតថា "មួច:" ហើយមានពាក្យឆ្លើយថា "អង្គុណ:" នាកាលព្រឹស្សូរស្ពោ

---

១ អសោក (ពាក្យសំស្ក្រឹត អ បុព្វបទ សោក ប្រែថាក្រៀមក្រំ សៅសោក) អសោក មិនសៅសោក ។

ក់យ៉ាយាមម្ដង ។ ហេតុដូច្នេះ ប្រឹងតាំងស្ងប់ស្ងាត់ឈឹងគេចានតែសូរសំឡេងសត្វចចកដែលស្វែងរកចំណីអាហារ និងសូរសំពូសត្វចង្រិតយំរងំក្នុងស្មៅខ្ពក់ ។

ព្រះចន្ទ្រឆ្នូរពន្លឺរស្មីស្រោចលើសំណាមហាច្បារសាខបញ្ចាំងជញ្ជាំងព្រះវិសណ្ឋានដ៏ឆើមច្នៃដរលើបរលង់ - ហើយរស្មីនៃដួងចន្ទ្រក៏ចោលពន្លឺទៅលើហ្វូងកុមារីស្រីក្រមុំដាតំណែ្ន មានរូបឆើតឆោម ១ ក្រុម ដែលនៅក្នុងបន្ទប់តំណាក់ដ៏វិសេស ហាក់ដូចហានស្ងួតជាលំនៅនៃពួកនាងទេវី ។ នៅក្នុងតំណាក់នៃក្សត្រសិង្ខាចំរើនោះ គេស្រាលឆ្លើសរើសរកតែកុមារីមានរូបឆោមឆើតឆាំងអស់មកពុកក្នុងតំណាមួយគ្នា នាងកុមារីអស់នេះមានរូបឆោមគួរឲ្យចាប់ចិត្តស្នេហាណាស់ មានចិត្តសុជរិតស្មោះត្រង់ចំពោះព្រះរាជឧទ្យានណាស់ ដរុបនាងនិមួយៗ សោតៈទៀតក៏គួរឲ្យចាប់ចិត្តប្រតិព័ទ្ធ, ពួកនាងកំពុងនំគ្រាលក់ស្ងប់ស្ងាត់ កាលបើអ្នកឯទៀតឃើញ គួរឲ្យសន្មតថា "នាងនេះឆើតជាងគេតាំងអស់" ។ ប៉ុន្តែកាលអ្នកចោលភ្នែកមើលទៅចំនាងនេះខាងស្ដាំ រួចនាងទៅខាងឆ្វេងតែ្បរៗ គ្មានោះ មុខជាអ្នកឯទៀតថា "នាងនេះល្អជាងគេតាំងអស់" ។ ហើយភ្នែករបស់អ្នកនៅឯព្រឹលស្រាំង គន់មើលនាងមួយមិនចេះឆ្អែតឆ្អន់ ដូចជាស្ត្រីដែលតិនិត្យមើលគ្រឿងអលង្ការរចនាដោយមាសឆ្ងាក់ ដែលមានរស្មីចាប់ភ្នែក មិនចេះជិនឆ្អន់ មិនចេះអស់ចិត្ត ។

នាងតាំងនោះដេកសម្រាកកាយយ៉ាងក្រមក្សាន្ត អាយុវែរបស់នាងមានសំបុរប្រែផេះ មានសំពត់បិទបាំងកាយត្រឹមមួយចំណែកៗ ទៀតទៅទេ ។ សក់នាងលាបប្រែងរលើបរលង់ រួបគួបចងទៅគ្រោយជាមួយនឹងក្បាំងមាសឫកម្រងផ្កា ឬមិនដូច្នោះទេ គឺរំសាយសក់វែងលាយដូចជារលកទឹកសំបុរខ្មៅធ្លាក់ទៅគ្រោយ ប្រកបដ៏វិចិត្តរបស់នាង ។ នាងកញ្ញាអស់នេះកំពុងលន់លក់សិប់ស្នូនសប្បាយ ដោយអស់កំឡាំងនឹងការប្រឹងរាំដូចបក្សីទាំងឡាយមានសំបុរស្រស់ ដែលវាតែងប្រឹងសប្បាយពេញមួយថ្ងៃ រួចវាពួនសម្ងំសឹកក្បាលវាទៅគ្រាមស្បាបដេកលក់ទៅ ដរាបដល់អរុណរះឡើង ក៏តាំងប្រឹងសប្បាយតទៅទៀត ។ តាមប្រទីបផ្កាលា ជាវិការៈនៃប្លុក ចងក្បរនៅពិតានដោយប្រភព្ធប្លុក ហើយដុតសុទ្ធសឹងតែប្រែងក្រអូប មានពន្លឺត្រជាក់ ផ្សំជាមួយនឹងពន្លឺដួងចន្ទ្រកើតទៅជាពន្លឺមួយយ៉ាងស្រទន់ត្រជាក់ភ្នែក ដែលអាចឲ្យមើលឃើញទ្រង់គ្រោយសព្វគ្រប់ នៃពួកនាងកុមារីក្រមុំគួរឲ្យចាប់ចិត្តស្នេហាអស់នោះ ដើមទ្រូងនាងពន់ប៉ោងឡើងតាមឲ្យលំដាបដង្កើម, ប៉ាទៃដែលស៊ីលំទ្រហម[1] ខ្ទះលាដៃ ខ្ទះក្តាប់ដៃ, រវាងភ័ក្ត្រស្រស់ញញឹមមានចិញ្ចើមទៅកោងដូចដងធ្នូ, បបូរមាត់ប៉ើកបន្តិច, ធ្មេញនាងសភ្លឺដូចត្បូងមុក្តាដែលពួកឈ្មួញចងក្រងសម្រាប់ធ្វើជាកងក, ភ្នែកនាងមានត្របកភ្នែក

---

๑ ស្ត្រីហិណ្ឌូនិយមយកជាតិហង្គុ · លាបបាទដៃ ។

រលើបរលង់មានពេមក្នែកបំនែគបរទៅលើថ្ពាល់ដ៏ស្អាត, កវៃនាងមូល ។
ដើងនាងរៀវគូបស្តើង មានភាក់ចន្ត្រឹងនឹងសាយសាយ កាលដែលនាង
ដេកលក់ហើយប្រែខ្លួន ចន្ត្រឹងនោះកំបញ្ចេញសូរសព្ទពិពេរ ធ្វើឲ្យនាង
នោះយល់សប្តិ អរញ្ញញឹមសប្បាយចិត្ត នឹងការប្រែងកំបែបច្នៃ ដែល
នាំឲ្យព្រះពន្ធរសទ្រង់សព្វព្រះពន្ធហឫទ័យ ហើយទ្រង់ឃានប្រទាន
ជំរឿនយ៉ាងល្អ ទុកជារង្វាន់នៃសេចក្តីស្នេហា ។ នៅពីនោះ មានកុមារី
ក្រមុំមួយនាក់ ដេកលក់សុបិត្តដ៏ខ្លួន មានពិណជាក់ប្រហនឹងថ្ពាល់
នាង ហើយវៃនាងកាន់ខ្សែពិណជាប់ ហាក់ដូចកំពុងដេញពិណនៅ
ខ្សឹយ តាមសំតួចំរៀង ដើម្បីបំពេអ្នកដែលបើកក្នែកក្រឡង់នៅខ្សឹយ
ឲ្យលន់លក់នោះឯង ។ មានន្ទាងម្នាក់ដេកលក់ដែរ ដៃឧបតួនក្តាន់
ក្បាលតូច ស្មែងខ្លៅរលើបក្រាបក្រៅបនោះខ្លួនស្តើននាងដែលទុកដូច
ជាខ្នែងប្តីសំបុកដ៏សុខសម្រាន្ត ។ សត្វចតុប្បាទមានភ័ព្វនេះកំពុងដើរ-
កោតផ្ការកូលាបក្រហម ហើយខ្នងវាន់ធឹងនាងម្នាស់ភ្ញាសប្បាណដេកកំ
លក់នៅជាមួយគ្នានៅ ៖ ហើយវៃនាងម្ខាង៖ គោតន់ផ្ការកូលាបនៅខ្សឹយ
ដែលសត្វនោះចូនបរិភោគអស់ពាក់កណ្តាល មានតែបកផ្ការកូលាបនៅ-
ជាប់នឹងបបូរមាត់ក ។ បន្ទាប់ពីនោះទៅ មានកុមារីជាសំឡាញ់គ្នាពីរ
នាក់ដេកជិតខ្ទឹមគ្នា មុនឡើងដេកនាងទាំងពីរចូនត្រង្គាមោគ (Mògra)
ជាក់ម្រងផ្ការយផ្ការយ មានខ្សែដោតជាប់តៗគ្នា ហើយចងផ្សេបគ្នា,

អរិយៈ នឹងអរិយៈ, ចិត្តនឹងចិត្ត, នាងមួយដេកលើផ្ការ នាងមួយទៀតដេកលើស្រីសំឡាញ់របស់នាង ។ មានខាងកុមារីម្នាក់ទៀតខោះ មុននឹងដេកបានយកដុំសិលាមកដោតក្រងធ្វើជាខ្នែក គឺថ្មមានពណ៌ក្រហមប្រផេះ, ផ្កាថ្ម, តួរងថ្មនឹងថ្មសិលាធ្យូង។ ខោកវែងនាងពាក់ខ្សែមួយមានរស្មីភ្លឺឆែក ហើយនាងកាន់ថ្មពណិបៃតងមួយ ដែលគេធ្លាក់ជាខេវ៉ែប ហើយរបនាដោយមាស ដើម្បីយកមកដោតក្រងបង្ហើយជាខ្សែក ។ ឯទឹកស្ងឹងខៅទីខ្សាន កំបោញសូរសំពូទឹកហូរ ភ្នុះធំលន្ធធំលន្ធោច ហាក់បំពេនាងកុមារីតាំងឡាយ ឲ្យលន់លក់ងោងោលើកម្រាលព្រំដ៏វិចិត្រ- ដូចជាផ្កាកុលាបថ្មីៗ រុំក្តោបដោយសន្ទឹក ផ្ទៃចាំងលស់អរុណរះនឹងរីករាយផ្សាយគន្ធពីដោរ ក្នុងខណៈដែលប៉ះនឹងស្មើនៃព្រះទិនករ ។ នេះហើយជាទីបន្ទប់ព្រះតំណាក់ព្រះបរមក្សត្រសិទ្ធាថ៌ ប្រកបដោយសភាព គួរស្នេហាយ៉ាងនេះឯង ប៉ុន្តែខៅក្បែរភាងទីនោះ ជិតចាំងដោយព្រះសន្ធិយា មានរំយោលយ៉ាងវិចិត្រពេក មានខាងនោមឆើតដាច់គេពីខាងដេកលក់ខៅទីនោះ គឺនាងគុង្កា នឹងនាងគោតមី ដែលជាចាងហ្វាងត្រួតត្រាលើចាងចាសាទជាទីស្នេហានោះឯង ។

ព្រះសន្ធិយា មានពណ៌ក្រហមរដ្ឋនឹងពណិខៀវផ្ទៃមេឃ ភ្លឺឆ្លុះដោយងងឹនមាស ចង់សំយុងខៅមុខភ្នំងងឹ ដែលឆ្លើតីខ្ទឹមចំនួនធ្លាក់ជាក្បាច់រចនា មានជណ្តើរបីសម្រាប់ជាន់ឡើងខៅកាន់ក្រឡាបន្ទំដ៏វិសេស

វិសាល មានព្រះវិនយបន្ទូមួយដំណាលនៅលើថ្នាក់ខ្ពស់ ក្រាលដោយសំពត់
ធ្វើពីប្រាក់ហាក់គំនរផ្កាឧទុម្ពរ (Nim) ។ ជញ្ជាំងសុទ្ធតែជាគ្ឃ្លងមុត្តា ដែល
គេយកមកពីសមុទ្រកោះលង្កា ហើយនៅលើពិតានធ្វើពីថ្មកែវ រំលេច
រចនាយ៉ាងវិចិត្រសុទ្ធឧឡារ, ថ្មយ៉ុក ទឹងថ្មមានដំឡែជវែងទៀត ផ្ទាក់ជារូប
ផ្កាឈូក ជារូបបក្សី គួរឲ្យពិតពិលរមិលមើលមិនឆ្អែតឆ្អន់ នៅជុំវិញមហា
ប្រាសាទនៅទឹងជញ្ជាំង ទឹងទីបរិវេណជុំវិញសឹងមានចម្ការចរចនាយ៉ាង
ឆើត, តាមបន្ទាប់ចង្កូច មានពន្ធឹងឆ្លងចន្ទ្រាំងចូលមក ព្រះពាយរំតើយ
ផាត់ បន្សាត់ក្លឹនបុប្ផាដ៏ក្រអូប មានផ្ការម្ងំធារដើម ប៉ុន្តែនៅតែមិនមានលំ-
អអ្វីមួយ ឬចំហាយត្រជាក់ខន់ក្លិនអ័ម្ពុយ អាចយកទៅប្រៀបផ្ទឹមស្មើទឹង
ចំហាយដែលឲ្យាយចេញ អំពីអង្គក្សត្រិយ៍សាក្យៈដ៏ប្រមប្រិយ ទឹងអគ្គ-
មហេសីព្រះនាមយសោធរានោមឆើត ស្រស់ញញឹមស្តេចគង់ជាមួយគ្នា
ក្នុងទីនោះឡើយ ។

ព្រះនាងដើរតែនឡើងត្រមាត់កណ្តាលអង្គ អំពីក្រឡាព្រះបន្ទូ
ដ៏ខន់ក្លិន តែរៀងខាងព្រះពាជស្វាមី ព្រះពុទ្ធ (ព្រះពស្តុជាហ៊ុម) ក៏ដ្រះ
របូតផ្ទាក់មកនៅត្រឹមព្រះអង្គ ហើយព្រះនាងយកព្រះហស្តទាំងពីរខ្ញីព្រះ
នលាដ ទ្រង់នព្រះកាយចុះសម្រក់ទឹកព្រះនេត្រាលើព្រះស្វាមី ។
ព្រះនាងទ្រង់ជុំគ្គិតព្រះសិទ្ធិចរពាជស្វាមី ញាដង រួចទ្រង់ខ្សឹកខ្សួលថា "ន
ព្រះម្ចាស់ថ្លៃខ្ញុំម្ចាស់អើយ ! ទ្រង់តែនឡើង សូមទ្រង់មានព្រះបន្ទូល

ថ្កាប់ខ្ញុំម្ចាស់ឲ្យឃ្លាត់ព្រួយ" ព្រះអង្គទ្រង់តបថា "តើតរឿងអ្វីម្ល៉ូន តុដ៏វិត
មាសបង? ប៉ុន្តែព្រះនាងនៅតែនឹងនឹងខ្លឹកខ្លួល ពុំអាចពោលវាក្យអ្វីដល់
មួយព្រះឧស្ឋឡើយ ។ លុះតមកទើបព្រះនាងក្រាបទូលថា "ទក្សត្រិយ៍
ដែលខ្ញុំម្ចាស់អើយ ខ្ញុំម្ចាស់ធំលក់យ៉ាងសុខសម្បាន្ត ពីព្រោះភាវកដែលនៅ
ក្នុងទ្រូងខ្ញុំម្ចាស់ឃ្លានកំរើកក្នុងវេលាល្ងាចនេះ ហ្ន៎ខ្លួយនៃខ្ញុំម្ចាស់ក៏រំភើប
ញាប់ញ័រត្រេកត្រអាលដោយសេចក្តីសុខ ទឹងសេចក្តីស្នេហាយ៉ាងចំណែក
ហើយកែវភ្នែកទឹងសូរស័ព្ទតន្ត្រីដ៏ពិរោះ ប៉ុន្តែអនិច្ចា! កន្លងណាៈខ្ញុំម្ចាស់
កំពុងធ្លក់ស្រាប់តែខ្ញុំម្ចាស់ឃាយល់សុបិនទុំមិត្ត ជាអតីតក្តីលៗ យ៉ាង
គាលបើទឹកដល់ទំមិត្តនេះ ខ្ញុំម្ចាស់តក់ស្លុតរន្ធត់ចិត្តណាស់ ។ គឺខ្ញុំម្ចាស់
ឃាននេះឃើញគោឈ្មើងកសំបូរសេសុទ្ធ ១ មានស្នែងធំសំបើម ជាគោឧសភ-
ភជ (ស្តេចគោ) ដើរចេញតាមវិថីក្រុង នៅតែធំថ្ងាសមានតួងពេជ្ឈ
មានរស្មីភ្លឺផ្លេកដូចដួងតារា ឬដូចមណីកណ្តុកៈនៃស្តេចនាគ ដួងមណី
នោះបញ្ចេញពន្លឺរស្មីទៅគ្រប់ទាំសាល ហាក់ដូចជាពន្លឺថ្ងៃ ។ ស្តេច
គោនោះ ដើរសន្សឹមៗតាមវិថីទាំងឡាយ សំដៅចេញក្នុងទ្វារព្រះពុទ-
ធានី ហើយគ្មានបុគ្គលណាមួយហានចូលចាប់គោឧសភភជនោះឡើយ
បើទុកជាមានសូរសំឡេងស្រែកថ្ងាប់ពីវេយន្តថ្ងាសាទព្រះតន្ត្រីថា
"ប្រសិនបើអ្នកណាស្គាល់គ្នា មិនចាប់គោនោះចង់ទុកទេ ដោគដ៏យនៃពុទ្ធានី
ឥឡឹងសាបសូន្យមិនទាន" ។ ក៏គ្មានជនណាមួយអាចហានចាប់គោឧសភ-

ភាជនោះឡើយ ។ ខណៈនោះ ខ្ញុំម្ចាស់ក៏សោយសោកហើយតាំងនូបកគោទសកភាជពេញកំឡុងតាំងអស់ ហើយបង្គាប់ឲ្យប្រជាជនពាំងភនៅតាមក្នាងក្នារតាំងឡាយដោយមាំមួន ប៉ុន្តែស្តេចគោទសតក្រវីក្បាលរើបង្រាសរបូតពីដៃខ្ញុំម្ចាស់ទៅ ពាន្យារំលែងបង់អស់ទៅ តាំងដើរចូលទៅដល់តួកយាមល្បាតខ្ចាត់ខ្ចាយអស់ទៅទៀត ។

មានសុបិន ๑ ទៀតក៏ប្លែកអស្ចារ្យ គឺ " មានទេវបុត្រ ๔ អង្គមានរូបឆោមស្រស់បំព្រងមានក្អែកភ្ញីខ្មែកល្អណាស់ ហាក់ដូចជាស្តេចលោកប្លែលដែលស្ថិតនៅនាភ្នំសុមេរុ ទេវបុត្រទាំង ๔ អង្គនេះមានរស្មីព្រាងព្រាយកណ្តាលនភាល័យ ក្នុងចំណោមក្បួនបរិសុទ្ធសឹងតែទេពនិករច្រើនលើសលន់គណនា តែក្បែរកំពែងព្រះរាជធានី នៅត្រង់កន្លែងដែលខ្ញុំម្ចាស់ឃ្លាតយើញទង់ជ័យព្រះតន្លូបក់រវើចលើខ្នងភ្នំរហើយស្រាប់តែឃ្លាក់លំឆ្នាក់ដល់ដី ក្នុងមួយរំពេចនោះ ស្រាប់តែលេចទង់ជាយមួយសំបើមអស្ចារ្យកើតឡើងដំនូលសឹមានព្រួយជាយភ្នំខ្មែក ដោយតួងទឹមរចនាដោយសាយសុយឃ្លាក់ មានរស្មីភ្លឺចាប់ភ្នែក ចារឹកជាពាក្យសុភាសិតច្បាំងពាក្យស្មោក ធ្វើឲ្យប្រជានិករតាំងឡាយកែតឃ្លាសប្បាយគ្រប់គ្នា ហើយនៅខាងទិសបូព៌ មានព្រះតាយបក់រំកើយធាត់ដង់ជាយនោះ ដើម្បីឲ្យមហាជនអានពាក្យទាំងនោះឮបាន ចែមទាំងមានឆ្លាយ៉ាងរិសេសអស្ចារ្យមិនដឹងជាគេបេះយកមកពីប្រទេសណាទេ មានតណ្ហាប្លែកពីណាផ្លាក្នុងសួនច្បារបស់យើង ធ្លាក់ចុះមកដីហាក់ដូចជាទឹកភ្លៀង ។ (មានត)

មហា ទិម-ណាគ្គី រៀបរៀង

(ភាគ)

ឥដមោធតំ បេក្ខ មោធតំ

កតបុញ្ញា ឧភយត្ថមោធតំ

សោមោធតំ សោ បមោធតំ

ធិស្សា កម្មវិសុទ្ធិមត្តនោ ។

បុគ្គលអ្នកធ្វើបុណ្យ ផ្តែលជាគុណល្អនោមនាយ

តែងបានសុខចិត្តកាយ រីករាយក្នុងឥធលោក ។

ទទឹងក្នុងលោកខាងមាយ សែនរីករាយដោយជ័យជោគ

សម្បូណ៌សម្បត្តិកោគ ដោយបុណ្យយោគយោងជួយជ្រោមជ្រែង ។

អ្នកធ្វើបុណ្យនោះ ។ តែងសោមនស្សចិត្តក្សេមក្សាន្ត

ព្រោះឃើញកម្មកល្យាណ បរិសុទ្ធិរបស់ខ្លួន

ឥធ សោចតំ បេក្ខ សោចតំ

ចាបតាវ ឧភយត្ថ សោចតំ

សោសោចតំ សោវិហញ្ញតំ

ធិស្សា កម្មកិលិដ្ឋមត្តនោ ។

ប៉ុគ្គលអ្នកធ្វើបាប　　អំពើនាបឆាប្រតែតី

តែងសោយសោកតិតភ័យ　　ក្នុងលោកនេះលោកខាងនាយ ។

ប៉ុគ្គលអ្នកធ្វើបាប　　អំពើនាបធងំនាំងឡាយ

តែងសោយសោកយំស្ដាយ　　នៅក្នុងលោកនាំងពីរពិត ។

ជនអ្នកធ្វើបាបនោះ　　សោយសោកសុះក្រហាយចិត្ត

កន្លងលោកដោយពិនិត្យ　　ឃើញកំលំដួតមួយខន ។

ទុនកាកំសេចនា ភាម　　ទាបកម្មា បមុច្ចតំ

សាត្តំ ន្ធន តមំសរ្ដ្ឋិ　　សាត្តូ មណ្ឌកកច្ចនា

ឆាតោចសុំសុមាភច　　យេចញ្ញេ ឧបកោចកា ។

បើជនអ្នកធ្វើបាបលាមក　　អាក្រែតដោយការយាយចាចិត្ត

អាចរួចបាតបាបកម្មខ្លួនពិត　　ដោយការប្រតិត្តិលាងខ្មែតបាន ។

នោះមុខជាសត្វអណ្ដើតត្រី　　ក្រពើ នាគភ្លើងាំងប៉ុន្មាន

សត្វទឹតជនៃទៀតគ្រប់ប្រាណ　　នាំគ្នាទៅហានស៊ូគំមិនសល់ ។

សចេ ភាយសំ ងុក្ខេសរ្ដ្ឋ　　សចេ តេ ងុក្ខេមប្បាយំ

មាកាសំ ទាមកំ តម្ដ　　អាវិ ភ យនិ ភវមេភ ។

ប្រសិនបើអ្នកខ្លាំមស្លើមស្លប់　　មិនចង់ប្រសប់តប់ឆួបខ្លួតួ

ចូរកុំធ្វើបាបចំពោះមុខ　　នាំងតង់ទីស្លុតតំប៉ាំងឡើយ ។

ត្រូវសិក្សាទេសនា ចេះសីលភាវនាធម៌
ទាំងវេជ្ជញ្ញ រុបំ ចាត្ថ បឋមជ្ឈានសម្បទា ។
បើអ្នកចង់ប្រាថ្នាសុខសាន្តសព្វ គួរអ្នកខ្មីឃ្លាតអំពីទុក្ខទោមនស្ស
ហើយត្រូវបំពេញនូវបុណ្យចុះ កុំធ្វើបាបសោះដងណាឡើយ ។
បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហា ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។
បុរសបើអ្នកបានធ្វើបុណ្យ ចូរខំធ្វើគុណនោះញយ ។
កុំខុចកុំគ្រាតកុំងាករគ្រាយ កុំថយឲ្យសោកត្រូវស្មោះចិត្ត ។
ស្រឡាញ់ត្រេកអរនឹងបុណ្យនោះ ព្រោះការសន្សំបុណ្យសុចរិត
តែងនាំនាំសុខមកឲ្យពិត សប្បាយកាយចិត្តឥតឃ្លៀងឃ្លាត ។
ចាបញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហា ឆន្ទំ កយិរាថ ធុក្ខោ ចាបស្ស ឧច្ចយោ ។
បុរសបើធ្វើបាបឈាមក កុំដក់ធ្វើបាបនោះញយ ។
ត្រូវវៀសដៀសវាងឆ្ងាយគ្រាយ កុំឲ្យទឹកចិត្តស្ងប់ឥតឈប់ ។
ព្រោះការធ្វើបាបអកុសល តែងនាំនាំផលទុក្ខថោកទាប
មកឲ្យផល់ខ្លួនជាជាប នាំសាបនាំសោយតែសោកសៅ ។
ឧភោ បុញ្ញញ្ច បាបញ្ច យំ មច្ចោ កុរុតេ នរ
តញ្ហិ-តស្ស សកំ ហោតិ តញ្ច អាទាយ គច្ឆតិ
តញ្ចស្ស អនុគំ ហោតិ ឆាយាវ អនុបាយិនី ។

អ្នកធ្វើបាបបុណ្យទាំងពីរប្រការ យ៉ាងណាៗក្នុងលោកនេះពិត
បាបបុណ្យនោះឯងតែងជាកម្មសិទ្ធិ គឺពិតជាច់ខាតជារបស់ប្រាណ ។
លុះស្លាប់ទៅកើតជាតិឃ្លាតជីវិតទៅ ត្រូវគាន់យកទៅកម្មទាំងពីរហូន
ដូចជាស្រមោលអន្ទោលតាមប្រាណ មិនដែលឈប់សាបានពីបុណ្យ
ទើងបាប ។

យាធិសំ វប្បតេ ពីជំ តាធិសំ លភតេ ផលំ
កល្យាណការី កល្យាណំ បាបការី ច បាបកំ ។
បុគ្គលសាបព្រោះពូជបែបណា តែងបានផ្លែផ្កាបែបនោះវិញ
ជនធ្វើល្អផលល្អបំពេញ ជនធ្វើបាបមិញបានផលបាប ។
រថេន សាគរំ យន្តិ ដាភារុប្លេន ឧព្ភតំ
បុញ្ញេន សុគតឹ យន្តិ ចាវេន យន្តិ ទុគតិំ ។
គេទៅកាន់ភ្នំដោយសាររថ ទៅកាន់សមុទ្រដោយទូកភ្ជារ
ទៅកាន់សុគតិដោយបុញ្ញា ទៅកាន់ទុគ្គតិដោយសារបាប ។
ន ហិ ធម្មោ អធម្មោ ច ឯតោ សមវិថាតកិនោ
អធម្មោ និរយំ នេតិ ធម្មោ ចាវេតិ សុគតឹ ។
សភាពធម៌ទាំងឡាយពីរប្រការ ឈ្មោះថាកុសលទើងអកុសល
ឲ្យគុណទើងទោសអសម:ផល អកុសលនាំខ្លួនសត្វទាំងឡាយ
ឲ្យធ្លាក់ទៅកាន់កំណើតនរក ជាស្ថានលាមកគ្រហល់គ្រហាយ
កុសលនាំទៅខ្លួនសត្វទាំងឡាយ ឲ្យសុខសប្បាយក្នុងសុគតិ ។

កត្ញូមេកោ ឧប្បជ្ជន្តិ ឯវយំ ចាបកម្មិនោ
សត្តំ សុកតិនោ យន្តិ តេនិធ្ញតន្តិ អនាសវា ។
សត្តូនាំធម្មាយខ្ញុះតែងវិកវែ ទៅកើតកង្គតិនៃមាតា
អ្នកមានបាបកម្មតែងយាត្រា ទៅកើតទៅនានរកស្ថាន ។
អ្នកមានកម្មជាដំណើរល្អ រមែងទៅកាន់សួគ៌សុខសាន្ត
អ្នកគ្មានអាសវៈកង់សន្តាន តែងទៅនិញ្ញានគ្មានកើតទៀត ។

ឆម្មោ ហាវេក្ខតិ ធម្មចារិំ
ឆម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ឆម្មេ សុចិណ្ណោ
ន ទុគ្គតិំ គច្ឆតិ ធម្មចារី ។

ធម៌តែងរក្សាអ្នកប្រព្រឹត្ត នូវសុចរិតធម៌ស
ធម៌ដែលគេសន្សំដោយល្អ តែងប្រមូលសុខមកឲ្យប្រាណ ។
នេះជាអានិសង្សការប្រព្រឹត្តិ នូវសុចរិតធម៌កល្យាណ
អ្នកប្រព្រឹត្តធម៌រមែងបាន មិនទៅកាន់ហានទុគ្គតិឡើយ ។

សត្តោ បសវតោ មិត្តំ មាតាមិត្តំ សកេ ឃរេ
សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ
សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ ។
ពួកឈ្មួញជាមិត្តអ្នកដើរផ្លូវឆ្ងាយ មាតាគឺម្តាយជាមិត្តកង់ផ្ទះ
សំឡាញ់ទាំងឡាយជាមិត្តវិស្សាស កង់កាលប្រទះកិច្ចការរឿយៗ ។

អំពើកុសលដែលគេប្រឹងប្រែង ធ្វើដោយខ្ជួនឯងសន្សំទុកហើយ
ជាមិត្តវិសេសទៅបរលោកនាយ ជួយឲ្យរីក-រុងរឿងរុងរកេចន៍ ។

តស្មា ករេយ្យ កល្យាណំ ឯឧយំ សម្បរាយិកំ
បុញ្ញានិ វរលោកស្មឹ បតិដ្ឋា ហោន្តិ ទាណិនំ ។

ហេតុនោះជនានុជនទាំងឡាយ ចូរខំខ្ជាប់ខ្ជួយកសាងសន្សំ
នូវបុណ្យកុសលកល្យាណកម្ម ទុកនៅប្រចាំក្នុងសន្តានចិត្ត ។
គ្រាន់ជាទីពាក់ព័ន្ធអាស្រ័យ ជាប់ជាបច្ច័យទៅលោកនាយពិត
ព្រោះបុណ្យជាទីពឹងនឹងជីវិត របស់ពួកសត្វកន្លងលោកខាងមុខ ។

អវិសានភាសិតនៃបុញ្ញាបរិគ្គ,

ភាក្យ ៨

ទាន សីល ភាវនាទាំង ៣ ប្រការ ឱតជាកុសលដែលគួរកសាង
ទុកជាកំណប់តបជាសំណាង ជាលំភូហនអាងប្រចាំជីវិត ។
មិនលោភមិនក្រោធមិនវង្វើងភ័ន្ត ជាឫសគល់បុណ្យគុណគាប់សក្តិសិទ្ធិ
លោភៈ ទោសៈ នឹងមោហៈចិត្ត ទាំង ៣ នេះពិតជាឫសនៃបាប ។

ភាក្យ ៧

បុណ្យនាំឲ្យឋានទៅស្ថានសួគ៌ បុណ្យគួរតែធ្វើកុំឈប់ខាន
បុណ្យចោរលួចប្លន់យកពុំបាន បុណ្យជាលំអាននៃអ្នកប្រាជ្ញ ។

ចូរបងាំឲ្យបានទៅអចួយ ចូរបគួរដៀសឲ្យគួរខ្ពើមខ្ជាប
ចូរបធាបច្ចាមិត្តកោងកាច ចូរបគាចជាផ្លូវមែនពាលខ្លៅ ។
បុណ្យនាំឲ្យបានក្សេមក្សាន្តសុខ ចូរបនាំឲ្យទុក្ខទោសមួមៅ
បុណ្យនាំត្រជាក់ត្រជុំខៅ ចូរបនាំឲ្យក្តៅក្តុកក្តួលក្តន់ ។
បុណ្យជាគុណគាប់គួរពេញអាន ចូរបទោសសាមានឲ្យគួរបង្អន់
បុណ្យតែងគាប់ចិត្តបណ្ឌិតជន ចូរបកម្ចគ្រែនពាលគាប់ចិត្ត ។
បុណ្យនាំឲ្យទេពមនុស្សស្រឡាញ់ ចូរបនាំគេខ្ពាញ់ស្អប់ខ្ពើមពិត
បុណ្យនាំឲ្យមានពលៈបុទ្ធិ ចូរបនាំឲ្យតតអានុភាព ។
បុណ្យនាំឲ្យថ្កើងរុងរឿងខ្ពស់ ចូរបនាំធ្លុបត្រែនថ្លស់ថោកទាប
បុណ្យ!បុណ្យ!ត្រូវធ្វើជាដរាប ចូរប!ចូរប!ត្រូវលះកុំខានអីយ!! ។

ចប់បុញ្ញកថាវិភាគ

ទានសីលវិភាគ

អត្ថេ ច បមាទាច ឯវំ ទានំ ន ទិយ្យតិ
បុញ្ញមាភក្ខ្ងមាឯន ទេយ្យំ ភោគតិ វិដានតា
ត្រៃវត្តតំណាញ់នឹងប្រហែសធ្វេស តាំងពីរយ៉ាងនេះឯងជាប្រធាន
ទើបនរជនមិនអាចឲ្យទាន អ្នកចង់ចានបុណ្យគួរឲ្យទានចុះ ។
អដ្ឋ ឋានំ វត្តុយានំ មាលាភដ្ឋំ វិលេបនំ
សេយ្យាវសថំ បទីបយ្យំ ទានវត្ថុ វរមេធសំ

ប៉ាយ ទឹក សំពត់ យានកម្រងផ្កា មាលាគន្ធារគ្រឿងលាបធ្វើន ។
ទីដេកទីជាក់គឺទឹកផ្ទៃធ្វើន ប្រទីបភ្លឺចែងចង្អៀងនានា ។
តាំង ១០ យ៉ាងនេះជាវត្ថុទាន អ្នកមានធនធានឧត្តមានសទ្ធា
ធំចង់ប៉ានសុខសាន្តសព្វវេលា អញ្ជើញម្ចាស់ប្រាថ្នាគប្បីមាន ។

អាយុធាយី ពលធាយី សុខំ វណ្ណំ ធនោធនេ
ធីយា យុ យសកា ភោគំ យត្ថ យត្ថ បបជ្ជតំ

នរជនអ្នកឲ្យអាយុ វណ្ណៈ លុខៈ ពលៈ តាំងនេះជាទាន
កើតទីណាៗរមែងតែងប៉ាន មានអាយុយឺនយូរវែងមានយស ។

អាកមកេថា វនកេថា យេ ជនា សេតុការកា
បវត្តារ ចុទធានញ្ច យេ ធនន្តិ ចុបស្សយំ
តេសំ ទីឃចរត្តេន សទ្ធាបុញ្ញំ បវឌ្ឍតំ
ឆម្មដ្ឋា សីលសម្បន្នា តេជនា សក្កតាមិនោ

ជនណាដាំសួនច្បារ , ច្បារដើមឈើ , ធ្វើស្ពាន , សាងភនពោងឲ្យទានទឹក
ជីកស្រះអណ្តូងសម្រាប់ធ្វើផឹក តាំងថ្លៃយប៉្រាកដល់ជនានា ។
ជនណាឲ្យទីសំណាក់អាស្រ័យ ដល់ជនដទៃដោយចិត្តសទ្ធា
បុណ្យតែងចំរើនកើតវឌ្ឍនា គ្រប់ទីទាំងដល់ជនទាំងនោះ ។
ជននោះឈ្មោះថាតាំងនៅក្នុងធម៌ ធំធំបរិបូណ៌ដោយសីលខ្ជាប់ខ្ជួន
រមែងនៅតាន់សួគ៌ាសោឡស ប្តូរថ្លៃដ៏ស្រួចស្រស់សុខសាន្តរីករាយ ។

អន្នទោ ពលទោហោតំ វត្ថទោ ហោតំ វណ្ណទោ
យានទោ សុខទោ ហោតំ ទីបទោ ហោតំ ចក្ខុទោ
យោច សព្ពទទោ ហោតំ យោ ធម្មាតំ ឧបស្សយំ
អមតទ្ទ ទោចសោហោតំ យោ ធម្មមនុសាសតំ ។

អ្នកឲ្យបាយឈ្មោះចាឲ្យកម្លាំង ឲ្យទានវត្ថុ[1] ឈ្មោះឲ្យពណ៌កាយ
ឲ្យយានឈ្មោះថាឲ្យសុខសប្បាយ ឲ្យប្រទីបមាយថាឲ្យចក្ខុ ។
អ្នកឲ្យទីជាក់សំណាក់អាស្រ័យ ឈ្មោះឲ្យបច្ច័យគ្រប់បែបប្រការ
នរណាបង្រៀនប្រដៅធម៌អាថ នរនោះឈ្មោះថាឲ្យព្រះនិព្វាន ។

យថា អាវិរហា ឫក បវរ្សវន្តំ សាគរំ
ឯវម្មេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ

ផ្សរទឹកតិចខ្ទេះស្លឹងបឹងបួរ តែងហូរទៅកាន់មហាសាគរ
ពោលគឺសមុទ្រឲ្យបរិបូណ៌ ពេញប្រៀបហៀរពោរនោះយ៉ាងណាមិញ?
ទានដែលបុគ្គលបានលះចែកចាយ ចំណាយកងលោកនេះតែងចំណេញ
បានផលដល់បេតៈជនពេញលេញ សេចក្តីនេះមិញក៏យ៉ាងនោះដែរ ។

សព្ពទានំ ធម្មទានំ ជិនាតិ
សព្ពរតឹ ធម្មរតិ ជិនាតិ

---

1 សំពត់ ។

សព្វេសំ ធម្មរសោ ជិនាតិ

តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ

ធម្មទានតែងឈ្នះទានទាំងអស់ ធម្មរសឈ្នះរសទាំងពួង

ធម្មប៉ិតឈ្នះប៉ិតសព្វ (๑) អស់តណ្ហាឈ្នះអស់សព្វទុក្ខ (๒)

សង្ខាហិ ធានំ ពហុនា បសត្ថំ

ឥតា ច ខោ ធម្មបទំវ សេយ្យោ

បុព្វេ ហិ បុព្វតរេ សន្តោ

ឥញ្ជនមេវដ្ឋកមុំ សមញ្ញា ។

ការពិដលឲ្យទាន៖ដោយសទ្ធាចិត្ត បណ្ឌិតសរសើរដោយច្រើនប្រការ

គ្រាន់តែសម្តែងបទធម៌ ๑ ណា ក៏ប្រសើរឲ្យាងទាន ។

សប្បុរសទាំងឡាយជាច្រើនពួក ដាន់មុនយូរយាកប៉ុន្មានក្បាញ្ញាណ

លោកបានដល់ខ្ទុំវាន្តព្រះនិព្វាន ព្រោះអាស្រ័យទានធម៌ ๑ បទនោះ ។

សីលវា ហិ ពហូ ភិក្ខវេ សញ្ញមេន ទមេន ច

ទុស្សីលោ បន អត្ថភិ ឆំ សតេ ចាបមាចារំ

អ្នកមានសីលសុទ្ធតែងមានមិត្តច្រើន ព្រោះតែចំរើនដោយគុណសំវរៈ

ឯអ្នកទុស្សីលប្រព្រឹត្តិអាក្រក់ រមែងប្រកបប្រាក់ខាតមិត្តពាំងឡាយ ។

អវណ្ណញ្ច អកិត្តិញ្ច ទុស្សីលោ លភតេ ឆរេ

๑ លេខក្តីត្រែកអះពាំងពួង ។ ๒. ទុក្ខពាំងអស់ ។

วณฺณี กิตฺติ ปสํสญฺจ สทา ลภติ สีลวา

នរជនឈ្មោះពាន់គ្នាទំនើលសោកា តែងបានទីខ្លួ, ស្អុយខូចក្លិនឈ្មោះ

ឯអ្នកមានសីលនាមល្បីពិភោះ តែងម្តើងយសសរសើរ សព្វកាល ។

สีลํ ภเกฺขยฺเยมชาวี ปตฺตมาโน ตโต สุเข

ปสํสา วิตฺถลาภญฺจ เปจฺจ สคฺเค ปโมทติ

អ្នកមានបញ្ញាតាលច្បាស់ខ្លាសុខ ៣ ជាតិមុខ តំ បសំសា,

ខ្ញុំលាត, លះលោកទៅកើតសួគ៌ា, ក៏គួរក្សាសមាធានសីល

ยาวชีวมฺปิ เจ ธีโร ขุสฺสีลปิ เอสมาหิโต

ฌานาทิ ปีติลาภี จ สีลวนฺตสฺส ฌายิโน

សេចក្តីរស់នៅតឹមតែមួយថ្ងៃ នៃអ្នកមានសីលនឹងឈានឧត្តម

ក៏ប្រសើរជាងរស់នៅរយឆ្នាំ នៃអ្នកសាំញ៉ាំគ្មានសីលចរិយា ។

อปฺปมตฺตสฺส ปญฺญาย ยถา ตคฺฆนฺติ ธีรา

ยถา สีลวโต ปญฺญา ปาตุ เธเวสุ ชายเร

ភ្លើងនៃខ្លឹមចន្ទ័ននឹងក្រស្នា ភ្លើងនេះធម្មតាមិនប្រមាណ

ចំណែកប៉ែកភ្លើងនៃអ្នកមាន សីលកល្យាណផងតាំងឡាយ ។

នោះទើបក្រអូបក្រអែបឈ្ងប់ ឈ្មួយធ្វាញខ្ពស់លបឮខ្លាយ

ទៅក្នុងទេពតា មនុស្សតាំងឡាយ សុះសាយកាយសព្វគ្រប់ទិសទី ។

สีลเตน สุคตึ ยนฺติ สีลเตน โภคสมฺปทา

សីលេន ឯកន្តិ យន្តិ តស្មា សីលំ វិសោធយ

គេទៅកាន់សុគតិភាន ដោយសីលកល្យាណពិតប្រាកដ

គេបានសម្បូណ៌ដោយសម្បត្តិ ក៏ដោយបន្ទាត់តីសីលា ។

គេទៅកាន់ឋានព្រះនិព្វាន ក៏ដោយសារយានសីលសិក្ខា ។

ហេតុនេះអ្នកចូរខំរក្សាហ៍ ជម្រះសីលាឲ្យផូរផង់ ។

បរិយោសាន

"ធម្ម-ណា គឺ" ទីបណ្ឌិតចិត្តដ្រៃឆ្លាស ប្រាន់រចនារៀបរៀបរៀងរឿងគាសិត

ទុកជំណាងដំណើរសាសនាពិត គ្រាន់ជាកិត្យប្រតិត្តិប្រាណឲ្យបានការ។

សូមសត្វសត្វកង់សង្សារសុខសប្បាយ សុខាំងកាយសប្បាយ

ចិត្តសមប្រាថ្នា !

សូមប្រទីបទូបអាស៊ីរុង៍រឿងឆ្ងា ! សូមសាសនាព្រះគោតមវែងស្ទឹ !

ការសំដែងនិទ្ទេស មុនីសុគាសិត ដោយសង្ខិត្តគ្រាសង្កេបបែបយ៉ាងខ្លីឈប់

ប៉ុណ្ណេះស្មេរប៉ុណ្ណឹងអស់សេចក្តី ចប់រាប់នៃឥទ្ធាជាតិ !!! ។

សញ្ញាប័ត្រលេខ ៣០២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គិន-ឡាំ នាមនាយា ព្រហ្មជោត កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រស្តាំខេវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣០៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុំម-សម នាមនាយាមង្គលសិរី កើតឆ្នាំវក អាយុ ២៩ វស្សា ៧ ជាគ្រូសូត្រឆ្វេង ខេវត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣០៤ ចុះថ្ងៃចន្ទ ៩ កេច ខែកត្តិកឆ្នាំដូត សំរឹទ្ធិស័ក តាំងលោកគ្រូ សោម-កែវ នាមនាយាសុវណ្ណកេសរ កើតឆ្នាំ អាយុ ២៩ ជាគ្រូសូត្រឆ្វេង វត្តគោគដុំ ឃុំគោគដុំ ស្រុកបាកយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣១០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កុក-ម៉ុង នាមនាយា ធម្មកេសរ អាយុ ៣០ ជាគ្រូសូត្រស្តាំ ខេវត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣១១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ភឿក-កែម នាមនាយា សុវណ្ណជោត កើតឆ្នាំកុរ អាយុ ២៦ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្តច្រលង ឃុំច្រលង ស្រុកបាកយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣១២ ចុះគាល់ថ្ងៃទី...ដែល តាំងលោកគ្រូ ពត-ប៊ុក នាមធាយា ចន្ទប្បញ្ញោ កើតឆ្នាំមមែ អាយុ ៤២ វស្សា ២១ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣១៣ ចុះគាល់ថ្ងៃទី...ដែល តាំងលោកគ្រូ កែ-ជា នាមធាយា ផោតប្បញ្ញោ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៦ ជាគ្រូសូត្រស្តាំ វត្តជម្ពុសត្តាភម ឃុំអណ្តូងពោធិ៍ ស្រុកចំការយណ៍ ខេត្តកំពង់ធំ។

សញ្ញាប័ត្រលេខ ៣១៤ ចុះគាល់ថ្ងៃទី...ដែល តាំងលោកគ្រូ គន-ជិម នាមធាយា មុនីសុវណ្ណកេសរ កើតឆ្នាំមមែ អាយុ ៤២ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តក្រពាំ ឃុំក្រពាំ ស្រុកចំការយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣១៥ ចុះគាល់ថ្ងៃទី...ដែល តាំងលោកគ្រូ មៀ-ភ័ត នាមធាយា ធម្មត្ថេរ កើតឆ្នាំ ១៨២០ អាយុ ៤៨ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តគុត ឃុំស្រែឡៅ ស្រុកចំការយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣១៦ ចុះគាល់ថ្ងៃទី...ដែល តាំងលោកគ្រូ អៀង-យ៉ី នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំឆ្លូត អាយុ ២៥ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្តពណ្ណាភម ឃុំចេង-ដើង ស្រុកចំការយណ៍ ខេត្តកំពង់ធំ។

សញ្ញាប័ត្រលេខ ៣១៧ ចុះគាល់ថ្ងៃទី...ដែល តាំងលោកគ្រូ ភ្នំ-វង នាមធាយា ព្រហ្មផោត អាយុ ៤១ វស្សា ២០ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣១៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ញឹក-តាំង នាមនាយា មង្គលត្ថេរ កើតឆ្នាំ ១៨០៣ អាយុ ៤៩ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្តស្វាយក្ងែង ឃុំស្វាយក្ងែង ស្រុកបាភាយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣១៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ូ-លី នាមនាយា ចន្ទសរ កើតឆ្នាំ ១៨៧៨ អាយុ ៣០ វស្សា ៨ ជាចៅអធិការ វត្តស្វាយខ្ពស់ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣២០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-ឯក នាមនាយា ធម្មសិរីត្ថេរ អាយុ ៣០ វស្សា ៥ ជាគ្រូសូត្រធ្ងន់ វត្តសរសើរ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣២១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អៀង-ហ៊ី នាមនាយា ធម្មប្បញ្ញោ អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣២២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-ប៊ុម នាមនាយា ជោតត្ថេរ អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្តល្វា ឃុំច្រនៀង ស្រុកបាភាយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣២៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ មាយ-អ៊ុត នាមនាយា ចន្ទវង្ស អាយុ ៣៣ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តថ្លា ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣២៤ ចុះគ្រាលថ្ងៃទី ដែល តាំងលោកគ្រូ ឆួក - គង់ នាមឆាយា ឥន្ទជោត អាយុ ២៣ វស្សា ២ ជាគ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តដែល ។

សញ្ញាប័ត្រលេខ ៣២៥ ចុះគ្រាលថ្ងៃទី ដែល តាំងលោកគ្រូ មាស - ម៉ាត់ ធម្មសិរី អាយុ ២៥ វស្សា ៦ ជាចៅអធិការ វត្តត្រែង ឃុំ ឈូកឡាប់ - ស្រុក - ខេត្តដែល ។

សញ្ញាប័ត្រលេខ ៣២៦ ចុះគ្រាលថ្ងៃទី ដែល តាំងលោកគ្រូ ម៉ា - កឹម នាមឆាយា ឯកវិនយៈ អាយុ ៣២ វស្សា . . . ជាគ្រូសូត្រស្តាំ វត្តជ្រោសាខ ឃុំ - ស្រុក - ខេត្តដែល ។

សញ្ញាប័ត្រលេខ ៣២៧ ចុះគ្រាលថ្ងៃទី ដែល តាំងលោកគ្រូ គង់ - វង្ស នាមឆាយា គោណ្ឌញ្ញៈត្ថេរ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេង នៅវត្ត ឃុំ - ស្រុក - ខេត្តដែល ។

សញ្ញាប័ត្រលេខ ៣២៨ ចុះគ្រាលថ្ងៃទី ដែល តាំងលោកគ្រូ ខៀង - ពត នាមឆាយា សុវណ្ណបញ្ញោ អាយុ ៣៩ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ជ្រុំ ឃុំ ស្រុក - ខេត្តដែល ។

សញ្ញាប័ត្រលេខ ៣២៩ ចុះគ្រាលថ្ងៃទី ដែល តាំងលោកគ្រូ ជាម - សុម នាមឆាយា ធម្មត្ថេរ កើតឆ្នាំម្សាញ់ អាយុ ២៧ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តស្រែបន្ទាយ ឃុំច្រខៀង ស្រុក - ខេត្តដែល ។

សញ្ញាប័ត្រលេខ ៣៣០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហួត-ស៊ីម នាមនាយា សុវណ្ណត្ថេរ អាយុ ៤៥ វស្សា ១៧ ជាចៅអធិការ វត្តស្រែបន្ទាយ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៣១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅម-ថោង នាមនាយា ធម្មប្បញ្ញោ អាយុ ៧១ វស្សា ១២ ជាចៅអធិការ វត្តស្រីង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៣២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ីង-សេក នាមនាយា ធម្មប្បញ្ញោ អាយុ ៣៩ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ ឃុំគ្រៀល ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៣៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-គំ នាមនាយា ឥន្ទុត្ថេរ អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៣៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាវ-ម៉ន នាមនាយា ធម្មត្ថេរ អាយុ ៣៦ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តចតុលោក ឃុំចាពយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៣៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សំ-រី នាមនាយា មុនីបញ្ញោ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៣៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
តែវ-ហ៊ុន នាមឆាយា ព្រហ្មប្បញ្ញាថេរ អាយុ ៣៩ វស្សា ១៦ ជាគ្រូ
សូត្រស្តាំ វត្តចាយណ៍ ឃុំចាយណ៍ ស្រុកចាយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៣៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ស៊ុយ-យ៉ិម នាមឆាយា សុវណ្ណកេសរ អាយុ ៣៩ វស្សា ១៨ ជាគ្រូ
សូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៣៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
តែវ-ឈិន នាមឆាយា ចន្ទោ អាយុ ៣៣ វស្សា ១០ ជាចៅអធិការ
វត្តក្តីតាចិន ឃុំគៀម ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៣៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
វស់-ប៊ែន នាមឆាយា ព្រហ្មសត្ថា អាយុ ៤៣ វស្សា ៩ ជាគ្រូសូត្រ
ស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៤០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ខន់-តឹក នាមឆាយា ខន្តិសេរ អាយុ ៦៨ វស្សា ៣៣ ជាចៅអធិការ
វត្តកក់ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៤១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ប៉ុល-យន់ នាមឆាយា យន្តប្បញ្ញោ អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រស្តាំ
វត្តជា ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៤២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គួយ - ទិម នាមធាយា សុវណ្ណត្នេរ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រស្តាំ ខេត្តវត្តចុងដូង ឃុំចុងដូង ស្រុកបាកយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៤៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខោង - យ៉ែង នាមធាយា ធម្មលិទ្ធិត អាយុ ២៥ វស្សា ៤ ជាគ្រូសូត្រ ឆ្វេង ខេត្តវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៤៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន - មាស នាមធាយា ធម្មសត្ថា អាយុ ៣៣ វស្សា ១៣ ជាគ្រូសូត្រ ស្តាំ វត្តពពេច ឃុំចុងដូង ស្រុកបាកយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៤៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃួន - តឹក នាមធាយា តន្ទសី អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តឧត្តមស្ថិត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៤៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហែម - ញឹក នាមធាយា តន្ទប្បញ្ញា អាយុ ៣៧ វស្សា ១៧ ជាគ្រូ សូត្រឆ្វេង វត្តតាំងគោក ឃុំសូយោង ស្រុកបាកយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៤៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម - យុន នាមធាយា តន្ទត្នេរ អាយុ ៣៩ វស្សា ១៨ ជាគ្រូសូត្រ ស្តាំ ខេត្តវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាបំត្រលេខ ៣៤៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក-មុត នាមនាយា សុវណ្ណប្បញ្ញោ អាយុ ៦០ វស្សា ៩ ជាចៅអធិការ វត្តបឹងខ្ទុយ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាបំត្រលេខ ៣៤៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-ម៉ុម នាមនាយា ធម្មត្ថេរ អាយុ ៣២ វស្សា ៨ ជាចៅអធិការ វត្តព្រះសំបូណ៌ ឃុំពង្រ ស្រុកឃ្លាំងយណ៌ ខេត្តកំពង់ធំ ។

សញ្ញាបំត្រលេខ ៣៥០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-ជុម នាមនាយា សុវណ្ណកេសរ អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រ ឆ្វេង វត្តព្រះស្រែង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាបំត្រលេខ ៣៥១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-យ៉ែម នាមនាយា គន្ធត្ថេរ អាយុ ៦៩ វស្សា ១៤ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាបំត្រលេខ ៣៥២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហម-គួន នាមនាយា ជន្ធកេសរ អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រ ស្តាំ វត្តគុកនគរ ឃុំពង្រ ស្រុកឃ្លាំងយណ៌ ខេត្តកំពង់ធំ ។

សញ្ញាបំត្រលេខ ៣៥៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-ហ៊ុន នាមនាយា សុវណ្ណត្ថេរ អាយុ ៣៤ វស្សា ៩ ជាគ្រូសូត្រ ឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៥៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឆាយ-ប៊ុន នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំវក អាយុ ៦៥ វស្សា ៤៣ ជាចៅអធិការ វត្តថ្មគ្រែ ឃុំសំបុក ស្រុកគ្រចេះ ខេត្តគ្រចេះ ។

សញ្ញាប័ត្រលេខ ៣៥៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខូច-ស៊ុម នាមឆាយា ចន្ទឆោត កើតឆ្នាំវក អាយុ ២៨ វស្សា ៦ ជាចៅអធិការ វត្តពោធិ៍វល្លី ឃុំបុសលាខ ស្រុកគ្រចេះ ខេត្តគ្រចេះ ។

សញ្ញាប័ត្រលេខ ៣៥៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៀប-ណែម នាមឆាយា សិរីសុវណ្ណ អាយុ ៥៤ វស្សា ៣៣ ជាគ្រូសូត្រស្តាំ វត្តស្វាយរែក ឃុំលាង ស្រុកកំពង់ត្រាញ ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៣៥៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថ្ងាង-អឹម នាមឆាយា តន្ទសុវណ្ណ កើតឆ្នាំមមែ អាយុ ៤២ វស្សា ២១ ជាគ្រូសូត្រឆ្វេង វត្តស្វាយរែក ឃុំលាង ស្រុកកំពង់ត្រាញ ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៣៥៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចឹក-ប៉ក់ នាមឆាយា ធម្មប្បញ្ញោ អាយុ ៣០ វស្សា ២៧ ជាចៅអធិការ វត្តតាំងក្រសៅ ឃុំតាំងក្រសៅ ស្រុកសន្ទុក-ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៥៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចេង-ហម នាមឆាយា ធម្មសិរីយសត្ថេរ អាយុ ៣១ វស្សា ១១ ជាចៅអធិការ វត្តកំពង់ឈើទាល ឃុំតាំងក្រសៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៦០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉ែម-ង៉ាន ឈ្មោះធាយ៉ា សុវណ្ណត្នេរ អាយុ ៣៤ វស្សា ១៣ ជាចៅអធិការ វត្តគោកប្រក់ ឃុំតាំងក្រសៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៣៦១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-យ៉ែម នាមធាយ៉ា ចន្ទូកេសរ អាយុ ២៧ វស្សា ៦ ជាចៅអធិការ វត្តឆ្នាវ ឃុំឆ្នាវ ស្រុកវាំងល ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៣៦២ ចុះថ្ងៃ ១៥ កើតខែអស្សុជឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ពេជ-លី នាមធាយ៉ា . . . . . កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៣ ជាចៅអធិការ វត្តគោរកែវមណីខ្ពស់ ឃុំខ្នារ ស្រុកឫស្សីកោង ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៣៦៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈឹម ឆឹន នាមធាយ៉ា តុទ្ធប្បញ្ញោ កើតឆ្នាំមមែ អាយុ ៣២ វស្សា ១១ ជាគ្រូសូត្រឆ្វេង វត្តតាមិញ ឃុំស្មោង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៦៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-អ៊ុន នាមធាយ៉ា បញ្ញាធម្ម កើតឆ្នាំរោង អាយុ ៣៣ វស្សា ១៣ ជាគ្រូសូត្រស្តាំ នៅវត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៦៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ

ឌី - ជា នាមនាយា ធម្មវត្តិត កើតឆ្នាំកុរ អាយុ ៥០ វស្សា ៨ ជាគ្រូសូត្រ
ស្តាំ វត្តកោះបុប្ផារាម ឃុំមហាខ្ញង ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៣៦៦ ចុះគោលបរិច្ឆេទដដែល តាំងលោកគ្រូ
យិន ជិញ នាមនាយា ធម្មជោត កើតឆ្នាំវក អាយុ ២៩ វស្សា ៨
ជាគ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៦៧ ចុះគោលបរិច្ឆេទដដែល តាំងលោកគ្រូ
សុខ - តន្ធូ នាមនាយា តន្ធូត្ថេរ កើតឆ្នាំកេង អាយុ ៤៥ វស្សា ២២
ជាគ្រូសូត្រឆ្វេង វត្តដំរិល ឃុំដំរិល ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៣៦៨ ចុះគោលបរិច្ឆេទដដែល តាំងលោកគ្រូ
អ៊ុង - សេង នាមនាយា សុវណ្ណកេសរ កើតឆ្នាំច្រូ អាយុ ៤៨ វស្សា ២៣
ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៦៩ ចុះគោលបរិច្ឆេទដដែល តាំងលោកគ្រូ
អ៊ី - ឡេ នាមនាយា តន្ធូត្ថេរ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣២ ជា
ចៅអធិការ វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៧០ ចុះគោលបរិច្ឆេទដដែល តាំងលោកគ្រូ
ឡុង - ឌុយ នាមនាយា មហន្តសីស កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១២
ជាគ្រូសូត្រឆ្វេង វត្តវិហារទន្ទឹម ឃុំតូច្រឹងឃ្មុំ ស្រុកតូច្រឹងឃ្មុំ ខេត្តកំពង់ចាម។

សញ្ញាប័ត្រលេខ ៣៧១ ចុះគោលបរិច្ឆេទដដែល តាំងលោកគ្រូ

មួង - វុំញ នាមនាយ រដ្ឋបញ្ញោ កើតឆ្នាំខាល អាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រស្តាំ នៅវត្ត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៧២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ - ខួត នាមនាយ បញ្ញាថេរកេសរ កើតឆ្នាំជូត អាយុ វស្សា ៦១ ជាគ្រូសូត្រស្តាំ វត្តចាកយណ៍ព្រៃដី ឃុំចាកយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៣៧៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម - ក្រង់ នាមនាយ វិនយធម្មត្ថេរ កើតឆ្នាំខាល អាយុ ៥៨ វស្សា ៣៨ ជាគ្រូសូត្រធ្វើង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៧៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ិន - សយ នាមនាយ សុធម្មត្ថេរ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៣ ជាចៅអធិការ វត្តព្រៃរាជវរវិកស្ថាន ឃុំស្រីសន្ធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៣៧៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ វង - អ៊ូត នាមនាយ ឥន្ទបញ្ញោ កើតឆ្នាំវក អាយុ ២៩ វស្សា ៥ ជាចៅអធិការ វត្តវៃព្រៃចាស់, ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

កម្ពុជសុរិយា

ROYAUME DU CAMBODGE
RÉGIE
DU
TIMBRE

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុទ្ធសករាជ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ឹក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ស្សរ-ហាយ
ព្រះធម្មដំពុំព្រះវិន័យចំដាក់ នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
លោក ឈឿង-កុល	រឿងអតីតវរិណ៌យក្ខិនី	៦៤១
មហា ទេព-ណាត្រី	និទានសុភាសិត	៦៤៦
លោក អ៊ូ-ឆ្ង	រឯរកសុំយកយ៉ុំ ក្នុងរសេៀកភ្នំ ឬរូងគ្រោះភ្នំ	៦៦៤
លោក ភ័យ-ប៊ុក ក្រមការ	សុភាសិតខ្មែរភាគទី ២ (តទក)	៦៧២
ហ្លួងនិពន្ធមន្ត្រី ញ៉ឹក-ថែម	ស័ព្ទបារាំងប្រែជាខ្មែរ (តទក)	៦៧៥
	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តទក) ..	៦៨២
អ្នកឧកញ៉ា ង្ហ-ពន	រឿងសាមកុក (តទក)	៦៨៩
ផ្នែកសាសនា		
ព្រះទេពមុនី ឃ្ស-ប៊ុណ្ណា	បឋានកថា	៦៩៦
កំណត់ទីនប្រវត្តិការណ៍		
លោកឧកញ៉ា ឈិន	ពិធីបុណ្យសម្ពោធ្យសាលាធម្មវិន័យ	៧០១
ក្រសួងធម្មការ	បញ្ជីរាយនាមហៅអធិការដែលតាំងថ្មី (តទក) ...	៧០៧

ចំ.ទី ៦១ – លេ ៨ ខែ កញ្ញា ឆ្នាំ ១៩៦៨ – តំលៃដារ ១ ចាំ ៩៦ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
M. Chhœung Kul	Aticârini yakkhini	641
Mahâ Om-Nagry	Nidânasubhasit	656
M. Oû Koû	Cueillette des ruches situées dans des grottes et vallées	664
M. Ray-Buc kramokar (I.B.)	Proverbes et maximes Tome II (suite)	672
Luong Nibandhamantrî Nhok-Thêm	Traduction du français en Cambodgien par la Commission culturelle (suite) .	675
—id—	Histoire sommaire de l'Inde (suite) ..	682
Néak Okuha Nou-Kân	Histoire de «Sam-Kok» (suite)	689

Partie religieuse :

Brah Tep-Moni You-Ponn	Patheanakatha	696

Notes et chroniques

Vén. Mahâ Chhin	Inauguration de l'école Dhammavinaya	711
Ministère des cultes	Nomination des nouveaux chau Adhikar (suite)	717

21e Année: N° 9 Septembre 1949 — Prix d'abonnement: 96$00 par an.

រឿងអតីតាវ៉ៃយក្ខិនី

លោក ឈឿន កុល

ត្រូវបង្រៀនសាលាបឋមសិក្សាថាកាំង ខ្សែ ស្រុកពោធិ៍សុទិន ក៏ពង់ជាខេត្តបែរៀបរៀង

និទានអំពីស្ត្រីប្រព្រឹត្តអនាចារធ្ងន់ធ្ងរ។ មានសុភនិដ្ឋគតិចិត្តផិតប្តី ពោលមុសាវាទជាដើម;

សេចក្តីថា - កន្លងអតីតកាលកន្លងយូរយារមកហើយ មានអគ្គមហេសីនៃព្រះរាជា ១ ព្រះអង្គទ្រង់សោយរាជ្យក្នុងនគរពារាណសី[1] ឈ្មោះអតីតាវ៉ៃយក្ខិនី អ្នកលេងសុភ, ប្រព្រឹត្តផិតប្តីនឹងមានប្រតិតពោលមុសាវាទជាដើម។ លុះឆ្លើដ៏ពាជន្មមរណៈទៅ ក៏កើតជាយក្សមានអត្តភាពប្លែកអំពីត្រកូលយក្ស ទាំងឆ្លងដោយការណ៍ចាញ់សម្បថ នឹងពោលមុសាវាទជាដើម បណ្តាលឲ្យកើតជាយក្ស មានមុខជាសេះខ្លួនជាយក្ស ហៅថា "អស្សមុខិ-យក្ខិនី"។

ស្តេចនៅក្នុងលេណគុហានាឋាតក្នុងមួយ ដោយចូលទៅធ្វើឧបដ្ឋានការនៃស្តេចវេស្សវ័ណ អស់កាល ៣ ឆ្នាំទើបស្តេចទ្រង់ប្រទានគោចរកក្ស ឲ្យបណ្តាយ ៣០ យោជន៍ ទទឹង ៩ យោជន៍ ដើម្បីនឹងចាប់សត្វនឹងមនុស្សទាំងឡាយបរិភោគ។

១— ពារាណសីនេះជាឈ្មោះក្រុងមួយក្នុងដែនកាសី (ប្រទេសឥណ្ឌា) ពាំងនៅខាងត្បែយខាងទ្វេង (ខាងកើតនៃទន្លេគង្គាជាយូរអង្វែងណាស់មកហើយមិនដែលរុះរើទៅណាឡើយ ជាក្រុងមានឈ្មោះប្រាកដក្នុងគម្ពីរខាងព្រះពុទ្ធសាសនា តែក្នុងសម័យសព្វថ្ងៃនេះភ្លាយឈ្មោះជា បេណារេស ឬ បេណារែស (ហៅតាមឈ្មោះក្នុងដែនទីលោក)។

ក្នុងថ្ងៃមួយ មេយក្ខិនីនោះចាប់ឃាត់ព្រាហ្មណ៍ម្នាក់មានរូបឆោមសម
រម្យល្អយ៉ាងចំណាប់ ឲ្យដេកលើខ្នងខ្នែនាំទៅដុតក្នុងគុហា ក៏មានសេចក្តី
ប្រតិព័ទ្ធចំពោះសម្ផស្សនៃបុរស ញាំងសេចក្តីស្នេហាឲ្យកើតមានដល់
ព្រាហ្មណ៍នោះ ដោយអំណាចនៃកិលេស ។ ក៏ជំគល់ព្រាហ្មណ៍នោះ
ដុតឆ្អើស្វាមី ចាប់ដើមតាំងពីថ្ងៃនោះមកមេយក្ខិនីតែងសូវស្វែងរកចាប់
មនុស្សទាំងឡាយ ដើម្បីនឹងយកវត្ថុទាំងឡាយមានសំបត់អាវសាវស្បែ
នឹងអង្ករ ស្លឹកឈើ ម្ហូបចំណីមានរសឆ្ងាញ់យ៉ាងវិសេសជាដើម មកឲ្យដល់
ព្រាហ្មណ៍ជាស្វាមីនោះសព្វគ្រប់ពេញ; ហើយទ្រនងធ្វើពាក្យសុំសាច់ស្រស់
នៃមនុស្សនឹងសត្វជាដើម; ក្នុងពេលត្រាច់គោចរទៅដល់ណា ក៏យក
ដុំសិលាមួយដ៏ធំមកខ្ទប់ទ្វារ ព្រោះខ្លាចព្រាហ្មណ៍នោះរត់ ។

ក្នុងគ្រានោះ ព្រះពោធិសត្វ (ជាម្ចាស់នៃយើង) ក៏ទ្រង់ចុះមក
ចាប់បដិសន្ធិក្នុងគភ៌នៃនាងអស្សម្ទិយក្ខិនីនោះ លុះគ្រប់វស្សាសក៏ប្រ-
សូតចេញចាកគភ៌មក; នាងនោះក៏មានសេចក្តីស្នេហាចំពោះកូននឹងបិតា
យ៉ាងក្រៃលែង: ទើបទុកបុរុងដោយនានគ្គរសគោជនៈឆ្ងាញ់ៗ ហើយ
ឲ្យស្វាមីនឹងកូនទៅគុហានោះ រួចបិទទ្វារដុត ឃាត់ចេញដើរទៅតាន់
គោចរតក្សាតាមធម្មតា ។

លុះដល់ពោធិសត្វ មានវ័យវឌ្ឍចំរើនឡើងគាំងដាំងមក ក៏ប្រ-
មៀលដុំថ្ម ដែលមាតាបិទទ្វារគុហានោះចេញ ហើយនាំបិតាមកអង្គុយ

កំសាន្តលេងឮដំខាងក្រៅ ដល់យក្សជាមាតាត្រឡប់មកវិញ នោងិសត្វ
ក៏ប្រាប់ភ្លាមថា ខ្ញុំបានប្រមៀលដុំច្នេះចេញហើយឯងឆីតអន្ធការណាស់
ទៅមិនបានទេ; ខ្ញុំអង្គុតណាស់; នាងនោះហេតុតែស្រឡាញ់ពេញ
ចិត្តនឹងកូនក៏ទៅស្ទើមគ្នានថាអ៊ីខ្ចើយ; ដល់ថ្ងៃក្រោយមក កុមារមាន
សេចក្តីឆ្ងល់នឹងមាតារបស់ខ្លួនថា ពីព្រោះហេតុអ្វីបានជាគាត់មានមុខដូច
សេះដូច្នេះ ទើបសួរទៅបិតា ។ ក៏ប្រាប់ហេតុនោះដល់កូនថាម្តាយឯងឆ
ជាយក្សទេ យើងគាំងព័នោក់ជាមនុស្សជាតិ ។

នោងិសត្វបានដឹងហេតុដែលបិតាប្រាប់សព្វគ្រប់ហើយ ក៏នាំបិតា
រត់ចេញពីទីនោះទៅ; លុះមាតាត្រឡប់មកវិញមិនឃើញកូននឹងស្វាមី
ក៏ហោះទៅតាម ដោយសន្ធុះលឿនដូចខ្យល់ទៅទាន់នាំយកមកវិញ;
លុះកន្ទុងទៅបានពីរបីថ្ងៃក៏នាំបិតារត់ទៅទៀត យក្សតាមទាន់ទៀត ។

មានថ្ងៃមួយ នោងិសត្វនឹកពិការល់កន្ទុងចិត្តថា មាតារបស់អញមាន
ឫទ្ធិអាចបរិច្ចេទ កំណត់ពីត្រឹមណាដល់ត្រឹមណាអេះ? បើដូច្នោះ
ចាំអញល្បងសួរមាតា អំពីសីមានឹងអំណាចដែនខ័ណ្ឌឲ្យដឹងសិន; លុះ
គិតហើយក៏សួរទៅមាតាៗក៏ប្រាប់ទីស្នាន សព្វភពផ្ទែងដល់កូន, លុះកន្ទុង
ពីនោះមកនោងិសត្វបានឫទ្ធិស្ទាត់ ក៏បញ្ជិះកបិតានាំរត់ទៅដោយសន្ធុះ
ដ៏លឿនដូចខ្យល់ បានទៅដល់ផ្នែរស្ទឹងជាទីបំផុតនៃខ័ណ្ឌសីមារបស់យក្ស
ជាមាតានោះ ។ លុះចុះទៅដល់ពាក់កណ្តាលស្ទឹង មាតាទៅតាម
ទាន់តែពុំអាចនឹងហាន១ចាប់យកមកវិញ ព្រោះហ្វូសព្វិចរលំដែនរបស់

ខ្លួន កំនិយាយអង្វរការជនពាំងពីរនាក់នោះ ឲ្យត្រឡប់មកវិញដោយ អាការផ្សេងៗ; ដំណឹងថាមុខជាកូននឹងស្វាមីមិនត្រឡប់មកវិញទេ ក៏មាន សេចក្តីទុក្ខខ្លឹកខ្លួលយំសោកជាគំរោភាព ព្រោះស្រឡាញ់កូនយ៉ាងក្រៃលែង; ទើបស្រែកហៅកូនថា: នែកូនសម្ងាញ់មាសម្តាយ បើអ្នកមិនត្រឡប់មកវិញទេ ចូរកូនរៀនយកមន្តវិជ្ជាមួយពីម្តាយទៅចុះ ព្រោះថាអាជីពរបស់មនុស្សលោកតែរៀវលែងនូវសិប្បៈ ហើយរស់នៅបានដោយក្រៃក្រែណាស់ ។ ឯវិជ្ជានោះឈ្មោះចិន្តាមណី មានអានុភាពយ៉ាងវិសេស ខុកជាចោរនាំយកទូរកណ្តាលៅលាក់ទុកអស់ ១២ ឆ្នាំក៏អាចតាមជានដើងចាប់ចោរនោះបានភ្លាម ។

ម្យ៉ាងទៀត នែកូន ឯមន្តវិជ្ជានេះមានដំឡៃណាត់មិនបាន ចូរកូនយកទៅរក្សាទុកចុះ នឹងបានចិញ្ចឹមជីវិតសុខស្រួលជាយ នឹងតែខ្លួនឲ្យមានដំឡៃយ៉ាងខ្ពស់ក្រៃដ្ឋ ។

តោដិសត្វឈរទៅពាក់កណ្តាលស្តាប់ស្តាយថ្វែងគុណនៃចិន្តាមណីវិជ្ជានោះរួចហើយ ក៏ថ្វាយបង្គំព្រះមាតារៀនយកទូរមន្តវិជ្ជាសព្វគ្រប់ភ្លាម; ហើយពោលថា សូមលោកម្តាយអញ្ជើញត្រឡប់ទៅវិញចុះ (ខ្ញុំសូមថ្វាយបង្គំលាហើយ) ។ ចំណែកខាងនាងអស្សម្ខិយកូនី កំនិយាយប្រាប់កូនថា នែកូន ជីវិតរបស់ម្តាយមិនបានរស់នៅទេ ថាដូច្នោះហើយក៏ប្រហារដើមទ្រូង បែកប្លាំងយ៉ក្សយ៉ប្រល័យប្រាណកូនទីនោះទៅ ។

ចប់រឿងយក្ខិនី ជាស្ត្រីប្រព្រឹត្តអនាចារ ដល់អនាថាមរណៈតែបុណ្ណោះឯង ។

និទានពីពោធិសត្វលុះឃើញមាតាស្លាប់ដូច្នោះហើយ ក៏ធ្វើដើងក្តារ រួចលើកយកសពមាតា ដំកល់លើដើងក្តារ បូជាភ្លើងរួចហើយ ក៏ចូលជាបុដ្ឋជាតិផ្សេង។ មានឆ្កែបន្ទូលជាដើមហើយក៏ថ្វាយបង្គំលាជាតុព្រះមាតា, ឪពុកតាទៅកាន់ត្រកូងតាពណាសីទៅ, លុះដល់ហើយក៏ស្ថិតនៅក្បែរត្រង់នោះ ហើយសំដែងមន្តិដ្ឋានដល់ព្រះរាជា ថាមាណពអ្នកធ្វាស់ក្នុងតិរិយាចាប់ចោរដោយឆ្មោងជាមនុស្សដ៏ចោរមកដល់ហើយ: ព្រះរាជាក៏ឲ្យហៅចូលមកថ្វាយបង្គំហើយទ្រង់សួរ; មាណពនោះក៏ចាន់ថ្លែងតិសិប្បៈវិជ្ជាដែលខ្លួនចេះនោះគ្រប់ជួលដល់ទ្រង់។ ក៏មានព្រះរាជឱង្ការថាយើងដូច្នោះចូរឲ្យធ្វើការយើងចុះ យើងនឹងឲ្យរង្វាន់ ១ ពាន់កហាបណៈរាល់ថ្ងៃ ។

លុះដល់ថ្ងៃខាងក្រោយមក មានបុរោហិតម្នាក់ចូលទៅដល់ស្តេច ហើយដំណាលពីមាណពនោះថា: បពិត្រមហារាជដ៏ព្រះអង្គមិនទាន់ដឹងជាមាណពនោះមានសិល្បសាស្ត្រពិតមែនឬមិនពិត, គួរតែយើងខ្ញុំឯងឡាយល្បងមើលសិល្បសិនទើបគួរ ។ ព្រះរាជាក៏ទទួលពាក្យបុរោហិតនោះ ហើយព្រមព្រៀងគ្នាធ្វើចោរកម្មចាំងពីរបួប រួចចំណាយនូវចន្ទោះព្រះរាជ-និវេសន៍ ៣ កន្លែងហើយនាំយកវត្ថុនោះ ចេញអំពីច្រាសាទដោយពាក់បង្អោងខ្សែង រួចចេញទៅខាងក្រៅកំផែង ហើយចូលទៅសាលាវិនិច្ឆ័យ រួចតាំងលើកបង្អោងពាក់ខ្សែងទៅម្ខាងទៀត ហើយយាងចុះតាមខាងចុងបំផុតនៃកំផែង យាងទៅកាន់ផ្ទះស្រះបោក្ខរណី ធ្វើប្រទក្សិណ ៣ ជុំរួចហើយនាំយកកណ្ឌៈទៅលាក់ខាងក្នុងស្រះបោក្ខរណីនោះទៅ) ដែលទ្រង់

យ៉ាងធ្វើបែបនេះបំណងកុំឲ្យមាណពនោះរកឃើញ ។ កំយ៉ាងទៅគាន់ប្រាសាទលំនៅព្រះអង្គវិញហោង ។

លុះដល់ព្រឹកព្រាងភ្លឺស្វាងអរុណាហើយ គោលាហលក៏តើតឡើងថា ចោរលួចយកវត្ថុសារ ពីព្រះរាជនិវេសន៍អស់ទៅហើយ ។

ព្រះរាជាធ្វើហាក់ដូចជាមិនឲ្យដឹងដាប់ ទើបឲ្យគ្រាស់ឲ្យហៅពោធិសត្វមកហើយមានព្រះបន្ទូលថា អ្នកចូរពិចារណារកចោរនោះទៅមើល ; ព្រះពោធិសត្វក៏ទទួលព្រះរាជឫទ្ធារថា បពិត្រព្រះសម្មតិទេព្រះបរមៃហើយ ។ ក៏ថ្វាយបង្គំនឹកដល់មាតា រួចតាំងស្មាធ្យាយនូវចិត្តាមណ៌ិមន្ត, ទើបគ្រាបទូលថា បពិត្រមហារាជ ដានដើងចោរតាំងឡាយពីរនាក់ប្រាកដ. ហើយក៏ដើរតាមដានចោរតាំងនោះសព្វគ្រប់ខ្នែង រួចយកបង្វិចខ្សែវដែលចោរលាក់ខុតមកបង្ហាញព្រះរាជា (ហាក់ដូចជាលាក់ខុតដោយខ្លួនឯង) ហើយគ្រាបទូលថា បពិត្រមហារាជ ចោរតាំងឡាយពីរនាក់ប្រាកដហើយ; ស្តេចឲ្យគ្រាស់ថា អ្នកឯងអាចចាប់ចោរតាំងឡាយនោះឬទេ? បពិត្រព្រះសម្មតិទេព ចោរតាំងឡាយនោះនាក់ទីនេះមិនខ្លាយទេ! ឲ្យគ្រាស់បញ្ជាក់ថា ចោរណាមួយ ចោរណាមួយ? ។ បពិត្រព្រះសម្មតិទេព ក័ធម្មតាចោរឯណាប្រាថ្នាចង់ប្លន់ចោរនោះហើយ អ្នកគាន់យកនូវខ្សែព្យាបស់ព្រះអង្គ សូមឲ្យគាន់កុំចោទបញ្ជាក់ទៀតឡើយ ។

ព្រះរាជាគាល់ប៉ែនសារនាគារដូច្នោះហើយ ក៏ទ្រង់សួរដេញដោលទៅទៀតដោយពាក្យអង្វរករថា នែអ្នកដ៏ចំរើន អ្នកឯងចាប់ខោរគាំងនោះឲ្យបានយកមកឲ្យយើងឆុះយើងឲ្យឆ្អែន ១ ពាន់កហាបណៈរាល់ថ្ងៃ ។ ព្រះពោធិសត្វមានសេចក្តីសង្រ្គាះដល់ព្រះរាជាអង្គនោះ ក៏ដួយចិត្តចុាំងទៅសារខោរគម្មបស់ស្តេចនឹងបុរោហិត ទុកជាស្តេចទ្រង់សួរបញ្ជាក់ញយៗក៏មិនប្រាប់ ប៉ើយនាំរឿងអតីតកាល ៥ រឿងមកសំដែងថ្វាយ... ។

រឿងទី ១ – កុងកាលដ៏កន្លងយូរមកហើយ មានអ្នកវប្ចាំម្នាក់ឈ្មោះឋាតលីនៅកុងក្រុងពារាណសី ; ។ អ្នកវប្ចាំនោះជាមនុស្សស្រែងស្រា លុះដល់ថ្ងៃសុីងខែទឹកកួចយកទៅ ក៏ស្រែកប្រកាសថា ទឹកជាទំពីងរបស់មហាជនតទ្បូវនេះសម្ងាប់ខ្ញុំហើយ។ ក៏លង់ស្រាប់ទៅ ។

រឿងទី ២ – កុងអតីតកាល មានសូនឆ្នាំងម្នាក់នៅស្រុកក្បែរក្រុងពារាណសី ។ បើរាគនឹងលាងរបស់គាត់តែងធ្វើឡ ដើម្បីនឹងដុតឆ្នាំង ភ្លើង ដើងគ្រាន លក់ដូរជាជម្មតា មានចង្រៃចៃដន្យកុងថ្ងៃមួយនោះ ស្រាប់តែភ្លៀងបង្អុរចុះមកជាខ្លាំងទឹកក៏ហូរចូលឋាតឡ្បូ។ ក៏ស្រុតធ្លាក់ចុះមកបែកក្បាលនាយសូនឆ្នាំងនោះឯង ។ នាយសូនឆ្នាំងក៏ទោមនស្សខ្សឹកខ្សួលអួលទ្រូង រៀបរាប់ថា – "មហាប្រិថពីជាទំពីងនៃមហាជនតទ្បូវនេះវាយក្បាលខ្ញុំបែកហើយ" ។

រឿងទី ៣ – កុងកាលដ៏កន្លងទៅហើយមានបុរសម្នាក់នៅកុងក្រុងពារាណសីដែរ ។ កាលបើភ្លើងនេះផ្ទុះហើយខ្លួនរត់ចេញមិនទាន់ ក៏

ស្រែកប្រកាសថា (លោកអើយមើលចុះ) ក្តៅដាច់ពីដងរបស់មហាជន តឡូវនេះដុតខ្ញុំសម្លាប់ហើយ ។

រឿងទី ៤ – ក្នុងកាលដែលកន្ទួងទៅហើយ មានអ្នកដំណើរម្នាក់នៅក្នុងក្រុងពារាណសីនោះដែរ ។ បរិភោគអាហារមិនស្គាល់ប្រមាណច្រើនជ្រុលហួសកំរិតពេក តេដោនាតុពុំអាចនឹងរំលាយអាហារឲ្យទ្រុងទ្រោមរលួយទៅបាន ក៏ច្រាសច្រាលខ្លាំងឡើង។ ស្រែកប្រកាសច្រាប់គេឯងថា លោកអើយមើលចុះ ៗ ចាយជាខ្ញុំឲ្យរស់នៅ តឡូវនេះសម្លាប់ខ្ញុំស្លាប់ហ៊ឹយ” ។

រឿងទី ៥ – ពីក្នុងអតីតកាល មានខ្សល់កំបុតត្បូងក្តួចយកបុរសម្នាក់ក្នុងក្រុងពារាណសីនោះដែរ ឲ្យដល់ខ្លួរកំរើយាបែកផ្លាយខ្លួចខ្លីអាយវៈ មានដៃដើងជាដើម ។

លុះបុរសនោះភ្ញាក់ខ្លួនឡើង ក៏ស្រែកយំខ្លួញថា លោកអើយមើលចុះ “ខ្សល់ក្នុងគំហ្មៈតូវតែងជាខ័ន្ធនៃជនឲ្យសប្បាយតែពាយ តឡូវនេះធ្វើខ្ញុំឲ្យឋាកបែកដៃដើងអស់ទៅហើយ” ។

រឿងទី ៦ – ពីក្នុងអតីតកាលកន្ទួងមកជាយូរហើយ មានដើមឈើធំមួយដើម ក្នុងព្រៃហិមពាន្ត ឈើនោះជាទីលំនៅនៃសកុណជាតិជាច្រើនពាន់ ។

មានសម័យថ្ងៃមួយ មានមែកឈើធំៗ ពីរបីសន្ធឹកគ្នា ហុយធ្លាក់នឹងកំពេចក្តៅឆ្អាប់ចុះមក ។ ពួកសត្វស្វាបង់ឆ្លាយនោះ កាលឃើញ

ហេតុដូច្នោះហើយ ក៏មានសេចក្តីតក់ស្លុតតក់ស្លុតញ័រខ្លួនញាប់ញ័រមិនសាស៊ុះធ្លាហើរចេញឃ្លាយ ស្រែករញ៉ែករញ៉ាចដាំងអស់គ្នាថា "មហាព្រឹក្សាជាទីពំនាក់អាស្រ័យនៃយើងដាំងឡាយ ឥឡូវនេះ ញ៉ាំងភ័យឲ្យកើតឡើងដល់យើងដាំងឡាយហើយ ចាំដូច្នោះហើយក៏ហើរចៀសចេញអស់ទៅ" ។

រឿងទី ៧ — ក្នុងកាលដ៏កន្លងទៅហើយ មានកុលបុត្តម្នាក់ នៅក្នុងដែនកាស៊ី នាកាលបិតាធ្វើកាលមរណៈហើយ ក៏ទំនុកបំប៉ុងបំរើគោ-តមាតាជាអលង្ហ ឯមាតាយើញកូនមានវត្តប្រតិបត្តិល្អ ក៏នាំស្ត្រីម្នាក់មានកត្តិស្រស់ប្រឹមប្រិយ៍មកវៀបចំឲ្យកូនខោះ ។

ចំណែកខាងខាងខោះ ក៏នាំម្តាយរបស់ខ្លួនមកនៅជាមួយត្រកូលប្តី ហើយទំនុកបំប៉ុងដល់មាតាដាំងសងខាង តាមគន្លងអបចាយនធម៌; លុះដល់ចំពោះបុត្រធីតាច្រើនឡើងត្រមាំងមានវេទនាគ្របសង្កត់ជាច្រើនដង ក៏មានចិត្តញាស់សាមានឮច្បាស់មកកាន់សន្តាន គិតសម្ងាប់ម្តាយក្មេកចោលក៏កើតរឿងដែលជាអនិដ្ឋារម្មណ៍ ឃុកមកបង្ខិចហើយច្រាប់ដល់ស្វាមីថា ឥឡូវនេះយើងគិតសម្ងាប់ម្តាយយើងចេញ ព្រោះវេទនាខ្លាំងណាស់ គាត់ចាស់ចង្កែងខ្សុសអស់ធ្មេញចាស់ដាំងភ្លុង តែងបន្ទោបង់អាចម៍នោមមកច្រាច់ច្រលង្ហល់ខ្លក់ពេញតែលើផ្ទះសំបែង ដូចជាកូនក្មេងមិនដឹងអីសោះ តែឯងមិនទៅពេលណាហើយធ្វើច្រាបតែអញឲ្យវេទនាពាប់មិនឈ្នះ ។

បើដូច្នោះយើងគិតសម្លាប់គាត់ទៅ ឬ ?

បុរសជាស្វាមី : កាលឮប្រពន្ធនិយាយរ៉ាយរាប់ច្រើនហេតុញយ ។ ពេក ក៏និយាយថា ការសម្លាប់មនុស្សនីមួយ ។ មិនងាយទេក្រែណាស់នាង!

ភរិយានោះនិយាយតបវិញថា បុតិ្តអ្នកស្វាមីការសម្លាប់នោះងាយទេ, មើលតែគាត់ដេកលក់ យើងចង់ត្រែសែងទម្លាក់ទឹកស្ទឹងខាងក្រោយធ្លុះយើងទៅ, ឲ្យធ្លាមមកវិញស៊ុ ខ្លះអ៊ីនោះខាងក្រោយធ្លុះ មានធ្លាមមកវិលវិលគាត ។ កុលបុត្រនោះក៏សួរថា មាតាអញដេកកន្លែងណា? ម្តាយឯងដេកកន្លែងណា? ស្ត្រីនោះច្រៀបថា ម្តាយអ្នកសម្លាប្តីត្រង់កន្លែងនោះ ម្តាយខ្ញុំដេកត្រង់ណោះ ។ ស្វាមីច្រៀបថាបើដូច្នោះចូរឯងចង់ត្រែម្តាយអញទុកឲ្យស្រែចទៅ, ហើយកំណាត់ចំណាំឲ្យច្រៀកដដល់ពាក់កណ្តាលអង្រែត សឹមយើងសែងយកទៅទម្លាក់ក្នុងទឹកស្ទឹងទៅ ភរិយានោះក៏ធ្វើតាមបង្គាប់ស្វាមី, លុះសព្វគ្រប់ហើយក៏ដេកលក់ទៅ; ឯានបន្តិចមកកុលបុត្រនោះក៏ចូលទៅស្រាយចំណងពីត្រែម្តាយខ្លួនចេញ ហើយយកទៅចង់ត្រែម្តាយខាងប្រពន្ធ (គឺម្តាយក្មេក) លុះចង់សព្វគ្រប់ហើយក៏ដើរចូលទៅជាស់ប្រពន្ធថា នែ ឯងក្រែកឡើង យើងល្ងាមសែងគាត់យកទៅទម្លាក់ចោលហើយ, ជនខាំងពីនាក់គឺ ស្វាមីនឹងភរិយាក៏ម៉ឺងើកត្រែសែងយកទៅទម្លាក់ក្នុងទឹកស្ទឹង ខាងក្រោយធ្លុះដោយប្រញាប់ប្រញាល់ខ្លាចត្រែងគាត់ភ្ញាក់ខ្លាន ។

ពួកសត្វសាហាវទាំងឡាយ មានផ្ទាមមករាជាដើម ជញ្ជែងគ្នាស៊ីម្ហាយស្ត្រីនោះអស់ទៅ ។

លុះដល់ត្រីកន្ទ្រោងស្វាងឡើងកាលណា ព្រះចន្ទ្រកឹមអស្តង្គត់ទៅ ព្រះអាទិត្យក៏រះឡើង កំចាត់ងងឹតអំពូស្វាងអស់ទៅ ។

នាងជាតិយោនោះ ឃើញម្ហាយក្មេកនៅកន្តើយៈហើយទៅបាត់ឯម្ហាយខ្លួនវិញ ក៏តូចចិត្តក្តៅក្រហាយអន្ទះសាពន់ពេក ទើបកេងបាយសម្រាប់ម្តងទៀត ក៏ប្រាប់ដល់ស្វាមីថា ម្ហាយខ្ញុំស្លាប់ទៅហើយ តទ្បាយនេះយើងគិតធ្វើដើងឬទុកក្នុងព្រៃស្មសាន, ហើយនាំគ្នាត់យកទៅដុតសម្រាប់ចោលទៅ ។ ប្តីក៏ទទួលព្រមថាល្អហើយនាងកាលបើមាតានៃជនទាំងពីរដេកលក់ហើយ ក៏នាំគ្នាសែងយកទាំងគ្រែជាក់លើដើងឬរ ហើយប្រាព្ធនឹងដុតភ្លើង, ទទួលពេលនោះក្មេចជាក់ឈើគួសទៅផង ក៏នាំគ្នាត្រឡប់មកយកភ្លើងវិញ ។

កាលជនទាំងពីរនាក់ ត្រឡប់មកឆ្ងរវិញបាត់ យាយចាស់នោះក៏ភ្ញាក់ឡើងក្រោកអង្គុយ ដោយសេចក្តីមត្តជាក់ខ្លាំង; លុះមើលសព្វទៅជឹងខ្លួនថាគេយកមកសម្រាប់ដូច្នោះ ក៏ចុះចេញទៅ ហើយបានសាកសពខ្មោចពពែ១ យកទៅដាក់លើគ្រែរួចគ្របសំពត់សពីលើ ហើយកៀសខ្លួនចេញពីទីនោះ ដើរចូលទៅកាន់គុហា១ ក៏រំពឹងត្រិះរិះក្នុងខ្លួនថា ឯងស្មានថាបានកូនប្រសាមកជាតិពីន តទ្បាយនេះវាធ្វើអញឲ្យក័យយ៉ាងក្រៃលែង ។

ចំណែកបុរសប្តីប្រពន្ធយកភ្លើងបានមក ក៏ដុតសាកសពនោះទៅ ដោយសំគាល់ថាជាម្តាយនោះពិតមែន ។

ឯណែនៃឯគុហានោះ មានចោរម្នាក់វាយកបង្គិចមាសធ្លាក់ទៅលាក់ទុកជាមុនយាយនោះទៅដល់បានបន្តិចមកចោរនោះ វាទៅនាំយកទ្រព្យរបស់វា ស្រាប់តែឃើញយាយចាស់នោះឈរនៅមាត់លេណៈក៏ភ្ញាក់ស្មានថាជាយក្ស មិនហ៊ានចូលទៅ ក៏ត្រឡប់មកវិញ ហៅពេទ្យខ្មោចម្នាក់ឲ្យចូលទៅសង្កេតមើល ពេទ្យខ្មោចនោះក៏ធ្វើមន្តវិជ្ជាការ ព័ទ្ធស័មាហើយក៏ដើរចូលទៅកាន់គុហា ។

ចំណែកយាយចាស់នោះថា យើងមិនមែនជាយក្សទេ ចូរចូលមកចុះយើងទាំងពីរនាក់នឹងចែកទ្រព្យគ្នា ។ ពេទ្យនោះតបថា យើងមិនជឿទេ ; បើអ្នកឯងមិនជឿយើងចូរអ្នកឯងយកអណ្តាតមកដាក់លើអណ្តាតយើងចុះនឹងដឹងច្បាស់ថាយើងជាមនុស្សពិតហើយ ; ពេទ្យនោះក៏ធ្វើតាមពាក្យយាយចាស់នោះទៅ យាយនោះក៏ទាំអណ្តាតពេទ្យជាប់ដោយឆ្នេញចង្កឹមមួយយ៉ាងចំណាប់ពេទ្យខ្មោចនោះខំប៉ះរុចហើយស្រែកថ្ងូរប្រាប់គ្នាថាយក្សទេវីយយក្សទេវូចក៏នាំគ្នារត់ចេញទៅ ។ លុះដល់ក្នុងច្បាស់ឡើងយាយចាស់នោះក៏ដញ្ជួនយកមាសធ្លាក់ វែក ពេជ ចាវ៉ុក ខ្នុំ ការកងវែក ដែលចោរលាក់ទុកក្នុងលេណៈនោះ ត្រឡប់មកផ្ទះវិញ ។

ចំណែកខាងកូនប្រុស ត្រឡែកឃើញម្តាយមកវិញមានបង្គិចទ្រព្យមកផង, ក៏ធ្វើរាក់ទាក់បងិសណ្ឋារៈគួរសមយ៉ាងអស្ចារ្យ ហើយ

និយាយតបទៅវិញថា តុលោកម្ដាយគេយកទៅដុតកងវៃព្រោះតែឲ្យប៉ាជាប្អូនមាសប្រាក់ តែវាកងពិធូរឫសូរិកោន្យ ពេជ្រ ខ្លែល យ៉ាងដូច្នឹង? បើដូច្នោះខ្ញុំសូមឲ្យលោកម្ដាយយកខ្ញុំទៅដុតម្ដងវិញចុះ តើនឹងប្អូនដូចជាលោកម្ដាយដែរឬទេ? អើបើកូនធ្វើដូច្នោះនឹងប្អូនដូចជាអញ្ចឹមិនខានទេ ។

ស្ដីនោះជាស្ដីពាល លោកចង់ប្អូនតែឲ្យមិនគិតវែងឡើ ក៏ឲ្យស្វាមីយកទៅដុតកងវៃស្មុសាន ដើម្បីនឹងបានប្រយោជន៍, ស្វាមីក៏នាំយកទៅដុត ភ្លើងឆេះអស់ខ្លួចខ្លីទៅ ។

រឿងស្រីពាលចិត្តអន្យត្តិរិយ ប្រុសក្លាយអក្ខរៈទោសនោះត្រឡប់ជ្ងាក់មកលើខ្លួនវិញ ក៏ដល់នូវសេចក្ដីក្សិណក្សុយនាគណ្ដាលក្ដក់ភ្លើងនោះហោង ។

រឿងទី ៨ - កុងកាលដ៏កន្លងទៅហើយ មានបុរសម្នាក់នៅកុងក្រុងពារាណសីចង់ប្រាថ្នាបានកូនប្រុសម្នាក់ លុះដល់បានកូនប្រុសនោះហើយ ក៏ខំប្រឹងចិញ្ចឹមដោយបំណងថា "កូននេះនឹងចិញ្ចឹមអញ កុងកាលនៃអញចាស់ជរា" ឯកូនក៏បណ្ដោញបុរសនោះដែលដល់ខ្លួនជរាហើយ ឲ្យចេញពីផ្ទះដោយពាក្យថា ឥឯងមិនអាចធ្វើការកើតទេ ចូរចេញពីផ្ទះនេះទៅ បុរសនោះគាលចិញ្ចឹមជីវិតដោយការសូមយ៉ាងពិបាក ក៏ខ្សឹកខ្សួលថា "កំយកើតមានដល់អញ ព្រោះតាស្រ័យកូនដែលអញខំប្រឹងចិញ្ចឹមដោយបំណងថានឹងបានចិញ្ចឹមអញដល់ចាស់ជរា" ។

និគមវចនៈ

ព្រះពោធិសត្វបានតាំរឿងអតីតនិទានទាំង ៨ រឿងដូចបានសំដែងមកហើយនោះគឺ: រឿងបុរសលង់ទឹកស្ទាប់ ១ រឿងនាយស្មូនធ្នាំងឲ្យគ្រប សង្កត់ស្ទាប់ ១ រឿងបុរសកេះឆ្នេះស្ទាប់ខ្នង ១ រឿងបុរសស៊ីបាយចាក់ច្រាសងាប់ ១ រឿងបុរសខ្យល់ក្តួចដួលបែកក្បាល ១ រឿងសត្វស្វាបន្ទោនឹងដើមឈើធំ ១ រឿងកុលបុត្រចំរើម្ហាយ។ នាំស្រីការឡកណ្តើមកឲ្យជាប្រពន្ធ ១ រឿងបុរសចិញ្ចឹមកូនដើម្បីជាទីពឹងដល់ខ្លួនជាស់ ១

លុះសំដែងចប់ហើយ ក៏យកកណ្តាសារមកថ្វាយព្រះមហាសត្វ ហើយពោលថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គជាបន្ទូរចោរឯនោះចុះ ដូចការណ៍ដែលខ្ញុំព្រះអង្គដំណាលមកនេះឯង ។

ព្រះរាជាអង្គនោះ នៅតែទទូចឯងឯកសួរតទៅអញ្ជើតថា ចូរអ្នកឯងឆ្លាប់ចោរណាមួយឲ្យច្បាស់ជាហើយប្រាសចាកងឹកណ្តាលជ្រុង បើសឲ្យចុះ ។

ទើបពោធិសត្វ ពោលថា អើស្តេចនេះ មិនត្រូវការឲ្យគេជួយការពារខ្លួនទេ តើខ្ញុំព្រះអង្គនឹងចាប់ចោរតឡូវនេះ ។

សូមព្រះអង្គទ្រង់សណ្តាប់ចុះ ហើយប្រកាសថា បពិត្រមហាជនទាំងឡាយអើយ សូមស្តាប់ចុះ ស្តេចអង្គនេះ ១ ចុះពោលិតនេះ ១ ធ្លើចោរកម្ម ។

លុះយកកណ្តាសារជាព្រះពន្ធទ្រង់ ទៅលាក់ទុកហើយក៏រៀបរាប់សារសំតួ តាមដំណើរដើមដែលសំដែងមកនោះឯង ។

ពួកមហាជនគាំងឡាយ ឃ្លានឮព្រះពុទ្ធសំដែងទោសចោរកម្ម ដូច្នោះហើយ ក៏យល់ហេតុថា ស្តេចជាម្ចាស់យើងនេះ គិតលើកទោសរបស់ខ្លួនទៅទម្លាក់លើបុគ្គលដទៃទេតើ ឃ្លានឆាយកទ្រព្យរបស់ខ្លួន ទៅលាក់ទុកក្នុងស្រះឃ្លានណាហើយស្តែងរកថាប់ចោរដូច្នេះ ។

បើដូច្នោះពួកយើងចាំតែទៀត ស្តេចលាមកអនុសាសពិធីធម៌ ហើយទុកធ្វើអ្វី? ក៏នាំគ្នាចាប់ស្តេចនឹងបុកពេញតែសម្លាប់បង់ព្រះជន្មទៅ ។

លុះសម្លាប់ស្តេចអង្គនោះហើយ ក៏ប្រជុំប្រឹក្សាគ្នារកបុគ្គលអ្នកមានបុណ្យស្មមួយទៀតនោះលើស្រុកដួតែ សោយរាជសម្បត្តិលើផែនដីឥតពី ឲ្យមានពួកគណកុះកុំមកម៉ាលើផែនដីតែពីក្បែរសុខសប្បាយ ។

បើតាមពិតទៅ ឃើញតែមាណពអ្នកចេះសិល្បមន្តនោះឯង គួរទ្រទ្រង់បុណ្យស្តិតនៅលើស្រុកដួតែឥតខ្ចោះ ។ ហើយគប្បីបាំងអាណាប្រជានុពស្តេរបស់ព្រះអង្គឲ្យតស៊ូនឹងកុងទសពិធកុងធម៌ ប្រដៅប្រយោជន៍បច្ចុប្បន្ននឹងបរលោកឲ្យក្លាសុវុធរឿង រហូតដល់ទីចំផុតជាអាសានហោង ។

(ហេតុដូច្នេះ ខ្ញុំសូមរំលឹកដល់ឃ្លានគាំងឡាយឲ្យឃ្លានក្លាថា ចូរខំស្តាប់រៀនសូត្រឲ្យមានវិជ្ជាចរិយាបណ្ឌិតទៅចុះ ព្រោះវិជ្ជាអាចធ្វើមនុស្សឲ្យថ្លៃឯង មិនថាត្រកូលចោកគាបខ្ពង់ខ្ពស់ទៅឡើយ ដូចជារឿងព្រះពោធិសត្វដែលលោកស្តិតនៅក្នុងត្រកូលចោកគាបសោះទេ តែអំណាចមានវិជ្ជាក្នុងប្រាណ តែព្រះអង្គឲ្យឃ្លានជាស្តេចម្ចាស់ផែនដីទៅឯង) ។

ជំនាន សុភាសិត

"ដោះបន្ទុ ដោយបន្ទុ"

(សុជាត ជាតក ចញ្ចកនិបាត)

មហោ ទិម-ណារ៉ូ

ឃុំស្វាយចៅ ស្រុកសង្កែ ខេត្តបាត់ដំបង ប្រែរៀបរៀង

កន្លងអតីតកាល កាលព្រះចៅព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វជាម្ចាស់នៃយើង កើតក្នុងត្រកូលក្រុដុម្ពីក៍មាននាមថា "សុជាតៈ" ឋានសិក្សាសិល្បសាស្ត្រតាមសម័យនិយម ហើយក៏អាស្រ័យនៅជាមួយបិតា ។

ថ្ងៃមួយ ជំនាន់នៃសុជាតកុមារ ឋានឆ្លងកាលកន្លែងយោគាន់បរលោក ។ ក្រុដុម្ពីក៍ ជាបិតារបស់សុជាតកុមារ មានចិត្តខ្វោចឆ្យារំភើបរំជួលឈួលទៅដោយសោកសៅក្តៅក្រហាយស្តាយធំ រំយោគយំរៀបរាប់ពាំនៃអាល័យបិតា ដែលឆ្លងកាលកន្លែងយោគាន់លោកខាងនាយដែលមិនអាចត្រឡប់វិញបាន; សូម្បីថ្ងៃនិងយប់តន្លង់ទៅ ។ ក៏នៅតែមិនស្ងប់ស្ងាត់ មិនចាត់បរិវេណក្នុងសោះ ។ កាលឆ្លងឈានបានកិច្ចបួងសពរួចហើយ ក៏គាត់មិនស្ប៉ើយល្ហើយចាកក្នុងនោះដែរ គាត់តែងទុក្ខព្រួយដើរទៅទីប៉ាដែលដុតរាងកាយបិតា ប្រមូលរើសរាងឆ្អឹងខ្ចប់ធឹងតំណាត់សំពត់ ហើយយកទៅបញ្ចុះក្នុងកន្លែងសួបដែលកុសាងឆ្លងឡើង ដោយដឹងសួនដំណាំខាង

ក្រោយផ្ទះរបស់ខ្លួន ។ រាល់ៗថ្ងៃ គាត់តែងតែទៅធ្វើកិច្ចគោរពបូជាអដ្ឋិក្នងស្តូបនោះ ដោយមែកឈើផ្កាឈើផ្សេងៗ ដើរប្រទក្សិណស្តូបហើយក៏តាំងតែរៀបរាប់ដោយវិរិយោគក់ចាជាអង្វែកបង្ការ, រូបកាយរបស់គាត់ស្ទឹងសៅហ្មងក្រៀមក្រំខ្លួញយំតប់ប្រមល់ អង្គុយថ្ងូរបង្ហូរទឹកភ្នែកដេកមិនលក់បាក់មិនល្ហើយក្លេចង្ងុតទឹកមិនទឹកឃ្លានអាហារ ការងារក៏អាក់ខានមិនបានធ្វើ ។

សុជាតកុមារ ឃើញអាការរបស់បិតាវិបត្តិប្លែកជាងប្រក្រតីធម្មតា ទើបត្រិះរិះថា "បិតាអញ តាំងពីលោកតាអនិច្ចកម្មទៅ មានតែសោកសៅខូចចិត្តឥតរសាយ មនុស្សដែលក្រៅពីអាត្មាអញហើយ មិនមាននរណាឡើយនឹងអាចជួយលុបលាងបន្ទោបង់សេចក្តីសោករបស់គាត់ឲ្យបាន ចាំអញរកឧបាយណាមួយជួយឥន្ទ្រល់គាត់ ឲ្យលះការសោកសៅនោះចេញ" ។

សុជាតកុមារ ចំពិនិត្យរកឧបាយជាច្រើនថ្ងៃ; ថ្ងៃមួយចេញអំពីផ្ទះទៅក្រៅភូមិ បានប្រទះឃើញគោស្ទាប់មួយ ដែលគេអូសយកទៅចោលឧបាយដែលគិតខុកយូរហើយ ក៏លេចប្រាកដឡាស់ឡើងទើបទៅយកស្មៅនឹងទឹកមកជាក់ខាងមុខគោ កាលឃើញជនណាមួយដើរទៅជិតក៏តាំងលួងលោមនិយាយអង្វរគោស្ទាប់នោះថា "នែអាពួកម៉ាកកំសត់! សំឡាញ់ចាស់! ចូរក្រោកឡើង! មកស៊ីស្មៅផឹកទឹកឲ្យសប្បាយចុះ អញបាននាំស្មៅនឹងទឹកមកត្រៀមទុកឲ្យស្រួលបួលហើយ" ។

មនុស្សទាំងឡាយ ដើរទៅឃើញគេធ្វើដូច្នោះ ក៏ប្លែកក្នុងចិត្តគិតសង្ស័យទៅបាកស្លរថា "លោកសុជាត! ពីពេលមុនមក ខ្ញុំដឹងស្គាល់លោកថាជាអ្នកប្រាជ្ញ ជាមនុស្សល្អ តែថ្ងៃនេះលោកជាអ្វីទៅ! ក៏គោនោះវាស្លាប់ទៅហើយមិនមែនឬ? លោកនិយាយជាស់ឲ្យវាភ្ញាក់ត្រាកស៊ីស្មៅផឹកទឹកដូចម្តេចទៀត?. ខ្ញុំមើលទៅលោកហាក់ដូចជាមនុស្សវិកលចរិតទៅ? រៀលនេះ សតិរបស់លោកនៅទេញៀលញៀចរឹបូណ៌តាមប្រក្រតីទេឬ?" ។

សូម្បីបានឮពាក្យទាំងនោះ សុជាតកុមារក៏មិនតឆ្លើយតួងដល់ជនណាមួយឡើយ នៅតែធ្វើអាការដូច្នោះយ៉ាងត្រេះឆ្លើយតឆ្លើយហាក់ដូចជាមិនដឹងមិនឮ ។ កិច្ចការដែលសុជាតកុមារធ្វើនោះបានឮសាយសុះសព្វភូមិស្រុកពាសពេញទីក្រុងទាំងមូល ។ មនុស្សជាញាតិខ្លះ នាំដំណឹងនោះទៅប្រាប់កុដុម្ពីក៍ ជាបិតារបស់សុជាតកុមារថា "លោកកុដុម្ពីក៍! លោកមិនខាន់ឮ មិនបានដឹងខ្លះទេឬ? អំពីរឿងកូនរបស់លោកធ្វើកិរិយាខុសវិស័យធម្មតា ការនោះ ក៏ឮសាយសុះសព្វទីក្រុង កូនរបស់លោករៀលនេះ ក្លាយទៅជាមនុស្សវិកលចរិតហើយ ដោយបានដាំទឹកនឹងស្មៅទៅជាក់ខាងមុខគោស្លាប់មួយនិយាយលួងលោមឲ្យគោនោះ ត្រេកឡើងស៊ីស្មៅផឹកទឹក ការធ្វើយ៉ាងនេះ លោកនឹងឃើញថាសមមុខវង្សត្រកូលនៃយើងឬ?" ។

កដុម្ពីក៍ឃាតកម្មដូច្នោះ ទើបហៅកូនមកហើយសួរថា "កូនសំឡាញ់! តើថាកូនឯងមិនបានធ្វើកិរិយា មានសភាពដូចយ៉ាងគេនិយាយគ្រប់គ្នាមែនឬ?" ។

– ឱពុក! ខ្ញុំធ្វើយ៉ាងម៉្លឹងមែនលោកឥតុក?

– កូនសំឡាញ់! ឥតុកសូមសួរកូនឯងបន្តិច ហេតុអ្វីទើបឯងទៅនាំយកស្មៅនឹងទឹកទៅដាក់ខាងមុខគោស្ទាប ហើយនិយាយនឹងគោដែលច្រោសចាកជីវិតឥតវិញ្ញាណថា "នែសំឡាញ់ចាស់! ចូរក្រោកឡើងមកស៊ីស្មៅផឹកទឹកឲ្យសប្បាយចុះ" ដូច្នេះ គោដែលស្ទាប់ទៅហើយក៏នឹងត្រឡប់មានជីវិតវិញបាន ដោយការនិយាយលួងលោមយ៉ាងដូច្នោះឬ? មនុស្សឲ្យត្រង់អត់បញ្ញាការពិនិត្យ ទើបធ្វើកិរិយាអាការមិនសមហេតុផលដូចកូនធ្វើនេះកើត កូនធ្វើយ៉ាងនេះ ដូចកូនមិនមែនជាបណ្ឌិត ព្រោះអំពើរបស់កូន ច្រោសចាកប្រយោជន៍ទាំងពួង ។

សុជាតកុមារ ស្តាប់បិតាថាដូច្នេះ ឃើញថាជាឧកាសដ៏សមគួរយ៉ាងក្រៃលែង ទើបពោលដោយក៏ចាន់កូនច្រកបដោយហេតុផលតបពាក្យបិតាថា "ឱពុកលោកឥតុក! កិរិយាដែលខ្ញុំធ្វើនោះ ខ្ញុំសូមទទួលកំហុសថាខុសវិស័យធម្មតា មនុស្សអន់ចន់ខ្សោយដោយគ្មានវិចារណញ្ញាណ ទើបគួរធ្វើបែបនេះ ដូចលោកឥតុកថាមែន ព្រោះថាធម្មតាគោស្ទាប់ទៅហើយ អាយុវែងគ្រប់ចំណែកក៏ស្ទាប់ទៅតែម្តងគ្នា មិនអាចកន្ត្រើកបាន

ទេ ប៉ុន្តែចុះគោជែលស្លាប់ខោះ ក៏នៅមានកូនស្រាល មុខ មាត់ ត្រចៀក ក្អែក ច្រមុះ ស្មែង កន្ទុយ ដាជើម ច្រើនដប្បាស់ជាងកូនលោកឥពុក ឆ្ងាយណាស់ខ្លាំង ; ខ្ញុំសូមសួរលោកឥពុកខ្លះចា ការដែលលោកឥពុកសៅសោកវៀបភប់ភ្ញាំរ៉ៃ អាល័យលោកគ្មានជែលអនិច្ចកម្មទៅទៀតសល់តែឆ្នើងជញ្ជុំកងចេតិយ៍ ដោយមិនឃើញច្រើនកាយ សូម្បីត្រឹមអាយុវ៉ះណាមួយឡើយ លោកគាន់ចិត្តឬចាស់ឡើងរំភើយដោយការយំសោកយ៉ាងនោះបានឬ? លោកឥពុកបានផលប្រយោជន៍អ្វីខ្លះ អំពីការធ្វើនោះ? លោកឥពុកពិនិត្យគិតមើលទៅ ការធ្វើរបស់ខ្ញុំនឹងរបស់លោកឥពុក តើខាងណាគាន់បើជាង? សូមលោកឥពុកពិនិត្យគិតមើលឲ្យច្បាស់ ហើយសូមអញ្ជើញមានប្រសាសន៍មកចុះ" ។

កុដ្ឋម្ចាស់បានស្តាប់សំដីដ៏សមហេតុសមផលរបស់បុត្រដើរពិនិត្យមើលការធ្វើរបស់ខ្លួន ក៏ឃើញសមតាមពាក្យរបស់បុត្រមែនហើយគិតថាកូនរបស់អញជាបណ្ឌិតពិតជាច្រើន អាចដឹងច្បាស់កិច្ចការប្រយោជន៍នឹងមិនមែនជាប្រយោជន៍ ការដែលកូនអញធ្វើដូច្នោះគឺដើម្បីឲ្យអញដឹងខ្លួនទេតើ! ទើបពោលនឹងកូនថា :

"ម្នាលសុជាត! អ្នកបានគិតរកឲ្យឥពុកដឹងច្បាស់ថា សង្ខារទាំងឡាយមិនទៀងទាត់ ចាប់តាំងពីពេលនេះតទៅ ឥពុកមិនសៅសោកទៀតទេ ដែលឈ្មោះថាកូនអ្នកឆ្ងួយឥពុក ឲ្យរួចចាកទុក្ខ ឲ្យសុខសប្បាយ ឲ្យរសាយចាត់សៅសោករកមិនបានងាយឡើយ" ។

គាលសំដែងសេចក្តីសរសើរបុត្រៈបស់ខ្លួន ទើបពោលជាគាថាថ្វាយ៖

"មិនខាតទុំសព្រោះនពុកមានសុបុត្រ
ជួយលែតអគ្គីសោកឋានសូន្យសោះ
ជួចលត់ភ្លើងរៃព្រៃដែលឆេះដោយទឹកស្មោះ
នៅសោមនស្សមនោពោរសប្បាយ ។
របស់សំឡាញ់ព្រាត់ខ្លៅទ្បើតសោក
ជួចខែលចិលបាកលោកជាត់ចំហាយ
អ្នកមានបញ្ញាគាបខន់ទឹកត្នែកភ្លាយ
ដូនអ្នកខ្សៀយណាយរឿងលោកមិនសោកចិត្ត ។
នពុកត្រូវកូនសរសោកមកប៉ះពាល់
ស្ទើរជាច់ខ្យល់ដល់មរណៈជិវិត
កូនបានជួយដកសរសោកសុបសៅចិត្ត
ជួចជួយដបជីវិតវែងដល់បិតា ។
សុជាតធ្វាតទុត្តមសមជាបណ្ឌិត
ជួយកែចរិតនពុកឲ្យបានការ
ប្រើវិធីជោះបន្ទាដោយបន្ទា
ព្រោះប្រាជ្ញាប៉ាវកយណាស់កូនអើយ !!!" ។

គតិរបស់រឿង

រឿងនេះ ប៉ានគតិយ៉ាងនេះ គឺ: —

១ — អ្នកមិនប៉ានសិក្សាពាក្យពេចន៍របស់អ្នកចេះដឹង មិនប៉ានពិចារណាមើលគតិធម្មតារបស់ការ:ទាំងឡាយ ដែលមានហាន:តែងតែប្រព្រឹត្តទៅកន្លងលោការមែងមិនអាចដឹងសេចក្តីពិតប៉ាន កាលបើយ៉ាងនេះ បើជួបប្រទះទៅលើអារម្មណ៍ជាទីប្ញាថ្នា ក៏ត្រេកអររីករាយចូលចិត្តថាប៉ានជួបប្រទះសេចក្តីសុខ ពេលណាប៉ានជួបប្រទះអារម្មណ៍មិនជាទីប្ញាថ្នា ពេលនោះក៏កើតទោមនស្សតូចចិត្ត ចូលចិត្តថាប៉ានជួបប្រទះសេចក្តីទុក្ខ; ពេលណាប៉ានជួបប្រទះអារម្មណ៍ ដែលជាកណ្តាល។ មិនល្មមនឹងទោមនស្សប្ញសោមនស្ស ពេលនោះក៏មិនដឹងតាមសេចក្តីពិត ។ អ្នកមិនដឹងតាមសេចក្តីពិតដូច្នេះ ឈ្មោះថាសាត់អណ្តែតសែតអញ្ជង់ទៅតាមអារម្មណ៍ រមែងប៉ានទទួលសុខខ្លះ ទុក្ខខ្លះ , មិនមែនសុខខ្លះ មិនមែនទុក្ខខ្លះ ជាហេតុមិនមានវេលាស្ងប់មិនរួចពាក់ទុក្ខទៅប៉ាន ។

២ — អ្នកតូចដែលនៅក្រោមអំណាចការគ្រប់គ្រងរបស់អ្នកធំ កាលដឹងឃើញថា អ្នកធំធ្វើមិនល្អប្រព្រឹត្តខុស ក៏មិនគួរសំដែងអគារវ: មើលងាយក្រអឺតក្រអោងកោងកាច ប្រើការយាច្រឡោះចោះច្រឡាងខាមជាក់លោកឡើយ គួរតទ្ញាយកលដ៏សមហេតុឆលណាមួយមកជួយជាសត្វើនក្រើនរំលឹកលោក ដោយទ្ញាយសម្រួលល្មមឲ្យលោកក្ញាក់គំនិតគិតដឹងខ្លួន នេះជាកិច្ចដ៏ប្រពៃពាំងផ្លូវធម៌ពាំងផ្លូវវិន័យ ។

๓ - អ្នកធំដែលមានឧបាទីគ្រប់គ្រងអ្នកតូច គួរធ្វើខ្លួនឯងឲ្យជាទិដ្ឋានុគតិ ដើម្បីជាសណ្តាប់តម្រាប់តម្រាគួរដែរថ្នាជល់ចិត្តរបស់អ្នកតូច នឹងមិនគួរប្រកួតប្រកាន់វិជ្ជមាន:ឡើយ ការធ្វើការណាទៅហើយដឹងច្បាស់ថាមិនត្រឹមត្រូវសមប្តុស កំគួរវៀរលែងធ្វើតទៅទៀត ឬបានទទួលការជាស់តឿនអំពីអ្នកតូច ដោយការដែលសមគួរ កំគប្បីពិនិត្យគិតមើលការធ្វើគឺអំពើរបស់ខ្លួន កុំធ្វើទទឹងសំដែងការដោយការធំ ការដឹងថាបានធ្វើមិនល្អឬប្តុស កំកែឲ្យល្អត្រឹមត្រូវឡើងយ៉ាងនេះទើបជាការនាំឲ្យចំរើនដល់ខ្លួន នឹងពួកគណ:ដោយពិត ។

ប្រវត្តិស្ទឹកឃ្មុំក្នុង

រវាងភូមិ ឬ រូងជ្រោះភ្នំ

របស់ អ៊ូ - គូ

អាចារ្យវត្តព្រះត្រែតាំង - ឃុំដំដែក

ស្រុកសូទ្រនិគម ខេត្តសៀមរាប

(រឿងលេខ ២)

មានភ្នំមួយ ឈ្មោះភ្នំ ឫក - គោ ភ្នំនោះធំហើយខ្ពស់ធង ក្នុងមានរូងជ្រោះជ្រៅ មានតើងថ្មធំ ៗ ជួន ឬ ជ្រុំថ្នាក់ ដល់ខាងលើបង្គស់មានរវាងថ្មធំ ៗ នៅអំពីខាងលើដូចជាដំបូលធ្នះ ។ ថ្នោះ មានសណ្ឋានខ្ទង់ខ្ទាយដូចជាបង្គងឃ្មុំ ម្ល៉ោះហើយពពួកឃ្មុំ តែងនាំគ្នាទៅធំធ្វើជាលំនៅរបស់ខ្លួន ៨០ ឬ ៩០ បង្គង ។

ដល់រដូវខែផល្គុន ឬខែចេត្រ ដែលជារដូវគ្មានភ្លៀងធ្លាក់ ជនខាងឆ្ការយសុទ្ធតែជាអ្នកស្គាត់ជំនាញខាងការយកឃ្មុំមកធ្វើគ្រឿងបូន តែងដើរដម្រង់ទៅកាន់ភ្នំនោះគ្រប់ ៗ គ្នា បើអ្នកណាបានទៅឃើញមុននោះ គេតុកជាឃ្មុំរបស់គេ អ្នកដទៃមិនអាចហ៊ានទៅយកឡើយ ប៉ុន្តែកម្រណាស់មនុស្សដែលហ៊ានទៅយកឃ្មុំកងរូងភ្នំនោះ ដាល់តែអ្នកណាចិត្តស៊ូប្រថុយស្វាប់ទើបទៅយកបាន ពីព្រោះការទៅយកឃ្មុំនោះពិបាកណាស់ ។

ពន្លឺដែលតឹងទៅបកឃ្មុំ

ឃ្មុំកាលបើគេឃើញផ្ទុះច្មាះហើយ គេកគ្នាបាន ៦ នាក់ មនុស្ស
ខាំង ៦ នាក់នោះ ក៏តាំងផ្តាំប្រពន្ធកូនគេលដែលទៅយកឃ្មុំថា តាំងពី
នេះទៅមិនត្រូវគាត់សក់ខ្ទុះតញ្ជក់លាបប្រេងម្សៅឡើយ ផ្តាំផ្ទុះច្មាះហើយក៏
នាំគ្នាទៅ លុះទៅដល់គោងភ្នំក្តុំ ក៏ចោទឈើយកមកវេញធ្វើជាព្រំត្រែចំ-
នួនប្រវែង ២០០ ម៉ែត្រ ។ លុះវេញរួចគេកាប់កូនឈើប្រវែងមួយហត្ថ ។
យកមកចងភ្ជាប់នឹងព្រំត្រែ ធ្វើជាផ្ទៅរសម្រាប់សំយុងចុះ គេយោលយក
ឃ្មុំកងជ្រោះភ្នំនោះ ក៏នាំគ្នាកាប់ឈើមកតធ្វើជាផ្ទៅរ ។ ឯផ្ទៅរនេះ
គេធ្វើជា ៣ ថ្នាក់ ក្នុងមួយថ្នាក់ៗ កំពស់ប្រហែល ៥០ ម. ថ្នាក់ទី ២ កំពស់
៥០ ម. ថ្នាក់ទី ៣ កំពស់ប្រហែល ៧០ ម. រួមកំពស់ចម្ងាយប្រមាណ
១៧០ ម. បានជាខ្ពស់ដល់ម្ល៉ោះ ពីព្រោះឡើងទៅដល់ថ្នាក់ទី ៣ ត្រឡែក
មើលមកដំរាញ យើញសត្វខ្លាឃ ឬ ត្រចៀវដែលគេស៊ីដើងភ្នំប្រ-
ហែលប៉ុនផ្លែ ។ លុះគេធ្វើផ្ទៅរួចហើយ គេកាប់មែកឈើដែលស្វឹក
ស្រស់ ។ យកមកធ្វើគប់សម្រាប់បង្ហុយយកឃ្មុំ ។

ឯគប់នោះគេយកពាមឈើស្វាតតូច ។ ដុតភ្លើងយកស្វឹកស្រស់ស្រោប
ពីក្រៅ ធ្វើជាកូនញុះសម្រាប់ដុតបង្ហុយដែរឲ្យឃ្មុំផ្អើល គេធ្វើគប់នោះ
បានចំនួន ៤០០ ឬ ៥០០ រួចហើយ គេកេសត្វបង្ហុយ នឹង ត្រកួត យក
មកកាត់ក្បាលធ្វើពលីការ អុជទៀនធូប បួងសួងសែនព្រៃនថ្វាយដល់

អារក្សខេត្តដែលនៅថែរក្សាភ្នំនោះ ។ ឯជង្វាយដែលធ្វើពលីការសែនព្រៃនោះ ខុសតែពីក្បាលបង្ហុយនឹងត្រកួតចេញ ខេត្តពុំអាចនឹងខ្វះបានឡើយ ។ បើគេរកសត្វទាំង ២ មុខនោះមិនបាន គេមិនហ៊ានយកឃ្មុំទេ តែងពេលដែលធ្វើពលីការសែនព្រៃនោះ ដូចជាអស្ចារ្យណាស់ អ្នកដែលយកឃ្មុំទាំងអស់គ្នានោះ គេតាំងអុចខ្មៀនធួប ហើយពោលទាំងអស់គ្នាថា "នគុណាតេជះព្រះម្ចាស់ថ្ងៃខ្ញុំអើយ ឥឡូវនេះ ព្រះគុណនៅថែរក្សាឃ្មុំនេះយូរណាស់មកហើយ ព្រះគុណជម្រាបថាឲ្យខ្ញុំរកក្បាលបង្ហុយ នឹងត្រកួត យកមកបូជាថ្វាយព្រះគុណ ដើម្បីនឹងដូរយកឃ្មុំរបស់ព្រះគុណ សូមអញ្ជើញព្រះគុណមកសេពសោយចុះ បើព្រះគុណត្រូវការសេពសោយហើយ សូមព្រះគុណយកឃ្មុំមួយសំបុក ៨ ឬ ១០ មកឲ្យខ្ញុំមើលផង ។

ហាក់ដូចជាអស្ចារ្យណាស់ ថាតែប៉ុណ្ណោះហើយ ក៏ស្រាប់តែមេឃ្មុំទាំងឡាយហើរធ្លាក់ចុះមកតាសពេញទាំងសំណែន បីដូចជាមកឧប្ថម្ភយកហើយមកអង្វរអ្នកនោះថា សូមអ្នកឡើងទៅយកចុះ មេឃ្មុំទាំងឡាយគ្រាន់តែហើរមកចំមួយស្របក់ឬមួយសំកាំងស្រាប់តែប៉ុណ្ណោះ ក៏នាំគ្នាហើរទៅវិញអស់ទៅ ។

មនុស្សទាំងឡាយ ឃើញអាការរបស់ឃ្មុំដូច្នោះ ក៏តាំងបបួលគ្នាបង្អាត់គប់តាម គេឡើងទៅនៅបន្តគ្នាតាមថ្នាក់ មួយថ្នាក់ម្នាក់ៗ ។ ឯដំណែ

ជណ្តើរនោះ តតាមថ្នាក់តើងថ្នាំងបីថ្នាក់ បួនទឹងថ្នាក់ចុងជណ្តើរខាងលើបង្អស់ ។ ថ្នាក់ក្រោមបង្អស់នោះ គេនៅចាំពីរប្តីបីនាក់សម្រាប់ជុតភ្លើងគប់ ទឹងចាំច្រមុលយុំដែលធ្លាក់មក អ្នកនៅថ្នាក់លើតាំងបីជាន់នោះ ចាំយោងគប់បន្តគ្នាឡើងទៅ ដើម្បីទឹងថែមជាបដល់យកយុំអស់ ។ ថ្នាក់ខាងចុងជុតនោះ ម្នាក់នៅទឹងមាត់ជ្រោះចាំមើលការខុសត្រូវ ទឹងចាំមើលខ្សែព្រួដែលសំយុងចុះទៅ ទឹងសំយុងគប់ថែមទៅឲ្យទៀតផង តែអ្នកនោះត្រូវជាបងប្អូនឬអាពុកឬជាកូនបង្កើតរបស់អ្នកដែលចុះទៅនោះឯង ព្រោះខ្លាចក្រែងកាត់ខ្សែព្រួ ។ ឯអ្នកដែលចុះទៅនោះ គេចងខ្លួនភ្ជាប់ទឹងខ្សែព្រួឲ្យជាប់ ហើយគេចងក្លិងគប់ស្រោចដុំរំញ៉ួលខ្លួន ទើបយោលទៅគប់ទិសដុំរំញ៉ួ គាស់តែចាក់យុំយកចុះអស់ ហើយឡើងតាមខ្សែព្រួជាជណ្តើរមកដល់មាត់ជ្រោះ ហើយចុះតាមជណ្តើរឈើតាំងបីថ្នាក់មកដួបដុំគ្នាឯថ្នាក់ក្រោមបង្អស់វិញ ហើយច្រមុលយុំរែកចុះមកដួរវិញ ។

អំពីយកយុំបោះពួយ

មួយយ៉ាងទៀត អ្នកយកយុំដែលហៅថាបោះពួយនោះ មានគ្រប់កន្លែងក្នុងខែត្រសៀមរាប ។ យុំដែលវាទំនឹងដើមឈើធំៗ តែច្រើនមានទឹងដើមយាង ដែលដុះក្នុងព្រៃឬដោយគោកខួលណាមួយជិតស្រុកភូមិ-ភូស្រែ គេហៅថា យុំស្រែ វាទំក្នុងដើមឈើមួយដើមៗ មានចំនួន ៥០ ឬ ៦០ ឡើងទៅក៏មាន ពីកាលសម័យជាន់ដើម គេហៅថា យុំ

សួយ ព្រោះមានតស្សរជនណាមួយក្នុងស្រុកនោះ គេដាក់ឲ្យត្រកូលណាមួយ ដែលស្មាត់ជំនាញក្នុងការហ៊ោះពួយយកឃុំនោះ ដាក់ជាសួយរៃជូនរាជការ ប៉ុន្តែចំពោះតែត្រង់ដើមឈើដែលដុះក្នុងព្រៃគោកខ្លួលណាច្រើនចំនួន ៥០ ដើមឡើងទៅ ទើបត្រូវជាសួយពន្ធ ។ បើមានតែមួយដើមប្តីរបីដើម ក្នុងត្រង់ធ្វើ ។ ប្តូរក្នុងត្រង់ជិតព្រៃស្រែចម្ការរបស់ជនណាដែលធ្លាប់កាន់កាប់ចែករក្សាមកជាកេរ្តិ៍មត៌ក ជននោះគេយកជាប្រយោជន៍របស់ខ្លួន ប្តូរក៏ជនណាដើរទៅឃើញក្នុងព្រៃ ទៅចឹតត្រង់ណាមួយក៏យកតាមចិត្តទៅ ។ ឯរបៀបហ៊ោះពួយនោះ គេយកឫស្សីដែលគល់ចាស់ខ្លឹមយ៉ាងសំខាន់មកបិតឲ្យស្រួចដូចកន្ទុយអន្ទង់ ឬដូចបុងលំពែងប្រវែងមួយតឹកកន្ទុះ គេពេលភ្លើងឲ្យល្អទើបយកទៅហ៊ោះ គេហ៊ោះពួយបាំងដំបូង ហើយឡើងឆាន់ពួយខាងត្រើម ដៃចាប់ពួយខាងលើ គេហ៊ោះចម្ងាយតិគ្នាចំនួនមួយហ៊ឹក ឈានដើងឡើងទៅលើជណ្តើរលុម ។ អន្ទង់គេចង់ក្លាប់ចុងខ្សែនឹងចង្កេះ ដៃលូកចាប់យកពួយដែលជាក់នឹងបង្គិចថ្នក់ត្រកាត់ក្លាប់នឹងចង្កេះ ហើយដៃឈោងហ៊ោះពួយក្លាប់នឹងសំបកឈើឈានដើងម្ខាងឡើងទៅជាន់ពួយខាងលើ ទើបយកអន្ទង់ពាយ គេពាយបីអន្ទង់មិនឲ្យលើសទេ នេះជាទំនៀមរបស់អ្នកហ៊ោះពួយ ហើយលែងអន្ទង់ពីដៃ ទៅចាប់យកពួយក្នុងថ្នក់ ឈានដើងម្ខាងឡើងទៅជាន់ពួយខាងលើទៀត . ដៃម្ខាងឈោងហ៊ោះពួយទៅលើឲ្យជាប់នឹងសំបកឈើដូច

មុខ ។ បើគេដាន់ពួយខាងគ្រែមដោយដើងធ្វេង ក៏ចាប់ពួយខាងលើដោយដៃធ្វេង បើដាន់ពួយខាងគ្រែមដោយដើងស្តាំ ក៏ចាប់ពួយខាងលើដោយដៃស្តាំដែរ ។ ដៃមួយចាប់ពួយដៃមួយក៏យ ចេះតែផ្ទាស់ប្តូរឯកាម ដៃណាដែលចាប់ពួយចោះនឹងឈើឲ្យជាប់ជាបណ្តោះអាសន្ន រួចហើយដៃនោះឯងចាប់អន្ទងក៏យសម្រេច ចោះជាមបានជិតដល់ប្រតាមមែកឈើ នៅខ្វះ ៣ ពួយទៀត គេឈប់ប៉ុណ្ណោះសិន ហើយចុះមកចាំដល់ពេលយកឃ្មុំ គេចោះបន្ថែយទៅ ។ ប្រដាប់នឹងយកឃ្មុំនោះ គេយកដើមល្អឯងប្តូរឈើណាដែលឆ្អែតភ្លឺនតបក់យបែកព្រាយច្រើន គេរកយកមកចងជារមូរច្រើនដុំ ដែលល្មមកយយកឃ្មុំបាន ហើយគេរកគ្នាចំនួនបី ឬ បួននាក់ទៅ ហើយរកខ្សែវែងដែលល្មមសំយុងគ្រស ដែលជាក់សំបុកឃ្មុំមកដល់ដី រៀបនឹងទៅយកនោះ ·គេហាមប្រពន្ធមិនឲ្យតាក់តែងខ្លួន មានសិត-កាត់សក់ លាបប្រេងក្រមួនជាដើម ។ ទៅដល់ហើយ គេបេះស្លឹកឈើ ៧ សន្ធឹក.ទៅចោះភ្ជាប់នឹងឫសឈើដែលគោងធំជាងឫសឯទៀត ធ្វើនេះ ជាឧបកិច្ច ប្រគាំរបស់គេអ្នកយកឃ្មុំ ឯអ្នកខ្លែងនោះបើឃើញសត្វអ្វី ប្រហែលដូចជាសត្វកណ្តុរ ឬឃើញហាក់ដូចអ្វីគួរសង្ស័យនោះ គេឲ្យទុបផ្ចឹបដើមខ្លែងទៅនឹងដើមឈើ. បើមិនប្រយ័ត្នដូច្នោះ គេថាមានព្រាយកំណាចក់មកស៊កបំផើដើមខ្លែងឲ្យធ្លាក់ស្លាប់ ឯអ្នកដែលទៅគាំងប៉ុន្មានអ្នកនោះ គេយកតែបង់ប្អូន ឬអាពុកនឹងកូនបង្កើត

ទើបខុកចិត្តច្បាន ព្រោះដួនកាលគេធ្វើឲ្យសណ្តាកតួយនោះឲ្យធ្លាក់មកអស់កំមាន់ ។ គេយកតែវេលាយប់ វេលាថ្ងៃគេមិនដែលយកឡើយ ។

អំពីយកឃ្មុំធម្មតា

ចំនេរឿមអ្នកយកឃ្មុំជាធម្មតានោះ តែងលាតិម្ហូរដូរ ហើយគេដើរទៅរកឈើដែលមានផ្កាដោយព្រៃ ឬកន្លែងដែលមានទឹក ។ បើឃើញមានមេឃ្មុំមកវាមយកផ្កាទៅធ្វើជាសំបុក ឬក្រែចឆឹកទឹក ទៅចិញ្ចឹមកូនវា គេចាំមើលបើវាហើរទៅមក ត្រង់ទិសណា គេតែងទៅឈរឬឡើងឈើត្រង់ផ្លូវដែលវាហើរទៅហើរមកដើម្បីដេញស្រាវរកសំបុកវា បើឃើញហើយតែឃ្មុំនោះ មិនទាន់កើតសំបុកពេញលេញនោះ គេចងសំគាំឈើនៅគល់ឈើដែលវាគោង ។ បើឈើនោះខ្ពស់ គេតាប់ស្មោះសំបកឈើនោះជាដុំរួចសំគាល់ថាជាឃ្មុំរបស់គេ មិនអាចអ្នកណាហ៊ានយកទេ ជួនកាលគេយកតប់ទៅយកពេលថ្ងៃ ។ ដែលគេយកពេលយប់នោះ ព្រោះឃ្មុំនោះកាចយកពេលថ្ងៃវាទិចយកពុំបាន ។ ខ្លះគេទៅរុករកកន្លែងព្រៃធំឆ្ងាយអំពីស្រុកឬព្រៃវនាមួយបួនមាត់ទន្លេសាប គេវែកអង្កាំឆ្នាំងចាយទៅចោះដាក់ស្នាក់ដំរកន្លែងព្រៃនោះ គ្នាច្រើនក៏មាន តិចក៏មាន គេឲ្យម្នាក់ទៅចាំកន្លែងត្រៀតពីនេះនាំគ្នាចេញទៅរកឃ្មុំ ។ មួយវិញទៀត ខែដែលមានទឹកគេរកដោយមាត់ទន្លេ ឬតាមព្រែកកៀនកោះនៃទន្លេ គេដើរកដោយខ្លួនហៅថា "ចេក រកឃ្មុំ" តែឯឃ្មុំនោះ តែងមានតែកន្លែងតិម្ហូរដូរ ត្រៀតី

នោះមិនសូវឃើញមាន ។ ក្នុងវស្សានៈរដូវ បើទឹកទន្លេឯណា នៅតែមួយ
យប់ឬពីរយប់ហើរទៅទៀត មិនដែលឃើញមានកើតជាសំបុកល្មមជា
ប្រយោជន៍ឡើយទេ ក៏ហើរទៅមក គ្រាន់តែគោងស្រមាកសម្រាប់ប៉ុណ្ណោះ
ព្រោះរដូវនោះគ្មានផ្លាឈើ បើកទន្លេឯណា ឈើមានផ្លាច្រើន ក៏កើតខ្លះ
តែមិនសូវឃើញមានគេរកឡើយ ។

អាចារ្យ អ៊ុំ - ឆ្វ

២ – បណ្ឌិតវគ្គ (ត)

១៥ – មិត្តខ្ពត់ខ្ពមធំបំផុតនៅវិជ្ជា
សត្រូវក្លាកាចបំផុត នោះឫទ្ធី
ការស្រឡាញ់ក្រៃបំផុតគាយន្ទិយ
ពលពលីខ្លាំងបំផុតនៅឯលកម្ម ។

១៦ – ក្រអូបអ្វីមិនស្មើក្រអូបសីល គ្រឿងមន្ទិលអ្វីមិនស្មើកង់កិលេស
មានអ្វីខ្ពាំងអស់មិនស្មើមានចំណេះ គានវិសេសអ្វីមិនស្មើគានធម្មា ។
រហ័សអ្វីមិនស្មើចិត្តដែលគិត ពិសកាចពិតអ្វីមិនស្មើពិសពាលា
ជួបអ្វីប្រសើរមិនស្មើជួបពុទ្ធា រសពិសាអ្វីមិនស្មើរសព្រះធម៌ ។

១៧ – កុំប្រាថ្នាសត្វបក្សាឲ្យរោទរហីរ
កុំប្រាថ្នាសត្វក្រពើឲ្យហែលទឹក
កុំប្រាថ្នាសត្វមានពិសឲ្យខាំចឹក
កុំប្រាថ្នាបណ្ឌិតថ្នឹកឲ្យស្ងាត់ឡាយ ។

១៨ – ជាតិក្អែកគោកកុំត្រាប់ក្អែកទឹក រុក្ខាព្រៃព្រឹក្សកុំត្រាប់សត្វ
ពួករាស្ត្រកុំត្រាប់ត្រកូលខត្តិយ៍ មហាក្សត្រកុំត្រាប់រាស្ត្រប្រជា ។

ផ្តែចចកកុំត្រាប់ពាជសីហ៍ សត្វបក្សីកុំត្រាប់ពាជហង្សា
អ្នកលង់ទៅកុំត្រាប់អ្នកប្រាជ្ញ ប៉ាះគ្នៀវក្អាកុំត្រាប់សត្វតែសេះ ។

១៩ – ពួជទាមិនដែលឡើងខ្ពែនំ ពួជសត្វពែកុំមិនដោស្រុក
ពួជបណ្ឌិតមិនខ្វល់កង្ខ្វក់ខ្លួនខ្មែក ពួជសត្វកុកមិនដែលចោះបង់ប៊ឹង ។

២០ – ព្រះធម៌ស្ថិតទៅមនោស្អាត ព្យាយាមសង្កាត់ទៅបណ្ឌិត
ការជួយធុរៈជាកំទៅមិត្ត ការរបៀតស្ថិតទៅកង់សង្វារ ។
ការខ្ជិលទៅអ្នកតតំសំណាង ការប្រឹតស្ថិតស្ទង់ទៅកញ្ញា
ការមិនខ្ជែងគាំងខ្ជែងទៅមរណា ជួយជាតិសាស្ត្រោះប្រុសវ័ត្ត ។

២១ – ថ្ងៃនេះឯងចួនថ្ងៃស្អែកគេ ចួនថ្ងៃនេះដេរថ្ងៃស្អែកជា
ថ្ងៃនេះបំណិតស្អែកឥលា ថ្ងៃនេះវង្គ្រានស្អែកវិនាស ។
ដូចេះគួរតែកុំប្រមាទ គួរខំសំអាតចិត្តនិកស
ចាកចោលចោះបង់អំពីភាស តុកាសអង្គកង់អំពើស្អ ។

២២ – ហ៊ឺងតីងគក់ដើងខ្វី អួតសំដីចង់ទៅកាន់ ស្រែស្រែង់
ហេមវ័ន្ត ជនខ្វិនខ្លាន់អួតចង់រត់ ។ មាសប្រាក់តែសូរ្យកាន្ត អាចអួតហាន
ទឹងពេជ្រតែន តមរជាតិកន្ធង់សត្វ អួតហើរកាត់កុំសុះមេរ៉ុ ។

២៣ – មិនត្រូវធ្វើចាំពែងកស្មា មិនត្រូវធ្វើការខ្ទុសលំអាន
មិនត្រូវខ្ជិលរៀនខ្ជូនាន ប្រាណ មិនត្រូវឲ្យគានគ្នានពិចារ ។

๒๔ – មានបុណ្យពុំស្មើមានសម្បត្តិ មានធនធានក្តាត់ពុំស្មើមានកុសល
មានបរិពារពោរពាសពុំស្មើបុត្តនិម្មល ជនច្រើនរង៌ាល់ពុំស្មើព្រះពុទ្ធមួយ ។

๒๕ – បក្សីត្មាតបង្ខោសនិគមស្រុក អ្នកឈឺរង៌ាំទុក្ខថាអាហារ
អ្នកក្រៃបង្ខោសត្រែង៌ាស្មា អ្នកខ្វិលតុះថាពេលម៉ិនល្អ ។

๒๖ – ស្ទឹកសុក្ខាច្រើនជាង៌ផ្កាផ្លែ ទឹកស្ទឹង៌ទន្លេច្រើនជាង៌ត្រី
ពាលច្រើនជាង៌ប្រាជ្ញកង៌លោកិយ អ្នករង៌ាំទុក្ខភ័យច្រើនជាង៌សុខា ។

๒๗ – ក្រៃបីប្រាត់ទើបធ្លើរបង៌ ដល់ពេលប្រឡង៌ទើបស្វាធ្យាយ
ដល់ពេលចេញដើរវៀបសំពាយ បីនេះអន្ធពាយអសារបង៌ ។

๒๘ – ឃ្មុំគន្ធង៌វៀរបង៌ឈើគ្មានផ្កា សត្វម៉ែគាវៀរបង៌ពែក្តើង៌នេះ
សត្វបក្សីវៀរឈើគ្មានផ្លែបេះ ចោរតែង៌រេះចាកតំបោរប៉ុព្វ ។
ស្រីជាតទង៌វៀរបង៌ប្តុរសខ្សត់ បណ្ឌិតប្រាកដវៀរបង៌ជនពាលេ
ស្រីក្សត្រិយ៍ស្នងវៀរជន្ធូសុក្កបក្ខ ភ័ព្វដេវៀរចាកដីខ្វិលខ្ពស់ ។

๒๙ – បក្សាសប្បាយនឹង៌នកាល័យ សត្វក្នង៌ព្រៃសប្បាយនឹង៌ព្រឹក្សា
សេដ្ឋីសប្បាយចិត្តនឹង៌ទ្រព្យា សប្បុរិសាសប្បាយនឹង៌វៀនធម៌

๓๐ – ជនណាតោលភាសាជាតិ យូរទៅជាប់ចិត្តភ្លេចពាក្យខ្លួន
ភ្លេចជាតិសាស្នានឹង៌ច្បាប់ក្បួន ដូចគ្រែតើសួនរង្វង៌ចឹង ។

(តៅមានត)

ស័ព្ទទាក់ទងច្រែងច្រើន

របស់

គណៈកម្មការវប្បធម៌

ហ្គងនិពន្ធមន្ត្រី ញ៉ាក-ថែម របូរម

(តមក)

Taxes de circulation = ពន្ធចរាចរ

Taxes de consommation = ពន្ធទុបភោគបរិភោគ

Surtaxe = ពន្ធបន្ថែម

Alcool de luxe = ស្រាឆើត, ស្រាប្រណិត

Boissons alcooliques = ទឹកស្រវឹង

Boissons hygiéniques = ទឹកអនាម័យ

Directeur = ចាង់ហ្វាង

(Le 20 1-48)

Inspecteur = អធិការ

Receveur-contrôleur = នាយផ្នែក

Chef de brigade = នាយត្រួត

Chef de poste = នាយកង់

Brigadier = អ្នកត្រួត

Sous-brigadier = អ្នកគ្រួតឆ្មៃ

Agent de surveillance = អ្នកឆែក

Gérant = អ្នកគាន់គាប់ការ

Police urbaine = ប៉ូលិសក្រុង, ក្រុមនគរបាល

Rappel = ហៅរំលឹក

Centième additionnelle = កាតបន្ថែម

Industrie = ពេង១សិប្បកម្ម

Atelier = ពេងជាង

Fabrique = ពេងកម្មការ

Usine = ពេងចក្រ

Ingénieur = វិស្វកម

Hôtel = សណ្ឋាគារ

Palace = មហាសណ្ឋាគារ

Restaurant = ភោជនីយដ្ឋាន

Auberge = ភោជនាគារ

Bungalow = " "

Ouvrier = កម្មករ

(Le Mardi 24 — 1 — 48)

Matériel = សម្ភារៈ

Ménagère = អ្នកផ្ទះ

Maîtresse de maison = មេផ្ទះ

Idée chimérique = គំនិតហួសហេតុ

Sorcier = មេធ្មប់

Sorcière = មេគាប

Fée = ទេពធីតា

Vieille fée = យាយទេព

Elfe = រលាហកទេវតា

Sens propre = អត្ថាន្តរូប

Sens figuré = អត្ថបដិរូប

Théorie = ទ្រឹស្តី

Chef d'œuvre = ស្នាដៃឯក

Sous toute réserve = មិនពាក់ព័ន្ធ

Tous droits réservés = ខ្ពុកសិទ្ធិ, រក្សាសិទ្ធិ

Atmosphère = បរិយាកាស

Milieu = មជ្ឈដ្ឋាន

Epice = គ្រឿងទេស

(Le Vendredi 27–1–48)

Homogène = សភាគ

Hétérogène = វិសភាគ

Greve = កូដកម្ម

Emeute = កុប្បកម្ម

Soulevement = ការជ្រួលច្រើម

Insurrection = ការចលាចល

Rebellion = ការបះបោរ

Guerre civile = ចំបាំងគ្នាឯង

Trouble = វរវែក, វិកវរ,

Agitation = ការរំដើបរំដួល

Avantage matériel = អត្ថប្រយោជន៍សម្ភារៈ

Intérêt = ផលប្រយោជន៍, (ការប្រាក់)

Bien du peuple = សារប្រយោជន៍នៃប្រជាជន

profit = គុណប្រយោជន៍

Utilité = ប្រយោជន៍

Service = ហិតប្រយោជន៍

Hasard = ឆៃជន្យ (Jeu de hasard) ល្បែងផ្សង

Présage = ប្រផ្នូល

Accident = គ្រោះ

Incident = ឧប្បត្តិហេតុ

Danger = ភ័យ

Homme dangereux = គេវង្គជន

(Le Vendredi 6 – 2 – 48)

Ecole des Officiers de santé = សាលាសិក្សាមន្ត្រីសុខាភិបាល

Assistance médicale = គិលានសង្គ្រោះ

Action sociale = សង្គមកិច្ច

Assistance sociale = ប្រជាសង្គ្រោះ

Prévoyance sociale = សន្និច័យសង្គម

Infirmier = គិលានុបដ្ឋាក

Infirmière = គិលានុបដ្ឋាយិកា

Assistante sociale = នាងប្រជាសង្គ្រោះ

Poète = កវី

Poésie = កាព្យ

Statique = ឋិតិវន្ត, ស្ថិតិវន្ត

Dynamisme = ថាមភាព

Stabilité = ឋិរភាព, ស្ថិរភាព

Stable = ឋិរវន្ត

Instable = អចិរវន្ត

Collaborateur-trice = សហការី-សហការិនី

Confrère = សហគាត៌

Consœur = សហគតិនី

Collègue = សហសេវិត, សហសេវិកា

Compagnon = សហជីវន

Compagne = សហជីវិនី

Camarad = គូកន

Ami = សម្លាញ់, មិត្ត

Homme de loi = អ្នកកាន់ច្បាប់

Juriste = នេតិបណ្ឌិត

Justice = យុត្តិធម៌

Magistrature = តុលាការ

Normale = ប្រកតិ, អនុរូប

Ordinaire = ធម្មតា

Timide = មនុស្សម្ងួរម្ងុ, (មង្ឃុត)

Timidité = អាការម្ងួរម្ងុ

Audace = វិសារទភាព

(Le 17-6-48)

Sympathi = សមាធចិត្ត

Amitié = មិត្តភាព, មិត្រភាព, មេត្រីភាព

Conscience = សម្បជញ្ញ, មនសិការ

Expérience = ការពិ សាធន៍

Date = កាលបរិច្ឆេទ (ការៈចុះថ្ងៃ-ខែ-ឆ្នាំ)

Circonférence = វ័ណ្ឌមណ្ឌល

Périmètre = បរិមាត្រ

Diamètre = វិឍ្ឍមាត្រ (គូសកាត់រង្វង់មូល)

Diagonale = វិឍ្ឍកោណា (គូសកាត់រង្វង់មុខ)

Conscience professionelle = មនសិការកង់វិជ្ជាជីវៈ (ការយកចិត្តទុកដាក់កង់វិជ្ជាជីវៈ)

Consciencieux = មានមនសិការ

Habile = ប្រសប់

Au courant = ច្បឹក

Cercle = មណ្ឌល

Circonscription = មណ្ឌល

Fait accompli = និដ្ឋិតកម្ម (អំពើដែលគេបានធ្វើរួចស្រេចទៅហើយ)

ប្រវត្តិសាស្ត្រនិងប្រទេសផ្សេងៗ

ហ្វូងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែ-រៀបរៀង

(តមក)

ជនចំពូកនេះ គឺពួកនៅប្រទេសទីបេត ដែលបានរួមកម្លាំងគ្នាតាំងអំណាចមានព្រះចៅផែនដីឡើង តាលមិនយូរប៉ុន្មានទេ ក៏មានកម្លាំងកងទ័ពរឹងមាំ ហើយមួយចំណែកទៀតគឺពួកនេប៉ាល ដែលមានព្រះចៅផែនដីហើយគាន់ព្រះពុទ្ធសាសនាផង ទ្រង់ព្រះនាមថា នរេន្ទ្រទេវៈ ក៏ចាំតែរកឧកាសចូលមកវាយឥណ្ឌាដែរ ទើបជាហេតុឲ្យព្រះចៅផែនដីចិនប្រែកម្លាំងកងទ័ពរបស់ពួកទីបេត ទន្ទឹងពួកនេប៉ាលលុកចូលមកក្នុងដងទន្លេគង្គា ហើយចាប់ខ្លួនអរជុនៈនាំយកទៅស្រុកចិនបាន ។ តាំងអំពីនោះមកស្រុក ការខាងដំ ក៏មិនមានពលរេលានទ័តាំងខ្លួនឲ្យរុងរឿងឡើងទៀតឡើយ មិនយូរប៉ុន្មានក៏បានទៅខាងពួកកស្មីរៈ ហើយតអំពីនោះមកក៏ធ្លាក់ទៅទៅទន្ទឹងពួកពុតៈ ហើយតមកគ្រាយទៀតក៏ធ្លាក់ទៅទៅទន្ទឹងពួកអីស្លាម ដូចមានន័យយ៉ាងនេះទៅទៀត ។

ចាប់តាំងអំពីពាជវង្សក្សត្រ ជានិស្ការ ឃ្លានអស់អំណាចទៅហើយ ពួកក្សត្រនោះដែនកស្មីរៈក៏បានព្យាយាម ទន្ទឹងគ្រប់គ្រងផែនដីផ្សេងៗ ក្នុងដងទន្លេគង្គា ព្រះមហាក្សត្រអស់នោះសុទ្ធតែជាអ្នកគាន់ព្រះពុទ្ធសាសនា ហើយមានស្ពានមេត្រីនឹងប្រទេសចិនដោយរៀបរយល្អ តមកវាងវាងពុទ្ធ-

សតវត្ស ๑๙๐๐ មហាអាណាចក្រចិនកំពើតចលាចលរវើរវាយឡើង ពួកទីបេត៌ធីពួកអាវបក៌នាំគ្នាលុកលុយបានដំយដំនះ ក្នុងដែនដីចំណែកនេះ ហើយគាត់ផ្តួលមនាគមរាងចិននឹងតំណាងជាច់ចេញពីគ្នា អំណាចរបស់កស្ទីរៈក៏ខ្សោះតែមចុះទៅជាលំដាប់ គាលផុតអស់អំណាចរបស់កស្ទីរៈ ហើយក៏មានពួកក្សត្រ ๑ ពួកទៀតចាប់ផ្តើមរុងរឿងឡើងមានព្រះនាមថាក្សត្រៀតជពុត ក្សត្រៀតជពុតមានខ្សែស្រឡាយចេញមកពីពួជវង្សក្សត្រយូអេជី ពួកនេះធ្លាប់តែកាន់សាសនាព្រាហ្មណ៌តាំងពីដើមមក ។ ពួកជពុត មិនរួមធ្មប្អូគ្នាជាជាតិទេ គ្រាន់តែតាំងជាគណៈអ្នកឫកំនែងដែលស្តុកស្តម្ភ, អត់ធន់, និងអង់អាច ហើយប្រកាន់ខ្ជួនជាពួកមានឈាមភាហានសុទ្ធលើគ្នាចេញទៅបូនស្រុកទេសផ្សេង ។ ហើយក៏បែងចែកគ្នាគ្រប់គ្រង មានប្រមុខតាំងខ្លួនឡើងជាម្ចាស់ផែនដី អាណាចក្រដែលពួកជពុតតាំងជវង្សឡើងនេះ មានជាច្រើនអាណាចក្រដែរ គឺវង្សតូម៉ារៈ តាំងទៅដិលហី វង្សព្រះ តាំងទៅកាទោជី, វង្សប្រមរៈ តាំងទៅខ្មែរ:, វង្សកន្ទេលៈ តាំងទៅកាលិន្ទជារ៌ ហើយវង្សគាលក្យៈ តាំងទៅឯមហាក្រុង ។

ក្នុងសម័យដែលពួកជពុតមានអំណាចឡើងនេះឯង ជាសម័យដែលប្រវត្តិសាស្ត្របស់តំណៀ ប៉ាន់ផ្លាស់ប្រែរូបទៅជាប៉ាតដែនដែរ ដោយការលុកលុយចូលមកនៃពួកអីស្លាម ។

ពួកអ័ស្លាម គឺពួកសាវតរបស់ ព្រះមហាហ៊ុត ចូលមកក្នុង
តំណែ្ជាគ្រាដំបូងនោះ ជាពួកខ្សែ ដែលចូលមកតាំងទីលំនៅ ។
ក្នុងតំបន់ខាងក្នុង អាហ្គានីស្ថាន មានពួកខ្លះចូលមកខាងបញ្ជាប ហើយ
ចូនយកស្រុកទេសផ្សេង ។ ជារៀង ៧៧ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១៥៤៣
ដល់ពុទ្ធសករាជ ១៥៧៣ ដោយមានប្រមុខរបស់ពួកនេះហៅថា សុល្តង់
មានន្តរថា មហាហ៊ុត កាសានេវីត បុគ្គលនេះទុកជាអនិច្ចកម្មទៅហើយក៏
ដោយ ក៏នៅតែមានពូជអំបូររបស់គេតាំងអាណាចក្រនៅបញ្ជាប មាននៅ
ស្រុក លៈហ៊ ជាដើម ។ ប្រសិនបើស្រុកផ្សេង ។ ក្នុងភាគណ្ណាល
របស់តំណែ្ជាមិនបានប្រឹងប្រែង តាំងតទល់ឲ្យរឹងប៉ឹងទេ ពង្សាវតាររបស់
តំណែ្ជាមុខជាធុតរលត់អស់គ្រឹមណៈដែង តែជាគ្រាះគ្រោះល្អរបស់
តំណែ្ជា ដោយហេតុអាណាចក្រតាំងឡាយដែលពួកពាជពុតនៅតែបន្តគ្នា
គឺការនោជី, ដិលហ៊ី, កាលិខូណាវ, ខិនឆេនៈ បានតាំគ្នាខំប្រឹងប្រែង
តទល់នឹងពួក អ័ស្លាម យ៉ាងម៉ឺងម៉ាត់ ។

ជាន់ដំបូង ស្រុក កាន្ទោជី ក៏ត្រូវមហាហ៊ុតកាសានេវីត លើកមកពាយ
ហើយស្រុកនេះក៏ជាស្រុកចំណុះពួកអ័ស្លាមទៅ កាលពីពុទ្ធសករាជ
១៥៦១ តែតមកគ្រាយក៏រួចរបូតពីអំណាចអ័ស្លាម ត្រឡប់មកតាំង
ខ្លួនជាឥស្សរៈឡើងវិញទៀតបាន ដោយកម្លាំង ពាជពុត រង្សីពាធ៍បាន
ជួយទំនុកបំរុង ។ ចំណែកខាងដើលក៏មានក្បត្រ ពាជពុត ១ អង្គព្រះនាម

អនង្គបាល ជាអ្នកវង្សក្សត្រឈ្មោះថា វង្សមាតុរៈ បានប្រឹងខំនុកបំរុងពួកគាណាចក្រឲ្យបានចំរើនរឿងបានជាច្រើន ។ ក្នុងពុទ្ធសករាជ ១៥៨៥ ជាឆ្នាំដែលដេលីចាប់ផ្តើមមានអំណាចនឹងចំរើនខ្លាំងជាច្រើន លុះតមកដល់ពុទ្ធសករាជ ១៦៨៤ ក៏ផុតពួកវង្ស តូមារៈទើបមានការតាំងពួកវង្សថ្មីទៀតហៅថា វង្សគោហ៍ន ជាពួកពួតដែរ បានឡើងសោយរាជសម្បត្តិមក ឯព្រះមហាក្សត្រអង្គទី ៦ ក្នុងពួកវង្សនេះទ្រង់ព្រះនាមប្រិចវី បានគ្រប់គ្រងរាជ្យដែលដល់ជារេលា ១៩ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១៧១៨ ដល់ពុទ្ធសករាជ ១៧៣៦ ទើបកើតសង្គ្រាមឡើងនឹងស្រុកកាឡាដ ក្នុងពួកពួតធង់គា ជាសង្គ្រាមធំគ្រាមួយ ហើយជាហេតុបើកឱកាសឲ្យពួក អ័ស្លាម ចូលមកលុកលុយទៀត ឯពួក អ័ស្លាម ដែលចូលមកលុកលុយគ្រាយនេះ ជាពួកអាហ្វកានហៅឈ្មោះគោរីត្រ ចូលមកគ្រប់គ្រងរាជ្យបញ្ចាបនំទួសពួក ខ្លួនគឺ កាសនេរីត ដែលយើងបានពោលរួចហើយ ។ ពួកគ្រាយនេះ មានប្រមុខហៅថា មហាហ្មត់គោរ៍ កាលមហាហ្មត់គោរ៍ តាំងនិក្ខន្តទៅស្រុកលៈហ៍រ បានហើយក៏ចូលទៅលុកលុយដែនដីរំនាបតាមជង្ហរនទីគង្គាមួយរំពេច ។

ពួកគាហានពួត មានព្រះបាទប្រិចវីជាប្រមុខបានចេញច្បាំងទប់ទល់នឹងពួកគាហាន អ័ស្លាម យ៉ាងអង់អាច តែត្រូវបរាជ័យក្នុងពុទ្ធសករាជ ១៧៣៦ ។ កាលព្រះបាទប្រិចវីបរាជ័យហើយ ព្រះបាទចន្ទ្រ:

ម្ចាស់ផែនដីស្រុក កាឌោដី ដែលជាសត្រូវចាស់របស់ព្រះបាទប្រឹថវី ក៏ខ្ចែងខំប្រឹងតស៊ូទប់ទល់នឹងពួកអ៊ីស្លាម តែនៅទីបំផុតក៏ទប់ទល់មិនបាន ទើបពួកអ៊ីស្លាមបានធ្វើជាចៅហ្វាយនាយ លើទីកំនាប់ជាដរាបតទៅគ្មានគាំងអស់ ។

ក្នុងគ្រានេះឯង ដែលប្រតិសាស្ត្រតណ្ហៀបែបប្រួលមើលឃើញយ៉ាងច្បាស់លាស់ សុល្តង់ របស់គោរិត្យ ក៏បានរួមអាណាខែត្រ ដេលី, កាឌោដី, នឹងពាពណាសី រួមចូលគ្នាជាអាណាចក្រតែមួយមកនៅក្រោមអំណាចរបស់ខ្លួន កាលពីពុទ្ធសករាជ ១៧៣៣ ហើយបណ្តាស្រុកទាំងឡាយ ដែលធ្លាប់មានព្រះពុទ្ធសាសនាចំរើនរុងរឿងមកអំពីដើមនោះ ក៏ធ្លាក់ទៅនៅក្នុងកណ្តាប់ដៃរបស់ អ៊ីស្លាម តាំងអំពីនោះមក ទើបក្សត្រពួកពាធពុតរង្ករាជ ឬានទាំងគ្នាគេចរត់ពីអំណាចរបស់ អ៊ីស្លាម ទៅតាំងរាជអាណាចក្រថ្មីឡើងទៀតហៅថា រាធពុតនេះ ។

មួយផ្សេងទៀត មានក្សត្រ រាធពុត ១ ពួកទៀត ជារាជវង្ស តន្ទេលៈ ឬានតាំងអាណាចក្រ ១ កន្លែងដែរ តាំងអំពីសតវត្សទី ១៥ នៃពុទ្ធសករាជ ឲ្យឈ្មោះថា កាលិន្ទជាវ អាណាចក្រ កាលិន្ទជាវ នេះធ្លាប់ត្រូវពួកអ៊ីស្លាម ពួកមុនលុកលុយមកហើយដែរ តែនៅតាំងខ្លួនបានរហូតដល់ព្រះពុទ្ធសករាជ ១៧៤៦ ហើយធ្លាក់ទៅនៅក្រោមអំណាច អ៊ីស្លាម ពួកមកក្រោយគឺពួកគោរិត្យនេះឯង ។

ចំណែកឯតណ្ហៀតាគតកណ្តាលខាងដែនម៉ាលវៈ កន្លងវេងដែលកើតវេរីកនេះ នៅមានក្សត្រភាជពុត រង្សប្រមាៈនៅគ្រប់គ្រងទៅទៀត ។ ពួកនេះមានកេរ្តិ៍ឈ្មោះល្បីល្បាញ ខាងការទំនុកបំរុងអក្សរសាស្ត្របស់តណ្ហៀ ហើយមានក្សត្រ ១ អង្គព្រះនាមថាពោជៈ ទ្រង់ជាចិន្តកវីដោយព្រះអង្គឯងផង ។ កាលអស់បុណ្យព្រះទៅដែនដីអង្គនេះហើយ អាណាចក្រម៉ាលវៈ ដែលមានស្រុកខ្នែងជាទីក្រុងនោះក៏សាបសូន្យបុះទៅហើយនៅទីបំផុតក៏ធ្លាក់ទៅនៅក្នុងវិវេរបស់ពួកអីស្លាម កាលពីពុទ្ធសករាជ ១៧៦៣ ។

ក្នុងតណ្ហៀភាគខាងលិចនេះ មានអាណាចក្រ ១ ដែលនៅគង់ទ្រង់គឺអាណាចក្រចេង្គីល ដែលមិនបានខ្វះខ្លួលគ្រោះថ្នាក់ដូចជាអាណាចក្រឯទៀត ។ ហើយអាចរក្សាសេចក្តីសុចរិតយៅបានជាវែលាយូរ ដោយមិនត្រូវពួតអីស្លាមលុកលុយញាំញី ហើយនៅតែកាន់ព្រះពុទ្ធសាសនារហូតមកដល់ពុទ្ធសករាជ ១៧៤៩ ហើយទុកជាអាណាចក្រឯទៀត ។ តណ្ហៀបានក្លាយទៅជាហិណ្ឌូយូរហើយក៏ដោយ ។ នៅក្នុងវេង ២៥៦ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១៣៥៨ ដល់ព្រះពុទ្ធសករាជ ១៦០៣ អាណាចក្រចេង្គីលបានគ្រប់គ្រងដោយរង្សក្សត្រព្រះនាមថាឆាល: សឺង មានក្សត្រគ្រប់ ។ អង្គ សុទ្ធតែកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ហើយតែងមានស្តាន់មេត្រីនឹងក្រុងចិនដោយល្អរហូតមក ។ ពាជវង្ស ឆាល:

ប្លាន់ផុតអស់ តាលពុទ្ធសករាជ ១៦៤៣ ហើយវង្សក្សត្រដែលទទួលគ្រងរាជសម្បត្តិតមកហៅថាវង្សសេនៈ ក៏ប្លាន់គ្រប់គ្រងខែត្តដែនបង្កើលរហូតដល់ពុទ្ធសករាជ ១៧៦៦ ទើបស្រុកបង្កើលត្រូវសត្រូវចូលលុកលុយជួយយ៉ាងអាណាចក្រឯទៀត ។ របស់តំណៀនោតំបន់អស់នោះដែរ ហើយនៅទីបំផុត ស្រុកបង្កើលដែលជាអាណាចក្រកាន់ពុទ្ធសាសនាចុងក្រោយបង្អស់ ក៏ធ្លាក់ទៅនៅក្រោមអំណាចពួកអីស្លាមទៀត នៅក្នុងឆ្នាំពុទ្ធសករាជ ១៧៨៥ នេះឯង ជាឆ្នាំដែលព្រះពុទ្ធសាសនាប្លាន់សាបសូន្យអស់ទៅពីប្រទេសតំណៀ ។

ការណ៍ដែលព្រះពុទ្ធសាសនាសាបសូន្យប្លាត់ពីប្រទេសតំណៀនោះជារឿងមុខគួរឲ្យអាណាចអាធម្មច្រើន ហើយជាហេតុដ៏សំខាន់មួយរបស់លោកដែលយល់រឿងនេះប្លាន់ងាយលំប្លាកចន្លិច ។ ប្រសិនបើព្រះពុទ្ធសាសនាប្លាន់សាបសូន្យទៅដោយសារស្មារដៃពួកសាសនាអីស្លាម ក៏ល្មមយល់ប្លាន់ងាយដែរ ព្រោះកន្លងសម័យនោះ ពួកអីស្លាមកំពុងលុកលុយប្លាន់ជ័យជំនះដែនផ្សេង ។ របស់តំណៀដូចប្លាន់រាល់រួចមកហើយ តែព្រះពុទ្ធសាសនាមិនរមែនរលត់ប្លាត់ពន្លឺរស្មី ទៅដោយអំណាចសាសនាអីស្លាមទេ្លយ ការណ៍ពិតនោះព្រះពុទ្ធសាសនាចាប់សាបសូន្យតាំងអំពីមុនពួកអីស្លាមចូលមក ហើយសាបសូន្យព្រោះសាសនាព្រាហ្មណ៍ដែលជាសាសនាប្រចាំដែនដីតំណៀ តាំងអំពីសម័យបូរាណមុនព្រះពុទ្ធសាសនានោះឯង ។

រឿងសាមកុក

ឧបាសកទិកញ្ញា ខូវ - កន រៀបរៀង

(ត្រមក)

ចូរឆ្លូវទូលតែងស្រាមកហើយតាំងសម្បាថា ខ្ញុំសុំសម្លាប់តាំងតុឲ្យបានអង្គុន បានឮដូច្នោះក៏ត្រេកអរណាស់ ទើបចូលទៅហូតយកគ្រឿងក្តឹមកឲ្យចូរឆ្លូវ ។ ក៏លាអង្គុនទើនាហ្នឹងតាំងតុចេញទៅ ។

លុះដល់វេលាព្រឹកឡើង ចូរឆ្លូវ ក៏យកគ្រឿងនោះស្រៀតបង្កប់កងអាវហើយដើរទៅដល់ឆ្នេរ តាំងតុ បានសួរនាយគ្វាវថាមហាឧបាជទៅត្រង់ណា? នាយគ្វារប្រាប់ថា ទៅកន្លងកំពុងមើលសំបុត្រ ចូរឆ្លូវ ក៏ឡើងទៅឃើញតាំងតុកំពុងមើលសំបុត្រ, ឯ លីហ៊ោ ទៅបម្រើចេញចូលជិតតាំងតុ តាំងតុ ក្រេឡេកមកឃើញ ចូរឆ្លូវ ក៏សួរថា ហេតុម្តេច ក៏មកដល់ថ្ងៃម្ល៉េះ? ចូរឆ្លូវ ឆ្លើយថា សេះដែលខ្ញុំធ្លាប់ជិះនោះវាឈឺដើងនឹងរកសេះដំនួសមិនបានៗជាមកដល់ថ្ងៃ តាំងតុ បានស្តាប់ក៏បង្គាប់ លីហ៊ោថា សេះដែលគេយកមកឲ្យពីស្រុកស៊ីង្គ ១ ចូរទៅយកមកឲ្យចូរឆ្លូវ លីហ៊ោទៅហើយ តាំងតុ ក៏ឆ្អែកចុះប្រែមុខទៅមើលសំបុត្រខាងជញ្ជាំង ចូរឆ្លូវ ឃើញដូច្នោះក៏អរណាស់ ឧកញ៉ាលីហ៊ោក៏ចេញទៅហើយ ទើនេះឃើញទឹងសមដូចប្រាថ្នាដែលអញគិតជាប្រាកដ ក៏ហូតដកគ្រឿងក្តឹមចេញមកហើយដើរឆ្ពោះទៅទឹងសម្លាប់ តាំងតុ ។ ក្រេឡេកឃើញស្រមោលក្នុង-

កញ្ចក់ដែលព្យួរជាប់នឹងជញ្ជាំង ក៏ស្ទាំងស្ទុតចិត្តបែរមុខមកសួរបូតូថា ឯងជកគ្រប៊ីកាន់ចូលមកនឹងសម្ងាប់អញឬ? ខ្ញុំលលីបោ"ក៏ចូលមកដល់ ។

បូតូភ័យណាស់ព្រោះមិនសមតាមច្បាប់ ក៏លុតជង្គង់ចុះហុចគ្រប៊ីខាងដងទៅឲ្យតាំងតុ ហើយតែខ្លួនថា ខ្ញុំបាទនឹងបង់ប្រមាទលោកដោយគំនិតអាក្រក់ក៏ទេ សព្វថ្ងៃលោកមានគុណូបការដល់ខ្លួនខ្ញុំបាទច្រើនណាស់ ខ្ញុំបាទនឹងរកវត្ថុអ្វីនឹងតបស្នងសងគុណលោកក៏គ្មាន មានតែគ្រប៊ីក្លីនេះមានជម្ងៃច្រើន ជាកេរ្តិ៍ពីជីតាឪានត ។ ត្រាមកដល់ខ្លួនខ្ញុំបាទ ។ ក៏យកមកតបស្នងគុណលោក តាំងតុក៏ដឿមិនមានសេចក្តីសង្ស័យហើយទើបទទួលយកគ្រប៊ីនោះមកមើលក៏ឃើញថាល្អមែន ទើបប្រើលីបោ"ឲ្យយកទៅរក្សាទុក ហើយតាំងតុក៏នាំបូតូចេញទៅមើលសេះហើយថា សេះនេះអ្នកយកទៅជិះចុះ បូតូឪានឮដូច្នោះក៏គិតថាអញប៉ងមកសម្ងាប់តាំងតុក៏មិនសមប្រកបតាមច្បាប់ បើនឹងទៅកងស្រុកក្រុងតទៅ ខ្លាចក្រែងតាំងតុនឹងដឹងនឹងសម្ងាប់អញវិញ បើដូច្នោះគួរអញកុំទៅកងទីនេះ គួរតែជិះសេះរែរចេញទៅរកបំតានឹងឪានគិតការតទៅលុះគិតហើយក៏និយាយជំរាបតាំងតុថា ដែលលោកឲ្យសេះជំនិះមកខ្ញុំបាទគ្រានេះ ព្រះគុណធ្ងន់មិនមានទីបំផុត តែខ្ញុំសូមឡើងជិះល្បងមើលថ្នើរជើងនឹងកម្លាំងវាសិន តាំងតុឆ្លើយថា គ្រឿងក៏ចងអស់ហើយនឹងជិះល្បងមើលក៏ជិះចុះ ។ បូតូមានសេចក្តីត្រេកអរណាស់ ក៏ឡើង

ផែលសេះហើយបំផាយចេញទៅ លុះដល់ទ្វារក្រុងខាងទិសឯកើត ក៏ស្រែកប្រាប់នាយទ្វារថា មហាឧបាសកប្រើយើងចេញទៅជាការប្រញាប់ណាស់ ចូរឆ្ងូ កំបំផាយសេះចេញទៅក្រៅទីក្រុង ។

ក្រោយនោះ លីចុ៉ ដំរាប តាំងតុ ចា ដែលចូរឆ្ងូយកគ្រប៉ាមកនោះ បំណងនឹងប្រទុស្សព្រាយលោកជាប្រាកដណាស់ តែចាប់ណ្យាលោកមិនត្រូវឲ្យគេដឹងប្លាន ចូរឆ្ងូ ក៏កែទ្ងូនធ្វើជាឆ្ងូនគ្រប៉ានោះទៅវិញ តាំងតុ តបចាអ្នកនិយាយដូច្នេះ យើងនៅឆ្ងល់ណាស់ ទ្ងូល លីយ៉ូ ចូលទៅទ្រឹត តាំងតុ ក៏ពណ៌នាឲ្យស្តាប់ លីយ៉ូ ចាខ្ញុំបាទ ក៏នៅឆ្ងល់ដែរ បើដូច្នោះសូមលោកចាត់បំរើទៅមើល ចូរឆ្ងូ សំនួ ជានៅក្នុងទីកន្លែងដែលធ្លាប់នៅប្ដូទៅឯណាទៅហើយ បើឃើញទ្ងូននោះគឺជាត្រឹមពិត បើមិនឃើញទ្ងូនទេ គឺជាវៀចដូច លីចុ៉ ចាជាប្រាកដទើបគេចរត់ទៅ តាំងតុ យល់ឃើញដង ទើបចាត់បំរើទៅមើល ចូរឆ្ងូ ឯទីគ្រីហាប៉ាន បំរើក៏ប៉ានវិលមកដំរាប តាំងតុ ចា រកទ្ងូន ចូរឆ្ងូ មិនឃើញទេ ឮចាបំផាយសេះចេញទៅទ្វារទិសឯកើត ប្រាប់នាយទ្វារថា មហាឧបាសកប្រើឲ្យទៅជាការប្រញាប់ លីយ៉ូ ក៏ចាមែនហើយ គឺ ចូរឆ្ងូ គិតប្រទុស្សព្រាយលោកជាប្រាកដ តាលមិនសមដូចប្រាថ្នាប្លានជារត់ទៅដូច្នេះ តាំងតុ យល់ដូច្នោះក៏ខឹងណាស់ថា ចូរឆ្ងូ នោះយើងចិញ្ចឹមក្បាជាមនុស្សទំនុកទុកចិត្ត គួរឬមកធ្វើមិត្តទ្រុស្តនឹងយើងវិញ ក៏នេះចំជាមនុស្សអកតញ្ញូ ។ លីយ៉ូ ឆ្លើយថា ដែល

ចូរឆ្លូតគិតប្រយុទ្ធប្រយែងដល់លោកវេលានេះ មិនមែនគិតម្នាក់ឯងទេប្រហែលមានបក្ខពួកគប់គិតជាមួយគ្នាជាច្រើន ទើបអាចហានធ្វើការធំដល់ម្ល៉េះ បើដូច្នេះយើងត្រូវចាំចិត្តគិតចាប់ចូរឆ្លូឲ្យបាន ហើយនឹងស៊ើបយកពួកមាក់ដែលរួមគំនិតជាមួយគ្នានោះ សម្លាប់ចោញទើបនឹងអស់ចំរូងចំរៃ ។ តាំងតុ យល់ព្រមក៏បង្គាប់ឲ្យគូរូប ចូរឆ្លូ ហើយសរសេរសំបុត្រចាត់ទៅគប់ខែត្រខំណាថា នរណាឃើញរូបដូច្នេះឲ្យចាប់ខ្លួនបញ្ជូនទៅស្រុកត្រង់យើងនឹងឲ្យបំណាច់រង្វាន់ឡើងវិជានាហ្ន៎ធំ បើនរណាចូលសមគំនិតគិតលាក់ចាំងខ្លួនចូរឆ្លូទុក នឹងឲ្យធ្វើទោសប្រហារជីវិតព្រមទាំងបុត្រកំរិយាបង់ ។

ឯចូរឆ្លូបរសេរទៅដល់ស្រុកចុងភ្នំ ពួកគយល្បាតឃើញរូបចូរឆ្លូប្រហែលរូបគំនូរក្នុងសំបុត្រ ក៏ប្រគល់ខ្លួនបញ្ជូនទៅឲ្យតាន់កុងរហៀកហ្ន៎ ស្រុកចុងភ្នំ ។ សួរថា អ្នកឯងឈ្មោះចូរឆ្លូឬ? ចូរឆ្លូឆ្លើយថា ខ្ញុំឯងឈ្មោះហង៎អ៊ូជាដង្កើលក់ដូរទេ ។ តាន់កុងពិនិត្យរម៉ល់ក៏ចាំថាខ្លួនឯងក់លាក់ហើយថា អ្នកឯងឈ្មោះចូរឆ្លូហេតុម្តេចក៏ថាឈ្មោះហង៎អ៊ូវិញ អ្នកឯងនិយាយមិនពិតត្រង់ទេ ពេលនេះយប់ហើយយកទៅជាក់គុកទុកសិនចុះព្រឹកស្អែកនឹងបញ្ជូនខ្លួនចូលទៅស្រុកត្រង់ លុះវេលាពាក់កណ្តាលអធ្រាត្រ តាន់កុងក៏ឲ្យទៅយកខ្លួនចូរឆ្លូមកឆួបក្នុងទីស្ងាត់ហើយសួរថា យើងបានឮកិត្តិសព្ទថា មហាឧបរាជមានចិត្តស្រឡាញ់ពាប់អានអ្នកឯង

ច្រើន អ្នកឯងមានធ្វើការអ៊ីចឹមហាឥបរាជ្ញាសមិត្តទើបកើតហេតុដូច្នេះ ។
ចូរឆ្លុតបបា ខ្ញុំលោកឥបបាដូចសត្វបក្សីតូចមួយ ត្រូវការអ៊ីនឹមកកន្ទុង
ដើងគំនិតស្តួចគ្រួ ដែលមានសេចក្តីសំបុត្រតាំងតុបង្គាប់មកឲ្យធ្វើយ៉ាង
ម្តេច លោកត្រូវតែធ្វើតាមបង្គាប់ទៅចុះ តទ្បាវលោកចាប់ខ្ញុំនយើងប៉ាន
ហើយត្រូវតែបញ្ជូនខ្ញុំនយើងចូលទៅស្រុកគ្រួងយកសេចក្តីតាប់ចុះ កុំមក
ល្បួងបញ្ឆោតសួរគំនិតរបស់យើងឡើយ តាខ្មុងប៉ានស្តាប់ដូច្នោះហើយ
ក៏យល់អធ្យាស្រ័យ ទើបបណ្តេញមនុស្សឯទៀតឲ្យចេញអំពីនោះអស់
ហើយនិយាយនឹងចូរចូរបា អ្នកឯងកុំអាលម៉ើលងាយថា យើងមានគំនិត
ពក់ខាក់ សព្វថ្ងៃដែលយើងមកធ្វើជាចៅក្រុងស្រុកបត្តាយ៉ាងនេះ ព្រោះ
ខាលគំនិតគិតធ្វើអ្វីមិនកើត ដែលនឹងឲ្យគេញ៉ាំងក្តីនឹងតំណែងនេះក៏ទេ
យើងទៅគិតរកមនុស្សក្លាហានខ្លាំងតូចតែមានប្រាជ្ញាស្មោះត្រង់ឆ្លាតបង្កែក
សិន ហើយនឹងប៉ានគិតការនេះតទៅទៀត, ចូរចូរប៉ានឮដូច្នោះក៏តបថា
ពីដើមដីតានឹងបិតាយើងជាខាហ្មឺនប៉ានស៊ីបៀវត្សរ៍ការ ដល់ស្រុកខេស
ចលាចលដោយសារខ្លួនឯង ១០ នាក់សោណា យើងក៏ប៉ានចូលធ្វើ
ពលការក្នុងវេលានោះ ពេលនេះបណ្តាលមកអំពីតាំងតុតាំងខ្ញុំនជាខាហ្មឺន
ធំសម្រាប់អម្ចាស់ផែនដីមានសេចក្តីក៏រើបខ្លើងជាខ្លាំងណាស់ បើយើង
នឹងស្ងៀមនៅមិនគិតកុំបះបំបោកកើហាក់ដូចជាមិនមានកតញ្ញូនឹងផែនដី
ឯដែលយើងទៅនៅធ្វើខ្ញុំនឹងតាំងតុជាមនុស្សអែប្រិយ យើងមានបំណង

ទឹងបង្ហាញវាចេញប៉ុណ្ណោះ សុះយើងធ្វើការនោះមិនសម្រេចតាមប្រាថ្នា
ក៏ត្រឡប់សនារបស់យើង ទឹងវិញ្ញាណរបស់អាណាប្រជានុរាស្ត្រក្នុងផែនដី ។
ទើបតាន់កុងសួរថា ដែលអ្នករត់ចេញពីតាំងតុមកនេះទឹងប្រាថ្នាទៅគិត
ការអ្វី? ចូឆូឆ្លើយថា យើងទឹងរត់ទៅរកបិតាយើង ហើយទឹងលះតែង
ជាសំបុត្រព្រះតម្រាស់ព្រះចៅហៀនតេ ហើយទឹងបញ្ជូនទៅដល់គ្រប
ខែត្រទាំងពួងឲ្យលើកទាហានមកប្រសព្វគ្នា ហើយចូលទៅពំនូចាប់
តាំងតុ ដែលជាសត្រូវដល់ពួកជសម្បត្តិនោះសម្លាប់ចេញ ។ តាន់កុង
ឮនាងដូច្នោះ ក៏ចូលទៅដោះខ្នោះច្រវាក់នាំចូឆូចេញមក ទើបអញ្ជើញ
ឲ្យអង្គុយលើកៅអីហ៊ុយនិយាយថា ដែលអ្នកមានគំនិតគិតដូច្នេះនេះ ខ្ញុំក៏
មានសេចក្តីពេញចិត្តណាស់ ព្រោះថាពួកស្ត្រទាំងពួងទឹងឮនសេចក្តីសុខ
ក៏ដោយសារគំនិតប្រាជ្ញារបស់អ្នក ។ ចូឆូសួរថា លោកឈ្មោះអ្វី? ឮន
ជាមានសេចក្តីត្រេកត្រអាលទឹងយើង ។ តាន់កុងឆ្លើយថា ខ្ញុំឈ្មោះ
តាន់កុងជាសែតាន យើងយើញថាអ្នកមានសេចក្តីស័ត្យសុចរិតត្រង់ទឹង
ផែនដី ទើបមានសេចក្តីត្រេកអរដូច្នេះ ឯនាទីរបស់យើងគ្មានតែជា
ចៅហ្វាយស្រុកចតូ ប៉ុណ្ណោះ យើងលះចោលមួយរំពេចមិនមានស្តាយ
ស្រណោះទេ យើងសូមទៅធ្វើការជួយទំនុកបំរុងផែនដីជាមួយនឹងអ្នក
ឋាហើយ តាន់កុង ក៏ចូលទៅរៀបចំយកទ្រព្យរបស់ដែលមានជម្លៀនឹងត្រប
ឲ្យចូឆូកាន់ ១ ខនឯងកាន់ ១ ហើយក៏ឡើងជិះសេះមួយម្នាក់នាំគ្នាចេញ
ចាកអំពីត្រីហ៊ាហានក្នុងវេលាយប់នោះ ។

លុះតាន់កុងនឹងចូនទ្រេញដំណើរទៅបាន ៣ ថ្ងៃដល់ភូមិ ១ ចូនចូ
និយាយប្រាប់តាន់កុងថា ពេលនេះក៏ចួនជាល្ងាចណាស់ហើយ ភូមិនេះ
គឺជាផ្ទះក្មេីបតាឡុំឈ្មោះបែ៉ះគ្នៀ យេីងនាំគ្នាទៅសំណាក់មួយយប់សិន
ទឹងបានស្រួរឿងក៏រៀងតួងឆង · ថាហើយចូនចូក៏នាំគ្នាទ្រកុងបត់សេះចូល
ទៅផ្ទះបែ៉ះគ្នៀ ។ យេីញចូនចូក៏ប៉ុនមកទ្រលឲ្យទ្បេីងទៅលេីងរហើយប្រាប់ថា
តទ្បាវមានសំបុត្រតែនរ ម្ចាសបង្កាប់មកពីស្រុកក្រុងថា ឲ្យបាប់ខ្ញុនកុយឯង
បញ្ជូនចូលទៅក្រុង ឯ.ចូនតោ ជាបិតាកុយក៏យភ្លាចដោរខ្ញុនទៅនៅស្រុក
តាន់លីវហើយ ។ ចូនចូក៏សាសំពួកប្រាប់អាច់សេចក្តីសព្វគ្រប់ឲ្យបែ៉ះគ្នៀ
ស្តាប់ ហើយប្រាប់ថា នេះឈ្មោះតាន់កុង ចេវហ្វាយស្រុកចុងភ្លួន លះ
បង់ទីពជការតេមកគិតការជាមួយនឹងខ្ញុំ ឃានជាខ្ញុំរស់ប្រចងរិតមកនេះ ។
បែ៉ះគ្នៀ ឃានស្តាប់ក៏និយាយនឹង តាន់កុង ថា ខ្ញុំមានអំណរគុណនឹងលោក
ដែលមានគតញ្ញូនឹងផែនដីខ្មោះណាស់ បេីកុំឃានតែលោកជួយដោះទុក្ខ
មុខជាចូនចូស្លាប់មិនខាន បេីដូច្នះលោកនាំគ្នាសម្លាន់ខ្មៅផ្ទះខ្ញុំមួយយប់
សិនចុះ ស្អែកសិមអះញ្ជេីញទៅ ហើយបែ៉ះគ្នៀក៏ចូលទៅក្នុងផ្ទះបង្កាប់
បុត្រកនិយាថា ឲ្យធ្វេីជ្រកនឹងមានរៀបចំាយទឹកជាបញ្ចាប់ ប្រាប់ហើយ
ក៏ចេញមកខាងក្រៅប្រាប់ចូនចូថា ស្រាដែលមានក្នុងផ្ទះមិនសូវល្អ មារ
សុំទៅតេញិស្រាថ្មីល្អមកជូនកុយពិសា ថាហើយក៏ចុះដេីរទៅ ។

ឋដានគាថា

របស់ព្រះទេវមុនី- យ្យូរ ប៉ណ្ណា

នៅវត្តឧណ្ណាលោម

ជាក្រុមជំនុំព្រះវិនៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ នឹងសំដែងអំពីបឋានកថា ដើម្បីជាពន្លឺដល់ពុទ្ធសាសនិកជនទាំងឡាយក្នុងពុទ្ធសាសនមណ្ឌលដូចតទៅនេះ ។

បឋានៈ ប្រែថាសេចក្តីព្យាយាម គឺព្យាយាមញុំាងសាធារណៈប្រយោជន៍ទាំងបច្ចុប្បន្ន ទាំងបរលោក ឬញុំាងប្រយោជន៍ផ្ទាល់ខ្លួនមួយ ។ ឲ្យកើតឲ្យមានឡើង ហៅថាបឋានៈ ។

ឯពាក្យដែលជាវេវចនៈនឹងបឋានៈនោះ មានច្រើនប្រភេទណាស់ដូចតាក្យថា វិរិយៈ ប្រែថាសេចក្តីអង់អាច មានតេជានុភាព អាចហានពុះពារបំពេញប្រយោជន៍ឲ្យសម្រេចដល់ទីបំផុត ។ បរក្កមៈ ប្រែថាមានដំណើរទៅមុខមិនរួញរា បើទុកជាមាន ឧបសគ្គៈ មកពាំងយ៉ាងណា ។ ក៏មិនរំភើប ញាប់ញ័រ តក់ស្លុតឡើយ ។ ឧស្សាហៈ ប្រែថាមានសេចក្តីអត់ធ្មត់ខ្ជាំខ្ជែគស្ងួ ឧហាត់សង្វាតធ្វើកិច្ចការគ្រប់យ៉ាង ។

ទុដ្ឋា ៩ : ប្រែថាលះបង់នូវសេចក្តីត្រិះរិះច្រណែនអួស ហើយត្រេកអរឡើងស្រួចចាប់ការងារតតាំងធ្ងន់ធ្ងរខាន់ ។ អាតប : ប្រែថាជូតកំណេរ ប្តូរតិបាញកន្ត្រាក់នូវតែដែលខាំឲ្យសៅហ្មងចេញចុតអំពីសន្តានចិត្ត ។ កិតិ ប្រែថាមានសេចក្តីរន្ធត់ខ្លាចយ៉ាងម៉ឺងម៉ាត់ចំពោះកិច្ចការសព្វយ៉ាង ។ អដ្ឋិត ប្រែថាអំពើណាមួយដែលកើតឡើងត្រូវគាល ត្រូវទំនង ហើយមិនពាក់ព័ន្ធ មិនអាស់អែក ធ្វើអំពើនោះភ្លាមៗមិនឲ្យកន្លងពេល ។ អប្បដិកណ្ឌី ប្រែថាបើមានធ្វើកិច្ចការណាមួយមិនខាន់ឬនសម្រេចទេ មិនឈប់ត្រាយ មិនលះបង់ចោលនូវកិច្ចការនោះឡើយ ។

ពាក្យដែលឮនៅលើមកទាំងប៉ុន្មាននេះ ផ្សែងគ្នាតែព្យញ្ជនៈឯសេចក្តីអធិប្បាយ មានដំណើរស្រដៀងគ្នា រួមមកឬនសេចក្តីថាព្យាយាមដូចគ្នាទាំងអស់ ។

បធានៈនោះមាន ៤ យ៉ាងគឺ :

๑ - សំវរប្បធាន ព្យាយាមកងការប្រយត្នមិនឲ្យបាបកើតឡើងបាន ។

๒ - បហានប្បធាន ព្យាយាមកងការលះបង់នូវបាបដែលកើតឡើងហើយ ឲ្យវិនាសទៅវិញ ។

๓ - ភាវនាបធាន ព្យាយាមកងការធ្វើកុសលឲ្យកើតឡើង ។

៤ - អនុរក្ខាថាបនា ឲ្យយោមក្នុងការរក្សាកុសលដែលកើតឡើងហើយ ឲ្យរឹងតែតែចំរើនឡើង ។

បធាន: ទាំង ៤ យ៉ាងនេះ បើសំដែងរួបរួមដោយកិច្ចមាន ២ យ៉ាងគឺ:

១ - បហានកិច្ច កិច្ចដែលត្រូវលះបង់ ។

២ - ភាវនាកិច្ច កិច្ចដែលត្រូវចំរើន ។

អធិប្បាយថា: បហានកិច្ច កិច្ចដែលត្រូវលះបង់នោះគឺលះបង់នូវអំពើបាប; ពាក្យថាបាប សំដៅយកអំពើអាក្រក់ ៣ យ៉ាងគឺ កាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣ ; កម្មដ៏លាមកទាំង ៣ នេះ សុទ្ធតែចាត់ជាបាបទាំងអស់ ។ ក្នុងបាលីមានសំដែងអំពីបាប ៣ ពួកនេះច្រើនជាងចំណែកដទៃ ។ ព្រោះបាបទាំងអម្បាលនេះ ជាប្រធានរបស់បាបទាំងពួង; សូម្បីបាបដទៃ ក៏រួមចូលក្នុងបាប ៣ ពួកនេះដែរ; បាបទាំងនេះបួនភាសហៅថាបាបដដែល ប្រែថាកម្មដ៏លាមក, បួនភាសហៅថាទុច្ចរិត ប្រែថាការប្រព្រឹត្តអាក្រក់, បួនភាសហៅថាអកុសល ប្រែថាអំពើមិនល្អ, បួនភាសហៅថា អករណីយកិច្ច ប្រែថាកិច្ចមិនគួរធ្វើ, បួនភាសហៅថា អធម្មចរិយ: វិសមចរិយ: ប្រែថាការប្រតិបត្តិមិនជាធម៌ ការប្រព្រឹត្តិមិនសម ។

បណ្តាបាបទាំងប៉ុន្មានដែលបានពោលមកនេះ តតមានចំណែកណាមួយដែលជារបស់គួរធ្វើ គួរប្រព្រឹត្តសោះឡើយ សុទ្ធតែជាកិច្ចមិនគួរធ្វើ មិនគួរប្រព្រឹត្តទាំងអស់ ។ សមដូចព្រះគម្ពីរមុនី ទ្រង់ត្រាស់នឹងព្រះ-

អានន្ទថា ឯកំសេនាហំ អានន្ទ អករណីយំ វទាមិ ម្នាលអានន្ទ តថាគត ហៅកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយ ជាច់ខាត; កាលបើបុគ្គលណាមួយ ដែលកាយ ពាក ចិត្ត ធ្វើអករណីយ-កិច្ចនោះហើយ ត្រូវដឹងខ្លួនចុះថាមុខជានឹងមានទោសពុំខាន ។

ឯទោសប្រព្រឹត្តទុច្ចរិតនោះមាន ៥ យ៉ាងគឺ:

๑ - អត្តាបិ អត្តានំ ឧបវទតិ សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯងដែរ ។

๒ - អនុវិច្ច វិញ្ញូ រហេដ្ឋិ លោកអ្នកចេះដឹងរិះគន់មើលរមែងតិះដៀលបាន ។

๓ - ចាមតោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កេរ្តិ៍ឈ្មោះអាក្រក់ រមែងល្បីខ្ចរខ្ចាយទៅសព្វទិស ។

๔ - សម្មុឡ្ហោ កាលំ ករោតិ រង្វេងភ្លេចស្មារតីក្នុងពេលដែលខៀបស្លាប់ ។

๕ - កាយស្ស ភេទា បរម្មរណា ឧក្កដំ ឧបបជ្ជតិ ទៅកើតក្នុងទុគ្គតិ ។

បុគ្គលណាធ្វើបាបដូចបានពោលមកនេះ រមែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺ:ក្នុងលោកនេះ រមែងក្តៅក្រហាយដោយគិតថា អាត្មាអញធ្វើបាបដូច្នេះៗ, លុះច្យុតចាកលោកនេះទៅហើយក៏តែងក្តៅក្រ-

ហាយជាន់នេះទៀត ។ ព្រោះហេតុនោះបានជាព្រះអរហំសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ឃ្លាបនេះជាអំពើមិនគួរធ្វើ មិនគួរប្រព្រឹត្តទៀយ, នេះហៅថា បុហានកិច្ច ។

ការនាកិច្ច កិច្ចដែលគួរចំរើននោះ គឺកម្មដែលកំចាត់បង់នូវសេចក្តីអាត្រកត់ហៅថាកុសល ការដែលព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើង ហៅថាចំរើញកុសលឲ្យបរិបូណ៌, កុសលនេះប្រែថាគ្មានកង្វល់ ប៉ុន្តែប្រសប់ខាង១ចាយធ្វើឲ្យដុរដាល ឲ្យលុតលាស់ចំរើនឡើងនូវគោតសម្ព័ទ្ធចំណេះវិជ្ជាភាំងនូវលោកធម៌ ។ កុសលនោះ បើសំដែងដោយឫសគល់ ឃ្លានខាងអលោភៈ មិនលំពាក់ចិត្តនឹងទ្រព្យសម្បត្តិ មិនបង់បានទូវទ្រព្យសម្បត្តិរបស់អ្នកដទៃ គឺមិនលួចលាក់ឆក់ដណ្តើមបំបាត់ប្រវ័ញ្ច សង្កត់សង្កិនរបៀនយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ អនោសោ មិនប្រទូស្តមិនខឹងមិនកេរ្តិ៍កេហេតុអ្នកដទៃ ឲ្យដល់នូវសេចក្តីវិនាស ។ អមោហោ មិនវង្វេងភ្លេចស្មារតីដោយអ្នកដទៃគេគម្រាមកំហែង បំភាន់គំនិតជាដើម ទៀយ ។

មួយទៀត កុសលនេះបើសំដែងដោយទំរើតមាន ១០ ប្រការ គឺ

๑ — ការឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យដោយសេចក្តីសាទ្ធាៈ ប្តូបូជាគុណ មានឲ្យដល់មនុស្សកំសត់ ប្តូបូជាដល់លោកអ្នកមានសីលធម៌ ទឹងមាតាបិតាជាដើម ហៅថាទានៈ ។

๒ - ការវៀរចាកអំពើអាក្រក់ដែលកើតអំពីការយកវាថា មានវៀរបញ្ចៀរជាដើម ហៅថាសីល: ។

๓ - ការឆ្លើចិត្តទៅស្ងប់រម្ងាប់ចាកអកុសលធម៌ មានទីវណ៌ធម្មជាដើម ដោយសមថវិធី ឧដ្ឋិបស្សនាវិធី ហៅថាភាវនា ។

๔ - ការទំរុទំភេមអស្ចឹមាន: ដែលកើតមានក្នុងចិត្តដោយសេចក្តីគោតក្រែងចំពោះបុគ្គលដែលគួរគោតក្រែង គឺជនដែលចំរើនដោយជាតិដោយវ័យ ដោយគុណ ហៅថាអបចាយន: ។

๕ - ការឆ្លួយខ្លួនខ្លាយក្នុងកិច្ចការកុសល ហៅថាវេយ្យាវច្ចៈ ។

๖ - ការឲ្យខ្លួនចំណែកបុណ្យ ដែលខ្លួនបានធ្លើហើយដល់អ្នកដទៃដោយមេត្រីចិត្ត ដើម្បីឲ្យគេត្រេកអរតាម ហៅថាបត្តិទាន: ។

๗ - ការគេខ្មុំមោទនាត្រេកអរតាមខ្លួវសេចក្តីល្អ របស់អ្នកដទៃដែលគេបានធ្លើហើយ ដោយចិត្តដែលប្រាសចាកសេចក្តីច្រណែនឈ្នានិស ហៅថាបត្តានុមោទនា ។

๘ - ការណែនាំបង្ហាត់បង្រៀនប្រៀនប្រដៅអ្នកដទៃឲ្យចេះចំណេះវិជ្ជាដែលឥតខ្ចោះ ឬពន្យល់ប្រាប់ក្នុងផ្លូវលោកផ្លូវធម៌ ឲ្យស្គាល់កិច្ចគួរធ្លើ ឧដ្ឋិមិនគួរធ្លើ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសុខ - ចំរើនក្នុងបច្ចុប្បន្ននេះរហូតដល់សម្បត្តិសួគ៌សម្បត្តិព្រះនិព្វានជាទីបំផុត ហៅថាធម្មទេសនា ។

៩ — ការតាំងចិត្តស្តាប់ធម៌ ស្តាប់ពាក្យទន់ ពាក្យប្រៀនប្រដៅ ដោយប្រុងឲ្យចេះចាំស្ទាត់ ធ្លើកើត និយាយបាន ហៅថាធម្មស្សវនៈ ។

១០ — ការធ្វើទិដ្ឋិគឺសេចក្តីយល់ឃើញរបស់ខ្លួនឲ្យត្រូវតាមគន្ថធម៌ដែលពិតមែន ហៅថាទិដ្ឋុកម្មៈ ។

អំពើទាំង ១០ ប្រការនេះ ហៅថាបុញ្ញកិរិយាវត្ថុ គឺជាទីតម្កល់សម្រាប់កើតបុណ្យ ។ បុគ្គលណាបានធ្វើកុសលដូចបានពោលមកនេះ បុគ្គលនោះរមែងបានខ្លះអានិសង្ស ៥ យ៉ាង គឺ

១ — អត្តាបិ អត្តានំ ឧបវទតិ សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯងមិនបាន ។

២ — អនុវិច្ច វិញ្ញូ បសំសន្តិ អ្នកប្រាជ្ញទាំងឡាយលោកឃើញតាមការពិត លោករមែងសរសើរ ។

៣ — កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ មានកិត្តិសំពុតពីពេរល្បីឮខ្ចរខ្ចាយទៅសព្វទិស ។

៤ — អសម្មុឡ្ហោ កាលំ ករោតិ មិនវង្វេងភ្លេចស្មារតីធ្វើមរណកាល ។

៥ — សុគតិំ សគ្គំ លោកំ ឧបបជ្ជតិ ទៅកើតក្នុងសុគតិ គឺស្ថានសួគ៌ ទីមនុស្សលោក ។

អានិសង្សទាំង ៥ យ៉ាងនេះ រមែងមានដល់បុគ្គលអ្នកមានសេចក្តី

ព្យាយាមបំពេញសុចរិតធម៌ ហើយឲ្យសង្ឃឹមខ្ពុកចិត្តចុះ ថាមុខជានឹងជួបប្រទះនូវសេចក្តីសុខ - ចំពោះក្នុងលោកនេះ នឹងលោកខាងមុខមិនខាន នេះហៅថាការនាកិច្ច ។

កិច្ចទាំងពីរយ៉ាងនេះ ជាដំណើរខាងធម៌; បើជាខាងផ្លូវលោកវិញ សំដៅយកការលះបង់នូវបុគ្គល ការយោគអាត្រកត់ ត្រកឹតត្រកោងគោងការចិញ្ចឹលប្រអូស ដើរលេងស៊ីឆ្ងាក ចាយវាយឲ្យសម្បត្តិតប្រយោជន៍ តតសណ្តាប់ធ្នាប់ មានឆ្កើយចោរកម្លួចប្លន់ឆក់ជណ្តើម រឹបជាន់សង្កត់សង្កិនយកធនជាន់អ្នកជាខ្មែជាដើម ។ អំពើទាំងអស់នេះ សុទ្ធតែជាអំពើនាំឲ្យចោកទាប ខន់ខ្សោយអាប់ស្មីដល់ខ្លួនឯង នឹងប្រទេសជាតិមាតុភូមិ ជាអំពើនាំឲ្យលោកតិះដៀល: បុគ្គលអ្នកស្រឡាញ់សេចក្តីល្អគួរលះបង់ចោល ។

យើងកើតមកជាមនុស្សម្នាក់ៗ ក្នុងលោកសន្និវាសនេះ: មានអាយុវែងត្រប់ត្រាន់ មិនវិកលវិការៈ ដោយអាឃាតនៈណាមួយ គួរតែបំពេញកិច្ចរបស់ខ្លួនឲ្យត្រប់ត្រាន់ កុំពីធ្វើឆ្គងទៅលើរូបបុគ្គលណាមួយឲ្យគេចិញ្ចឹមខ្លួនដោយងាយ ។ នោះ មិនឃ្លានសម្រេចប្រយោជន៍ប៉ុន្មានទេ, ព្រោះរូបនិមួយៗ - សុទ្ធតែមានសេចក្តីសុខទុក្ខជាប់ជាក់ទង់ដោយពាក់កាយប្រុកមានពាក់កាយជាទីអាស្រ័យនៅនៃសេចក្តីសុខទុក្ខ ដូចជាគេហដ្ឋានជាទីអាស្រ័យនៅនៃមនុស្ស, ជិតសោតៈទៀតដែលនឹងតាំងនៅជាន ក៏ព្រោះ

តែអាស្រ័យរាងកាយ, ការគ្រប់គ្រងចិញ្ចឹមរាងកាយឲ្យធាប់ធំមាំមួនខ្លាំង
ពូតែខ្លៅឯង ក៏ព្រោះអាស្រ័យសេចក្តីព្យាយាមស្វែងរកអាហារសម្រាប់
ទុកដើម្បីខ្លួន, កាលបើបាត់អាហារហើយ សន្ធតិរូប គឺរូបដែល
ចំរើនឆាប់តែខ្លោកឈប់ចំរើន តាំងជីវិតសោតខ្លែត ក៏តាំងនៅបានដោយ
កម្រ ។ អាហារនេះជារបស់សំខាន់បំផុត សម្រាប់បម្រុងជីវិតឲ្យ
ប្រព្រឹត្តទៅ សមដូចបាលីថា សត្តា អាហារដ្ឋិតិកា "ពួកសត្វរាល់
រូបដែលមានជីវិតរស់នៅបានក៏ព្រោះអាហារ" ។ រត្តុងខ្លែត ។ ត្រូវ
ពឹងអាហារនោះមានច្រើនប្រភេទណាស់ ដូចយ៉ាងលំនៅឯងពីផ្ទៃកគោន
សំពត់សម្រាប់ស្លៀកដណ្តប់ ថ្នាំសម្រាប់កែរោគក្នុងពេលដែលត្រូវការ
ប៉ុណ្ណោះឯដើម, រត្តុងអម្បាលនេះ សុទ្ធតែជារបស់ជួយឧបត្ថម្ភបន្ថែម
ជីវិតទាំងអស់, បើបាត់របស់ណាមួយហើយ ជីវិតមែនតាំងនៅ
ដោយលំបាក ។

សូមតាញរឿងឧបមាខ្លះមកសំដែងក្នុងទីនេះ ឲ្យឃើញអានិសង្ស
នៃសេចក្តីព្យាយាម ។ យើងគួរយកគំរូតាមសត្វកណ្តុរ; កណ្តុរ
ជាសត្វមានខ្លួនតូចណាស់, តែកណ្តុរមានសាមគ្គីធម៌ព្រមព្រៀងគ្នា
ព្យាយាមជញ្ជូនដីបន្តិចម្តង ។ រាល់ថ្ងៃ កញ្ចូនកើតខ្លែងនៅជាដំបូកមួយ
យ៉ាងធំ ចាននៅជាធ្លុះសំបែងសម្រាប់ការពារញាតិមិត្តកូនចៅរបស់
ពួកគេសេចក្តីសុខ-ចំរើន តែមានសត្វហានចូលលុកលុយបាន តាំង

សម្បូរដោយគ្រឿងចិញ្ចឹមជីវិតរបស់ពួកឥតមានខ្វះខាត ។ មួយទៀត ដូចពួកក្នុងជាតិផ្សេង ។ ជាជាតិមានដើមមានឫសខ្លីខ្លះយកទឹកឆាស់តែបើពួកក្នុងជាតិនាំនេះ ដុះទៅលើធម្មជាតិណាមួយមានជាតុរឹងច្រើនហួសនឹងឫ ពួកជាតិនោះ ចុះលូតឫសច្រើនចាក់ចុចសឹកស្មៅតបន្តិចម្តង ។ កាលនៃថ្ងៃធម្មជាតិនោះ តស៊ូនឹងពួកជាតិពុំបាន ក៏របើករបះច្រេះបែកទៅដោយកំឡាំងភ្ញាយាមរបស់ពួកជាតិ ពួកជាតិក៏មានគំណាចចាក់ឫសទៅដល់ផែនដីស្រូបយកតំឡាំងជាតុមកចិញ្ចឹមដើមរបស់ពួកឲ្យរឹងតែតែមានកំឡាំងខ្លាំងឡើង, នេះក៏មកអំពីសេចក្តីព្យាយាម ។

ម្យ៉ាងទៀត ដូចជាព្រះបរមគោដ៏សត្វព្រះនាមមហាជនក កាលលាមាតាចុះសំពៅទៅដួញជាមួយនឹងពួកឈ្មួញ, លុះដល់កណ្តាលមហាសមុទ្រ សំពៅក៏បែកធ្លុះឆ្លាយទៅដោយខ្យល់ព្យុះខ្លាំង, ពួកឈ្មួញគាំងអស់ក៏មានសេចក្តីតិតក៏យតក់ស្ញូតខ្លាចសេចក្តីស្លាប់, ខ្លះស្រែកឡើងហោយំខ្លះបន់ស្រន់ពួកទេព្តាអាកែវអ្នកតាឲ្យជួយស្រោចស្រង់ជីវិត, មិនសមប្រកបក៏លិចលង់ស្លាប់ក្នុងមហាសមុទ្រអស់ទៅ ។ ចំណែកខាងព្រះពោធិសត្វ មិនមានសេចក្តីតិតក៏យតក់ស្ញូតនឹងសេចក្តីស្លាប់សោះឡើយ លោកនឹកដល់គុណមាតាបិតា គុណសិលធម៌ដែលលោកធ្លាប់ប្រព្រឹត្តមកហើយ ក៏លោតចេញអំពីសំពៅច្រើនហួសសំដៅទៅកន្លែង

ម្ខាងអស់ចំនួន ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ ជាថ្ងៃឧបោសថ លោកវក្ខាន្ធវ
ឧបោសថសីលនាំគ្នាតំពុងព្យាយាមហែលក្នុងកណ្តាលមហាសមុទ្រ ។

ពេលនោះមានឥន្ទ្រទេពធីតា ១ អង្គឈ្មោះមណិមេខលា នៅវក្ខ
មហាសមុទ្រ, លុះឃើញព្រះបរមពោធិសត្វប្រឹងព្យាយាមហែលឥតមាន
ឈប់ឈរយ៉ាងនេះក៏ស្រែកសួរថា

កោយំ មជ្ឈ សមុទ្ទស្មឹ អបស្សន្តីវមាយុហោ
កឹ តុំ អត្តាសំ, ញត្វា ឋវំ ភយាមសេ កុសំ

អ្នកណានេះ កាលបើមិនឃើញខ្លួរគោរត្រីយសោះ ម្តេចក៏ខំប្រឹង
ហែលក្នុងកណ្តាលមហាសមុទ្រ, តើអ្នកដឹងខ្លួរប្រយោជន៍ដូចម្តេច ចាន
ជាខំប្រឹងព្យាយាមហែលអ្វីម្ល៉េះ?

ព្រះមហាជនកពោធិសត្តឥបច

ឯសម្ម វត្តុំ សោកស្ស ភាយមស្ស ច នេវតេ
តស្មា មជ្ឈ សមុទ្ទស្មឹ អបស្សន្តីវមាយុហោ ។

ម្នាលនេរកា ខ្ញុំពិចារណាខ្លួរវត្តនៃសត្វលោក និងអានិសង្សនៃ
សេចក្តីព្យាយាម, ព្រោះហេតុដូច្នោះ ខ្ញុំបើពុំបានឃើញខ្លួរគោរត្រីយ
ក៏ដោយចុះ ក៏នៅតែប្រឹងព្យាយាមហែលក្នុងកណ្តាលមហាសមុទ្រ
(ពុកជាតម្រាប់ដល់លោក ស្ងាប់ពេលណា ឈប់ពេលនោះ មិនលះ
បង់ខ្លួរសេចក្តីព្យាយាមទេ) ។

នាងទេពធីតាគោលថា

តច្ចិវេ អប្បមេយ្យស្មឹ តីរំ យស្ស ន ទិស្សតិ

មោឃោ តេ បុរិសវិយោគោ អប្បត្វា វ មរិស្សសិ

ត្រើយមហាសមុទ្រជ្រៅធ្លាយគ្រប់មាណមិនឃើញ មិនច្បាស់ដល់អ្នកណា ការព្យាយាមតាមកំឡាំងបុរស ក៏ជាការឥតអំពើដល់អ្នកនោះ អ្នកមិនដល់ត្រើយទេ មុខជាទីឆ្ងាប់ (ក្នុងមហាសមុទ្រនេះពុំមានទេឬយ) ។

ព្រះបរមពោធិសត្វគប្បីថា

អណាធោ ញាតិនំ ហោតិ នេកន្តំ បិត្តុ ឯកកំ សោ

តវ បុរិសកិច្ចានិ ន ច បច្ចានុភុយ្យតិ

(ម្នាលទេវតា) បុគ្គល (កាលកំពុងព្យាយាម សូម្បីទីឆ្ងាប់) ក៏ឃើញថាជាអ្នកមិនមានបំណុល គឺថាពួកញាតិ ពួកទេវតាទីឆ្ងាមាតាបិតាមិនតិះដៀលឡើយ , បុគ្គលនោះកាលបើឃើញផ្លែកិច្ចរបស់បុរសហើយ រមែងមិនក្តៅក្រហាយឡើយក្នុងពេលជាខាងក្រោយ ។

នាងទេពធីតាគោលទៀតថា

អថារណេយ្យំ យំ កម្មំ អប្បលំ តិលមត្តកំ

តត្ថ កោ ភយមេនត្តោ មកុ យស្សកិនិច្ចតំ

ការងារណាមិនសម្រេចដោយសេចក្តីព្យាយាមទេ ការងារនោះទៅជារបស់តិចតួច មានតែសេចក្តីលំបាកជាកម្រៃ, សេចក្តីស្លាប់រមែង

សម្រែចដល់បុគ្គលណា បុគ្គលនោះ ទំងមានប្រយោជន៍ដូចម្តេច (ដល់តាវ ព្យាយាមនោះ?)

ព្រះបរមគោធីសត្ថុតបទៅវិញថា

អថារណេយ្យំ អកុព្ពំ យោ វិនិក្ខាន ទោវតេ
ន រក្ខេ អត្តនោ ថាលំ ឥញ្ញ សោ យធិ ហាបយេ
អធិប្បាយផលំ ឯតេ អស្មឹ លោកស្មឹ ទោវតេ
បយោជយន្តិ កម្មានំ តាធំ ឥជ្ឈន្តិ ភ ន ភ
សន្ទិដ្ឋកំ កម្មផលំ ន ន បស្សសិ ទោវតេ
សន្តា អញ្ញេ តកមហំ តញ្ច បស្សាមិ សន្តិកេ
សោ អហំ កយ្យមិសាមិ យថាសតិ យថាពលំ
តញ្ច ថារំ សមុទ្ទស្ស កាលំ បុរិសការិយំ

ម្នាលទេវតា បុគ្គលណាដ៏ឆ្លាស់ថា , ការងារមានទីបំផុតត្រៃពេក មិនគប្បីសម្រែចទេ ហើយលះបង់ចោលបែរជារក្សាទុកជំរិតរបស់ខ្លួនទៅវិញ ក៏បន្ថយទុកសេចក្តីព្យាយាមចោលដែរ, បុគ្គលនោះតង់ដឹងទុកផលនៃសេចក្តីខ្ជិលច្រអូសនោះពុំខានឡើយ ។ ម្នាលទេវតា បុគ្គលពួកខ្លះក្នុងលោកនេះ កាលបើឃើញទុកផលនៃសេចក្តីច្នាច្នាហើយ រមែងប្រកបទុកការងារទាំងឡាយ ការងារទាំងនោះទោះបីសម្រែចក្តីមិនសម្រែចក្តី គួរតែខំប្រឹងព្យាយាមកុំខាន ។ ម្នាលទេវតា ព្រែងអ្នក

ប៉ុន្តែយើញនូវផលនៃសេចក្តីព្យាយាមដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ? ឯនទាំងឮយ៉ាងណាទៀត ។ លិចចុះក្នុងមហាសមុទ្រអស់ហើយ មកពីមិនមានសេចក្តីព្យាយាម ។ ឯខ្ញុំតែម្នាក់ឯងនេះដែលកំពុងហែលឆ្លងមហាសមុទ្រ តាំងបានយើញអ្នកដែលស្ថិតនៅក្នុងទីជិតខ្ញុំ ខ្ញុំនេះនឹងព្យាយាមតាមសមគួរដល់សេចក្តីអង់អាច នឹងសមគួរដល់កំលាំង តាលបើខ្ញុំបានដល់ត្រើយនៃមហាសមុទ្រហើយ ខ្ញុំនឹងធ្វើនូវសេចក្តីព្យាយាមដែលបុរសគប្បីធ្វើនោះឲ្យសម្រេចជាកិយ្យាតាម ។

នាងទេពធីតាបានស្តាប់ព្រះមហាជនកពោធិសត្វហើយ ក៏ពោលសារសើរថា ។

យោ តុំ ឣវំ កតេ ឥមេ ឣប្បមេយ្យេ មហាណ្ណវេ
ឩម្មាយាមសមុដ្ឋាបេ ភុម្មា ទាវសីនសិ
សោ តុំ តត្ថេវ កច្ឆាមិ យត្ថ តេ ឯរតោ មនោ

តាលបើមហាសមុទ្រមានអន្លង់ទឹកដ៏ជ្រៅប្រមាណមិនបាន ប្រព្រឹត្តទៅយ៉ាងនេះ អ្នកណាប្រកបដោយសេចក្តីព្យាយាមដោយធម៌ រមែងមិនលិចចុះដោយកម្មគឺសេចក្តីព្យាយាមឡើយ ចិត្តរបស់អ្នកត្រេកអរក្នុងទីណា អ្នកនោះចូលទៅក្នុងទីនោះចុះ ។

នាងទេពធីតាពោលសារសើរតែប៉ុណ្ណោះហើយ ក៏ស្ទុះទៅចាប់ដើមដៃព្រះពោធិសត្វកើតទាញនាំយកទៅជាក់ដល់មិចិលានគរនោះឯង ។

នាំរឿងពីរមកប៉ុណ្ណោះឲ្យឃើញថា គុណសម្បត្តិនៃសេចក្តីព្យាយាម
នេះ អាចឲ្យសម្រេចដល់បុគ្គលអ្នកមានសមត្ថភាព តឹតាពនៃសេចក្តី
អង់អាច សេចក្តីមោះមុត, សមត្ថកាល វេលាដែលនៅប្រឹងបាន នៅ
ឆ្ងើការកើត កំពុងពេញកំឡាំងនៅឡើយ ។ បុគ្គលណាតាលបើមាន
សេចក្តីពេញចិត្តកន្លងការបំពេញកិច្ចរបស់ខ្លួនយ៉ាងនេះហើយ បុគ្គលនោះ
បើទុកជាស្ងាប់កន្លងពេលកំពុងព្យាយាមបំពេញកិច្ច, ក៏ចាន់ឈ្មោះចារឹកសើរ
បំផុត ។ ខ្លួនស្ងាប់ចាត់ទៅមែន តែកេរ្តិ៍ឈ្មោះនៅស្អាត, ខ្លួនស្ងាប់ទៅ
ចុះ កុំឲ្យតែស្ងាប់សេចក្តីព្យាយាម ។ សមដូចភាសិតថា រូបំ
មំ យេតំ មច្ចានំ ឆាមតោត្តំ ន មំ យតិ រូបនៃសត្វទាំងឡាយ
រមែងស្ងាប់ទៅ តែនាមនឹងគេត្រូមិនស្ងាប់ឡើយ ។ ព័រយេន ឧក្តុ-
ដ្ឋេតិ កន្លងខ្លួរសេចក្តីទុក្ខថានដោយសេចក្តីព្យាយាម ។

សំដែងអំពីបាតកថាចប់តែប៉ុណ្ណោះ ។ សូមឆ្លាយចំណែកគុសល
ដល់ពុទ្ធសាសនិកជនទាំងឡាយក្នុងកម្ពុជរដ្ឋទាំងមូលឲ្យបានសេចក្តីសុខ-
ចំរើនត្រប់ប្រការ ។

ឧក្តុក្កេកកយា វេរា សោកា សត្តុ ច ទុក្ខា
អនេកា អន្តរាយាបិ វិនស្សន្តុ ច តេជសា

សេចក្តីទុក្ខ នឹងភេត នឹងភ័យ នឹងពៀរទាំងឡាយក្តី សេចក្តីសោក
នឹងសត្រូវ នឹងឧបទ្រពទាំងឡាយក្តី អន្តរាយទាំងឡាយដ៏ច្រើនក្តី សូមឲ្យ
វិនាសបាត់ទៅ ដោយតេជៈ (នៃធម្មទេសនានេះ), ។

វត្តមុលស្សរង្សីដ៏

បើកសាលាបរិយត្តិធម្មវិទ្យ

វត្តព្រះពុទ្ធឯកភាវ ឃុំកពង់ឃ្លាង ស្រុកដង្កែក ខេត្តសៀមរាប ។

លោកមហា ឈិន រៀបរៀង

ដូច្នៅថ្ងៃច័ន្ទ ៨ កេចឆែកាសាធ ឆ្នាំឆ្លូវឯកស័ក ព. ស. ២៤៨២ វេលាថ្ងៃរសៀលមោង ១៥ នឹង ៤០ នាទី ជួបជុំគ្នាសាមណេរ នឹង ឧបាសក - ឧបាសិកាក្នុងសាលានោះ ដើម្បីលោកព្រះមហា ឈិន ថ្លែងសុន្ទរកថាចំពោះលោកគ្រូអនុគណ ស្រុកដង្កែក ដែលលោកជាអ្នកបួច ផ្តើមទំនុកបុរុងក្នុងទីវត្តនោះ ហើយបានទិមន្តលោកព្រះមហាអង្គនេះ មកធ្វើជាអាចារ្យបង្ហាត់បង្រៀនដោះក្នុងទីវត្តនេះផង ។

សេចក្តីថ្លែងការណ៍របស់លោកព្រះមហា ឈិន នោះដូចមានរៀបរាប់ក្នុងសុន្ទរកថានោះស្រាប់ ។ បន្ទាប់មកលោកគ្រូអនុគណ បានឲ្យទន្ទេរដល់តិក្ខសាមណេរ ដែលចំរុងចួនបានចូលសិក្សាក្នុងសាលាបរិយត្តិធម្មនេះតទៅ ។

ទិវាទរបស់លោកគ្រូអនុគណ

• ក្នុងឱកាសនេះ ជាវេលាល្អប្រកបដោយនក្ខត្តឫក្ស មានសិរីសួស្តីដល់ក្រមពុទ្ធបរិស័ទទាំងឡាយ បានមកជួបជុំគ្នាក្នុងទីសន្និបាតនេះ ដើម្បីនឹងធ្វើពិធីបើកសាលាបរិយត្តិធម្មនេះ ។ ដូច្នេះសូមអ្នកទាំងឡាយជ្រាបថា

សាលាបរិយត្តិបឋមវិជ្ជាកង់ឃុំកំពង់ឃ្លាង ស្រុកដំរែគង ខែត្តសៀមរាប នេះមានខ្វះដែរហើយ តែសាលាបរិយត្តិធម៌នោះមិនទាន់មានទៅឡើយទេ ក្នុងស្រុកនិគមយើងនេះ ហេតុដូច្នេះហើយបានជាខ្ញុំព្រះករុណា-អាត្មាភាព ខំប្រឹងប្តូចរដ្ឋើមបង្កើតសាលាបរិយត្តិធម្មនេះឡើងដោយតេញកំលាំង មិនមានគិតដល់សេចក្តីខ្លឿយហត់នោះសោះឡើយ ។ តែស្រុកទេសដែលកំពុងវិបត្តិប្រែប្រួលយ៉ាងនេះក៏ដោយ ក៏នៅតែមានសេចក្តីប្រឹងប្រែងរកគ្រូបាអាចារ្យឲ្យខាងតែបានមកបង្ហាត់បង្រៀនបង្កប់ព្រះពុទ្ធសាសនាតទៅមិនឲ្យអាក់ខានឡើយ ។ ដោយសេចក្តីយល់ឃើញថា ខេមរជាតិយើងទាំងអស់គ្នា សុទ្ធតែជាអ្នកគោរពរាប់អានព្រះពុទ្ធសាសនា តាំងពីបូពណាកាលដរាបដល់ឥឡូវមកហើយ, ដូច្នេះគួរយើងទាំងអស់គ្នាយកចិត្តទុកដាក់ខំសិក្សារៀនសូត្រដោយហ្មត់ចត់ កុំធ្វើត្រដើមឡើយកន្លែងនឹងការរៀនសូត្រក្នុងផ្លូវប្រតិបត្តិនោះឡើយ។ ព្រោះសាសន៍ដទៃបានដឹងច្បាស់ថាខេមរជាតិយើងសុទ្ធតែជាជាតិអ្នកកាន់ព្រះពុទ្ធសាសនាជាយូរអង្វែងឆ្នាំមកហើយ ។ ដូច្នេះត្រូវយើងគ្រប់គ្នាខំគ្រែបជាញាក់ យកជាតិវិសព្រះពុទ្ធសាសនាមកកំណត់ទុកក្នុងចិត្តគ្រប់ៗគ្នាតទៅ ។

ចំណែក-ឧបាសកឧបាសិកា ត្រូវប្រឹងរក្សាកាយវាចាចិត្តតាមហ៊ាន: ជាអ្នករក្សានិច្ចសីល ឱ្យឧបោសថសីលឲ្យបានត្រឹមត្រូវតាមពុទ្ធបញ្ញត្តិឱ្យពុទ្ធានុញ្ញាត កុំឲ្យលង់ខ្លួនទៅកង់សេចក្តីប្រមាទនោះឡើយ ។

បន្ទាប់អំពីនោះមក លោក អាចារ្យ សាមឿន ជាអាចារ្យវត្ត-កំពង់ឃ្លាង ឲ្យនាគដល់ពុទ្ធបរិស័ទតាំងឡាយនោះចែមទៀត ដើម្បីឲ្យបានប្រឹងប្រយ័ត្នកាយ វាចា ចិត្ត ហើយនឹងស្ថិតនៅក្នុងសីលសមាធិ-បញ្ញា ដោយបរិបូណ៌ លុះដល់វេលាម៉ោង ១៧ ជាបរិយោសានកិច្ចនៃវិធីសម្ពោធិបើកសាលាបរិយត្តិធម៌នោះឯង ។

សុន្ទរកថា

សូមពិតព្រះពុទ្ធដីកាព្រះតេជព្រះគុណជាគោរព សូមអានុជ្ញាប ។ វត្តព្រះពុទ្ធឯកភាជ្យនេះ ឋានៈប្តូរត្តិះខ្លីនតាំងពីឆ្នាំណាមកដល់ឆ្នាំបច្ចុប្បន្ននេះ? មានសភាពយ៉ាងណា ? មានសេចក្តីប្រព្រឹត្តិមកយ៉ាងណា ? ព្រះតេជព្រះគុណជ្រាបស្រាប់ ។

ដល់ទីបំផុត ឧបាសកឧបាសិកា ចំណុះដីនវត្តតាំងឡាយ អ្នកប្រាថ្នាសេចក្តីចំរើនរុងរឿងដល់វត្ត បានព្រមព្រៀងគ្នាទុកជាកំវត្តនេះឲ្យនៅក្រោមសេចក្តីទំនុកបំរុងព្យាបាលរក្សារបស់ព្រះតេជព្រះគុណ ដោយហេតុតែព្រះទ័យដ៏ប្រកបដោយសេចក្តីមេត្តាករុណា នឹងសេចក្តីប្រាថ្នាដ៏បរិសុទ្ធក្នុងការជួយទំនុកបំរុងផ្សេងៗ ដើម្បីឲ្យវត្តនេះឈានដើរទៅការសេចក្តីចំរើនរុងរឿង សមជាវត្តដែលជាទីគួរជ្រះថ្លាដល់បណ្តាជនអ្នកត្រូវការដោយបុញ្ញក្ខេត្តរបស់ព្រះតេជព្រះគុណ ហើយបានចាត់ឲ្យកិច្ចសាម-ណេរមកគង់នៅក្នុងទីវត្តនេះ ថែមទាំងបាននិមន្តលោកគ្រូដែលបុនប្រសប់

រៀនវៃក្នុងវិធីធ្វើការផ្សេង ។ មកធ្វើជាចៅអធិការវត្ត ដោយហេតុតែព្រះ-
ទ័យយល់ឃើញថា, បណ្តាប្រទេសជាតិនានាក្នុងលោកសន្និវាសដែល
នឹងឈានលឿនទៅកាន់ភាពជាអារ្យប្រទេស ឬអារ្យជាតិទៅបាននោះ
រដ្ឋាភិបាលរបស់ប្រទេសនោះ។ សុទ្ធតែចំប្រឹងប្រែងរកឧបាយវិធីបណ្តុះ
ការសិក្សា ដល់ប្រជាជាតិក្នុងប្រទេសខ្លួន។ ឲ្យបានពេញលេញ
បរិបូណ៌ឡើង, ចំណែកខាងព្រះពុទ្ធសាសនាក៏ដូចគ្នាដែរ ដែលនឹង
ចំរើនរុងរឿងអាចហុចប្រយោជន៍សេចក្តីសុខ - ចំរើនទៅបាននោះ លុះ
តែតាមអ្នកកាន់គ្រប់គ្នា បានទទួលការសិក្សារៀនសូត្រប៉ែកខាងបរិយត្តិធម៌
ដឹងខុស - ត្រូវ - ល្អ - ពក់ - ខ្ពស់ - ទាប ក្នុងព្រះពុទ្ធសាសនាដោយពេញ
លេញបរិបូណ៌ ទើបបានសមឈ្មោះថា ជាអ្នកកាន់ព្រះពុទ្ធសាសនាមុត
មាំ ជាអ្នកជួយលើកដំកើងព្រះពុទ្ធសាសនា ជាអ្នករក្សាសេចក្តីពិតសេចក្តី
ល្អមនុក្នុងព្រះពុទ្ធសាសនានោះ។ ព្រះសាសនាគឺឈ្មោះថា ជាសាសនា
ដែលដល់នូវភាវៈនៃសាសនាដ៏ប្រសើរជា អារ្យសាសនា ។

សេចក្តីពិតមែននោះ ពុទ្ធសាសនាជាសាសនាអារ្យស្រាប់ហើយ
គ្រាន់តែអ្នកកាន់គ្រប់ៗគ្នាសិក្សារៀនសូត្រប្រតិបត្តិ ធ្វើខ្លួនឲ្យទៅជាអារ្យ
ប៉ុណ្ណោះឈ្មោះថាជួយលើកដំកើងព្រះពុទ្ធសាសនា, ដោយព្រះទ័យ-
យល់ឃើញដូច្នេះហើយ បានជាទំយកព្រះទ័យទុកដាក់ដឹកនាំកិច្ច-
សាមណេរ ឧបាសកនឹងឧបាសិកា ដែលនៅគ្រាមម្ចប់ចារមិឲ្យខំប្រឹង-

យកចិត្តទុកជាក់ក្នុងការសិក្សារៀនសូត្រដម្រង់ព្រះពុទ្ធសាសនា ឲ្យបានត្រឹមត្រូវ សមតាពជាបិតាសង្ឃក្នុងទីនេះ ។

ចំណែកវត្តព្រះពុទ្ធឯកពាជ្យនេះ ក្នុងធ្នាំនេះព្រះតេជព្រះគុណមានបំណងឲ្យកិច្ចសាមណេរក្នុងវត្តបានរៀនការសិក្សារៀនសូត្រ ព្រះធម្មវិន័យ ដែលជាទ្វីមសារ ថ្លៃថ្លៃមាត់របស់ព្រះពុទ្ធសាសនា ឲ្យបានចាត់ទុកខ្ញុំព្រះករុណាមកបង្ហាត់បង្រៀនជាគ្រាំងបូង, ខ្ញុំព្រះករុណាមានសេចក្តីស្តាយជាពន់ពេក ដែលរកឧកាសមកតបស្នងព្រះគុណតាំងពីដើមដៃមិនបាន ទើបតែនឹងមកក្នុងពេលមិនយូរប៉ុន្មាននេះ តែទុកជាដូច្នោះក៏ដោយ ខ្ញុំព្រះករុណាក៏សូមខំប្រឹងពេញទំហឹង ដោយកំឡាំងកាយនឹងកំឡាំងចិត្តអាចប្រតិត្តទៅបានក្នុងការបង្ហាត់បង្រៀន ដើម្បីមិនឲ្យខូចបំណងដែលព្រះតេជព្រះគុណបាត់ថ្លៃមកហើយក្នុងការនេះ ខ្ញុំព្រះករុណាបានទទួលសេចក្តីជួយទំនុកបំរុងយកចិត្តទុកជាក់អំពីព្រះតេជព្រះគុណជាចៅអធិការវត្តនេះដោយអស់ពីចិត្ត សឹងខ្ញុំព្រះករុណាកត់សំគាល់ទុកថាជាឧបការមួយដែលមិនអាចនឹងភ្លេចទៅបានជាបកប្បាវសាន ។

ខ្ញុំព្រះករុណាយល់ផ្តាល់ខ្លួនថា វត្តនេះនឹងបិតថេរយើនយូរនៅក្នុងវង់នៃសេចក្តីចំរើនតទៅខ្ចីអនាគតកាលឯម្ខ្ចៃទៀតនោះ ក៏ដោយសារជែកគ្រែកម្លាំងនៃសេចក្តីទំនុកបំរុងរបស់ព្រះតេជព្រះគុណ ។

ក្នុងទីបំផុតនៃការថ្វែងដ៏បរិសុទ្ធចិត្តនៃខ្ញុំព្រះករុណា សូមព្រះតេជ-
ព្រះគុណ មេត្តាប្រោសប្រទានដម្បូន្មានដល់បណ្តាភិក្ខុសាមណេរ
ឧបាសកឧបាសិកា ដើម្បីឲ្យបានប្រកបដោយជោគជ័យ សិរី សួស្តី
ហើយនឹងសូមព្រះសង្ឃគាំងអស់អង្គផងមេត្តាចិត្តសូត្រ ជយន្តោ ដើម្បី
ជាជ័យមង្គលនៃសាលារៀនព្រះបរិយត្តិធម្មវិន័យ ក្នុងវត្តព្រះពុទ្ធ-
ឯកពាជ្យនេះតទៅ ។

សុន្ទរកថាខេះថ្វែងទៅនៃកាលចេីកសាលាបរិយត្តិធម្មវិន័យ ក្នុងវត្តព្រះពុទ្ធឯកពាជ្យ
ឃុំកំពង់ឃ្នាង ស្រុកដីក្រែង ខេត្តសៀមរាប

ត្រូវថ្ងៃច័ន្ទ ៨ រោចខែអសាធឆ្នាំជូវឯកស័ក ព. ស. ២៤៩២ ត្រូវនឹងថ្ងៃ ១៣ ខែកក្កដា
ឆ្នាំ ១៩៤៩ ។

ហត្ថលេខា មហា ឈិន

សញ្ញាប័ត្រលេខ ៣៧៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់ ស៊ីន នាមធាយ៉ា សេនកបណ្ឌិត កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៦ ជាគ្រូសូត្រស្តាំ វត្តស្ទុងគេហបតី ឃុំកំពង់ហ្លួង ស្រុកពញាអ្ម៉ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៣៧៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ៅ - ស៊ីង នាមធាយ៉ា សុមង្គល កើតឆ្នាំពេង អាយុ ៣៣ វស្សា ១១ ជាគ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៧៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឆុម - ផន នាមធាយ៉ា ដលត្ថេរ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តព្រែកឫកាំង ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៣៧៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អឹម - សាស នាមធាយ៉ា សុមនត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៨០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុន - ខេត តាមធាយ៉ា ព្រហ្មជោត កើតឆ្នាំ ១៩១៩ អាយុ ៣៣

វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តស្វាយ ឃុំសៀមភាប ស្រុកសៀមភាប ខេត្តសៀមភាប ។

សញ្ញាប័ត្រលេខ ៣៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃឹម-ភៃ នាមឆាយា បញ្ញាសី កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៨២ ចុះថ្ងៃ ១១ កេីតខែអស្សុជឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ខៀវ-ផាន់ នាមឆាយា សុវណ្ណជាត កើតឆ្នាំ ១៩២៣ អាយុ ២៨ វស្សា ៤ ជាចៅអធិការ វត្តត្រពាំងថ្នាវ ឃុំពាមខ្ទីរ ស្រុកស្វាយភាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៣៨៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពុំ-ជា នាមឆាយា ជមត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៨ ជាចៅអធិការ វត្តត្រពាំងត្រាវ ឃុំញាវ ស្រុកស្វាយភាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៣៨៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាយ-វេស នាមឆាយា យសត្ថេរ កើតឆ្នាំច អាយុ ៦៣ វស្សា ៤២ ជាចៅអធិការ វត្តញាវ ឃុំញាវ ស្រុកស្វាយភាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៣៨៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពេជ-ខន់ នាមឆាយា តន្ធសារោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៦ ជាចៅអធិការ វត្តអង្គរំដួល ឃុំក្បែត្រែ ស្រុកស្វាយភាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៣៨៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
សុខ-ឆុត នាមឆាយា ធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៨
ជាចៅអធិការ វត្តក្តីកណ្តាល ឃុំក្បែត្រ ស្រុកស្វាយទាប ខេត្ត-
ស្វាយរៀង ។

សញ្ញាប័ត្រលេខ ៣៨៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
មាស-តន្ធ នាមឆាយា ពុទ្ធប្បញ្ញោ កើតឆ្នាំជូត អាយុ ២៩ ជាគ្រូសូត្រ
ស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៣៨៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
សុខ-ជា នាមឆាយា ពុទ្ធសរ កើតឆ្នាំជូត អាយុ ២៩ វស្សា ៩ ជា
គ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៨៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ហ៊ុង-អិន នាមឆាយា ញាណសរៈ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦
ជាគ្រូសូត្រស្តាំ វត្តខ្លួសារាម ឃុំស្វាយជ្រំ ស្រុកស្វាយរៀង ខេត្ត-
ស្វាយរៀង ។

សញ្ញាប័ត្រលេខ ៣៩០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ផៃ-ផុន នាមឆាយា វជិរប្បញ្ញោ កើតឆ្នាំវក អាយុ ២៩ វស្សា ២
ជាគ្រូសូត្រឆ្វេង នៅវត្ត ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៣៩១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ

ឥន្ទ - សុឹម នាមយាធា សុវណ្ណប្បញ្ញោ កើតឆ្នាំថោះ អាយុ ៥៨ វស្សា ៣៨ ជាចៅអធិការ វត្តខ្ពស់ពង្រ ឃុំគ្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឱក - ជា នាមធាយ ព្រហ្មរង្សត កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣៣ ជាចៅអធិការ វត្តកំចាយមារ ឃុំគ្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ វ៉ាម - សែម នាមធាយ សេមត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាចៅអធិការ វត្តស្វាយអង្គ ឃុំព្រៃ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត - ឡុក នាមធាឃោ ឥន្ទប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៧ ជាចៅអធិការ វត្តមុនីរតនៈ ឃុំសាំងហ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ធិត - ហេង នាមធាយ បញ្ញាវិសុទ្ធិ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្តស្វាយអាត់ ឃុំព្រៃ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ឹក - សីយ នាមធាយ៉ា សុធម្មោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។ (មានត)

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះតាមផ្លូវយ
អំពីពុទ្ធសាសនចក្រកម្ពុជ

ចលាចិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិតិភ័ទ្ធទន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
ចលាចិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា សួរ-ហាយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	- មាតិកា	ទំព័រ
មហា ទម-ណាត្រី	ពរិធម្មកាសិត	៣២១
លោក ជា-ជួន	ការធ្វើសំណង់ហួល, ជាមួង, និងសារុង.....	៣២៤
លោក ភ័ឃ-ប៊ុក ក្រមការ	សុភាសិតខ្មែរភាគទី ២ (តមក).....	៣៣១
ហ្លួងនិតិភ័ទ្ធមន្ត្រី ញ៉ុក-ថែម	ស័ព្ទបារាំងប្រែជាខ្មែរបន្ថែមតាមកម្មការរបៀបធម្មិ (តមក).....	៣៣៥
-	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក)..	៣៤៥
អ្នកនាយញ៉ាត្រែយ៉ាំងខង	រឿងកោតកុលកុមារ តាក្យកាព្យ (តមក)	៣៥៦
ផ្នែកសាសនា		
លោក ភ័ឃ-ប៊ុក ក្រមការ	ពន្ធអាស៊ីទ្យ (តមក)	៣៦៣
មហា ទម-ណាត្រី	ឱវាទកថា	៣៧៨
កំណត់ទំនៀមប្រពៃណីការណ៍		
ក្រសួងធម្មការ	បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី(តមក)...	៣៨៣
លោក ភ័ឃ-ប៊ុក ក្រមការ	កំណត់ស្តើងអំពីរឿងស្ថាបនាវិទ្យាស្ថានជួយសម្រាប់ សិក្សាភាសាខ្មែរ ឥណ្ឌូ នៅភ្នំពេញ.....	៣៩៨

មហាឱម - ណាគ្គី

ឃុំស្វាយចៅ ស្រុកសង្កែ ខេត្តបាត់ដំបង ថ្ងៃរៀបរៀង

អាភេក្ខប្បមា លាភា សន្តុដ្ឋិ បរមំ ធនំ
វិស្សាសា បរមា ញាតី និព្វានំ បរមំ សុខំ ។

ការនៅឯសង្ឃាសង្ឃាត់ខ្ពាត់ចាកពេគ ចាត់ជាជោគលាភលន់ពន់ពេកក្រៃ
ការមានពេគរុំរឹតឈឺពុំរៃ តែងជាភ័យចង្រៃនៃពួកជន ។
ការសន្តោសត្រេកអរតាមមានបាន ជាហេតុឲ្យកើតសាន្តសុខលើសលន់
ឲ្យចំរើនកើនប្រយោជន៍បច្ចុប្បន្ន ឲ្យសម្បូណ៌សម្បត្តិធនានា ។
ជាមង្គលដ៏ខ្ពង់ខ្ពស់ក្នុងលោក ជារបស់នៅកង់តពភព
អ្នកសន្តោសកង់សន្តានសព្វវេលា នឹងរួចទុក្ខទោសនានាជាមិនខាន ។
ឲ្យវឌ្ឍនាថាវរៈមិនថ្នាក់ចិត្ត ឲ្យប្រព្រឹត្តព្រះសទ្ធម្មមាំមួនបាន
ឲ្យសប្បាយទាំងកាយចិត្តឥតរំខាន ឲ្យក្សេមក្សាន្តបានសុខស្រួល
ជានិរន្តរ៍ ។

សេចក្តីល្មោកលោភលើសលើសចំនួន ខុសក្បួនជ្រុលជ្រួសហួសដើមទុន
ជាហេតុឲ្យកើតទុក្ខទោសទម្ងន់ ឲ្យក្តុកក្តន់ក្តៅក្តួលរំជួលចិត្ត ។
ឲ្យធ្លាប់ជាប់អំពើទាបភាពអាក្រក់ ឲ្យលួចឆក់ឆបោកទុច្ចរិត

ឲ្យក្រហាយក្រហល់ខ្លួនខ្លួនចិត្ត ឲ្យប្រព្រឹត្តទុច្ចរិតឥតអៀនខ្មាស ។
ការស្មាលស្មុំខ្លួនមេត្រីក្តីរាប់អាន ចាត់ជាញាតិសន្តានពន់ពេកណាស់
ការរាប់អាននាំឲ្យមានមិត្តភ័ក្តិគ្រាស់ ការវិស្សាសល្អវិសាលគួរនិយម ។
អ្នកជាខៃឲ្យប្រយោជន៍ខ្លួនជាញាតិ ញាតិបើឃ្លាតខ្លួនជាជាតិជនក្រៃក្រម
ការរាប់អានអាចធ្វើជនឲ្យជួបជុំ គួរអប់រមការរាប់អានឲ្យមានណា ។
ព្រះនិព្វានជាឋានសុខសប្បាយក្រៃ ព្រះនិព្វានគ្មានទុក្ខភ័យក្ស័យតណ្ហា
ព្រះនិព្វានគ្មានកើតស្លាប់កង់សង្សារ ព្រះនិព្វានគ្មានអាល័យចៃអាឡោះ ។
ព្រះនិព្វានសុខអនេកឯកអនន្តគ្ម ព្រះនិព្វានគ្មានចំពាក់ចាក់ខ្ទើសសោះ
ព្រះនិព្វានគ្មានស្រណោកសោកស្រណោះ ព្រះនិព្វានអស់សម្រែកស្រែកឃ្លានហើយ ។
ព្រះនិព្វានជាទីនៅនៃអរហន្ត ព្រះនិព្វានបុថុជ្ជនមិនឃើញឡើយ
ព្រះនិព្វានគ្មានជាតិជរាព្យាធិជាគ្រឿយ ព្រះនិព្វាននៅកន្លែយស្បើយ
ទុក្ខអើយ !!

សុភាសិត

๑ - នរជននឹងធ្លាក់ចុះថោកទាប ប្តូចំរើនខ្ពង់ខ្ពស់ឡើង ក៏ព្រោះកម្មរបស់ខ្លួនជាអ្នកបណ្តាលឲ្យប្រព្រឹត្តទៅ, ដូចបុគ្គលដីកស្រែក៏ត្រូវចុះទៅកាន់ទីទាប, បុគ្គលកកំពែងក៏ត្រូវឡើងទៅកាន់ទីខ្ពស់ ។

២ — របស់ដែលកម្មទំនុកបំរុងមិនចាំបាច់ឲ្យនរណាជួយថែរក្សា ក៏រមែងតង់រង់បិតនៅឋានៈ, របស់ដែលកម្មទម្ងាយទម្ងុះទោះបីនរណាជួយពិតក្បែរក្សាយ៉ាងណាក៏ដោយ រមែងវិនាសទៅជាល់តែបាន ។

៣— ពាក្យសំដីដែលគោលដោយប្រពៃត្រឹមត្រូវ សូម្បីអ្នកនិយាយជាកូនក្មេងក៏គួរស្តាប់ចាប់យកជាឧប្រតិបត្តិបាន តាលមិនយើញពន្ធឹព្រះអាទិត្យ ពន្ធឹប្រទីបធម្មតានឹងប្រើឲ្យជាគុណប្រយោជន៍មិនបានទៅឬ? ។

៤ — សេះ, សស្ត្រាវុធ, សៀវភៅ, ពាក្យសំដី, ពិណ, ប្រុស, ស្រីនឹងភ្លើងដែលនឹងប្រើបានល្អ ឬ មិនល្អក៏ស្រេចនឹងវិធីការរបស់អ្នកប្រើ ។

៥ — តាលយើញសេចក្តីវិបត្តិធ្លាក់ដល់នរណា សូម្បីគេមិនអង្វរកពឹងពាក់ ក៏គួរកុលបុត្រអនុគ្រោះប្រាប់ឲ្យដឹងខ្លួន នេះឯងជាគុណសម្បត្តិរបស់អ្នកល្អទាំងឡាយ ។

៦ — អ្នកដែលគ្រោធដោយមានហេតុផល តាលកំចាត់ហេតុផលដែលគ្រោធនោះចោលហើយក៏ស្ងប់ដោយរហ័ស តែអ្នកដែលមានចិត្តគ្រោធដោយប្រាសចាកហេតុផល ·នរណានឹងធ្វើយ៉ាងណា ទើបនឹងលួងលោមគេឲ្យត្រេកអរបាន? ។

៦ — នរៈណាមានប្រាជ្ញា នរៈនោះក៏មានកំឡាំង នរៈណាមិនមានប្រាជ្ញា នរៈនោះនឹងបានកំឡាំងមកអំពីទីណា? ចូរមើលរាជសីហ៍ដែលមានខ្លួនធំ ហើយក៏ចាញ់កង្កែបដែលមានខ្លួនតូច ។

ការធ្វើសំពត់ហូល, ជាអ្នកនិងសារុង

របស់ ជា - ជួន ឃុំបឹងគ្រំ - ស្រុកល្វាឯម - ខេត្តកណ្តាល

(រឿងលេខ ៣)

.....

នៅស្រុកខ្មែរ មានបែបដម្បាញសំពត់, ផាមួង, ហូល, សារុង ព្រៃលាត ជាដើម ។ បែបនេះនៅស្រុកខ្មែរយើង មានច្រើនកន្លែងណាស់ មានស្រុកហ៊ាទី, ច្បារអំពៅ, តាខ្មៅ, ថ្កូវ, បឹងគ្រំ, ល្វាស, ព្រៃកវៃ, ព្រៃកក្រូចជាដើម ។ ឯអ្នកប្រើនោះតែងស្ទើរតាក់សឹងគ្រប់គ្នាក្នុងស្រុកខ្មែរ ចែមទាំងមានកេរ្តិ៍ឈ្មោះល្បីទៅដល់ប្រទេសក្រៅផង ។

គ្រឿងទុសម្ភារៈបែបដម្បាញនេះ គឺកី, រហាត់, អាក់, អង្គឹង, បំពង់, ឈើអន្ទង, ត្រល់, ខ្នារ, ឈើពាក់ ។

មុនដំបូងយកសូត្រជាក់ទឹងអាក់ អាក់នោះមានមេបញ្ជ្រាពីរកំពស់ ៣ តឹក ។ តួអាក់មានសណ្ឋានដូចដុំរទេះ មានមេសណ្តាក ១ ទឹង ១ តឹក បណ្តោយ ៤ តឹក ដើម្បីឲ្យទឹង ។ លុះពាក់រួច គេប្រមូលស្រាវរើសមុខ គឺកេះក្រមវជែលត្រឹមៗ ចេញ រើសសរសៃតូច-ធំ កណ្តាលណាតូចជាក់ដោយតូច ធំជាក់ដោយធំ កណ្តាលជាក់ដោយកណ្តាល ។ រួចយកទៅជាក់រហាត់ខ្នារជាក់បំពង់ ។

រហាត់– រហាត់នោះមានមេសណ្តាក ១ ច្រវែង ៥ តឹក បន្ទា ៥ ហ៊ុន ទោល ៣ ហ៊ុន មេទឹង ១ បន្ទាទោលដូចគ្នា ។ គេជាប់បញ្ចុះ

មេខាងលើទៀត ។ ស្ងោរហាត់ខោះផ្លែអំពិលឬស្សី គេយកឫស្សីពីរសាច់ បិតឲ្យសំបែត ស្រួចចុង កណ្តាលធំ ស្ងោរហាត់ទាំងអស់ ៨ គេដាក់ ៤ ម្ខាង។ យកខែ្សផ្តៅបិតឲ្យភ្ជាប់គ្នាប៉ុនគ្រាប់ត្រសក់យកមកចាក់តែឲ្យតឹងកោង ដាក់ត្រៀវឲ្យវិល ដាក់លើមេបញ្ឈរពីរខោះ ដើម្បីពាក់សូត្រខាងដាក់បំពង់ ។

បំពង់គេកាត់ឫស្សី ១ សាច់ បណ្តោយពីរតឹក ទំហំ ៥ ហ៊ុន មានកងមូល រវៃរវិលស្រាវពីរហាត់មកដាក់បំពង់ លុះខាងដាក់បំពង់រួចហើយយកទៅរវៃឲ្យភ្ជាញ់ ប្តូរវៃបញ្ចូលឲ្យត្រូចជាមុខពីរ ឬមុខបី រួចយកទៅពាក់ដាក់កុងឲ្យជិតចុំខ្លួនសាច់សូត្រចុងប៉ុន្មាន ។ រួចស្រាវយកទៅប្រមោក ។ ប្រមោកគឺគេយកទៅលាងទឹកក្តឹងឲ្យជ្រះក្អែល ឲ្យសស្អាត ទើបយកទៅជ្រលក់ល័ក្ត ។ ពេលជ្រលក់ត្រូវតម កុំឲ្យមានមនុស្សស្រីមានផ្ទៃពោះមកមើល តែមើលឃើញសូត្រខោះនឹងធ្លុកមិនជិតល័ក្ត ។

វិធីតម — ពេលដែលរៀបជ្រលក់ល័ក្តត្រូវធ្វើបន្ទប់ ឬបិទចុំឆ្ងាយ កុំឲ្យជិត កុំឲ្យអ្នកដទៃមកជិត ពុំនោះសោតជ្រលក់ក្នុងផ្ទះក៏ប៉ាន ប៉ុន្តែហាមផ្តាច់មិនឲ្យមនុស្សស្រីមានផ្ទៃពោះមើលឲ្យសោះ ។ បើជាម្ចាស់ខ្លួនមានផ្ទៃពោះវិញមិនជាការខ្វាស់អ្វីទេ ។ ការជ្រលក់ល័ក្តមានពណ៌ផ្សេង។ គឺពណ៌ក្រហម គេជ្រលក់ល័ក្តក្រហម ពណ៌ស្វាយ គេជ្រលក់ល័ក្តស្វាយ ពណ៌ខៀវ គេជ្រលក់ល័ក្តខៀវ ជ្រលក់ដាក់ក្នុងថ្លាង ស្ងោរ

ជាមួយនឹងសាច់ដូរ ប្រយោជន៍ដើម្បីឲ្យចាំពណ៌កុំឲ្យហើរ ឬចេញលំពួ
រួចយកទៅខាងជាក់បំពង់យកទៅអន្ទង បំពង់នោះខាងឲ្យបានចំនួន ៤០
ទើបអន្ទង ។

ឈើអន្ទង - ឈើអន្ទងនោះ គេធ្វើមេពីរបន្លា ១ តឹក ទោល
៥ ហ៊ុន ប្រវែង ១ ម៉ែត្រ ជាប់ប្រហោងជាក់កូន ១៦ ម្ខាង ដូចជា
ធ្នេញរនាសដែរ មានឈើសណ្តែកជាក់ខ្លស់ចំកណ្តាល កុំឲ្យខន់ឬជាបបុះ
បានយកដើងម៉ា ឬ តឿល់ជាក់ខ្ទចំកណ្តាលទៀត ។

ឈើពាក់ - ឈើពាក់នោះ យកដើមពីងពង់ឲ្យត្រង់ល្អ គៀង
ជាក់ក្រវិលចំនួន ៤០ ក្រវិល ប្រវែង ១០ ម៉ែត្រ ចងឲ្យខ្ពស់ផុតក្បាល
យកមុខសូត្រដែលនៅនឹងបំពង់មកស៊កកុងក្រវិលនោះ ទើបទាញយក
មកចងនឹងកូនអន្ទង ជាក់ប្រែងយកទៅមូរ ។

ក្តារមូរ - ក្តារមូរបណ្តោយ ១ ម៉ែត្រ ៦ តឹក ទោល ៥ ហ៊ុន មាន
មនុស្សពីរនាក់កាន់ចុងក្តារម្ខាងម្នាក់ មានពីរនាក់ទៀត កាន់ជាមអូសនាំ
មុខកុំឲ្យសូត្រជំពាក់ មានម្នាក់កាន់ចុងសូត្រដែលលានោះ ទាញឲ្យតឹង
អ្នកមូរចេះតែមូរតាមអូសជាម អ្នកឈរទាញចេះតែទាញឲ្យតឹង លាមួង
ចំនួន ១០ ម៉ែត្រ មូរជុំវិញដល់អស់ ពីរនាក់ឈរកាន់ ទើបយកទៅ
ចាក់ធ្នេញត្រដូចស៊កកុងធ្នេញឈើ ។

ធ្នេញឈើ - ធ្នេញឈើធ្វើពីឫស្សី យកឫស្សីពុះឲ្យធំរាងស្តើង
ប្រវែង ១ តឹក យកទៅចងស្រែះនឹងខ្សែអំបោះមានសណ្ឋានដូចជាស្តឹត

សឹតថៃ ម្នាក់ចាក់ឆ្នេញ្រកដូប ម្នាក់ស៊ីកសរសៃសូត្រគ្រប់ចន្លោះឆ្នេញ ហើយទើបថ្លរ ពេលដែលថ្លរនោះ គេយកទៅដាក់ទឹងក៏ដែលសម្រាប់ត្បាញ ។

ក៏នោះមានគ្រឿងច្រើនយ៉ាង គឺមានមេសណ្តក ២ បណ្តាយ ៥ ម៉ែត្រ បន្ទា ១ តឹក ទោល ៥ ហ៊ុន មានដើង ៤ មុខពីរ ក្រោយពីរ កំពស់ពីដីប៉ឹតឹក មានមេចម្រឹង ៤ កំពស់ ១ ម៉ែត្រ មានមេខាងលើ ៤ ទៀត ធ្វើជារនេងឲ្យរឹង មានឈើ ១ ដាក់ទទឹងគេហៅថា "ភ" សម្រាប់ចងព្យរពីថ្លរមក មានឈ្នាន់ ៤ ខាងក្រោមសម្រាប់ជាន់ឲ្យជង្គរញែកហាសរសៃសូត្រអន្លង់ឲ្យប្រហោង ដើម្បីហ៊ុះត្រលត្បាញ ។

ត្រលំ ត្រលំនោះគេធ្វើអំពីឈើមានចំនួន ១ តឹកកន្លះ គេឈូសចុងដើមឲ្យស្តើងដូចជាមុខកប៉ាល់ ហើយគេលកចំកណ្តាល រួចគេយកជែកធ្វើត្រ ឬជែកវិធីតែតូចល្មមទៅបញ្ចុះដាក់បណ្តាយសាច់ត្រលំ ។ មានឈើទទឹងខាងចុង ១ មូលប៉ុនកដៃសម្រាប់ទាញតែពីក្តារមួយឲ្យតឹង ។

ពេលត្បាញ គេខាសូត្រដាក់ខ្នាតូចប៉ុនចង្កើះស៊ីកនឹងជែកដែលទៅកត្រលំ កាលណាចាក់ត្រលំគេជាន់ឈ្នាន់ឲ្យហា ទើបហ៊ុះត្រលំទៅ ហ៊ុះម្តងរួចចាក់តទៅទៀត ចាក់ទៅចាក់មកកង ១ ថ្ងៃបានប្រមាណ ៥ តឹកយ៉ាងលឿន ។ គ្រឿងជម្បាញនេះ មានកង់គម្ពីរធម្មបទដ្ឋកថាភាគ ៧ ទំព័រ ១៣ ខាងព្រះពុទ្ធសាសនា ។

មានសេចក្តីដំណាលថា មានកុលបុត្រម្នាក់នៅក្រុងសាវត្ថី ទៅបួសជាភិក្ខុ ឃ្លានាមបញ្ញត្តិថា "តិស្សត្ថេរ" ពេលគ្រោយមកលោកឃ្លានសំពត់សាដក ១ សាច់ក្រាស់ចំនួន ៨ ហត្ថ ក៏យកមកផ្តើនដល់អ្នកស្រីលោក ។ ឯអ្នកស្រីនោះជាស្រីឈ្លាសក្នុងវិធីត្បាញ នាងក៏គិតថា បងអញមិនសមបើប្រើសំពត់ក្រាស់បែបនេះសោះ គិតហើយក៏យកសំពត់នោះទៅបែកជាចំរៀកតូច។ ហើយបុកឲ្យម្អិតយកមកបោចច។ ហើយការ។ ហើយថ្លាវ។ ហើយអន្ធង។ ហើយត្បាញ កើតឃ្លានជាសំពត់មានសាច់ម៉ដ្តប្រវែង ៩ ហត្ថ ។

សំពត់ហ្វូល – របៀបធ្វើប្រដាប់ទាំងអស់ដូចគ្នានឹងសំពត់ជាមួងដែរ ឃើញប្លែកតែមានក្រឡាមានគោមតែប៉ុណ្ណោះ ។ ឯគ្រឿងដែលត់សូត្រខុសគ្នា សំពត់ហូលចង់គាតទើបឃ្លានគេដែលត់ជាគ្រោយ ចង់គាតនោះយកស្រទបចេកណាំព័ទមកសកឲ្យស្តើងប៉ុនកូនដៃ យកមកពុំសូត្រទុកឲ្យសល់ប៉ុន្មានដែលត្រូវការដែលត់ ធ្វើជាក្រឡា ជាក្រឡាគោម ។

សារុង – របៀបធ្វើដូចគ្នាទាំងអស់ ប្លែកតែក្រឡា គេអន្ធងមានធ្វាស់ក្រឡាផ្សេង មានមេកូន ឬសខ្មៅប៉ុណ្ណោះ ។

ព្រៃលាត – ព្រៃលាតនោះ របៀបធ្វើដូចខាងដើម គ្មានដែលល័ក្តខ្នេ គេធ្វើសូត្រសុទ្ធ ។

๑ - សេចក្តីអធិប្បាយអំពីសំពត់ផាមួង - សំពត់ផាមួងមានពណ៌ ៥ យ៉ាង គឺពណ៌ស្វាយត្នាំ ๑ ខ្មាញ់ក្តាម ๑ ពណ៌មាស ๑ ពណ៌ត្នួយលៀប ๑ ពណ៌ស្វឹកចេក ๑ ។ កាលណាគេអន្ទង់ស្វាយ គេចាក់ស្វាយទៅជាស្វាយត្នាំ, អន្ទង់ក្រហមចាក់ក្រហមទៅជាពណ៌មាស, អន្ទង់ក្រហមចាក់លឿងទៅជាពណ៌ខ្មាញ់ក្តាម, អន្ទង់ក្រហម ចាក់ខៀវទៅជាពណ៌ត្នួយលៀប អន្ទង់ខៀវ ចាក់ខៀវទៅជាពណ៌ត្នួយចេក ។

សេចក្តីពន្យល់អំពីសូត្រ - កង់សូត្រ ๑ ម្តី មានទម្ងន់ ๒ នាល កន្ទុះ យកទៅធ្វើបានសំពត់ ๔ ទាំងចាក់ទាំងអន្ទង់ កង់សំពត់មួយ ។ ប្រវែង ๓ ម៉ែត្រ ទទឹងធ្មេញឈើ ๑ ម៉ែត្រ ក្រាស់ស្តើងស្រេចតែអ្នកធ្វើ បើចង់ឲ្យក្រាស់គួបមុខពីរ គឺរៃសូត្របញ្ចូលពីសរៃសទើបក្រាស់ បើចង់ឲ្យស្តើងអន្ទង់ ๑ សរៃស ចាក់ ๑ សរៃស ។

๒ - សេចក្តីអធិប្បាយអំពីសំពត់ហូល - សំពត់ហូលមានក្រឡាច្រើនបែប គឺក្រឡាផ្កាយព្រឹក ឆ្កាមេស ។ល។ កង់សូត្រ ๑ ម្តីធ្វើបានសំពត់ហូល ๘ ទាំងចាក់ទាំងអន្ទង់ បណ្តាយ ๑ ម៉ែត្រ ๙ តឹក ទទឹងធ្មេញឈើ ๘ តឹក ។

๓ - សេចក្តីអធិប្បាយអំពីសារុង - សារុងគេជ្រលក់សូត្រច្រើនពណ៌ក្រហម - លឿង - ខ្មៅ - ខៀវ ទុកឲ្យសខ្លះពេលដែលអន្ទង់ ជួនកាលមេអមសខ្មៅ ជួនកាលជាក់មេអមខ្មៅ - ខៀវ ធ្វាស់

ក្រឡាតាមចិត្ត អ្នកជម្លាញស្រឡាញ់ ឬនិយមតាមអ្នកស្រុកគេប្រើ សព្វថ្ងៃគេសន្មតឲ្យឈ្មោះតែពីរ គឺសារុង៨ពណ៌ ១ សារុង៨ស ១ ។ ក្នុងសូត្រ ១ ម៉ឺ ធ្វើបានសារុង ៩ ទាំងចាក់ទាំងអន្ទង បណ្តាយ ១ ម៉ែត្រ ៨ តឹក ធ្មេញឈើ ១ ម៉ែត្រ ១ តឹក ។

៤ – **អធិប្បាយអំពីត្រែលាត** – គឺគេធ្វើសសុទ្ធ ដួនកាលមានផ្លាខ្លះតែសដដែល ទើបគេយកមកជាន់មាក់ក្រឿឲ្យភ្លៅ ធ្វើជាសំពត់ស្រី។ ក្នុងសូត្រ ១ ម៉ឺ ធ្វើបាន ២៥ ម. ទាំងចាក់ទាំងអន្ទង ។

រឿបៀបធ្វើសូត្រអស់តែប៉ុណ្ណេះ ខ្ញុំបានខ្ជាប់ធ្វើផ្ទាល់ខ្លួន ចេះគាំងពីឪពុកខ្ញុំមកដរាបមកដល់សព្វថ្ងៃនេះ ខ្ញុំធ្វើរបៀបនេះជាមួយនឹងម្តាយខ្ញុំ សូម្បីតែក្បាញក៏ខ្ញុំចេះដែរ ។

កាលបើក្រមជំនុំទំនៀមទម្លាប់ មានសេចក្តីសង្ស័យ សូមទៅសួរខ្ញុំបាទចុះ ខ្ញុំបាននឹងដំរាបតាមចេះចាំដោយសព្វគ្រប់ ។

ចប់របៀបធ្វើសូត្រតែប៉ុណ្ណេះ

បណ្ឌិតវគ្គ (ក)

៣១ – ការដំនូញជាប្រទីបពួកពាណិជ ក្រុមសង្ឃកិច្ចមានប្រទីបគឺធម្មា កសិសង្គ្រាមជាប្រទីបពួកយោធា ច្បាប់មាត្រាជាប្រទីបចៅក្រម ។

៣២ – លោកធ្វើមាត់មួយម្ខាមដែលជប់ សង្ឃារច្បាវឆ្កែសត្វប្រដៅ ត្រូវដែលធ្វើការជាន់ចៅរ៉ៅ មិនត្រូវនៅស្ងៀមកើតជាមនុស្ស ។

៣៣ – ការហាត់ច្បាប់ប្រាណ ស្មាធ្យាយលំអាន គិតគួរច្បាប់ចិត្ត តែប្រែចម្រើន ច្បាប់ជាតិក្រមក្រិត្យ រួមមូលមួយមិត្រ ពិតច្បាប់សាសនា ។

៣៤ – សុនខតែពូកែបស្សាវៈ ចង្កឹមនខៈ ពូកែខាងខ្លា មាន់ជល់ពូកែឆ្មាលប់សោតណា គំនិតប្រាជ្ញពូកែខាងមនុស្ស ។

៣៥ – ផ្លូវវែងប្រែឰ ធម្មជាតិលោកិយ ប្រែតាមសង្ខារ ស៊ីវិល័យប្រទេស អាទិត្យចន្ទ្រា ចាស់ប្រែកុមារ រកធម្មាពិត ។

៣៦ – បុង្គកុលាប តែងមានបែបភាព បង្ខាស្រួចមុត សត្វមនុស្សកូមិកព មិនបានសុខសុទ្ធ ចៀសទុក្ខមិនផុត កុំឲ្យប្រមាទ ។

๓๗– បណ្ឌិតព្រឹទ្ធាចារ្យ បុរាណាបមកាល ប៉ាត់ឈ្មោះចក្រពឡ ឬមាននាមលុះសព្វថៃ្ង លោកជាស្រែវិទ្យា មានគុណថៃ្ងប្រសើរពិត ។ ប្រាសាទមានតួចធំ អភិរម្យតាមគំនិត បុរាណយល់ទិមិត្ត មានឆ្វាយជិតទុកស្នាដៃ រូបកាយជាអនិច្ច ប៉ាត់អាត្មាសូន្យគ្រប់ថៃ្ង តែនាមគោត្របច្ច័យ ទុកនិស្ស័យឲ្យប៉ាត្រកាយ ។

๓๘ – មនុស្សចាស់ក្មេងកុំប្រមាទ ក្មេងទំនងាត ចាស់កុំម៉ើលងាយ ។ ក្មេងគោរពចាស់លោកថាយ ថាអាចពណ្ណាយ . ក្មេងនាំលោកយ ។ ក្មេងទំរៀនសូត្រឃ្មាតខ្ជិ ចាស់ខំពោលស្តី ថាវាស្មាតាប ។ តាមពិតត្រូវគិតតាមការ បុណ្យក្មេងខ្ពស់ជាប់ សឹងស្មានពុំត្រូវ ។

๓๙– ខ្សែតែខ្លាំងជាប់ ពត់រុក្ខាស្រែច ខ្លាំងឫកខ្ពាត់ខ្ពាយ ត្រង់ការពត់មនុស្ស ខ្លាំងទុក្ខអន្តរាយ ពត់ចិត្តមិនងាយ ក្មេងស្រួលពត់ចាស់ ។

๔๐ – មានហេតុមានផល សង្ក្រាមសាកល កើតឧប្បាទាន អគ្គីឆាបឆេះសម្រាម់ប្រធាន ភ្លាយោបក់ចាន ស្ទឹកឈើរីរក់ ឬបបុណ្យគុណគោស កសាងតាមថ្នាក់ រូបល្អសមស័ក្តិ ដូរតែកាន់សីលា ។

๔๑ – ខ្ពស់ណាស់ឃើញដី ទាបណាស់មេឃស្តី ច្រែនណាស់ព្រួយទុក តិចណាស់ព្រួយរក តូចណាស់ឃើញមុខ ហត្ថីសក្តក ធំឃើញស្រមោច ។

៤២ — កូនដ៏ឃើញប្រាក់ កុំឃើញកូនចក្រ កូនជាតិសត្រូវ
កូនរូបឃើញចិត្ត ឃើញពេជ្រសិលា ១ខ្នងវិបស្សនា ចិត្តានិព្វាន ។

៤៣ — មានប្រាក់ចេះចាយ ចេះធ្វើមានចំណាយ មានមនុស្សចេះប្រើ
មានជាតិចេះសូន មានស្ងាបចេះហើរ ចំណេះចេះស្ទើរ តែងជិះកងឆ ។

៤៤ — ពួជហង្សាមិនចោលស្រះឈូក មិនចោលប្រមាទជ្រកសូកវៈ
ពួជនារីមិនចោលការចោកជាក់ ពួជលាមកមិនចោលទុច្ចរិត ។

៤៥ — ពួជសត្វកសាង ព្រួយប្រាណដុសលាង ដូចការប៉ផ្ទៃដូង
ត្រូវបកសំបក ខាតច្រើនពេលមោ៉ង លោតុសរ៉ូង ទើបបានបរិភោគ ។
ស្អាងជាតិព្រួយគ្រប់ កំរិតប្រាត្ថ រលីរលែចយថោក ការប៉ដូងមិនជាប់
គោកធ្លកសោយសោក សូមរលែកង់លោក ដំយជោគប្រាថ្នា ។

៤៦ — ស្រឡាញ់កុំសូមទ្រព្យប្រសើរ ពីក្មេីពួកម៉ាកនាំខូចចិត្ត
ប្រៀបយកព្រះខាន់តម្រង់ពិត តែងកគួរគិតក្រែយជីវ ។

៤៧ — ប្រាក់ចាយគង់អស់ ពោលពាក្យសប្បុរស ចាយក្រៃពន់ពេក
បើចាយខាងល្បែង ក្រមានអនេក វិទ្យាចេះប្លែក ចាយចែកនៅតែញ ។

៤៨ — បើចង់ធ្មីមៀន ឲ្យបកប្រឹតប្រែន សំបកចោលសិន
ទើបធ្មីសាច់ស រសផ្អែមឈ្ងុយក្លិន កុំធ្វើស្រែកន់ ធីទាំងសំបក ។
រហ័សណាស់ខាត យឺតយូរគង់ខូច គិតរួចសឹមរក ធ្វូវល្អអាក្រក់
គួរដឹងភាពច្បក លំបាកវែកចក ត្រូវស្គាល់សព្វគ្រប់ ។

๔๙ — ព្រលិតខ្មៅក្រហមត្រោតត្រោតត្រៅ បកសំបកទៅវែជាសផ្លែត្នោតស្រអាប់សាច់ក្នុងល្អ មានទឹកក្នុងកជាតិផ្អែមរស ។ គរសំបកគត្រឹមមិនស្អាត ក្នុងមានជាតិសសាច់សោតសោះ រូបអាក្រក់កុំមើលងាយមនុស្ស មានច្បាជ្ញាយសទុគ្គមក្រែ ។

๕๐ — អ្នកណាអួតខ្លួនថាច្បាជ្ញព្រោក តាមភាពប្រយោគល្ងង់លើសលុប អ្នកណានៅស្ងៀមក្លឹថ្លៃយប់ អ្នកឆ្លងគោរពចូលសាកសួរ ។

๕๑ — មនុស្សសត្វបក្សី នៅនាក្រុងវៃក្រ ធ្លាតជាឯស្រុកស្រែព្រោះមានសុវិលល័យ តែឯច្បាជ្ញគេចកែ បញ្ហាប្លួលប្រែ មានច្បាជ្ញាច្រើន ។

๕๒ — អ្នកណារៀនចេះក្បួនច្បាប់ច្រើន តែមិនត្រើនកិច្ចអាត្មា ប្រមាទមើលងាយការធម្មតា គិតថាតាបថោកច្រើនអត់ប្រយ ។ គេស្គាល់ច្បាជ្ញដោយការធម្មតា ប្រសើរអស្ចារ្យព្យាយាមកាយ គិតត្រូវធ្វើចំរើនផ្សព្វផ្សាយ វត្តស្រុកអាយមានកេរ្តិ៍ឈ្មោះ ។ ធម្មជាតិរបស់ងាយធ្វើមិនបាន ទៅចង់ប្លូរច្បាណាប៉ងចាក់ដុះ គ្រឿងចក្រយន្តវិលតាមល់ហោះ ដូចបុរសខ្វិនអួតចង់រត់ ។ បើឡើងវុក្ខាឡើងពីគល់ ឡើងផ្ទះមណ្ឌលជណ្តើរបត់ ត្រូវរៀនមោកខំកត់ ទើបច្បានកំណត់មើល សៀវភៅ ។

សព្ទានុក្រមខ្មែរ

របស់

គណៈកម្មការវប្បធម៌

ហ្លួងធិពន្ធមន្ត្រី ញាក-លែមរុបមួម

(ត្រឹម)

Crise ministérielle = វិបត្តិរដ្ឋមន្ត្រី-

Antipathi = វិសមានចិត្ត

(ឱ1 –2 48)

Inspecteur de l'Enseignement Primaire = អធិការបឋមសិក្សា

Inspecteur en chef de l'Enseignement Primaire = អធិការ-

នាយកបឋមសិក្សា

Inspecteur adjoint de l'Enseignement Primaire = អធិការ-

នាយករងបឋមសិក្សា

Inspecteur d'Education Physique = អធិការកាយសិក្សា

Directeur d'Ecole Primaire Complémentaire = ចាងហ្វាងសាលា

បឋមសិក្សា បំពេញវិជ្ជា

Mo iteur des Ecoles rurales = គ្រូបង្ហាត់សាលាជនបទ

Directeur d'Ecole Primaire Elémentaire = ចាងហ្វាងសាលា-

បឋមសិក្សាជាន់ដំបូង–

Moniteur des Ecoles de pagodes = គ្រូបង្ហាត់សាលាវត្ត

Moniteur de l'Enseignement technique (Ecole professionelle)

គ្រូបង្ហាត់សាលាទិកនិក (សាលាវិជ្ជាជីវសិក្សា)

Moniteur D'Education Physique = គ្រូបង្ហាត់កាយសិក្សា

Instituteur auxiliaire journalier = គ្រូបង្រៀនជំនួយទិនិក

Instituteur = គ្រូបង្រៀន

Education = ការហ្វឹកហ្វឺន, ការបង្រៀនប្រដៅ;
ការអប់រំ

Instruction = ការសិក្សា

Enseignement = ការបង្ហាត់, បង្រៀន

Moniteur = គ្រូបង្ហាត់

Instituteur = គ្រូបង្រៀន

professeur = អាចារ្យ, សាស្ត្រាចារ្យ

Maître = គ្រូ

journalier = ទិនិកជន

(27–2 48)

Certificat = វិញ្ញាបនប័ត្រ

Aptitude = សម្បទា

Brevet = ប្រកាសនីយប័ត្រ

Diplôme = សញ្ញាប័ត្រ

Certificat d'Aptitude Pédagogique franco khmer = វិញ្ញាបនប័ត្រ
គរុកោសលសម្បទា

Pour les instituteurs anxiliaires = សម្រាប់គ្រូបង្រៀនជំនួយ

Brevet d'Aptitude Pédagogique (Pour les instituteurs) = ប-
កាសនីយប័ត្រគរុកោសល (សម្រាប់គ្រូបង្រៀន)

Certificat de fin d'Etudes normales Cambodgiennes = វិញ្ញា-
បនប័ត្រចប់ការរៀនគរុវិជ្ជាខ្មែរ—

Certificat d'Aptitude à l'Enseignement Elémentaire Camdodgien (Pour les bonzes instituteurs) = វិញ្ញាបនប័ត្រសម្បទាសម្រាប់
ការសិក្សាជាន់ដំបូងខ្មែរ (សម្រាប់គ្រូបង្រៀនលោកសង្ឃ) ។

(1:—3 48)

Certificat d'Aptitudes aux fonctions de Directeur d'Ecoles d'Application ou d'Inspecteur des Ecoles de pagodes rénovées=
វិញ្ញាបនប័ត្រសម្បទាខាងមុខការចាងហ្វាង-
សាលាអនុវត្តន៍ឬអធិការសាលាវត្តទំនើបថ្មីៗ

Cours Enfantin = កុមារវិជ្ជាន

Cours Préparatoire = បឋមវិជ្ជាន

Cours Elémentaire = អាទិកជ្ឈាន

Cycle primaire Elémentaire = បឋមភូមិជាន់ដំបូង ๓

Cours Moyen 1er Année = មជ្ឈមជ្ឈានឆ្នាំទី ๑

— 2e — — ឆ្នាំទី ๒

Cours Supérieur = ឧត្តមជ្ឈាន

Cycle primaire complémentaire = បឋមភូមិបំពេញវិជ្ជា—

Equité = សមភាព

Iniquité = វិសមភាព

Homogène = ឯកត្តភាគ, សភាគ

Hétérogène = នានត្តភាគ, វិសភាគ

Impartial = គតិគមន៍ (មិនលំអៀង)

Partial = អគតិគមន៍ (លំអៀង)

Appliquer = អនុវត្ត

Application = អនុវត្តន៍

Rénové = បែបថ្មី—

(ร-ช—48)

Fonction = មុខការ, ដំណែង, ប្រតិត្តិការ

មុខត្រសួង,

Fonctionnement = ការប្រតិត្តិទៅ

Fonctionner = ប្រតិត្តទៅ

La saisine = តាហាបញ្ជា (សេចក្តីបង្គាប់ពីលោកចាងហ្វាងឲ្យរកហេតុ)

Prendre en considération = ទទួលពិចារណា

Enfin = ក្នុងទីបំផុតនេះ

Procédure = នីតិក្រម

(Le) procédé = វិធីធ្វើ

Carte de visite = នាមប័ណ្ណ

Carte d'Identité = ប័ណ្ណសំគាល់ខ្លួន (អត្តសញ្ញាណប័ណ្ណ)

Prestation en nature = តាវកាលិកប័ត្រធម្មជាតិ

Carte de rationnement = បរិភោគប័ណ្ណ

Carte d'alimentation = ភោជនិយប័ណ្ណ

Circulaire = សារពរ

Comité de solidarité = គណៈកម្មាធិការសាមគ្គីធម៌

(10 —3—48)

Vacance = វិស្សមកាល

Récréation = វិស្សមោកាស

Secrétariat du Gouvernement = លេខាធិការដ្ឋានៃរដ្ឋាភិបាល ។

Paria = បណ្ណាល (ឬ. បណ្ណាលី)

Repos = ការសម្រាក

Congé = ការឈប់សម្រាក

Loi de l'offre et de la demande = ច្បាប់ធម្មជាតិលក់ទិញ

Colonne du journal = ខ្នងសារពត៌មាន

5e Colonne = ជួរទី ៥

Le palais du gouvernement de la ville = សាលាក្រុង

Titre ចំណងជើង, ងារ, ឋានន្តរ

(23-3-48)

Editorial = វិចារណកថា

Cycle primaire supérieur = បឋមភូមិជាន់ខ្ពស់

1er année = ឆ្នាំទី ១

2e — ឆ្នាំទី ២

3e — ឆ្នាំទី ៣

4e — ឆ្នាំទី ៤

Enseignement secondaire moderne National = មធ្យមសិក្សា

បែបថ្មីសម្រាប់ជាតិ

Classe de 6e ថ្នាក់ទី ៦

— — 5e	— ๕
— — 4e	— ๔
— - 3e	— ๓
— 2e	— ๒
— — 1er	— ๑

Mathématiques élémentaires ou Philosophie — គណិតសាស្ត្រជាន់ដំបូងឬទស្សនវិជ្ជា

Commission = សគុណ (សម្រាប់ដំនួញ)

(Le 9—4 48)

Loi = ច្បាប់

Décret = ក្រឹត្យ

Décision = សេចក្តី (សម្រាប់គណៈរដ្ឋមន្ត្រី)

Arrêté = អនុក្រឹត្យ

Décision = ដីកា (សម្រាប់ចៅហ្វាយខេត្ត)

Ministère de l'agriculture = ក្រសួងកសិកម្ម

Bureau du personel = ប៊ុយរ៉ូបុគ្គលិក

(Le 13 - 4 - 48)

Grade = ឋានន្តរសក្តិ

Classe = ថ្នាក់

Cadre = ក្របខ័ណ្ឌ

Renaissance khmère = នេមរបជិការ

Décoration (Distincion honorifique = គ្រឿងឥស្សរិយយស—
Médaille de la reconnaissauce de la Nation aux membres de
l'Enseignement en or (en argent) មេដៃយមាស (ថ្នាក់) ជាតិ-
បជិការសម្រាប់សមាជិកសិក្សាធិការ

Palme de l'académie en or (en argent)— តាលប័ត្រមាស(ថ្នាក់)

Bureau de la comptabilité = ប៊ុយរ៉ូបញ្ជី

Comptable = អ្នកបញ្ជី

Secrétaire particulier = លេខាធិការឆ្មាល់

Secrétariat = លេខាធិការដ្ឋាន

Agriculture = កសិកម្ម

Agriculteur = កសិករ

Elevage = ការចិញ្ចឹមសត្វ

Eleveur = អ្នកចិញ្ចឹមសត្វ

Eaux et Forèts= គង្គា នឹងរុក្ខា

pêche = នេសាទ

Chasse = ប្រមាញ់

Chasseur = ព្រាន

Riziculture = កសិកម្ម

(Le 16 - 4 48)

Partisan = បក្សពួក

Règle = ក្បួនខ្នាត

Règlement = បទបញ្ជា

Document = ឯកសារ

Archive = ទីកន្លែងឯកសារ

Archiviste = អ្នកឯកសារ

Documentation = ការបង្ហាញឯកសារ

Etude = ពិនិត្យគ្រោងការ

Propagande = ឃោសនាការ

Domaine public = ដែនសាធារណៈ

Domaine privé = ដែនឯកជន

Bureau d'ordre = ប៊ីយ៉ូរបៀប

Arrivée = សំបុត្រចូល

Départ = សំបុត្រចេញ

Titre = ងារឋានន្តរ

Attaché militaire = សេនានុពន្ធ

Directeur des affaires politiques, administratives sociales, et culturelles= នាយកនៃកិច្ចការខាងនយោបាយ ខាងរដ្ឋបាល, ខាងសង្គមនឹងខាងវប្បធម៌

Salle de conférence = សាលាសន្និសីទ

Causerie = ប្រាប់កថា

Directeur des affaires économiques et financières = នាយកនៃកិច្ចការខាងសេដ្ឋកិច្ច នឹងខាងហិរញ្ញវត្ថុ

Directeur des bureaux administratifs = នាយប៊ុយរ៉ូរដ្ឋបាល

Inspection en chef de l'Enseignement primaire = មន្ទីរអធិការនាយកបឋមសិក្សា

Service d'ordre = ក្រមរបៀប

Réunion, Bibliothèque = សន្និប៉ាត, បណ្ណាល័យ

Etablissement scolaire = គ្រឹះហានសិក្សា

Bourses = អាហារូបករណ៍—

Secours scolaire = ជំនួយសិក្សា

Office des Etudiants Cambodgiens = មន្ទីរសង្គហនិស្សិតខ្មែរ

Propagande, Publication et organisation sociale scolaire = ឃោសនាការ, នឹងការរៀបចំ, - សង្គមសិក្សា

(Vendredi 30 - 4 - 48)

ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា

ហ្ជឹងទិពន្ធមន្ត្រី ញ៉ុក - ថែម រៀបរៀង

(ពុម្ព)

ឯសាសនាព្រាហ្មណ៍ដែលយើងបានពណ៌នាមកហ៊ាយខោះ គាល
បើពិគ្រោះមើលទៅ ក៏មិនឃើញអ្វីល្អវិសេសលើសលែងសាសនាដទៃ ។
+ ខ្លះទេ ប៉ុន្តែជាសាសនាដែលមិនចេះរលំរលាយផ្តួលមិនដួល ; ព្រះពុទ្ធក្តី
ព្រះមហាវីរៈក្តី ព្រះមហាហ្ម៉ាតក្តី ព្រះយេស៊ូក្តី ទុកជាបានផ្តាញ់ផ្តាល
គស៊ីនឹងសាសនាព្រាហ្មណ៍យ៉ាងណាក៏ដោយ សាសនាព្រាហ្មណ៍ទៅ
តែមានអាការខ្លាប់ខ្ជួនរឹងប៉ឹងមិនចាញ់ភ័ហិមាល័យឡើយ ហើយស្ថិតស្ថេរ
ផ្សាយទូលាយចេញទៅ រហូតមកដល់ក្រុងតម្ពធាដែលជាដែនព្រះពុទ្ធ-
សាសនាសុទ្ធ ។ ក៏នៅតែមានមនុស្សនិយមកាន់តាមជាច្រើនដែរ ។

តាំងអំពីលទ្ធិព្រះពុទ្ធសាសនា បានបែកខ្ញែកគ្នាជា ២ និកាយ
ហើយ ។ បានផ្សាយចេញទៅរហូតដល់ស្រុកចិនក៏ដោយ ចំណែក
ខាងតណ្ឌៀមានតែខ្លះៗគ្រាមចុះទៅ សាសនាព្រាហ្មណ៍តែឡប់ជា
ចំរើនរុងរឿងឡើងវិញ ហើយតមកគ្រាក្រោយនេះ ខាងលទ្ធិមហា-
យានបានចាត់បង្កើតលទ្ធិថ្មីឡើង ១ ទៀតហៅថា លទ្ធិ តន្ត្រិស្ម៌ ។

ឯលទ្ធិតន្ត្រិស្ម៌នេះកើតឡើងដោយគំនិតរបស់ពួកមហាយាន ដែល
យល់ថា បើបានបញ្ចូលទ្ធិអ្វីថ្មីឡើង នឹងធ្វើឲ្យសាសនាបានរុង

រឿង ១ ស្រេបក់មិនខាន ដូចជាការតាំងបង្កើតលទ្ធិមហាយានឡើង ជាការជួយឲ្យព្រះពុទ្ធសាសនាផ្សាយចូលទៅក្នុងស្រុកចិនបាន តែពួកនេះមិនបានពិចារណាឲ្យឆ្លៀងដែរថា ការណ៍ដែលលទ្ធិមហាយានបានផ្សាយចូលទៅក្នុងស្រុកចិនបាននោះ មិនមែនដោយអំណាចលទ្ធិមហាយានទេ តាមពិតនោះ ផ្សាយចេញទៅបានដោយអានុភាពរបស់ព្រះមហាក្សត្រទេតើ ! បើពុំជាគ្មានលទ្ធិមហាយាន ព្រះពុទ្ធសាសនាក៏នៅផ្សាយចូលទៅក្នុងស្រុកចិនបានដែរ ហេតុដូច្នេះការដែលតាំងលទ្ធិតន្ត្រិស្ម៌ ដោយយល់ថា នឹងធ្វើឲ្យព្រះពុទ្ធសាសនាចំរើនរុងរឿងជាការយល់ខុសទាំងស្រុង ។ មួយវិញទៀត លទ្ធិតន្ត្រិស្ម៌នេះ មិនមានធម៌អាចជាខ្លឹមសាររបស់ព្រះពុទ្ធសាសនាសោះឡើយ មានតែបញ្ញត្តពីវេទមន្ត-គាថា ហើយបញ្ញត្តថា បង្គាត់ក្មេងឲ្យឆ្លងផ្លូវពិធីយ៉ាងនោះ ។ អាចនឹងបានឡើងស្ថានសួគ៌ ប្រៅនិព្វានបានក្លាម ។ លទ្ធិនេះប្រហែលគ្នាយកឈ្នោះព្រះពុទ្ធសាសនាទៅស្រោបពុំព័ទ្ធខាងក្រៅសាសនាព្រាហ្មណ៍ ធ្វើឲ្យសាសនាត្រឡប់តាំងខ្លួនឡើងវិញបាន ។ ការដែលលទ្ធិតន្ត្រិស្ម៌-ផ្សាយចេញទៅបាន ដោយអាស្រ័យពួកក្សត្រវង្សរាជពុតជួយទំនុកបំ-រុងផង ហើយវង្សរាជពុតនេះ ជាអ្នកកាន់ខ្ជាប់ខ្ជួនកងលទ្ធិសាសនាព្រាហ្មណ៍ កាលបានចូលទៅគ្រប់គ្រងទៅខែត្រដែនណា ក៏ធ្វើឲ្យខែត្រដែននោះក្លាយទៅជាសាសនាព្រាហ្មណ៍ផង ដូច្នេះហើយទើប

ព្រះពុទ្ធសាសនារួញចុះយ៉ាត់ចេញទៅនៅខាងក្រៅ ។ គឺខាងកស្មីរ, នេប៉ាល, បង្គ្លឹ, ឧដ្ឋលង្កា ។ ក្នុងសេចក្តីតត់ហេតុរបស់ ព្រះសមណ យួនធាងបានសំដែងឲ្យយើញថា ក្នុងសម័យដែលលោកចូលទៅប្រទេស តុណ្ឌ្រៅនោះសូម្បីមានក្សត្រិយ៍ជាច្រើនអង្គ ទៅតែខ្លាប់ខ្ជួនក្នុងព្រះពុទ្ធ-សាសនាក៏ដោយ តែបណ្តាប្រជាជនត្រូវប់រាន់លទ្ធិសាសនាព្រាហ្មណ៍ឯតអស់ហើយ លុះមកដល់ព្រះពុទ្ធសករាជ ១២៩០ ព្រះវិស្ណុ នឹងព្រះសិវៈក៏ចំរើនរុងរឿងឡើងយ៉ាងក្រៃលែង ទើបនាំឲ្យលទ្ធិសាសនាហិណ្ឌូផ្សាយរីករាយចេញទៅក្រៅជាច្រើន ។

ឯពាក្យថា ហិណ្ឌូ ។ នេះ ជាឈ្មោះច្បាប់របស់សាសនាព្រាហ្មណ៍ ដោយមានរបៀបគោលថារឹតនឹងពិធីតែប្រែប្លែកពីលទ្ធិដើម របស់ព្រាហ្មណ៍ខ្លះដែរ យើងបានដឹងពីខាងដើមមកហើយថា សាសនាព្រាហ្មណ៍ជាន់ដើមមានព្រះធាតុខ្ពង់ខ្ពស់បំផុតតែមួយទេ គឺព្រះព្រហ្មតែកាលខាងព្រះពុទ្ធសាសនាមាន ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃជាគោលថារឹត ៣ ប្រការ ដែលហៅថា ព្រះរតនត្រៃឡើងហើយ ពាក្យថា ត្រៃរតន៍ក្លាយទៅជារបស់សំខាន់ លទ្ធិគ្រិស្តសាសនាក៏មានបញ្ញត្តិឡើងដែរហៅថា ត្រីនិតេ (Trinité) គឺព្រះបិតា, ព្រះបុត្រ នឹងព្រះវិញ្ញាណ ។ ឯសាសនាព្រាហ្មណ៍ក៏ចង់ឲ្យធំសំបើមឡើងដែរ ក៏ត្រូវតែមានដូចគេដែរ ទើបដំឡើងដំណែងព្រះវិស្ណុ ដែលជាន់ដើមជាព្រះ

ជាន់បន្ទាប់នោះឲ្យខ្ពស់ឡើងមក ហើយឃានព្រះសិរៈមកមួយអង្គទៀតរួម
គ្នាទាំង ៣ អង្គឲ្យឈ្មោះថា ត្រីបុរតិ ។ ឯព្រះសិរៈដែលយើងធ្លាប់ហៅ
ថាព្រះឥសូរនោះ តាមគម្ពីរវេទនិយាយថាជាអង្គជាមួយគ្នា ទុះដែល
មិនមែនជាព្រះឥណ្ឌៃប៉ែកខាងអារិយកសុទ្ធសាតទេ គឺពួកព្រាហ្មណ៍
ទៅយកមកអំពីពួកមិលក្ខៈហើយយកមកតាំងឲ្យធ្វើធំឡើង ដើម្បីប្រឡោម
ចិត្តពួកមិលក្ខៈឲ្យចូលកាន់សាសនាព្រាហ្មណ៍ច្រើនឡើង ហើយរួមជាវត្ត
វត្តន៍របស់ហិណ្ឌូ ទើបនាំឲ្យលទ្ធិសាសនាហិណ្ឌូផ្សាយចេញបានច្រើន
ហើយក្លាយទៅជាម្ចាស់ប្រទេសឥណ្ឌៀជាដំនួសព្រះពុទ្ធសាសនា ដែល
ធ្លាប់ចំរើនរុងរឿងមកពីដើម ហើយធ្លាប់ធ្វើបុណ្យ គុណទុកដល់ប្រទេស
ឥណ្ឌៀជាអនេកប្រការ ។ សាសនាព្រាហ្មណ៍កាលបានឈ្មោះថា
ហិណ្ឌូហើយ ក៏កើតមានលទ្ធិចំឡែកឡើងទៀតជាច្រើន ដូចជាហូជា
សិរៈលិង្គជាដើម ។ មានសៀវភៅរបស់វីនេរគ្រុសេត់ពោលទុកថា"
ឥណ្ឌៀដែលជាប្រទេសរបស់អ្នកចាជ ចំរើនរុងរឿងដោយសិល្បវិជ្ជា ជា
ដែនដីនៃព្រះសាក្យមុនី ជាមហាអាណាចក្ររបស់ព្រះចាទអសោក
នឹងព្រះចាទមិលិន្ទ កាលអស់បុណ្យមហាបុរសទាំង ៣ ហើយ បណ្តា
ភស្តុនាំគ្នាមកប្រជុំគ្រាបថ្វាយបង្គំលិង្គនឹងយោនីទាំងហ្នឹង ។

ឥណ្ឌៀភាគខាងត្បូង

គាំងអំពីវគ្គទី ១ ដល់មកវគ្គទី ៨ នេះ យើងនិយាយអំពីរឿងព័ត៌
របស់ឥណ្ឌៀភាគខាងជើង ដែលជាដែនដីរបស់ពួកអារីយកដោយច្រើន ។
ឯរឿងព័ត៌របស់ឥណ្ឌៀ នៅមានសេចក្តីសំខាន់ ១ ភាគទៀតគឺឥណ្ឌៀភាគ
ខាងត្បូង ពីដើមហៅថា ពួកមិលក្ខ: តែតមកសម័យក្រោយ ពួកនេះ
មានសេចក្តីចំរើនរុងរឿងឡើងច្រើនមិនចាញ់ពួកខាងជើងទេ ដូចមាន
រឿងព័ត៌តគួរពោលទុកដោយសង្ខេបដូចេ្នះ

ឥណ្ឌៀភាគខាងត្បូងដែលហៅថាដីកកំន ជាដែនដីរបស់ពួកមិ-
លក្ខ: នោះមានផ្ទៃដែនដីដោយច្រើនជាច្រើនក្រសរពេន ហើយដេរ
ជាសនៅដោយកំតូច-ធំ ពួកមិលក្ខ:ដែលបានពោលមកហើយ ជា
ម្ចាស់ដែនដីតណ្ឌៀនៅភាគខាងជើងអំពីដើម ហើយត្រូវពួកអារីយក:លុក
លុយដូចមានសេចក្តីក្នុងវគ្គទី ១ ហើយ ទើបនាំគ្នាថយចុះមកទិសខាងត្បូង
ហើយបានចាត់តាំងអាណាចក្រធ្វើង ។ អាណាចក្រទ្វះនៅតែឯងមិន
ទាក់ទងនឹងពួកអារីយក: មានអាណាចក្រទ្វះចង់ស្ថានមេត្រីនឹងពួកអារីយក:
ហេតុដូចេ្នះហើយ បានជាមានអាណាចក្រទ្វះដូចមហាភក្តិ បានទទួល
យកអារ្យៈធម៌មកអំពីពួកអារីយក:រក្សាទុកដោយល្អ មានអាណាចក្រទ្វះគឺ
តេលុគុ, ខមិឡ; ទឹងម័ស្សរ មានអារ្យធម៌របស់ខ្លួនឯងសុទ្ធ ។ មិនច្បូក
ច្របល់នឹងពួកអារីយក:សោះឡើយក៏មាន ។

អាណាចក្រផ្សេងៗ ខាងជើងកំនេះ មានឈ្មោះហៅម្យ៉ាងទៀតថា តវណៀខាងមាត់សមុទ្រ ។ ភូមិប្រទេសចែកចេញជា ៤ អន្ទើគឺ: ម៉ាល-វ:១ គនជ័វន:១ ជិកកំន ១ មិស្សរ ១ ។

ទៃត្រដែនម៉ាលវ:ជាទីលួលខ្ពស់ តាំងនៅក្នុងរវាងទន្លេយមុនានទឹងក្នុ វិនួយ:ទឹងក្នុអាវល្លី ជាទីមានផ្ទៃដីខ្ពស់ ។ ពាប ។ ចែកចេញជា ៣ អន្ទើ គឺទន្លេន, ក្បាលអានទឹងតណ្ឌ ។ ឯដែនដីគនជ័វន:នោះ តាំងនៅខាងជើងស្ទឹងនាវ៉ាជា ទឹងស្ទឹងសោន;ជាទីស្តុកស៊ៅដោយព្រៃព្រឹក្សា ហើយនៅទិសខាងកើតនៃដែនដីចំណែកនេះ ជាលំនៅរបស់ពួកគនជ័ ដែលជាមនុស្សព្រៃ ១ ពួករបស់តវណៀមានសំបុរខ្មៅដូចពួកណែគ្រី រហូតមកដល់សម័យនេះ ពួកនេះនៅតែសាត់ត្រាត់មិនមានលំនៅជាប្រាក់ហានឡើយ ។

ចំណែកឯដែនដីដែលហៅថា ជិកកំន សុទ្ធ ។ នោះជាទីតាសតេញទៅដោយភ្នំភូច ។ ទឹងជាទីលួលខ្ពស់នៅមាត់ទន្លេគោជាវ៉ាទឹងក្រឹស្ណា នៅទិសខាងលិចមានលួលខ្ពស់ ។ រហូតទៅដល់សមុទ្រអូម៉ាន ។ ក្នុងខែត្រដែនជិកកំនេះជាទីមានសត្វសាហាវនៅពាសពេញ មានស្រុកផ្សេង ។ ដូចនាសិក, ប៊ុណ: ទឹងសាត្រ: ក្នុងតំបន់អស់នេះជាដែនដីរបស់ពួកមហាភស្តូ ដែលពួកដីនៅក្នុងមានកំឡាំងមាំមួនល្អ ហើយជាគាហានដ៏អង់អាច ប៉ុនធ្លើការលុកលុយចូលមក ហើយចាត់តាំងវង្ស

ក្បត្តគ្រប់គ្រងទីផ្សេង ។ គ្រាតែទៅជាពួកដែលមានវិជ្ជីអំណាចដ៏ធំ សំបើមទៅដែនដីតណ្ហាគាគខាងត្បូងនេះ; ។

ពួកមហាក្សត្រនោះ ជាន់ដើមជាពូជពង្សពួកមិលក្ខសុទ្ធ តែអំណើះកាលតមក ជនពួកនេះបានទទួលការរៀនធម៌អំពីពួកអរិយកៈយកមកប្រើ សូម្បីការសាដែលប្រើសុទ្ធតែមានមូលមកពីសំស្ក្រឹត កាលបើនិយាយអំពីអក្សរសាស្ត្រ ពួកមហាក្សត្របានទាំយកមកអំពីអាណាចក្រផ្សេង ។ ខាងទីទំនាបជងទន្លេគង្គាទាំងអស់ ។ ខ្សែស្រឡាយពួកមហាក្សត្រនេះ មិនបានខោចំពោះតែងប៉ុណ្ណោះទេ ដែលជាកន្ទែងរបស់មហាក្សត្រសុទ្ធៗ ប៉ុណ្ណោះទេ ទៅមានហៀរចូលទៅក្នុងទីទួលខ្ពស់នៃម៉ាលវៈ ទឹងទីទួលខ្ពស់នៃគុនដ៍វនៈ ទឹងខាងទិសខាងកើតនៃទីទួលខ្ពស់របស់ដែនដីកព័នទៀតផង ។

ទីទួលខ្ពស់ទៅទិសខាងកើតដីកព័ននោះ ជាដែនដីរបស់ពួកតេលុគុ ដែលមានខ្សែស្រឡាយទឹងៈប្រកាសាមិលក្ខៈសុទ្ធ ពួកនេះបានតាំងទីលំទៅគ្រប់គ្រងដែនដីរកងទន្លេគោធាវីទឹងទន្លេកិស្ណា ។

ឯកូមិប្រទេសរបស់ពួកម៉ាស្សុរនោះ ជាទីខ្ពស់ៗ ខាបៗ ច្រើនបំផុត ទើបនាំឲ្យពួកម៉ាស្សុរអោចការពារ ទប់ទល់ការលុកលុយបានជានិច្ច ហើយពួកម៉ាស្សុរសោតទៀតក៏ជាពួកអ្នកចម្បាំងដែលខ្លាំងពូកែ ក្នុងគ្រាដែលអង់គ្លេសចូលមកដាយយកតំណែ្នាះ អង់គ្លេសគោងចូលពេល

វេលាជាយូរ ទើបប្រែកម្លាំងជ្រើនទម្រាំតែរាយយកវិទ្រនេះបាន ។ បណ្តាអ្នកស្រែកមើសូរនោះហៅឈ្មោះថាម៉ូរីយាងប្តូការនេះ ជាពួកតេលុគុទើងពួកទមិឡផ្សំលាយគ្នា ។

តាំងអំពីខ្លួនខ្ពស់ជាដែនដីរបស់ពួកមើសូរនេះទៅ មានស្ទឹងមួយហៅថា គារើ ដែលមានឈ្មោះមា្យ៉ាងទៀតថា "ទន្លេគង្គាខាងក្រោម" នៅតំបន់នេះមានស្ទឹងវែកជាច្រើនទាំងផ្លូវផែនដីមានដីជាតិល្អ មានទីធំនាប ១ អន្លើហៅថាការខ្ទុត ជាតំបន់ដែលពួកទមិឡនៅ ។ ឯពួកទមិឡនេះជាពួកដែលមានសេចក្តីចំរើនរុងរឿងបំផុតក្នុងចំណោមមិលក្ខៈ ជាពួកដែលស្ងាត់ជំនាញខាងការជាំជំណាំ ជាជាងដែលមានថ្វីដៃពូកែឆន ។ ភាសារបស់ពួកទមិឡជាភាសាថ្លៃថ្លាមានពាក្យនិយមប្រើច្រើន រហូតដល់សាសនាដែនិស្ក័ក៏បានប្រើភាសានេះ សម្រាប់ចារឹកគម្ពីរដីភាក្នុងសាសនាផង ។ ពួកទមិឡមានកវីដែលបានទទួលសេចក្តីសរសើរថា ជាកវីពូកែបំផុតរបស់ឥណ្ឌាម្នាក់ ឈ្មោះតិរុវ៉ាលុវ៉ា ។

តាំងអំពីដើមមក អាណាចក្រទាំងឡាយដែលតោលមកហើយនេះនៅក្នុងហានៈ ដែលមានសេចក្តីចំរើនតិចជាង ឬនៅជាវៃព្រៃនៅឡើយ ចាញ់អាណាចក្រខាងជងទន្លេគង្គាឆ្ងាយណាស តមកហូតដល់រវាងពុទ្ធសករាជ ១២០០ ឆ្នាំទើបបណ្តាអាណាចក្រនៅចំណែកនេះ ចាប់ផ្តើមប្រឹងវែងខ្លឹឃ្មាតផ្លូវខ្លួនឲ្យបានចំរើនឡើងស្មើនឹងពួកខាងជើង ។ ការ

ដែលពួកមិលក្ខ:មានសេចក្តីចំរើនឡើងស្មើនឹងពួកជនទន្ទេគង្គា ឬថាពួកមិលក្ខ:មានសេចក្តីចំរើនស្មើនឹងពួកអរិយកៈនោះ ព្រោះអាស្រ័យអាណាចក្រមហាក្សត្រជាសំខាន់ ។

អាណាចក្រមហាក្សត្រនេះ គាំងនៅក្នុងខែត្របុមរៃយសព្វថ្ងៃនេះ ពីដើរក្សត្រដំបូងដែលបានគ្រប់គ្រងអាណាចក្រនេះហៅថា វង្ស គាលុក្ស: គាំងទីក្រុងនៅស្រុកវ៉ាតាប៊ី ក្សត្រវង្សនេះគាំងឡើងកាលពីពុទ្ធសករាជ ១១០០ ដោយក្សត្រពីរជាតិ ១ អង្គព្រះនាម ព្រះបាទបុលិកេសីមទី ១ ក្សត្រអង្គនេះបានរួបរួមខែត្រដែនធ្លេង ។ ពីឆ្នាំកំណាចរបស់មហាក្សត្រឲ្យបានធំចំរើនឡើង លុះមកដល់ពុទ្ធសករាជ ១១៥៣ ព្រះចៅផែនដីគ្រងរាជ្យជាដំណតមក ទ្រង់ព្រះនាមថា បុលិកេសុីមទី ២ ពីឆ្នាំកអាណាខែត្រឲ្យរីកធំតទៅទៀតរហូតអស់ដែនដីកក័ន ។ ឯគូប្រណាំងប្រដែងយ៉ាងសំខាន់របស់មហាក្សត្រគឺពួកបាលវៈ ជាប្រជាជន ១ ពួកដែលមិនទាន់មានអ្នកចេះពង្សាវតារជាតិនេះពិតប្រាកដទេ គ្រាន់តែយល់ថាជាពួកប៉ាវ័ធ ដែលបានលើកគ្នាចេញមកតៗគ្នា ហើយនៅទីបំផុតបានតាំងទ្បាក់ជ្នាន្ធខ្ញាប់ខ្ជួននៅស្រុកការន័ត ។ ព្រះបាទបុលិកេសុីមទី ២ ទ្រង់មានជម័ជំនះពួកបាលវៈដណ្តើមយកខែត្រឆ្ងិ ជិតមាសុលិបៈតំម ទើបតាំងពង្សវង្សតូច ១ វង្សឡើងថ្មីទៀត ជាសាខារបស់វង្ស គាលុក្ស:ឲ្យឈ្មោះថា " គាលុក្ស:ខាងកើត " កាលពុទ្ធសករាជ ១១៦៣ ។

ព្រះបាទបុលិកេសុមទី ២ នេះ ឆ្លាប់ឆ្លើយមរ៉ាំងទប់ទល ព្រះបាទសិលាទិត្យ កាលជិតផុតរជ្ជសម័យរបស់ព្រះអង្គនោះ ពួកចុលវៈខាងស្រុកការនតំបន់ គ្នាបះបោរឡើងបំផ្លាញកងទ័ពរបស់ព្រះអង្គអស់ទៅជាច្រើន តែអ្នកទទួល គ្រងរាជសម្បត្តិតមកទ្រង់ព្រះនាម ព្រះបាទវិក្រមាទិត្យៈទី ១ បានច្បាប ច្បាំងពួកចុលវៈបានឡើងវិញទៀត ។ ពុទ្ធសករាជ ១២៨៥ រាជវង្ស គាលុក្យៈ ដែលគ្រងក្រុងវាតាប៉ុក៏អស់អំណាចទៅ ហើយមានក្សត្រ ១ អង្គទៀត ព្រះនាមវង្សវ្រះស្តេកុត ឋានគ្រប់គ្រងខែត្រមហាវាស្ត្រហូតដល់ ព្រះពុទ្ធសករាជ ១៩១៦ ព្រះរៀវដែនជំអង្គទី ២ នៃរាជវង្សនេះព្រះនាម ព្រះបាទក្រីស្នាវាងទី ១ ឋានកសាងវិហារតែលាសឡើងនៅស្រុកអិលូវ៉ា ជិតបុមបៃយ៍ រាង់ពុទ្ធសករាជ ១៣០៣ ដែលជាវត្ថុសំខាន់ ១ នៃសិល្បៈ កម្មរបស់តំណៀ ។ វង្សវ្រះរាជកុតនេះឯងដែលឋានបំផ្លាញអំណាចពួកចុល-វៈទៅ ហើយជាតិចុលវៈក៏សាបសូន្យអស់ទៅ ដោយអំណាចរបស់ វង្សវ្រះស្តេកុតនេះ ។ តែលុះពួកចុលវៈសាបសូន្យអស់ទៅហើយទើប ពួកទមិឡនៅតំបន់គោលៈ ក៏ប្រែក្លាយឡាំងពូកែជាជំនួសពួកចុលវៈ ឡើងវិញ ហើយចូលគ្រប់គ្រងខែត្រដែនការនត ហើយជាសត្រូវធំ នឹងមហាវាស្ត្រតទៅទៀត ។

លុះតមកដល់ពុទ្ធសករាជ ១៩១៦ ពួកក្សត្រវង្សគាលុក្យៈឋានតាំង ខ្លួនឡើងគ្រប់គ្រងខែត្រមហាវាស្ត្រឋានទៀត ហើយហៅវង្សក្សត្រដែល

តាំងខ្លើងចុំនេះថា គាលុក្ស:នៃកល្យាណ៏ ព្រោះឃាតតាំងពី កន្លងទៅស្រុក
កល្យាណ៏ ជិតបុមបៃយ៍ទៅក្នុងរវាងនេះហើយមានអំណាចរហូតដល់
ពុទ្ធសករាជ ១៦៧៣ ឆ្នាំគាលុក្ស:ក៏ឃាតធ្វើសង្គ្រាមនឹងពួកទមិឡ:តមក
ម្ខាងទាញម្ខាងឈ្នះ គឺរវាងពុទ្ធសករាជ ១៤៤០ ពួកទមិឡ:មានជ័យជំនះ
តែតមក ៥០ ឆ្នាំក្រោយទៀត រវាងពុទ្ធសករាជ ១៦០២ ពួកគាលុក្ស:
ត្រឡប់មានអំណាចកម្ចាត់ខ្លើងទៀត ហើយឃាតកំចាត់ពួកទមិឡទៅ
ខាងគោល:ឃានសម្រេច តែតមករវាងពុទ្ធសករាជ ១៦៩០ ឆ្នាំគាលុក្ស:
នៃកល្យាណ៏ក៏រឿរពេយទៅ ទើបតព័នោះមកទៀត ដែនជ័នេះក៏ធ្លាក់
ទៅខ្មៅក្រោមអំណាចពួកយាខវ: ដែលពីដើមជា សុភចំណុះពួកគាលុ-
ក្ស: ។ ក្ស តវឆ្នាំយាខវ:នេះ គួរកាប់ជាក្ស តវឆ្នាំទី ៤ ដែលទៅគ្រប់
គ្រងដែនមហាភស្តា តាំងអំពីនោះមក អំណាចរបស់ដែនមហាភស្តាក៏
ខ្លះៗ តាមឱយខ្លាយរៀង ។ ទៅ ហើយកម្ចាត់ពលំកំចយខ្លាយចុះ
ទៅដោយការសង្គ្រាមនឹងពួកមីសូរមិនឈប់ឈរ តមកក្នុងពុទ្ធសករាជ
១៨៦១ ក៏ធ្លាក់ទៅខ្មៅក្រោមអំណាចពួកអីស្លាម ។

ឥឡូវនេះ យើងនឹងសើរើនិយាយអំពីពួកទមិឡខ្លើងវិញ ។

ទៅខាងជើកបកាគខាងត្បូងនៃការខ័តនោះ ឃានអាស្រ័យនៅ
គារើរើធ្វើឲ្យទីជីមានជីរជាតិល្អ ជាដែនជ័ដែលពួកទមិឡចូលមកតាំងទៅ
តាំងអំពីរវាងពុទ្ធសករាជ ៥០០ មកហើយ ។

រឿងភោគកុលកុមារ

អ្នកឧកញ៉ាព្រះឃ្លាំង ខង រៀបរៀង

(តមក)

ខ្ញុំសូមក្រាបលាទៅ ផ្ញើរាជ្យនៅក្សត្រៃលោក្យថា ពុំចេះខ្ចីមេត្តា អត់ទោសខ្ញុំជាខ្ញុំ ។ ស្តេចស្តាប់ព្រះសុណិសា ក្រាបទូលលាក្រាបដោយដំ - ណើរនោះទើបបរម ក្សត្រាត្រាស់បន្ទូលថា ។ ម្ចៃបុត្របណ្តូល ចាមកទូលសុំក្រាបលា អាពុកតតបើថា បើកតាមត្រមចិត្តបំណង ។ ចូរចាយកមន្ត្រី សេនាតីអាយទៅផង កំដរបុត្រស្ងួនត្រង់ គ្រាន់ប្រយ័ត្នប្រយោជន៍ច្បាណ ។ ព្រះពោធិរង្គ្រិល ស្តាប់ហើយទូលទៅរ៉ឹងថ្កាន បពិត្រខ្ញុំសូមទាន សូមតែនាងនាថជាយា ។ ន្ទូវសេះអាជានេយ្យ ព្រះខ័នជ័យធសរច្ចា យកទៅផងអាត្មា ក្រែងក្រីក្រគ្រាន់ប្រស័យ ។ ស្តេចស្តាប់រាជបុត្រទូល ក្សត្រតស្ងួរត្រមព្រះទ័យ បើកបុត្រពីរច្បាថ្ងៃ ពុំឃាំងឃាត់តាមចិត្តា ។ ទើបព្រះវរជននី ទបបុត្រីសោយសោកា បន្ទូលឆ្លែឆ្លាំងថា ម្ចៃកូនស្ងួនសំឡាញ់ម្តាយ ។ នាងទៅនឹងស្វាមី ឃ្លាឃ្លាតទូរទីហានឆ្ងាញ ទៅនៅនគរនាយ ចូរឆ្ងិតឆ្ងល់ឆ្ងល់ស្មារតី ។ ប្រុងច្បាណក្រាបប្រណិបត្ត ព្រះរៀមរត្នជាស្វាមី តាមដោយក្រិត្យក្រមស្រី កុំឲ្យព្រួយព្រះចិត្តា ។ ហើយកូនកុំបោះបង់ ម្តាយលន់លង់យូរឃ្លាតឃ្លា ម្តាយមានតែនាងជា ថ្ងៃម

បណ្តែចបណ្តូលចិត្ត ។ នាងនាថសោតសង្វិនសោក សែនអាមោកអួលអាណិត អនាថពន់ពេកក្តាត់ តិតជនន៏ទូរបិតា ។ បន្ទោរទុក្ខស្រោលស្រែច ទើបសម្តេចព្រះរាជា ទូរនាងនាថលុតលា រំលែងមកមណ្ឌលទី ។ ផ្តែផ្តាំអស់បរិពារ ស្រីស្រង្គារស្នំនារី ទូរអស់មុខមន្ត្រីជ្រៀតនឹងស្តេចទៅទូរស្នាន ។ ស្តេចឲ្យយកពាជី ជាព្រះទីនាំងក្សត្រក្សាន្ត ចង់គ្រឿងសឹងមាសមាន ដំឡៃតតងគណនា ។ បង្ហៀរទូរឃ្លុំមុខខ្សែតែអុកសង្វិនសុវណ្ណា ភានជាប់មាសមុខក ភយរំលេចសឹងមណីរត្ន ។ ប៉ែកឈ្នាន់ខាន់ដ៏បចង់ ចន្ត្រែន៏ផងសឹងពិចិត្រ ខ្សែហាងគុមតែកែតែត ភ្លឺរុងរឿងសមសោភា ។ សំយាកសំយុងខ្សែ សោតសង្វិនតែសុវណ្ណាលួសលាយខែងទឹបជា ផ្កាដួងដាំសឹងពត់កាយ ។ ទើបក្សត្រពីរព្រះអង្គបែងចែងគ្រឿងពណ្ណរាយ រុងរឿងឆោមឆើតឆាយ ល្អលើសលែងទិវាករ ។ ស្តេចសៀតព្រះទម្រង់ ទំនង់ជ័យទ្រង់ធ្នូសិល្បសារ នាំនាងនាថបវរ ចាកមន្ទីរមណ្ឌលថ្ងៃ ។

បទអាគតិ

ក្សត្រក្សាន្តពីរពង្ស ល័ណាឡើងគង់ លើរាជមនោម័យ ត្រចង់ត្រចះ ល្អល្អះប្រពៃ ហាក់សុរិយោទ័យ ចរចូលចន្ទ្រា ។ គួរគង់បើកបរ ទីនាំងអស្សតរ លន់លឿនលីលា ចេញចាកអំពី បុរីរដ្ឋាឆ្ពោះទៅសីមា ពាក់ណាស៏ ។ ស្តេចដែរយមគា ចូលកង់អង្វា

ព្រៃព្រឹក្សទូទី លូតលាស់ផ្ទៃផ្កា ផលាពុំខ្វះ មានរសពិសី ពិសេសពិសា ។ ស្ពៃចដល់ព្រៃស្វាយ នាំនាងនោមធាយ ចរចុះយាត្រាព្រះនេត្រវៃ ទតព្រៃព្រឹក្សា សំណោះចរចា ច្រៀបព្រះប្អូនស្រី ។ ប្អូនមាសប្រុសើរ សូនអើយមាសម្រើល ស្វាយក្បាលដំរី ស្វាយដំពុះសេក ស្វាយចេកតន្លើយ ជិតស្វាយចន្ទី ជុះដោយពណ៌ក ។ ប្អូនមើលស្វាយមាស ស្វាយមីងដេរដាស មីងត្រុសសែដា មាក់ព្រូនស្វាយព្រៃ ក្រាស់ក្រៃត្រៀបត្រា ទាំងស្វាយរំពា ស្វាយរមៀតផង ។ មានស្វាយចន្ទុះ ស្វាយកណ្តុរជុះ ជាសដោយឆ្ងល់ ស្វាយសង្កើចឆ្អែះ ស្វាយសេះពង់ត្រង ស្វាយខាន់ស្ករធង ឃ្មោកតន្ទូលាំ ។ ខ្ទះពុំអន្ទង ខ្ទះជ្រុះបង់ខង ដោយដំណោកដាំ សេកសោតទ្រោះទ្រៀវ ខ្ចាខ្ចៀវនានាំ គ្នាហើរទៅពាំ ចាន់បរិភោគ្គា ។ ប្អូនមាសវរវង្ស មើលក្រូចមាក់ប្តង់ សម្រែសំសា ក្រូចចំនក្រូចចង សក់ធង់នានា ក្រូចឆ្មារក្រូចក្លា ច្រើនពណ៌ពេកក្តាត់ ។ មាសមើលក្រូចព្រៃ ជាពិដោរព្រៃ ខ្លូរក្រូចពោធិសាត់ ផ្ទៃពុំខ្លាល ចាសចាលច្រើនក្តាត់ ខ្លូរក្រូចឈើងសាត់ ក្រូចសើចក្រាស់ក្រៃ ។ មានចេកអំបូង ចេកឥតត្រយូង ខ្លូរចេកមហាថ្ងៃ ចេកខ្លួនចេកស្នែង ជុះឯងវិស័យ ចេកក្រូចកងៃ នាងខ្លួនចេកផ្ងារ ។ ចេកកាដសីហ៍ ជុះដោយពួលទី ចេកផេះមហា-ត្រ-កាលចេកលំភ្ជ ចេកចាក់នាគី ចេកស្នាប់មុខរាក់ ខ្លូរចេកពង់មាន់ ។

ដេរជាសដោយវៃព្រៃ ច្រងច្រាងច្រើនវៃក្រៃ មានថ្លែណាណាន់ ខុំខែង
រន្ធាល ច្រាសច្រាលច្រើនជាន់ ឆាដូរខែត្រចំណ្ងូ ដុះដោយពណិក ។
ស្តេចនូវជាយា ចេះផលាហារ ដោយជងមាគ៌ា មង្សុតគូលែន មំក-
ប៉ែនពុត្រា ខ្លាំងចាយស្រា លង់លុតពិលញ្ជោ ។ សាចសំរមាន់
មៀន មំកប្រាងខ្លួនេ ដូងខ្ទិះអំពៅ លាំងសាតសាវម៉ាវ បង្កាវបង្កើ
ត្រៀលត្រមែកក្តៅ សំពោចស្រគំ ។ ពោនតួចជន្ទស គុយកៀវត្រីង
ត្រុស ដុះដោយវៃពក្ត ផ្ទែច្រើនច្រាសច្រាល រន្ធាលខែងខុំ ពីរក្បែត
ត្តម ស្តេចសោយស្កប់ស្កល់ ។ ស្រែចស្តេចខ្លែងគង់ លើយានរ
ម-ង្គិលគាប់សួស្តីសល់ ត្រែចចរេខ្មៀតខៅ សំដៅដួចដល់ ឯលវែងយង់
យល់ សត្វសត្វមាមា ។ មើលមានគជសីហ៍ គជសិង្ហព្យគ្ឃ៍ ក្រាស់ក្រៃ
ត្រៀបត្រា កេសកោតកុញ្ជរ កេសរសីហា ឧសភង្គធុំកា - មិត្រមាំង
ត្មាតសី ។ ព្រោះវៃព្រមាំង រមាសខ្លីដាំង គោមៀមចាមរី កិលេន
លៀងកា ស្មាន់លាពាដំ ខនសិង្ហនសីហ៍ ដំរីខ្មោងខ្លា ។ ខន្សោង
ខន្សាយ ខន្សោងឈ្លូសទ្រាយ គោមហិង្សា ចចកស្វាស្វាន ប្រើស
ក្តាន់សុកក ឆ្កែត្រុលច័មា ពង្រុលលាក់មុខ ។ ល្ងីសំពោច
ឈ្លូសធ្នាប់ចាវោច កង្កែនកំប្រុក បង្កួយជាសស្ការ ពស់ចាន់ថ្ងៃខ្ចក
វៃវៀរសុក រកេន្ធនិត្យខៅ ។ ស្តេចយល់អម្រឹត កៀងគូគគីក
ស្លែរកេធីស្មៅ បើកបរំលែង ដល់ដងវៃត្រៃត្រា យល់បក្សាខៅ

បក្សីតាំងឡាយ ។ ហិចហើរតឿងឆាប ខន្ធេងខន្ធាប ខន្ធឹមរៀងរាយ ដោយមែកព្រឹក្សវៃព្រៃ ក្សត្រៃថ្ងៃពណ្ណរាយ បន្ទូលច្រាប់ច្រាយ ព្រះឫទ្ធិតំណា ។ សូនអើយមាសមើល បក្សាផងហើរ បង្កៀរឿងគ្នា សេកុសោមបណ្ដិត នៃបនិត្យសារិកា កែវកោកិឡា កុកក្រកគ្រោង គ្រែង ។ ដបលាយសៀនឃ្យៀន ជដេតជើងខ្ទៀន រន្ទេចព្រលេង ប្រមង់ពព្វាក់ ទ្រមាក់ភ្លៃខ្ទែង សំបុងពាក់កន្ទែង ដំដែកខ្ទុកខ្ទុ ។ សម្បុកទំពាំង ស្លឹកលោតជាចស្បាំង ខែលខេងហូពូវ ចចាតច្រៃឡ ព្រាបវៃព្រៃគូ កវែកស្រែកឈូរ ចាបពួកពូម៉ា ។ មាសមើលហែមហង្ស មយូរពេនពង់ ចាក់ចាន់ផ្លុំគា ជីវកជីវក ក្រៀលក្រាកក្រសា តាជក់អកអា - អូតនុឡស្ទឹក ។ ប្រចៀចចេកខុំ ចៀបក្រចាសត្តំ ពពួកពុះទឹក លលកលលេ រំពេប្រឹក មាន់ទោមាន់ទឹក ស្មោញចង្កឹតឡៅ ។ មាន់ព្រៃពស់វែក ត្រៃចៀកកំភែក ប្រហិតស្ងិតថៅ ល្ងាចេកប្រចៀវ ខ្ទៀខ្ទៀតាវើ ខីឧយមៀមខៅ ផ្ទីរចង្រៀលខ្ទង ។ ក្ងានក្ងោក កូប៉ោលតោក រនាលត្រយ៉ង សសេះសេះលាវ រង៉ាវ កកកង គេងកុកត្រសង ត្រសិតហើរហិច ។ នាងន្ទួនក្អែកក្អាត គូកគរលើងភ្នាត តុំត្រដៀវរុំច កង្កួចសករ ចាកក្រពាកស្ដួច - គោលិដ្ឋប្រពេច ខុងខោមទទា ។ បតាវចិន្ទោ អន្ទឹតកុលជោ អង្គួចតន្ទ្រោ សេកយារសេកអាត់ ច្រើនក្ដាត់ត្រៀបគ្រា ភូមីភូមា ត្រឹបតេសរភ្លឹ ។

ស្តេចទតចណ្តើរ ដោយផ្លូវដំណើរ ប្រាប់ព្រះប្អូនស្រី ទៃឆំបើកបរ
បវរតាជ័ ដល់ឆ្នេរដលធី លើសពក់ពុំជ្រៅ ។ ស្តេចបរធ្លាស់ឆ្ងន
សមុទ្រមួង ពីនោះទៀតទៅ យាត្រាត្រចត្រង់ ដម្រង់សំដៅ
ដល់ស្រុកលំនៅ ហានធម៌មាតា ។ ពីរពង្សក្សត្រៃ ចុះចាកអាជានេយ្យ
ឡើងលើគ្រីហា ជួនចាស់ស្រាក់ស្រួល សាកសួរក្សត្រា ស្តេចប្រាប់
ដោយនា ដំណើរការគល ។ សុះសព្វសេចគ្រប ជួនចាស់ស្តាប់ស្តេច
អវតធ្មឹមដល់ រួសរៀបអាហារ តស្តុការគោជន៍ផល ចូរយក្សត្រនិមល
តាំងពីរអង្គា ។ ស្តេចសោយស្កប់ស្កល់ ធុំនោមណ្ឌល ហានធម៌មាតា
លុះព្រឹកស្រាង៉ស្រេច ស្តែងស្តេចលាគលា ឆ្ពោះទៅចំការ ទីដែល
និត្យនៅ ។ អ្នក សុកផងយល់ ក្សត្រៃនិមល ទូរព្រះប្អូនទៅ
ទ្រង់គ្រឿងខ្ទោល ច្រាសច្រាលដ្ឋិនផ្តៅ តូរគង់នែបនៅ លើសេះ
អាជានេយ្យ ។ សឹងគន់គិតឆ្ងល់ ថាចោគោគកុល ទូគិតក្រៃក្រ
ជានសេះពីឯណា សោកាប្រពៃ តាំងគ្រឿងមាសមៃ ថ្លៃឥតគណនា ។
សឹងសរសើរសេរ្ញ ពុះលេចដងដល់ គាមគោជកជា មេស្រុកកំណាច
គិតកាចឫស្យា ចាំបងរវេរ នឹងព្រះពោធិ ។ ដើរមកមើលយល់
ក្សត្រៃនិមល ទូរនាងនារី រៀលរឹមមកដល់ មណ្ឌលហានទី ជានា
តាំងពាដី ទីនាំងថ្លៃថ្លា ។ ទើបមេស្រុកទៅ ដល់ក្សត្រកម្លៅ
ព្រហ្មទត្តពាលា រិះរកកលគិត តំនិតមុសា - ក់ទរៀចទូលថា បពិត្រ

ក្សត្រៃលែ ។ តទ្បូវនេះទៅ គោគកុលចេញទៅ ចាត់យូរលង់ទៃ្ល សម
ទៅអន្ទង់ ក្សត្រធង់ជទៃ មកក្បត់ក្សត្រទៃ្ល ពិតពុំឃ្លាតឃ្លា ។ រីលមក
ឃ្លានទាំង អស្សតរទីនាំង បញ្ជិះតរិយា ទ្បិចានដេរទៅ យល់នៅចំការ
មើលឫកយល់ជា ប្រែចិត្តទីទៃ ។ បើព្រះអង្គនៃ្លយ ប្រហែសអត់ឲ្យ
ទុកនៅក្នុងទៃ្ល គ្រាមក្រែងក្រគេកាយ សូមឲ្យក្សត្រថ្ល ផ្ទាញ់ឲ្យក្រយ
ជីវិតទើបជា ។ ស្តេចស្តាប់ទំនូល តាមគោជកទូល ត្រៃតត្រាស់ទៅថា
យើង៎ឲ្យទៅយក ហៅមកយល់ជា មាណពនោះវ៉ា ពុំមកដូចចិត្ត ។
បើឲ្យសេនា ទៅចោមចាប់វ៉ា សម្លាប់ជីវិត យល់ជាពុំបាន វ៉ាមាន
សិល្បសិទ្ធ៌ ច្នេះយើង៎នឹង៎គិត ដូចម្តេចកំជា ។ ទើបតាមគោជក ជា
ទៅមឿង៎ស្រុក ទូលទៅទៀតថា បពិត្រព្រះអង្គ សូមទ្រង់ចិន្តា ឲ្យ
អស់សេនា បរពលតាំង៎ឡាយ ។ គោះចិនចាមជ្ញា ឃ្លាំង៎លន្ធា
បរទេសសៃសាយ លើកទៅចោមចាប់ សម្លាប់ខ្ចាត់ខ្ចាយ កុំគិតមើល
ងាយ ប្រហែសនឹង៎វ៉ា ។

ពាក្យពំនោល

កាលណោះព្រៃហ្នទត្តជា ស្តេចស្តាប់វ៉ាថា ពាក្យតាមគោជក
ក្រាបទូល ។ ព្រឹសត្រមព្រះទំយដួចចូល ក្សិណាក្សត្រឥស្សរ បន្ទូល
ត្រាស់ប្រើសេនា ។ ចៅចេញបរពលអាសា រួសពន់ម៉ឺម៉ា ឲ្យឃ្លានចូល
មកធាប់ ។ ។ អាមាត្យឃ្លាត់ឃ្លានស្តេង៎ស្តាប់ ទទួលបង្គាប់ បង្កើប្រណាម្យ

លុតលា ។ ចរចេញប្រាមប្រាប់គ្នីគ្នា គាហានអាសា យាត្រាប្រញាប់ហរ
ពល ។ ប្រជាកស្តេកងមណ្ឌល ខៃត្រខ័ណ្ឌសកល ពាកណាស៊ីសេមា ។
កំកាន់ត្រប់គ្រឿងសស្ត្រា ចូតចង់គាថា ប្រទាលកជះគុជគង់ ។ ពាក់
មួកពាក់អាវគ្រែងផ្ចង់ ប្រដាប់ការអង្គ ប្រយោជន៍ប្រយុទ្ធប្រជ្រាណ ។
ស្រែចចូលមីរមូលមកប្លាន ដល់មុខព្រះលាន ប្រកិតអាវុធត្រៀបត្រា ។
កាលណោះព្រហ្មទត្តពាធា ស្តេចឲ្យយកឫទ្ធា ដំរីទំាងនិរភ័យ ។ ចង
គ្រឿងកញ្ចោងមាសមៃ ភ្លឺផ្លេកប្រពៃ ពិចិត្រសឹងវត្ថុដាំជាក់ ។ ក្បាច់
ក្បាំងទង្គ័ន់ខ្សែធ្នាក់ ដងក្រពាត់ពាក់ ប្រភក់មាសមានរស្មី ។ ស្បាប់
មុខស្រោមកកដំរី សឹងមាសមណី ភង្វេរសឹងវត្ថុរចនា ។ ស្តេចឲ្យ
រៀបពលយោធា គាហានអាសា ចេញជាបតុព្យូហ៍យុទ្ធ ។ ស្រួចប៉ែក
ឆ្វេងស្តាំមោរមុត ណាន់ណែនប្រាជក ប្រកបដោយលេខទីទៃ ។
សេនាភូមានិរភ័យ សឹងកាន់ទង់ជ័យ បញ្ជ្រាបញ្ជាប់ត្រាត្រៀម ។
អណ្តាប់នោះសោតសឹងសៀម ពាយរៀបមេរៀម ឆាក់លើដំរីផ្តង់ធ្ង ។
សេនាខ្មែរសឹងកាន់ធ្នូ ចេះប្រាញ់ត្រង់ត្រូវ មុតមែនកែនស្លាត់ជម្រង់ ។
អណ្តាប់នោះចិនហៃហុង រឹងរូសដ៏ខ្លែនង់ ក៏កាន់ដាវខ្លីស្រោងស្រោង ។
ប៉ែកស្តាំសោតសឹងឫកាំង ក៏កាន់ស្នាប់ចុំាង ម្នោម្នះមហិមា ។
អណ្តាប់នោះសឹងគួឡា កាន់សាមសែងារ គ្រវីពញ្ចមពន់ពេក ។
អណ្តាប់នោះសេនាខែក កាន់សេខ្លាស្បែក ខ្នូវដាវភ្លុនស្រាលឆង់ដា ។

បែ៉កឆ្នេងសោតសឹងសេនា យួនយកអាសា កំកាន់គាំក្តើងស្មុកគោង ។
សេនាជាតាតក្រអោង ដួតក្បាលសំពោង កំកាន់ខ្លួវគ្រឹសគ្រប់ដៃ ។
សេនាចាមចិនហានក្រៃ កាន់គាំក្តើងដៃ បញ្ឈរច្រូងច្រាឥតឈាស ។
ទ័ពហានលន្លាស្លាត់ណាស់ កាន់មេសរចុះស់ របៀបចុំបីសំញែង ។
សេនាយ៉ាពុនខរែង កំកាន់ដាវវែង គ្រវីគរយើនគឃ្លាវ ។ អណ្តាប់
នោះសេនាលាវ កាន់លំពែងសាវ ចាមរីចង់ចូនរាល ។ សេនាមនទៅ
កណ្តាល ជិតដើងគជសា គដេន្ទ្រទំនាំងក្បត្រា ។ កាន់ស្មែងក្រមង់ងា
ខ្លះកាន់គ្រឿ ខ្លះកាន់ដបខចាំបែរ ។ ខ្លះកាន់គួរឫតន្ត្រីត្រែ - សង្ខ៍សឹង
ដើរហែ អណ្តាប់អណ្តាយរៀងគ្នា ។ ទើបក្បត្រព្រហ្មទត្តពាជ ទ្រង់
ពាតស្ពា ប្រដាប់អស់អង្គតន្ត្រីយ៍ ។ ទ្រង់គ្រោះពេជរត្នមណី ឡើង
គង់ជំនឿ ទំនាំងបើកចុំាងកូសកុំ ។ ស្តេចឲ្យដំរីសាសម រូបកាងឆាត់ធំ
ចុះប្រែងហូរហៀរដល់ក្មុក ។ ឆាក់ឲ្យរៀគាមគោជក ដំរបរាំមុខ
ទំនាំងព្រះចុាទក្បត្រា ។ ស្តេចលើកវេហ៍តលយោធា ឆ្ពោះត្រង់ចំការ
ព្រះពោធិសត្វនិមិល ។ ដល់ស្រែចស្តេចឲ្យអស់ពល ចោមដុំម៉ុលលុំ
ចុាំពីរជាន់ជិតត្រៀបត្រា ។ ហោរហាឱរភ្លារមហិមា ទើបស្តេចត្រាស់ថា
ហៃចៅកោគកុលកុមារ ។ ចៅនាំកវិយាត្រអាល រចញ្ជៅតិតការ
តំនិតនឹងក្បត្រជាខៃ ។ ចៅយកខ្លួឲ្យមានដំណែ្ឋ ទៅថ្វាយប្រសិរ្ស័យ
យើតយោងអង្គងមកក្បត់ ។ យើងមានដំ រើងប្រុកជ យើងនឹងធ្វើតត់

សម្លាប់ចៅនេះតទៅ ។ ដ្បិតចៅចេញជាសត្រូវ ពុំគួរទុកនៅ ឲ្យរស់
ជីវិតដន្លាំ ។ កាលណោះព្រះពង្សពុទ្ធា ស្តែងស្តាប់ពាក្យ ស្តេចព្រហ្ម-
ទត្តទិដ្ឋ ។ ព្រះអង្គតតក្អឹកភ័យពី សឹកដូចកេសរី សីហនាទចេញចាក
គូហា ។ មានព្រះបន្ទូលទៅថា រ៉ីយក្សត្រមោហា អង្គអន្ធពាលធោត
ធុក ។ ដោយតែពាក្យគាម.ភាជក នាំទៅនរក ពុំគិតឃាតពៀរវែង ។
រកកលនឹងធ្វើទោសា ឲ្យយើងមរណា នឹងយកកិរិយាយើងទៅ ។
ទាល់តែនាងនាងពុំនៅ រត់រលឹងទៅ ដល់ព្រះបិតាក្សត្រកក្បាន្ត ។
យើងត្រែចទៅតាមព្រួយចិត្តណា យកនាងមកឃាត អំពីព្រះរបិតា ។
តទ្បាយលើកពលយោធា មកចោមចាប់ថ្នា ចង់ចាប់សម្លាប់យើងទៀត ។
រកកលមុសាធ្លាស់ទ្រឹត ថាយើងចែរបៀត ចូលនឹងសត្រូវដទៃ ។
ចូរចេញចយទៅវែរ ។ បើខំនៅកន្លែយ ព្រះឯន្តតទ្បាយនេះច្បាត់ ។ កាល
ណោះព្រះឃាតព្រហ្មទត្ត ស្តាប់ហើយត្រេកធ្លាត់ ថាពះអល់ពល-
យោធា ។ ចូរចោមចាប់យកតូវ មកកាត់សិរសា ឲ្យឃាតតទ្បាយាប់ ។ ។
អស់អង្គសេនាស្តែងស្តាប់ រត់ចូលប្រញាប់ តាមដោយព្រះពជគាជ្ញ ។
ឯអង្គពួងពង្សសាស្តា តតតិតកយា ស្តេចយកព្រះកេរ៉ីណ្ហជ័យ ។
ទធាក់ដំខ្នើងពត់រៃ ព្រះហស្តក្សត្រៃច្ចៃ ខ្ចែងថ្នាត់បន្ទោះចេញទៅ ។
លាន់ពួកត្រែកាំត្រែលែកៅ ខ្ទួទាំងលំនៅ កណ្តាប់នៃចក្រពត្តិ ។
ដូចសែនរន្ទេះមហិមា ឃ្លាញ់ចុះត្រមគ្នា ហាក់ដូចនឹងផ្តាប់ប្រឹថពី ។

ពុះពោរដន់ដោរដលដ៏ សុមេរុគិរី កកើតរំពើតពេតក្តាត់ ។ កាល
ណោះឯអង្គមហាកប្បត្រ ព្រះបាទព្រហ្មទត្ត ខ្ញុំវគាមកោដកអប្រិយ ។
តិតធ្លាក់ពីលើដំរី ជួលដល់ដែនដី ក្បាលក្បាយជីវិតជន្មា ។ ធ្លាក់ទៅ
សោយទុក្ខវេទនា នៅនរកមហា - តាបដល់កន្លះកល្បតត់ ។ អស់ពាល
ផងកិតវន្តត់ ស្ងើតស្ងាំងស្ងន់ស្ងុត ដួលដេកនៀលត្រៀបត្រា ។ អស់
មុខមន្ត្រីឯណា ដែលគិតនឹងមហា - ក្បត្រាសឹងក្បាយជីវិត ។ ឯណា
ពុំបានចូលគិត មូលមួយគំនិត ក៏សឹងរួចរស់ជន្មា ។ ត្រាកឡើងញ័រ
អស់អង្គា កិតភ័យតក្កមា ចង្កិបប្រណម្យទូលទៅ ។ បពិត្រអម្ចាស់ចម
ទៅ សូមទានទ្រង់នូវ - មេត្តាករុណាអត់ទោស ។ ឲ្យទានជីវិតសន្ដោស
អាសូរប្រាណប្រោស ឲ្យគង់ដាំទុំតទៅ ។ ទើបព្រះពុទ្ធពង្សពុទ្ធផៅ
បើកបន្ទូលទៅ ថាហៃអស់មុខមន្ត្រី ។ គ្រប់គ្នាតើមានទោសអ្វី កុំភ័យទៅ
ថ្វី អញសោតពុំយកទោសា ។ មន្ត្រីត្រេកអរគ្រប់គ្នា ដង្ហិតស្ដេចមេត្តា
ប្រោសទុកជំរិតឲ្យគង់ ។ ទូលថាបពិត្រព្រះអង្គ អម្ចាស់ថ្លៃទ្រង់- ព្រះ-
គុណព្រះករុណាណាស់ ។ ឥតអ្វីផ្ទឹមគុណក្រៃក្រាស់ អញ្ជើញអម្ចាស់
ទាំងពីរទៅសោយពាជ្យរម្យ ។ ជាឥស្សរអស់យើងខ្ញុំ គ្រងថ្លៃក្រោមក្រែ
ពិភពពិភ័ក្តិកស្តេចផង ។

(នៅមានត)

លោកប៉ាយ-ប៊ុក ក្រុមការ រៀបរៀង

(តទៅ)

គ្រានោះ ព្រះពុទ្ធសាមីត្រាស់ថា "ន! ព្រះនាងថ្លៃមថ្លៃ រឿងកំរាំងនេះ ល្អមើលណាស់" ។

ព្រះនាងក្រាបទូលតទៅទៀតថា "ក្បត់ថ្លៃខ្ញុំម្ចាស់អើយ, តាំពីសុបិននេះទៅ ខ្ញុំម្ចាស់ប៉ាងតែសុះសំឡេងមួយគួរឲ្យស្បថស្បែងស្រែកថា "ពេលជិតដល់ហើយ! ពេលជិតដល់ហើយ! រួចតមកខ្ញុំម្ចាស់ប៉ាងយើញសុបិនទី ៣ ហាក់ដូចខ្ញុំម្ចាស់មានបំណងចង់ប៉ះពាល់ព្រះអង្គម្ចាស់ថ្លៃខ្ញុំអើយ ទៅលើក្បាលខ្ញុំម្ចាស់ប៉ាងយើញតែរង ព្រះសិរស្នាតតមខ្ញុំល ទឹង ព្រះភ្លុសាកាសារប៉ុណ្ណោះ ប៉ុន្តែតត ព្រះអង្គគង់នៅសោះ! - តែតត ព្រះអង្គទុកដូចជាប្រទីប ជាដួងជីវិត ជាក្បត់ជាចក្រពត្តិ របស់ខ្ញុំម្ចាស់! ខណៈនោះបេះទាំងអស់ស្ងប់ស្ងាត់ច្រៀប ខ្ញុំម្ចាស់ប៉ានក្រោកឡើងប៉ានយើញទឹមទាតប្រជាបត្ន្ធមុក្តារបស់ ព្រះអង្គទៅទីនោះ ក្រពតកាយខ្ញុំម្ចាស់ ស្រាបតែក្បាយទៅជាពស់មួយ បែរមកចឹកខ្ញុំម្ចាស់វិញ កង់ ព្រះបាទខ្ញុំម្ចាស់ក៏ជាក់ជ្រុះទៅដ៏ កងប្តីខ្ញុំម្ចាស់ក៏ប៉ាក់ជាប់ខ្លួចខ្លីធ្លាម្ចុះដែលក្រងប្រជាប់ ព្រះកេសាក៏ជ្រុះតត់រាយអស់ទៅ ព្រះទែនសេយ្យានា ក៏ត្រឡប់ប៉ាក់អស់ ព្រះសន្ធិយាក៏រៃកជាច់ជាច ។ គ្រានោះ

ខ្ញុំម្ចាស់ចាន់ឮសូរសម្រែកគោះទុកពីសនោះពីចម្ងាយបន្តាប់ពីនោះ ខ្ញុំម្ចាស់ចាន់ឃើញទន់ដាយចាក់នោះបក់វិច ហើយឮសូរសម្រែកដូចមុន នោះទៀតថា " ពេលមកដល់ហើយ ! ។ សម្រែកនេះ ធ្វើឲ្យវិញ្ញាណ ខ្ញុំម្ចាស់រំភើបញាប់ញ័រនៅឡើយ ។ ន ក្សត្រីថ្លៃម្ចាស់ខ្ញុំអើយ ! តើសុបិន នេះប្រែសេចក្តីដូចម្តេច បើតាមខ្ញុំម្ចាស់យល់ គឺថាខ្ញុំម្ចាសនឹងសោយ ព្រះវិលាលយ័ ឬមិនដូច្នោះទេព្រះអង្គនឹងច្រាសបង់ចោលខ្ញុំម្ចាស់ទៅ ឬត្រូវស្តេចចាកចេញពីព្រះពជ្ឈាន ? "

ព្រះសិទ្ធត្ថពជ្ឈសត្វទន់ទត ព្រះនេត្រទៅកាន់ព្រះពជ្ឈទេពីដែលកំពុងទុក្ខព្រួយ ដោយព្រះទ័យមេត្តាច្រើនណា ហាក់ដូចព្រះសូរិយាសំដែងអាការញញឹមមុនអស្តង្គតទៅ ហើយទ្រង់មានព្រះបន្ទូលថា " ទេវី សំឡាញ់ , កុំព្រះនាងព្រួយឡើ បើទុកជាសុបិនព្រះនាងអាចក្លាយទៅជាមានពិតទៅអនាគតក្តី ទុកជាពួកទេព្តាតង់លើ អាសនាមិនបានសុខស្រួលក្តី ពិភពលោកវេកបុគ្គលណាមួយជួយដោះទុក្ខគ្មានក្តី ទោះបើជោកវាសនាប្រែប្រួលទៅជាដូចម្តេចក្តី ក៏សូមឲ្យព្រះនាងដឿឹកចិត្តចុះថា ពីមុនព្រះដង្ហាស្រឡាញ់ព្រះនាងយ៉ាងណា ឥឡូវក៏នៅតែស្រឡាញ់ព្រះនាងយ៉ាងនោះដែរ ។ សូមឲ្យព្រះនាងជ្រាបថា ព្រះដង្ហាមានចំណង់ច្រើនខែមកហើយ ដើម្បីស្វែងរកមធ្យោបាយដួយស្រោចស្រង់ ពីភពលោកដែលប្រកបដោយទុក្ខលំបាក ដែលព្រះ

ដែរឬទ្យាបានឃើញមកហើយ ហើយពេលវេលានោះមុខជានឹងមកដល់ខាងមុខមិនខាន ការដែលត្រូវបំពេញកិច្ចការនៅឡើយ ។ ប៉ុន្តែបើហឫទ័យព្រះដែរឬទ្យាព្រួយលំបាកចំពោះទុក្ខទោសដែលមិនមែនជារបស់ខ្លួនទេ សូមឲ្យព្រះនាងជ្រាបថា ព្រះចិន្តារបស់ព្រះដែរឬទ្យាហោះហើរអណ្តែតទៅលើសត្វសត្វមានជីវិតទាំងអស់ ដោយសេចក្តីមេត្តាប្រាណីគ្មានទីបំផុតពិតមែនហើយ ព្រះនាងជាទីស្រឡាញ់ពេញចិត្តព្រះដែរឬទ្យាណាស់ ព្រះនាងគួរចាប់ចិត្តស្នេហាបំផុត, ប្រសើរបំផុត, ដោយពិតបេះដូងព្រះដែរឬទ្យាជាបំផុត ។ អាហ៍ ! ព្រះនាងនេះហើយ ជាព្រះមាតារបស់ទុរសេដែរឬទ្យា ព្រះនាងនេះហើយបានរួមកាយចិត្តជាមួយនឹងព្រះដែរឬទ្យា ប៉ុន្តែព្រះទ័យព្រះដែរឬទ្យាបានគ្រាលគ្រៃបន្តិចដែរ នឹងសត្វសមុទ្រ - តោរពេញដោយសេចក្តីមេត្តាករុណាធ្លាយទៅកាន់មនុស្សលោកខ្លួនទៅ ប្រៀបដូចមេត្រាបស្ទុះហើរយ៉ាងលឿនទៅលើអាកាស តែងមានចិត្តខន់ទៅកាន់សំបុករបស់វាដែលមានកូនតូចៗ ហើយតែងវិលមកកសំបុកវិញជានិច្ច ត្រជាងស្ងាបយ៉ាងរីករាយដោយសេចក្តីស្នេហា ។ ចំពោះព្រះនាងវិញ ដែលជាស្ត្រីប្រសើរបំផុត ជាស្ត្រីគ្រប់លក្ខណ៍ខន់ក្នុងលោកស្ត្រីជាអង្គព្រះដែរឬទ្យាពិតប្រាកដ ។ បើមានហេតុគេះទៅអនាគតដូចម្តេចសូមឲ្យព្រះនាងនឹករលឹកដល់គោលសក្តាដែលស្រែកកោះរំពង នឹងខន់ជាយដែលរចនាដោយពេជ្រនិលចិន្តា ត្រូវព្រះពាយុបក់ផាត់រំលិច ដូចមាន

ក្នុងសុបិនព្រះនាង ហើយសូមព្រះនាងជឿចុះថា ព្រះដង្ហាស្រឡាញ់ពេញចិត្តព្រះនាងយ៉ាងណា ដល់មកតទល្បះនេះ ក៏នៅតែស្រឡាញ់ពេញចិត្តនឹងព្រះនាងជានិច្ចយ៉ាងនោះដែរ ហើយរបស់ដែលព្រះដង្ហាទំស្នែងសូរកសព្វអន្ទី ជាប្រយោជន៍ចំពោះព្រះនាងជាមុនបង្អស់ ។ ប៉ុន្តែព្រះនាងត្រូវបន្ទោបង់ទុក្ខសោក ដោយនឹកថា សន្តិភាពនឹងមានមកក្នុងលោកដោយសារសេចក្តីនឿយព្រួយរបស់យើង ហើយចូរព្រះនាងសំដែងសេចក្តីស្នេហាស្នោះត្រង់ ទទួលអំណរគុណអរ ព្រមទាំងព្រះពរសព្ជីសាធុការ ។ របស់អស់នេះ មិនសូវប្រែពីថ្ងៃថ្លាប៉ុន្មានទេ ព្រោះកំឡាំងសេចក្តីស្នេហានៅទន់ខ្សោយណាស់ ចូរព្រះនាងចុម្ពិតព្រះទស្ន ព្រះដង្ហា ហើយក្រែបធឹកនៅសំដីវាចា ដែលហូរចេញពីដួងហឫទ័យនៃព្រះដង្ហា ដើម្បីឲ្យព្រះនាងជ្រាបថា ជនជាតិខ្ញុំតស៊ូតស៊ូធ្ងន់តងធ្ងន់អ្វីសោះ គឺថាព្រះដង្ហាស្នេហាចំពោះព្រះនាងវិសេសជាងសត្វលោកជាតិខ្ញុំតទាំងអស់ ។ ព្រះដង្ហាចង់ក្រោកឡើងពិចារណាហេតុការណ៍ទាំងឡាយ, ម្នាលក្សត្រី សូមឲ្យព្រះនាងគង់នៅទីនេះសិនចុះ ។

ម្ល៉ោះហើយ ព្រះនាងក៏ទ្រង់ព្រះកន្ទែងធ្ងុលក់ទៅទាំងខ្សឹកខ្សួលអួលអាក់ក្នុងព្រះបិន្ទា ព័ត្រោះព្រះនាងយល់ព្រះសុបិនដូចមុនឃ្លាតដាក់ស្តែង ហើយបានឮពាក្យដូចមុនម្តងទៀតថា "ពេល ! ពេលមកដល់ហើយ !" ប៉ុន្តែព្រះសិទ្ធត្ថរាជកុមារ ទ្រង់បែរព្រះកន្ត្រកចេញពីព្រះនាង

ហើយក្នុងពេលនោះ ព្រះបន្ទូបញ្ជាំងរស្មីភ្លឺខែង ហើយដួងតារាទាំង
ឡាយមានភន្លឺដូចប្រាក់ សមដូចពាក្យទំនាយដែលទាយទុកមកយូរ
ហើយ ហាក់ដូចប្រាប់ថា "ពេលនេះ ជាពេលរាត្រី ចូរព្រះអង្គដ្រេស
រើសយកផ្លូវចង្កូលចុំថ្កើរឆ្ងើរឿង ឬផ្លូវសប្បុរសចិត្តល្អ ; ចូរព្រះអង្គដ្រេស
យកផ្លូវសោយរាជសម្បត្តិជាចក្រពត្តិ ឬភាពជាអ្នកត្រៃចរង្គាតទៅតែឯក
ឯង តតមកុដរាជ្យ តតប្រាសាទរាជដ្ឋាន ដើម្បីជួយសង្គ្រោះសាកល
លោក" ។ ក្នុងវេលាគ្រានោះ ព្រះពាយរកើយងាត់ក្នុងរាត្រីងងឹត
ខ្យឹបជាក់ព្រះកាណ៌ព្រះអង្គ នឹងដំបូន្មានដែលពួកទេវតាឋានពោលជាស
ត្មឹនតាមសុវសំតូខ្យល់ ហើយមានពួកទេពនិករចោមរោមដុំរញ្ជែងព្រះជា
ម្ចាស់នៃយើង ដែលទ្រង់កំពុងពិចារណាដួងតារាដ៏ត្រចះត្រចង់ ។

ព្រះអង្គត្រាស់ថា "ខ្ញុំបង់ចេញទៅតទ្បូរ, ពេលមោ៉ងដល់ហើយ !
ឧក្សត្រីជាទំស្នេហា, បបូរព្រះឧស្ឋដ៏ទន់ភ្លន់ នាំឲ្យព្រះដេដ្ឋាប្រាថ្នាខឹង
ឆួយស្រោចស្រង់ពិភពលោក ប៉ុន្តែយើងត្រូវតែត្រាត់ប្រាសគ្នា ហើយ
ខណៈដែលមហាមេឃស្ងប់ស្ងាត់នេះ ព្រះដេដ្ឋាកំពុងពិនិត្យដោតវាស្នា
ក្នុងលិខិតទាំងឡាយយ៉ាងចិញ្ចែង ។ ព្រះដេដ្ឋាមានព្រះបំណងនឹង
ត្រែចទៅតាមផ្លូវដែលត្រូវត្រែច អស់យប់ចែងាច្រើនមកហើយ ព័ត្រោះ
ព្រះដេដ្ឋាមិនត្រូវការមកុដរាជ្យ ដែលនឹងប្រាសជារបស់ខ្លួនទេ ទាំងមិន
ព្រមទៅត្រប់ត្រែងភពអាណាចក្រ ដែលរង់ចាំទទួលព្រះឱនរាជ្យរបស់ព្រះ

ដេដ្ឋា ភជរថ់រេបស់ព្រះដេដ្ឋានឹងមិនរិល ដោយមានកាំកង់ប្រឡាក់ឈាម ដោយការមានជ័យជំនះរឿងៗទៅ ដើម្បីឲ្យនៃនដ័រក្សាកត្តិនាមទុកជាអនុស្សាវរីយ៍ មានពណ៌ក្រហមឆ្អៅ ។ ព្រះដេដ្ឋាពេញចិត្តប្រើដើងត្រែចទៅតាមផ្លូវដើង តតមានមោរមៃសៅហ្មង យកនៃនដ័ជាព្រះនៃនបន្ទុំ យកកាល់ឡាច់ដ៏រហាហានជាប្រាសាទដំណាក់នឹងវត្តហ៊ីនភាពទាំងឡាយជាមិត្ត មានសំលៀកបំពាក់ដូចពួកមនុស្សគ្មានវណ្ណៈ មានភោជនាហារបានមកពីអ្នកស្រុក ដែលមានចិត្តជ្រះថ្លាធ្វើបុណ្យ តតលំទៅអ្វីក្រៅពីគួហាងងឹត ប្តូរកំពោតត្រៃកុំឲ្យគ្រំ ។ នេះឯងហើយដែលព្រះដេដ្ឋាត្រូវធ្វើ ពីព្រោះសូរសៃមេកគួរាណោចរាធម្មនៃដ៏រតនឹងពួកសត្វមានដ៏រតទ្ធទៅ ធ្លាបដល់ព្រះគាណិព្រះដេដ្ឋាទាំងអស់ ហើយដូងហប្ញទ័យនៃព្រះដេដ្ឋាពុះពោរដោយមេត្តាករុណា ចំពោះទុក្ខសោកនៃពិភពលោកដែលត្រូវតែជួយសង្គ្រោះនេះ ដោយវិធីលះបង់ជាប់ខាត នឹងការតេទល់ជាប់ស្រេចចំពោះអាសវកិលេស ។ ឯពួកទេពនិករទោះមានសំគ្គីធំគ្គីសំគ្គីតូចគ្គីតើអង្គណាខ្លះដែលមានអំណាចហើយមានចិត្តមេត្តាអាណិត (ចំពោះសត្វទាំងនេះ)? - តើអ្នកណាបានឃើញពួកទេពនិករទាំងនោះ? - ហើយពួកទេពទាំងនោះបានជួយស្រោចស្រង់ ពួកជនដែលគោរពបូជាខ្លួនដូចម្តេច ? - តើបានធ្វើប្រយោជន៍អ្វី ដល់មនុស្សដែលសូត្រធម៌, ដែលបានធ្វើពលីការដោយគ្រាប់លូសណ្តែកនឹងច្រែង, ដែលសូត្រមន្តគាថាអាគម,

ដែលបូជាយញ្ញដោយជីវិត, ដែលកសាង ព្រះវិហារយ៉ាងសំបើមថ្កៃថ្លា ថ្វាយ, ទំនុកបំរុងពួកសង្ឃ ហើយដែលចំបង់ស្រង់បួងសួងដល់ព្រះវិស្ណុ ព្រះសិវៈ, ព្រះសុរិយៈ ដែលគ្មានជួយអ្នកណាមួយឲ្យផុតចាកទុក្ខទោស ដល់ម្ដងសោះ? តើមានបងប្រុសខ្ញុំណាមួយ, ដោយសារប្រតិបត្តិតាម ទំនងនេះ ឋានរួចរបូតចាកទុក្ខសោកកងជីវិត, សេចក្ដីលំបាកដ៏ជូរចត់នៃ សេចក្ដីស្នេហា នឹងការត្រាត់ប្រាស់ចាកវេរ៉ាដែលជាទីស្រឡាញ់, គ្រូនរ៉ាដែលធ្វើឲ្យកាយចិត្តរន្ធត់ញាប់ញ័រ, មរណៈដែលគួរស្បថស្បែង, សត្វសង្ហារតែងវិលជុំវិញកងនៃសំសារចក្រ ហើយកតថ្មីតែងធ្វើឲ្យកើតទុក្ខថ្មីទៀត, ការតេពូជពង្សវង្សត្រកូលច្នាំងអំពើបំពេញចំណង់ថ្មី ដែលបង្កើតឡើងដំនួសចំណង់ចាស់ដែលរលត់ទៅ? តើមានបងស្រីខ្ញុំណាមួយ ឋានទទួលផលអ្វីនៃការអត់អាហារ បុការសូត្រមន្តការខា, តើនាងឋានឆុតពីទុក្ខលំបាកពីការប្រែសូត្របុត្រ ដោយសារការបូជាទឹកដោះគោសុទ្ធ ឬដោយការបូជាសំពត់ប៉ាក់ស្លឹកតុលសី ក៏គ្មានសោះ! ពិតមែនពួកទេព្តាខ្លះល្អខ្លះអាក្រក់ ប៉ុន្តែសុទ្ធតែខ្ចត់ខ្សោយអាយុកាល · ពួកទេព្តាអស់នោះខ្លះក៏មានមេត្តា ខ្លះក៏កាចសាហាវ ហើយទាំងអស់នោះ ក៏ដូចជាមនុស្សលោកដែរ តែងជាប់នៅកងសំសារចក្រ ហើយវិលកើតវិលស្លាប់តស្រាក ពីព្រោះព្រះគម្ពីរឋានប្រដៅដោយត្រឹមត្រូវទុកថា កាលណាបើជីវិតចាប់មានខ្លឹងហើយទោះបីជីវិតកើតពីដើមចមអ្វីឬពីហេតុអ្វីក៏ដោយ

តែងតែគ្រែចង្កាត់កងវដ្តសំសារ ចាប់តាំងពីបរមាណូទៅដល់ចាណក សត្វ, ជង្ហឹរ, សត្វលូនវារ, ត្រី, សត្វស្លាប, សត្វមានភេមលើកងកាយ ហើយដរាបមកដល់មនុស្ស, កូតបីសាច, ទេព្តា, ព្រះព្រហ្មតែងវិលចុះមកកើតនៅដីតទៅទៀត ហេតុដូច្នេះ សព្វសត្វទាំងអស់សុទ្ធតែជាសាច់ញាតិជាតិជាមួយ ប្រសិនបើគេជួយសង្គ្រោះមនុស្សឲ្យផុតពីការអន្ទោលនេះទៅបាន ពិតជាលោកទាំងមូលនឹងបានគុណខែង ចេញចាកអំពីអវិជ្ជាដែលគួរស្អប់ស្អែងនេះបាន ដែលមានសេចក្តីខ្ជាក់ខ្ជាមជាស្រមោលនឹងការកំណាចយោរយៅជាគ្រឿងកំសាន្ត, អើមែន, ប្រសិនបើមានអ្នកណាមួយអាចជួយសង្គ្រោះពិភពលោកបាន ហើយវិធីនេះគង់តែមាន ទំពឹងពំនាក់របស់លោកត្រូវតែមាន ! មនុស្សទាំងឡាយតែងស្អប់រឿងដោយឃ្លង់រងាត្រជាក់ តមកទើបមានអ្នកចេះដំឲ្យកើតជាផ្លាកើងឡើង ។ មនុស្ស (ពីដើម) ស៊ីតែសាច់សត្វដូចជាសត្វបចក តមកទើបមានអ្នកគ្រោះសាបស្រវាសាលីដែលដុះឡើងដូចជាស្មៅធម្មតា ហើយដល់មកឥឡូវនេះអាចចិញ្ចឹមមនុស្សលោកឲ្យរស់នៅបាន ។ មនុស្សទាំងនោះខំប្រឹងញាក់មុខមាត់ហើយខំពោលពាក្យឡើង ពាល់តែកើតជាភាសា ១ ប្រឹងឲ្យមានពាក្យសំដីឡើង ហើយម្រាមដៃខំហាត់សរសេរ ទៅជាលាយលំក្ខណ៍អក្សរបញ្ចេញសូរសព្ទឆ្លើយឆ្លង ។ តើបងប្អូនខ្ញុំបានឧបត្ថម្ភអំណោយអ្វីខ្លះដែលកើតមកពីការស្វះស្វែងការខិតខំធំធេងនឹងការបូជាយ័ញ្ញដោយចិត្តស្មោះ

ត្រង់? ចើដូច្នេះ ចើមានមនុស្សម្នាក់ដែលមានទ្វីអំណាច មានឆ្មាំ
ក៏ស្មាមានកោតសម្ញែ មានសុខភាពបរិបូណ៌ មានសេចក្តីរីករាយក្សេម
ក្សាន្ត ដែលសមគួរនឹងសោយភោជសម្បត្តិ ទឹងបានជាស្តេចចក្រពត្តិ
ប្រសិនចើមានមនុស្សម្នាក់មិនមែនជាចាស់ជរាដោយមានអាយុច្រើន
ប្រកបដោយសេចក្តីសប្បាយរីករាយ តាំងនៅក្នុងបឋមវ័យ; មិនមែនជា
អ្នកឆ្អែតស្កប់ស្កល់ដោយលោកាមិស គឺជាអ្នកនៅស្រេកឃ្លានៅឡើយ;
ប្រសិនចើមានមនុស្សមួយមិនមែនចាស់ស្បែកជ្រីវ មានទុក្ខព្រួយគឺជា
អ្នកសប្បាយរីករាយ នៅក្នុងជោគជ័យនឹងការសប្បាយលាយឡំដោយ
អំពើអកុសលក្នុងលោកនេះ មានសំឡីជ្រើមយកតាមចិត្តទូវត្តដែលខ្លួន
ស្រឡាញ់ពេញចិត្តនោះលើផែនដី ជាបុគ្គលមួយ ដូចជារូបព្រះដង្ហានេះ
តតទុក្ខព្រួយ តតត្រេកអរអ្វី តែមានសេចក្តីព្រួយចំពោះសេចក្តីព្រួយ
របស់ជនដទៃ តតមានទុក្ខព្រួយអ្វីក្រៅពីមនុស្សជាតិទេ បុគ្គលបែបនេះ
បើត្រូវការឲ្យក៏ឲ្យគាំងអស់ហ៊ានលះបង់ដោយសេចក្តីមេត្រីចំពោះមនុស្ស
គាំងឡាយ ហើយប្តូរជីវិតខ្លួនឯងទៀត ដើម្បីស្វែងរកសេចក្តីពិត នោះ
ប៉ាមនុស្សនោះនៅលាក់ខ្លួនពួននៅក្នុងនរក ឬក៏ឋានសួគ៌ក្តី នោះប៉ាមនុស្ស
នោះលួងលៅនៅក្បែរយើងក្តី នោះប៉ានៅឲ្យណាស់មិនដឹងជាពេលណា
ឬ យ៉ាងដូចម្តេចក៏ដោយ សំពត់ដែលបង់បិទក្តែកក៏ត្រូវបើកចេញឲ្យភ្លឺខែង
ផ្លូវនឹងបើកនៅមុខ សម្រាប់ដើងដែលពុះពង មុខជានៅនឹងនៅដល់

គោលបំណង គឺការចុះបង់ចោលនូវសម្បត្តិមហាចក្រកង់លោក ហើយ
ស្តេចមកចុតជាមុខជានឹងបានជួបចៅហ្វាយរបស់ខ្លួន ។ អំពើនេះហើយដែល
ព្រះជង្ហាប្រាថ្នានឹង ធ្វើព្រះជង្ហាត្រូវចុះបង់ព្រះរាជអាណាចក្រមួយព្រះ
ជង្ហាមានបំណងដូច្នេះ ព្រោះព្រះជង្ហាស្រឡាញ់អាណាចក្ររបស់
ព្រះជង្ហា ព្រោះបេះដូង ព្រះជង្ហារន្ធត់ញាប់ញ័រ ជាមួយនឹងបេះដូង
របស់សត្វឯទៀតដែលទុក្ខព្រួយទាំងអស់ ទាំងដែលស្គាល់ ទាំងដែល
មិនស្គាល់ បណ្តាសត្វលោកពាប់លានគោដែលជារបស់ព្រះជង្ហា ឬ
ដែលនឹងត្រូវចុះជារបស់ព្រះជង្ហាសឹងត្រូវព្រះជង្ហាជួយស្រោចស្រង់
ដូចគ្នាទាំងអស់កង់កាលតឡូវនេះ ។ ឧដ្ឋងតារាជាទីប្រឹក្សាទាំងឡាយ,
តឡូវខ្ញុំមកហើយ ! ផែនដីដែលវង់តែទុក្ខទោស ! តឡូខ្ញុំលះបង់នូវ
សេចក្តីសប្បាយកង់បឋមវ័យ, នូវរាជបល្ល័ង្ក នូវសេចក្តីរុងរឿងទាំងយប់ទាំងថ្ងៃ, នូវសេចក្តីក្សេមក្សាន្តកង់ព្រះរាជវាំង នៃព្រះ-
អគ្គមហេសីសម្លាញ់, ព្រះហត្ថាព្រះនាង ធ្វើឲ្យព្រះជង្ហាលំបាកនឹងលះ
បង់ជាងវត្ថុដទៃទៀតទាំងអស់ ។ ប៉ុន្តែព្រះនាង ក៏ត្រូវព្រះជង្ហាជួយ
ស្រោចស្រង់ ទៅពេលដែលជួយសង្គ្រោះពិភពលោក ។ ចារកដែល
ទៅកង់ព្រះទ្រព្រះនាង គឺបុត្រសំឡាញ់របស់ព្រះជង្ហា ដែលជាផ្លាជា
ទីស្នេហារបស់យើង ដែលអាចនឹងធ្វើបំណងរបស់ព្រះជង្ហាឲ្យទន់ខ្សោយ
ទៅ ប្រសិនបើព្រះជង្ហាចាំបាច់មកថ្នមតារ ។ ព្រះទេពី ! ឧកូនឧពុក !

ទ្រង់ព្រះវរាជបិតា ! ទ្រង់ប្រជាជន ! ត្រូវអ្នកពាល់គ្នាគ្រាំទ្រទូរសេចក្តី
ត្រួយលឺបាក ក្នុងរយៈវេលាមិនយូរប៉ុន្មានទេ មុខជាមានពន្លឺដ៏ភ្លឺច្បាស់
ហើយសត្វលោកទាំងអស់នឹងបានសិក្សាព្រះធម៌ ។ ឥឡូវនេះ ខ្ញុំបាន
ដាច់ចិត្ត ខ្ញុំនឹងចេញទៅ ហើយនឹងមិនបានវិលមកវិញ មុនបានជួប
ប្រទះរបស់ដែលខ្ញុំត្រូវការស្វែង ប្រសិនបើការព្យាយាមស្វែងរកដោយ
ពេញកំឡាំង ប៉ានសម្រេចផលដូចបំណង" ។

នៅវេលាគ្រានោះ ព្រះអង្គ ទ្រង់សំដែងអាការគោរពនៅទៀប
ព្រះបាទាក្សត្រីជាអគ្គមហេសី ទ្រង់ទតចំព្រះភក្ត្រព្រះនាងដែលកំពុងផ្ទុ
លក់មានព្រះអស្សុដែលជោកព្រះភក្ត្រានៅឡើយ ដើម្បីទ្រង់លាចាកទៅ
ហើយទ្រង់សន្សឹម។ ប្រទក្សិណ ៣ ជុំក្រឡាព្រះបន្ទំដោយសេចក្តីគោ-
រព ហាក់ដូចជាវត្តជាទីគោរព ព្រះហត្ថាឧបព្រះនលាដ៏ញាប់ញ័ររំជួលជា
ខ្លាំងទ្រង់ព្រះបន្ទូលថា "តាំងពីថ្ងៃនេះតទៅ ខ្ញុំលែងផ្ទុកន្ទឹងនេះទៀត
ហើយ" ។ ទ្រង់តាំងព្រះទ័យយាងចេញទៅដល់ ៣ ដង ប៉ុន្តែទ្រង់
ត្រឡប់យាងចូលមកវិញដល់ ៣ ដង មិនចេះដាច់ស្រេច, លំអារព្រះ
នាងយសោធរាមានវិទ្ធិអំណាចណាស់, សេចក្តីស្នេហារបស់ព្រះសិទ្ធត្ថ
បរមក្សត្រក៏ខ្លាំងក្លាណាស់ ។ រួចទ្រង់ទាញព្រះកូសាចេញពីព្រះកេស
ក្សត្រីទ្រង់ជាកព្រះអង្គចេញបើកព្រះសិទ្ធិយាឡើង ។

(មានត)

(ភាពខេមរភាជនីយ)

មហា "ឱម-ណាគ្រី"

ឃុំស្វាយចេ៉ា ស្រុកសង្កែ ខេត្តបាត់ដំបង ប្រែរៀបរៀង,

ឧទ្ទេស សុភាសិត

កាលនេមិរាជជាតកមានសេចក្តីដំណាលថា កាលដែលព្រះមុនីនួ
សម្ពុទ្ធជាម្ចាស់របស់យើងទាំងឡាយ ឋិតនៅក្នុងព្រះជាតិជាព្រះបាទ
នេមិរាជក្នុងក្រុងមិថិលា ក្សត្រាបានទ្រង់តាំងនៅក្នុងសីលនិងធម៌ដ៏ល្អ
ទាំងទ្រង់ដឹកនាំក្រមប្រជានិករាជបវរសំខ ឲ្យប្រតិបត្តិប្រព្រឹត្តតាមព្រះអង្គ
ផង, ប្រជារាស្ត្រទាំងកម្មករពួកខ្លះ ដែលបានប្រតិបត្តិតាមពាក្យប្រៀន
ប្រដៅរបស់ព្រះអង្គ កាលលះបង់អាយុដ៏វែងមុនព្រះអង្គទៅ ក៏បានទៅ
ឧប្បត្តិកើតក្នុងឋានតាវតឹង្សទេវលោកជាច្រើនគ្នា ហើយបានពណ៌នា
សរសើរគុណរបស់ព្រះអង្គក្នុងទីប្រជុំសមាគមទេវតាជាន់តាវតឹង្សរឿយ ៗ
រហូតដល់ព្រះឥន្ទ្រកោសិយ ទ្រង់មានព្រះហឫទ័យចង់ទស្សនាទើបទ្រង់
ត្រូវការថ្វាយបង្គំស្តាប់ធម៌របស់ព្រះបាទនេមិរាជ ទើបទ្រង់មានទេវបញ្ជា
បង្គាប់ប្រាប់ច្រើឲ្យមាតលីទេពសារថីនាំយកវេជយន្តរថ ចុះមកអញ្ជើញ
ព្រះបាទនេមិរាជឲ្យស្តេចយាងទៅតាវតឹង្ស ។

កន្ធទណ្ឌ: ដែលព្រះបាទនេមិរាជគង់វែយន្តៈ ដរាប យាត្រាចេញចាកព្រះនគរទៅនោះ ទ្រង់មានព្រះពាជបំណងប៉ងទស្សនាការស្ថានទរក ទើបត្រាស់ឲ្យមាតលីទេពសារថី បែររថចុះទៅផ្លូវបាជាលដំណាលសំដែងរឿងនរកថ្វាយព្រះអង្គឲ្យទ្រង់ជ្រាប តាមសមគួរដល់សេចក្តីមានប្រាកដក្នុងគម្ពីរដូចតទៅនេះ:

๑ - វេតរណីនទីនរក: នរកស្ទឹងបង្អាផ្តៅ (អធិប្បាយរួចហើយ[๑])

๒ - សុនខនរក: នរកសុនខ គឺនរកដែលពេញទៅដោយឆ្កែផ្សែងៗ មានគាថាសំអាងថា:

សាមា ច សោណា សវលា ច កិដ្ឋា
ការោលុសង្ឃា ច អនេន្តិ ភេរវា ។

ប្រែថា "កន្ធនរកនេះ ពេញទៅដោយឆ្កែផ្សែងៗ ក្រហមខ្លះ ពណ៌ល្អខ្លះ មានទាំងហ្វូងគ្មានគណនា ដែលមានខ្លួនធំៗ គួរខ្លាច" ។

កំពុងសេចក្តីតាមអដ្ឋកថាថា:

ឆ្កែទាំងនោះ មានខ្លួនធំៗ ប៉ុនដំរីសារ សម្រាប់ទាំងត្រចក់ពួកសត្វនរក ទឹងពួកសត្វក្នុងនរកនេះ មានរាងកាយកំពស់ ๓ គាវុត គឺ ๓๐๐ សិន, កាលពួកឆ្កែដេញខាន់ហើយ ក៏ត្រចក់ទាំងឲ្យដួលចុះលើ

---

๑ មើលភាគ្មុគសុវិយោ ឆ្នាំ ๑๙๔๑, លេខ ๑ ទំព័រ ๘๖ ។

ផែនដែកក្រហម យកដើងមុខទាំងពីរឡើងជាន់ចំដើមទ្រូង ទាំងថ្ពាល់
សាច់ស៊ីទាល់តែអស់ នៅសេសសល់តែឆ្អឹង ។ ពួកត្មាតតាជក់
សុទ្ធសឹងតែមានខ្លួនធំ ។ ប៉ុន្តែរូបរាងនេះ មានចំពុះជាដែក តែងចឹកហែកស៊ី
សត្វក្នុងនរកនេះ ។

ចំពោះកម្មដែលនាំឲ្យធ្លាក់នរកនេះ លោកសំដែងទុកត្រឹមពីរយ៉ាង គឺ
សេចក្តីកំណាញ់ទីងការដេរស្តីសមណព្រាហ្មណ៍ មានគាថាបញ្ជាក់
ពន្យល់ទុកមកថា

យោ កោចិមេ មច្ឆរិនោ កទរិយោ
បរិភាសកោ សមណព្រាហ្មណានំ
ហីនេន្តំ ភេសន្តិ សុចាបជម្ហា
តេ លុទ្ទកម្មា បសវេត្វ ចាបំ
តេ មេ ជនេ តាតោ លុទ្ទសង្ឃា អនេន្តិ ។

ប្រែថា បុគ្គលណាមានសេចក្តីកំណាញ់ទីងហាមប្រាមគេមិនឲ្យ
ធ្វើទាន ទីងដេរស្តីបៀតបៀនគំរាមគំរេកសមណព្រាហ្មណ៍ បុគ្គលពួក
នោះឈ្មោះថាធ្វើកម្មដ៏អាក្រក់ត្រូវធ្លាក់នរកនេះ ត្រូវពួកក្អែកត្មាតទីងតាជក់
ចឹកពាសកាយ ។

๓ - អយបឋវីនរក: នរកផែនដែកក្រហម គឺនរកដែល
មានផែនដីជាផែនដែកក្រហមប្រមាណ ๙ យោជន៍ ពួកសត្វនរកនេះ

ត្រូវពួកនាយនិរយបាលវាយដោយអន្ទង់ដែកក្រហមប៉ុនដើមត្នោត ឲ្យដួលចុះ ហើយសំពង់ដោយញញួរដែកចែមទៀត រហូតដល់បែកល្អិតល្អន់ ទើបទ្វីមានគាថានិពន្ធថា

សញ្ជាតំ កូតា បមវី កម្មន្តំ
តង្គេហិ ខន្ទេហិ ច បោថយន្តិ ។

ប្រែថា ពពួកសត្វក្នុងនរកនេះ ជាអ្នកមានរាងកាយអណ្តែតឡើងដើរទៅតាមផែនដី ត្រូវពួកនាយនិរយបាលសំពង់ដោយញញួរដ៏ក្តៅ ។ ឃាបកម្ម ដែលនាំឲ្យធ្លាក់នរកនេះ លោកពោលទុកតឹមការបៀតបៀនទំនឹងគ្រាមគ្រៃ មានគាថាសំអាងថា

យេ ជីវលោកស្មឹ សុចាបចម្មិនោ
ឧរញ្ជ ឆារិញ្ជ អចាបចម្មំ
ហឹសេន្តិ ភេសេន្តិ សុចាបចម្មា
តេ លុទ្ទកម្មា បសវោតូ ចាបំ
តេមេ ឆជា ខុទ្ទមាតា សយន្តិ ។

ប្រែថា ជនណាកើងជាវលោកនេះ ជាអ្នកមានចិត្តអាក្រក់បៀតបៀនត្រគោះតំពាមគំពេះផេះស្លឹនជនជាតិប្រុសស្រី ដែលមិនមានសេចក្តីខុសជនដែលធ្វើកម្មដ៏អាក្រក់ទាំងនោះ លុះធ្លាសេចក្តីអាក្រក់ហើយ រមែងត្រូវប្រហារដោយញញួរដែក ។

៤ – អង្គារកាសុនរក : នរកឆេីកភ្លេីង គឺនរកឆេីកភ្លេីង ក្នុងនរកនេះពួកសត្វនរកត្រូវនាយនិរយបាលដេញវាយដោយញញួរដែកក្រហមក្តៅ ឲ្យចុះទៅក្នុងរណ្តៅឆេីកភ្លេីង ពួកសត្វនរកធ្លាក់ទៅក្នុងរណ្តៅឆេីកភ្លេីងតឹមចង្កេះ ចំណែកពួកនាយនិរយបាល បានយកកន្ត្រងដែកធំៗ ជួសជងរឆេីកភ្លេីងដែកក្រហមចាក់តរបន្ថែមលេីក្បាលទៀត សត្វនរកទាំងនោះ កាលមិនអាចអត់ទ្រាំកំដៅបាន ក៏នាំគ្នាយំអន្ទះអន្ទែងខ្ញាចផ្សា ។

ឋាបកម្មដែលនាំឲ្យធ្លាក់នរកនេះ លោកពោលទុកតឹមតែមួ៉ាង មានគាថានិពន្ធថា

យេ កោធំ បូតាយ ឥធ សត្តា ហេតុ
សក្កឹ កាតុ្វ ឥមំ ជា យន្តិ
តេ ជាយរិត្វា ឧនតំ ឯនិន្ទ
តេ លុទ្ធកម្មា បតរវេត្វ ឆាបំ
តេមេ ឯជា អង្គារកាសុំ ឋុនន្តិ ។

ប្រែថា ជនណា ដេីរធេ្វីកវៃរោសនាវត្ថុរបស់អ្នកស្រុកមកបរិភោគដោយអាងថាវៃរៅសាងថាវរវត្ថុ ឬបូជាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កាលបុគ្គលនោះស្លាប់ហេីយវមែងធ្លាក់នរកឆេីកភ្លេីង ។

๕ — លោមាកុម្ភីនរកៈ នរកខ្លះទៀតដែរ (អធិប្បាយរួចហើយ[๑]) ។

๖ — អយោឧកាឧរកៈ . នរកទឹកដែលក្រហម ក្នុងនរកនេះ ពួកនាយនិរយបាល យកឈើដែលឆេះជាអណ្តាតភ្លើងចង្កៀកសត្វនរកទាំងឡាយទាញកន្ត្រាក់ឲ្យដួលចុះ ហើយតែមួលកឲ្យដាច់ទៅ ដូចមួលកចាបម្ភកមាន់ហើយបោះចុះទៅក្នុងទឹកក្តៅ មានគាថាពន្យល់ថា

លុញ្ចន្តិ តិរំ អថ យេឋយិត្វា

ឧណ្ហោឧកស្មិំ បកិលេឧយិត្វា ។

ប្រែថា ពួកនាយនិរយបាលចង្កៀកសត្វនរកហើយមួលឲ្យដាច់ហើយបោះចុះទៅក្នុងទឹកក្តៅ ។

ក្នុងអដ្ឋកថាថា សត្វក្នុងនរកនេះ មានខ្នងកំពស់ ๓๐๐ សិន កាលត្រូវនាយនិរយបាលមួលកដាច់ហើយ ក៏មានកដទៃទៀតកើតឡើងជំនួសសោយទុក្ខតទៅ ។

ចាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់អ្នកធ្វើចាបជាគ្រឿងសត្វស្លាប មានគាថាសាធកៈថា

យេ ជីវលោកស្មិំ សុចាបឆម្ភិនោ

ឧក្កឹ កមោត្វាន វិហេឋយន្តិ

---

๑ មើលអដ្ឋកថាសុរិយោលេខ ๙ ឆ្នាំ ๑๙๘๘ ទំព័រ ๖๘๓ ។

តេ ភោជយិត្វា សកុណាំ ឧដ្ឋិតេ
តេ លុទ្ធកម្ហា បរិវត្តេ ឆាបំ
តេមេ ជនា លុទ្ធវិសា សយន្តិ ។

ប្រែថា មនុស្សមានចិត្តអាក្រក់ឯណាក្នុងលោកនេះ បៀតបៀនសត្វស្លាប់ទាំងឡាយ មនុស្សដែលមានចិត្តអាក្រក់ទាំងនោះ រមែងត្រូវមួលក (ឲ្យដាច់) ។

៧– ឧសនរក: នរកអង្គារ កងនរកនេះជាស្ទឹងមួយដែលមានទឹកថ្លាពេញប្រៀប កាលពួកសត្វនរកត្រូវសេចក្តីក្តៅដោយអណ្តាតភ្លើងកងរណៃដែលទៅលើផែនដែកក្រហម, លុះឃើញស្ទឹងនោះ ក៏ចូលចិត្តថាទឹងហានង្ងូតធឹកសប្បាយ តែកាលលោតចុះទៅហើយធឹកទឹកនោះ ចូលទៅដល់កងពោះ ទឹកនោះក៏ក្លាយជាអង្គារដ៏ក្តៅ ឆេះពោះវៀនដាច់ជាកំណាត់ៗ ហើយហូរធ្លាក់ចុះទៅតាមទ្វារក្រោម មានគាថាបញ្ជាក់ថា:

ឥហ តុ តោយា អនិច្ចាតកម្មា
ឧទី អយំ សន្ទតិ សុបតិត្ថា
យម្ហា កិតត្តា មនុជា បវដ្ដិ ។

ប្រែថា ស្ទឹងនេះ ពេញទៅដោយទឹក មានច្រាំងមិនជ្រៅ មានកំពង់ល្អ ពួកសត្វទាំងឡាយ ដែលត្រូវសេចក្តីក្តៅគ្រប់សង្កត់ហើយរមែងធឹកទឹកក្នុងស្ទឹងនោះ ទឹកដែលធឹកទៅហើយ រមែងក្លាយជាអង្គារ ។

កម្មដែលនាំឲ្យធ្លាក់នរកនេះ ឃានដល់ការយកស្រូវស្អកឬអង្កាមបន្ទុំ (ចែកជាវគ្គ) ធ្វើជាអង្កលក់ មានគាថាជាបច្ចន្តថា

យេ សុទ្ធញ្ញំ វណាសេន មិស្សំ
អសុទ្ធកម្មា ភយំនោ ឧទន្តិ
ឃម្មាភិតត្តាន បិបាសិតានំ
បិវន្តញ្ហេសំ ថុសំ ហោតិ ចាតិ ។

ប្រែថា មនុស្សមានចិត្តមិនបរិសុទ្ធពួកណា ឃានលាយអង្កវដែលល្អស្អាតដោយអង្កាម លក់ឲ្យអ្នកដទៃ មនុស្សពួកនោះ គ្រាត្រូវសេចក្តីក្តៅគ្រប់សង្កត់ហើយ មានសម្បែកស្រែកទឹក, ទឹកដែលគេផឹកចូលទៅក៏ក្លាយជាអង្កាម ។

៨ – អយសូលនរក : នរកចម្រឹង លោកសំដែងទុកថា មានពួកនាយនិរយឃាលចាំចាក់ឆ្អឹងជំនីរសត្វនរកដោយអាវុធផ្សេងៗ មានចម្រឹងដែកជាដើម ពង្រាយសត្វនរកទាំងនោះ ឲ្យដាប់ជាកំណាត់តូចកំណាត់ធំ មានគាថាសំដែងទុកថា

ឧស្សហិ សត្តីភិ ច តោមរេហិ
ឧភយោឯ បស្សេ ភុនន្តិ ភេទ្ធុំ

ប្រែថា នាយនិរយឃាលទាំងឡាយ វាមែងចាក់ឆ្អឹងជំនីរទាំងពីរបស់ពួកសត្វនរកដែលគាំគ្រានៅ ដោយចម្រឹងនឹងលំពែងនឹងដែកស្រួច ។

កម្មដែលនាំបណ្តាលឲ្យធ្លាក់នរកនេះ លោកពោលទុកត្រឹមតែយ៉ាង គឺការលួច ៣ យ៉ាងមានគាថាសំអាងថា

យេ ជីវលោកស្មឹ អសាធុកម្មនោ
អនិដ្ឋមាធាយ ភវេន្តិ ជីវិតំ
ឆឡាំ ឆនំ វជ្ជ ជាតរូបំ
អជេឡកញ្ចាបិ បសុំ មហាសំ
តេ លុទ្ធកម្មា បសវេត្វ ចាបំ
តេមេ ជនា សត្តហតា សយន្តិ ។

ប្រែថា ជនពួកណា ដែលជាអ្នកបួលចិត្តប្រព្រឹត្តធ្វើអំពើមិនល្អកន្លងជីវលោកនេះ ឃានលួចយកស្រូវអង្ករ, ទ្រព្យមាសប្រាក់, ចៀមគ្រប់របស់អ្នកដទៃមកចិញ្ចឹមជីវិត ពួកអ្នកដែលធ្វើអំពើមិនល្អទាំងនោះ លុះធ្លើសេចក្តីអាក្រក់ហើយ រមែងត្រូវចាក់ដោយលំពែង ។

๙– សញ្ជោតិនរកៈ :– នរកអាវុធដែកក្រហម លោកសំដែងទុកថា មានពួកនាយនិរយបាល ចងកសត្វនរកដោយខ្សែដែកដ៏ធំ ដែលឆេះជាអណ្តាតភ្លើង ទាញអូសទៅតាមផែនដីដែកដ៏ឆេះសន្ធោសន្ធៅ គ្រាសត្វនរកដួលចុះហើយ ក៏ប់យដំដោយអាវុធផ្សេងៗ មានគាថាបញ្ជាក់ថា

តីហាយ ពន្ធា កសិរាមេ បុនេកេ
អញ្ញេ វិកន្តា វិលកតា សយន្តិ ។

ប្រែថា ពួកសត្វនរកក្នុងនរកនេះ រមែងមាននាយនិរយបាលយកខ្សែចងកសំខ្សែសាច់ចេញជាកងទុក្ខដូចសំខ្សែសត្វត្រៃ ។

ក្នុងអដ្ឋកថាថា សត្វក្នុងនរកនេះត្រូវនាយនិរយបាលសំខ្សែសាច់កងទុក្ខជាកងធំៗ ។

កម្មដែលនាំឲ្យមានកំហុស បណ្តាលឲ្យធ្លាក់ចុះនរកនេះ លោកថាទុកតែត្រឹមការសំឡាប់សត្វលក់ មានគាថាជាបច្ចន្តនថា

ឯវញ្ហិ កោ សូករំ កោ ច មញ្ជិកោ
បសុំ មហាសញ្ញ អជេឡកញ្ច
ហាន្តាន សូណោសុ បសារយីសុ
តេ លុទ្ទកម្មា បសវេត្វ ចាបំ
តេមេ ជនា វិលកតា សយន្តិ ។

ប្រែថា បុគ្គលពួកណាសម្លាប់ពពែ ចៀមជ្រូកត្រីគោក្របីហើយនាំទៅលក់ទីផ្សារ បុគ្គលពួកនោះ រមែងត្រូវនាយនិរយបាលសំខ្សែសាច់ចេញទុកជាកងធំៗ ។

๑๐ ភូថនរកៈ — នរកដុំលាមក (អធិប្បាយរួចហើយ)[๑]

๑๑ លោហិតបុព្វនរកៈ — នរកឈាមទឹកខ្ទុះ ពួកសត្វក្នុងនរកនេះឯងផឹកស៊ីតែឈាមទឹកខ្ទុះ មានគាថានិពន្ធថា (មានន)

---

๑ មើលកម្ពុជសុរិយាលេខ ๘ ឆ្នាំ ๑๙๖๘ ទំព័រ ๖๙๒ ។

សញ្ញាប័ត្រលេខ ៣៩៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ម៉ុក-វស់ នាមឆាយា ធម្មសរ កើតឆ្នាំជូត អាយុ ៦១ វស្សា ៤០
ជាចៅអធិការ វត្តស្នោង ឃុំស្នោង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
វស់-ហ៊ីង នាមឆាយា ធម្មសរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៧
ជាចៅអធិការ វត្តជង្កោង ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ចាន់-ជិន នាមឆាយា ជិនត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៧
ជាគ្រូសូត្រស្តាំ វត្តស្វាយអង្គ ឃុំព្រៃ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
កូវ-ចក់ នាមឆាយា សុវណ្ណជោត កើតឆ្នាំជូត អាយុ ២៥ វស្សា ៥
ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
យ៉ែម-ដួង នាមឆាយា គន្ធសរ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូ
សូត្រស្តាំ វត្តក្រចៅ ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៀវ-ធន នាមឆាយា ធម្មប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រធ្លេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម-មួង នាមឆាយា ចន្ទត្ថេរ កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣៥ ជាគ្រូសូត្រស្តាំ វត្តសង្កែ ឃុំសាំងយ៉ាង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គឹម-សែម នាមឆាយា ធម្មកេសរ កើតឆ្នាំរកា អាយុ ៤០ វស្សា ២០ ជាគ្រូសូត្រធ្លេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ វង ខេត្រ នាមឆាយា តន្ទជោត កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តជង់ក្តោង ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កូវ-សាន នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំឆ្លូវ អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យឺ-ញ៉ាង នាមឆាយា សុវណ្ណជោត កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តមុនីវតន: ឃុំសាំងយ៉ាង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុង - សន នាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ - តេង នាមឆាយា សុវណ្ណជោត កើតឆ្នាំ ១៨៩០ អាយុ ៥៨ វស្សា ២៦ ជាចៅអធិការ វត្តបន្ទាយជ័យ ឃុំកំពង់ត្រាស ស្រុកក្រូចឆ្នារ កំពង់ចាម ។

សញ្ញាប័ត្រលេខ ៤១០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អឹម - ហួន នាមឆាយា ជោតត្តេរ៍ កើតឆ្នាំមមី អាយុ ៣១ វស្សា ១០ ជាចៅអធិការ វត្តស្អាង ឃុំទីពោធិ៍ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤១១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុិខ - ចេង នាមឆាយា តន្ទវិនយ កើតឆ្នាំកែង អាយុ ៣៣ វស្សា ១០ ជាចៅអធិការ វត្តពោធិ៍ពិសី ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤១២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ពេជ្រ - សួន នាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ៣២ ជាចៅអធិការ វត្តស្វាយទាប ឃុំស្ទុំត្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-អ៊ុច នាមនាយា ឥន្ទ្រត្ថេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៧ ជាចៅអធិការ វត្តអង្គខ្នាប់ ឃុំព្រៃញាត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤១៤ ចុះថ្ងៃសៅរ៍ ៥ រោចខែកត្តិកឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ហ៊ាក់-ទុម នាមនាយា ឥន្ទ្រជោត កើតឆ្នាំច អាយុ ៥១ វស្សា ២៩ ជាចៅអធិការ វត្តតន្ទលីបូណ៌ វត្តកំពង់អំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៤២០ ចុះថ្ងៃចន្ទ ១៣ រោចខែកត្តិកឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ព្រំ-មាស នាមនាយា ឥន្ទ្រត្ថេរ កើតឆ្នាំមមី អាយុ ៥៥ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ ឃុំពោធិ៍អង្គ្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤២១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សួស មាស នាមនាយា មណ្ឌត្ថេរ កើតឆ្នាំវក អាយុ ២៩ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាបត្រលេខ ៤២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គុយ-តុប នាមនាយា វតនត្ថេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៧ ជាគ្រូសូត្រស្តាំ វត្តអង្គវៀល ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤២៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ពេជ្រ-កៀក នាមឆាយា សុមនត្ថេរ អាយុ ៣៧ វស្សា ១៧ ជាគ្រូ សូត្រធ្វើង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈុន-ធិន នាមឆាយា គន្ធជោត កើតឆ្នាំច អាយុ ៥១ វស្សា ១៤ ជា គ្រូសូត្រស្តាំ វត្តព្រះនិព្វាន ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤២៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កើត-សឿង នាមឆាយា សុមនត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តធ្លង ឃុំធ្លង ស្រុកខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក-ចាន់ នាមឆាយា ចន្ទត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រធ្វើង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ-ព្រឿង នាមឆាយា ព្រហ្មសរ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ៦ ជាគ្រូសូត្រធ្វើង វត្តខ្វែក ឃុំទឹកល្អក់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-សៀក នាមឆាយា សុន្ទរត្ថេរ កើតឆ្នាំច អាយុ ៣៩ វស្សា ១២ ជាគ្រូសូត្រស្តាំ វត្តខ្នុមតីរ ឃុំស្វាយតាត្រៅ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពៅ-ផូរ នាមឆាយា ចន្ទត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៩ ជាគ្រូសូត្រធ្វើង នៅវត្ត:ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជាម-ឈន នាមឆាយា ចន្ទត្ថេរ កើតឆ្នាំពេង អាយុ ៣៣ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តកាត់ក្តុក ឃុំផុង ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-សាន់ នាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រធ្វើង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សម-ជាំ នាមឆាយា ព្រហ្មត្ថេរ កើតឆ្នាំពេង អាយុ ៣៣ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តគ្រាំងក្រូច ឃុំដើងរុក ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ស៊ីម នាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ២៤ វស្សា ៤ ជាគ្រូសូត្រធ្វើង វត្តខ្លូលក្វាស ឃុំផុង-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ឡុង នាមឆាយា ធម្មប្បញ្ញោ កើតឆ្នាំជូត អាយុ ៦១ វស្សា ២៦ ជាគ្រូសូត្រស្តាំ វត្តអង្គព្រះស្រី ឃុំព្រៃភ្នាត ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៥ ចុះគាលបរិច្ឆេទដដែល នាមឆាយា ចន្ទត្នេរ កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ១៦ ជាគ្រូ សូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អាន-វុន នាមឆាយា សុវណ្ណត្នេរ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តអង្គរោង ឃុំព្រៃញាត ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន-អ៊ុន នាមឆាយា ឥន្ទជោត កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តថ្កល់រកា ឃុំបវែត ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន យ៉ែម នាមឆាយា សុធម្មប្បញ្ញោ កើតឆ្នាំមមែ អាយុ ៣០ វស្សា ៨ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កឹម-ពេជ្រ នាមឆាយា ធម្មជោត កើតឆ្នាំមមី អាយុ ៤៣ វស្សា ២២ ជាគ្រូសូត្រស្តាំ វត្តបវែត ឃុំបវែត ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ-ណៃ នាមឆាយា សុវណ្ណត្នេរ កើតឆ្នាំមមី អាយុ ៤៣ វស្សា ១១ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែ-សឿង នាមនាយា តន្ធូត្តេរ កើតឆ្នាំមមី អាយុ ៤៣ វស្សា ២១ ជាគ្រូសូត្រស្តាំ វត្តអង្គសំទង ឃុំស្នំក្រពើ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃួន-នាង នាមនាយា តន្ធូត្តេរ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ណុប-យិម នាមនាយា តន្ធូជោត កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តកំពង់ថ្ម ឃុំនិគាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួង-សាផន នាមនាយា តន្ធូត្តេរ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តស្វាយគាប ឃុំស្នំក្រពើ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ូ-ទីវ នាមនាយា តន្ធូត្តេរ កើតឆ្នាំខាល អាយុ ២៣ វស្សា ១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួង-កឿង នាមនាយា ហិន្ធូត្តេរ កើតឆ្នាំរោង អាយុ ៤៥ វស្សា ១២ ជាគ្រូសូត្រស្តាំ វត្តអង្គព្រះពាន ឃុំវាល ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ក់-ជិត នាមនាយា ព្រហ្មជោត កើតឆ្នាំថោះ អាយុ ៥៨ វស្សា ៣៨ ជាគ្រូសូត្រស្តាំ វត្តត្រពាំងត្រពើ ឃុំព្រះនិព្វាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ វ៉ែន-ពូក នាមនាយា ពុទ្ធត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប-អឹម នាមនាយា សុធម្មត្ថេរ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តអង្គលំទង ឃុំនិព្វាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ដែក-ហត់ នាមនាយា សុធម្មត្ថេរ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក-សួង នាមនាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ល្ប៉ាំ ឃុំស្វាយរំពា ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ុប-អ៊ូច នាមនាយា ឥន្ទជោត កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ុក - ជិម នាមធាយា ធម្មវិជ្ជោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជា គ្រូសូត្រស្តាំ វត្តអង្គទន្ទាប់ ឃុំព្រៃញាត ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤៥៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សួស - ប៉ាត់ នាមធាយា ធម្មកេសរ កើតឆ្នាំជូវ អាយុ ២៤ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ តន់ - សួន នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ៥២ វស្សា ៣១ ជាគ្រូសូត្រស្តាំ វត្តអន្ទង់គគីរ ឃុំព្រៃនិព្វាន ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ី - សាប៊ុន នាមធាយា ព្រហប្បញ្ញោ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក - វ៉ែន នាមធាយា វិនកេសរ កើតឆ្នាំ ១៩១២ អាយុ ៣៦ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តព្រៃទទឹង ឃុំព្រៃនិព្វាន ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ណន - រឿន នាមធាយា សិរិមត្ថេរ កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។ (មានត)

ស្នើអំពីរឿងស្ថាបនាវិទ្យាស្ថានមួយ

សម្រាប់សិក្សាភាសាឥណ្ឌៅ - ខ្មែរ នៅភ្នំពេញ

លោកវ៉ាយ - ប៉ុក ក្រុមការក្រុមពុទ្ធសាសនបណ្ឌិត្យ ថ្លែងចេញពីបរទេសមកខ្មែរ

ការសិក្សាភាសាឥណ្ឌៅទូទៅ ជាកិច្ចមានប្រយោជន៍ នឹងសារៈសំខាន់ចំពោះប្រទេសកម្ពុជា ដូចគ្នានឹងការសិក្សាភាសាក្រិក - ឡាតាំង ដែលគេដាក់ទុកសម្រាប់និស្សិតរៀនសូត្រ នៅសាលារៀនក្នុងប្រទេសបារាំង, ការចេះដឹងនូវភាសាសំស្ក្រឹតនឹងបាលី ព្រមទាំងអារ្យធម៌ឥណ្ឌៀ ដែលខាក់ខែងដោយអារ្យធម៌នៃប្រទេសជិតខាង ខាងផ្លូវប្រវត្តិសាស្ត្រ, ជាកិច្ចគួរបំពេញ ដើម្បីស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីបុរាណខ្មែរ ដែលមានអត្ថដ៏គម្ពីរភាព ហើយនឹងងាយស្វែងរកនូវតុ ដែលជាបុព្វហេតុនៃទំនៀមទម្លាប់នោះ ។

ព្រោះហេតុដូច្នេះ ត្រូវតែបណ្ដិតខ្មែរកុងកាលជាអនាគតប្រមូលគ្នាឲ្យបានច្រើនជាងមុន ដើម្បីនឹងចូលទៅសន្ធនាការអំពីរឿងបូព៌ាវិទ្យានិយមរវាងប្រជាជាតិ (l'orientalisme international) មានការសិក្សាខាងភាសាឥណ្ឌៀជាកិច្ចត្រូវស្វែងរកដោយពិសេស, បណ្ឌិតទាំងនោះ ក្នុងពេលសន្ធនាការរឿងរ៉ាវក្នុងសាកលលោក អាចធ្វើតទុកាសរកផល

ប្រយោជន៍ក្នុងរឿងនោះ ជាកត់បញ្ចូលមកក្នុងចំនៀមទម្លាប់ប្រពៃណីខ្មែរបាន លោកអ្នកប្រាជ្ញទាំងប៉ុន្មាន អាចចូលទៅប្រសើយចំពោះកិច្ចការខាងសាលាបានពិបូតាប្រទេសដែលជាតំណាងក្នុងការស្វែងរកបូតាវិទ្យានិយមជាសាធារណៈ អាចរៀបចំនូវក្រមសញ្ញាតិខ្មែរ ខាងសិលាចារឹកបុរាណវិទ្យា នឹងស្ថាបនានូវមជ្ឈមសិក្សានិស្សិតខ្មែរ ដែលត្រូវយកសាស្ត្រាចារ្យមានសមត្ថភាពខាងភាសាតណ្ហៀមកបង្រៀនបានដោយងាប់រហ័ស ។

ដើម្បីនឹងឧបត្ថម្ភបណ្ដិតខ្មែរ ដែលពេញចិត្តក្នុងការស្វែងរករឿងនេះ, ប្រទេសបារាំងសែសគួរស្នើចំពោះកម្មវរដ្ឋអំពីគ្រោងការស្ថាបនាវិជ្ជាស្ថាននៅក្រុងភ្នំពេញ សម្រាប់សិក្សាទត្តមវិជ្ជាដែលគេអាចយកគោលការសិក្សាកិច្ចស្វែងរកភាសាតណ្ហៀនៃសាលាទត្តមវិជ្ជានៅប៉ារីសមកបញ្ចូលផងបាន ។

ការសិក្សានេះ ត្រូវបើកសិទ្ធិឲ្យជនគ្រប់រូបចូលទៅរៀនបានដោយសេរី ឥតមានរើសមុខ, គុណបំណាច់ដែលរៀនក្នុងសាលានោះ ត្រូវបានសញ្ញាប័ត្រមួយ ដែលនឹងប្រគល់ឲ្យបាន លុះត្រាតែបេក្ខជននោះបានធ្វើកិច្ចការអ្វីមួយដ៏គាប់ប្រសើរ ហើយបានចូលទៅរៀនបណ្ដោះអាសន្ននៅសាលាក្នុងរយៈពេល ២ ឆ្នាំ ដោយទទួលសេចក្ដីយល់ព្រមពី

គណៈកម្មការសាលា ដែលបានយកវប្បធម៌ខ្មែរទៅបង្ហាញចំពោះចាងហ្វាងសាលានោះ ។

នៅភ្នំពេញ ការសិក្សានេះដែលនឹងធ្វើបាន លុះត្រាតែចាត់ចាងហ្វាងនៃការសិក្សាមួយនាក់ពីប៉ារីស ក្នុងរយៈពេល ៦ ខែក្នុង ១ ឆ្នាំ, លើខាងការផ្ទាន់ជាអាចនៅក្នុងនៃវិជ្ជាស្ថានខ្មែរសិក្សានេះ ត្រូវមានសមាជិកខាងសាលាបូព៌ាប្រទេសម្នាក់មកកាន់ការនៅភ្នំពេញ បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ សម្រាប់ជាមន្ទីរធ្វើការឆ្លងៗ នៃក្រុមនេះ, ប្រាក់ចំណាយក្នុងរឿងនេះ ត្រូវប្រទេសបារាំងសែស នឹងប្រទេសកម្ពុជាខ្ចួលបន្ទុកជួយគ្នាទៅវិញទៅមក, ប្រាក់ប្រៀវត្សនៃចាងហ្វាងសាលាត្រូវប្រទេសបារាំងសែសចេញឲ្យ ចំណែកខាងប្រទេសកម្ពុជា ត្រូវចេញតែខាងប្រាក់ចំណាយសោហ៊ុយសំណាក់អាស្រ័យក្នុងពីរនេះ នឹងថ្លៃយានដំនិះ ។

ចំពោះឆ្នាំ ១៩៥០ ប្រាក់ចំណាយក្នុងរឿងនេះ តាមសេចក្តីស្មាន នៃពាជវរដ្ឋាភិបាលខ្មែរប្រហែលជា ៦ - ៧ ម៉ឺនរៀល ។

កម្ពុជសុរិយា

ស្បៀតវិទ្ធ ផ្សាយដំណឹងខាងសាសនា ទំនៀតប្បវេណី ប្រពៃផ្សេងៗ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហួង ខឹម ភ្នូ ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះវេតសត្ថា ស្មរ-ហាយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	បញ្ជីរឿង	ទំព័រ
ឃុន សំរ៉ាមេធ ស្រ៊ែ-អ៊ូ	បណ្តាំមាតា	៨១១
កំពូ ឈឹម-សារេត	រថរត្ងៀស្រែ	៨០៦
លោក ភ័ឃ-ប៊ុក ក្រមការ	សុភាសិតខ្មែរភាគទី ២ (តទៅ).....	៨២១
ហួង ខឹម ភ្នូ ញ៉ុក-ថែម	ស័ព្ទបាតំនៃប្រែជាខ្មែរបច្ចុប្បន្នកាលកម្មការវិប្បធម៌ (តទៅ).....	៨២៥
—	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តទៅ)..	៨៣៩
អ្នកឧកញ៉ាព្រះឃ្លាំងខង	រឿងកោតកុលកុមារ ពាក្យកាព្យ (តទៅ)	៨៤៥
ផ្នែកសាសនា		
លោក ភ័ឃ-ប៊ុក ក្រមការ	ពន្ធអាស៊ីទ្វីប (តទៅ)	៨៥៥
មហា ឧទ-ណាត្រ	ខ័រយកថា(តទៅ-ចប់)	៨៦៤
កំណត់ទំនៀមប្រវត្តិការណ៍		
ក្រសួងធម្មការ	បញ្ជីរាយនាមថៅតធិការដែលតាំងថ្មី(តទៅ)...	៨៧២
លោក ភ័ឃ-ប៊ុក ក្រមការ	កំណត់ស្នើអំពីរឿងស្ថាបនាវិទ្យាស្ថានជួយសម្រាប់	
	សិក្សាភាសាខ្មែរ តទៅ នៅភ្នំពេញ.....	៨៧៤

ឆ្នាំទី ២១ – លេខ ១១ ខែវិច្ឆិកា ឆ្នាំ ១៩៤៩ – តំលៃដាច់ ១ ឆ្នាំ ៩៦ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
Khun-Sirimedhi Sry-Ou	Conseil de la mère	801
Phikhu Chhim-Sareth	Les Travaux des rizières.....	806
M. Ray-Buc Kramakar (I.B.)	Proverbes et maximes Tome II (suite)	821
Luong Nibandhamantrî Nhok-Thèm	Recueil des mots traduits par la Commission des mœurs et coutumes (suite)	825
—id—	Histoire sommaire de l'Inde (suite) ..	839
Néak Oknha Nong	Bhugkul kumar poésie (suite)	845

Partie religieuse :

M. Ray-Buc kramakar (I.B.)	La Lumière d'Asie (suite)	855
Mahâ Om-Nagry.	Nirayakathâ (suite et fin).....	864

Notes et chroniques

Ministère des cultes	Nomination des nouveaux chau Adhikar (suite)	872
M. Ray-Buc Kramakar I. B.	Note proposant la création d'un centre de hautes études Indo-Khmères à P.-Penh (Traduction).....	878

21e Année: N° 11 Novembre 1949 — Prix d'abonnement: 96$00 par an.

បណ្ដាំមាតា

ឃុនសិរីមេធី ស្រី - អ៊ី ក្រុមដំនុំព្រះវិហារបាបទីសក្រសួងពុទ្ធសាសនបណ្ឌិត្យជាអ្នករៀបរៀង ដោយឃុនយើញច្បាប់ចាស់ ក្នុងគ្រាំងមួយឈ្មោះច្បាប់ស្រីកាព្យពាក្យ ៧ មានសេចក្ដីពីរោះសមមម្យគួរយកមកចុះធ្យាយក្នុងសៀវភៅកម្ពុជសុរិយានេះ តែច្បាប់នោះរលុបឃ្លាត់ខ្លះ ឃ្លាល្អះកាព្យឃ្លោងក៏មិនសូវត្រឹមត្រូវតាមច្បាប់កាព្យឆន្ទ ទាំងមិនយើញឈ្មោះអ្នកតែងនោះទៀតផង ។ ខ្ញុំក៏តែងបន្ថែមបំពេញសេចក្ដី តែតម្រង់ឲ្យឃ្លានត្រឹមត្រូវតាមច្បាប់កាព្យទាំងប្រែឈ្មោះដើមចេញ ឲ្យឈ្មោះថាបណ្ដាំមាតាវិញ ព្រោះយើញសេចក្ដី ក្នុងផ្លែច្បាប់នោះ ជាឱវាទមាតាខ្លួនានកូនស្រី ។

៣ក្យ ៣ក្យ ៣

រឿងនេះខ្ញុំឯងចែងចងលើក ជាកាព្យល្បិចល្បើកពាក្យនេះណា
សម្រិទ្ធិសម្រាំងដោយសញ្ញា ទុកជាទំនងតរៀងទៅ ។
ជាច្បាប់មាតាទុកខ្លួនាន កូនស្រីគ្រប់ប្រាណដែលល្ងង់ខ្លៅ
ពុំដឹងកិច្ចកលការពេក់ស្បៅ ប្រដៅឲ្យដឹងក្ដីគួរសម ។
តែងតាមពាក្យចាស់លោកលើកមក គ្រាន់តែលំលកកេរបន្សំ
គ្រប់ពាក្យ ៧ តាមនិយម បញ្ចូលពាក្យផ្សំតាមបរិយាយ ។

ឱនឆែងចរចាចាហៃស្ងួន ពន្លកខ្ចីមខ្ជួនសំឡាញ់ម្ដាយ
ចូរនាងស្ដែងស្ដាប់អកិច្ចាឃ្យ នោមនាយកុំនាងគិតផ្ដេសផ្ដាស ។
ជ្រាតនាងនេះធំក្រែមុំពិត កុំពុងចូលចិត្តកញ្ចក់ក្រាស
ក្រមួនប្រែងមេម្ល៉ាខ្ចូរចារុំមាស ចំញៀនកងពាសពាក់ដើងដៃ ។
ខ្ជួននាងក្រមុំត្រូវគិតក្រែង កុំស្រើបដោយល្បែងនោះយប់ថ្ងៃ
កុំដើរមើលល្ខោនមើលអាយ៉ៃ ចាំឆ្លៃដល់ខ្ជួនស្ងួនពុំងា ។
កុំលោតអន្ទាក់ឈាក់កន្ទែង រត់ចាប់កូនក្ងែងបញ្ចូលគា
ឈរមើលយ៉ាកេបែរបៀតគ្នា ពុំងាយ៉ាងនេះប្រុសមើលងាយ ។
កុំលេងបៀប៉ោងប្ដូរស៊ីសង លេងនោះខុសច្បងណាស់ស្ងួនម្ដាយ
ជក់អាកៀនធឹកស្រោងឆ្ងាំងឡាយ ខូចកាយកុំឆ្លើអំពៅច្មោះ ។
រ៉ាសោតឯល្បែងឯងស្រីញ៉ែ កុំទៅរកវ័ក្បែរឲ្យសោះ
នាំឲ្យចោកឯយអាប់កេរ្តិ៍ឈ្មោះ គឺមោះពុំត្រូវនឹងច្បាប់ស្រី ។
ធម្មតាកំឡោះនឹងក្រមុំ កុំលេងលាយឡំនៅដោយដី
ពុំដែលត្រង់ទេមេកុំបី ឆឿឆ្ងីចិត្តប្រុសនោះណានាង ។
ខ្ជួននាងក្រមុំសមរាងរូប កាយកូនក្រអូបសព្វសិរីឆ្អឹង
ប្រុសត្រីលនឹងរបំឈប់ពាសពាង ឃើញនាងញញឹមញាក់រកគ្នា ។
ហើយចូលមកលេងនឹងឯងតត មានកោតក្រែងចិត្តក្រែងចិន្តា
លួកឡកឡឹមឡឺសុំដល់ស្ងា ហាគ្នាអង្អែលនុបអង្គឯង ។

ត្រែនាគេយើញខ្ញុំនឹងពិសី ដើរលេងដោយដឹតតងត្រែង
ទំនើងតែចិត្តចង់ប្រែឡង ចំបែងនឹងអ្នកស្រែស្រើបស្រាល ។
ម្ន៉ោះហើយនឹងកើតស្ដីអាស្រូវ កាចខ្នាសគេកូវភ្លេងលេង
គេជឹងសព្វសុសប្រុសតេញពាល កុំស្ងាលស្នេហ៍ស្និទ្ធនិតមេត្រី ។
ខានខេវខកសល់ជល់សេវកែ គ្មានប្រុសមួយស្នេហ៍ស្និទ្ធប៉ែតី
ដូចិតលេងពាក្យតោចន៍ពុំគប្បី ភ្លុលប្លីជាក់ជាអ្នកលេងរបេ ។
ហេតុខោះឯងមិញសំឡាញ់ម្ដាយ កុំគិតសប្បាយហើយបំភ្លេច
អស់ច្បាប់ទម្លាប់សព្វសេចក្ដែច វេះគេចដើរលេងមិនខុសប្លាហ៍ ។
ជាស្រីកុំលេងល្បែងទាំងអស់ ខឹងខូចកេរ្តិ៍យសខុសលក្ខណា
ខុបខ្ពែចចង្រៃត្រែមហិមា ខុក្លាជល់ជ្រុលមានជ្រុលជ ។
ខ្ញុំតើតជាស្រីស្រែចម្ការ រៀនធ្វើការងារឲ្យមានបង
រៀនត្បាញវៃឲ្យម៉ត់ចត់ កុំគិតខ្ជីឃ្លាតចំឲ្យម្ដង ។
រៀនដេរខោអាវខ្ចីយ៉ឺឲ្យល់ ពូកតែបកើយកល់ជាទ្រព្យខ្លួន
ត្រីងជ្រ៉ាក់ស្រែះស្រាក់ជាក្បាច់ក្បួន ជួសជុលចូរស្ងួនរៀនឲ្យគ្រប់ ។
ចង់គោមគាតតែប្រែឲ្យស្រេច រំលើករំលេចឲ្យសុសសព្វ
ចង់ជាផ្កាពុលផ្កាយីហឺប់ ជរជាប់ជាយស៊ីប់គួរយង់យល់ ។
ចង់ជាបុប្ផាផ្កាខទឹម តម្រង់តម្រឹមឲ្យអស់កល់
ក្អក់ពេជរំលេចដោយយោបល់ កុំឲ្យមានសល់សោះជាម្ដង ។

រៀនចង់ដាហង្សតង់តេនតើត ឯទាញដំខើតទំផ្លៀងផ្នង
ហ៊ិចហោះឆ្លងផ្លោះអាកាសលង់ង ហើយចង់ជារូបសត្វបក្សី ។
ចង់ជាចាបតូចចាបជង្កួរ ឬចាបស៊ីស្រូវណាកូនស្រី
ចង់ជារូបដៀបកប្បាសខ្ចី ពីសិចង់ជាផ្កាគ្រចាប់ ។
រឿងខាងឯហូលរៀនឲ្យចេះ ឲ្យស្គាត់រឿងនេះរហ័សធាប់
ចង់រួចជ្រលក់គក់ប្រញាប់ ផ្ចង្កាប់តា្បញ៉ាទៅពៅពុងា ។
ឯព្រៃរៀនកែគំនូរលៃលើក ជាតំជាល្បិចល្បើកតាមច្បាច្បា
កុំឲ្យមានខាល់សល់ត្រង់ណា ឧស្សាហ៍សន្សំខំកុំធ្វេយ ។
សង្វាតខ្ចីឃ្មោតឲ្យមាំមួន ធ្លើហ៊ើយចែងធួនមើលមុខក្រោយ
ក្រែងឆ្អែប្រខាំនាំដាច់ដោយ ប្រយ័ត្នកុំឲ្យពិបាកម្ដាយ ។
ធ្លើការជរិទោរចិត្តយប់ សំងំសៀមសូបកុំនិយាយ
ពីនេះពីនោះសុសសត្វសាយ ហើយសើចក្អាកក្អាយទៅពីស៊ី ។
មួយទៀតទំនៀតរៀនឥតក្បុរ រៀនធម៌រៀនឆាប់រៀនសំដី
រៀនសត្វសើចគ្រេចពាក្យពេចន៍ក្តី លោកិយនេះទើបច្រឡំគេ ។
មួយខ្លួនត្រមុំកុំធ្លើការ អង្គុយមាត់ទ្វារណាមាសមេ
ទោះយប់ទោះថ្ងៃចរៃនែ្ទ ពុំនោះសោតទេវាតលក្ខណា ។
កុំធ្លើឫកពាបែបឡេះឡោះ ប្រុសពាសតេញនោះហ៊ើយយាគ្រា
បង់ចោយត្រែងត្រែលង់ស្មា ចរចាញញឹមធ្លើសំដី ។

ចំអន់ចំអកឡកនេះខ្ទុះ មិនទាញមិនតុះធ្លើប្រើមប្រើយ
សំឡឹងសំឡក់ដូចឃើញអ្វី ស្រដីរែកចំគ្នាខនឹងខ្លួន ។
ខាងធ្វើយ៉ាងនេះគេរិះគិត ខុកជាចោរចិត្តខៅហើយស្មន
គេទឹងប្រមាទជាបដល់ខ្លួន គេកូនរែងតើតអាស្រែកែក ។
កុំសើយកុំលាត់ព័ត្តភាតប្តា កុំចរយោគាប្តូលកែវផ្ទៃ
ពាក់អាវគែបខ្លួនកូនមាសថ្លៃ កុំឆ្លើសើយស្រីអ្នកលេង ។
ធ្លើប្តូកសង្ហាត់តាសសោះ ស្លៀកពាក់ឃើញពោះអស់ក្តីធេង
ប្តូកពាមារយាទដូចកូនក្មេង ពេលគេនឹលែងដោះអស់ចេញគ្រៃ។
ស្រីនោះពិតពុំប្រែពៃទេ មាសមេកុំបៀតណាពាលទៅ
កុំតាមកុំគ្រាប់រាប់ជាធៀ ពុំហៅត្រូវច្បាប់ទេណាខាង ។
កងលោកសព្វថ្ងៃស្រីកងគ្រៃ បែរមៀនមើលទៅសព្វស៊ាឆ្គ
តតលក្ខណ៍កងជាណាមានតែពាង បើខាងធ្លើខ្លួនខុកជាជុះ ។
មួយថ្ងៃធ្លើខ្លួនបួនដប់ដង គាប់គកគាប់ស្រង្គើចហិះហុះ
ធាត់មេរៀសិតសក់កញ្ជក់ធ្នុះ រើរើរឹតសិតបន្តែ ។
លាបប្រែងគ្រមួនជួនថែមទៀត ធាត់មេរៀរមៀតមើលតតល្លែ
កន្ត្រាក់កញ្ជក់ស្ទុះស្ទើរតែ រលំផ្ទះគែងក្អកសុក្រំ ។
មកធ្នុះសព្វសុសដប់ដងគត់ ចាប់យកសំពត់ស្លៀកសក្តិសម
ពាក់អាវថ្នាំងថ្មីដៃលមានចំ បន្ទំចរចុះឲ្យប្រុសមើល ។ (អាន)

ឧបករណ៍ស្រែ

១ អំពីការធ្វើស្រូវប្រាំង, ២ ស្រូវស្ងួត, ៣ ស្រូវពង្រោះ,

របស់កសិករ ឈឹម - សារេត

សិស្សសាលាចាលីជាន់ខ្ពស់ - ក្រុងភ្នំពេញ

ស្រូវប្រាំង

ស្រូវប្រាំងនេះ គេធ្វើឥតពឹងដល់ទឹកភ្លៀងទេ តែត្រូវអូសយ៉ាងទឹកព្រែកឬបឹង ហើយធ្វើតែកន្លែងដែលអស់ទឹកភ្លៀង គឺកន្លែងដែលជាន់ឈ្មោះថា "ស្រូវប្រាំង" ។

របៀបធ្វើ ក្នុងរវាងរនោចខែបុស្សឬខែតខែមាឃ ត្រូវកកន្លែងសាបសំណាប ឯច្បាលសាបខោះ ត្រូវធ្វើកែរមាត់ព្រែកឬមាត់បឹង ដើម្បីនឹងប្រាបទឹកពីព្រែក - បឹងដាក់ ។

អំពីពូជ ស្រូវសម្រាប់ធ្វើស្រែប្រាំង គេជ្រើសយកតែស្រូវចៃម្យ៉ាង ព្រោះស្រូវនេះស្រាលរវាង ៣ ខែប៉ុណ្ណោះ ខ្ញុំបានប្រាប់ ។

កន្លែងធ្វើ របៀបធ្វើដែលគោលមកនេះ នៅក្នុងខែត្រស្វាយរៀង គេធ្វើតែកន្លែងជិតបឹងនឹងជិតព្រែក ព្រោះនៅជិតបឹងនេះសាខនឹងជិតព្រែកស្វាយរៀង វេលាខែប្រាំងទឹកនៅតិចល្មមធ្វើស្រូវបាន ។

វិធីដែលខ្ញុំធ្វើនោះទៀត គឺមានលំបាកខ្លះតែរកស៊ីខ្លួយ ព្រោះក្នុងថ្លៃព្រែកនោះ មានគល់ស្លាប់ដ៏ខ្លាំងស្រាប់ តែខ្ញុំតែងគាស់ណាចេញសង្ខប់ប៉ុណ្ណោះ សូម្បីទឹកក៏មិនបាច់យោងឬបាចដាក់ដែរ ព្រោះព្រែកនោះមានទឹកជោរនោច វេលាទឹកជោរឡើងក៏ពាចចេញសព្វគ្រប់សន្ធឹង ដល់ទឹកនោចចេញវិញរាងរាង ១ សង្ក្តាហ៍ប៉ុណ្ណោះខ្ញុំជោរឡើងវិញ ជាដំណោះស្រួលជាប់ជានិច្ច គឺមានស្ងួតសន្ធឹងឡើយ ។ ប៉ុន្តែអ្នកដែលធ្វើស្រែក្នុងថ្លៃបឹងនេះខាង ខ្ញុំយល់ថាតិចណាស់ ព្រោះបឹងនោះមានដែនទោចជាប់និងព្រែក វេលាទឹកឡើងច្រើនក្នុងថ្លៃបឹងក៏មានទឹកច្រើន បើទឹកនោចក្នុងថ្លៃបឹងក៏មានទឹកនោចដោយអន្ទុះ ព្រោះហេតុនោះ អ្នកធ្វើស្រែក្នុងបឹងត្រូវធ្វើទំនប់ ១ គ្រងជុំវិញបឹងសម្រាប់បើកឲ្យទឹកចូល ក្នុងពេលទឹកជោរ សម្រាប់ទប់ទឹកខ្ពុកក្នុងពេលដែលនោច ហើយក្នុងថ្លៃបឹងនោះមានស្មៅច្រើន ត្រូវប្រាបស្មៅរួចសឹមស្ងួត ។ អ្នកស្ងួតត្រូវស្ងួតឲ្យរង្គើលៗ ចំនួន ៥០ សង្កើមុត្រពីគ្នា ព្រោះថ្លៃព្រែក - បឹង តែងល្អជាងថ្លៃស្រែធម្មតា វេលាដែលស្ងួតរួចហើយ ត្រូវចាំថែមើលកុំឲ្យគោក្របីស៊ី ព្រោះរដូវនេះ ចំណីអ្នកស្រែលែងគោក្របីតបើគិត ។

វិធីបូងស្ងួន វេលាដែលស្ងួតរួចរាល់សព្វគ្រប់ហើយ ត្រូវធ្វើរបៀបសម្បូងសង្កែង ដល់ម្រៃញ្ញគិន្ធាលដែលខៅរក្សា ជង - ស្ទឹង - បឹង - ព្រែក ត្រូវធ្វើប៉ាយ៉ាប ហើយជាក់ខំបំណើ ពួតប៉ាយ ៤ ពំនូតជាក់លើប៉ាយ៉ាប

រួចយកទៅដេះតនៅមាត់ត្រែកឬបឹង ឬក៏ត្រង់កន្លែងណាដ៏សមគួរ ហើយ
អំពាវថា ហ៊ា អស់លោកនៅរក្សាទឹកដីនេះ ខ្ញុំសូមថ្វាយចាយ៉ាបនេះ
ហើយសូមឲ្យលោកជួយរក្សាដំណាំ ថែមទាំងកុំចាប់ខោសអូសដំណើរ
ដល់ខ្ញុំដែលមកនៅលើទឹកដីនេះ ។

ឯរបៀបធ្វើចាយ៉ាបនេះ សូមមើលក្នុងរឿងធ្វើស្រែវាគ្រាន់ធងចុះ
រំលែកដែលសន្លូងបែកគុម្ព បើនៅមានដីខូលាយមិនទាន់ស្លូង អាច
ទឹងចំបែកពីគុម្ពដែលរឹតធំៗ ទៅស្លូងទៀតបាន ដល់រំលែចេញឆ្អែតក៏
ចេញដំណាលគ្នា ។

លុះពេលដល់ស្រែទុំល្មមច្រូតហើយ ក៏ចាប់ច្រូតដូចស្រែរំលែសឹងតែ
តែតមានរឹងឆ្អែកដោយឈើឆ្អែកទេ ។ ទាំងរបៀបយកគ្រាប់ស្រែ ទឹង
យកស្រែងាក់ដង្រែក ក៏ដូចគ្នាក្នុងរឿងធ្វើស្រែរំលែសឹងនោះដែរ ។

រឿងធ្វើស្រែចុំាងនេះ មិនសូវមានរបៀបរៀបរយច្រើនទេ ទាំង
រឿងព្រងសោតទៀតក៏គ្មាន ប៉ុន្តែបានជាប្រឹងបរិយាយរឿងនេះ ដោយ
យល់ឃើញថា "របស្រែវចុំាង" នេះ ជារបមានប្រយោជន៍ធំមួយ
ប៉ុន្តែ គាល ព្រះអង្គស្តេចទៅដល់ព្រាសាទ ហើយបាន់នោះលុះតែចំនួន មនុស្ស ១០០ នាក់ ទើបអាចបើកចូលដោយលំបាកពន់ពេក តែព្រាសាទនោះរបើកឯងយ៉ាងស្ងប់ស្ងាត់ តាមធម្មតាទោះគេលបើកព្រាសាទម្តងៗ គេបានឮសូរសព្ទចំឡែកយ៉ាងណាៈ គឺគ្រែងគ្រែំ ដូចសូរផ្គរលាន់ សូរគងដ៏ធំសំបើម ។

នាគាល ព្រះសិទ្ធត្ថស្តេចយាងទៅជិតដល់ព្រាសាទនោះ ចំពេលនឹងព្រាសាទបន្លាប់ទៅទៀត សឹងរបើកឡើងឯងយ៉ាងស្ងប់ស្ងាត់ ក្នុងខណៈដែលទ្រង់ធ្វើព្រះតំណើរចេញចូលតាមព្រាសាទទាំងនោះ ; ពួកនាហានយាម ទាំងនាយនាហាន ទាំងកូនទាហាន សឹងឆ្ងាកជាវ លំពែងនឹងខែលពីដៃ ហើយដេកលក់តតដឹងខ្លួនដូចជាស្លាប់ - ព័ត្រោះតែងគេលនោះ មានភាយោបកំរើតើយ។ ចេញមកពីភាលមលា (Molwa[1]) ដែលជាដើមអាកៀនជាច្រើនហាក់ដូចសណ្តាំអរិយៈ ឲ្យលន់លក់អស់ទៅដូច្នេះហើយបានជាស្តេចយាងចេញទៅបានដោយសេរី —

លុះដល់ផ្លាយព្រឹកវេលាតីដង្គឹមមេឃទិសខាងកើត ហើយមានខ្សល់ព្រឹកព្រហាមបក់រំភើយឲ្យត្រជាក់លើកូនប្រាថ្នា ធ្វើឲ្យកើតជារលកនៅសឹងអនោមា ដែលជាព្រំប្រទល់ដែនខៃព្រះពុទ្ធអាណាចក្រ ព្រះបរមកូនត្រកក៏ទ្រង់បញ្ឈប់ពាជីនៅទីនោះ ទ្រង់ចុះមកដែនដី ហើយ

---

1 — ជាឈ្មោះទេព្តា ១ របស់ដើកណ្តៀ ដែលគេដាំដើម Pavot សម្រាប់ធ្វើអាភៀនជាច្រើន ។

ខ្ញុំថ្នមអង្អែលសេះកណ្ដក: ដោយព្រះទ័យមេត្តាច្បាណ៎ រួចខ្ញុំមានព្រះបិយវាចានាយឆន្នៈថា "អំពើដែលឯងបានធ្វើមកនេះ នឹងនាំឲ្យឯងបានទទួលសេចក្ដីសុខ ចំពោះខ្លួនឯង ចំពោះសត្វលោកទាំងពួងឯង, ចូរឯងដឿងជាក់ថា អញស្រឡាញ់ឯងដោយស្មោះត្រង់ជានិច្ចដូចដាឯងបានសំដែងចិត្តស្មោះត្រង់ចំពោះអញ ។ ចូរឯងនាំយកសេះទៅវិញ ហើយយកព្រះមាលាជាត្បូងមុក្តា ព្រះគូសាសម្រាប់ក្បត្រ ដ្បិតតាំងពីថ្ងៃនេះទៅ ទៅជារបស់តម្រាយោជន៍សម្រាប់អញ, ចូរយកព្រះកាយតំខ្ពន់ជាំពេជ្រ ព្រះខ័នខឹងព្រះកេសាវែង ដែលអញកាត់បេញពីសិរសា ដោយព្រះខ័នឲ្យ ។ ចូរឲ្យាយត្រុតាំងអស់នេះដល់មហាក្បត្រ ហើយក្រាបបង្គំទូលឲ្យខ្ញុំជ្រាបថា "សិទ្ធាថ៍សូមឲ្យខ្ញុំក្មេចទំកំតែខ្ញុំត្រឡប់ចូលមកវិញ ប្រកបដោយកិត្តិយសដ៏ខ្ពង់ខ្ពស់ជាង ១០ ដង នៃកិត្តិយសរបស់ក្បត្រ ដោយខ្ញុំស្វះស្វែងរកធម៌ឃើញតែមួយព្រះអង្គឯង ។ កាលបើបានរកធម៌ឃើញហើយ ប្រថពីទាំងមូល ជារបស់អញ ហើយដោយការបំពេញពុទ្ធការកធម៌ ដោយសេចក្ដីមេត្តា! ពីព្រោះមនុស្សមានសង្ឃឹមតែក្នុងពួកមនុស្សដូចគ្នា ហើយគ្មានជនណាមួយបានស្វះស្វែងរក ដូចអញមានបំណងនឹងធ្វើនេះទេ, ខ្លួនអញដែលខំលះបង់ពិភពលោកដើម្បីជួយស្រោចស្រង់ពិភពលោកទេតើ" ។

(ជាតទេមិកជាតក)

(តមក - ចប់)

វមោនោ អយំ លោកេតបុព្វបូរេ
ទុក្កដ្ឋវូទោ អសុចិ បូតិ ភាយតិ
ឃម្ហាកិតន្តា មនុជា ចិរដ្ឋិ ។

ប្រែថា នរកនេះពេញទៅដោយឈាមនឹងខ្ទុះ ជារបស់ស្មោកគ្រោក គួរខ្ពើម ពួកសត្វកើតក្នុងនរកនេះ រមែងដឹកស៊ីឈាមនឹងខ្ទុះដូសតាំងបាយទឹកព្រោះអត់ទាំសេចក្តីស្រេកឃ្លានមិនបាន ។

កម្មដែលឲ្យធ្លាក់នរកនេះ ប្អូនដល់ការសម្លាប់មាតាបិតានឹងព្រះអរហន្ត មានគាថាជាតំកាងថា:

យេ មាតរំ បិតរំ ឯវលោកេ
ចាភដ្ឋិកា អរហន្តេ ហនន្តិ
តេ លុទ្ទកម្មា បសវេត្វ ចាបំ
តេមេ ឧភា លោហិតបុព្វភក្ខា ។

ប្រែថា ជនពួកណាកើតក្នុងលោកនេះ ជាអ្នកសំឡាប់មាតាបិតាឬ

ជាអ្នកសំឡាប់ព្រះអរហន្ត ជនពួកនោះ ចាត់ជាមនុស្សអាក្រក់អាក្រក់ គ្រាធ្វើសេចក្តីអាក្រក់ហើយ រមែងមានឈាមនឹងខ្ទុះជាអាហារ ។

កថ៌អដ្ឋកថាពន្យល់សេចក្តីថា មិនមែនត្រឹមតែសំឡាប់ព្រះអរហន្តប៉ុណ្ណោះទេ សំឡាប់កិកុសង្ឃសាវកដទៃៗ ក៏ត្រូវធ្លាក់កង់នរកនេះដែរ ។

១២ - ក្នុងសាវនរក នរកមនុស្សកោងក្នុងនរកនេះមានពួកនាយនិរយបាល យកសន្ទូចដែកធំៗ ប៉ុនដើមត្នោត ការាវ្តក់អណ្តាតរបស់សត្វនរក នឹងបោះក្លាប់ដែដើងសត្វនរក សន្ធឹងត្រជាងទុកនឹងដែនដែតក្រហម ដូចគេបោះសន្ធឹងស្បែកឆ្កែបុកលើដែនដី មានគាថាទិពន្ធទុកមកថា

ជីវញ្ជេ បុរិសេ តត្ថ តិណ្ហេន
វិមាតំ យថា សត្ថេន ចម្មំ
ឧទ្ធរិត្វា មញ្ចេ ឋលម្ហិ ខិត្តា
អុញ្ជន្តិ នេរយិកា កិមិនោ ។

ប្រែថា ចូរមើលពួកសត្វនរក ដែលត្រូវការាវ្តក់អណ្តាតនឹងសន្ធូចត្រជាងសន្ធឹងទុកដូចត្រជាងស្បែក រមែងអន្ទះអន្ទែងដូចជាត្រីដែលគេចាប់បោះទៅលើគោក មានតែយំយោគហូរទឹកភ្នែកសស្រោកសស្រាក់ ។

កម្មដែលនាំឲ្យធ្លាក់នរកនេះ ជាន់ដល់ការដំឡើងជម្ងឺឲ្យកោងវៀចដោយឃើញដល់ការចំណេញ មានគាថាជាបច្ចន្តនថា

យោ កោចិ សរណគ្គនតមនុស្សា
អក្បេន អក្ខំ កយំ ហាបយន្តិ
ក្ខជេន ក្ខដំ ឆនលោកហេតុ
ឆន្ទំ យថា កវិចរំ វនាយ
ឧ ហិ ក្ខ៩ការិស្ស តវន្តិ តាណា
សកេហិ កម្មេហិ បុរក្ខតស្ស
តេ លុទ្ធកម្មា បសវេត្វ ចាបំ
តេមេ ជនា វជ្ឈយស្ស សយន្តិ ។

ប្រែថា បុគ្គលណា ចាន់ខន្ធលវែងម្ខែលក់របស់ ហើយវែងថ្លៃគោង រឿចវែរ ព្រោះឃើញដល់ខ្លួន ចំណែកសំដីនិយាយខន់ភ្លូនផ្អែមល្ហែម ព័ពេះ ដើម្បីបិទបាំងលាក់លៀមការគោងរឿចរបស់ខ្លួន ដូចមនុស្សវែលអែបលាក់ខ្លួនពួនចាញ់សត្វ អ្នកដែលគោងរឿចដូចនេះ រមែងមិនមានអ្វីការពារមិនឲ្យធ្លាក់នរកចាន់ គាលស្លាប់ហើយរមែងត្រូវសន្ធប់ថ្លក់អណ្តាតក្នុងនរកនេះ ។

១៣— អយបញ្ជរនរក: នរកភ្លុំដែក ក្នុងនរកនេះពួកសត្វនរកត្រូវចាប់ហ្វោះទៅក្នុងទឹកទន់ដែងខ្លះ ត្រូវភ្លុំសង្កត់សង្កិនខ្លះ មានគាថាជាគ្រឿងអាងថា

ជាវ ៥មា សម្បរិតិន្ទកត្តា

បក្ខយ្ហ កន្ធន្តិ កុជា វុដ្ឋា

សុមក្ខតា សោហិតបុព្វលិត្តា

តាកេ យថា អាយាតនេ វិកន្តា

ខជ្ជាតំវត្តន្តិ សជោតិកូតា ។

ប្រែថា· ស្រីពួកនេះ ត្រូវនាយនិរយចាលចាក់ពងកាយសត្វសុះនាំ គ្នាលើកដៃទ្រហោយំ មានពងកាយច្រាលខ្ទោលទៅដោយឈាមនឹងខ្ទុះ ពួកនាយនិរយចាលដេញឲ្យចុះទៅកាន់ដែនដែកក្រហមត្រឹមបង្កេះ នឹងកម្រើកដាកវេទៅមកមិនបាន ដូចគោដែលគេឃុំឃាំងទុកកន្លែងគោលសំរាប់សំឡាប់ ស្រីពួកនេះ មានពងធំធាត់ នេះជាអណ្តាតក្តៀង ។

កន្លែងអដ្ឋកថាថា ស្រីសត្វនរកពួកនេះ មានពងកាយធំប៉ុនភ្នំ តែក្នុងខណៈដែលនាយនិរយចាល ឃុំឃាំងទុកលើដែនដែកក្រហមលិចចុះទៅត្រឹមបង្កេះនោះ មានភ្នំដែកដែលនេះជាអណ្តាតក្តៀង, រមៀលមកអំពីទិសទាំង ៤ សង្កត់សង្កិនកំទេចស្រីពួកនោះឲ្យល្អិតជាធូលីទៅ ។

តម្នាំដែលនាំឲ្យធ្លាក់នរកនេះ ឋានដល់តារប្រព្រឹត្តិត្រៃចិត្តស្វាមី មានវារៈចាលីបញ្ជាក់ថា

គោ លិត្តំយា យោ ឥធ ជីវលោកេ

អសុទ្ធកម្មា អយុត្តំ អចារុំ

តា ឆុត្តវូថា បតឺ វិប្បហាយ

អញ្ញំ អុថារុំ វតិ្ថខិដ្ឋភោគុ

តា ឥវំលោកស្មឺ រមាបយិត្វា

ខជ្ជាតិវត្តន្តិ សយោតិកូតា ។

ប្រែថា ស្រីពួកណាកន្លងនូវលោកនេះ ជាអ្នកខុចុះតែប្រតិ្តដ្ឋដ៏មិនសមគួរ គឺប្រតិ្តដ្ឋនឹងតែក្រែចិត្តស្វាមី គប់រកបុរសដទៃ ព្រោះឃើញដល់សេចក្តីស្រើបស្រាលរីករាយ លុះស្រីពួកនោះស្លាប់ហើយរមែងធ្លាក់ក្នុងនរកនេះ មានកាយធំប៉ុនភ្នំ ត្រូវក្រើនសន្ធោសន្ធៅនៅជានិច្ច ។

១៤ - ឥលិតអង្គារនរក : នរកឈ្មោះរណ្តៅរងើកភ្លើង ក្នុងនរកនេះមានរណ្តៅធំ ។ ពេញទៅដោយរងើកភ្លើង ពួកនាយនិរយបាលដេញចាក់ពួកសត្វនរកទៅលើនូវដែកគ្រហមគាំងហួង ។ ដួចហួងគគ្រែបី លុះដេញគាន់ហើយ ក៏ចាប់ចោទចុះទៅកន្លងរណ្តៅរងើកភ្លើងដ៏ក្តៅទៅជានិច្ច មានគាថាភាសិតថា

ថាៈទ តបោត្វា តតិ សរ្បិមេ បតេតេ

អវំសិរា ឯរតេ ថាតយន្តិ ។

ប្រែថា ពួកសត្វកន្លងនរកនេះ រមែងត្រូវនាយនិរយបាលចាប់យកដើងខ្នើងលើ យកក្បាលសំយុងចុះក្រោម ចោះចុះទៅកន្លងនរក ។

ចាប់តម្តងដែលនាំឲ្យធ្លាក់ចុះ នរកនេះ ចានដល់ការប្រតិ្តបំអនាចារនឹងភរិយាអ្នកដទៃ មានគាថាសំអាងថា :

យេ ឥមស្មិំ អសាធុកម្មិនោ
បុរិសា ឯវំ អតិក្កមន្តិ
តេ តាទិសា ទុគ្គមកណ្ហដេជា
តេមេ ជនា (អាសីវា) នរកេ ឋាតយន្តិ
តេ វស្សបូគានំ ពហូនំ តត្ថ
និរយេសុ ទុក្កដំ វេទនំ វេទយន្តិ
ន ហិ ចាមការស្ស តត្ថ តាណា
សតោហិ កម្មេហិ បុរក្ខតស្ស
តេ លុទ្ទកម្មា បសវិត្វ ចាបំ
តេមេ ជនា (អាសីវា) នរកេ ឋាតយន្តិ ។

ប្រែថា បុរសពួកណាក្នុងលោកនេះ ជាអ្នកធ្វើកម្មមិនល្អគឺកន្ទួចប្រដេញនឹងកិរិយាអ្នកដទៃ បុរសពួកនោះ ត្រូវនាយនិរយចាំលាចាប់ក្បាលសំយុងចុះ ចោះចុះទៅកាន់នរក បុរសពួកនោះរមែងទល់ទុក្ខវេទនាខ្លោកក្នុងនរកអស់កាលជាយូរយារ, បុរសដែលកសាងសន្សំធ្វើសេចក្តីអាក្រក់ទុកទាំងនោះ រមែងមិនមានអ្នកការពារ លុះត្រាស្លាប់ហើយ រមែងត្រូវនាយនិរយចាប់សំយុងក្បាលចុះក្រោម ចោះចុះទៅកាន់នរក ។

๑๕— មិច្ឆាទិដ្ឋិកនរក: នរកមិច្ឆាទិដ្ឋិ គឺពួកអ្នកដែលជាមិច្ឆាទិដ្ឋិ រមែងជ្រាក់នរកនេះ មានគាថាជាគ្រឿងសំគាងថា

ตุច្ចាវចាមេ ภิกฺขเว อุปกฺกมา

ฉินฺนายุสฺส ฉินฺนสฺสฺส สุเขนาวฺหจา

แปลว่า สัตว์เหล่านี้ ทั้งหลายย่อมเป็นผู้ประกอบด้วยกรรม มีอายุขาดสิ้นไปแล้ว ๆ

ในอรรถกถาว่า พวกสัตว์ในนรกเหล่านี้ ชื่อว่าเป็นผู้มีสัญญาวิปลาสว่า "ทานไม่มีผล, การบูชาไม่มีผล, การบูชาไฟไม่มีผล, การเลี้ยงแขกไม่มีผล, มารดาไม่มี, บิดาไม่มี, สมณพราหมณ์ไม่มี, สัตว์ที่เป็นโอปปาติกะไม่มี, โลกนี้ไม่มี, โลกหน้าไม่มี" มีคาถาประกอบว่า

เย ปาปลาภกามาสฺมึ สุขาปนิชฺฌิโน

วิสญฺญิสกมฺมานิ กเรยฺยุ โมหา

ปราภิ นิชฺฌิสุ สมาธเปยฺยุ

เต ขาปนิชฺฌึ ปรเมสฺวา ขาปึ

เตเม ชนา อนิมคฺคา ทุกฺขา ตีรยฺหา

จก กกฺขฬกา เวธนา เวธยนฺติ ฯ

แปลว่า บุคคลพวกใดในนรกนี้ เป็นผู้มีสัญญาวิปลาสเหล่านี้ ชื่อว่าเป็นผู้มีสัญญาวิปลาส เพราะตนเองเป็นผู้ปรารถนาบาปลาภ ทำกรรมต่าง ๆ ด้วยความหลง ติเตียนผู้อื่น ตั้งความเพ่งเล็งไว้ในผู้อื่น ตั้งความเพ่งเล็งไว้ในผู้อื่น ตั้งความเพ่งเล็งไว้ใน

យើញទុសតាមខ្លួនខ្លះ បុគ្គលពួកនោះសុះស្ងាប់ហើយ រមែងបានទទួលសេចក្តីទុក្ខយ៉ាងធំ មានទុក្ខវេទនាដ៏ក្តៅខ្លោចផ្សាយ៉ាងពន់ពេកណាស់ ។

ឯកមកាសិត

ទី ១ វេគណីនទី ទី ២ សុនខនរកា

ទី ៣ អយបឋវីណា ៤ អង្គារកាសុនរក ។

៥ នរកលោហកុម្ភី ទី ៦ អយោទក:

ទី ៧ នរកចុណ: ៨ អយសូល:ណា ។

៩ សញ្ជោតិនរក ទី ១ ០ គូថ:នរកា

១១ លោហិតបុព្វគន្ធា ១២ ឈ្មោះកូដគារី ។

១៣ អយបត្តត: ១៤ដល់តអង្គារនរក

១៥ គឺមិច្ឆាទិដ្ឋិ រួមទំយាវ ១៥ រណ្តៅ ។

នរកទាំងនេះតែងសុខសាន្ត សុទ្ធសឹងតែមានបានសោកសៅ

សែនទុក្ខបុកម្នេញពេញក្តួលក្តៅ សមតាមកម្មខ្លៅដែលខ្លួនសាង ។

គួរគោតគួរខ្លាចគួរកុំធ្វើ អំពើអាក្រក់គ្រប់បែបយ៉ាង

អកុសលកម្មគ្មានផ្លូវគាង មុខជាដួលធ្លាងទៅអបាយ ។

បើមិនតិរច្ឆានកំតង់ប្រែត បើមិនប្រែតតង់អសុរកាយ

ឬធ្លាក់នរកផងតាំងឡាយ ក្រហល់ក្រហាយតែតសាន្តសុខ ។

ណាគ្រប់ណាត់ប្រែតប្រងំប្រែង ប្រែតែងរៀបរៀងរឿងនរក

បាកនេមិរាជជាតក សាធកសង្ខេបប៉ុណ្ណេះហោង ។

(តមក)

សញ្ញាប័ត្រលេខ ៤៥៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួង-ចាប នាមនាយា ចន្ទវត្ថេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តស្វាយចារ ឃុំស្ពឺក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ធន-រ៉ោត នាមនាយា គណ្ឌវត្ថេរ កើតឆ្នាំចោរ អាយុ ៣៥ វស្សា ១៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ លឹម-ញ៉ែន នាមនាយា ញាណប្បញ្ញោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តធំតង្រំ ឃុំទឹកល្អក់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-សួន នាមនាយា សុវណ្ណប្បញ្ញោ កើតឆ្នាំខាល អាយុ ២៣ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខឹម-ដិន នាមនាយា ពុទ្ធញ្ញាណ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជា ចៅអធិការ វត្តត្រែស ឃុំត្រពែក ស្រុកកំចាយមារ ខេត្តវិពែរវែង ។

សញ្ញាប័ត្រលេខ ៤៦៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម-យី នាមឆាយា ធម្មប្បញ្ញោ កើតឆ្នាំវក អាយុ ៤១ វស្សា ២១ ជាចៅអធិការ វត្តសាំងឃ្លាង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤៦៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-ណៃ នាមឆាយា មុទិសុធម្ម កើតឆ្នាំមមែ អាយុ ៣២ វស្សា ១១ ជាចៅអធិការ វត្តមគាគីរី ឃុំត្រពាំង ស្រុកកំពង់សោម ខេត្តកំពត ។

សញ្ញាប័ត្រលេខ ៤៦៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ឆើត នាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំវក អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-យិម នាមឆាយា តន្ថុត្តរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តសាលាម្នាង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កួយ-ចិត នាមឆាយា សុធម្មត្ថេរ កើតឆ្នាំវក អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហាស-យិម នាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តគីរីអង្គដុំ ឃុំពោធិ៍បឹង ស្រុកកំពង់សោម ខេត្តកំពត ។

សញ្ញាប័ត្រលេខ ៤៧០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ដួង-ឆូរ នាមនាយា តន្ត្រីប្បញ្ញា កើតឆ្នាំមមែ អាយុ ៣០ វស្សា ៧ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប្ងួរ-ឆ្ងួន នាមនាយា សុវណ្ណត្ថេរ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តអង្គគ្នោត ឃុំជងពែង ស្រុកកំពង់សោម ខេត្តកំពត ។

សញ្ញាប័ត្រលេខ ៤៧២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៀន-គី នាមនាយា កិន្នីតត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តអន់ង្គើត ឃុំដីខ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខ្ឃឹក-ខុយ នាមនាយា តន្ត្រីប្បញ្ញា កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តពោធិ៍គីរី នៅឃុំច្នស ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈឹម-តាត់ នាមនាយា ចន្ទប្បញ្ញា កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តគីរីសាគរ នៅឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចិត-ឆន នាមនាយា ញាណប្បញ្ញា កើតឆ្នាំវក អាយុ ២៩ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តចំបក់មាស ឃុំសន្ទែរ ស្រុកកំពែរ ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៤៧៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថាច់-ម៉ម នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំ ១៨៨៧ អាយុ ៦១ ជាចៅអធិការ វត្តសំពៅង ឃុំចុងជូង ស្រុកញែវចាញ់ ខេត្តឃ្លាំង (កូសំដ៏ស៊ីន) ។

សញ្ញាប័ត្រលេខ ៤៧៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គិម-ភ័ នាមឆាយា វិនយប្បញ្ញោ កើតឆ្នាំ ១៨០៣ អាយុ ៨៥ វស្សា ២៤ ជាចៅអធិការ វត្តរោងថ្ពោក ឃុំកែគាង ខ័ណ្ឌឱញ្ញចាញ់ ខេត្តឃ្លាំង (កូសំដ៏ស៊ីន) ។

សញ្ញាប័ត្រលេខ ៤៧៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ លិម-ស្តើង នាមឆាយា គិរីតន្ធកេសរ កើតឆ្នាំ ១៨៨០ អាយុ ៥៨ វស្សា ៣៧ ជាចៅអធិការ វត្តបួនព្រះកត្តិ ឃុំកៀកគិម ខ័ណ្ឌញែវចាញ់ ខេត្តឃ្លាំង (កូសាំងស៊ីន) ។

សញ្ញាប័ត្រលេខ ៤៧៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ លិម-អិត នាមឆាយា នពជោត កើតឆ្នាំ ១៨៨១ អាយុ ៦៧ វស្សា ៤៧ ជាចៅអធិការ វត្តចម្ប៉ា ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថាច់-ភន់ នាមឆាយា សមន្តសារ កើតឆ្នាំ ១៩១៥ អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្តខនេរុងរ៉ី ឃុំថាញ់ត្រៃ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សើន-សម នាមនាយា សន្ធម្មប្បរញ្ញា កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៩ ជាចៅអធិការ វត្តបឹងក្រចាប់ថ្មី ឃុំតំងហឹង ខ័ណ្ឌដេញមី ខេត្តឃ្លាំង (កូសំង៉ស៊ីន) ។

សញ្ញាប័ត្រលេខ ៤៨២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ាញ់-ហោ នាមនាយា សុវណ្ណជោត កើតឆ្នាំ ១៩១៧ អាយុ ៣១ វស្សា ៩ ជាចៅអធិការ វត្តកំពង់ខ្ទៀ ឃុំតឹងហ្វា ខ័ណ្ឌញៀវចាញ់ ខេត្តឃ្លាំង (កូសំង៉ស៊ីន) ។

សញ្ញាប័ត្រលេខ ៤៨៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ាញ់-ពិ នាមនាយា មុនីសុវណ្ណ កើតឆ្នាំ ១៨៩៥ អាយុ ៥៣ វស្សា ៣៣ ជាចៅអធិការ វត្តពាងសំរិទ្ធ ឃុំតាំងប៉ាញ ខ័ណ្ឌ ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៤ ចុះថ្ងៃសុក្រ ២ កើតខែមិគសិរឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ទក-វន់ នាមនាយ៉ា សុវណ្ណត្នេរ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តបម្ងាចារ ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤៨៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ខែម នាមនាយា ខន្ធវិជ្ជា កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ម៉ា-ថោង នាមធាយ៉ា តន្ធត្ថេរ កើតឆ្នាំវក អាយុ ៤១ វស្សា ១៦
ជាគ្រូសូត្រស្តាំ វត្តត្រតាំងវែង ឃុំត្រែងវិញាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ខុម-ណែម នាមធាយ៉ា ធម្មជោត អាយុ ៣៨ វស្សា ១៨ ជា
គ្រូសូត្រស្តាំ វត្តមង្គលមានជ័យ ឃុំភោធិ៍ម្រាល ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ញ៉-ម៉ូវ នាមធាយ៉ា តន្ធជោត កើតឆ្នាំមមី អាយុ ៤៣ វស្សា ២១
ជាចៅអធិការ វត្តគិរីវង្ស ឃុំកំងខ្វាវ ស្រុកកំពែរពញ ខេត្តតាខ្មៅ ។

សញ្ញាប័ត្រលេខ ៤៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ប៉ែន-តាំ នាមធាយ៉ា ឥលសុវណ្ណ កើតឆ្នាំកេង អាយុ ៥៥ វស្សា ១៧
ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
លិម-អ៊ាន នាមធាយ៉ា វិនយត្ថេរ កើតឆ្នាំ ១៩២២ អាយុ ២៦ វស្សា ៦
ជាចៅអធិការ វត្តរកាដូរ ឃុំឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៩១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
គិម-ហ៊ុន នាមធាយ៉ា ធម្មជោត កើតឆ្នាំច អាយុ ៣៩ វស្សា ១៨ ជា
ចៅអធិការ វត្តបឹងជ្រា ឃុំឈើទាល ស្រុក-ខេត្តដដែល ។ (មានត)

ស្មើអំពីរឿងស្មាបទានវិទ្យាស្ថានមួយ

សម្រាប់សិក្សាភាសាឥណ្ឌា - ខ្មែរ នៅក្នុងពេញ

លោកវ៉ាយ - ប៊ុក ក្រុមការក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែចេញពីជាវ៉ាំងមកខ្មែរ

ការសិក្សាភាសាឥណ្ឌូនៅ ជាកិច្ចមានប្រយោជន៍ ទំនាក់ទំនង សំខាន់ចំពោះប្រទេសកម្ពុជា ដូចគ្នានឹងការសិក្សាភាសាគ្រិក - ឡាតាំង ដែលគេដាក់ឲ្យសម្រាប់និស្សិតរៀនសូត្រ នៅសាលារៀនក្នុងប្រទេសជាច្រើន, ការចេះដឹងនូវភាសាសំស្ក្រឹតនឹងជាលិ ព្រមទាំងអារ្យធម៌ឥណ្ឌា ដែលទាក់ទងដោយអារ្យធម៌នៃប្រទេសដទៃទាំង ខាងឆ្វេងប្រវត្តិសាស្ត្រ, ជាកិច្ចគួរបំពេញ ដើម្បីស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីបុរាណខ្មែរ ដែលមានអត្ថន័យគម្ពីរភាព ហើយនឹងងាយស្រួលរកនូវវត្ថុធាតុ ដែលជាបុព្វហេតុនៃទំនៀមទម្លាប់នោះ ។

ព្រោះហេតុដូច្នេះ ត្រូវតែបណ្ឌិតខ្មែរក្នុងកាលជាអនាគតប្រមូលគ្នាឲ្យបានច្រើនជាងមុន ដើម្បីនឹងចូលទៅសន្ទនាការអំពីរឿងបូព៌ាវិទ្យានិយមរវាងប្រជាជាតិ (l'orientatlisme international) មានការសិក្សាខាងភាសាឥណ្ឌាជាកិច្ចត្រូវស្រួលរកដោយពិសេស, បណ្ឌិតទាំងនោះ ក្នុងពេលសន្ទនាការរឿងរ៉ាវក្នុងសាកលលោក អាចឆ្លើយតបនូវសារៈប្រយោជន៍

ប្រយោជន៍កន្លងមកនេះ ជាកម្លាំងសម្រាប់ប្រទេសជាតិខ្មែរយ៉ាងច្រើន ។ លោកអ្នកប្រាជ្ញទាំងប៉ុន្មាន អាចចូលទៅប្រឹក្សាយោបល់ក្នុងការស្វែងរកបច្ចេកវិទ្យានិយមជាសាធារណៈ អាចរៀបចំនូវក្រុមសញ្ជាតិខ្មែរ ទាំងសិល្បៈវិកប្រពៃណីវិទ្យា និងស្ថាបនានូវមជ្ឈមសិក្សានិស្សិតខ្មែរ ដែលត្រូវយកសាស្ត្រាចារ្យមានសមត្ថភាពខាងភាសាឥណ្ឌៀមកបង្រៀនបានដោយធម្មតាហ៍ស ។

ដើម្បីនឹងឧបត្ថម្ភបណ្តិតខ្មែរ ដែលពេញចិត្តក្នុងការស្វែងរកវិជ្ជានេះ, ប្រទេសជាតិសែសគួរស្នើចំពោះកម្ពុជរដ្ឋអំពីគ្រោងការស្ថាបនាវិជ្ជាស្ថានខ្មៅក្រុងភ្នំពេញ សម្រាប់សិក្សាទត្តមវិជ្ជា ដែលគេអាចយកគោលការសិក្សាកិច្ចស្វែងរកភាសាឥណ្ឌៀនៃសាលាទត្តមវិជ្ជាខ្មៅប៉ារីសមកបញ្ចូលផងបាន ។

ការសិក្សានេះ ត្រូវបើកសិទ្ធិឲ្យជនគ្រប់រូបចូលទៅរៀនបានដោយសេរី ឥតមានរើសមុខ, គុណបំណាច់ដែលរៀនក្នុងសាលានោះ ត្រូវបានសញ្ញាប័ត្រមួយដែលនឹងប្រគល់ឲ្យបាន លុះត្រាតែបេក្ខជននោះបានធ្វើកិច្ចការអ្វីមួយជាគាប់ប្រសើរ ហើយបានចូលទៅរៀនចន្លោះអាសន្នខ្មៅសាលាក្នុងរយៈវេលា ២ ឆ្នាំ ដោយទទួលសេចក្តីយល់ព្រមពី

គណៈកម្មការសាលា ដែលបានយកប្រមេក្ខជនទៅបង្ហាញចំពោះចាងហ្វាងសាលានោះ ។

នៅកំពេញ ការសិក្សានេះដែលនឹងធ្វើបាន លុះត្រាតែចាត់ចាងហ្វាងនៃការសិក្សាមួយនាក់ពីប៉ារីស ក្នុងរយៈវេលា ៦ ខែក្នុង ១ ឆ្នាំ, លេខាធិការដ្ឋានដ៏អាចរៃនៃវិទ្យាស្ថានឧត្តមសិក្សានេះ ត្រូវមានសមាជិកខាងសាលាបូព៌ាប្រទេសម្នាក់មកគាន់ការនៅកំពេញ បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ សម្រាប់ជាមន្ទីរធ្វើការផ្សេងៗ នៃក្រុមនេះ, ប្រាក់បំណាយក្នុងរឿងនេះ ត្រូវប្រទេសបារាំងសែស នឹងប្រទេសកម្ពុជាទទួលបន្ទុកជួយគ្នាទៅវិញទៅមក, ប្រាក់បៀវត្សនៃចាងហ្វាងសាលាត្រូវប្រទេសបារាំងសែសចេញឲ្យ ចំណែកខាងប្រទេសកម្ពុជា ត្រូវចេញតែខាងប្រាក់ចំណាយសោហ៊ុយសំណាក់អាស្រ័យក្នុងទីនេះ នឹងថ្លៃយានដំនិះ ។

ចំពោះឆ្នាំ ១៩៥០ ប្រាក់ចំណាយក្នុងរឿងនេះ តាមសេចក្តីស្មានៃភដ្ឋាគិបាលខ្មែរប្រហែលជា ៦ - ៧ ម៉ឺនរៀល ។

ខៅកម្ពុជសុរិយាឆ្នាំ ១៩៤៩ លេខ ១០ ត្រង់សុភាសិតភាគទី ២ ទំព័រ ៧៣២

លេខ ៣៧

ពាក្យចាស់:	ពាក្យកែ:
៣៧-បណ្ឌិតព្រឹទ្ធាចារ្យ បុពណា បឋមកាល ឋាត់ឈ្មោះចត្រកំឡ ឋ្មមានឆាមលុះសព្វថ្ងៃ ។ លោកជាស្រែវិទ្យា មានគុណថ្លៃ ក្បួនសាស្ត្រាច្បាប់ចរណៃ ធម៌លោកតាមសម័យ មានគុណថ្លៃប្រសើរពិត ។	៣៧ – បណ្ឌិតព្រឹទ្ធាចារ្យ បុពណាបឋមកាល ឋាត់ឈ្មោះ ចត្រកំឡ ឋ្មមានឆាមលុះសព្វ ថ្ងៃ ។ លោកជាស្រែវិទ្យា ក្បួនសាស្ត្រាច្បាប់ចរណៃ ធម៌លោកតាមសម័យ មានគុណថ្លៃប្រសើរពិត ។

លេខ ៤១

ពាក្យចាស់:	ពាក្យកែ:
៤០ – មានហេតុមានផល សង្ក្រាមសាកល កើតឧឋាន អគ្គីឆាបឆេះ សម្រាមឋ្ងាន ពាយោបក់ច្រាន ស្ទឹកឈើរីរក់ ។ ឋាបបុណ្យគុណឆោស កសាងតាមថ្នាក់ រូបល្អសមស័ក្តិ ដូរតែកាន់សីលា ។	៤០ – មានហេតុមានផល សង្ក្រាមសាកល កើតឧឋាន អគ្គីឆាបឆេះ សម្រាមឋ្ងាន ពាយោបក់ច្រាន ស្ទឹកឈើរីរក់ ។ សត្វខុសចរិត មុខភាពផ្សេងចិត្ត ផលល្អលាមក ឋាបបុណ្យគុណ ឆោស កសាងតាមថ្នាក់ រូបល្អ សមស័ក្តិ ដូរតែកាន់សីលា ។

២ – សន្ធិកច្បាប់រពាក្យខុសត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
កំរិតច្រើន	កាំចិតច្រើន	ទី៣៣	៩
គេស្គាល់ច្រើដ្ឋាដោយការធម្មា	គេស្គាល់ច្រើដ្ឋដោយការធម្មា	ទី៣៤	១០

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងទាងសាសនា ទំនៀមប្រពៃណី ប្រវត្តិសាស្ត្រ ប្រជុំនិទានកថា
អំពីពុទ្ធសាសនៈបណ្តាំត្បូង

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ព៉ាយ-ប៊ុក ក្រមការ
នៅពុទ្ធសាសនៈបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ស្មរ-ហាយ
ព្រះគ្រូធម្មវិន័យវិត្រវិចិត្រចំរើន នៅពុទ្ធសាសនៈបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
អ្នកនាងកញ្ញា ឈឹម-ក្រសេម	ក្រែរាជដំណើរតាមភាគទី ២ (សម័យខែនេះ)	៨៨១
លោក ព៉ាយ-ប៊ុក ក្រមការ	សុភាសិតខ្មែរភាគទី ២ (តទៅ-ចប់)	៨៩១
ឃុនស៊ីរមេធី ស្រី-ភ្ជូ	បណ្តាំមាតា (តទៅ-ចប់)	៨៩៧
ហ្លួងនិពន្ធមន្ត្រី ញ៉ឹក-វ៉ែត	ស៍ព្វជ្ញាភិនប្រែជាខ្មែរបស់គណៈកម្មការវប្បធម៌ (តទៅ)	៩០៦
	ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌៀ (តទៅ-ចប់)	៩១៣
នេកញ្ញា នូរ-ពន	រឿងសាមកុក (តទៅ)	៩២១
កសាសនា		
ឯនិពន្ធមន្ត្រី ញ៉ឹក វ៉ែត	ប្រវត្តិព្រះអានន្ទៈត្ថេរ	៩៣៥
	ជ្រាប់ក្រមសាមណេរ	៩៤០
ហាត់ទំនៀមប្រពៃណី		
ប្រមូលធម្មការ	បញ្ជីឈ្មោះតាមថៅអធិការវង្សតាំងថ្មី (តទៅ)	៩៤៧
លោក ព៉ាយ-ប៊ុក ក្រមការ	កំណត់ស្តើងអំពីរឿងស្តាបនាក្បែស្តានទ្ធយសម្រាប់ សិក្សាកសាខ្មែរ ឥណ្ឌៀ នៅភ្នំពេញ	៩៤៩

ភ្នំទី ២១ — លេខ ១២ ខែធ្នូ ឆ្នាំ ១៩៤៩ — ជំរៀងជាវ ១ ឆ្នាំ ៩៦ រៀល ។

សម័យនគរធំ

អ្នកនិពន្ធ ញ៉ែន ពាន ឈឹម - គ្រែសម រៀបរៀង

សេចក្តីប្លែងការណ៍

ព្រះពុទ្ធសាសនាកម្ពុជាតាំងមូល ត្រូវចាត់ជាកាន់ជាសម័យដូចមានពោលហើយក្នុងភាគទី ១ សម័យនគរកុំនោះ ឥឡូវនេះនឹងបានសំដែងក្នុងភាគទី ២ សម័យនគរធំតទៅ ។ ក្នុងសម័យនេះ ត្រូវគិតពីរជ្ជកាលព្រះបាទជយវរ្ម័នទី ២ (យមេស្វរៈ) ដល់រជ្ជកាលព្រះបាទជយវរ្ម័នយមេស្វរៈ គឺ ព. ស. ១៣៨៥ ដល់ ១៨៨១ ពប់ជាសម័យនគរធំ ។

ឯព្រះពុទ្ធសាសនា ដែលគេហៅឈ្មោះថា "ព្រះពុទ្ធសាសនាក្រុងកម្ពុជា" ច្បាប់ចាស់ ។ តាំងប៉ុន្មាន ដែលនិយាយពីប្រវត្តិសាស្ត្រក្នុងសម័យនគរធំ យើងពិនិត្យទៅឃើញពុទ្ធរូបជាច្រើនប្រការ គឺ

ក – ពុទ្ធសាសនាក្នុងសម័យនគរធំ ជាបឋមសម័យ

ខ – ពុទ្ធសាសនាប្រើសកពជ ឥតមានត្រូវបន្តិចសោះ

គ – ពុទ្ធសាសនាហៅព្រះនាមស្តេច ឥតមានត្រូវតាមសិលាចារឹកដល់ ១ អង្គសោះ

ឃ - ខុសត្រង់ផ្នែករឿងព្រះពុទ្ធសាសនានោះ ច្រើនពណ៌នាទៅជារឿងព្រៃឯ រឿងប្លែកៗផ្សេងៗ សឹងល្ងង់ចេញពីរឿងពិតយ៉ាងឆ្ងាយ គួយ៉ាងដូចរឿងព្រះថោង រឿងព្រះកេតុមាលា រឿងសាធនគរធំ ធនគរតូច គឺនគរវត្តជាដើម នឹងយកជាខ្លឹមសារសម្បីតែបន្តិច ក៏ពុំបានឡើយ ។

តាលរៀបរឿងព្រះពុទ្ធសាសនា ភាគទី ២ សម័យនគរធំគ្រានេះ ដោយអាស្រ័យតម្រាប់តម្រាបែបផែនផ្សេងៗ ជាគ្រឿងប្រកប គឺ:

១ - សិលាចារឹករបស់ខ្មែរយើងដែលលោកបានចារឹកទុកតាំងពីក្នុងសម័យនោះមក សឹងមានចំនួនជាច្រើន សិលាចារឹកទាំងនោះ ពាក់ព័ន្ធគោលសំខាន់បំផុត ក្នុងការរៀបរឿងប្រវត្តិសាស្ត្រខ្មែរ ។

២ - បូព៌ណវត្តស្ថាន នឹងឈ្មោះស្រុកខ្លះ ដែលគង់នៅដល់សព្វថ្ងៃនេះ ពាក់ព័ន្ធរបស់សំខាន់ សម្រាប់ប្រៀបធៀបប្រវត្តិសាស្ត្របាន ១ យ៉ាងទៀត ។

៣ - ឥន្ទ្រាវតារ - សេចក្តីកត់ហេតុរបស់ចិន (ជូណាង ណ៍រត្យ៍ជូ) ដែលបានតាមទាន់ឥន្ទ្រាវតារខ្មែរ ដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្រ ជាតិប្រាំងបានប្រែស្រង់ចេញជាភាសាប្រាំងមកហើយ ។

៤ - សេចក្តីអធិប្បាយពីបូព៌ណស្ថានផ្សេងៗ របស់ខ្មែរយើងដែលអ្នកប្រាជ្ញប្រាំង មានលោក ល្វី - ហ្វីណូត៍ នឹងលោក ហ្សក-សឺដេស

ជាដើម ឃានអធិប្បាយទុក សឹងមានប្រែជាភាសាខ្មែរ សឹងមានចារពុម្ព
ផ្សាយកន្លងទស្សនាវដ្តីកម្ពុជសុរិយា ក្នុងឆ្នាំជំបូង ។ ខ្លះហើយ ។

៤ – ប្រវត្តិសាស្ត្រសាកល របស់ហ្គូងវិចត្រៃភទការ, ទឹន

៦ – ប្រវត្តិព្រះវៃរមរកង (ខ្លាម ឡូប ឧង ព្រះវៃរមរកង) របស់
អយ័ណាយោស ។ ល ។

សេចក្តីពិត ព្រះរាជពង្សាវតារក្រុងកម្ពុជាសម័យនគរធំរបស់យើង
គ្រប់ ។ ច្បាប់ដែលមានមកហើយ គួរឲ្យជាទីអាស្រ័យយ៉ាងច្រើនតែម្តង
តែនេះមិនដូច្នេះ តែឲ្យប់ជាអាស្រ័យឲ្យយ៉ាងតិចជាបំផុត ទាំងនេះ
ដោយហេតុព្រះរាជពង្សាវតារសម័យនោះ ជាជារបស់ចាស់ជាន់ដើម
ហើយជារបស់ដែលត្រឹមត្រូវពិតប្រាកដនោះ បានសាបសូន្យទៅយូរ
ហើយ នៅមានសេសសល់ខ្លះ តែដោយសិលាចារឹក នឹងសេចក្តីកត់ហេតុ
របស់ជាតិដទៃ, ព្រះរាជពង្សាវតារក្រុងកម្ពុជាបណ្តាដែលមាននៅកង
ក្នុងបច្ចុប្បន្ននេះ សុទ្ធតែជារបស់ដែលគេរួបរួមឡើងកងសម័យក្រុងឧត្តុង្គនេះ
ឯង ។ នេះ អ្នករៀបរៀងឯង បានបញ្ជាក់ទុកនៅទំព័រខាងដើមថា ខ្លួនរួប
រួមឡើងដោយអាស្រ័យស៊ើបសួរអ្នកចាស់ព្រឹទ្ធាចារ្យទាំងឡាយដែលមាន
នៅកងពេលនោះ ។ ព្រោះតែខ្លះសេចក្តីស្មានជាវជាច្រើនដូច្នេះ
ហើយ ព្រះរាជពង្សាវតារក្រុងកម្ពុជា សម័យនគរធំគ្រប់ ។ ច្បាប់ទើប
ប្រាកដមានសេចក្តីខុសឆ្គងជាច្រើនអន្ទៅ ដូចពោលមកហើយ ។

ការរៀបរៀង ព្រះរាជពង្សាវតារបស់ខ្ញុំក្នុងគ្រានេះថ្វីបើខ្ញុំបានស្រាវជ្រាវមកជាយូរន្មាំ គឺបានពិនិត្យមើលសិលាចារិកខ្លះ ព្រមទាំងការពិនិត្យពង្សាវតារសេចក្តីកត់ហេតុរបស់ជាតិដទៃខាង ដោយសព្វគ្រប់មកហើយក៏ពិត តែក៏នៅតែមិនបានសេចក្តីល្អិតល្អន់សព្វគ្រប់នៅឡើយ គឺបានត្រង់នេះ នៅខ្វះត្រង់នោះ បានត្រង់នោះនៅខ្វះត្រង់នេះ សឹងមានជាដរាបដូចមានប្រាកដក្នុងព្រះរាជពង្សាវតារដែលខ្ញុំរៀបរៀងនោះហើយ ក្នុងខនេះខ្ញុំគោងញ័រមុះចាញ់ហើយ ដោយហេតុចាផុតវិស័យរបស់ខ្ញុំនឹងស្រាវជ្រាវឲ្យបានសព្វគ្រប់ដូចបំណង ។ ទោះបីដូច្នោះក៏ដោយ ត្រង់សេចក្តីដែលខ្ញុំបានលិខិតទុកហើយ ខ្ញុំអាចនឹងរ៉ាប់រងថាមានខ្ចីមសារជាច្រើនប្រៀបដូចរូបភាពដែលគេគូរកាសទុក ឆ្អឹងរូបភាពដែលហៅថា គំនូរកាស (គឺគំនូរព្រាង) មិនដែលមានលក្ខណៈ ល្អិតល្អន់សព្វគ្រប់ទេ តែបើពិនិត្យគំនូរកាសនោះទៅដោយហ្មត់ចត់ហើយ គង់យល់បាន ថារូបភាពនោះជាអ្វី ។

ដោយហេតុ ប្រការខ្វះផុតវិស័យរបស់ខ្ញុំដូច្នេះ ក្នុងទីបំផុតនេះ ខ្ញុំទើបសូមទៀងឲ្យអ្នកសិក្សាប្រវត្តិសាស្ត្ររបស់ជាតិ ជួយស្រាវជ្រាវតទៅ ។ ខ្ញុំមានសេចក្តីសង្ឃឹមខ្លាំងថា ប្រវត្តិសាស្ត្ររបស់ជាតិយើង ដែលនឹងត្រឡប់មានសេចក្តីបរិបូណ៌ឡើងវិញ ប្រាកដជាអាស្រ័យអ្នកសិក្សាប្រវត្តិសាស្ត្ររួមគំនិតជាមួយខ្ញុំ ជួយស្រាវជ្រាវតទៅផង ។

ព្រះចាន ជ័យវរ្ម័ន ទី ២

ព.ស. ១៣៤៥ - ១៤១២ — ម.ស. ៨១២ ៨៦៩

ព្រះជ័យវរ្ម័នអង្គនេះ ជាព្រះពជវង្ស ១ អង្គ ក្នុងអំបូរពជវង្សវរ្ម័នដែរ តែមិនច្បាស់ជាពាជនសេរបស់ក្សត្រិយ៍អង្គណា ។

ក្រោយដែលព្រះបាទគាណាទិត្យវរ្ម័នទ្រង់ធ្វើសឹកបរាជ័យចាញ់ដៃជ្វា ហើយព្រះអង្គជ័យវរ្ម័នទ្រង់ឈប់ចាប់ក្នុងព្រះហប្ដីជាបំផុត ព្រោះរឿងនេះ, ទោះបីព្រះអង្គមិនបានទ្រង់ខុសត្រូវ ដោយបំពោះ ក៏ពិត តែក្នុងហ៊ានៈ ព្រះអង្គជាខ្មែរ មានសេចក្ដីស្នេហាជាតិពេញបន្ទុក ទាំងជាខត្តិយ-ជាតិ គឺជាអ្នកបំបាំងរបស់ជាតិមក យើញសេចក្ដីបរាជ័យយ៉ាងងាយៗ ខែមុខដូច្នេះ ទ្រង់ក៏ទ្រាំខែសៀម្ដងខែពុំបាន តោងស្ដេចគៀសចេញអំពីស្រុក ខែកាន់ប្រទេសជ្វា ដើម្បីស៊ើបនឹងពិនិត្យមើលកំឡាំងជ្វាឲ្យជាក់ ដោយព្រឺនេត្ររបស់ព្រះអង្គ. ឃានស្ដេចយាងខែដល់ក្រុងស្រីវិជ័យ ដ៏ជាពជធានីរបស់ជ្វា ខឹងខែស្រុកសំខាន់ៗ ជវែងទៀតជាច្រើនអន្លើ ក្រោយបំផុត ឃានស្ដេចមកស្នាក់ខែស្រុកបន្ទាយដុង ខែឆ្នេរទន្លេបន្ទាយដុង អស់រយៈ ៤ - ៥ ខែហើយក៏ស្ដេចត្រឡប់មកព្រះនគរវិញ ។

រយៈស្ដេចដល់ព្រះនគរហើយ ទ្រង់ព្រះចិន្ដាថា តស្សក្រោពរបស់ជាតិជារបស់មានដំឡៃជាងគេ ទាំងអស់ ហើយជាមុខងាររបស់ជាតិសឹងមានក្សត្រិយ៍ជាប្រមុខ ឧទ្ធិគប្បីសន្ធជាងជីវិតរបស់ខ្លួនខែខ្មែរ ។

ការដែលនឹងរក្សាឥស្សរភាពទុកបាន គោលទៅតាមសម័យដែលនិយម សម្បូណ៌សិទ្ធិពាជ ក៏ដោយមានព្រះមហាក្សត្រិយ៍ដែលខ្លាំងមានព្រះសមត្ថភាព នឹងព្រះឥទ្ធិពលដ៏បរិបូណ៌ ។ ក្នុងខនេះ សមដូចព្រះពាជបន្ទូលដែលគេបានចារឹកទុកនៅស្តូកកូម ក្នុងស្រុកស្រីសោភណ ថា "..... ដើម្បីកុំឲ្យកម្ពុជទេសនេះ អាយ័តឥឡូលេយ លេងអាច គឺក្រមគេងផ្ទៃក្រោម តណាចក្រពត្តិ" នេះជាព្រះពាជយោបល់ នឹងព្រះពាចានៃព្រះជយវរ្ម័ន ។

បន្ទាសេចក្តីកងរឿងដោះស្រាយបញ្ហាអាយ័តឥឡូនោះ ខ្ញុំឈ្មោះយល់ថាត្រូវបំពេញកិច្ចពីរ ២ ផ្លូវដូចខ្លះ ។

១ — ត្រូវធ្វើសឹកក្នុងប្រទេសពោលគឺ ធ្វើបរិវត្តន៍ខម្លាក់ស្តេចដែលខ្លាំងឲ្យសូវថ្លៃចេញពីពាជបល្ល័ង្ក ព្រោះខ្លាំងខ្លាយព្រះសមត្ថភាពណាស់ មិនអាចការពារឥស្សរភាពរបស់ជាតិឲ្យគង់នៅបាន ។

២ — ត្រូវទទួលរាប់រងធ្វើសឹកនឹងប្រទេសក្រៅ គោលគឺជាមួយផ្លូវទៀតជាខាងក្រោយ ។ បើអាចតាំងពីផ្លូវនេះ ឥស្សរភាពរបស់ខ្មែរអាចនឹងមានជីវិតឡើងវិញបាន ។ ក្នុងរឿងនេះ ព្រះវរជយវរ្ម័ន ខ្ញុំប្តេជ្ញាថា : ក្នុងជីវិតរបស់ព្រះអង្គត្រូវតែស្រោចស្រង់មាតុភូមិ ឲ្យរួចអំពីអាយ័តរបស់ជាតិដទៃ បើមិនសម្រេចទេ សូមឲ្យជីវិតរបស់ព្រះអង្គនឹងសូន្យទៅក៏តាមការ ។ អំពីនោះ ខ្ញុំក៏ធ្វើមរបូរមសេនាទាហាន

អំពីតំបន់ផ្សេង ។ តាមដែលប្រាកដឈ្មោះ គឺអំពីក្រែស្តបុរៈ (ប្រាសាទ-ប្រាកសេ) អំពីកម្ពុបុរៈ (ក្រចេះ) អំពីតន្ទ្រូបុរៈ (តូរ៉ងឃ្មុំ) អំពីវធ្យានបុរៈ (ប្រាក់) រួមបានជាកងទ័ពធំមួយ ។ គ្រាខោះ មានមន្ត្រីតូចពីរនាក់ (មិនប្រាកដឈ្មោះ) ខៅទតបុរី (ខ្មែរបច្ចុស) ជាអ្នកមានគុណវុឌ្ឍិ ប្រាទមកក្រាបទូលសូមយកអាសាផែនដី, ព្រះជយ-វរ្ម័ន ទ្រង់ទទួលមន្ត្រីទាំងពីរខោះទុកជាសេនាបតីរបស់ព្រះអង្គ ។ ការលប-ដុំសេនាគាហានបានគ្រប់ហើយ ស្តេចក៏លើកទៅលុកក្រុងតន្ទ្រូបុរៈ(១) ធ្វើការបដិវត្តន៍ទម្លាក់ព្រះបាទាលាវិត្តវរ្ម័ន ចេញពីរាជបល្ល័ង្ក បាន សម្រេច ហើយព្រះអង្គក៏ឡើងគ្រងរាជសម្បត្តិ កុងឆ្នាំ ៣. ស. ១៣៤៥ (ម. ស. ៧២៥) ខោះទ្រង់មានព្រះអគ្គមហេសី ព្រះនាម "កម្ពុជាលក្ស្មី" ក្រោយមកទ្រង់មានព្រះរាជនុរស ១ អង្គ ព្រះនាមដើមដូចម្តេច មិនប្រា-កដ តែកាលព្រះរាជនុរសបានសោយរាជ្យកុងវេលាក្រោយមក ប្រាកដ ព្រះបរមនាមថា ជយវរ្ម័ន ដូចព្រះរាជបិតា ។

សង្គ្រាមជ្វាគ្រា ទី ២

កុងខែដែលគ្រាស់ថា គោងធ្វើសង្គ្រាមនឹងប្រទេសជ្វានោះ ខៅ ទីសេចក្តីពិតឥតស្មៀង គឺការសង្គ្រាមជ្វាជាបថា ប្រទេសកម្ពុជាផ្ទាស់

(១) ក្រុងនេះនៅខាងជើងខេត្តសៃ គឺក្រុងដែលក្នុងព្រះរាជពង្សាវតារកម្ពុជាហៅថា តន្ទ្របត្តបុរី តែមិនមែនខេត្តរាជ ។

ព្រះពាជាម្ចាស់ផែនដី កំចាត់ពាជទូតឲ្យមកផ្តៀងថា ប្រទេសកម្ពុជាត្រូវនៅ
ក្រោមបង្គាប់ប្រទេសជ្វាដូចកន្លងមកក្នុងសង្គាលមុន ។ ព្រះបាទជយវរ្ម័នត្រាស់
តបពាជទូតជ្វាដោយព្រះពាជឫទ្ធារស្មូរសីហនាទថា សំដីដែលថា ប្រទេស
កម្ពុជាត្រូវនៅក្រោមបង្គាប់ប្រទេសជ្វានោះ អាចមានបាន ចំពោះតែកន្លង
មកសង្គាលមុន មួយពេលប៉ុណ្ណោះ, សម្រាប់សង្គាលបច្ចុប្បន្ន មិនត្រូវ
ការនឹងអ្នកសំខ្លែងបែបនេះទៀតទេ សូមកុំឲ្យជ្វាសង្ឃឹម យ៉ាងដែលជ្វាប់
សង្ឃឹមនោះតទៅទៀតឡើយ ។ ពាជទូតជ្វាបានស្តាប់ព្រះពាជឫទ្ធារដូច្នោះ
ក៏ក្រាបថ្វាយបង្គំលាត្រឡប់ទៅវិញ យកសេចក្តីក្រាបទូលស្តេចជ្វា តាម
ព្រះពាជតម្រាស់នោះគ្រប់ប្រការ ។ ព្រះពាជាជ្វាទ្រង់ព្រះសណ្តាប់ហើយ
ក៏ឈ្លួសក្នុងព្រះពាជហឫទ័យ ហាក់ដូចអសិរពិសដែលគេប្រហារត្រូវ
កណ្តាលខ្នង ទើបត្រាស់ព្រះសូរសៀងយ៉ាងសីហនាទថា ត្រូវកម្ចាប
កម្ពុជាឲ្យខ្លាច ! ហើយក៏ត្រាស់ឲ្យសេនាបតី ត្រួតបេរពលមកពេមុក
លុកកម្ពុជរដ្ឋ ដោយបំណងនឹងកំទេចឲ្យល្អិតលើសពីកាលមុន ចំណែក
ព្រះអង្គ ក៏ទ្រង់តំណែងជាស្តេចសឹក នាំទ័ពតាមទ្រង់ទឹកចូលមក
ប្រទេសកម្ពុជាពីខាងត្បូង ។

ព្រះបាទជយវរ្ម័នកាលទ្រង់ជ្រាបពត៌មានសឹកជ្វា លើកមកដល់
ដោយព្រះពុទ្ធគាណាវិធីត្រហើយ ក៏ត្រាស់ឲ្យប្រជុំគណៈសេនាធិបតី
ដើម្បីជាដំណឹងក្នុងផ្លូវការ ទើបត្រាស់ឲ្យសេនាបតីយុទ្ធនាធិការរៀបក្បួន

ខ័ត្តដោយរួសពន់ ចំណែកព្រះអង្គក៏ទ្រង់តំណែងជាក្សត្រិយ៍សឹក លើកខ័ត្តហួងទៅកំចាត់បច្ចាមិត្រ ។

សង្គ្រាមគ្រានេះ បើគិតតាមចំនួនរយៈពេល នឹងតទ្ធិពលរបស់ប្រទេសទាំងពីរ ត្រូវគេកជាសង្គ្រាមធំ ១ ក្នុងប្រវត្តិសាស្ត្រ ព្រោះប្រទេសទាំងពីរជាមហាប្រទេស មានតទ្ធិពលប្រហែល ។ គ្នា ហើយការដែលកើតសង្គ្រាមគ្រានេះ ក៏ដោយមានសេចក្តីអាឃាដយ៉ាងខ្លាំងទាំងសងខាង តែខាងធ្លាប់ស្មានខុសថា គង់ជាឈ្នះខ្មែរដូចលើកមុន ។ ឯខាងខ្មែរគេអាចខុសចិត្តបានថា ព្រះបាទជ័យវរ្ម័នជាក្សត្រិយ៍សឹកដ៏ឯក ដោយទ្រង់មានព្រះសមត្ថភាពក្នុងផ្លូវយុទ្ធសាស្ត្រ នឹងសេចក្តីក្លាហានគេញញើ ។ ឯសេនាធិការបស់ព្រះអង្គសោត ក៏សុទ្ធតែមានវិន័យមានសេចក្តីក្លាហាននឹងសេចក្តីសាមគ្គី-ភក្តីចំពោះព្រះអង្គដ៏ចំហុត, ដោយហេតុនេះគាល កងខ័ត្តតាំងពីខាងលើកទៅដល់ទល់មុខគ្នាហើយ ក៏ឋានតយុទ្ធគ្នាយ៉ាងអង់អាចតែមិនយូរប៉ុន្មាន កងខ័ត្តខ្មែរក៏សង្កត់កងខ័ត្តជ្វាជាប់ ដោយខាងខ្មែរមានចតុរង្គសេនាគ្រប់តាំង ៤ ពួក ឯជ្វាមានតែពលថ្មើរជើងមួយពួក ឋានគាប់សម្រាប់ពលជ្វា នឹងចាប់ឋានខ្លួកចំបាំងជ្វាច្រើនជាអនេក, ក្សត្រិយ៍ជ្វា នឹងរយៈពេលដែលសល់ពីត្រូវអាវុធស្លាប់ ក៏នាំគ្នារត់ចុះខ្លួក ជាយត្រឡប់ទៅវិញ គាហានខ្មែរក៏ចុះខ្លួកចំបាំងជ្វាដែលចាប់ឋាន បំផាយដេញតាមទៅរហូតផុតដែនមាលយូ ដែលរយៈនោះជាជាយអាណាខែត្តនៃ

ប្រទេសកម្ពុជា ទើបត្រឡប់មកវិញ ។ ព្រះពាជបំណងរបស់ព្រះបាទ
ជយវរ្ម័ន ទី ២ ឈ្មោះថា បានសម្រេចហើយក្នុងពេលនេះ ។

ការផែនដី: ជាទំនៀម ព្រះមហាក្សត្រិយ៍ខ្មែរពាល់។ ព្រះអង្គតាំង
អំពីដើមមក កាលទ្រង់ធ្វើព្រះពាជសង្គ្រាមមានជ័យជំនះហើយ តែងតែ
ទ្រង់សាងហាន ទី ឬវត្ថុសំខាន់និមួយ ទុកជាអនុស្សាវរីយ៍ជាដរាប ។ ព្រះ
បាទជយវរ្ម័ន ទី ២ កាលទ្រង់ធ្វើព្រះពាជសង្គ្រាមស្រង់ប្រទេសជាតិមាតុ-
ភូមិ ឲ្យរួចអំពីហាន:ជាអាយ័តផ្លាហើយ ទ្រង់ក៏បានចាត់ការតសាងតាម
ប្រពៃណីនេះ គឺដំបូងទ្រង់សាងក្រុងថ្មី ១ ឲ្យឈ្មោះថា "ហរិហរាល័យ"
(ដែលតាក្យសាម័ញ្ញ ហៅថា លវៃ) នៅក្នុងស្រុកសូទ្រនិគម ខែត្រ
សៀមរាប ក្នុងបច្ចុប្បន្ន ហើយស្តេចចេញពីក្រុងគន្ធបុរៈ ទៅគង់នៅ
ក្រុងថ្មីនេះ ។ តពីនោះ ជាវារៈទី ២ ទ្រង់បានសាងប្រាសាទ ១ ហៅថា
"អមរេន្ទ្របុរៈ" (បន្ទាយឆ្មារ) នៅភូមិស្រុកខែត្រជាប់ជំបង ហើយ
ឆ្លាក់រូបភាពកងទ័ពរបស់ព្រះអង្គ ដែលធ្វើសង្គ្រាមជាមួយឆ្លាមានជ័យជំនះ
ទុកជាអនុស្សាវរីយ៍ តាំងជាប់ជាប្រវត្តិសាស្ត្ររបស់ជាតិធង ។ តអំពី
នោះ ជាវារៈទី ៣ ទ្រង់បានសាងព្រះពាជធានីថ្មី ១ អន្ទៀត នៅលើ
ខ្នងភ្នំគូលែន ហៅថា "ក្រុងមហេន្ទ្របតិត" ហើយស្តេចចេញពីក្រុង
ហរិហរាល័យ ទៅគង់នៅក្រុងថ្មីនេះ ។ ស្ថានទីដែលពោលនេះ សឹង
មានជាពុទ្ធសាក្សីនៅដល់សព្វថ្ងៃនេះ ។ (នៅមានត)

លោក ព័យ-ប៊ុក គ្រូមការ រៀបរៀង

(ត.ម.)

បកិណ្ណកវគ្គ (ត)

៥ – កុំលំនុនអង្គខ្លាចឥស្សា ធ្វើចិត្តហានក្សាសាធជាតិខ្លីង ទើប
ប្រទេសជាតិបានរុងរឿង ជាតិភ្លើងឆ្នុះភ្លឺដល់សាសនា ។

៦ – មនុស្សក្រែចខ្នាតធ្លុះសូកាល ស្មែងអំពើពាលការទុច្ចរិត
មនុស្សទឹកត្មោតតែងប្រព្រឹត្ត សុចរិតពិតពុំសង្កា ។ បុគ្គលនេាង
ឱ្យដល់ចាស់ បុគ្គលស្វាយស្រអកុសលា ពីខាងក្នេងកាចតាមការ
លុះដល់ដកប្រែសែងម ។

៧ – កុំត្រាប់កងកេងប្រចណ្ឌប្តី ត្រាប់មានទ្រព្យស្តីកាន់សច្ចៈ
កុំត្រាប់កុកសប្រហែសជាប់ ត្រាប់កុកសាប់ឱ្យក់អប្បមាទ ។ កុំឱ្យ
ត្រាប់ត្មាតរកកូនលាមក ឱ្យត្រាប់ឱ្យានសុខតាមច្បាប់ខ្លាត ត្រដេរវិចារក្សា
ស៊ុតសង្ឃាត ប្រាជ្ញាតប្រយ័ត្នមិនផ្ទេរខ្លួន ។

៨ – ប្រើកូនគេដូចខ្លាក់ក្អែកពីរ ខ្លាក់ម្ខាងពេញវ័យប្រើកូនឯង
បើប្រើអាត្មាប្រាកដស្តែង ដូចក្អែកភ្លឺបែងចាំងរស្មី ។

៩ - ឆុងទេព្តសូរសព្ទខ្ចាំង សុនខសាំនព្រៃសមិនដែលខាំ រក្ខជាតិ
ព្រឹក្សផលាជាំ ផ្ការច្រើនចំណាំមិនសូវផ្លែ ។ ផ្លែសូរច្រើនដងមិនដែល
ក្លៀង មនុស្សរកៀសដៀងតាមសត្វប្រែ និយាយប្រាជ្ញព្រោងអ្នកតូចតែ
តែបែរកត្តូមកស្គាល់ល្ងីតល្ងង់ ។

១០ - កង្កែបខែត្តេត្រូវក្លៀងធំ សប្បាយស្រួលសមដូចបុប្ផា
ត្រូវនឹងសន្សើមធ្លាក់បសុធា សុខស្រួលកាយគតទុក្ខកំយ។ មនុស្សណា
មានទុក្ខក្តៅក្រហាយ ឃ្លានដល់សប្បាយឈ្លក់ដោគជ័យ ក្លេចនិកទុក្ខ
ព្រួយហេតុបច្ច័យ និស្ស័យជាតិមនុស្សគតតែសុខ ។

១១ - កង្កែបខ្មៅកងអន្ធង់ទឹក ស្មានមេឃតូចនឹកប៉ុនគ្រប់ឆ្នាំង
បុគ្គលល្ងីតល្ងង់អវិជ្ជាចាំង តែងចាត់ខ្លួនគាំងប្រៀបដូចកង្កែប ។

១២ - ទុក្ខខ្សោយជាងចិត្ត សត្វខ្សោយកម្មតិត លោកខ្សោយ
ជាងធម៌ ជាតិខ្សោយសាសនា លាមកខ្សោយល្អ អាត្មាខ្សោយតរ
ជនសត្រយើញ ។

១៣ - ត្រីស្តូហ្គូលមប៍ជាអ្នកប្រាជ្ញ គេសរសើរអាចរកខ្វីប្រា
អាមេរិកឃ្លានឃើញតាមប្រាជ្ញ ចេះសួនមើលការឃ្លានសម្រែច ។ ដល់
ត្រឡប់វិញមានពួកបច្ចា ពោលពាក្យនិន្ទាស្តីបង្កាច់ ថាការខៅរកតំណែល
ត្រែច អាមេរិកស្រែចជាងាយស្រួល ។ ត្រីស្តូហ្គូលមប៍យកពង៍មាន់
ជាក់លើតុកាន់ពាក្យបបួល ប្រកាសប្រាប់បុគ្គលឲ្យទទួល ផ្តួលជាក់

បញ្ញារលើតុបាន ។ មិនមានអ្នកណាប៉ុនប្រៀបប៉ែ ឆ្លើមិនកើតគ្រប់នាគូមិស្មាន គ្រិស្តហ្វូប្រើឧបាយចិត្តក្លាហាន គោះភង់មាន់ចានបញ្ញាតាម ។ បុគ្គលតង្ហាចាឆ្លើបាន ឬកដគោះចានបើមិនហាម អ្នកឬជថាការកគិតក្លាម ស្រួលងាយដឹតជាមមិនយល់ដាន ។

"ការងាយខាងលង់ លំបាកគិតកង្ក ខាងពួកបណ្ឌិត ដែនទីសម្រាប់ពួកនិរពិនិត្យ មេរំពាស្គាល់ចិត្ត គំនិតសត្រូវ" ។

๑๘ - ទ្រូបជាគ្រូបច្ចុប្បន្ន បង្រៀនគាត្មាស្រឡាញ់ជាតិអាស៊ីជាគ្រូទំនងាត ប្រដៅទុក់ខអនាគត ។

๑๙ - មនុស្សត្រូវពឹងមនុស្ស រុក្ខាមូស្មោះ ជន្ទង់ពំនឹង មនុស្សត្រូវពឹងសត្វ ទាបយកខ្លួស់ពឹង ធំផ្អែកតូចសឹង បង្កើលរង់រឿង ។ បណ្ឌិតធម្មា ចុះបពឹងពាលា គ្រឡាចពឹងទ្រឹង ជាតិដ្ឋប្រុសសម្ងពឹងគ្រឿង មហាភដច្ចុំថ្កើង ដោយពលទាហាន ។

๒๐ - ឃើញសុំបកថាខ្វឹមក្លែ យល់ពួកបច្ចាថាជាមិត្រ ពាលជនច្រឡំថាបណ្ឌិត ច្រមុំលាមកពិតថាបុប្ផា ។

๒๗ - មនុស្សមានភ្នែកលិត មានត្រចៀកច្រើនពិត ហៅក្រពេកពន់ ចេះមិនច្រតិបត្តិ ហៅលង់លើសលន់ មានវិទ្យាគុណ ហៅមានច្រាកដ ។

១៨ — កុំយកមាន់ទៅផ្ទើនឆ្កែស្មាច់ កុំយកឥម៉ាំងទៅផ្ទើនឆ្កែខ្លា ឯ
ជាតិកែកុំផ្ញើមច្ចា កុំផ្ញើមនុស្សក្រែចាក់មាសពេជ្រ ។

១៩ — ធ្លើស្រែយកស្រូវ បើកៀបអំពៅ គេយកស្ករជាតិ បុគ្គល
ជួយយើង ក្រែថ្នាសង្វាត កម្រៃតាមខ្នាត មិនមែនខ្ចេ ។

២០ — អ្នកធ្វើដំនួញ ចេញសំពៅជួញ ខាត់ក្បាច់ចំណេញ
មិនដែលហៅខាត អ្នកចំប៉ាំងចេញ ចូលទៅប្រដេញ ព្រោះឃើញ
ផោគជ័យ ។

២១ — រុក្ខាខ្ពស់ធំ វាយោច្រដុំ ចោកបក់ខ្លាំងក្លា រលំលាន់ឮ
សត្វព្រៃព្រឺក្បា សូរសន្ធរលោកា ដាន់ស្មៅដើងក្រាស់ ។

ឥត្ថីវគ្គ

១ — បើការស្ងប់រស់កុំច្រឡប់ស្ត្រី បើប៉ុនដាំខ្ចី ។ ច្រាក់ទិញ ការ
ស្ងាត់កំប៉ាំងកុំបញ្ចេញ បើប៉ុនដាវែញឲ្យមូលមួយ ។

២ — ស្រីស្អាតត្រង់ភ័ក្ត្រ សំពត់ល្អដាក់ ចំពោះជរាយ៉ាយ អ្នកមាន
បុណ្យសំគ្តិ គ្រឿងយសនោមធាយ ដាតិឯកពាជផ្សាយ ល្អផុតលោកា ។

៣ — មនុស្សមិនស្គាល់មនុស្ស កុំយកចំពោះ ធ្វើការខុសគ្គម
ស្រីពុំស្គាល់ស្រី កុំឲ្យសេពសម ករិយាជាធំ អគតិពុវិនាស ។

៤ — រុក្ខាផ្ងាស់ពណ៌ពេលផ្កាផ្លែ នារីប្រែវណ្ណាដល់យុវតី ផ្ងាស់
ជាតុមនុស្សសត្វសព្វបក្សី ចេញចូលប្រែស័យគ្រប់វេលា ។

៥ – ស៊ូយកស្រីផ្កាមាសជាកវិយា មិនឲ្យធ្វើពេស្យាប្រតន្ទខ្លួន ស្រវឹងប្រសើរក្នុងទ្វីបបួន មិនស្មើលោកស្រីចាំង - កែ - ចិក ។ ប៉ាន់ជួយ ស្វាមីពីសែអាន ។បាយកល្យាណកលកិច្ចនឹក មានប្រាជ្ញាចូលខាង អាមេរិក រវៃស្រីខាំដឹកជាតិចិនថ្លើង ។

៦ – ប៉ុន្តែអំណាចស្រេចមកចូរជ កម្ទាំងអង្គអាចស្រេចស្រមោច មហាសុខនិព្វានអស់តូជ មានោស្រួចមុតជាច់ស្ត្រី ។

៧ – ឆ្មេញតែងចាំដីក្អូរអណ្តាត ចានកវៃជាខ្លាតែងរណ្តំគ្នា កស្តាខេត្តីខៅរួមគ្រែហា គង់ឥសាស់អាត្មាឈ្មោះមិនខាន ។

៨ – កុំយកអង្គរស្រវៃផ្ងើនឆីមាន់ កុំយកផ្កាច័ន្ទន៍ផ្ងើនឆីស្រី កុំផ្ងើជាងឈើដែកស្វានវៃ កុំផ្ងើត្រយ៉ាលក្ខណ៍ឆីពួកពាល ។

៩ – តរុំណោខៅដិតតរុណី ត្រូបីខៅដិតរុក្ខាបេក ហត្ថីអំពៅ ចូលចោចសែក ស្រមោចស្តាវៃចូកកាត្រែង ។

១០ – ផ្សារកំពង់ទឹកមិនវៃលស្ងាត់ ខាងការប្រាសព្រាត់ស្រេចសង្វារ ជនគាបចំអើតដល់មេឃា ស្រីមានតស្តាខើបសោកំណ ។

១១ – ស្ត្រីល្អមានខ្មាស ដល់ចិត្តវិបល្លាស កេរ្តិ៍ឈ្មោះអាស្រវៃ ចេញមុខប៉ាត់អៀន ពេស្យាពាលផ្ងូវ បុកណាប្រដៅ ឥតុតិរិយា ។

បណ្ឌិតខ្មាសចាប សេពគប់ពាលភាព សង្ឃឹមអាត្មា ដល់ពួកសត្វស្លូ
កពកូមិលោកា អាសោចកាយា ធ្វើចាបក្លាហាន ។

១២ - កុំកាន់ធម៌ស្រែ កុំគ្រាប់ប្លាឆ្កែ ស្ងាត្រែវាយោ ខ្លួកដំរះ
ឃ្លែងឃ្លោង ចូលទឹកពេញពោរ កុំឲ្យឡើងដោរ ដោយសារពាក្យស្រែ ។

១៣ - នាងវិសាខា កងកតលោកា ជាស្ត្រីខត្តម បុង្គាគ្រអូប
លោកជាតុស្សតិព្រហ្ម បញ្ចពិធល្អសម នារីវិសេស ។

១៤ - ស្រឡាញ់ណាស់ប្រែស្អប់ បុត្រល្អសំណប់ ថ្នមហួស
ខូចខុស ស្រឡាញ់ភរិយា ប្រច័ណ្ឌសាយសុស ស្រីដែលស្អប់ប្រុស
ច្រែនធាប់ប្លាន់ប្តី ។

១៥ - ស្ត្រីខំតាក់តែងខ្លួនប្លាណស្អាត ប្រសប់មេម៉ាតាមខ្នាតទឹក
អប់ឈ្ងុយ សំពត់ល្អិតក្តីរសែកងស្អុយ មារយាខុយពេស្យាអាត្មាបង់ ។

(ខ) ស្ត្រីតាក់តែងខ្លួន លាបមេម៉ាត្រមួន ទឹកអប់គន្ធ
ស្ងៀកពាក់ស្អាតសម រាងកងមិនស មេឃស្អាប់ពុំល្អ បណ្ឌិតស្គាល់
ជាក់ ។

១៦ - ធ្វើការដាំមួយប្រសាលព្រួយល្មម លំប៉ាកណាស់ត្រម
ស្រែពាលា ធ្វើកាំរគ្មានរបៀបរង់ខ្ចោចផ្សា ពួកសប្បុរិសារួមស្រួល
ងាយ ។

ឃុនសិរីមេធី ស្រី - អ៊ូ រួបរួម

(តមក ចប់)

ឈានដើងញាំញើញាប់រន្ធត់ញ័រ លះលេញឆេកឆោកដើរឆៀងឆើល
របុលរប៉ូចដូចគេផ្តើល ផ្លើត្រើលជាក្អកឲ្យប្រុសដឹង ។
គ្រហែមណេះណោះប្រុសមិនបែរ ធ្វើជាភ្លូញភ្លែរស្តីដូចខឹង
តតកែវតតាសផ្តាសមិនដឹង គាខតឹងស្ទើរតែនឹងជាប់ឲ្យល់ ។
ខ្លួនខាងគ្រមុំកុំធ្វើផ្តាស ភ្ញាក់ខ្លើងចំអាសអស់កិច្ចកល់
កែវភ្នែកកុំឲ្យណាមិនមានសល់ ហួសដល់លោកសង្ឃនៅឯវត្ត ។
រីរឿងដែលសួរដួសក៏ចា ចិត្តស្មុគ្រចង់ថាថែមប្រាកដ
ពុំត្រង់ស្តុងស្តូតរបូតមាត់ ពិតជាបំភ្លាត់តាមសញ្ញា ។
ដូច្នោះចំពោះពិតប្រាកដ មិនដឿឲ្យស្បថចុះរាល់គ្នា
ជាក់ជាក្តងចិត្តគិតចង់ថា នរណាមិនដឹងដំណើរនោះ ។
នេះឯងខាតលក្ខណ៍ជាក់ជាជន ផ្ទះពេកពន់ពិតចំពោះ
ចរិយ៉ាក្រែពេកពុំគោះ ហេតុព្រោះផ្សឹតខ្លួនមិនតាមច្បាប់ ។
ដេកយប់ខាស់ខ្លាបើទបង្ហិច សឹកខាស់ខាលាប្តូចឲ្យសព្វគ្រប់
ថែទាំរៀបចំរបស់ទៃឲ្យ រឹតបន្ទឹងដឹងជាដើមចុង ។
មើលសព្វក្លើងផ្លែងក្រែងព្យុះខ្យល់ បក់ប្រាកមកដល់ក្តីបុប្ផ

រឆ្កឹកាត់ទុសប្រែរត្រោងកូន ដើងគ្រានវែកឆ្ងល់ណាឆេះផ្ទះ ។
បើសួនបណ្ដូលចូលទៅហើយ ចោកពួកខ្ញុលខ្ជើយមើលឲ្យជ្រះ
ថែឲ្យស្អាតស្អំសំនាងប្រែ ដេកទៅរហ័សធាប់ភ្លាក់ឡើង ។
លុបមុខភ្លុះមាត់មាសស៊ីស្លា រួចហើយម្ដីម្កាកុំកន្ដើង
ត្រែកឡើងខន្ដែផ្ទះនឹងដើង ចេចើងចរចេញមកត្រៃហាន ។
រំសាយទាំងសក់អាត្រកក់ត្រៃ ពេញហៅចង្រៃពន់ប្រមាណ
ខាតអស់នូវលក្ខណ៍សត្តិយសប្រាណ កល្យាណកុំធ្លើដូច្នោះណា ។
កុំនាងលីលាទៅលេងឆ្ងាយ កំចាំងពីម្ដាយទៅមិនថា
ស្រែកប្រែងរំពងពុំនឹកនា ត្រែងគេនិន្ទាទៅផ្តេសផ្តាស ។
ប្រុសប្រាណបានឃើញដូច្នោះឯង មិនលែងឡកឡើយណាកូនមាស
ម្ដាយឃើញម្ដាយយល់តែអំពាស កាច់ខ្នាសមេប៉ាមកច្រែនហើយ ។
កុំនាងជាលដោយប្រុសល្ងង់លោភ រួមរសូបនោមជាតិជាគ្រឿយ
តែនោតតាមក់ពុំជាឡើយ កូនអើយប្រយ័ត្នកុំឲ្យឆ្ងាយ ។
បើឃើញកំឡោះដោះដៃចេញ កុំនៅលេលេញត្រែងត្រកែងក្រាយ
កុំឃើញតែប្រុសចុះចង់ដោយ ឡកលយខ្សែបឡុបប្រែបត្រមកូន ។
ប្រែឡែងប្រឡូកលូកបីបាម ប្រឡោមថ្ងាក់ថ្នមចោសត្រលឹង
មិនមានត្រែងចិត្តឥតកំដឹង រំពឹងឲ្យជ្រៅទៅគ្រោយមុខ ។
តែខ្លែងប្រែងឡើងល្អចំណាប់ ធ្លើការគាន់កាប់ចុះបានសុខ

ឆ្ពាំព្រៃពានដីធ្លើស្រែស្រុក　　ទៀងទុកក្តើរក្រោយឲ្យកូនចៅ ។
ប្រុសឡូចមិនដូចឯងស្រីទេ　　ហេតុនោះកុំមេជឿស្ងួនស្ងៅ
ធ្លើធោតលលោតដោយំគេទៅ　　ពាលពៅពុំត្រូវតាមភាក្យម្តាយ ។
ខាងចំប្រពឹត្តគិតប្រយ័ត្ន　　កុំឲ្យក្លេចក្លាត់ពាក្យបរិយាយ
ចូរចាំឲ្យមាំណាកូនម្តាយ　　គិតកាយកុំឆ្លេសចូរគិតគន់ ។
ធម្មតាយកគ្នាចិត្តទំនឹងចិត្ត　　ពុំដែលថេរបិតដល់គស់ជន្ម
ច្រើនតែលែងចោលទៅតព្រន់　　ពាំបាកចិត្តលន់លើសគេឯង ។
ហេតុព្រោះថ្ងូរស់ភ្លោយដោយភាក្យព្រាង　　បណ្តោតឲ្យខាងលុះគារវែច្រង
ពាក្យតម្កាថាមិនលែង　　ធ្លើក្លែងស្បថស្បែតែមាត់ក្រៅ ។
គឺមោះកងពោះមិនមែនសោះ　　ធម្មតាកំឡោះមិនដែលខ្លៅ
ប្រាជ្ញាកុងកាប់ចាប់សំដៅ　　មិនជឹងស្តាប់ទៅចូលចិត្តជោក ។
ភាល់តែធុកប្រាណបានដៃជាប់　　រួមសេរប្រាមិនអធ្យាក
មិនមានអាណិតគិតយល់យោគ　　ដល់កើតស្អាក់ស្អេកគាំងជាល់តប់ ។
ពាក្យប្រែក្រឡែងព្រងើយ　　ធ្លើជាគោរតើយពិតពុំពប់
មិនមានលើកលែងប្រែជាស្អប់　　ត្រឡប់ធ្លើជាមិនដឹងខ្លួន ។
ឯងទៅកំព្រាជាមេម៉ាយ　　សង្ឃឹមសហាយគេចរៃភ្លួន
ចង់ក្តើខ្លួចឈ្មោះខុសក្រៅក្បួន　　មាសសួនកើតកូនអត់ឧសអាង ។
លំបិនលំបាកខ្លែងស្ទើរបែក　　សម្រក់ទឹកភ្នែកមុខក្រៃមក្តាំង

ព្រោះតែថ្ងូរដង្ហើយដោយមោហ៍ចាំង ស្មោកគាំងគំនិតគិតទញ់តុះ ។

យ៉ាងនេះពុំគាប់ស្ងាប់មិនខាន កុំធ្វើជួបបាននិយាយខ្ទុះ

ម្តេច ។ ខំគ្រាអត់សិនចុះ កុំធ្វើឲ្យលុះខុសខ្ចប់ច្រណា ។

បើជាខោះប័ណ្ណអាត្រកក់ តំរែកតំរក់ក៏គង់មាន

ប្រុសឈ្មោលចូលស្តីមិនដែលខាន ប្រុងច្រណាកាន់កេរ្តិ៍តាមច្បាប់ស្រី ។

ហៃកូនសំឡាញ់ពេញចិត្តមែ៎ នាងនែបើនាងទៅមានប្តី

កុំខឹងក្រែរក្រោធតតមេត្រី ចូរស្រីស្រុសស្រួលទទួលទៅ ។

បើប្តីខេរខឹងសំឡឹងមុខ នាងខំអត់ទុកឲ្យស្ងៀមទៅ

កុំធ្វើយតបតប្រុះប្រាកទៅ ស្រីពៅចាំមាត់សង្កត់ចិត្ត ។

កុំខឹងប្រុះប្រាកគំហកតប ឲ្យប្តីខ្លាចខ្លួបមិនមានគិត

ខ្លួនឯងដាស្រីស្រាលគំនិត ពេកពិតតុំដីខ្ទុះត្រូវអ្វី ។

ស្លួនម្តាយនាងធ្ងន់តម្រង់ចិត្ត ផ្តក់ផ្តង់គំនិតប្រតិបត្តិប្តី

នាងបៀកស្ងាមមូរប៉ារី កុំបីឆ្លើឆ្លេសប្រហែសខ្លួន ។

យប់ព្រឹកប៉ាយទឹកវៀបបុង ប្រដាប់ប្រៀបប្រុងម៉ែលថែឆ្លួន

វៀបរួចសិតទឹកមកមែនម្លួន ហើយស្លួនលើកប៉ាយដាបន្លាប់ ។

បៀកស្ងាប៉ារីដាក់ដើងពាន ភ្លើងផ្សែងសោតមានត្រប់ប្រដាប់

យកមកឲ្យសត្វត្រប់ស្រែចស្រាប់ កុំឲ្យប្តីច្បាប់ញយ ។ ដង ។

លើកប៉ាយដល់មុខរកហៅប្តី សំណោះមេត្រីកុំបីឆ្គង

អញ្ជើញពិសាណាអ្នកបង សូនគ្រងរួសពាយទៅគាន់ប្តី ។
ប្តីមកដល់ចោ៉កអង្គុយប៉ុក នាងទៅតីមុខគាល់ស្វាមី
មើលបេះឆ្អឹងឆ្អែងគ្រែងប្តីសិ នឹងអស់អ្វី ។ ត្រូវជួសជាក់ ។
ថែមទៀតជាថ្មីកុំបីខ្វិល ប្តីគាញរម្ដិលថាសចេញជាក់
នាងហុចពានស្ងោថាហែអ្នក រំលេកឃ្លាឆ្លើងច្នោះណាពាលទៅ ។
ប្តីហូបរួចពាល់សល់ប៉ុន្មាន សឹមកូនគល្បាណានាងលើតទៅ
រៀបរកស៊ីចុកថែកកូនចៅ ទើបហៅគោតទ្វាចស្ងាម៉ែកត្តិ ។
ថាបើប្តីជ្រាណាមានមេត្តា ឲ្យញុំាងឆ្នាំគ្នាសូនរំលេកឃ្លាំ
ឲ្យប្តីហូបឆ្ងាយបីមា៉ាត់ជាក់ ស្រែចហើយទើបអ្នកនាងញុំាគ្រែយ ។
អង្គុយបត់ដើងឲ្យត្រឹមត្រង់ រៀបអង្គុឲ្យគួរកុំបីឆ្ងាយ
មានសៀវភៅតបានាងកុំឲ្យ ខាតពុំសតាមដោយច្បាប់តម្រា ។
ចំពូកមួយទៀតរ៉ាំណោក បើនាងចូលជេកឲ្យទុស្សាហ៍
ចោសពូកខ្នើយខ្នាល់ហើយនិគ្រា ពុំជាកុំគេងត្រឹមនឹងប្តី ។
ត្រូវប្តីចូលជេកមុនប្រពន្ធ ហើយសឹមស្រីតន់តូចពិសី
ចូលទៅនិគ្រាជាគ្រែយខ្លី ទើបត្រូវឥតបីមានពុំសច្បាប់ ។
ជេកកុំឲ្យលក់លុះព្រឹកព្រាង ចង្វៃដល់នាងពិតពុំគាប់
គ្រែកឡើងមុនប្តីស្រីប្រញាប់ ផ្ដួផ្ដាប់សិតទឹកទុកឲ្យប្តី ។
រៀបស្ងោម្ហូបថ្នាំប្រចាំខែ កន្ងហិបណាទៅកែវពិសី

ដល់ថ្ងៃរឿងរៃពេញតិចី ហើយស្រីតណ្ដាំប្ដាយទឹកទៅ ។
ប្រយ័ត្នកែងជួនជាប្ដីសី ចេញទៅពនដីប្ដាយផ្ដៅ
តាប់ខសប្ញស្សីអ្ហីណាទៅ ការត្រៀងខែក្ដីណាខ្លួន ។
កុំស្ដីដើមប្ដីឲ្យខ្លួនខ្ហាយ ដូចគេដេកផ្ងារស្ពោះលើខ្លួន
ខ្លួចជាយ៉ាងណាវាក្បាសខ្លួន បំពួនបំពាក់លាក់ទៅជា ។
បើប្ដីមានយសខ្ពស់បុណ្យសក្ដិ មានមនុស្សពីងពាក់បុណ្យវាស្នា
នាងកុំព្យយដំបង្ខំវា នោះនឹងរួញរាពុំលែងឡើយ ។
ថាបើមានខ្វៃកំដរផង នាងយកចិត្តចងកុំគោះតើយ
កុំព្យយកុំដេរវោះនោះឡើយ ទៅអើយនាងស្ដាប់ម្ដាយឧបមា ។
បើនាងមានចិត្តគិតយោគយល់ ដូចគល់ទឹកត្រៀតត្រជាក់ថ្ងា
អស់ទាំងនាគាសត្វមច្ឆា ប្រាថ្នាពឹងពាក់សំណាក់នៅ ។
ថាបើទឹកក្ដៅនៅពុំបាន ឱ្យគិតកែប្រែប្រាណបៀសចេញទៅ
នៅពុំបានសោះព្រោះទឹកក្ដៅ គេហៅគង្វាអាប់ឥតបាន ។
រីទឹកឧបមាដូចកូនសួន ពន្លកខ្ចីមខ្ចួនកែវកំសត់
រីឯមច្ឆានោះប្រាកដ សន្ធត់ខុកជាដូចមនុស្សផង ។
វែលខ្សែត់ពីប្រាកយ៉ាកដន្ទាក់ រត់មកពឹងពាក់លើខ្លួនល្អង
បើនាងមេត្តាវាជាមួង ផ្ទង់ដូចជាទឹកត្រជាក់ ។
ថាបើនាងធ្វើកញ្ជោកវោត មិនមានអន្ទាក់ឲ្យចំជាក់

យប់ព្រឹកសន្ធឹកឥតមានអាក់ រលាក់រលើងធ្វើពុំគិត ។
បើធ្វើដូច្នោះពាលែងនៅ រត់ចេញចោលទៅបង់គំនិត
អស់ពីអង្គាក់ពុំស្ងួតត្រី ព្រោះដង្កូតនាងធ្វើក្រៃលែងច្បាប់ ។
នេះឯងជូចជាគង្គាក្តៅ ត្រីពីងពុំនៅតំយក្រែងស្ងាប់
ហេតុនោះកូនសូនខ្លួនខាងស្ងាប់ ម្តាយប្រាប់ប្រដៅរដាយមាត្រា ។
កុំឃើញប្រុសល្អចរចោលប្តី ដើមនោះឥតបីបើនឹកនា
ស្រឡាញ់ថ្មោងថ្មីធ្លាប់មុស្ស ចិត្តក៏មិនគិតក្តៅខ្លាសខ្លួន ។
លុះដល់ខ្លួនប្រាណឃ្លានទោក ស្លឹកណាប្តីដឹងជានឹមខ្លួន
ប្រព្រឹត្តធិតផ្តាសាលាក់បំពួន ជាប់ជួនជិតដោយសុហាយស្មន់ ។
ប្តីដឹងគេក៏យកចំណាក់ផង គេចាប់គេចងធ្វើទុក្ខគន់
គេលក់គេលែងឯងអៀនអន់ ទទ្រន់ទទ្រេកអ្វីគ្មាន ។
ពីឃ្លាតដល់ក្បាយនៃជីវជន្ម នៅរងទុក្ខធ្ងន់ឥតស្រាកស្រាន្ត
ស៊ីខ្លះឈាមសាច់អាចម៍ខ្លួនប្រាណ ពុំឃ្លានឃ្លាយទឹកដល់តិចតួច ។
យមឃ្លាលអ្នកចាប់ឃ្លានកាយា ឲ្យឡើងរកាបន្ទាស្រួច
មុតអស់ខ្លួនប្រាណប្រែពុំរួច ស្រែកយំគ្រលួចឰវ៉ែង ។
ត្នោតក្អែកប្រញឹកចឹកស៊ីពាស សាច់ជាប់ជាប់ជាសចំពុះផង
ឈាមហូរសស្រាក់ភ្លាក់ពយរង ទុក្ខធ្ងន់ភន្ធឹងឈឺខ្លោចផ្សា ។

ខោះតាំងថ្ងៃយប់គ្រប់ពេលពិត ពុំមានស្បៃយស្បូតដល់តំបូលណា
គ្មានតាំងសំពត់វ័ណ្ណអាត្មា កាយាទេតំនេរនៅ ។
ស្ងាប់កើតមួយថ្ងៃមួយរយជង ពីបាតកន្ទង់រង់ទុក្ខជ្រៃ
ខោះអស់បង់ប្អូនកូនញាតិនៅ ធ្វើបុណ្យជូនទៅពុំរដោះ ។
ព្រះពុទ្ធគ្រាស់ដាអម្បាលឱ្បាច់ ប្រៀបសូបាណពុំដាច់ពុំរួចសោះ
ពីត្រង់ស្រីចោរធិតប្តីនោះ រង់គ្រោះកំណត់ប្តូរយដាតិ ។
គ្រាន់តែរដោះពីទីជ្រៃ ម៉ាករង់ទុក្ខទៅពិតពុំឃ្លាត
កើតជាប្រែតប្តូរណាព្រោះប្រមាទ- ធិតប្តីជាអាទិ៍ឲ្យវេទនា ។
ហេតុនោះឯងមិញសំឡាញ់ខ្លាយ ខំធ្វើតង្ហង់តាយពាល់ទិក
កុំឲ្យខូចកេរ្តិ៍ណាសូនក្លា គ្រប់ពេលវេលាតទៅទៀត ។
ប្រយ័ត្នប្តូរណាប្រុងអង្គតាយកាល់ គិតកង់រយោបល់ឲ្យបង្ហើត
កុំឃើញតែងាយហើយឈ្លក់ឈ្លៀត សិក្សៀតណែនណាំណា
មាសមិត្រ ។

កាលដើមខ្ជូនម្តាយទៅគ្រមុំ ប្រុសឆង់ចោមជុំម្តាយមិនស្បៃត
ឲ្យពាក្យសំដីស្តីមកស្ងិច ម្តាយពុំលង់ចិត្តនោតដោយគេ ។
តែពួនណាថាណែនណាំ ម្តាយចៀសចេញស្មោះមិនគ្រាលគ្រៃ
មិនជិតមិនស្និទ្ធស្នាលទៀតទេ ងាកវេរប្រែប្តូរណាដើរចេញទៅ ។

ម្តាយរក្សាប្រាណដល់មានប្តី មិនមានមោះអ្វីទេណាស៎ៅ

គ្មានប្រុសណាមួយមកនាទៅ ប្រាជ្ញខ្លៅសរសើរសឹងគ្រប់មាត់ ។

តទ្បូវនេះម្តាយចាស់ម្ល៉ះហើយ ស្រីថ្លូម្តាយអើយចាំកុំភ្លាត់

ធ្វើតាមពាក្យម្តាយទើប្រាកដ តាមដោយបូរបទកុំឲ្យឃ្លាត ។

នោះបើស្រីណាបើបានស្តាប់ ធ្វើតាមបង្គាប់នេះដាច់ខាត

ស្រីនោះនឹងបានស្ថានសួគ៌ស្អាត ប្រាសាទប្រសើរសឹងសុវណ្ណា ។

ប្រកបស្រីស្មុគ្រមការផង មាសប្រាក់តែវគង់ច្រើនត្រៀបត្រា

សំដីសុខតទុក្ខកង់អាត្មា នាល់រូចដល់មហានិព្វានហោង ។

ស័ព្ទចាំងប្រែជាខ្មែរ

របស់

គណៈកម្មការវិប្បធម៌ ហ្គ្លងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តមក)

Compte courant = គណនីចរន្ត

Capital social = ដើមទុនក្រុមហ៊ុន

Courant = ចរន្ត

Créances = ប្រាក់តេជំពាក់

Concessionnaire de mine = អ្នកទទួលសម្បទានអណ្តូងរ៉ែ

Capitalisme = មូលធននិយម

Capitaliste = មូលធនិក

Créancier = ម្ចាស់បំណុល

Dette = បំណុល

Colon partiaire = អ្នកទទួលប្រាក់ស់ដី

(Le Mardi 17-8-48

Merveilleux = អស្ចារ្យ

Merveille = អច្ឆរិយវត្ថុ

Une grande âme = មហត្មា

Humanité = មនុស្សធម៌, មនុស្សជាតិ

Emotion = ការរំជួលចិត្ត

Epreuve = វិញ្ញាសា

Vérité = សច្ចៈ សំត្យ

Merveilleux = អច្ឆរិយគតិ

Miracle = ឫទ្ធិបាដិហារ, អតត្តហេតុ

S'émouvoir = រំជួលចិត្ត

(Vendredi 20 8-48)

Société Franco-khmère de Navigation = [ក្រុមហ៊ុននាវចរ-ឫទ្ធិ-ខ្មែរ]

Féminisme = នារីនិយម

Sociologie = សង្គមវិជ្ជា

Club = ក្លឹប (សមាសនេយ្យចាយ,ភីឡាមណ្ឌល, មិត្តសមាគម)

Extrémiste = អច្ចន្តិកជន, អច្ចន្តិក:

Modéré = មជ្ឈន្តិក:(ឥ.មជ្ឈន្តិកា)

Impôts sur les revenues = ពន្ធលើផលទុន

Impôt sur les bénéfices = ពន្ធលើចំណេញ

Impôt sur les traitements de salaires = ពន្ធលើបៀវត្សរ៍

Impôt général sur le revenu = ពន្ធទូទៅលើផលទុន

Le Mardi 24-8-48)

Cession d'élément d'actif = អនុប្បទានវត្ថុជាតុសកម្ម

Caisse sociale = ហិបច្រាក់គ្រួសហ៊ុន

Capitaux mobiliers = មូលធនសង្ហារឹម

Capitaux engagés = មូលធនជាប់ប្រើ, ដើមទុនជាប់ប្រើ

Elément = ជាតុ, វត្ថុជាតុ

Capitaux disponibles = មូលធនទំនេរ

Capital mobilisé = មូលធនកប់

Capital investi = មូលធនប្រកបការ

Dégrèvement... (ការលះនុលា)
- décharge = ការដោះបន្ទុក
- réduction = ការបន្ថយ
- remise = ការបង្វិលឲ្យ
- modération = ការសម្រាល

Evaluer = វាយតម្លៃ

(Vendredi 27-8-49)

Présidente = អធិបតីនី, ប្រធានិកា

Echelon = លំដាប់

Echelonner = តាមលំដាប់

Moins-value = តុម្លៃថយ

Plus-value = តម្លៃលើស

Mensualité = អនុមាស

Négociant = មហាតាណិជ

Commerçant = តាណិជ, អ្នកដំនូញ

Marchand = ឈ្មួញ

Vendeur = អ្នកលក

Réforme = ការកែទម្រង់

Bilan = តុល្យភាព

Révaluation = ការកើលតម្លៃ

(Le Mardi 31-8-48)

Membre bienfaiteur = សមាជិកឧបការី (ត) - ឧបការិនី

— d'honneur = — កិត្តិយស

— donnateur = — ជនក (ត) ជនិកា—

— militant = — យុទ្ធិក (ត) យុទ្ធិកា

— actif = — សកម្មិក: (ត) សកម្មិកា

— adhérant = — សន្ធិ, (ត) សន្ធិកា

— sympatisant = — សមានចិត្ត—

Savoir - vivre = សុជីវធម៌

Courtoisie = ភ្ញៀវភាព

Affabilité = មនុញ្ញភាព (គួរស្រឡាញ់)

Aimabilité = ប្រិយភាព

Education = ការអប់រំ,ការប្រៀនប្រដៅ,ការសិក្សា

Tacite reconduction = ការបន្តអាយុដោយតុណ្ហីភាព

Valeur intrinsèque = តម្លៃសុទ្ធត្តិក:

— résiduelle = តម្លៃភាគ

— en porte feuille = តម្លៃក្នុងសំបុត្រ

Porte feuille = សំបុត្រ

Valeur extrinséque = តម្លៃពាហិរក:

Licence de distillateur = អាជ្ញាប័ណ្ណអ្នកបិទស្រា

Liquoriste = អ្នកលក់ទឹកស្រវឹង

Fabriquant = អ្នកធ្វើ

Dénaturateur = អ្នកបំប្លែងធម្មជាតិ

(Vendredi 10-9-49)

Titre d'identité de 194 . . N° . . . demeurant à . . . est autorisé à exploiter à . . . recette de . . . un établissement pour . . .

suivant décision N° . . . = អត្តសញ្ញាណប័ណ្ណ (ប័ណ្ណ) សំគាល់ខ្លួន
ត. ស. ១៩៨ — លេខ . . . នៅខា . . .
ឲ្យនាខ្លួលអនុញ្ញាតឲ្យបំពេស្រាខៅខា . . .
ផ្ទៃក . . . ក្នុងគ្រឹះស្ថានមួយរដើម្បី . . .
តាមលិខិតសម្រេចលេខ . . . . . ។

Il devra se conformer à tous les règlements sur la matière = អ្នកនាខ្លួលអនុញ្ញាត ត្រូវប្រតិត្តតាមបទបញ្ជាទាំងឡាយក្នុងរឿងនេះ ។

Cette licence devra être affichée dans un endroit apparent de l'établissement = អាជ្ញាប័ណ្ណនេះត្រូវបិទខ្ពុតនៅកន្លែងណាមួយ ដែលគេមើលឃើញដោយងាយក្នុងគ្រឹះស្ថាន ។

Licence gratuite délivré ce jour par nous, receveur soussigné à M . . .

A. . . le . . .

Le Receveur

នេះជាអាជ្ញាប័ណ្ណ ដែលយើងនាយផ្ទៃកបានចុះហត្ថលេខាខាងក្រោមនេះ ឲ្យក្នុងថ្ងៃនេះ ដោយតតយកថ្លៃចេញឲ្យដល់ . . . . .

— — — នា . . . នៅថ្ងៃ . . .

នាយផ្ទៃក

Timbre de l'entrepôt = នាយផ្ទៃក . . .

Licence de débitant en gros pour la vente exclusive des alcools indigènes

Est autorisé ouvrir à . . . un établissement pour la vente en gros des alcools indigènes exclusivement = បណ្ណសម្រាប់អ្នកលក់ដុំ ចំពោះតែស្រាអាយឃ្មានទទួលអនុញ្ញាតឲ្យតាំងនា . . . នៅគ្រឹស្ថានមួយ ដើម្បីលក់ដុំឃ្មានតែស្រាអាយ ។

Il devra se conformer . . . et notamment aux dispositions du titre 8 de l'arrêté du 18 octobre 1921 = មានបទបញ្ជាគឺកងំចំពូក ៨ នៃអារេត ចុះថ្ងៃ ១៨ តុលា គ. ស. ១៩២១ ជាដើម ។

La présente licence valable pour l'année 19 = អាជ្ញាបណ្ណនេះប្រើបានក្នុងឆ្នាំ ១៩ . . .

Perçu la somme . . . piastres = ឃ្មានទទួលប្រាក់ចំនួន . . . រៀល

Pour droit de licence = សម្រាប់ជាតម្លៃអាជ្ញាបណ្ណ

Quittance N° . . . de ce jour =, បង្កាន់ដៃលេខ . . ចុះថ្ងៃនេះ

Le Receveur provincial

នាយផ្នែកប្រចាំខែត

Les marchands colporteurs sont toujours tenus de présenter la licence à toute réquisition = អ្នកលែកលក់ ត្រូវបង្ហាញអាជ្ញាបណ្ណនេះជាដរាប បើមានអ្នកពាក់ការមកតាមរើល ។

Distillateur = អ្នកចំអ្រែស្រា (មាត្រ)

ប្រវត្តិសាស្ត្រនៃប្រទេសឥណ្ឌា

ហ្វូងនិពន្ធមន្ត្រី ញ៉ុក - ថែម ប្រែរៀបរៀង

(តទៅ ចប់)

ការខ័ត្តចាំងមូល ទៅគ្រានោះ អាណាចក្រវិជយនគរ មានអំណាច គ្រប់គ្រងប្រជាជនដល់ ៣ ចំពូក គឺពួកមីស្សរ, ពួកតេលុគុ, ខ័ណ្ឌពួក ទមិឡ ។ វិជយនគរទំ ចិនតស៊ូទប់ទល់ខ័ណ្ឌពួកអីស្លាមយ៉ាងម៉ឺនម៉ាត់អត់ធន់ជាជាងអាណាចក្រឯទៀត ។ ក្នុងឥណ្ឌា ហើយទើបតែបាជ័យ បាញ់ពួកអីស្លាម ក្នុងគ្រាដែលពួកអីស្លាមរួមកម្លាំងគ្នាចាមរោមចូលមក វាយ ទើបវិជយនគរធ្លាក់ទៅទៅក្នុងកណ្តាប់ដៃពួកអីស្លាម កាលពី ពុទ្ធសករាជ ២១០៩ ។

ទៅគ្រានេះហើយដែលប្រទេសឥណ្ឌាទាំងមូល ជាប្រទេសធ្លាប់ ចំរើនរុងរឿងដោយអារ្យធម៌របស់ខ្លួនឯងមកជាយូរ ត្រូវធ្លាក់ទៅទៅក្នុង អំណាចរបស់ពួកមហាហ្វូតអីស្លាម ហើយពង្សាវតាររបស់ឥណ្ឌាក៏ ផ្លាស់ប្រែប្រួលថ្មីពីបុរាណកាល ព្រះពុទ្ធសាសនាក៏សាបសូន្យបាត់ អស់ទៅ ទៅក្នុងឥណ្ឌាក៏តើតមានលទ្ធិសាសនា ២ ទៀង គឺសាសនា ព្រាហ្មណ៍ដែលកើតមកជាសាសនាហិណ្ឌូ ១ សាសនាមហាហ្វូតជាសាសនារបស់ពួកអីស្លាម ១ ។

សូម្បីបណ្ដានានាអាណាចក្រកន្លងផុតទៅនាំគ្នាលះបង់ចោលព្រះពុទ្ធសាសនាទៅហើយ តែនៅមានកោះ១ មួយដែលដាច់ចេញពីផែនដីធ្លាំងធំរបស់តំណែ្ង តាំងនៅក្នុងមហាសមុទ្រតំណែ្ង មានផ្នែកខ្លួនតូចទឹងផែនដីធ្លាំងធំឯនៅទិសខាងជើងកោះ ដែលយើងធ្លាប់ហៅថាកោះលង្កា ឬលង្កាទ្វីប។ នេះនៅមានជិតខ្មែនតែងកាន់តាមព្រះសាសនារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ កោះនេះហើយជាកន្លែងប្រតិស្ឋានសាខានៃមហាពោធិ៍ព្រឹក្ស ជាកន្លែងស្ដុកស្ដម្ភដោយគម្ពីរដីកានឹងព្រះសង្ឃសាវក ។

ដោយហេតុកោះលង្កានៅជាប់តំនឹងផែនដីធ្លាំងធំរបស់តំណែ្ង ទើបប្រវត្តិសាស្ត្ររបស់កោះលង្កាមានខ្លះដែលគួរសង្កេតជា ២ ប្រការ គឺកោះលង្កាឯងទទួលប្រជាជននឹងភាសាវៈធម៌មកអំពីតំណែ្ង ដោយមានពួកទមិឡចូលមកអាស្រ័យនៅក្នុងកោះនេះជាចំនួនច្រើន ហើយឯងនាំយកសាសនាព្រាហ្មណ៍ នឹងពុទ្ធសាសនាមកផ្សាយឯងនេះប្រការ ១ ប្រការ ១ ទៀត ដោយហេតុជាស្រុកកោះ ទើបរក្សាខ្លួនឲ្យឯងនឹងនៅឯងមិនត្រូវពួកអ័ស្លាមចូលលុកលុយខ្លួនឡើ ដូចជាអាណាចក្រតាំងឡាយក្នុងតំណែ្ង តាំងអំពីសម័យព្រះឯងអសោកមហារាជរហូតមកដល់សព្វថ្ងៃនេះ ។ ឯព្រះពុទ្ធសាសនាឯកជាត្រូវបៀតបៀនសង្កត់សង្កិនជាខ្លាំងក៏មិនឯងតស៊ូសាបសូន្យទៅឡើយ ។

គោះលង្កាបានស្គាល់ខ្លឹងគោរពកាន់តាមព្រះពុទ្ធសាសនា ដោយ
តែជានុភាពរបស់ព្រះបាទអសោកមហាពជ គាលវេងពុទ្ធសករាជ
៣១៣ ។ ព្រះបាទទេវ៉ានម្បិយតិស្សៈ ព្រះមហាក្សត្រលង្កាអង្គ
ដំបូងដែលបានប្រកាសព្រះអង្គជាពុទ្ធមាមក: ហើយទ្រង់ជួយទំនុកបំរុង
ព្រះពុទ្ធសាសនា កសាងព្រះវិហារសាលាខ្លឹងព្រះចេតិយខ្លឹងជាច្រើន
ច្រើន គាសាបាលីដែលជាគាសាសម្រាប់ប្រើក្នុងពាក្យ ក្នុងពាក្យអា-
ណាចក្ររបស់ព្រះបាទអសោកនោះ ក៏ក្លាយទៅជាគាសាយ៉ាងសំខាន់
ជាទីនិយមកាន់តាមនៃពុទ្ធសាសនិកជនទៅគោះលង្កា ។ ឯកិច្ចការដ៏
សំខាន់នៃក្សត្រលង្កាតៗ មក ក៏ប្រកាន់យកការឧបត្ថម្ភទុំទុកបំរុង ព្រះ
ពុទ្ធសាសនាជាសំខាន់ ហើយការដំកើងកិត្តិយសរបស់ទ្រង់គឺការកសាង
វិហារសាលា ពុទ្ធចេតិយ ជាពុទ្ធបូជា ព្រះមហាក្សត្រអង្គណាទ្រង់
កសាងទុកបានច្រើន ក៏មានកិត្តិយសច្រើន ហេតុនេះហើយបានជាមាន
បុពណវត្ថុសំខាន់របស់ព្រះពុទ្ធសាសនា សឹងបានសម្រេចដោយតែជា-
នុភាពរបស់ព្រះមហាក្សត្រលង្កាជាច្រើន ដូចព្រះបាទអភយទុស្ត ទ្រង់
កសាងលោហៈប្រាសាទខ្លឹង គាលពីពុទ្ធសករាជ ៤២៩ ព្រះបាទ
វដ្ដគាមនី ទ្រង់គ្រងរាជ្យក្នុងរវាងពីពុទ្ធសករាជ ៤៥៥ ដល់ពុទ្ធសករាជ
៥០៣ ទ្រង់បានកសាងវត្តអភយគិរី ។ អំណើះគាលតមក ទើប
លទ្ធិមហាយាន ឃានកើតនឹងចំរើនខ្លឹងយ៉ាងវិសេសក្នុងប្រទេសឥណ្ឌា

ខាងដើម ហើយផ្សាយចូលទៅរហូតដល់ស្រុកចិនផង ។ ព្រះពុទ្ធ-
សាសនាក្នុងគោរលង្កានេះ រកតាល់ចន៍បែកខ្ញែកចេញជា ២ ពួក ១ ពួក
គឺពួកអភយគិរិវិហារ ដែលមានយោបល់យល់ថា គួរធ្វើតាមបែបមហា-
យាន តែ ១ ពួកទៀត គឺពួកមហាវិហារយល់ថា គួររក្សាបែបផែនលទ្ធិ
ហីនយានយ៉ាងម៉ឺងម៉ាត់ ។ ទាំង ២ គណៈនេះ ទៅជាកើតជាដៃគូ
គាស់ចែងគ្នាក្នុងវង់គណៈសង្ឃទាំង ២ ពួក ។

ដោយហេតុគោរលង្កាតាំងពីដើមមក មិនដែលធ្លើការខាត់ឆនទឹង
ការផែនដី ឬការរាជការនឹងប្រទេសឯណៀ ព្រះចៅផែនដីរាជវង្ស
ជំបូង ។ ទើបមានឧកាសរវល់តែកិច្ចការក្នុងព្រះពុទ្ធសាសនាតែម្យ៉ាង
ច្បាប់សម្រាប់ស្រុកទេសដែល ព្រះមហាក្សត្រ ឲ្យតែ ឲ្យរៀបចំឡើង ក៏
ព្យាយាមធ្វើតាមច្បាប់សីលធម៌របស់ព្រះពុទ្ធសាសនាគ្រប់យ៉ាង ដូចព្រះ
ឋានអមន្តតាមនិទ្ទេសចេញព្រះរាជប្រកាសហាម មិនឲ្យសម្លាប់សត្វគ្រប់
ចំពួកក្នុងគោរទាំងមូល តែច្បាប់នេះមិនឋានស្ថិតស្ថេរប៉ុន្មានទេ ការ
អស់បុណ្យក្សត្រនេះក៏លើកលែងប្រើទៀ ។ ក្នុងសម័យដែលប្រទេស
ឯណៀកើតចលាចលវឹកវឹក ដោយការលុកលុយចូលមកនៃជនជាតិ
ប្រទេសក្រៅនោះ ពួកពុទ្ធសាសនិកជនក៏ឋានអាស្រ័យធ្វេកគោនគោរ
លង្កានេះឯងជាម្ចប់ ។ ក្នុងចំពួកពុទ្ធសាសនិកជនដែលចូលមកជ្រកម្ចប់
នៅក្នុងគោរលង្កានោះ មានព្រះថេរៈសំខាន់ ១ អង្គឈ្មោះពុទ្ធឃោសាចារ្យ

ការលើមខ្សែយទៅដែនមគធៈ ហើយចូលមកដល់ភោះលង្កា ការណ៍ពុទ្ធសករាជ ๙๖๓ កន្លងមកក្នុងសម័យព្រះបាទមហានាមគ្រងក្រុងលង្កា ។ ព្រះពុទ្ធឃោសាចារ្យសំណាក់នៅក្នុងមហាវិហារបានតែងគម្ពីរខុទ្ទកក្នុងព្រះពុទ្ធសាសនាជាច្រើន មានគម្ពីរយ៉ាងវិសេសមួយដែលជាស្នាដៃរបស់លោកគឺគម្ពីរវិសុទ្ធិមគ្គ ។ ព្រះពុទ្ធឃោសាចារ្យចេញពីភោះលង្កាតាំងអំពីពុទ្ធសករាជប៉ុន្មានមិនច្បាស់ជា គ្រាន់តែមានសេចក្តីដំណាលថា ចេញពីភោះលង្កាទៅប្រទេសភូមា ហើយតាំងអំពីនោះមក ភិក្ខុទៅភោះលង្កាតែងនាំយកប្រស័យគ្នាខឹងភិក្ខុទៅប្រទេសភូមា, មន ខឹងសៀម ។ លង្កាជាទីដល់ព្រះពុទ្ធសាសនាយ៉ាងមាំមួន តាមន័យដែលគោលមកនេះសាគារបស់ភោះលង្កាជាទីស្ងប់ស្ងាត់ សមជាទីស្នាក់នៃអ្នកសន្តោស, អ្នកតែងនឹងអ្នកគិត ។

តែការប្រណាំងប្រជែង-ចាស់ទៃង្គារវាងគណៈអភយគិរី និងគណៈមហាវិហារតែងតែមានជានិច្ច ។ លុះតមកដល់ពួកទមិឡមានអំណាចឡើង ភោះលង្កាក៏ត្រូវពួកទមិឡអ្នកស្រុកការនៅតចូលលុកលុយមុនពួកជាដៃទៀត ហើយដោយហេតុពួកទមិឡគាន់សាសនាជេនិស្ម័ខ្លះហិណ្ឌូខ្លះ តែមិនបានគាន់ព្រះពុទ្ធសាសនាទេ ការណ៍ចាំងលុកមកដល់ភោះលង្កាហើយ ទើបធ្វើឲ្យបាចដល់ពុទ្ធសាសនិកជនជាខ្លាំង ហើយបំផ្លាញកំរែចថាវរតអស់ជាច្រើន ។ កន្លងពុទ្ធសករាជ ๑๘๙๐ ភោះ

លង្កាក៏ត្រូវពួកបន្ទុយ:នៃស្រុកមន្ទុរ:ចូលមកលុកលុយទៀត តមកក្នុង
រវាងពុទ្ធសករាជ ១៥៤៨ ត្រូវក្សត្រគោល:ព្រះនាមពាជ:រាជ ចូលមក
លុកលុយដល់គោះលង្កាទៀត កាលគោះលង្កាត្រូវសត្រូវខាងក្រៅចូល
មកលុកលុយដូច្នោះ កិច្ចការព្រះសាសនាខាងក្នុងស្រុកក៏ត្រឡប់ជារួប
រួមមូលគ្នាវិញ ហើយសម្តេចព្រមព្រៀងគ្នាថា ត្រូវឲ្យពួកមហាវិហារ
ធ្វើជាធំ ទើបលទ្ធិហីនយានមានសេចក្តីខ្ជាប់ខ្ជួនល្អ អ្នកដែលអាចធ្វើឲ្យ
គួរឲ្យរួបរួមគ្នាបាននោះ គឺព្រះចាន្ទបរក្រមពាហុទី ១ ដែលទ្រង់ចាន
គ្រងរាជ្យតាំងអំពីពុទ្ធសករាជ ១៦៤៦ ដល់ពុទ្ធសករាជ ១៧២៧ ទ្រង់
ចានឲ្យប្រជុំសង្ឃនៅស្រុកអនុរាធបុរៈ កាលពីពុទ្ធសករាជ ១៧០៤ ហើយ
ទ្រង់ប្រកាសឲ្យលើកលែងជំនែងរវាងគ្នាគ្នាទៀត ទ្រង់ប្រកាសឲ្យមាន
សាមគ្គីរួបរួមគ្នា ហើយត្រូវប្រតិបត្តិតាមលទ្ធិហីនយានយ៉ាងម៉ឺងម៉ាត់ ។
ព្រះចាន្ទបរក្រមពាហុនេះ ទ្រង់ព្រះកិត្តិគុណថា ទ្រង់ជាព្រះមហា-
ក្សត្រដែលមានព្រះទ័យជាកុសលបំផុត ទ្រង់ចានកសាងមន្ទីរពេទ្យជា
ច្រើនអន្លើ ហើយទ្រង់ធ្លាប់ក្សាជម្ងឺដោយព្រះអង្គឯងក៏មាន ទ្រង់កសាង
ស្តូបចេតិយ វិហារ, សាលា សុទ្ធតែជាលំនៅរបស់សង្ឃពាប់ដោយ
តានរូប ។

លុះមកដល់ព្រះពុទ្ធសករាជ ១៧៧៣ ទើបគោះលង្កាត្រូវពួកចោរ
ហិណ្ឌូចូលមកលុកលុយញាំញីក្នុងគ្រាវិបត្តិនេះ ពួកពុទ្ធសាសនិកជនទាំង

ថាវាវត្តកង់ព្រះពុទ្ធសាសនា ត្រូវទំលាយបំផ្លាញអស់ទៅជាច្រើន ។ កាលពួកចោរសម្លុតចេញផុតទៅហើយ ទើបព្រះបាទរ៉ាជ័យតាហុតង់ឲ្យជួសជុលថាវាវត្តដែលបាក់បែកទៅឡើងវិញ ក្នុងព្រះពុទ្ធសកាជ ๑๗๙๓ ។ ទៅគ្រានេះ ខ្មែរឲ្យចាត់ការកសាងវិហារយ៉ាងធំឡើងទៅស្រុកគង្គ័ សម្រាប់ជាទីបញ្ចុះព្រះទាបជាតុរបស់ព្រះពុទ្ធជាម្ចាស់ដរាបមកដល់សម័យសព្វថ្ងៃនេះ ។ ព្រះរាជនរសរបស់ព្រះបាទរ៉ាជ័យ-តាហុ ខ្មែរព្រះនាមព្រះបាទបរកែមតាហុទី ๓ ដែលខ្មែរបានគ្រងរាជ្យរហូតមកដល់ព្រះពុទ្ធសកាជ ๑๘๔๘ នេះក៏ជាព្រះរាជវង្សដ៏សំខាន់ ๑ អង្គដែរ ក្នុងប្រវត្តិសាស្ត្រប្រទេសលង្កា គាំងចំណែកខាងស្រុកទេស គាំងចំណែកខាងសាសនា ខ្មែរបានចាត់ការកសាងស្រុក ស្រែវាល្បានបុរៈឡើងសាងស្ពាន, សាងធនាគារឡើងជាច្រើន ហើយមានសេចក្តីដំណាលថាខ្មែរជាមហាក្សត្រដែលសព្វព្រះទ័យនឹងបុណ្យកុសលជាបំផុតរបស់លង្កា ខ្មែរបានឲ្យលើកលែងប្រើប្រាស់ប្រហារដ៏រឹតចេញ ។ កាលព្រះបាទបរកែមតាហុទី ๓ សោយទិវង្គតទៅហើយ ក្នុងពុទ្ធសកាជ ๑๘๕๗ គោះលង្កាក៏ត្រូវពួកទមិឡអ្នកស្រុកការខ្មែរចូលមកលុកលុយទៀត ក្នុងគ្រានេះឯង គោះលង្កាក៏ធ្លាក់ទៅទៀតក្នុងអំណាចរបស់ពួកទមិឡពេញបន្ទុក ។ ពួកទមិឡមានអំណាចគ្រប់គ្រងនៅគាគខាងដើងរបស់គោះនេះទាំងអស់ ចំណែកពួកសីហឡ (អ្នកស្រុកលង្កា) គោងថយទៅ

នៅខាងត្បូង សេចក្តីចំរើនរបស់គោសិង្គកំរៀវរោយតាំងអំពីនោះមក ថាវាវត្តយ៉ាងល្អ ។ ក៏ឃ្លាតបែកខ្ចប់ខ្ចាតអន្តរាយទៅជាច្រៃបន្តិចម្តង ។ តែនៅមានបុព្វណវត្តខ្លះនៅគង់ខ្ជាល្អមិនអន្តរាយទៅ គឺព្រះមហាពោធិព្រឹក្ស ដែលបានផ្លាំមែកមកដាំនោះ មានអាយុជាង ២០០០ ឆ្នាំហើយ. នៅមានមែកសាខាត្រឈឹងត្រឈៃជាអនុស្សាវរីយ៍ សម្រាប់ដឹកនាំចិត្តរបស់ពុទ្ធសាសនិកជនឲ្យកើតសេចក្តីជ្រះថ្លាវហូតមកដល់សព្វថ្ងៃនេះ ។

ចប់ប្រវត្តិសាស្ត្រប្រទេសតង្កៀ ដោយសង្ខេបតែប៉ុណ្ណេះ ✓

រឿងសាមគុក

អ្នកឧកញ៉ាវិបុលកាជសេនា ខ្វូ-កន ប្រែរៀបរៀង

(ភាគ៣)

ឯពួកអ្នកធ្វើឃាតក្នុងដើមគ្រាន កំពុងនិយាយគ្នាថាយើងនឹងចងមុខ ឬសម្លាប់តែម្តងទៅ ចូត្ងូបានឮដូច្នោះក៏ដឹងសក្នុងចិត្តទើបឡើបសួរគាន់កុងថា ប៉ែះធៀ នេះគេគ្រាន់តែជាកើនដឹងប៉ិតាខ្ញុំ តុំមែនជាញាតិសាច់អ្វីសោះ ប្រហែលគេចេញទៅឃាប់មេស្រុកដំរបស់ក្នាក់ងារឃុំឲ្យមកចាប់យើងទេដឹង ទើបគេបង្គាប់ខុកឲ្យមនុស្សក្នុងចូរចាចងមុខឬសម្លាប់តែម្តងដូច្នោះ គាន់កុងថាខ្ញុំមិនគាចដឹង ព្រោះមិនបានស្គាល់ចិត្តប៉ែះធៀ នោះសោះ ចូត្ងូថាបើដូច្នោះយើងនឹងខុកចិត្តម្តេចបាន ថាហើយក៏ហូតគ្រប៉ដើរចូលទៅក្នុងផ្ទះ គាប់តាំយាបុត្រនឹមមនុស្សម្នា ប៉ែះធៀស្ងាប់អស់៨នាក់ ។ គាន់កុងឆាកទៅម្ខាងឃើញដែកគេចងខុកក្នុងចំណង ក៏ស្ទុតចិត្តគិតថាគេចងដែកខុកនឹងសម្លាប់ធ្វេរទេ ហេតុម្តេចអ្នកសម្លាប់បុត្រតាំយាប៉ែះធៀអស់ដូច្នេះខុសណាស់ ។ ចូត្ងូក៏ហួសចិត្តគិតនឹកឋាម្តងខ្លាចមិនគាចបង្ក្រឹងទៅលើផ្ទះនោះ ក៏នាំគាន់កុងចុះពីលើផ្ទះដំរសេះបរប្រញាប់ទៅ លុះទៅបានប្រមាណ ២០ សិន (៨០០ម៉ែត្រ) ទន្លួលដួបនឹងប៉ែះធៀ។ សួរថា ហេតុម្តេចក្រយមិនទៅតិសាឋាយសិនប្រញាប់ទៅណា ។ ចូត្ងូឆ្លើយថាខ្ញុំបានជាមនុស្សខុសហើយ នឹងស្រួត

ទៅឲ្យផុតរួចអំពីភ័យអន្តរាយ មាត់តែនិយាយសេះតែបរលឿនទៅត្រ-
លប់គិតបត់សេះមកគ្រោយវិញហៅថា មាឈប់សិនខ្ញុំផ្តាំពាក្យ ១
មាត់ទុក បែរឆៀកឈប់ ។ ចូឆូបរសេះទៅដល់ទន្លឹមកំហូតគ្រប់កាប់
បែរឆៀស្ទាប់នៅទីនោះទៀត គាន់កុងយើញដូច្នោះក៏តែតែស្ទុតចិត្តគិត
ហើយនិយាយនឹងចូឆូថា កាលអម្បាញ់មិញនេះអ្នកសម្លាប់បុត្រកំយា
នឹងមនុស្សម្នារបស់បែរឆៀស្ទាប់អស់ទៅហើយ ឥឡូវនេះ ហេតុម្តេច
មកសម្លាប់បែរឆៀទៀត ។ ចូឆូឆ្លើយថាកាលអម្បាញ់មិញ យើង
គិតច្រណែនសហូសខ្លួនទៅហើយ បើទឹងទុកបែរឆៀឲ្យនៅរស់នោះមុខជា
នឹងទៅប្តឹងមេស្រុកឯងចាប់ភ្នាក់ងារឃុំ ឲ្យរើតគ្នាមកតាមចាប់យើង
មិនខាន ហេតុនេះហើយយើងត្រូវតែសម្លាប់បែរឆៀចេញ ដើប
សូន្យផុតរលត់ដំណឹងនេះមិនមានមកដល់យើង ។ គាន់កុងឆ្លើយថា អ្នក
គ្មានសេចក្តីគិតសោះប្រញាប់ទៅសម្លាប់គេតតុស បើដឹងថាខ្លួនខុស
ហើយ មកថែមសម្លាប់គេទៀតដូច្នេះជាមនុស្សអកតញ្ញូមិនល្អទេ ។
ចូឆូថាអ្នកនិយាយនេះក៏ត្រូវហើយ តែចាន់ម្ចាស៊ើតមកជាមនុស្សត្រែងនឹង
ស្រឡាញ់រក្សាខ្លួនឲ្យបានសេចក្តីសុខ មិនត្រូវឲ្យអ្នកដទៃប្រទុស្សាយ
បាន ។ ជាខ្ញុំឆ្លើដូច្នេះ និយាយហើយក៏នាំគ្នាបរសេះទៅដល់ទីតំណាក់មួយ
ក៏នាំគ្នាចូលទៅសំណាក់ដេកនៅទីនោះ កាលចូឆូដេកលក់ស៊ប់ គាន់-
កុងក៏គ្រោកអង្គុយរំពឹងគិតថា ខ្លួនអញហៅពេញចោលម្បាត់ណាស់

តាំងចិត្តកាត់លះបុណ្យសក្តិទ្រព្យសម្បត្តិចេញ ព្រោះស្រឡាញ់រាប់អានបូតូ ដោយស្មានថាមនុស្សនេះល្អពិតត្រូវប្រាកដនឹងបានសន្តុយកគ្នាជាចិត្តគំនិតមួយ ដួយទុបត្ថម្ភទំនុកបំរុងគ្នាតទៅ តតដឹងថាបូតូជាមនុស្សអាក្រក់ដូជាតិសាមាន្យ គ្មានសេចក្តីកតញ្ញូដល់អ្នកមានគុណបកាវះសោះ បើដូច្នោះអញនឹងស្តែសមាគមរួមចិត្តគំនិតជាមួយតទៅឃើញថាពុំបាន គួរតែនឹងសម្ងាប់ចោលចេញកុំឲ្យមានភ័យជាម្តងតទៅ គិតហើយក៏ហូតគ្រឹបចេញមកនឹងសម្ងាប់បូតូក៏ឲយទៅគិតវិញថាហេតុទាំងនេះមិនពីព្រោះនរណា ព្រោះតែខ្លួនអញត្រូវចិត្តគំនិតនឹងគេមកពីដំបូងបានជាតាមគេមក បើបូតូធ្វើខុសនឹងសម្ងាប់ចេញក៏មិនមានផ្លូវចំណេញអ្វីមកពីអញ បើមិនគប់ចិត្តស្រឡាញ់ត្រូវតែតេយកខ្លួនឲ្យរួចទៅជាជាង គិតហើយតាន់កុងក៏ក្រោកភ្ញាមចរសេះដើរបាំងយប់ទៅនៅស្រុកតាំងកុង ។

បូតូលុះភ្ញាក់ពីដេកក្រឡេកទៅមិនឃើញតាន់កុង ក៏គិតថាតាន់កុងយើញធ្វើខុសទើបដោះខ្លួនរត់ចោលអញដូច្នេះ បើរកញនឹងទៅកុងទីនេះក៏នឹងមិនរួចអំពីភ័យ គិតហើយក៏ក្រោកឡើងចរសេះដើរទៅបាំងយប់នោះលុះដល់ស្រុកតាន់លីវ ក៏ចូលទៅរកចោកោជាបិតា ពុណ្ណនាវឿងរ៉ាវប្រាប់សព្វគ្រប់ប្រការ ហើយថាដែលខ្ញុំរត់មកនេះប្រាថ្នានឹងសុំមាសប្រាក់របស់បិតាយកទៅទិញសេះនឹងគ្រឿងសស្ត្រាវុធ ដើម្បីបញ្ចុះបញ្ចូល

មនុស្សឲ្យបានជាពួកម៉ាកច្រើន ហើយនឹងធ្វើការយកតាសាផែនដីតទៅ
ទោះគេធ្វើយថាទ្រព្យសម្បត្តិយើងមានខ្លះដែរ តែមិនគួននឹងបាត់ការបាន
កូនស្រុកនេះ យើងឃើញមនុស្សម្នាក់ឈ្មោះអ៊ុយហង៍មានទ្រព្យសម្បត្តិ
ច្រើនណាស់ចិត្តក៏ធូរធូលាយហើយត្រង់នឹងផែនដី បើកូនយកហេតុនេះ
ទៅប្រាប់ដល់គេៗក៏ដួយទំនុកបំរុងខ្លះមិនខាន កូនក៏មុខជានឹងបានពិញ
សេះនឹងគ្រឿងសស្ត្រាវុធតាមប្រាថ្នា ។

ចូតូបានឮដំណឹងបិតាឲ្យដូច្នោះក៏អរណាស់ ទើបបង្គាប់ឲ្យរៀបចំ-
ណីអាហារ ហើយឲ្យទៅអញ្ជើញអ៊ុយហង៍មកពីសាច្បាយ ចូតូក៏និយាយ
ប្រាប់រឿងឲ្យអ៊ុយហង៍ស្តាប់សេចក្តីថា សព្វថ្ងៃនេះតាំងគុ:ខុទ្ទរិតគិតធ្វើការ
ពុតការជាលាមកអាក្រក់គឺសត្រូវនឹងផែនដីខ្លាំងណាស់ ខ្ញុំបានឈឺចិត្ត
គិតទំនូរស្វែងមកទាំងម្ល៉េះនេះ ពីព្រោះតែប្រាថ្នានឹងយកតាសាផែនដី
ប្រយោជន៍ដើម្បីនឹងរំលាយបំផ្លាញតាំងគុ:នោះចេញ តែថាកំឡាំង
ទ្រព្យសម្បត្តិរបស់ខ្ញុំមានតិចណាស់ ទើបគេសុខមកកេងប្រាយនឹង
បញ្ចុះបញ្ចូលពួកម៉ាកឲ្យបានច្រើន ហើយនឹងលើកជាគង់វត្តត្រឡប់ចូល
ទៅច្បាំងនឹងតាំងគុ: បើខុតជាយ៉ាងណាក៏ត្រូវសម្លាប់ឲ្យបាន តទៀវ
ខ្ញុំបានឮដំណឹងថា លោកមានទ្រព្យសម្បត្តិជាច្រើន មានតាំង
សន្ធានចិត្តសុចរិតត្រង់នឹងផែនដី ខ្ញុំបាននឹងសុំខ្ចីប្រាក់លោកយកទៅ
ទិញគ្រឿងប្រដាប់ចម្បាំង គឺសេះនឹងគ្រឿងសស្ត្រាវុធនានានឹងបាន
ធ្វើការតទៅ ។

អ៊ុយហាង់ឃ្នាន់ស្តាប់ក៏ចាប់ចិត្តត្រែកអរណាស់ថា តាំងតាំងខ្ញុំបានភ្ជុំដំណឹងថាស្រុកគ្រួងកើតចលាចល ក៏មានតែសេចក្តីភ្ញាយខ្លាំងនឹងចង់ទុកបំរុងផែនដី តែគ្មានឧណាមកប្រាប្តប្រាប់សេចក្តីឲ្យចូលចិត្តសោះ ឥឡូវបានអ្នកមកបំភ្លឺឲ្យខ្ញុំយល់ នោះខ្ញុំមានសេចក្តីត្រែកអរណាស់ ទ្រព្យសម្បត្តិរបស់ខ្ញុំមានមិនខ្លះ ខ្ញុំអាចំហានប្រគល់ឲ្យអ្នកចាត់ចែងតាមត្រូវការ ។

ចូតូមានសេចក្តីត្រែកអរណាស់ ទើបធ្វើទង់ជ័យសមួយបន្ទះ ហើយសរសេរអក្សរកណ្តាលទង់ថា ឲ្យមនុស្សគ្រាំងតូងមានចិត្តសុចរិតទៀងត្រង់នឹងផែនដី ហើយដោតទង់នោះនៅចំពោះមុខផ្ទះ បណ្តាអ្នកស្រុកទាំងតូង ដល់ឃ្នាន់ឃើញទង់នឹងអក្សរដូច្នោះ ក៏នាំគ្នាចូលមកនៅជាពួកក្រមចូតូច្រើនណាស់ ចូតូក៏ចេះតែបញ្ចុះបញ្ចូលជាមនុស្សចុះចូលជាច្រើន ។

គ្រានោះមានឈ្មោះហៃហ៊ុនជាបង ហៃហ៊ុអៀនជាប្អូនទៅស្រុកថៃកុក ឯហៃហ៊ុនោះកាលពីអាយុ ១៤ ឆ្នាំ ទៅរៀនចំណេះវាហានក្នុងសំណាក់គ្រូ ១ មានកូនសិស្សម្នាក់មាក់ងាយគ្រូ ហៃហ៊ុនខឹងក៏សម្លាប់ឈ្មោះនោះស្លាប់ ហើយរត់ទៅនៅបុងស្រុក លុះដឹងដំណឹងថាចូតូឲ្យបញ្ចុះបញ្ចូលមនុស្សផាកងទ័ពដូច្នោះ ក៏បញ្ចុះបញ្ចូលពួកក្រមបានមួយពាន់ផ្ទាយ ហើយនាំហៃហ៊ុអៀនជាប្អូនទៅនៅជាពួកចូតូ ។

ឯចោរយិនទឹងចោរហង់បងប្អូន ២ នាក់ កំនាំពួកពលចំនួន១យពាន់ ផ្ទាយទៅជាមួយនឹងងាកដីនទៅស្រុកយុងបេង លិះគៀនទៅស្រុកសាន យុងទាំងអស់គ្នា ក៏ចូលទៅនៅជាមួយនឹងចូឆូ គ្រានោះអ៊ុយហង់ឃើញ បណ្តាអ្នកស្រុកនាំពួកម៉ាកទៅនៅនឹងចូឆូជាច្រើនដូច្នោះ ក៏មានសេចក្តី ត្រេកអរណាស់ ទើបយកមាសប្រាក់ទៅឲ្យចូឆូវិញ សេះនឹងគ្រឿង សស្ត្រាវុធសម្រាប់ការសង្គ្រាមចំរើនឡើងរាល់ ៗ ថ្ងៃ បណ្តាអ្នកស្រុក ទាំងប្រុស ស្រីក៏បបួលគ្នានាំយកសេះនឹងគ្រឿងការុងនូវស្រែអង្ករស្បៀង អាហារទៅឲ្យចូឆូជាច្រើន ឯចូឆូក៏រឹងរឹតតែមានសេចក្តីត្រេកអរសប្បាយ រីករាយឡើង ទើបឲ្យសង់រោងសម្រាប់ជាទីប្រជុំឱ្យជការនឹងសេនាទាហាន ឲ្យបរិភោគយ៉ាងសប្បាយសង្គ្រាមតាមពេលព្រឹកល្ងាច បណ្តាសេនា ទាហាន សឹងមានគ្រប់ហ្វឹកហាត់នូវស្បៀតគុនការុងមុតមាំពុំមានខាន មួយថ្ងៃ ។

ឯអ្នកសៀវផ្លែលតាំងតុះល្បួងលួងលោមយកចិត្ត តាំងពុកជាទី ចៅហ្វាយស្រុកពុតលៃ លុះឮដំណឹងថា ចូឆូប្រមូលពួកគ្រុមបានច្រើន ក៏ប្រឹក្សានឹងគ្រុមការទាំងពួងថា យើងនឹងលើកពលទាហានទៅចូលទៅ ជាពួកចូឆូចុះ សេនាទាហានទាំងនោះក៏យើញត្រូវឯង ទើបអ្នកសៀវក៏ លើកកងយោធាទៅរួបរួមចូលជាពួកចូឆូ ៣ ម៉ឺនផ្ទាយ ឯចូឆូលុះឃើញ អ្នកសៀវលើកពលមកជាពួកកងដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់

ចេញមកប្រឹក្សានឹងអ្នកនៅស្រុកថា តទៅនេះ យើងប្រជុំគ្នាធ្វើការធំមាំមួន
ណាស់ ត្រូវតែធ្វើសំបុត្រព្រះតម្រាស់ប្រាប់ទៅគ្រប់ខែត្រទាំងអស់ ជា
សេចក្តីបញ្ជុះបញ្ចូលឲ្យមូលមកបួមបួមនឹងយើងទើបស្រួល អ្នកនៅស្រុកយល់
ព្រមក៏តែងជាសំបុត្រព្រះតម្រាស់ព្រះចៅហ្លួងតេ សេចក្តីថាឲ្យនំគ្រាស់
ប្រើបុគ្គលឲ្យលបចេញមកប្រកាស អស់បណ្តាចៅហ្វាយខែត្រទាំងក្នុងព្រះ
រាជអាណាចក្រ ចូរឲ្យប្រាន់ដឹងគ្រប់គ្នា ដ្បិតសព្វថ្ងៃនេះ បណ្តាខាហ្លួនតូច
ធំនឹងអាណាប្រជាខុកស្តុកឯព្រះនគរ មានសេចក្តីក្តៅក្រហាយណាស់
ព្រោះតាំងតុជាសត្រូវរាជសម្បត្តិក្បត់សម្លាប់ចាន់ជូតៀន ដែលជាព្រះ
ជេដ្ឋាក្មួយព្រះជន្មទៀ ហើយលើកយើងឲ្យសោយរាជ្យជាម្ចាស់ផែនដី
បីដូចជាអ្នកតា តាំងខ្លួនក៏ជាមហាឧបរាជមានអំណាចកាន់កាប់មុខ
ងារាជការផែនដីស្រេចលើខ្លួនក៏តាំងអស់ មានតែចូធូជាមនុស្សត្រកូតញ៉ាំ ស៊ី
ប្លន់ដំរីតក្រៃពេក មានចិត្តទុហាតសង្ឃាត ចំធ្វើរាជការជាសុចរិត
ខ្លឹងត្រង់ប្រាកដ ប្រាន់សាប្រាសស្បថចំពោះព្រះតក្កថានឹងយកអាសា
រំលាងតាំងតុដែលជាសត្រូវរាជសម្បត្តិចេញឲ្យប្រាន់ជាធាប់ ។

ខណៈនោះចៅហ្វាយខែត្រទាំង ១៥ មណ្ឌលដែលជាធំគឺអ្នកស្រុក
ចៅហ្វាយស្រុកលាំយុង ១ ហ៊ានហុកចៅហ្វាយស្រុកគិរីវ ១ ខុងម៉ី
ចៅហ្វាយស្រុកសៀងជីវ ១ ខេវ៉ាតាយចៅហ្វាយស្រុកអ៊ីវជីវ ១ អង់ខង
ចៅហ្វាយស្រុកហោឡាយ ១ ខៀវមៅ ចៅហ្វាយស្រុកតាន់លីវ ១

តៀរហ៊ាចៅហ្វាយស្រុកតង់គុន ១ អួនអ៊ុយចៅហ្វាយស្រុកស៊ុនយុង ១ ចៅសិនចៅហ្វាយស្រុកចេប៉ាក ១ ខុនឡែនចៅហ្វាយស្រុកចា៉កវៃ ១ តៀរចៀរចៅហ្វាយស្រុកកង់ឡែង ១ គោកៀមចៅហ្វាយស្រុកឈីដារ ១ ម៉ាថេងចៅហ្វាយស្រុកសេលៀង ១ តៀរអៀងចៅហ្វាយស្រុកសៀង-គុង ១ ស៊ីនកៀនចៅហ្វាយស្រុកខៀងសា ១ ឋានទទួលសំបុត្រព្រះ-តម្រាស់ឋានដ៏ឆ្ងាស់សេចក្តីហើយ ក៏ឋានសេចក្តីត្រែកអពាំង់អស់គ្នា ទើបចាត់ការឃុំនាំពលយោធាខែត្រនិមួយ ៗ ខ្លះ ១ ម៉ឺន ខ្លះ ២ ម៉ឺន ខ្លះ ៣ ម៉ឺន លើកទៅបញ្ចូលជាមួយនឹងកង់ទ័ព បួនទ្ទួ រួមជា ១៦ ខែត្រនឹងអួនសៀវ បួនទ្ទួ ក៏លើកប្រមូលកង់ទ័ពទាំង់អស់នោះទៅដល់ព្រំដែនស្រុកឡុកអៀង ជាទីត្រុង ។

គ្រានោះ ឈ្មោះតង់ស៊ុនចាំនចៅហ្វាយស្រុកប៉ុកប៉ង់ឮដំណឹង់ថាមានព្រះតម្រាស់ដូច្នោះ ក៏ប្រមូលទាហានឋានមួយម៉ឺនប៉ាំពាន់លើកទៅដល់ខែត្រចេង់តួនគួន ដែលឡោតឈរកង្វា ឯឡៅពីដង់ថាកង់ស៊ុនចានលើកទាហានមក ក៏នាំគួនអ៊ូ តៀរហ៊ុយចេញទៅទទួលដល់ទ្វារស្រុកកង់ស៊ុនចានក៏ម៉ឺម៉ាគំនាប់ហើយសួរថា ដែលឋានមកជាមួយ ២ នាក់នោះឈ្មោះអ្វី មកនេះឋាថ្នាំនឹង់ទៅណា ? ឡៅពីឆ្លើយថានោះឈ្មោះគួនអ៊ូ នោះឈ្មោះតៀរហ៊ុយ ទាហានសេរបស់ខ្ញុំគាន់ឆ្លងសរ តឹជាឋ្លួនខ្ញុំទាំង ២ នាក់ឡាំង់ពូកែណាស់ ដែលអ្នកមានគុណបកការនឹង់ខ្ញុំពីដើមនោះខ្ញុំឮថា

អ្នកលើកវ័តមកផ្ទះនេះឲ្យនាងចេញមកទទួល ក្រាបថ្វាយនឹងអញ្ជើញអ្នកទៅ
ឈប់ស្នាក់សម្រាកកំឡាំងនាហានទៀ កងស៊ុនចានបានស្តាប់ក៏នឹកឃើញថាគួនអ៊ូតៀវប៊ុយ ហើយក៏ចូលទៅក្នុងស្រុកផេងខ្លួនគួន ទើបនិយាយនឹងទៀតពីថា គួនអ៊ូតៀវហ៊ុយនេះបានទៅជួយច្បាំងនឹងពួកចោរដួតក្បាលសឿងមានជ័យដែរ តែនឹងរកអ្នកឯណាជួយស្នើសុំសើរគុណបំណាច់ឲ្យគ្មានបានឆាខោងាហានទៀវដូច្នេះ លុះនិយាយហើយក៏អធិប្បាយពីព្រះតម្រាស់ដែលគ្រាស់ប្រើចូទូ ឲ្យចេញមកប្រកាសដល់បណ្តាខែត្រទាំងពួងឲ្យទៀតីស្តាប់ ហើយបង្គាលទៀតីថា សព្វថ្ងៃនេះអ្នកបានជាទីពេញហ្មាយស្រុកហើយ តែជាស្រុកតូចណាស់ ពេលនេះចូរអ្នកទៅជាមួយនឹងយើងចុះ បើសម្រេចការហើយ ខ្ញុំនឹងប្តូនអ្នកទាំង ២ នាក់ មិនលែងបានជាពេញហ្មាយស្រុកខែត្រឯកទេ ទៀតីមានសេចក្តីត្រេកអរណាស់ ក៏ស្រែះស្រួលទទួលតាក្យនឹងកងស៊ុនចាន តៀវហ៊ុយទ្វើយថា កាលទៅច្បាំងនឹងពួកចោរដួតក្បាលសឿងនោះ ខ្ញុំឃើញកិរិយាតាំងតុ: ជាមនុស្សអាក្រក់ មិនជាអ្នកស្គាល់ទោសនឹងគុណសោះ ខ្ញុំប្រុងនឹងសម្លាប់វាចេញ បងចេះតែឃាត់ខ្ញុំ បើកុំតែបងឃាត់ប្រហែលមិនមានរឿងធំដូច្នេះទេ គួនអ៊ូក៏ឃាត់តៀវហ៊ុយថា កុំឲ្យនិយាយថ្ងៃ ឥឡូវយើងបានទៅជាមួយនឹងកងស៊ុនចានហើយ គង់ឯងបានប្រទះគ្នាទៀតទេ ខ្ញុំអណាស់ទៀតីក៏ឲ្យរៀបចាត់ចែងនាហាន រើសយកតែមនុស្សណាដែលជាចំនុក

ខុសចិត្ត លុះរើសឃ្លានរួចស្រេចហើយ កងស៊ុនចានទឹងទៀតពី គួនអ៊ូ តៀវហ៊ុយ ក៏លើកកងទ័ពទៅដល់ប្រទល់ដែនទឹងក្រុងឡុកអៀង ។

ឯចូរូទឹងទៅហ្វាយខែត្តតាំងពួង ក៏ឲ្យតាំងបន្ទាយពាយកងទ័ពជាប់គ្នាជាលំដាប់ទៅ ផ្លូវនៅឆ្ងាយពីក្រុងប្រហែល ២០០សិន (៨ កិឡូម៉ែត្រ) ចូរូឲ្យរៀបកុតាំងលៀងគោដនាហារ បណ្តាទៅហ្វាយខែត្តតាំងអស់សឹងមកស៊ុលៀងព្រមគ្នា លុះបរិភោគរួចវេលាណា ក៏ចាត់ការទឹងឲ្យលើកតាហានចូលវាយស្រុកឡុកអៀង អង្វរឯនិយាយឡើងថា ឥឡូវនេះ យើងកាល់គ្នាសុទ្ធតែកត្តញ្ញូទឹងដែនដី ទើបនាំគ្នាចូលមកប្រជុំធ្វើការនេះ យើងមិនមានតាំងអ្នកឯណាឲ្យកាន់អាជ្ញាសិទ្ធិជាធំទឹងបង្កាប់បញ្ជានាយកងនាយពលសោះ បើដូច្នេះយើញថា ទឹងលើកចូលទៅវាយនោះនោមិនខានជ្រានេះ ចូរូជ្រានស្តាប់ក៏ថាប់ចិត្តគិតយើញត្រូវ ទើបនិយាយប្រកាសថា . អ្នកសៀវៈនោះធាមនុស្សមានតួដតង្ហាវង្វែងត្រកូលធានាហ្មឺនរៀងមកដល់ ៤ គ ៥ តេហើយ គួរទឹងលើកឲ្យធ្វើជាមេទ័ពធំកាន់អាជ្ញាសិទ្ធិបង្កាប់បញ្ជានាយកងនាយទ័ពតាំងពួង តើអ្នកតាំងអស់យល់យើញដូចម្តេច ? (មន្ត្រីខែត្តតាំងអស់ក៏ជានឧលយល់ព្រម) តែអ្នកសៀវៈបរធាមិនឧលតំណែងនេះ ទៅហ្វាយខែត្តតាំងអស់ទាស់អធ្យាស្រ័យគ្នាថា បើអ្នកសៀវមិនព្រមឧលធ្វើជាមេទ័ពធំទេ រយើញចានឹងវើសរកតទៅទៀតមិនជានេះ បើដូច្នេះតើទឹងត្រូវធ្វើដូចម្តេច ? ឯអ្នកសៀវ

យើញថាមិនស្រួល ក៏ព្រមទទួលធ្វើជាមេទ័ពធំក្នុងពេលនោះ ចូធូក៏ឲ្យ
សន់ពេងធំ ១ សម្រាប់អួនសៀវចេញនិយាយការពាក់ព័ន្ធការក្នុងបន្ទាយ លុះ
ឆលៃថ្ងៃមានឫក្សជោគដ៏ឃ្លាតដ៏ឃ្លាតល្អ ក៏អញ្ជើញអួនសៀវឲ្យឡើងអង្គុយលើតំណ
សមគួរ ហើយចូធូនឹងចៅហ្វាយខែត្រទាំង ១៧ មណ្ឌល ក៏ដំកល់គ្រឿង
សក្ការៈអុចខៀនជូបបួងសួងខៅតាអាកែ្សងឹកទឹកពិកទូសច្បា សន្មតថានឹង
តាំងចិត្តជាសុចរិតខៀងត្រង់នឹងផែនដីតទៅ ចូធូទើបចាត់ស្រាគំនាប់
ចៅហ្វាយខែត្រទាំងពួង ផឹកហើយក៏និយាយថា យើងនឹងធ្វើសង្គ្រាមធំ
គ្រានេះ មិនត្រូវបែកចិត្តគ្នាឲ្យខូចការដេ ចូរមានចិត្តជាពិតត្រង់នឹងគ្នា
ទើបធ្វើការនោះនឹងបានសម្រេចដោយស្រួលដាយ ។

អួនសៀវធ្វើយថា តម្រេះប្រាជ្ញាយើងក៏នៅជាប្រមាណ ដែលអ្នក
ទាំងអស់ស្រុះចិត្តគ្នាលើកឲ្យយើងធ្វើជាមេទ័ពធំនោះ យើងក៏ត្រូវធ្វើតាម
អាជ្ញាសិទ្ធិនឹងទំនៀមច្បាប់ពិដ័យសង្គ្រាម បើអ្នកឯណាមានគុណគាប់ប្រ-
សប់ធ្វើការ យើងក៏ត្រូវឲ្យបំណាច់ផ្ងាន់ទាន់ចិត្ត បើអ្នកឯណាខុចិត
ប្រព្រឹត្តខុស យើងក៏ត្រូវចុះទោសតាមច្បាប់អយ្យការសឹក អ្នកទាំងអស់
គ្នាបានស្តាប់ហើយកុំបីតូចចិត្តនឹងយើងឡើយ ចូធូនឹងចៅហ្វាយខែត្រទាំង
១៧ មណ្ឌលក៏ទទួលយល់ព្រម អួនសៀវទើបចាត់ឲ្យអួនស៊ុតជាប្អូន
ធ្វើមេទ័ពណូនសម្រាប់បញ្ជូនស្បៀងអាហារកុំឲ្យដាច់ ចាត់ស៊ុនគៀន
មេទ័ពមុខលើកទាហានចេញទៅឃុតយកស៊ុយគួន ស៊ុនកៀនក៏លើក
ទាហានទៅតាំងបន្ទាយជាប់នឹងគយនោះ ។

ឯនាយគយ លុះឃើញដូច្នោះ ក៏ធ្វើសំបុត្របង្គាប់ឲ្យបំរើសេះនាំចូលទៅ
ប្តឹងដល់ស្រុកក្រុង លុយចុងដងការ ក៏នាំសេចក្តីនោះទៅដាក់តាំងគុ្ង
ស្តុកចិត្តគិតភ័យណាស់ ទើបប្រឹក្សាទឹងលុយថា គ្រានេះ ទឹងបាន
ម្ចាស់ឯណាយកគាស់ ចេញទៅតតាំងច្បាំងចាប់យកស៊ុនកៀន ឲ្យ
បាន លុយប៉ោនឆ្លើយថា ដែលទៅហ្វាយខែត្រលើកពលចូលមកតាំងនេះ
ប្រៀបដូចមកមាច ខ្ញុំបានទឹងសូមយកគាស់លើកកងទ័ពចេញទៅសម្លាប់
ឲ្យបាន លោកកុំបីមានចិត្តគិតព្រួយបារម្ភឡើយ តាំងគុះបានស្តាប់ដូច្នោះ
ហើយ ក៏អស់រីតក្តីរីកមុខរោះរាយ ទើបនិយាយថា សព្វថ្ងៃនេះយើងបាន
លុយប៉ោមកនុកដាប់ត្រចិញ្ចើម ក៏ខឹកសង្ឃឹមថា បើទឹងបានគាហានដៃជាប់-
ម្ខាង ក៏មិនគួរស្មើទឹងមនុស្សម្នាក់នេះឡើយ ខណៈនោះមានគាហានម្នាក់
ឈ្មោះហួយង ទ្រង់ទ្រាយដូចខ្លាកំពស់ ៦ ហត្ថក្បាយ លុះបានឮលុយប៉ោអួត
ខ្លាយដូច្នោះ ក៏លុតជង្គង់សំពះតាំងគុះហើយថា ដែលទឹងសម្លាប់មាន
មិនត្រូវទៅគាន់តាំបិតដែលសម្លាប់គេយកទៅសម្លាប់មានទេ តាវគ្រា
នេះ គ្រាន់តែគ្រឹមទៅហ្វាយខែត្រតាំងពួនលើកទ័ពមកប៉ុណ្ណោះ មិនបាច់
ទឹងឲ្យលុយប៉ោឯាបុត្រលោកលើកពលទៅតាំងច្បាំងឲ្យលំបាកទេ តែគ្រឹមខ្ញុំ
បានក៏សូមយកគាស់ចេញទៅតាត់ក្បាលទៅហ្វាយខែត្រតាំងអស់មកដួង
លោកបានហើយ តាំងគុះបានស្តាប់ក៏ពេញចិត្តណាស់ ទើបឲ្យហួយង
ទៅទឹងទីឯានាយគាហានធំ ហើយចាត់គាហានឲ្យហួយង ៥ ម៉ឺនចេញទៅ

ជាមួយនឹងលីសុក ១ ហោជំនួន ១ តៀរធំមួ ១ តាំង ៤ នាយលើកចេញទៅ
ឯហួយុនឱនាយតាហានតាំង ៣ លើកតាលតាំងប្រាំមុខស្រែតរួតចេញ
ទៅតាំងបន្ទាយទៅតយកស៊ីយភ្លុន ។

ខណៈពោះចៅស៊ុន ដែលទៅក្នុងវត្តភ្លុនសៀវ គឺតចាស៊ុនកៀន
ជាមេទ័ពមុខលើកតលទៅកាយបន្ទាយកស៊ីយភ្លុនពោះ បើឃ្លានការ កំមាន
សេចក្តីគាប់ប្រសើរដែលស៊ុនគៀនម្នាក់ឯង ទើបចាត់ចែងឲ្យចៅតុង
ជាប្អូនតាំងាហានចេញទៅមួយផ្លូវទៀត ប្រៈយោនឲ្យស្រែតកាយបន្ទាយ
កំស៊ីយភ្លុនឲ្យបានជាមុន សេចក្តីគាប់ខឹងត្រឡប់ឃ្លានមកខាងខ្លួន កំបាន
ចាត់ការស្រែចឲ្យចៅតុងលើកទ័ពចេញទៅ លុះដល់ទល់គ្នាហើយ កំបរ
តលឲ្យចូលកាយបន្ទាយជាមុនស៊ុនគៀន ។

ឯហួយុនឃើញដូច្នោះ ក៏ដេញាហានប្រាំរយបើកទ្វារបន្ទាយ
ចេញមក ហើយស្រែកឲ្យចៅតុងថា ខ្លួនជាពួកចោរមកតតាំងប្លាំងនឹង
អញឬ? ចៅតុងឃានភ្លក់ក៏បែរមុខទៅយើញហួយុនមានសេចក្តីតំយណាស់
ភ្លាក់សេរបត្រឡប់ទៅខាងក្រោយ ហួយុនក៏បរសេរដេញបណ្តាយ
តាមយកជាវគាប់ត្រូវចៅតុងធ្លាក់ពីលើសេរស្ងាប់ ខាងឃានាហាន
ឈ្លើយជាច្រើន ហើយឲ្យគាត់យកក្បាលចៅតុងជាក់ចាំងបកសំបុត្រ
បញ្ជូនចូលទៅឲ្យតាំងតុក្នុងស្រុកក្រុង តាំងតុមានសេចក្តីត្រេកអរណាស់
ក៏ឆ្វើយតបសំបុត្រមកតាំងហួយុនជាគីនាហ្នឹនធំ ។

ចំណែកស៊ុនកៀនមានភាហានទៅជាមួយ ៤ នាក់ ឈ្មោះតៀវ
គាន់លំពែង ១ អ៊ុយកាយគាន់ដំបងវែក ១ មានមុខស្រួច ៤ ហ៊ានតុងគាន់
ដាវ ១ ចូមម៉ាគាន់ដាវដែមួយម្ខាង ស៊ុនកៀនតែងខ្លួនពាក់គ្រែះហើយគាន់
ដាវវែង នាំពួកភាហានចេញទៅឈរនៅមុខបន្ទាយហើយស្រែកថា
អាពួកក្បាថ អាឯងចូរបើកទ្វារចេញមកតយុទ្ធនឹងអញជាប្រញាប់ បើបង្អង់
យូរអញនឹងហែកបន្ទាយចូលទៅកាត់ក្បាលឲ្យអស់ត្រឡប់នេះ ហោជិនឃាន
ឮដូច្នោះ ក៏និយាយនឹងហួយុង់ថា ខ្ញុំបាទសុំភាហាន ៥០០០ ចេញទៅ
យកអាសារលោកជាមុន ហួយុង់ក៏ចាត់ភាហានឲ្យហោជិនហើយបើក
ទ្វារចេញទៅ ។

តៀនៅឃើញហោជិនចេញមក ក៏ឡើងសេះកាំលំពែងចេញទៅទល
តនឹងហោជិនបាន ៧ ក្នុង តៀនៅយកលំពែងចាក់ត្រូវកហោជិនធ្លាក់ពី
លើសេះស្លាប់ ភាហានក៏ដេញប្រកាប់ចូលទៅចាក់កាប់សំឡាប់ភាហាន
ហោជិនទល់នឹងដើរឆ្ងាំកំពែង ។

ហួយុង់ឃើញបរាជ័យ ក៏ឲ្យភាហានឡើងលើខ្នងកំពែងចាំញ៉ងសរ
ចោលដុំថ្មម្ខាក់ចុះទៅត្រូវភាហានស៊ុនកៀនបែកចាក់ពិការជាច្រើន ស៊ុន-
កៀនយល់ថានឹងវាយទំលាយពុំបាន ក៏ឲ្យភាហានថយត្រលាយមកវិញ
ហើយតាំងបន្ទាយនៅតំបន់លៀងតុង ទើបឲ្យបកសំបុត្រតាមដំណើរចូល
ទៅស្នើឲ្យកួនសៀវជ្រាបសេចក្តី សំបុត្រមួយបកទៅដល់អ៊ុនស៊ុតជាមេទ័ព
ណូនឲ្យបញ្ជូនស្បៀងអាហារមកឲ្យពួកពលភាហានបរិភោគជាប្រញាប់ ។

ប្រវត្តិព្រះអានន្ទត្ថេរ

ហ្វូងនិពន្ធមន្ត្រី ញ៉ុក - ថែម ប្រែទឹងរៀបរៀង

ព្រះអានន្ទត្ថេរ ជាព្រះឧរសរបស់ស្តេចសុក្កោទនសក្យពង្ស ដែលជាព្រះកនិដ្ឋភាតារបស់ព្រះបាទសុទ្ធោទនពង្ស គ្រងត្រកូលកបិលពស្តុ ព្រះមាតាព្រះនាមថា ព្រះនាងកិសាគោតមី បើកបរឿងតាមលំដាប់សាក្យវង្ស ខ្ញុំនលោកត្រូវជាព្រះអនុជរបស់ព្រះបរមសាស្តា ។ គ្រាកាលដែលព្រះបរមសាស្តាប្រថាប់នៅឯអនុបិយនិគមដែនមល្លក្សត្រនោះ ព្រះអានន្ទសក្យពង្សក៏បានចេញទៅបួសព្រមជាមួយនឹងសក្យពង្សឯទៀតគឺ ព្រះភទ្ទិយ, អនុរុទ្ធ, ភគុ, កិម្ពិល, កោលិយវង្សមួយ គឺព្រះទេវទត្ត រួមជា ៧ នឹងឧបាលីជាខ្ញាន់ព្រះកេស ។ កាលព្រះអានន្ទសក្យពង្សបានឧបសម្ប័ទហើយ បានស្តាប់ឥតដែលព្រះបុណ្ណមន្តានីបុត្រសោលខ្ញុំខ្ញានក៏បានសំរេចសោតាបត្តិផល ។ ក្នុងសម័យថ្ងៃ ១ ព្រះបរមសាស្តាទ្រង់គ្រាស់សុំឲ្យព្រះសង្ឃជ្រើសរើសភេតិកៈ ដែលត្រូវនៅបំរើព្រះអង្គជាប់ជានិច្ច ដ្បិតកាលពីមុននេះ តិក្ខដែលមកឧបដ្ឋាកបំរើព្រះអង្គ ច្រើនតែផ្ទាស់ប្តូរមិនទៀងទាត់ រៀលដែលផ្ទាស់ទៅ មិនមានអ្នកឧបដ្ឋាកជំនួស តោងព្រះអង្គគង់នៅតែមួយព្រះអង្គ បានសេចក្តីលំបាកក៏មាន ទើបព្រះសង្ឃជំនុំជ្រើសរើសព្រះអានន្ទថ្វាយព្រះបរមសាស្តា តែមុនលោកឧបដ្ឋាកជាតុក្ខប្បដ្ឋាក ព្រះអានន្ទត្ថេរបានក្រាបទូលសុំពរ ៨ ប្រការថា :

១ សូមកុំប្រទានបីវរៈដ៏ប្រណីតដល់ខ្ញុំព្រះអង្គ ។

២ សូមកុំប្រទានបិណ្ឌបាតដ៏ប្រណីតដល់ខ្ញុំព្រះអង្គ ។

៣ សូមកុំឲ្យខ្ញុំព្រះអង្គនៅក្នុងទីប្រថាប់ជាមួយនឹងព្រះអង្គ ។

៤ សូមកុំនាំខ្ញុំព្រះអង្គទៅកាន់ទីនិមន្ត ។

៥ សូមព្រះអង្គស្តេចយាងទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គបាន ទទួលទុក ។

៦ សូមអនុញ្ញាតឲ្យខ្ញុំព្រះអង្គនាំបរិស័ទ្យដែលចូលមកគាល់ឥឡូយ ចូលគាល់ព្រះអង្គបាន ក្នុងខណៈដែលមកដល់ ។

៧ បើសេចក្តីសង្ស័យកើតឡើងដល់ខ្ញុំព្រះអង្គវេលាណា សូមឲ្យខ្ញុំ ព្រះអង្គចូលគាល់ទូលសួរបាន ក្នុងវេលានោះ ។

៨ បើព្រះអង្គទ្រង់សំដែងធម៌ទេសនារឿងអ្វីមួយ ក្នុងទីកំបាំង មុខខ្ញុំព្រះអង្គ សូមព្រះអង្គសំដែងប្រាប់រឿងនោះដល់ខ្ញុំព្រះអង្គកុំខាន ។

ព្រះបរមសាស្តាត្រាស់សួរថា ម្នាលអានន្ទ ចុះអ្នកឃើញគុណទីន៍ នោះដូចម្តេច ទើបអ្នកសូមយ៉ាងនេះ ។ ព្រះអានន្ទក្រាបបង្គំទូលថា បើខ្ញុំព្រះអង្គមិនបានពរ ៤ ប្រការខាងដើមទេ នឹងមានពាក្យតះបាន និន្ទាថា ព្រះអានន្ទបានទទួលលាភសក្ការៈយ៉ាងនេះ ។ បានដាំទំនុកបំរុងព្រះបរមសាស្តា ការបំរុងបំរើយ៉ាងនេះ នឹងធ្វើប៉ុន្មានទៀត ។ ប្រសិនបើខ្ញុំព្រះអង្គ មិនបានទទួលពរ ៣ ប្រការខាងចុងទេ មនុស្សពាំងឆ្ងាយ

ន៏ដ៏ន៏ទ៏យាយបានថា ព្រះអានន្ទទំនុកបំរុង ព្រះបរមសាស្តាផ្ងើម្ល៉ៃ ព្រោះ
ព្រះអង្គមិនទ្រង់អនុគ្រោះដោយកិច្ចត្រឹមប៉ុណ្ណឹង ។ ប្រសិនបើខ្ញុំ
ព្រះអង្គមិនបានឥតខ្លួលតវោងបុងបង្អស់ទេ បើមានគេសួរខ្ញុំព្រះអង្គក្នុងទី
កំបាំងព្រះកន្ត្រកថា ធម៌នេះព្រះអង្គទ្រង់សំដែងក្នុងទីណា បើខ្ញុំព្រះអង្គ
សំដែងប្រាប់គេមិនបានទេ គេនឹងរោលតិះដៀលថា លោកមិនដឹងត្រឹម
រឿងប៉ុណ្ណឹង បំណាច់ដើរតាមព្រះបរមសាស្តា ដូចជាស្រមោលអន្ទោល
តាមប្រាណ អស់កាលយូរអង្វែង ។ លុះព្រះអានន្ទក្រែកប្រាប់ដំ
ខ្លួលពីគុណនឹងទោស នៃតវោងទាំង ៨ ប្រការយ៉ាងនេះហើយ ព្រះបរម
សាស្តាក៏ទ្រង់អនុញ្ញាតឲ្យតាមសេចក្តីសុំគ្រប់ប្រការ ។ តាំងអំពីកាល
ណោះមក ព្រះអានន្ទក្រែក ក៏ទបង្ហាក ព្រះបរមសាស្តា ដោយសេចក្តី
គោរព ហើយមានចិត្តស្មោះត្រង់ចំពោះព្រះអង្គជាយ៉ាងវិសេស តែវែង
ហានលះបង់ជីវិតថ្វាយព្រះបរមសាស្តាបាន ដូចមានឧទាហរណ៍ថា កាល
ព្រះបាទអជាតសត្រូវ ទ្រង់ឲ្យលែងដំរីនាឡាគីរី ដែលកំពុងចុះប្រែង
ឲ្យមកធ្វើអន្តរាយដល់ព្រះបរមសាស្តា ព្រះអានន្ទក្រែកនិមន្តទៅឈរនៅ
ខាងមុខដំរី មិនឲ្យធ្វើអន្តរាយដល់ព្រះអង្គបាន ។ ដោយហេតុតែលោក
ទៅជិតជាប់នឹងព្រះបរមសាស្តាមិនដែលឃ្លាត ទើបលោកបានស្តាប់ធម៌
ដែលទ្រង់សំដែងដល់ខ្លួនលោកនឹងអ្នកដទៃ មានស្មារតីចងចាំពុកបាន
ច្រើន មានសេចក្តីព្យាយាមយកចិត្តទុកដាក់ស្វាធ្យាយរៀនសូត្រចងចាំ

ខុក ហើយដាអ្នកឈ្មោសវៃ ក្នុងការសំដែងធម៌ណាស់ ទើបព្រះបរម
សាស្តាទ្រង់សរសើរលោកថា ជាអ្នកប្រសើរលើសលែងកិត្តិនាំងឡាយ
៥ ស្ថាន គឺជាពហុសូត្រ ១ មានសតិ ១ មានគតិ ១ មានព្យាយាម ១
ជាពុទ្ធុប្បដ្ឋាក ១ ។ មួយវិញទៀត អាស្រ័យគុណធម៌ដែលលោកជា
ពហុសូត្រនេះឯង កាលព្រះអង្គបរិនិព្វានទៅហើយ ទើបព្រះមហា-
កស្សបត្ថេរ កាលផ្តើមឆ្លើចប៉មសង្គាយនាព្រះធម្មវិន័យ ព្រះសង្ឃ-
នាំងពួងបានជ្រើសរើសលោកឲ្យជាអ្នកវិសជ្ជនា នាំងសុត្តន្តបិដក នាំង
អភិធម្មបិដក ។ ព្រះអានន្ទត្ថេរនេះ ឃ្លានសម្រេចអរហត្តផល ក្នុង
វេលាកន្ត្រឹមមុនចូលដល់សង្ឃប្រជុំឆ្លើសង្គាយនាបន្តិច ដូចំមានសេចក្តីដំ
ណាលថា មុនចូលដល់សង្ឃប្រជុំឆ្លើសង្គាយនាមួយភ្លែ លោកបាន
ទទួលសេចក្តីដាស់តឿនអំពីព្រះមហាកស្សបត្ថេរ ទ្រុំចំពេញព្យាយាម
លុះដល់វេលាល្ងាច លោកក៏ចំរើនសមណធម៌ តែរឹតបានសម្រេចព្រះ
អរហត្តផល ក្នុងចន្លោះតំរិយាចថ្នាំង ៤ ។ លុះអំណើះតាលតមក លោក
ពិចារណាឃើញអាយុសង្ខារបស់លោក ជិតដល់តំលរបរិនិព្វានហើយ
ទើបលោកនិមន្តទៅកាន់សួនភេហិនី ដែលជាវេនព្រំប្រទល់រវាងសក្យ-
វង្សនឹងកោលិយវង្ស មុននឹងបរិនិព្វាន លោកបានហោះឡើងទៅលើអា
កាស សំដែងធម្មទេសនាពុន្មានដល់ពួកមនុស្សនឹងពួកទេវតា វេលាចប់

ទេសនា ខ្ញុំសំដែងឥទ្ធិវិធីមានប្រការផ្សេងៗ ទើបតាំងសត្យាធិដ្ឋានថា កាលអាត្មានិព្វានហើយ សូមឲ្យកាយរបស់អាត្មាអញ បែងចែកចេញជាពីរចំណែក ហើយធ្លាក់ចុះទៅខាងត្រើយព្រះញាតិសក្យវង្សមួយចំណែក ខាងត្រើយព្រះញាតិកោលិយវង្សមួយចំណែក ដើម្បីមិនឲ្យព្រះញាតិទាំងសងខាងកើតវិវាទនាស់ខែងគ្នា ព្រោះហេតុអង្គិជាតុរបស់អាត្មាអញ ។ លុះអធិដ្ឋានស្រេចហើយ ក៏លោកវិលត់ខន្ធចូលកាន់បរិនិព្វានធ្លាប់អាកាសវេហាស៍ នាពាក់កណ្តាលស្តេចកេហិនិ សរីរៈកាយក៏បែងចែកចេញជាពីរចំណែក ហើយធ្លាក់មកដែនដីជាពីរចុំណែក សមដូចសេចក្តីអធិដ្ឋានគ្រប់ប្រការ ។

ចប់ច្រវត្តិសង្ខេបព្រះអានន្ទត្ថេរតែប៉ុណ្ណោះ(១) ។

---

(១) ព្រះអានន្ទត្ថេរ កាលបើតាំងនឹងមើលច្រវត្តិរបស់លោកនឹងឃើញប្លែកពីព្រះសាវកឯទៀតៗ ទាំងអស់ ដោយកំលោះនិព្វាន នឹងខន្ធនិព្វាន ។ គឺព្រះសាវកឯទៀតៗ បានត្រាស់ដឹងនិព្វាន ក្នុងពីរយោបថទាំង ៤ គឺដេកដើរឈរអង្គុយ ពីរយោបថណានីមួយ ។ ឯព្រះអានន្ទត្ថេរ បានត្រាស់ដឹងក្នុងបន្ទោះពីរយោបថទាំង ៤ ឈ្មោះថាខុសពីសាវកដទៃ ។ ដោយកំលោះនិព្វាន ។ លោកវិលត់ខន្ធចរិនិព្វានលើអាកាស ឈ្មោះថាខុសពីសាវកដទៃ ដោយខន្ធនិព្វាន ។

✓ ចប្បាប់ត្រែមសាមណេរ

ហ្វង់និពន្ធមន្ត្រី ញ៉ុក - ថែម រៀបរៀង

បទកាពតត

នេះគឺព្រះចប្បាប់ ទុកជាសណ្ដាប់ ខ្ញុំខ្ញានអ្នកផង គឺព្រះបន្ទូលមច្ចុរាសាង ចប្បាប់នេះកន្ទង លែងចប្បាប់ទាំងឡាយ ។ ព្រះអង្គគង់នា ឯតតនហោវិហារ វិសេសពណ្ណាភយ ស្ដែងស្ដេចទេសនាដោយបទបរិយាយ អាមាត្យទាំងឡាយ វិសេសជាំង ។ ខោះទាំងខ្វះតា មនុស្សសត្វធងណា ចូរមកបង្គំ ក្រែញគ្រាបត្រងត្រាប់ស្ដាប់ចប្បាប់ខ្ពស់ ដោយនូវក្រែត្រែម ពីព្រះទេស្ដ ។ ហៃជនទាំង-ឡាយ ចូរស្ដាប់អតិប្បាយ ទុកនៅរៀនតា រួសរៀនទុកកង កំឡុងវ័យា គ្មុះគប្បីមហា ជនធងត្រងត្រាប់ ។ កើតកង់លោកីយ៍ ឲ្យដឹងសេចក្ដី ឆ្លាំឆ្លងទុសគាប់ ខោះខ្យែតខោះមាន ខោះសខោះស្ងាប់ ឲ្យឆ្លើយដោយចប្បាប់ តាមព្រះពុទ្ធដីកា ។ កើតមកជាមនុស្ស ខោះស្រីខោះប្រុស លោកឲ្យអនិច្ចា អំពីកំណើត តាលកើតមកណា សឹងមានវេរា ពៀរពុំឃ្លាតឡើយ ។ អ្នកឯណាកើតមក រស់រួចរួបល្អ ប្លាន់បរិបូណ៌ហើយ ម្ដាយឪមរក្សា សត្វចៃដារត្រើយ កុំភ្លេចគុណឡើយ ទុកលើសិរសា ។ រីគុណឥពុក ឲ្យដំកល់ទុក ប្រហែលមាតា គុណ

ញាតិសន្តាន ផៅពង្សវង្សា ជិដូនដីតា សឹងមានគុណផង ។
ឲ្យនុងលំអុត រក្សាផ្តង់ផ្តត់ កុំឲ្យមានហ្មង លុះធំដឹងក្តី ដប់ពីរហើយ
ហោង ចាំបើកទ្វង អំពីខោះណា ។ ចាន១២ឆ្នាំ ឲ្យចងចិត្តចាំ
តិតក្តងអាត្មា ខោជាគ្រហស្ថ ពុំចានឡើយណា ឲ្យតិតអនិច្ច ហើយ
ផៅបួសហោង ។ បួសត្រូវណា ចរិបូណ៌ចានជា សាមណេរហើយផ្តង
ចិត្តចំបួសរៀន រៀនធម៌ឲង កុំចាយ្លើសឃ្នង យ្លើសពុំភ្ងាចត្រូ ។
កុំសើចកុំលេង រក្សាខ្លួនឯង ឲ្យដឹងខុសត្រូវ ដឹងបុណ្យដឹងចាប ជាបរៀងទៅ
ខោះចេះខោះខ្លៅ តាមដោយវាសនា ។ ប្រដៅសេចក្តី
ខោះពាក់ជ្រៃខ្ញី ឲ្យចាំតុខ្លួនដីតា កតង់ទុកនៅក្នង កំឡុងខ្ចីយ៉ា ទុកស្មើ
តែវាជា រក្សាខ្លួនហោង ។ បួសខោះបំរើ ដោយនៅអំពើ ឧឹងក្រឡៃ
ក្រមសង្ឃ កុំឲ្យលោកខ្ញាល់ សំចាដៅវង្ឆង កុំឲ្យមានហ្មង ខុសឧឹង
ព្រះវិន័យ ។ ខោះឈ្លោះខោះទ្រឹក ឲ្យមានចិត្តនឹក ជាអាចរៃន្តែយ៍
កុំដេកលន់លាក់ ស្រមុកដល់ថ្ងៃ រោះរឿងម្ល៉ឹងម្ល៉ា ។ ដណ្តើ
ចង្ហាន់ ទឹកស្រែងឹទឹកធាន់ ទឹកសូន្តក្តីណា រក្សាវង្តោក មូរមូនាគស្ងួ
សង្ឃាតទុស្សាហ៍ ផ្តាច់ឆ្កួនច្រកតី ។ ឲ្យលោកអាសូរ អាណិតស្រាក
ស្រួល ឧឹងដីសត្វថ្ងៃ បុណ្យទៅបរលោក បុណ្យក្នុងលោកយ៍ សឹង
ចានដូចនៃ ចិត្តដំណែ្ចថ្នា ។ ថាបើលោកអាក់ ពុំសូវកក់ទាក់ ឧឹងដី
ឡើយណា កុំឲ្យលោកខាយ ខំនាយពុំជា ខ្លួនដីសោតណា មុខជា

សៅហ្មង ។ ពាក្យគ្រូឆុតធាប់ បីដួចដង្កាប់ ដែកពេជ្រជាម្ពង ពុំដែលរសាយ រលាយឡើយហោង ដួចគលបំណង ពុំដែលឃ្លាតឃ្លា ។ លោកមានអំណាច ឲ្យឋាកោតខ្លាច អត់ឧនសិរសា ថ្កាត់ថ្កាយបង្គំ ច្រណាម្យាខ្លួ លាខោសអាត្មា នឹងគ្រូនោះហោង ។ ដីបួសឃ្យរខៅ ខោះច្បាជខោះខ្លៅ ដោយនៅគន្លង តាមដោយគម្ពីរ ព្រះវិន័យហោង កុំឆ្លើរលង ព្រះវិន័យណា ។ បើបង់ខៅផ្លុះ ក់រចួលសំពះ បង្គំគ្រាបលា ឋានវិត្រចីវរ ចីវរពាក់ស្មា សិស្សគណគ្គីគ្គា កំដរខៅផង ។ ខោះខើបហៅសង្ឃ ខោះរៀបខោះត្រង់ តាមដោយគន្លង ឋានជាបន្ទាល់សាក្យខ្លួនហោង ដោយនូវគន្លង ព្រះពុទ្ធសាសនា ។ កុំដើរម្នាក់ឯង បង់ចោយគ្រែង គ្រីញាក់ស្មា លោកសង្ឃរចារចាល គ្រងោលពុំជា ដើរគគ្គីគ្គា កំដរខៅផង ។ យល់សព្វអំពើ ឧបាសកធ្លើ ខ្ពុក ខោសសត្វផង ពុំពាក្យរគ្រែស្ងូវ ពុំគ្រែវគន្លង ខោរខ្លាអឺង្គង ដេរពោលដំគ្នា ។ អាបត្តិឋាបខោះ ធ្លាក់ខៅចំពោះ ដួចដល់អាត្មា ធ្លាក់ខៅនរកវង់ទុក្ខវេទនា នឹងនាំអាត្មា ពុំឋានឡើយហោង ។ ហើយនឹងនាំម្តាយ សាច់ញាតិទាំងឡាយ ខៅនរកឆ្កង លោភីយ៍គ្រែមោច ហ៊ានហោចទ្រព្យធង ពុំឋានដួចប៉ង ចំណង់ឋាច្បា ។ បើនឹងចង់ដើរ ដោយនូវដំណើរ តាមបទវិយា ឃ្លកស្បង់ចីវរ ឋវរហៅមហា - បំសុកូលខោះណា មកឃ្លុំស្រែចហោង ។ កាន់ផ្ទៃតនូវច្រែត ធ្លើឲ្យស្រែគត់ ស្តាយ

ជាតែខ្លួនឯង ចេញទៅយកជាតែ ជ្រែងសម្លស់សត្វផង កុំឲ្យឆ្គាំឆ្គងដោយពុទ្ធវិចារណ៍ ។ អ្នកឯងនោះគ្រែ ធ្វើចិត្តឲ្យល្អ នាំញាតិកា នាំម្តាយឪពុក ទៅទុក្ខនៅនា ឋានសុខសួគ៌ា បរិបូណ៌ពណ្ណរាយ ។ ចាំរៃហតុកុំផង ឯងអ្នកត្រាប់ត្រង់ ក្រែត្យក្រមចាំងឡាយ រក្សាសីលផង ស្មើនឹងពុកម្តាយ កុំឲ្យអន្តរាយ សីលផងទៀយណា ។ ឲ្យត្រង់ឲ្យសូត្រ ពាក្យពេចន៍កុំកូតមុសាវាទា ស្រដីឲ្យត្រង់ ធ្វើចិត្តឲ្យជា តាមដោយបុព្វា បំណងព្រៃងព្រឹទ្ធ ។ អ្នកកុំសប្បាយ លេងសើចរីករាយ ឲ្យធ្ងន់គំនិត ដឹងរាក់ដឹងជ្រៅ ដោយខ្លួរសុចរិត ឲ្យគន់ឲ្យគិត ដឹងគុណលោកផង ។ គុណគ្រូបាធ្យាយ គុណអាពុកម្តាយ ធ្ងន់ក្រៃកន្ធឹង ធ្ងន់ស្មើភ្នំព្រា - ប្រៀបពីឯងហោង រកអ្វីនឹងស្មង គុណពុំបានណា ។ ឲ្យចំសង្វាត ចំរើនស្មឹងស្មាធ៌ មេត្តាការុណា ចំសូត្រចំរៀន រៀនសាស្ត្រា ប្រយោជន៍អាត្មា ឯងទៅឯមុខ ។ កុំឲ្យឡើបខ្សៀវ កំកែះកំកៀវ សំឡឹងសំឡក់ ខោះខ្លែងតិចច្រើន ខោះល្អអាក្រក់ ឈើព្រៃគេទុក សត្វទិសវិងង៉ ។ កុំលួចកុំយក កុំប្លន់ធ្វក់មក បៀតបៀនគ្នាផង ខោះឯងហៅខុស ពុំដោយគន្លង កុំឲ្យចូលផង នឹងអ្នកខោះណា ។ អ្នែកឯងខោះ ឱឃ្លាតចំកោះ ខ្លែងគេពុំជា អំពីលំខៅ យកទៅនានា លោកហៅបព្វា - ដេយ្យុំចោរផង ។ អាបត្តិធ្ងន់ពេក បីដូចថ្មបែក សោះសូន្យជាម្តង លោកឲ្យបែជ្រាស់ លាកលះចេញផង កុំឲ្យចូលផង នឹងអ្នកខោះទៀយ ។ រក្សាកងវៃ ឲ្យដឹងយប់ថ្ងៃ កុំធ្វើតោះតើយ គ្រូលោកប្រដៅ ដោយខ្លួរធម៌ហើយ កុំធ្វើឲ្យឈ្មើយ ខុសនឹងពុទ្ធដីកា ។

បើខុសនឹងគ្រូ ឲ្យលោកគ្រូជូរ ក្រែរក្រាធាយថា ខ្លួនដ៏អសោច៌ ខ្លួច
ក្តៅតុំណា លុះដល់មរណា ខ្លួចខ្លួនជាមួង ។ មួយសោតដ៏ការ កុំឲ្យលោក
ខ្ញាល់ ខ្ញុំគោរខឹងផង ដ្បិតលោកមានគុណ មហាឥន្ទ័កន្ទង់ នឹងរកអ្វីសង
គុណតុំបានណា ។ ធ្វើឲ្យបរិសុទ្ធ ទានអង្គសំអុត ការក្តៅអ្នកជា
បំណាច់អ្នកបួស សាងផ្លែសង្ឃ សំណាក់សាសនា កូតកសំណាយ ។
ឱនឲ្យមានជា មេត្រីស្នេហា នឹងគ្រូចាធ្យាយ កុំធ្វើចិត្តកាច កំណាច
មាក់ងាយ ខ្មែស្តគ្រូចាធ្យាយ តុំជាឡើយហោង ។ ស្រដីឲ្យខ្ជៀង កុំឲ្យ
មានស្តើង ពាក្យពេចន៍សាសង ដោយពិតដោយត្រង់ ត្រូវតាមគន្ថង
កុំឲ្យមានហ្មង មន្ទិលឡើយណា ។ កុំធ្វើចិត្តកាច បពេសតុំខ្លាច
កកូតមាយា ស្រដីកុំស្តើង ឲ្យខ្ជៀងសត្យា តាមពុទ្ធដីកា ប្រាកដតុំ
លែង ។ កុំធ្វើបន្ទាល់ ចិត្តចង់ស្រើបស្រាល បង្ខំសេចង ឲ្យ
រក្សាខ្លួន ដោយក្សន្តជាក់ស្តែង ឲ្យគំតកោតក្រែង ខ្លួរអ្នកមានគុណ ។
កុំដោយចិត្តពាល កុំខៅស្នេហ៍ស្នាល នឹងអ្នកឥតធន នឹងអ្នកកំសត់
ខុតតិតតបុណ្យ កុំសេពសម្ផ្ទ មូលជាមិត្តផង ។ ភាន់ឯច្យុត រលោយ
ស្រុតស្រួត ខ្លួនដូច្នោះហោង ភាន់ឯរេចរិល ត្រង់លជាមួង កុំចូលចិត្តចង
នឹងអ្នកនោះណា ។ ខ្ញុំតតុំតាប់ កុំខៅប្រសព្វ ជាមិត្រស្នេហា ភា
ឯងអន្តរាយ ខ្លួចខ្លួនអសារ ខ្ញុំតដូច្នោះណា ប្រាកដតុំឃ្លាត ។ ថា
បើនឹងខៅ ជាមិត្តជាផៅ ឲ្យមើលមារយាទ មើលពង្សន្តាន ឲ្យ

ចាន់ដាក្នុត ប្លួបប្លូលសង្វាត ដាមិត្រស្នេហា ។ បរិបូណ៌ចាន់ទ្រព្យ
ចាន់ដូចបង្កាប់ ចាន់យសសក្តា កេរ្តិ៍មក្សាន្តស្រណុក ឥតទុក្ខភ័យ
ដូចអ្នកនោះណា តុំលែងខ្វៃយហោង ។ កេរ្តិ៍ខ្ជូនចុះណា ជីកុំឲ្យមាន
មន្ទិលសៅហ្មង ស្ងៀកសប្បាយកវៃត្រ ចីវរគ្រប់គ្រង ភាក់លើសុរ៉ែង
កុំឲ្យឃ្លាតឃ្លា ។ សង្ឃខ្ទះចិត្តខោរ យល់ក្បាលត្រដោល រួសរកប្រកាវ
សប្បាយកមកជូត ធ្វើសាស្តូចជ្ងា ចង្កៀនក្រទា ក្រតើនដើរទៅ ។
ខ្ទះស្ងៀកលយឆាយ ដើរលេងកែក្រាយ ចេញឆ្ងៃតខាងក្រៅ បង្គុសង្ខាង
ដូចឈ្នាងច្រកទៅ ខោះខំដើរទៅ តុំគិតគេចា ។ ម្នាក់ឯងឯកឯោក
ស្ទើរស្ទុះស្ទើរឈ្លោក រេក្បាលញាក់ស្មា ជាក់កផ្លៀងផ្អង តុំត្រូវក្រែត្បា
កុងវិន័យថា សង្ឃខោរអប្រិយ៍ ។ ទាយកឯងណា មានចិត្តថ្លៃថ្លា
សទ្ធាប្រកតី ឧឡឹងនិទានទៅ តុំស្ទូវប្រៃពៃ ជ្រុតសង្ឃខោះពៃ តុំត្រូវ
ក្រែត្តកា ។ ថាបើបួសខោ ខោះប្លាជ្រខោះខ្លៅ ធ្វើចិត្តឲ្យជា កុំឲ្យមាន
ល្អៀង ជ្រែជ្រៀងខ្វៃយណា តាមដោយពុទ្ធដីកា ត្រូលោកប្រដៅ
សង្ឃខ្ទះបើង ប្រែប្លាណាខេរឆឹង ប្រទូស្តដើរទៅ ស្រដីបញ្ហាត បំ-
ពោតសៅដៅ ក្រែងក្រែកក្រែងទៅ ឧឡឹងត្រូនោះណា ។ បុណ្យត្រូភ្ញាំង
ណាស់ ទុកស្មើអម្ចាស់ បង្កើតសិសោ ព្រះលោកបង្កើត ហើយមាន-
ខេរតា ខេត្រក្សរក្សា ចំរើនប្រកតី ។ គឺខេតសន្ធត់ ឲ្យលោកប្លា-
កដ ត្រួតត្រាស្រដី លើអស់កិកុថេរ សាមណេរផងក្តី ចិត្តឯងអប្រិយ៍

ថាលោកពុំគាប់ ។ គ្រូដូចអន្លង់ ដែកពិធំសំពង ព័យលើខ្នាប់ ចង់ឲ្យបានត្រូវ ចេះដឹងក្បួនច្បាប់ ចង់ឲ្យបានត្រឹម ដូចលោកគាំងឡាយ ។ នរអ្នកណា មានចិត្តមោហា ខ្មែស្តីលោកបាធ្យាយ ខ្មែស្តីមិត្រសំឡាញ់ ខ្មែស្តីអាពុកម្តាយ អ្នកនោះអន្តរាយ ខូចអគ្គិអាត្មា ។ នាគង់លោកយ បរលោកនោះក្តី ពុំបានជាការ មានទោសមានទុក្ខ ធ្ងន់ណាស់មហិមា ពុំបានជាការ ឥតបានស្រាន្តស្រាក ។ គេចង់ចាប់ជា ច្រើនជង់ច្រើនគ្រា កើតខ្យាត់លំបាក កំព្រាត្រមោច លន្លោចគោកយ៉ាក ដ្បិតចិត្តពុំស្រាក ខ្មែស្តីគ្រូបាធ្យាយ ។ ស្ងាប់ទៅនរក ពិបាកវង់ទុក្ខ ពុំបានរសាយ ភ្លើងឆេះពីក្រោម ខ្យែលាមត្រាងព្រាយ នៅអវិចីនាយ ម្នាក់ឯងកំព្រា ។ ហេតុចិត្តឆ្កួតខុស ឃ្លាតឆ្ងល់ចំពោះ បន្លាសអ្នកណា ខ្លួលវង់ភ័យ អវិចីវេទនា ទាំងប្លន់ធំធា ទោសធំក្លាត់ហោង ។ អ្នកណា ចិត្តស្លូត ពុំចេះតវ៉ាតូត មុសាក់ទង់ង ទោះបីប្លុសទៅ សឹកទៅក្តីហោង ចាំពុទ្ធដីកាធ្លង់ គ្រូលោកប្រដៅ ។ អក្សរបានចេះ រៀនចំណេះច្បាស់ព្រាយកទៅ បំរើក្សត្រា តម្រាក្បួនទៅ អ្នកកុំធ្លុកទៅ ខឹងច្បាប់នេះណា ។ លោកជាតម្លៃង អក្សរនោះឯង បិតកង់អាត្មា នេះហើយហៅវង្សញាតិផៅពង្សា បង់ប្អូនកូនជា ខ្លួនឯងមុខមាត់ ។ ទោះលោកស្រឡាញ់ ចាំវែងចំពេញ ហាយផ្តេកផ្តិត កុំព្រួយពុទ្ធដីកា ចិត្តានោះថ្លាត់ កុំឲ្យ

ឪយខាត់ ទំនាយពុំសុខ ។ ឲ្យព្រួយភ្ញុទ្ធដីកា អផ្សុកចិត្តា ឲ្យលោក
ជាទុក្ខ ស្រក់ទឹកព្រះនេត្រ ភាពអផ្សុក អ្នកច្បាប់កាន់ទុ នោះឯង
ប្រពៃ ។ ថាបើត្រង់ពិត ចូរបចូលក្នុងចិត្ត មូលមិត្រថ្លាថ្លៃ កុំបីឲ្យឆ្គង ឲ្យ
ហ្មត់ព្រះទ័យ ចាន់បរិបូណ៌ក្រៃ ដូចចិត្តប្រាថ្នា ។ ទៅះជីនឹងទៅ បំរើគាល់
ហ្លួ ព្រះមហាក្សត្រា លោកអ្នកមានបុណ្យ ទ្រព្យធនជាំ ចាន់ដូច
ប្រាថ្នា ពុំឃ្លាតបំណង ។ ចេះរៀនចេះដឹង គំនិតឲ្យនឹង ដឹងគុណ
លោកផង ឲ្យក្សាខ្ជួន ខឹងខួនទៅហោង អ្នកតាលឆ្កាំឆ្គង ដីកុំស្នេ-
ហា ។ ចោលអ្នកមានគុណ ទៅសេពមេថុន មិត្រភ្លាស្នេហា ខ្ជួនដី
ខឹងខ្ជូច អស់ពូជពង្សា ខុកជាឆ្កែឆ្នា ពុំជាប្រយោជន៍ ។ ឯខឹងកើត
ឡត់ សម្បត្តិខុគិត កំព្រាត្រែមោច អាសោចខ្ជួនដី . សមខឹងផ្សាខ្ញោច
លន្ធដ៍លន្ទោច លំបាកអាត្មា ។ បួយសោតពាក្យពេចន៍ ស្រដីឲ្យតិច
ខ្លីប្តេជ្ញា ថាកាចដោយកាច ថាជាដោយជា ស្រដីត្រង់ណា មែន
ត្រង់នោះហោង ។ មាត្រាព្រះច្បាប់ ក្រមសាមណេរគាប់ ជួយជួស
ពាក្យផង ជួយថែមពាក្យពេចន៍ តាមកិច្ចគន្ថ ពាក្យលោកនេះហោង
បរិបូណ៌ចែងចប់ ។

ច្បាប់ក្រែងសាមណេរចប់តែប៉ុណ្ណោះ ។

អំពីតាំងចៅអធិការថ្មី

(ត្រួត)

សញ្ញាប័ត្រលេខ ៤៨២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ នៅ នាមធម្មយោ តន្ធសារ កើតឆ្នាំ ១៩០០ អាយុ ៤៨ វស្សា ២៨ ជាចៅអធិការ វត្តឆ័ន ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុន - សួន នាមធម្មយោ វិនយសត្ថា កើតឆ្នាំ ១៩២៣ អាយុ ២៥ វស្សា ៦ ជាចៅអធិការ វត្តគ្រាំងដើម ឃុំ - ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រេ - គង់ នាមធម្មយោ តន្ត្រប្បញ្ញោ កើតឆ្នាំ ១៩១៥ អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្តធាន់លែង ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈួន - ខុក នាមធម្មយោ ធម្មាត្ថេរ កើតឆ្នាំ ១៩២១ អាយុ ២៧ វស្សា ៨ ជាចៅអធិការ វត្តវាលព្រីង ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ វ៉ែ - ហេង នាមធម្មយោ ចន្ទសិរិ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាចៅអធិការ វត្តព្រោធ៍ ឃុំប្រមេ ស្រុកជាំក្រាន ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៨៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុន-ចិន នាមធាយ ធម្មសិរី កើតឆ្នាំកេង អាយុ ៣៣ វស្សា ៧ ជាចៅអធិការ វត្តឈើទាល ឃុំឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៨៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សម-ប៉ក់ នាមធាយ៉ា វិនយគ្នែរ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាចៅអធិការ វត្តអណ្តូងព្រីង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ឹង-ធន នាមធាយ ធម្មគ្នែរ កើតឆ្នាំ ១៨២៤ អាយុ ២៤ វស្សា ៣ ជាចៅអធិការ វត្តក្តែង នោរឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ី-ខ្លួន នាមធាយ វិនយធម្មគ្នែរ កើតឆ្នាំ.១៨៨៣ អាយុ ៤៥ វស្សា ៣៤ ជាចៅអធិការ វត្តក្បាលដំរី ឃុំទំរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៩១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ា-សង នាមធាយ សុវណ្ណសរ កើតឆ្នាំច អាយុ ៤១ វស្សា ៣១ ជាចៅអធិការ វត្តព្រៃពកណ្តៀង ឃុំព្រៃពកណ្តៀង ស្រុកព្រៃវែង ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤៩២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-សៅ នាមធាយ ពុទ្ធកេសរ កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៤ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជា-មិន នាមឆាយា ធម្មវិន័យ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អឹម-ហួត នាមឆាយា តន្ទុត្តេរ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣២ ជាចៅអធិការ វត្តធម្មនិមិត្ត ឃុំគោកគង់ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥០៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ស៊ីវ-គង់ នាមឆាយា សុវណ្ណត្តេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៥ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-រឿង នាមឆាយា សុវណ្ណសរ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ង-អឹម នាមឆាយា តន្ទជោត កើតឆ្នាំមមែ អាយុ ៤២ វស្សា ២២ ជាចៅអធិការ វត្តក្បាលដំរី ឃុំថ្មពួន ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥០៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គាត-ចឹក នាមឆាយា ឯកត្តេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
មាស - ជា នាមនាយា កេសរបញ្ញោ កើតឆ្នាំមមី អាយុ ៤៣ វស្សា២៣
ជាគ្រូសូត្រស្តាំ វត្តកែវឡាមាស ឃុំគ្នោត ស្រុកកន្ត្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥១០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ឿង - ខួន កើតឆ្នាំមមី អាយុ ៤៣ វស្សា ២០ ជាគ្រូសូត្រធ្វេង វត្ត -
ឃុំ - ស្រុក - ខេត្តដដែល

សញ្ញាប័ត្រលេខ ៥១១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ខេត - សាក់ នាមនាយា សុវណ្ណកេសរ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៣
ជាគ្រូសូត្រស្តាំ វត្តគ្នោត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ឃួ - ខុន នាមនាយា សុវណ្ណធម្មត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៤៤ វស្សា២១
ជាគ្រូសូត្រធ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
សុខ - អ៊ី នាមនាយា ឧត្តលបញ្ញោ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៩
ជាគ្រូសូត្រស្តាំ វត្តត្រពាំងថ្ងាន់ ឃុំព្រាល ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
កង - ប៊ូរ នាមនាយា ព្រហ្មជោត កើតឆ្នាំច អាយុ ៣៩ វស្សា ៨
ជាគ្រូសូត្រធ្វេង វត្តត្រពាំង - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម-ស្ពឺង នាមនាយា សីតន្ទេរ កើតឆ្នាំរកា អាយុ ៤០ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ទង ឃុំកញ្ជ្រៀច ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ឹង-អាន នាមនាយា សុវណ្ណប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣៧ វស្សា ១២ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃិត-ថ្លាង នាមនាយា សទ្ធម្មន្ទេរ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តស្វាយរមៀត ឃុំក្តឿងរាយ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៀង-សៀម នាមនាយា តន្ទសារ កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តពោធិវ័ន ឃុំទួលស្រុក-ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៥១៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កុយ-បែន នាមនាយា ព្រហ្មសារ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥២០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ូវ-ឈាងគី នាមនាយា ទត្តមសិរិ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តសិលានទី ឃុំ-ស្រុកឆ្វេង ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៥២១ ចុះថ្ងៃចន្ទ ១២ កើតខែ មិគសិរ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ អ៊ុង - លិន នាមធាយ នាជគ្នេរ កើតឆ្នាំពេង អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្តអន្ទង់រៀន ឃុំឡាច ស្រុក ខេត្តត្រពេះ ។

សញ្ញាប័ត្រលេខ ៥២២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់ - យ៉ត នាមធាយ ចន្ទប្បញ្ញោ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៨ ជាចៅអធិការ វត្តឯ ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥២៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់ - ផាន់ នាមធាយ សុវណ្ណសរ កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៦ ជាចៅអធិការ វត្តព្រៃឆ្នាវ ឃុំនោម ស្រុកគីរី ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ៥២៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ណុប - ឌិម នាមធាយ តន្ទប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១២ ជាចៅអធិការ វត្តកំរែង ឃុំព្រៃស្វឹក ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥២៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន អំ នាមធាយ សុវណ្ណគ្នេរ កើតឆ្នាំខាល អាយុ ៥៨ វស្សា ៣៧ ជាចៅអធិការ វត្តគោះចូកម ឃុំគោះចូកម ស្រុកខ្សាច់កណ្តាល ខេត្ត កណ្តាល ។

សញ្ញាប័ត្រលេខ ១៤ ចុះថ្ងៃចន្ទ ១២ កើតខែមិគសិរឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ងិន-ស្តើង នាមនាយា ផាសភេ កើតឆ្នាំថោះ អាយុ ៣៥ វស្សា ១៤ ជាចៅអធិការ វត្តបេណ្ណាភម (ដើងចាប) ឃុំរនាម ស្រុកត្រាំង ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ៥៣០ ចុះថ្ងៃ ១ ភេចខែបុស្សឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ អ៊ុក-ឌួច នាមនាយា សុវណ្ណជោត កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១០ ជាចៅអធិការ វត្តឯករង្សី ព្រៃកនរិន្ទ ស្រុក-ខេត្ត ប៉ាត់ដំបង ។

សញ្ញាប័ត្រលេខ ៥៣១ ចុះថ្ងៃពុធ ៦ កើតខែបុស្សឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ សោម-ឃុន នាមនាយា តន្ទជោត កើតឆ្នាំភេង អាយុ ៦៩ វស្សា ៤៣ ជាចៅអធិការ វត្តអង្គគ្គី ឃុំសិង្ហ ស្រុកសំរោងខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ៥៣២ ចុះភាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-សរ នាមនាយា បញ្ញាគេសរ កើតឆ្នាំភេង អាយុ ៤៥ វស្សា ២៥ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៣ ចុះភាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-ជា នាមនាយា ជោតិប្បញ្ញោ កើតឆ្នាំរកា អាយុ ៤០ វស្សា ២០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៤ ចុះកាលថ្ងៃទីដែល តាំងលោកគ្រូ
រស់-រ៉ែម នាមឆាយា វិនយធម្ម កើតឆ្នាំមមែ អាយុ ៣០ វស្សា ៨
ជាចៅអធិការ វត្តវិហារខ្ពស់ ឃុំកំពង់ចាស់ ស្រុកទត្តុង្គ ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៥៣៥ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ
ញឹក-កាន នាមឆាយា ធម្មត្ថេរ កើតឆ្នាំថោះ អាយុ ៦២ វស្សា ៣
ជាចៅអធិការ វត្តអន្ទង់ក្រៃបី ឃុំក្រាំងចេក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៦ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ
ទិត-កុម នាមឆាយា ធម្មសំវរោ កើតឆ្នាំច អាយុ ៦៧ វស្សា
ជាចៅអធិការ វត្តច្រាំឆ្កណ៌ ឃុំកំពង់ចាស់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៧ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ
យិម-ហិន ធម្មត្ថេរ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាចៅអធិការ
វត្តពោធិ៍ថ្មីព្រៃតាម៉ុក ឃុំព្រៃ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៣៨ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ
ទិត--នាង សុវណ្ណត្ថេរ កើតឆ្នាំខាល អាយុ ៧១ វស្សា ៥១ ជា
ចៅអធិការ វត្តសង្កែ ឃុំសាំងយ៉ាង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៩ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ
គង់-ជិន ធម្មប្បញ្ញោ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១៤ ជាគ្រូសូត្រ
ស្តាំ វត្តដូនដោក ឃុំដាច ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៤០ ចុះគាលបរិច្ឆេទដដែល តាំងឈ្មោះគ្រូ ង៉ែត-យ៉ោក យោគត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រ ធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤១ ចុះគាលបរិច្ឆេទដដែល តាំងឈ្មោះគ្រូ សុខ-ផេង សុវណ្ណត្ថេរ កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រ ស្តាំ វត្តត្រពាំងប្រី ឃុំត្រពែក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤២ ចុះគាលបរិច្ឆេទដដែល តាំងឈ្មោះគ្រូ ឡាយ-សំរិទ្ធ សុវណ្ណកេសរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤៣ ចុះគាលបរិច្ឆេទដដែល តាំងឈ្មោះគ្រូ ម៉ា-វស់ ព្រហ្មសត្ថា កើតឆ្នាំចោរ អាយុ ៤៦ វស្សា ២៣ ជាចៅអធិការ វត្តស្រយូវ ឃុំស្រយូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៤ ចុះគាលបរិច្ឆេទដដែល តាំងឈ្មោះគ្រូ វល្លី-ហេង ចន្ទសិរី កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តទួលអណ្តែត ឃុំត្រពះរមេ ស្រុកជាំក្សាន ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៥ ចុះគាលបរិច្ឆេទដដែល តាំងឈ្មោះគ្រូ ថោង-ម៉ុម ធម្មប្បញ្ញោ កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣៥ ជាគ្រូសូត្រ ស្តាំ វត្តមុនីរតនារាម ឃុំខ្វែល ស្រុកបាកាយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង-លឿង ធម្មប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៤៤ វស្សា ២៤ ជាគ្រូសូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-យិម ធម្មសត្ថា កើតឆ្នាំម្សាញ់ អាយុ ៤៤ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្តខ្លួលអណ្តែត ឃុំទឹកក្រហម ស្រុកជាំក្សាន ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គីម-ជិក សុវណ្ណត្ថេរ កើតឆ្នាំវក អាយុ ២៩ វស្សា ៧ ជាគ្រូសូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កោត-ដី ចន្ទសុវណ្ណ កើតឆ្នាំ ១៩៤១ វស្សា ៥ ជាចៅអធិការ វត្តខ្សាច់ ឃុំសង្កើយ ស្រុកដីក្រែង ខេត្តស្ទឹមកប ។

សញ្ញាប័ត្រលេខ ៥៥០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ច័ន្ទ ពុទ្ធសុវណ្ណ កើតឆ្នាំវកា អាយុ ២៨ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តព្រៃស្រស់ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៥១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជា-សឿន ព្រហ្មសរោ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

(មានត)

ស្នើអំពីរឿងស្ថាបនាវិទ្យាស្ថានមួយ

សម្រាប់សិក្សាភាសាឥណ្ឌា - ខ្មែរ នៅកម្ពុជា

លោកវ៉ាយ - ប៊ុក ក្រមការក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែចេញពីជាវ៉ាំងមកខ្មែរ

ការសិក្សាភាសាឥណ្ឌាខ្លះៗ ជាកិច្ចមានប្រយោជន៍ ទំនងសាស
សំខាន់ចំពោះប្រទេសកម្ពុជា ដូចគ្នាទំនងការសិក្សាភាសា ក្រិក - ឡាតាំង
ដែលគេជំរុញទុកសម្រាប់និស្សិតរៀនសូត្រ នៅសាលារៀនក្នុងប្រទេស
ចាំង, ការចេះដឹងនូវភាសាសំស្ក្រឹតទំនងជាល្អ ព្រមទាំងអារ្យធម៌ឥណ្ឌា
ដែលទាក់ទងដោយអារ្យធម៌នៃប្រទេសផ្សេងៗ ទាងផ្លូវប្រវត្តិសាស្ត្រ
ជាកិច្ចគួរបំពេញ ដើម្បីស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីបុរាណខ្មែរ
ដែលមានអត្ថន័យគម្ពីរភាព ហើយទំនងជាយើងរកនូវវត្ថុជាតុ ដែលជា
បុព្វហេតុនៃទំនៀមទម្លាប់នោះ ។

ព្រោះហេតុដូច្នេះ ត្រូវតែបណ្ណិតខ្មែរកងកាលជាអនាគតប្រមូលផ្តុំ
ឲ្យបានច្រើនជាងមុន ដើម្បីទំនងចូលទៅសន្ទនាការអំពីរឿងបូព៌ាវិទ្យា
និយមរវាងប្រជាជាតិ (l'orientalisme international. មានការសិក្សាខាង
ភាសាឥណ្ឌាជាកិច្ចត្រូវស្នងរករងាយពិសេស, បណ្ណិតទាំងនោះ ក្នុង
ពេលសន្ទនាការរឿងព័ត៌មានសាលលោក អាចធ្វើតនុកាសរកផល

ប្រយោជន៍ក្នុងរឿងនោះ ដាក់បញ្ចូលមកក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរបាន លោកអ្នកប្រាជ្ញទាំងប៉ុន្មាន អាចចូលទៅប្រស្រ័យចំពោះកិច្ចការខាងសាលាបានពិបូកាប្រទេសដែលជាតំណាងក្នុងការស្វែងរកបូកាវិទ្យានិយមជាសាធារណៈ អាចរៀបចំនូវក្រមសញ្ញាតិខ្មែរ ខាងសិលាចារឹកបុរាណវិទ្យា ទឹងស្ថាបនានូវមជ្ឈមសិក្សានិស្សិតខ្មែរ ដែលត្រូវយកសាស្ត្រាចារ្យមានសមត្ថភាពខាងការសាត់ណ្តៀមកបង្រៀនបានដោយឆាប់ហ័ស ។

ដើម្បីនឹងចបត្ថម្ភបណ្ឌិតខ្មែរដែលពេញចិត្តក្នុងការស្វែងរករឿងនេះ, ប្រទេសបានពិសេសគួរស្នើចំពោះកម្មវត្ថុអំពីគ្រោងការស្ថាបនាវិជ្ជាស្ថានទៅក្រុងភ្នំពេញ សម្រាប់សិក្សាទត្តមវិជ្ជាដែលគេអាចយកគោលការសិក្សាកិច្ចស្វែងរកការសាត់ណ្តៀនៃសាលាទត្តមវិជ្ជាទៅប៉ារីសមកបញ្ចូលផងបាន ។

ការសិក្សានេះ ត្រូវបើកសិទ្ធិឲ្យជនគ្រប់រូបចូលទៅរៀនបានដោយសេរី តតមានរើសមុខ, គុណបំណាច់ដែលរៀនក្នុងសាលានោះ ត្រូវបានសញ្ញាប័ត្រមួយដែលនឹងប្រគល់ឲ្យបាន លុះត្រាតែបេក្ខជននោះបានធ្វើកិច្ចការអ្វីមួយជាប់ប្រសើរ ហើយបានចូលទៅរៀនបណ្តោះអាសន្នទៅសាលាក្នុងរយៈវេលា ២ ឆ្នាំ ដោយទទួលសេចក្តីយល់ព្រមពី

គណៈកម្មការសាលា ដែលបានយកប្រូបេក្ខជនទៅបង្ហាញចំពោះចាងហ្វាងសាលានោះ ។

នៅភ្នំពេញ ការសិក្សានេះដែលនឹងធ្វើបាន លុះត្រាតែចាត់ចាងហ្វាងនៃការសិក្សាមួយនាក់ពីប៉ារីស ក្នុងរយៈពេល ៦ ខែក្នុង ១ ឆ្នាំ, លេខាធិការដ្ឋានជាអចិន្ត្រៃយ៍ នៃវិជ្ជាស្ថានទុត្តមសិក្សានេះ ត្រូវមានសមាជិកខាងសាលាបូពាប្រទេសម្នាក់មកកាន់ការនៅភ្នំពេញ បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យសម្រាប់ជាមន្ទីរធ្វើការផ្សេងៗ នៃក្រុមនេះ, ប្រាក់ចំណាយក្នុងរឿងនេះ ត្រូវប្រទេសប៉ារាំងសែស ទឹងប្រទេសកម្ពុជាទទួលបន្ទុកជួយគ្នាទៅវិញទៅមក, ប្រាក់បៀវត្សនៃចាងហ្វាងសាលាត្រូវប្រទេសប៉ារាំងសែសចេញឲ្យ ចំណែកខាងប្រទេសកម្ពុជា ត្រូវចេញតែខាងប្រាក់ចំណាយសោហ៊ុយសំណាក់អាស្រ័យក្នុងទីនេះ ទឹងថ្លៃយានជំនិះ ។

ចំពោះឆ្នាំ ១៩៥០ ប្រាក់ចំណាយក្នុងរឿងនេះ តាមសេចក្តីស្មានខ្លះប្រហែលជា ៦ - ៧ ម៉ឺនរៀល ។
